រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

ចោយការណ៍

វេទិកាជាតិលើកទី២

ស្តីពីការប្រែប្រួលអាកាសធាតុ

ថ្ងៃទី០៣-០៥ ខែតុលា ឆ្នាំ២០១១

រាជធានីភ្នំពេញ កម្ពុជា

អនុវត្តន៍ដោយ៖

ក្រសួងបរិស្ថាន

ឧបត្ថម្ភដោយ៖

European Union

UNDP Empowered lives Resilient nations

Danida

EMBASSY OF SWEDEN

JCCI Joint Climate Change Initiative

របាយការណ៍ទេសកិច្ចជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុ

ថ្ងៃទី០៣ -០៥ ខែតុលា ឆ្នាំ២០១១
រាជធានីភ្នំពេញ កម្ពុជា

បោះពុម្ពដោយ៖ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)
ក្រសួងបរិស្ថាន
រាជធានីភ្នំពេញ កម្ពុជា

គម្រប និងរូបភាព រក្សាសិទ្ធិដោយ CCCA

សេចក្តីបដិសេធ

ក្រសួងបរិស្ថាន និងម្ចាស់ជំនួយមិនធានានូវភាពត្រឹមត្រូវ និងភាពពេញលេញរបស់របាយការណ៍ ឬមតិដែលបានចងក្រងក្នុងរបាយការណ៍នេះទេ។

© ក្រសួងបរិស្ថាន និង CCCA ខែមិថុនា ២០១២
បោះពុម្ពនៅកម្ពុជា

អារម្ភកថា

វេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងចាប់ពីថ្ងៃទី ០៣-០៥ ខែតុលា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ វេទិកាជាតិនេះ ត្រូវបានរៀបចំដោយគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ (NCCC) ក្រោមជំនួយពីនាយកដ្ឋានប្រែប្រួលអាកាសធាតុ (CCD) នៃក្រសួងបរិស្ថាន (MoE) និងដៃគូអភិវឌ្ឍន៍ (DPs) មួយចំនួនដែលរួមមាន សហគមន៍អឺរ៉ុប (EU) កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ (SIDA) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (DANIDA) អុកស្វាមអាមេរិច (Oxfam America) និងគំនិតផ្តួចផ្តើមប្រែប្រួលអាកាសធាតុរួមគ្នា (JCCI) ។

វេទិកាជាតិរយៈពេលបីថ្ងៃនេះ គឺជាវេទិកាចែករំលែកនូវចំណេះដឹង និងបទពិសោធន៍តាមរយៈវគ្គពេញអង្គ វគ្គបច្ចេកទេសស្របគ្នា កិច្ចពិភាក្សា និងការតាំងពិព័រណ៍បង្ហាញផ្សេងៗ។ វេទិកានេះ មានការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធសំខាន់ៗដែលរួមមាន មន្ត្រីជាន់ខ្ពស់ មន្ត្រីថ្នាក់កណ្តាលជាតិ និងខេត្ត DPs អង្គការក្រៅរដ្ឋាភិបាល (NGOs) សង្គមស៊ីវិល (CSOs) គ្រឹះស្ថានឧត្តមសិក្សា យុវជន វិស័យឯកជន និងប្រព័ន្ធផ្សព្វផ្សាយ។

វេទិកាជាតិនេះ ផ្តោតជាពិសេសលើការបង្កើតកិច្ចពិភាក្សាគោលនយោបាយដែលមានគំនិតស្ថាបនាមួយ ដើម្បីគាំទ្រដល់ប្រទេសកម្ពុជាក្នុងការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិដ៏មានប្រសិទ្ធភាពមួយ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយបញ្ចូល NCCC ក្រុមបច្ចេកទេសអន្តរក្រសួង និងអ្នកពាក់ព័ន្ធនានាក្នុងកិច្ចពិភាក្សា និងព្រមព្រៀងលើដំណើរការសម្រាប់ការអភិវឌ្ឍគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

វេទិកានេះ ក៏ផ្តល់ជាឱកាសដល់រាជរដ្ឋាភិបាលកម្ពុជាពិនិត្យឡើងវិញ និងកំណត់នូវជំហររបស់ខ្លួនក្នុងកិច្ចចរចានៅក្នុងសន្និសីទភាគីលើកទី១៧ (CoP១៧) នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី២៨ ខែវិច្ឆិកា ដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១ នៅទីក្រុងឌូបានប្រទេសអាហ្វ្រិចខាងត្បូង។ នៅក្នុងវេទិកានេះ មានអ្នកចូលរួមជាង ៧០០នាក់នាព្រឹកថ្ងៃទី១ និងជាង ៣០០នាក់ សម្រាប់វគ្គបន្តបន្ទាប់ទៀត ដែលរួមមានមន្ត្រីរដ្ឋាភិបាល តំណាងអង្គទូត DPs NGOs វិស័យឯកជន ព្រះសង្ឃ ជនជាតិភាគតិច ប្រជាពលរដ្ឋ និងនិស្សិត។

ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចូលរួមជាគណៈអធិបតី នៅក្នុងពិធីបើកវេទិកានេះ។ ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់សុន្ទរកថាស្វាគមន៍នៅថ្ងៃបន្តបន្ទាប់នៃអង្គវេទិកាជាតិនេះ។ នៅក្នុងនោះក៏មានការផ្តល់សុន្ទរកថាស្វាគមន៍ពីសំណាក់ DPs ដូចជាតំណាង UNDP ADB និង EU

ដែលបានបង្ហាញពីជំហរក្នុងការគាំទ្រ និងការប្តេជ្ញា ដើម្បីជួយកម្ពុជាក្នុងការឆ្លើយតបនឹងហានិភ័យពីការប្រែប្រួលអាកាសធាតុ។

ឯកសារនេះ ផ្តល់ជាសេចក្តីសង្ខេបពីដំណើរការពិភាក្សាសំខាន់ៗ និងសេចក្តីសន្និដ្ឋានគន្លឹះនានាដែលទទួលបានពីវេទិកានេះ។ សង្ឃឹមថា កិច្ចពិភាក្សានានាដែលបានចាប់ផ្តើមក្នុងវេទិកាជាតិលើកទី២នេះនឹងមានជាបន្ត ដើម្បីផ្តល់ជាមូលដ្ឋានក្នុងការពិភាក្សាខាងគោលនយោបាយការធ្វើសេចក្តីសម្រេចចិត្ត និងចំណាត់ការពាក់ព័ន្ធនានាក្នុងការឈានទៅរកភាពធន់នឹងការប្រែប្រួលអាកាសធាតុ សេដ្ឋកិច្ចដែលមានការបញ្ចេញកាបូនទាប និងដើម្បីប្រើប្រាស់ឱកាសថ្មីៗសម្រាប់កាត់បន្ថយភាពក្រីក្រ តាមរយៈការគ្រប់គ្រងហានិភ័យនៃការប្រែប្រួលអាកាសធាតុ។

ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉ែត
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន NCCC

សេចក្តីថ្លែងអំណរគុណ

ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ក្នុងនាមឯកឧត្តមជាប្រធាន NCCC សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះសមាជិកសមាជិកាទាំងអស់នៃ NCCC ដែលបានប្រឹងប្រែងនៅក្នុងការរៀបចំនូវវេទិកាជាតិលើកទី២ នេះឡើងដែលទទួលបានលទ្ធផលជាទីមោទន:។

ឯកឧត្តមសូមថ្លែងអំណរគុណជាអនេកកប្បការចំពោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ប្រធានកិត្តិយសនៃ NCCC ដែលបានផ្តល់នូវកិច្ចស្វាគមន៍ដ៏កក់ក្តៅ និងផ្តល់ការណែនាំនៅក្នុងពិធីបើកវេទិកាជាតិលើកទី ២ ដ៏មានអត្ថប្រយោជន៍នេះ។

ក្នុងនោះផងដែរ សូមថ្លែងអំណរគុណចំពោះ វាគ្មិនទាំងអស់ ក្រុមអ្នកជំនាញការ និងសហប្រធានវគ្គទាំងអស់ ដែលមានឈ្មោះនៅក្នុងរបាយការណ៍សង្ខេបនេះ ដែលបានចូលរួមចំណែកយ៉ាងសកម្ម និងបានរួមចំណែកជម្រុញឲ្យកិច្ចពិភាក្សានៅក្នុងវេទិកានេះមានភាពសម្បូរបែបតាមរយៈចំណេះដឹង និងបទពិសោធន៍ដ៏ទូលំទូលាយ។

សូមថ្លែងអំណរគុណចំពោះ អ្នកចូលរួមទាំងអស់ ដែលបានចូលរួមយ៉ាងសកម្ម និងចែករំលែកនូវទស្សនវិស័យរបស់ខ្លួនទៅតាមប្រធានបទផ្សេងៗគ្នា ដែលបានលើកឡើងក្នុងវេទិកានេះ។

ជាពិសេស សូមថ្លែងអំណរគុណដល់ DPs រួមមាន EU UNDP DANIDA SIDA Oxfam America និង JCCI ចំពោះកិច្ចសហប្រតិបត្តិការ និងផ្តល់ការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុ ដែលបង្កលទ្ធភាពឲ្យវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុនេះ ប្រព្រឹត្តទៅតាមការគ្រោងទុក និងសម្រេចបានលទ្ធផលគួរជាទីមោទន:។

រាជធានីភ្នំពេញ

ឯកឧត្តម បណ្ឌិត ម៉ុក ម៉ារ៉ែត
ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
និងជាប្រធាន NCCC

មាតិការអត្ថបទ

អារម្ភកថា II
សេចក្តីថ្លែងអំណរគុណ IV
មាតិការអត្ថបទ V
ពាក្យបម្រួញ X
សេចក្តីសង្ខេប 1

របាយការណ៍ 8

ថ្ងៃទី១៖ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១ 8

កម្មវិធីបើក 8

សុន្ទរកថាបើកដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី 8

សុន្ទរកស្វាគមន៍ដោយឯកឧត្តម បណ្ឌិត ម៉ុក ម៉ារ៉ែត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន NCCC 9

វគ្គដំណើរការ 11

សុន្ទរកស្វាគមន៍ដោយលោក DOUGLAS BRODERICK អ្នកសម្របសម្រួលអ.ស.ប ប្រចាំនៅកម្ពុជា 11

សុន្ទរកស្វាគមន៍ដោយឯកឧត្តម បណ្ឌិត ម៉ុក ម៉ារ៉ែត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន NCCC 12

វគ្គចាប់ផ្តើម 14

បច្ចុប្បន្នភាពនៃព័ត៌មានវិទ្យាសាស្ត្រ ផលប៉ះពាល់ និងកាលានុវត្តភាពនៃការប្រែប្រួលអាកាសធាតុ 15

បច្ចុប្បន្នភាពអំពីការអភិវឌ្ឍថ្មីៗនិងគំនិតផ្តួចផ្តើមសំខាន់ៗលើការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា 18

បទបង្ហាញអំពីលទ្ធផលសំខាន់ៗនៃរបាយការណ៍ជាតិលើកទី២ 19

សំណួរ និងចម្លើយ 21

វគ្គស្របភ្លាមទី១៖ បន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ- តាពជោគជ័យ ការប្រឈម និងមេរៀនទទួលបាន 23

ស្ថានភាពនៃការអនុវត្តកម្មវិធីសកម្មភាពជាតិបន្សុំនឹងការប្រែប្រួលអាកាសធាតុ 23

គម្រោងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម (គម្រោងអនុវត្តក្រោមកម្មវិធីNAPA) 24

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា 25

គម្រោងការរៀបចំយុទ្ធសាស្ត្រកម្មវិធីសាកល្បងសម្រាប់ភាពធន់.... អាកាសធាតុដំណាក់កាលទី១នៅកម្ពុជា.....26
ការប្រែប្រួលអាកាសធាតុ និងសុខភាព.....26
ការប្រែប្រួលអាកាសធាតុ និងសន្តិសុខស្បៀង៖ បរិបទប្រទេសកម្ពុជា.....28
សំណួរ និងចម្លើយ.....29

វគ្គស្របក្លាទី១៖ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ៖ ស្ថានភាព ការរីកចម្រើនមេរៀនទទួលបាន តាពខ្វះចន្លោះផ្នែកគោលនយោបាយនិងអនុសាសន៍ 31

ស្ថានភាព និងចក្ខុវិស័យនៃទីផ្សារកាបូនស្ម័គ្រចិត្ត.....31
ស្ថានភាពបច្ចុប្បន្ននៃយន្តការអភិវឌ្ឍស្អាតនិងឧទាហរណ៍មួយនៃគម្រោងយន្តការអភិវឌ្ឍន៍ស្អាតនៅប្រទេសកម្ពុជា.....34
គម្រោងថាមពលពីអង្កាម ANGKOR BIOCOGEN.....35
ផែនទីបង្ហាញផ្លូវអំពីកម្មវិធី REDD+ របស់ប្រទេសកម្ពុជា.....36
ជម្រើសគោលនយោបាយសម្រាប់ REDD+ នៅតំបន់ការពារធម្មជាតិ.....37
សំណួរ និងចម្លើយ.....40

ថ្ងៃទី២៖ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១ 41

សុន្ទរកថាគមន៍ដោយលោក PETER J. BRIMBLE សេដ្ឋកិច្ចវិទូជាន់ខ្ពស់នៃ ADB.....41
សុន្ទរកថាគមន៍ដោយឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល.....42

វគ្គស្របក្លាទី២៖ បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ- ស្ថានភាព ជោគជ័យ ការប្រឈម និងមេរៀនទទួលបាន..... 43

ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយគ្រោះភ័យនៃគ្រោះមហន្តរាយ 43
គំនិតផ្តួចផ្តើមក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មាការទន្លេមេគង្គ៖ ឧទាហរណ៍នៃគម្រោងបន្សាំថ្នាក់តំបន់.....45
ឧបសគ្គ និងកាលានុវត្តភាពសម្រាប់ការ បន្សាំប្រកបដោយប្រសិទ្ធភាព.....47
ឧបសគ្គនៅក្នុងការបន្សាំឲ្យមានប្រសិទ្ធភាព-
ទស្សនទានពីរបាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ២០១១.....48
សំណួរ និងចម្លើយ.....49

វគ្គស្របក្លាទី២៖ ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ៖ ស្ថានភាព ការរីកចម្រើនមេរៀនទទួលបាន តាពខ្វះចន្លោះផ្នែកគោលនយោបាយនិងអនុសាសន៍ 53

ការអភិវឌ្ឍបៃតង ការអភិវឌ្ឍដែលបញ្ចេញកាបូនទាប.....53
ទីផ្សារថាមពលកកើតឡើងវិញនៅក្នុងកម្ពុជា៖ ផ្ទាំងស្រូបថាមពលពន្លឺព្រះអាទិត្យនិងបច្ចេកវិទ្យាថាមពលខ្យល់.....55

ភាពជាដៃគូផ្នែកថាមពល និងបរិស្ថាននៅតំបន់មេគង្គ៖ ឧទាហរណ៍អំពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ 56
គោលនយោបាយកាបូន៖ បទពិសោធន៍ថ្នាក់តំបន់ និងពិភពលោក ឧបសគ្គសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័ននៅកម្ពុជា និងសំណើវិធានការឆ្លើយតប 58
សំណួរ និងចម្លើយ 61

វគ្គស្របគ្នាទី៣៖ ការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ 66

ការសម្របសម្រួល និងប្រសិទ្ធភាពជំនួយ 66
ហិរញ្ញវត្ថុសម្រាប់ការបន្សាំ 68
សំណួរ និងចម្លើយ 70

វគ្គស្របគ្នាទី៣៖ បញ្ហាអន្តរវិស័យនៃការប្រែប្រួលអាកាសធាតុ 71

ជីវចម្រុះ និងការប្រែប្រួលអាកាសធាតុ 71
យេនឌ័រ និងការប្រែប្រួលអាកាសធាតុ 74
សំណួរ និងចម្លើយ 76

វគ្គពេញអង្គ៖ ការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ 78

ពិធីប្រកាសគម្រោងដែលបានជ្រើសរើសនៅក្រោមការប្រកាសទទួលសំណើគម្រោងលើកទី១នៃ CCCATF 78
សុន្ទរកថាចំណាប់អារម្មណ៍លោកស្រីបណ្ឌិត កៅ សុជីវី អគ្គនាយករងរដ្ឋបាលជលផល 79
សុន្ទរកថាចំណាប់អារម្មណ៍របស់លោក ជា សារិទ្ធ ប្រធានអង្គការ WOMEN 80
សុន្ទរកថាចំណាប់អារម្មណ៍របស់លោកស្រីKrinstina Kuhnel នាយិកាអង្គការស៊ីដា 81
សេចក្តីណែនាំអំពី CCCA TF 82
សំណួរ និងចម្លើយ 83

ថ្ងៃទី៣៖ ថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១១ 84

សុន្ទរកស្វាគមន៍ដោយលោក RAFAEL DOCHAO MORENO ភារៈធារីនៃប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា 84
សុន្ទរកស្វាគមន៍ដោយឯកឧត្តម រស់ សីលវ៉ា អគ្គលេខាធិការរងនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ 85

វគ្គពេញអង្គ៖ ក្របខ័ណ្ឌគោលនយោបាយប្រែប្រួលអាកាសធាតុ៖ ដំណើរឆ្ពោះទៅកាន់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា 86

គោលនយោបាយនិងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ៖ បទពិសោធន៍អន្តរជាតិ និងបទពិសោធន៍ក្នុងតំបន់ 86
គោលនយោបាយតាមវិស័យដែលពាក់ព័ន្ធនឹងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា 89
ដំណើរឆ្ពោះទៅកាន់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា 92

ខ្លឹមសារសំខាន់ៗពាក់ព័ន្ធនឹងកិច្ចចរចាការប្រែប្រួលអាកាសធាតុនាពេលថ្មីៗនេះ 94
សេចក្តីពង្រាងគោលជំហររបស់កម្ពុជាសម្រាប់ដំណើរឆ្ពោះទៅកាន់ខ្ងបាន
អាហ្វ្រិកខាងត្បូង 98
សំណូរ និងចម្លើយ 100

ការតាំងពិព័រណ៍ 110

ពិធីបិទ 110

សុន្ទរកថាបិទដោយឯកឧត្តម បណ្ឌិត ម៉ុក ម៉ារ៉ែត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន
និងជាប្រធាន NCCC 110

សន្និសីទសារព័ត៌មាន 112

ឧបសម្ព័ន្ធ 116

ឧបសម្ព័ន្ធ ១ - កម្មវិធី 116

ឧបសម្ព័ន្ធ ២ - សុន្ទរកថាបើក និងបិទ 126

សុន្ទរកថាបើក ថ្ងៃទី០១ របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី យឹម ឆៃលី
តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា.....126

សុន្ទរកថាស្វាគមន៍ថ្ងៃទី០១ របស់ ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉ែត ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន NCCC 136

សុន្ទរកថាស្វាគមន៍ថ្ងៃទី០១ របស់លោក DOUGLAS BRODERICK
អ្នកសម្របសម្រួលរបស់កម្មវិធីសហប្រជាជាតិប្រចាំនៅកម្ពុជា.....142

សុន្ទរកថាស្វាគមន៍ថ្ងៃទី០១ របស់ ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉ែត
ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងបរិស្ថាននិងជាប្រធាន NCCC 147

សុន្ទរកថាស្វាគមន៍ថ្ងៃទី០២ របស់លោក PETER J. BRIMBLE
សេដ្ឋកិច្ចវិទូជាន់ខ្ពស់និងជា OIC នៃធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា.....151

សុន្ទរកថាស្វាគមន៍ថ្ងៃទី០២ របស់ឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម៉ែ
និងថាមពល 154

សុន្ទរកថាស្វាគមន៍ថ្ងៃទី០៣ របស់លោក RAFAEL DOCHAO MORENO ភារៈធារី
នៃប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា.....157

សុន្ទរកថាស្វាគមន៍ថ្ងៃទី០៣ របស់ឯកឧត្តម រស់ សីលវ៉ា
អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ 161
សុន្ទរកថាបិទ ថ្ងៃទី០៣ របស់ ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉ែត ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន NCCC 164

ឧបសម្ព័ន្ធ ៣ - បទឧបដ្ឋាញ្ញៅក្នុងវេទិកា 167

ឧបសម្ព័ន្ធ ៤ - ជីវប្រវត្តិសង្ខេប 494

ឧបសម្ព័ន្ធ៥-បញ្ជីរាយនាមអ្នកចូលរួម 508

ពាក្យបម្រួញ

ADB	Asian Development Bank	ធនាគារអភិវឌ្ឍន៍អាស៊ី
AFD	Agence France de Development	ទីភ្នាក់ងារអភិវឌ្ឍន៍នៃប្រទេសបារាំង
AFOLU	Agriculture, Forestry and Land Use	កសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដី
ASEAN	Association of Southeast Asian Nations	សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍
BAU	Business As Usual	តាមទម្លាប់ធម្មតា
CARD	Council for Agricultural and Rural Development	ក្រុមប្រឹក្សាអភិវឌ្ឍន៍កសិកម្ម និងជនបទ
CARDI	Cambodian Agricultural Research and Development Institute	វិទ្យាស្ថានស្រាវជ្រាវកសិកម្ម និងអភិវឌ្ឍន៍កម្ពុជា
CBD	Convention on Biological Diversity	អនុសញ្ញាស្តីពីជីវចម្រុះ
CCA	Climate Change Adaptation	ការបន្សាំប្រែប្រួលអាកាសធាតុ
CCAI	Climate Change Adaptation Initiative	គំនិតផ្តួចផ្តើមការបន្សាំប្រែប្រួលអាកាសធាតុ
CCB	Climate, Community and Biodiversity	អាកាសធាតុ សហគមន៍ និងជីវចម្រុះ
CCCA	Cambodia Climate Change Alliance	សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា
CCCSP	Cambodia Climate Change Strategic Plan	ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ កម្ពុជា
CCD	Climate Change Department	នាយកដ្ឋានប្រែប្រួលអាកាសធាតុ
CCSAP	Climate Change Strategies and Action Plans	ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព ប្រែប្រួលអាកាសធាតុ
CCSP	Climate Change Strategic Plan	ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ
CDC	Council for the Development of Cambodia	ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
CDCF	Cambodia Development Cooperation Forum	វេទិកាសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា
CDM	Clean Development Mechanism	យន្តការអភិវឌ្ឍន៍ស្អាត
CDRI	Cambodia's Leading Independent Development Policy Research Institute	វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កម្ពុជា
CERs	Certified Emission Reductions	ការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់
CH_4	Methane	មេតាន
CHDR	Cambodia Human Development Report	របាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជា
CI	Conservation International	ការអភិរក្សអន្តរជាតិ
CNMC	Cambodia National Mekong	គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

	Committee	
CO_2	Carbon Dioxide	ឧស្ម័នកាបូនិច
CO_{2e}	Carbon Dioxide Equivalent	សមមូលឧស្ម័នកាបូនិច
CoP	Conference of Parties	សន្និសីទភាគី
CRDB	Cambodia Rehabilitation and Development Board	គណៈកម្មាធិការស្តារ និងអភិវឌ្ឍន៍កម្ពុជា
CSO	Civil Society Organization	អង្គការសង្គមស៊ីវិល
DANIDA	Danish International Development Agency	ទីភ្នាងក់ងារអភិវឌ្ឍន៍អន្តរជាតិ នៃប្រទេសដាណឺម៉ាក
DCA/CA	Danish Church Aid/Christian Aid	ជំនួយរបស់វិហារដាណឺម៉ាក / ជំនួយគ្រឹស្តបរិស័ទ
DCs	Developing Countries	ប្រទេសកំពុងអភិវឌ្ឍន៍
DNA	Designated National Authority	ស្ថាប័នជាតិយន្តការអភិវឌ្ឍន៍ស្អាត
DPs	Development Partners	ដៃគូអភិវឌ្ឍន៍
DRM	Disaster Risk Management	ការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយ
DRR	Disaster Risk Reduction	ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ
DSPFF	Draft Strategic Planning Framework for Fisheries	ពង្រាងក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់វិស័យជលផល
EE	Energy Efficiency	ប្រសិទ្ធភាពថាមពល
EEP	Energy and Environment Partnership	ភាពជាដៃគូផ្នែកថាមពល និងបរិស្ថាន
ETS	Emission Trading Scheme	ប្រព័ន្ធពាណិជ្ជកម្មនៃការបញ្ចេញ
EU	European Union	សហគមន៍អឺរ៉ុប
FA	Forest Administration	រដ្ឋបាលព្រៃឈើ
FCPF	Forest Carbon Partnership Facility	មូលនិធិភាពជាដៃគូកាបូនព្រៃឈើ
FiA	Fishery Administration	រដ្ឋបាលជលផល
GCF	Global Climate Fund	មូលនិធិអាកាសធាតុសកល
GCMS	General Circulation Models	ម៉ូដែលចរន្តទូទៅ
GDANCP	General Department of Administration for Nature Conservation	អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ
GDCC	Government-Donors Coordination Committee	គណៈកម្មាធិការសម្របសម្រួលរដ្ឋាភិបាល និងម្ចាស់ជំនួយ
GDP	Gross Domestic Products	ផលិតផលក្នុងស្រុកសរុប
GEF	Global Environment Fund	មូលនិធិបរិស្ថានពិភពលោក
GERES	Groupe Energies Renouvelables, Environnement et Solidarités	អង្គការថាមពលកកើតឡើងវិញ បរិស្ថាន និងសាមគ្គីភាព
GHG	Greenhouse Gas	ឧស្ម័នផ្ទះកញ្ចក់
Gt CO2e	Giga Ton Carbon DioxideEquivalent	ជីហ្គាតោនឧស្ម័នកាបូនិចសមមូល

IFC	International Financial Corporation	សាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ
IGES	The Institute for Global Environmental Strategies	វិទ្យាស្ថានសម្រាប់យុទ្ធសាស្ត្របរិស្ថានពិភពលោក
IPCC	Intergovernmental Panel on Climate Change	ក្រុមការងារអន្តររដ្ឋាភិបាលទទួលបន្ទុកការប្រែប្រួលអាកាសធាតុ
IUCN	International Union for Conservation of Nature	សម្ព័ន្ធភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ
JCCI	Joint Climate Change Initiative	គំនិតផ្តួចផ្តើមប្រែប្រួលអាកាសធាតុរួមគ្នា
JI	Joint Implementation	ការអនុវត្តរួមគ្នា
JICA	Japan International Cooperation Agency	ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន
KS	Khmer Solar	ខ្មែរសូឡា
LCDF	Least Developed Countries Fund	មូលនិធិប្រទេសអភិវឌ្ឍន៍តិចតួច
LDCs	Least Developed Countries	ប្រទេសអភិវឌ្ឍន៍តិចតួច
LUCF	Land Use Change and Forestry	ការប្រែប្រួលការប្រើប្រាស់ដី និងព្រៃឈើ
M&E	Monitoring and Evaluation	ការត្រួតពិនិត្យ និងការវាយតម្លៃ
MAFF	Ministry of Agriculture, Forestry and Fisheries	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
MEF	Ministry of Economy and Finance	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
MIME	Ministry of Industry, Mines and Energy	ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
MLMUPC	Ministry of Land Management, Urban Planning and Construction	ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
MoE	Ministry of Environment	ក្រសួងបរិស្ថាន
MoEYS	Ministry of Education, Youth and Sports	ក្រសួងអប់រំ យុវជន និងកីឡា
MoH	Ministry of Health	ក្រសួងសុខាភិបាល
MoP	Ministry of Planning	ក្រសួងផែនការ
MoWA	Ministry of Women Affair	ក្រសួងកិច្ចការនារី
MoWRAM	Ministry of Water Resources and Meteorology	ក្រសួងធនធានទឹក និងឧតុនិយម
MRC	Mekong River Commission	គណៈកម្មការទន្លេមេគង្គ
MRV	Measure, Reporting and Verification	អាចវាស់វែងបាន អាចរាយការណ៍បាន និងអាចផ្ទៀងផ្ទាត់បាន
MW	Megawatt	មេហ្គាវ៉ាត់
N_2O	Nitrous Oxide	ឌីអាសូតម៉ូណូអុកស៊ីត
NAMA	Nationally Appropriate Mitigation Action	សកម្មភាពកាត់បន្ថយសមស្របជាតិ
NAP	National Action Plan	ផែនការសកម្មភាពជាតិ
NAPA	National Adaptation Programme of Action to Climate Change	កម្មវិធីសកម្មភាពជាតិបន្សាំនឹង

		ការប្រែប្រួលអាកាសធាតុ
NCCC	National Climate Change Committee	គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
NCDM	National Committee for Disaster Management	គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ
NDF	Nordic Development Fund	មូលនិធិអភិវឌ្ឍន៍ន័រឌីក
NEHAP	National Environmental Health Action Plan	ផែនការសកម្មភាពសុខភាពបរិស្ថានជាតិ
NGO	Non-governmental Organization	អង្គការក្រៅរដ្ឋាភិបាល
NPASP	National Protected Area System Plan	ប្រព័ន្ធផែនការតំបន់ការពារធម្មជាតិជាតិ
NSDP	National Strategic Development Plan	ផែនការអភិវឌ្ឍយុទ្ធសាស្ត្រជាតិ
OA	Oxfam America	អង្គការអុកស្វាមអាមេរិចកាំង
ODA	Official Development Assistance	ជំនួយអភិវឌ្ឍន៍ផ្លូវការ
PA	Protected Area	តំបន់ការពារធម្មជាតិ
PPCR	Pilot Programme for Climate Change Resilience	កម្មវិធីសាកល្បងសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ
REDD	Reducing Emissions from Deforestation and Forest Degradation	កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ
RGC	Royal Government of Cambodia	រាជរដ្ឋាភិបាលកម្ពុជា
SAPs	Strategic Action Plan	ផែនការសកម្មភាពជាយុទ្ធសាស្ត្រ
SAW	Strategies for Agriculture and Water Resources	យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងធនធានទឹក
SEA	Southeast Asia	អាស៊ីអាគ្នេយ៍
SIDA	Swedish International Development Agency	ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ
SME	Small and Medium Enterprise	សហគ្រាសខ្នាតតូច និងមធ្យម
SNA	Sub-National Authority	អាជ្ញាធរថ្នាក់ក្រោមជាតិ
SNAP-DRR	Strategic National Action Plan for Disaster Risk Reduction	ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិសម្រាប់កាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ
SNC	Second National Communication to UNFCCC	របាយការណ៍ជាតិលើកទី២
SNFCC	Second National Forum on Climate Change	វេទិកាជាតិលើកទី២ស្តីពីការប្រែប្រួលអាកាសធាតុ
SPCR	Strategic Programme for Climate Resilience	កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងការប្រែប្រួលអាកាសធាតុ
TF	Trust Fund	មូលនិធិប្រែប្រួលអាកាសធាតុ
TWG	Technical Working Group	ក្រុមការងារបច្ចេកទេស

UN	United Nations	អង្គការសហប្រជាជាតិ (អ.ស.ប)
UNDP	United Nations Development Programme	កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ
UNEP	United Nations Environment Programme	កម្មវិធីបរិស្ថានសហប្រជាជាតិ
UNESCAP	United Nations Economic and Social Commission for Asia and the Pacific	គណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក
UNFCCC	United Nations Framework Convention on Climate Change	អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ
$US	United State Dollar	ដុល្លាអាមេរិក
VCM	Voluntary Carbon Market	ទីផ្សារកាបូនស្ម័គ្រចិត្ត
VCS	Voluntary Carbon Standard	ស្តង់ដារកាបូនស្ម័គ្រចិត្ត
VEPF	Vietnam Environmental Protection Fund	មូលនិធិការពារបរិស្ថានប្រទេសវៀតណាម
VERs	Verified Emission Reductions	ការកាត់បន្ថយការបញ្ចេញដែលបានផ្ទៀងផ្ទាត់
VGS	Voluntary Gold Standard	ស្តង់ដារមាសស្ម័គ្រចិត្ត
WB	World Bank	ធនាគារពិភពលោក
WHO	World Health Organization	អង្គការសុខភាពពិភពលោក
WOMEN	Women Organization for Modern Economy and Nursing	សមាគមនារីអភិវឌ្ឍន៍សេដ្ឋកិច្ច និងអនាម័យ
WTE	Waste To Energy	សំណល់ទៅជាថាមពល
WWF	World Wildlife Fund	មូលនិធិសត្វព្រៃពិភពលោក

សេចក្តីសង្ខេប

វេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុត្រូវបានរៀបចំឡើងចាប់ពីថ្ងៃទី០៣-០៥ ខែតុលា ឆ្នាំ២០១១ នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ វេទិកាជាតិរយៈពេលបីថ្ងៃនេះ គឺជាវេទិកាចែករំលែកនូវចំណេះដឹង និងបទពិសោធន៍ ដោយផ្តោតជាពិសេសលើការបង្កើតកិច្ចពិភាក្សាគោលនយោបាយដែលមានគំនិតស្ថាបនាមួយ ដើម្បីគាំទ្រដល់ប្រទេសកម្ពុជាក្នុងការរៀបចំនូវគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិដ៏មានប្រសិទ្ធភាពមួយ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយបញ្ចូល NCCC ក្រុមបច្ចេកទេសអន្តរក្រសួង និងអ្នកពាក់ព័ន្ធនានា ក្នុងកិច្ចពិភាក្សា និងព្រមព្រៀងលើដំណើរការសម្រាប់ការអភិវឌ្ឍគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

វេទិកានេះ ក៏ផ្តល់ជាឱកាសដល់រាជរដ្ឋាភិបាលកម្ពុជាពិនិត្យឡើងវិញ និងកំណត់ជំហររបស់ខ្លួនក្នុងកិច្ចចរចានៅក្នុង CoP១៧ នៃ UNFCCC ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៨ ខែវិច្ឆិកា ដល់ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១១ នៅទីក្រុងឌួបានប្រទេសអាហ្វ្រិចខាងត្បូង។

នៅក្នុងកម្មវិធីបើក ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន NCCC បានផ្តល់នូវសុន្ទរកថាស្វាគមន៍ និងសុន្ទរកថាបើកវេទិកាជាតិជាផ្លូវការ ផ្តល់ដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ឃឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ ចំណែកសុន្ទរកថាស្វាគមន៍នៅក្នុងកម្មវិធីបន្តបន្ទាប់ត្រូវបានផ្តល់ដោយ លោក Douglas Broderick អ្នកសម្របសម្រួលអង្គការសហប្រជាជាតិ ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ឯកឧត្តម **ស្រ៊ុន តារា** អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លោក Peter J. Brimble សេដ្ឋវិទូជាន់ខ្ពស់នៃ ADB លោក Rafael Dochao Moreno ភារៈធារីនៃប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា។

វគ្គសំខាន់ៗនៅក្នុងវេទិកាជាតិលើកទី២នេះ ត្រូវបានរៀបចំ ដោយចែកចេញជាបរិបទផ្សេងៗ ដូចដែលបង្ហាញខាងក្រោម ដោយមានការធ្វើបទបង្ហាញពីអ្នកជំនាញជាតិ និងអន្តរជាតិ។

១. វគ្គចាប់ផ្តើម

២. វគ្គបច្ចេកទេសស្របគ្នា

ក. បន្សាំនឹងការប្រែប្រួលអាកាសធាតុ-ការប្រឈម ភាពជោគជ័យនិងមេរៀនទទួលបាន

ខ. ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ការរីកចម្រើន មេរៀនទទួលបាន ភាពខ្វះចន្លោះផ្នែកគោលនយោបាយ និងអនុសាសន៍

គ. ការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

ឃ.បញ្ហាអន្តរវិស័យនៃការប្រែប្រួលអាកាសធាតុ

៣. វគ្គពេញអង្គ

៣.១ ការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

៣.២ ក្របខណ្ឌគោលនយោបាយប្រែប្រួលអាកាសធាតុ ដំណើរឆ្ពោះទៅកាន់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា

៤.កម្មវិធីបិទ

៥. សន្និសីទសារព័ត៌មាន

៦. ការតាំងពិព័រណ៍ប្រែប្រួលអាកាសធាតុ

ឥឡូវចាប់ផ្តើម

បច្ចុប្បន្នភាពនៃព័ត៌មានថ្មីៗបំផុតអំពីវិទ្យាសាស្ត្រ ផលប៉ះពាល់ និងកាលានុវត្តភាពនៃការប្រែប្រួលអាកាសធាតុ បច្ចុប្បន្នភាពអំពីការអភិវឌ្ឍថ្មីៗ និងគំនិតផ្តួចផ្តើមសំខាន់ៗលើការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងលទ្ធផលសំខាន់ៗនៃរបាយការណ៍ជាតិលើកទី ២ ត្រូវបានលើកមកពិភាក្សា។ អ្វីគួរឲ្យកត់សម្គាល់នោះ គឺជាសញ្ញាណនៃកំណើនកម្តៅពិភពលោក ដូចជា ការប្រែប្រួលសីតុណ្ហភាព របបទឹកភ្លៀង កំណើនកម្ពស់ទឹកសមុទ្រ ព្រឹត្តិការណ៍ធ្ងន់ធ្ងរ និងភាពមិនប្រក្រតីនានាមានភាពខុសគ្នាទៅតាមតំបន់ និងតាមប្រទេស។ កំណើនសីតុណ្ហភាពកាន់តែខ្ពស់ ផលប៉ះពាល់ក៏នឹងកាន់តែខ្លាំងដែរ។

នៅកម្ពុជា សង្កេតឃើញថា ការបញ្ចេញ GHGs មានទំនោរកើនឡើង ដោយធៀបនឹងការបញ្ចេញនៅឆ្នាំគោល ២០០០ ទៅនឹងឆ្នាំគោល ១៩៩៤។ ឃុំភាគច្រើននៅកម្ពុជា ត្រូវបានកម្រិតពីភាពងាយរងគ្រោះទៅដល់ងាយរងគ្រោះខ្លាំង ដោយសារសេដ្ឋកិច្ច សង្គម និងលក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធនៅមានភាពទន់ខ្សោយ។ ការប្រែប្រួលនេះ នឹងផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់វិស័យជាច្រើន ដែលតម្រូវឲ្យមានការអភិវឌ្ឍ និងអនុវត្តនូវគម្រោងបន្សាំ និងគម្រោងសាកល្បងនៅថ្នាក់មូលដ្ឋាន។

ក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) និងកម្មវិធីសាកល្បងសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (PPCR) ត្រូវបានផ្តួចផ្តើមឡើងដែលបាន និងកំពុងអនុវត្ត។

បន្សាំនឹងការប្រែប្រួលអាកាសធាតុ៖ ភាពជោគជ័យ ការប្រឈម និងមេរៀនទទួលបាន

កម្ពុជា គឺជាប្រទេសដែលងាយរងគ្រោះបំផុតទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយសារការអភិវឌ្ឍសេដ្ឋកិច្ចផ្អែកលើកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងធនធានមនុស្សទន់ខ្សោយ ធនធានហិរញ្ញវត្ថុមានកម្រិត កង្វះខាតនៃការទទួលបានបច្ចេកវិទ្យាសមស្របសម្រាប់ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សមត្ថភាពបន្សាំមានកម្រិត បញ្ហាទាក់ទងនឹងក្របខណ្ឌស្ថាប័ន ភាពទន់ខ្សោយនៃអភិបាលកិច្ច និងការធ្វើសេចក្តីសម្រេចចិត្តជាដើម។

ទោះបីជាយ៉ាងណាក៏ដោយ មានកម្មវិធីមួយចំនួនត្រូវបានផ្តួចផ្តើម និងអនុវត្ត ដើម្បីគាំទ្រដល់កម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) ជាឧទាហរណ៍ CCCA និង PPCR ត្រូវបានលើកមកបង្ហាញ និងពិភាក្សា។ ការកសាងសមត្ថភាព ការបង្រួបបង្រួមការប្រែប្រួលអាកាសធាតុ និងយេនឌ័រទៅដល់ថ្នាក់ក្រោមជាតិ ការចូលរួមពីអន្តរវិស័យ និងការរួមបញ្ចូលបញ្ហានៃ

ការប្រែប្រួលអាកាសធាតុក្នុង NSDP ត្រូវបានស្នើឡើងថាពិតជាមានសារសំខាន់ណាស់ក្នុងការងារដោះស្រាយការប្រែប្រួលអាកាសធាតុ។

ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ៖ ស្ថានភាព ឥឌ្ឍនភាព មេរៀនទទួលបាន ភាពខ្វះចន្លោះផ្នែកគោលនយោបាយ និងអនុសាសន៍

នៅក្នុងបរិបទនៃជម្រើសកាត់បន្ថយ មានប្រធានបទជាច្រើនត្រូវបានលើកមកបង្ហាញ និងពិភាក្សា ចាប់ពីទស្សនវិស័យថ្នាក់តំបន់ដល់ថ្នាក់ជាតិ។ យន្តការអភិវឌ្ឍន៍ស្អាត (CDM) និងទីផ្សារកាបូនស្ម័គ្រចិត្ត (VCM) គឺជាយន្តការ ដែលអាចជួយគាំទ្រដល់សកម្មភាពកាត់បន្ថយ GHGs នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ (DCs)។ ប៉ុន្តែមានតែ CDM ទេ ដែលមានលក្ខណៈសមស្របបំផុតសម្រាប់ការអនុវត្តនៅកម្ពុជា ហើយតួលេខបានបង្ហាញថា ចំនួនកិច្ចសន្យាសម្រាប់ការអភិវឌ្ឍគម្រោង CDM មានការកើនឡើងគួរឲ្យកត់សម្គាល់នៅក្នុងឆ្នាំនេះ។

កម្មវិធីការកាត់បន្ថយការបញ្ចេញឧស្ម័ន ដែលបណ្តាលមកពីការបាត់បង់ និងការរេចរឹលព្រៃឈើបូក(REDD+) គឺជាកម្មវិធីមួយដែលអាចនាំមកនូវចំណូលថវិកាពីវិស័យព្រៃឈើ តាមរយៈការទប់ស្កាត់ការបាត់បង់ និងការរេចរឹលនៃព្រៃឈើ។ REDD+ គឺជាយន្តការមួយសំខាន់សម្រាប់កម្ពុជា ព្រោះវាស្របជាមួយនឹងគោលនយោបាយ និងទិសដៅរបស់ RGC ជាពិសេសការប្តេជ្ញាចិត្តក្នុងការរក្សាគម្របព្រៃឈើ ហើយនឹងអាចគាំទ្រផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន ជាពិសេសការអភិរក្សព្រៃឈើ និងសត្វព្រៃ។

ក្រៅពីនេះ ការអភិវឌ្ឍបៃតង គឺជាជម្រើសមួយទៀត ដែលសមស្របទាំងការបន្សាំ និងការកាត់បន្ថយ។ ការអនុវត្តការអភិវឌ្ឍបៃតង គឺមិនមែនជាបញ្ហាថវិកា និងបច្ចេកវិទ្យាទេ ប៉ុន្តែគឺជាបញ្ហានៃការប្តេជ្ញាចិត្តខាងនយោបាយ ចក្ខុវិស័យ និងជម្រើសគោលនយោបាយផងដែរ។ កម្ពុជា ជាប្រទេសកំពុងអភិវឌ្ឍន៍មួយ ដូចនេះការទទួលយកការអភិវឌ្ឍបៃតងគួរតែមានការប្រុងប្រយ័ត្ន។

ទីផ្សារថាមពលព្រះអាទិត្យ (ថាមពលកកើតឡើងវិញ) គឺជាជម្រើសនៃការកាត់បន្ថយមួយដែលអាចអនុវត្តបាននៅកម្ពុជា ហើយទំហំទីផ្សារកំពុងមានទំនោរកើនឡើងនាប៉ុន្មានឆ្នាំចុងក្រោយនេះ។ ប៉ុន្តែនៅដំណាក់កាលនៃការអភិវឌ្ឍទីផ្សារដំបូងមានឧបសគ្គជាច្រើនដូចជា ការយល់ដឹងជាសាធារណៈ ការយកពន្ធ សេវាកម្មថែទាំ និងកង្វះខាតព័ត៌មាន។ ដើម្បីធ្វើឲ្យទីផ្សារថាមពលព្រះអាទិត្យមានការកើនឡើង តម្រូវឲ្យមានការគាំទ្រយ៉ាងខ្លាំងពីរាជរដ្ឋាភិបាល វិស័យឯកជន និងអ្នកពាក់ព័ន្ធនានា។

បើក្រឡេកមើលគោលនយោបាយកាបូនវិញ សង្កេតឃើញថា វិបត្តិសេដ្ឋកិច្ចពិភពលោកបានជះឥទ្ធិពលយ៉ាងខ្លាំងលើទីផ្សារកាបូន ហើយការចរចារនៅកម្រិតអន្តរជាតិមានការរីកចម្រើនតិចតួចចំពោះការបង្កើតយន្តការថ្មីសម្រាប់ជំនួសពិធីសារក្យូតូ។ វត្តមានគោលនយោបាយកាបូន គឺជាគន្លឹះព្រោះយន្តការពឹងផ្អែកលើបរិបទទីផ្សារទូលំទូលាយខាងសេដ្ឋកិច្ច និងការវិនិយោគនៅកម្ពុជា ដើម្បីអាចផ្តល់ជាមូលដ្ឋានតាមបែបផែននៃការចូលរួមសម្រាប់ច្បាប់នានាទៅអនាគត និងភាពលំអិតនៃនីតិកម្មកាបូន ការបកស្រាយបំភ្លឺពីការយកពន្ធ និងសិទ្ធិជាម្ចាស់។

ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

ជំនួយសហប្រតិបត្តិការសម្រាប់កម្ពុជា មានការកើនឡើងគួរឲ្យកត់សំគាល់ស្នើរគ្រប់វិស័យជាពិសេសក្នុងវិស័យសង្គមកិច្ច។ នៅក្នុងការសម្របសម្រួល និងប្រសិទ្ធភាពជំនួយនិងហិរញ្ញប្បទាន

ក្រសួងពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលត្រូវបានកំណត់នូវតួនាទី និងទំនួលខុសត្រូវក្នុងការអនុវត្តជំនួយសហប្រតិបត្តិការនេះ។ ចំពោះយន្តការត្រួតពិនិត្យ វេទិកាសហប្រតិបត្តិការដើម្បីអភិវឌ្ឍន៍កម្ពុជា (CDCF) កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលរាជរដ្ឋាភិបាល និងម្ចាស់ជំនួយ (GDCC) នឹងត្រូវរៀបចំឡើង ដែលក្នុងនោះក្រសួងពាក់ព័ន្ធនឹងធ្វើបទបង្ហាញពីផែនការនីមួយៗ និងយុទ្ធសាស្ត្ររបស់ខ្លួនដើម្បីឲ្យ DPs ដឹងកាន់តែច្បាស់ពីអ្វី ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល និងអ្វីជាអាទិភាពសំខាន់ៗរបស់ DPs ។ បញ្ហាអន្តរវិស័យ (យេនឌ័រ និងការប្រែប្រួលអាកាសធាតុ) នឹងត្រូវលើកមកពិភាក្សាផងដែរក្នុងវេទិកានេះ ដើម្បីឲ្យប្រាកដថាកិច្ចការអន្តរវិស័យទាំងនេះ អាចអនុវត្តបានលើគ្រប់វិស័យពាក់ព័ន្ធនានា។ សំណើ និងការផ្តល់យោបល់ពីភាគីទាំងពីរគឺDPs និងរាជរដ្ឋាភិបាល នឹងត្រូវបានលើកឡើងផងដែរ ដើម្បីស្វែងរកនូវដំណោះស្រាយនានា ដែលអាចអនុវត្តនូវជំនួយសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ដែលជាបុព្វហេតុធ្វើឲ្យជំនួយសហប្រតិបត្តិការសម្រាប់កម្ពុជាមានការកើនឡើងជាលំដាប់។ ជំនួយប្រែប្រួលអាកាសធាតុ គឺជាប្រភពនៃជំនួយសហប្រតិបត្តិការថ្មីមួយសម្រាប់កម្ពុជា ដែលតម្រូវឲ្យមានយន្តការសម្របសម្រួលត្រឹមត្រូវមួយ ដោយអាចអនុលោមតាមយន្តការជាតិ ដែលមានស្រាប់សម្រាប់ជំនួយអភិវឌ្ឍន៍ផ្សេងទៀត។

ប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) និងប្រទេសកំពុងអភិវឌ្ឍន៍ (DCs) ត្រូវការថវិកា ១០០ពាន់លានដុល្លាអាមេរិក ប្រចាំឆ្នាំពីប្រទេសអភិវឌ្ឍន៍ដើម្បីគាំទ្រដល់ការងារបន្សាំនឹងការប្រែប្រួលអាកាសធាតុ ។ ប៉ុន្តែមានថវិកាប្រហែលជា ២ពាន់លានដុល្លាអាមេរិក ប៉ុណ្ណោះបានផ្តល់ជូនក្នុងចំណោមថវិកាសរុបដែលបានសន្យាប្រមាណ ៣២ពាន់លានដុល្លាអាមេរិក។ ជាងនេះទៀត ការបែងចែកមូលនិធិប្រែប្រួលអាកាសធាតុនេះ ពុំមានតុល្យភាពរវាងការបន្សាំ និងការកាត់បន្ថយទេ។ ប្រមាណជា ៧៩% នៃមូលនិធិសរុប គឺផ្តល់ឲ្យផ្នែកការកាត់បន្ថយ។ កង្វះខាតនៃមូលនិធិដែលមានស្រាប់អាចត្រូវបានបកស្រាយដោយសារកង្វះភាពដឹកនាំច្បាស់លាស់ ឬកង្វះការសម្របសម្រួលឲ្យ បានគ្រប់គ្រាន់ និងកង្វះការចូលរួម និងគណនេយ្យភាពចំពោះ CSOs និងសហគមន៍ដែលងាយរងគ្រោះ ជាពិសេសស្ត្រី។ មូលនិធិអាកាសធាតុបៃតង (GCF) ដែលគណនេយ្យភាព តម្លាភាព និងភាពជាម្ចាស់ គឺជាលក្ខខណ្ឌចាំបាច់របស់ GCF ។ GCF ផ្តល់នូវសក្តានុពលក្នុងការបង្កើតអភិក្រមថ្មីៗ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុនៅកម្រិតសកល ហើយការកសាងសមត្ថភាពស្ថាប័នមានសារសំខាន់ណាស់សម្រាប់ការបន្សាំដែលមានប្រសិទ្ធភាព។

បញ្ហាអន្តរវិស័យនៃការប្រែប្រួលអាកាសធាតុ

ការប្រែប្រួលអាកាសធាតុត្រូវបានទទួលស្គាល់ជាបញ្ហាអន្តរវិស័យ ដូចនេះបទបង្ហាញចំនួនពីរត្រូវបានលើកមកបកស្រាយរួមមាន ជីវចម្រុះ និងយេនឌ័រ។ កម្ពុជា គឺជាប្រទេសដែលសម្បូរទៅដោយជីវចម្រុះ ដែលជារតនៈសម្បត្តិជាតិ និងមានសារសំខាន់ជាសាកល។ ប៉ុន្តែ ជីវចម្រុះនេះកំពុងស្ថិតនៅក្រោមសម្ពាធយ៉ាងធ្ងន់ធ្ងរ ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ការប្រមាញ់ និងការទាញយកលើសកម្រិត។ មកទល់នឹងបច្ចុប្បន្ននេះ ពុំទាន់មានការសិក្សាពីផលប៉ះពាល់លើជីវចម្រុះ ដែលទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងគ្មានឯកសារបង្ហាញច្បាស់លាស់ដោយសារកង្វះខាងការសិក្សា និងតាមដានរយៈពេលវែងដែលផ្តោតចំគោលដៅ។ សក្តានុពលនៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវចម្រុះ គឺប៉ះពាល់ដោយផ្ទាល់ទៅលើប្រភេទនានា និងជីវចម្រុះតាមរយៈការផ្លាស់ប្តូរស្ថានប្រព័ន្ធ។ REDD+ អាចជាយុទ្ធសាស្ត្រកាត់បន្ថយមួយដ៏សំខាន់ដើម្បីថែរក្សានូវធនធានព្រៃឈើនៅកម្ពុជានិងក្នុងតំបន់។

មានការសិក្សាជាច្រើនបានបង្ហាញថា ចំនួនស្ត្រីស្លាប់ច្រើនជាងបុរសពេលមានគ្រោះធម្មជាតិកើតឡើងដោយសារវិសមភាពរវាងបុរស និងស្ត្រី ព្រមទាំងការចូលរួមរបស់ស្ត្រីក្នុងទំនួលខុសត្រូវនៅក្នុងគ្រួសារ។ វិសមភាព ដែលមានស្រាប់នឹងកាន់តែធ្ងន់ធ្ងរដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងកំហិតលើប្រសិទ្ធភាពនៃយុទ្ធសាស្ត្រកាត់បន្ថយ និងការបន្សាំ ប្រសិនបើបញ្ហាយេនឌ័រមិនត្រូវបានគិតគូរទេ។ ជាទូទៅ ស្ត្រីដើរតួយ៉ាងសំខាន់នៅក្នុងគ្រួសារ ក៏ប៉ុន្តែស្ត្រីមានលទ្ធភាពទទួលបាន និងអំណាចត្រួតត្រាតិចតួចលើធនធានសេវាកម្ម និងការសម្រេចចិត្តនានា។ នៅក្នុងទស្សនទានយេនឌ័រ ការបញ្ហាបបញ្ហាយេនឌ័រគួរតែត្រូវបានបញ្ចូលទៅក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ជាពិសេសការទទួលបានព័ត៌មាន និងការចូលរួមក្នុងការដោះស្រាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

ឥតគ្គពេញអង្គ៖ ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

CCCA គឺជាកម្មវិធីមួយដែលចាប់ផ្តើមនៅខែកុម្ភៈ ឆ្នាំ២០១០ ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងមហន្តរាយពីហានិភ័យនៅក្នុងកម្ពុជា។ គោលបំណងរបស់កម្មវិធីនេះគឺ ពង្រឹងសមត្ថភាពរបស់ NCCC និងធ្វើឲ្យក្រសួងពាក់ព័ន្ធ និងCSOs អនុវត្តនូវសកម្មភាពជាអាទិភាព ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។

CCCATF មានតួនាទីជាជំហ៊ាននាំមុខឆ្ពោះទៅការបង្កើតយន្តការផ្តល់មូលនិធិកាន់តែមានលក្ខណៈអចិន្ត្រៃយ៍សម្រាប់កម្ពុជា ការឯកភាពគ្នារវាង DPs និងសម្បទានហិរញ្ញវត្ថុពហុម្ចាស់ជំនួយដើម្បីផ្តល់ជាធនធានសម្រាប់សកម្មភាពការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ អនាគតនៃមូលនិធិនេះគួរតែបង្កើតឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗដូចជា ភាពជាម្ចាស់របស់ជាតិ ភាពជាតំណាងនៃអ្នកពាក់ព័ន្ធ ការកសាងទំនុកចិត្ត តម្លាភាពប្រកបដោយវិជ្ជាជីវៈ គណនេយ្យភាព តុល្យភាព ការប្រកួតប្រជែង ប្រសិទ្ធភាព និងប្រសិទ្ធផល។ គម្រោងចំនួនប្រាំបីត្រូវបានអនុម័តផ្តល់ជំនួយនៅក្នុងការប្រកាសទទួលសំណើគម្រោងលើកទី ១ ហើយការប្រកាសទទួលសំណើបន្ទាប់នឹងបើកនៅពេលឆាប់ៗខាងមុខនេះ។

ឥតគ្គពេញអង្គ៖ ក្របខណ្ឌគោលនយោបាយប្រែប្រួលអាកាសធាតុ ដំណើរឆ្ពោះទៅរកការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា

តាមរយៈការរៀនសូត្រពីបទបង្ហាញនានា និងការពិភាក្សាកន្លងមក ផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាពកម្ពុជាដ៏ល្អមួយ អាចត្រូវបានពង្រាងដោយការទាញយកនូវមេរៀន ដែលទទួលបានទម្រង់ និងរចនាសម្ព័ន្ធនៃផែនការយុទ្ធសាស្ត្រ និងសកម្មភាពនានាដែលមានស្រាប់នៅថ្នាក់តំបន់។

ការវិភាគគោលនយោបាយតាមវិស័យ ត្រូវបានបកស្រាយដោយផ្តោតជាសំខាន់លើវិស័យកសិកម្ម ធនធានទឹក សុខភាព ការកាត់បន្ថយគ្រោះហានិភ័យនៃគ្រោះមហន្តរាយ វិមជ្ឈការ និងសហវិមជ្ឈការ ព្រៃឈើ ជលផល ដី និងថាមពល។ ការទទួលស្គាល់គោលនយោបាយ និងការផ្តល់ជាអនុសាសន៍គោលនយោបាយស្តីពីការប្រែប្រួលអាកាសធាតុផ្តល់ជាធាតុចូលដ៏ល្អ ដើម្បីអភិវឌ្ឍ

ផែនទីបង្ហាញផ្លូវតាមវិស័យ និងឱកាសក្នុងការបន្សុីទៅក្នុងដំណើរការការកសាង CCCSP ។ ចំណែក ឯផែនទីបង្ហាញផ្លូវតាមវិស័យ នឹងត្រូវបានប្រើប្រាស់សម្រាប់កម្មវិធី ឬគម្រោងនានា ដើម្បីកសាងភាព ធន់តាមវិស័យទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

កម្ពុជា មិនមានគោលនយោបាយ ឬផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ ដែលមានលក្ខណៈទូលំទូលាយក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឡើយ ដោយសារកង្វះខាតនូវយន្តការមូលនិធិ ដែលមាននិរន្តរភាព (ដោយផ្អែកលើគម្រោង)។ បញ្ហាប្រឈមរបស់ប្រទេសកម្ពុជា គឺអវត្តមានគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ការបង្កើត CCCSP ដែលកំពុងត្រូវបានគិតពិចារណា គឺជាសមិទ្ធិផលដ៏សំខាន់មួយសម្រាប់ CCCA ។ CCCSP អាចដើរតួយ៉ាងសំខាន់ក្នុងការប្រែប្រួលអាកាសធាតុ ព្រោះវាជួយគាំទ្រដល់កម្ពុជា ជាពិសេស NCCC ក្នុងការត្រៀមលក្ខណៈចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ និងសកល ដែលផលប៉ះពាល់នេះជះឥទ្ធិពលដល់ការកាត់បន្ថយភាពក្រីក្រ។ CCCSP ក៏អាចជួយដល់កម្ពុជាក្នុងការត្រៀមចាប់យកឱកាសទទួលអត្ថប្រយោជន៍ ការគាំទ្រហិរញ្ញវត្ថុសកល សម្រាប់គំនិតផ្តួចផ្តើមឆ្លើយតបការប្រែប្រួលអាកាសធាតុ ដែលស្ថិតក្រោម UNFCCC ។ ការរួមបញ្ចូលវិស័យពាក់ព័ន្ធនានាដូចជាក្រសួង និងវិស័យឯកជននៅក្នុងការបង្កើត CCCSP គឺជាគន្លឹះឆ្ពោះទៅរកភាពជោគជ័យ តាមរយៈការបង្កើតភាពជាម្ចាស់នៃ CCCSP ។

ការបញ្ចូលវិស័យពាក់ព័ន្ធនានា រួមមានអន្តរក្រសួង និងវិស័យឯកជន វិស័យអាទិភាពរបស់ CCCSPនឹងត្រូវបានលើកមកពិភាក្សាក្នុងសិក្ខាសាលាប្រឹក្សាយោបល់យ៉ាងទូលំទូលាយនាពេលខាងមុខនេះ ដើម្បីរៀបចំកសាងនូវ CCCSP ។ ដោយសារផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមានលក្ខណៈមិនទៀងទាត់ ដូច្នេះភាពបត់បែននៃគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ គឺមានសារសំខាន់ណាស់។

ដំណើរឆ្ពោះទៅទីក្រុងឌូបាន ប្រទេសអាហ្វ្រិចខាងត្បូង ប្រទេសកម្ពុជាបានពង្រាងគោលជំហរចំនួនប្រាំដែលផ្តោតសំខាន់លើការបន្សុំ ការកាត់បន្ថយ និងមធ្យោបាយពាក់ព័ន្ធសម្រាប់ការអនុវត្តធនធានហិរញ្ញវត្ថុ ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព។ កម្ពុជាចង់ឃើញការសម្រេចនៅក្នុងកិច្ចពិភាក្សា និងជម្រុញឲ្យមានសកម្មភាព និងហិរញ្ញវត្ថុ REDD+ ឲ្យបានពេញលេញ។ វាត្រូវបានប៉ាន់ប្រមាណ និងផ្តល់ជាយោបល់ថា យ៉ាងហោចណាស់១,៥% នៃ GDP ប្រចាំឆ្នាំរបស់ប្រទេសអភិវឌ្ឍន៍ គួរតែបែងចែកសម្រាប់សកម្មភាពប្រែប្រួលអាកាសធាតុ និង៧០%នៃមូលនិធិនេះ ត្រូវបែងចែកសម្រាប់សកម្មភាពបន្សុំ។ សំខាន់ជាងនេះទៀតគឺ ហិរញ្ញវត្ថុបដិភាគគួរមិនក្លាយជារបាំង ឬលក្ខខណ្ឌសម្រាប់ការទទួលបានមូលនិធិនេះឡើយ។

ការតាំងពិព័រណ៍

នៅក្នុងការតាំងពិព័រណ៍ មានស្តង់ចំនួន១៦ មកពីក្រសួង DPs NGOs និងវិស័យឯកជន ដែលបានតាំងបង្ហាញពី ផលិតផលរបស់ពួកគេ រួមបញ្ចូលទាំងឧបករណ៍នានាក្នុងការលើកកម្ពស់ចំណេះដឹងប្រែប្រួលអាកាសធាតុ បច្ចេកវិទ្យាបញ្ចេញកាបូនទាប និងផលិតផលដែលមានប្រសិទ្ធភាពថាមពល។ ជាងនេះទៀត ក៏មានការតាំងបង្ហាញពីរូបភាពផ្សេងៗ ដែលទាក់ទងនឹងបរិបទប្រែប្រួលអាកាសធាតុផងដែរ។

កម្មវិធីបិទ

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន បានមានចំណាប់អារម្មណ៍ និងថ្លែងអំណរគុណចំពោះកិច្ចខិតខំប្រឹងប្រែងរួមគ្នាយ៉ាងសកម្មរបស់សមាជិក សមាជិកាទាំងអស់ ក៏ដូចជាការផ្តល់វិភាគទានថ្មីៗ ក្នុងការជួយកម្ពុជាឆ្លើយតបនឹងអាទិភាពបន្ទាន់នានាផ្នែកប្រែប្រួលអាកាសធាតុ ដូចជា ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេស ការសម្របសម្រួលការអនុវត្តគម្រោងជាក់ស្តែង ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការកៀរគរធនធាន ការអប់រំ និងលើកកម្ពស់ការយល់ដឹង និងការចរចាអន្តរជាតិ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ជាពិសេសការរៀបចំសេចក្តីព្រាងឯកសារជំហររបស់កម្ពុជាសម្រាប់ត្រៀមចូលចរចានៅក្នុង CoP១៧ នៃបណ្តាប្រទេសជាសមាជិកអនុសញ្ញាប្រែប្រួលអាកាសធាតុ នៅទីក្រុងឌូបាននៃប្រទេសអាហ្វ្រិចខាងត្បូងចុងឆ្នាំនេះ។ ឯកឧត្តមបានរំលឹកបន្ថែមទៀតថា កម្ពុជា គឺជាអ្នករងគ្រោះទៅនឹងបញ្ហាមួយ ដែលកម្ពុជាមិនមែនជាអ្នកបង្ក។ ប៉ុន្តែ កម្ពុជាចង់ក្លាយជាផ្នែកមួយនៃដំណោះស្រាយពិភពលោកចំពោះបញ្ហានេះ និងជឿជាក់ថាអាចប្រែក្លាយវិបត្តិអាកាសធាតុឲ្យទៅជាកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍមួយ ដែលមានចីរភាពជាងមុន។ ឯកឧត្តមក៏បានបញ្ជាក់ផងដែរថា កម្ពុជាត្រៀមខ្លួនជាស្រេចដើម្បីបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងជម្រុញភាពជាដៃគូដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងគួរឲ្យទុកចិត្ត។ ជាទីបញ្ចប់ ឯកឧត្តមបានថ្លែងអំណរគុណដល់អ្នកចូលរួមទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មនៅក្នុងវេទិកានេះ ជាពិសេសបណ្តាអ្នកឧបត្ថម្ភទាំងឡាយ ដែលបានផ្តល់ការគាំទ្រផ្នែកថវិកាដល់ការរៀបចំអង្គវេទិកានេះ។

សន្និសីទសារព័ត៌មាន

ការរៀបចំសន្និសីទសារព័ត៌មាន មានគោលបំណងចែករំលែកលទ្ធផលចម្បងៗ ដែលទទួលបានពី SNFCC ដោយមានការចូលរួមពីអ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាច្រើននាក់។ វាគ្មិនរួមមាន តំណាងមកពី RGC (MoE/NCCC) EU Sida និង UNDP ។ ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** បានសង្ខេបពីសមិទ្ធផលនានាដែលទទួលបានពី SNFCC ។ ឯកឧត្តមសង្ឃឹមយ៉ាងមុតមាំថា សន្និសីទសារព័ត៌មាននឹងផ្តល់នូវចម្លើយចំពោះសំណួរពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនានាបន្ថែមទៀតដល់សារធារណជនទាំងអស់។ សំណួរពិភាក្សានៅក្នុងសន្និសីទនេះ រួមមានជាសំខាន់លើ [១] បញ្ហានានាដែលនឹងត្រូវលើកមកពិភាក្សានៅក្នុងកិច្ចប្រជុំ CoP ខាងមុខ [២] ការបញ្ជ្រាបការយល់ដឹងពីការប្រែប្រួលអាកាសធាតុដល់ប្រជាជនមូលដ្ឋាន [៣] ផលប្រយោជន៍ដែលកម្ពុជាទទួលបានពីវិធានការកាត់បន្ថយ [៤] ការដាំឈើឡើងវិញឆ្ពោះទៅរកឥណទានកាបូន ដើម្បីគាំទ្រការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និង [៥] មូលនិធិ CCCA ។

របាយការណ៍

ថ្ងៃទី១៖ ថ្ងៃទី០៣ ខែតុលា ឆ្នាំ២០១១

កម្មវិធីបើក

សុន្ទរកថាបើក

*ដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី***

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក្នុងឱកាសបើកវេទិកាជាតិលើកទី២ នៅវិមានសន្តិភាព (CCCA, ២០១១)

ជាមួយនឹងភស្តុតាងខាងវិទ្យាសាស្ត្រនិងលទ្ធផលការស្រាវជ្រាវថ្មីៗ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ជាក់ថា ការប្រែប្រួលអាកាសធាតុកើតមានយ៉ាងពិតប្រាកដ ហើយបង្កឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើសង្គម សេដ្ឋកិច្ច និងបរិស្ថានដែលជាខឿនទ្រទ្រង់អត្ថិភាព ការរីកចម្រើន និងចីរភាពសង្គមជាតិ។ ឯកឧត្តមបានទទួលស្គាល់ការបន្តបញ្ចេញចោល GHGsយ៉ាងសន្ធឹកសន្ធាប់ពិសេសឧស្ម័នកាបូនិចពីសកម្មភាពមនុស្សក្នុងវិស័យផលិតថាមពល ការដឹកជញ្ជូន កសិកម្ម ការកាប់ព្រៃឈើ និងការចោលសំណល់ជាដើមជាពិសេស នៅបណ្តាប្រទេសឧស្សាហកម្មធំៗបានបង្កការព្រួយ បារម្ភបន្ថែមទៀត អំពីការប្រែប្រួលអាកាសធាតុនិងផលវិបាកធ្ងន់ធ្ងរយៈពេលវែងសម្រាប់មនុស្សជាតិ។ ការកើនឡើងកម្តៅផែនដី ការប្រែប្រួលរបបទឹកភ្លៀង ការកើនឡើងកម្ពស់ទឹកសមុទ្រ និងការកើតឡើងកាន់តែញឹកញាប់នូវព្រឹត្តិការណ៍អាកាសធាតុមិនប្រក្រតីបានបង្កនូវការបាត់បង់ជីវិត ការខូចខាតផ្នែកសេដ្ឋកិច្ច និងបរិស្ថានកាន់តែច្រើនឡើងៗ ដល់ប្រទេសនានាទូទាំងពិភពលោក។ ឯកឧត្តមបានសង្កត់ធ្ងន់ថា ប្រទេសក្រីក្រដែលមានការអភិវឌ្ឍតិចតួច ដូចជាប្រទេសកម្ពុជាជាដើម ងាយរងគ្រោះបំផុត ពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុពីព្រោះ បណ្តាប្រទេសទាំងនោះមានសេដ្ឋកិច្ចពឹងផ្អែកខ្លាំងលើ វិស័យកសិកម្ម ភាពក្រីក្រ ហេដ្ឋារចនា សម្ព័ន្ធរូបវន្តទន់ខ្សោយ ធនធានមនុស្ស និងហិរញ្ញវត្ថុមានកម្រិត និងកង្វះលទ្ធភាពទទួលបានបច្ចេកវិទ្យាសមស្រប សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។

ឯកឧត្តម **យឹម ឆៃលី** បានបញ្ជាក់ថា RGC ទទួលស្គាល់យ៉ាងច្បាស់ពីបញ្ហាប្រែប្រួលអាកាសធាតុក្នុងដំណើរការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិ ក៏ដូចជាពីកាតព្វកិច្ចផ្នែកសីលធម៌របស់ខ្លួនក្នុងនាមជាប្រទេសមួយ ដែលទទួលរងផលប៉ះពាល់ការពីប្រែប្រួលអាកាសធាតុ ដើម្បីរួមចំណែកជាមួយនឹងសហគមន៍អន្តរជាតិសំដៅដោះស្រាយបញ្ហាជាអាយុជីវិតមនុស្សជាតិ ក្នុងពិភពលោក។ ជាក់ស្តែង កម្ពុជាបានផ្តល់សច្ចាប័នដល់ UNFCCC តាំងពីឆ្នាំ១៩៩៥ ហើយបានចូលជាសមាជិកពិធីសារក្យូតូឆ្នាំ២០០២ និងបានចាប់ផ្តើមបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ២ ដោយផ្តោតជាពិសេសលើការជម្រុញការអនុវត្តបណ្តាគម្រោងបន្ទាំនានាក្នុង NAPA។ ជាងនេះ

ទៅទៀត ការប្រែប្រួលអាកាសធាតុបានក្លាយជាអាទិភាពមួយក្នុង NSDP បច្ចុប្បន្នកម្ម ២០០៩-២០១៣ដោយត្រូវបានបញ្ចូលយ៉ាងទូលំទូលាយក្នុងវិស័យពាក់ព័ន្ធនានា។

ឯកឧត្តមបានមានប្រសាសន៍ថាពិតមែនតែយើងបានសម្រេចនូវជោគជ័យជាទីមោទន:ក្តី យើងស្ថិតនៅលើកំណាត់ផ្លូវដ៏វែងឆ្ងាយមួយក្នុងការសម្រេចកសាងសង្គមមួយ ដែលបៃតងជាងមុនធន់នឹងការប្រែប្រួលអាកាសធាតុ និងធានាបានការអភិវឌ្ឍដោយសមធម៌និងចីរភាព ក្រោមលក្ខខណ្ឌការប្រែប្រួលអាកាសធាតុ។ ក្នុងនោះ ឯកឧត្តម ក៏បានគូសបញ្ជាក់នូវអនុសាសន៍ ៦ សំខាន។ ជាមូលដ្ឋានក្នុងការពិចារណាពិគ្រោះយោបល់ និងការធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុទាំងថ្នាក់ជាតិ និងអន្តរជាតិដូចជា [១] ការរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ [២] ការពង្រឹងសមត្ថភាពស្ថាប័ននិងសមត្ថភាពបច្ចេកទេសនិងការសម្របសម្រួល [៣] ការអនុវត្តគម្រោងឆ្លើយតបការប្រែប្រួលអាកាសធាតុ [៤] ការកៀរគរធនធាន [៥] ការអប់រំ និងការលើកកម្ពស់ការយល់ដឹង និង [៦] ការចរចាថ្នាក់អន្តរជាតិដើម្បីដោះស្រាយនូវបញ្ហាការប្រែប្រួលអាកាសធាតុ ។ គោលការណ៍នៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុជាមូលដ្ឋានយ៉ាងសំខាន់ ដល់រាជរដ្ឋាភិបាលកម្ពុជាប្រើប្រាស់ក្នុងការកំណត់ជំហររបស់ជាតិនៅក្នុងដំណើរការចរចាជាអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាពិភពលោកដ៏ប្រឈមនេះតាមរយៈការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញ GHGs ការផ្ទេរបច្ចេកវិទ្យានិងហិរញ្ញប្បទាន។

ឯកឧត្តម **យឹម ឆៃលី** ក៏បានលើកឡើងដែរថា កម្ពុជាមានអាទិភាពចំពោះមុខជាច្រើនដូចជាការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រការងារ ក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការតាមវិស័យពាក់ព័ន្ធ ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាពបច្ចេកទេស ការរៀបចំមូលនិធិប្រែប្រួលអាកាសធាតុ ការកៀរគរធនធាន សម្រាប់អនុវត្តគម្រោងបន្សាំនិងគម្រោងកាត់បន្ថយការបញ្ចេញ GHGs កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលការងារការអប់រំ និងការលើកកម្ពស់ការយល់ដឹង ការងារសិក្សាស្រាវជ្រាវ ការពង្រឹងនូវតួនាទីផ្នែកឯកជន ការត្រៀមចូលរួមចរចាថ្នាក់អន្តរជាតិ។ល។

មុនបញ្ចប់ ឯកឧត្តម **យឹម ឆៃលី** បានសង្កត់ធ្ងន់ថា RGC មានការប្តេជ្ញាចិត្ត និងឆន្ទៈនយោបាយខ្ពស់ក្នុងការខិតខំប្រឹងប្រែងរួមគ្នាជាមួយភាគីពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ដើម្បីឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដែលអាចធ្វើឲ្យអន្តរាយដល់វឌ្ឍនភាព និងឆ្ពោះទៅរកការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ជាតិដែលទាមទារវិធានការចាប់ពីពេលឥឡូវនេះដើម្បីធានាអនាគតមួយដែលធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។

សុន្ទរកថាស្វាគមន៍

*ដោយឯកឧត្តម **បណ្ឌិត ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានNCCC*

ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** បានសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តម **យឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងអ្នកចូលរួមទាំងឡាយ។ ឯកឧត្តមបណ្ឌិត បានមានប្រសាសន៍ថា បច្ចុប្បន្នមានការទទួលស្គាល់ជាទូទៅថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាពិភពលោកដ៏គម្រាមកំហែងមួយ ដែលនាំឲ្យមានផលប៉ះពាល់អវិជ្ជមានយ៉ាងខ្លាំងដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកម្ពុជា ក៏ដូចជាបណ្តា

ប្រទេសទាំងអស់ទូទាំងពិភពលោក។ នាបណ្តាឆ្នាំចុងក្រោយនេះ ប្រទេសនានាទូទាំងពិភពលោក ក៏ដូចជាកម្ពុជាបានជួបប្រទះបាតុភូតធម្មជាតិមិនប្រក្រតីកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុនដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះសង្ឃរាជាដើម ដែលបង្កផលប៉ះពាល់យ៉ាងខ្លាំងដល់ការផ្គត់ផ្គង់ទឹក ការធ្វើកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ សន្តិសុខស្បៀង អាយុ ជីវិត សុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋជាពិសេសនៅជនបទ។

ឯកឧត្តមទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថានក្នុងឱកាសបើកវេទិកាជាតិលើកទី២ នៅវិមានសន្តិភាព (CCCA, ២០១១)

ឯកឧត្តមបណ្ឌិត បានគូសបញ្ជាក់ដែរថា RGC ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់សម្តេចនាយករដ្ឋមន្ត្រី តាមរយៈ NCCC និងMoE បានយល់ច្បាស់អំពីបញ្ហាអន្តរវិស័យដ៏គម្រាមកំហែងនេះ។ជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងខ្ពង់ខ្ពស់ ព្រះរាជាណាចក្រកម្ពុជាបានចូលជាសមាជិក UNFCCC ចាប់តាំងពីឆ្នាំ១៩៩៥ និងចូលជាសមាជិកពិធីសារក្យូតូនៅឆ្នាំ២០០២ និងបានរៀបចំរបាយការណ៍ជាតិលើកទី ១ ស្តីពីការប្រែប្រួលអាកាសធាតុក្រោម UNFCCC ដាក់ជូនកិច្ចប្រជុំកំពូលរបស់ប្រទេសជាសមាជិកអនុសញ្ញាឆ្នាំ២០០២។ នាឆ្នាំ២០០៦ រាជរដ្ឋាភិបាលបានអនុម័តដាក់ឲ្យប្រើប្រាស់កម្មវិធី NAPA និងបញ្ជ្រាបវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុយ៉ាងទូលំទូលាយនៅក្នុងយុទ្ធសាស្ត្រចតុកោណ និង NSDP បច្ចុប្បន្នកម្ម ២០០៩-២០១៣។

ដើម្បីរួមគ្នាអនុវត្តនូវការងារឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ បន្ទាប់ពីទទួលបាននូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចនាយករដ្ឋមន្ត្រី ក្នុងឱកាសនៃវេទិកាជាតិលើកទី ១ ស្តីពីការប្រែប្រួលអាកាសធាតុ នាខែតុលាឆ្នាំ២០០៩ MoE ក្នុងនាមប្រធាន NCCC សហការយ៉ាងជិតស្និទ្ធជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ DPs NGOs និងវិស័យឯកជនមួយចំនួន បានខំប្រឹងប្រែងរហូតសម្រេចបាននូវសមិទ្ធផលសំខាន់ៗចំនួន ១៥។

ឯកឧត្តមក៏បញ្ជាក់ដែរថា ការប្រែប្រួលអាកាសធាតុ នឹងបន្តជាបញ្ហាប្រឈមដ៏គម្រាមកំហែងមួយដល់ ការអភិវឌ្ឍសេដ្ឋកិច្ច សង្គម ដែលអាចជះឥទ្ធិពលអវិជ្ជមានទៅដល់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍប្រទេសជាតិ ប្រសិនបើពុំមានការយកចិត្តទុកដាក់ក្នុងការឆ្លើយតបនឹងផលប៉ះពាល់របស់វា ឲ្យបានទាន់ពេលវេលា និងសមស្របទេនោះ។

ដើម្បីជាគតិ និងជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាសម្រាប់ការរៀបចំគោលជំហរជាតិក្នុងការចរចាដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការពិភាក្សាសំដៅរួមចំណែកកសាងប្រទេសជាតិឲ្យកាន់តែសំបូររុងរឿងប្រកបដោយសុខសន្តិភាព ស្រស់បៃតងជាងមុននិងធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ ឯកឧត្តមបណ្ឌិត **ម៉ុក មាម៉ែត** បានសូមអនុញ្ញាតគោរពអញ្ជើញ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** អញ្ជើញផ្តល់ជាមតិណែនាំ និងអនុសាសន៍ដល់អង្គវេទិកា។

តំណាងមកពីស្ថាប័នពាក់ព័ន្ធនានា ប្រមាណ៧០០នាក់ចូលរួមពិធីបើកវេទិកាជាតិលើកទី២ នៅវិមានសន្តិភាព (CCCA, ២០១១)

ឥតគិតដំណើរការ

សុទ្ធរកថាស្វាគមន៍

*ដោយលោក**Douglas Broderick***
អ្នកសម្របសម្រួលអ.ស.ប ប្រចាំនៅកម្ពុជា

បន្ទាប់ពីការស្វាគមន៍អ្នកចូលរួមលោក Broderick បានបរិយាយថា ការប្រែប្រួលអាកាសធាតុបង្កឲ្យមានផលប៉ះពាល់លើវិស័យទាំងអស់នៅក្នុងសង្គមមនុស្ស។ នេះគឺជាបាតុភូតសកលមួយ។ ផលប៉ះពាល់របស់វាបានបង្ហាញឲ្យឃើញជាក់ស្តែងដូចជា ភ្លៀងធ្លាក់កាន់តែច្រើនបង្កជាទឹកជំនន់ក្នុងតំបន់ ភាពរាំងស្ងួតកើនឡើងធ្ងន់ធ្ងរ ដំណាំក្លាយជាស្ងិតស្រពោន ប្រព័ន្ធអេកូឡូស៊ីកំពុងប្រែប្រួល កំណើនកម្ពស់ទឹកសមុទ្រ សីតុណ្ហភាពនៃបឹងធំៗកំពុងកើនឡើង។ សីតុណ្ហភាពក្តៅជាងមុនមានឥទ្ធិពលមកលើសុខភាពមនុស្ស។

នៅក្នុងកម្ពុជា លោកបានកត់សម្គាល់ថា ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ធ្វើឲ្យក្រុមមនុស្សងាយរងគ្រោះ ពិសេសគ្រួសារដែលមានស្ត្រីជាមេគ្រួសារ កុមារ និងជនជាតិដើមងាយប្រឈមនឹងហានិភ័យ។ ព្រឹត្តិការណ៍អាកាសធាតុកំណាចដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត ត្រូវបានទទួលស្គាល់ថាជាកត្តាចម្បងមួយដែលរួមចំណែកធ្វើឲ្យមានភាពក្រីក្រនៅកម្ពុជា។ ដូច្នេះ ការស្វែងយល់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ មានសារសំខាន់ណាស់ដើម្បីអាចប្រយុទ្ធប្រឆាំងប្រកបដោយជោគជ័យទន្ទឹមនឹងការជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ការប្រែប្រួលអាកាសធាតុ គឺជាការប្រឈមសំខាន់បំផុតមួយក្នុងការអភិវឌ្ឍ ដែលពុំមែនដោយសារការទទួលរងឥទ្ធិពលខ្លាំងឡើយ ប៉ុន្តែដោយសារសមត្ថភាពទាបក្នុងការបន្សាំ និងការទប់ទល់។

លោក Broderick ក៏បានបន្ថែមទៀតថា អភិក្រមដ៏ល្អបំផុត ក្នុងការកសាងការចិញ្ចឹមជីវិតដែលធន់ទ្រាំក្នុងបរិបទការប្រែប្រួលអាកាសធាតុ គឺជាការបន្សាំ ដែលផ្តល់អត្ថប្រយោជន៍តាមរយៈការដោះស្រាយអាទិភាពនានា សម្រាប់អភិវឌ្ឍន៍នាពេលបច្ចុប្បន្ន។ ការធ្វើបែបនេះនឹងអាចពង្រឹងភាពធន់ទ្រាំនៃប្រជាពលរដ្ឋងាយរងគ្រោះ និងកែលម្អសមត្ថភាពឆ្លើយតបនឹងផលប៉ះពាល់ដែលអាចកើតចេញពីការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែ ការធ្វើបែបនេះទាមទារឲ្យមា ការពិនិត្យមើលគោលបំណងអភិវឌ្ឍន៍រយៈពេលវែងតាមរយៈទស្សនវិស័យថ្មីមួយ និងការគាំទ្រ ការជជែកវែកញែកជាសាធារណៈ ប្រកបដោយការពិចារណា និងការយល់ដឹងជាមុន និងការធ្វើសេចក្តីសម្រេច ដែលអាចដោះស្រាយភាពមិនប្រាកដប្រជានិងហានិភ័យនានាដែលបង្កដោយសារការប្រែប្រួលអាកាសធាតុ។

លោក Broderick បានបញ្ជាក់ថាការប្រែប្រួលអាកាសធាតុ ជាប្រភពមួយនៃភាពងាយរងគ្រោះ និងការគម្រាមកំហែងដល់ការរីកចម្រើន និងការអភិវឌ្ឍរបស់កម្ពុជា។ ប្រការសំខាន់គឺត្រូវយកចិត្តទុកដាក់ ជាពិសេស ទៅលើភាពក្រីក្រ និងភាពងាយរងគ្រោះនៅជនបទ។ ដោយមានប្រជាពលរដ្ឋភាគច្រើនបំផុតជាអ្នកក្រីក្ររស់នៅតាមជនបទ និងពឹងផ្អែកលើ វិស័យកសិកម្ម ដូច្នេះការស្វែងយល់ និងឆ្លើយតបចំឬសគល់នៃ

ភាពក្រីក្រ និងភាពងាយរងគ្រោះមានសារសំខាន់ណាស់ដើម្បីយល់ដឹងអំពីការពាក់ព័ន្ធគ្នារវាងការអភិវឌ្ឍមនុស្ស បណ្តាលពីការប្រែប្រួលអាកាសធាតុ និងការបង្កើតមធ្យោបាយដើម្បីកាត់បន្ថយឥទ្ធិពលទាំងនោះ។

បន្ថែមលើនេះទៀត ប្រការសំខាន់គឺ ការដោះស្រាយរចនាសម្ព័ន្ធ ភាពក្រីក្រ និងភាពងាយរងគ្រោះ ជាងការផ្តោតតែលើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ លោក Broderick បានលើកឡើងអនុសាសន៍ចំនួនបី ដើម្បីពង្រឹងភាព អង់អាចដល់ការរស់នៅរបស់ប្រជាជនក្រីក្រ និង ជិតធ្លាក់ក្នុងភាពក្រីក្រដើម្បីអាចទប់ទល់នឹងផលប៉ះពាល់ពី ការប្រែប្រួលអាកាសធាតុ ដូចជា [១] ការបង្កើនការយល់ដឹង ចំណេះដឹង ព័ត៌មាន និងសមត្ថភាពកសាងផែនការ និងធ្វើសេចក្តីសម្រេច [២] ការធានាថាពលរដ្ឋក្រីក្រអាចមានលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបានការគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេស និង [៣] ការពង្រឹងសិទ្ធិរបស់អ្នករស់នៅជនបទទាក់ទងទៅនឹងការទទួលព័ត៌មានដែលអាចទុកចិត្តបាន សិទ្ធិក្នុងការត្រួតត្រា និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព និងសិទ្ធិដើម្បីចូលរួមប្រកបដោយអត្ថន័យក្នុងការកសាងផែនការ និងការធ្វើសេចក្តីសម្រេច។

លោក Broderick បញ្ជាក់ថា អ.ស.ប បានចាត់ទុកការប្រែប្រួលអាកាសធាតុ គឺជាអាទិភាពខ្ពស់មួយ ក្នុងរបៀបវារៈអភិវឌ្ឍន៍របស់ខ្លួន និងបន្តផ្តល់ការគាំទ្រដល់រាជរដ្ឋាភិបាល ដើម្បីកែលម្អការសម្របសម្រួល ពង្រឹងការយល់ដឹង និងការស្វែងយល់អំពីការប្រែប្រួលអាកាសធាតុ ការកៀរគរ ការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ ជាទុនដោះស្រាយភាពខ្វះចន្លោះទាំងនេះ។ អ.ស.ប ក៏នឹងបន្តការសម្របសម្រួលជាមួយ DPs នានា និងស្ថាប័នរាជរដ្ឋាភិបាល ដើម្បីសម្រួលឲ្យមានការសន្ទនាអំពីគោលនយោបាយនៃការប្រែប្រួលអាកាសធាតុ ក្នុងវិស័យខុសៗគ្នា និងផ្នែកខុសៗគ្នាផងដែរ។

លោក **Broderick** ក៏បានរំលឹកដែរថា ឥឡូវនេះ កម្ពុជា ត្រូវតែត្រៀមខ្លួនតាមរយៈការកសាងគោលនយោបាយស្ថាប័ន ចំណេះដឹង និងព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ និងត្រូវតែបង្កើតជាយន្តការហិរញ្ញប្បទានរឹងមាំ និងប្រកបដោយប្រសិទ្ធភាព ដើម្បីស្រូបយក និងគ្រប់គ្រងការចំណាយលើការប្រែប្រួលអាកាសធាតុ។ ការសំខាន់ដែរ គឺត្រូវពង្រឹងភាពអង់អាចរបស់ប្រជាពលរដ្ឋងាយរងគ្រោះ ពិសេសជនក្រីក្រ និងជិតក្រីក្រ កុមារ យុវជន ជនជាតិដើម និងស្ត្រីឲ្យមានចំណេះដឹងប្រសើរជាងមុន និងសមត្ថភាពដើម្បីលើកផែនការនិងធ្វើការសម្រេចដែលទាក់ទងនឹងការចិញ្ចឹមជីវិតរបស់ពួកគេនៅចំពោះមុខការប្រែប្រួលអាកាសធាតុ។

សុន្ទរកថាស្វាគមន៍

*ដោយ**ឯកឧត្តម បណ្ឌិត ម៉ុក មីរ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានNCCC*

ឯកឧត្តមបណ្ឌិត **ម៉ុក មីរ៉ែត** បានមានប្រសាសន៍ចាប់ផ្តើមជាមួយនឹងការទទួលស្គាល់ជាទូទៅថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមដ៏គម្រាមកំហែងមួយ ដែលពិភពលោកកំពុងនឹងជួបប្រទះ។ ក្នុងរបាយការណ៍លើកទី៥ របស់ក្រុមការងារអន្តរដ្ឋាភិបាលស្តីពី ការប្រែប្រួលអាកាសធាតុ (IPCC) នៃ អ.ស.ប និងលទ្ធផលស្រាវជ្រាវវិទ្យាសាស្ត្រ នាពេលចុងក្រោយនេះ បានអះអាងជាថ្មីប្រកបដោយកម្រិតជាក់លាក់ខ្ពស់ជាងមុនថា សកម្មភាពមនុស្សជាមូលហេតុចម្បងនៃការប្រែប្រួលអាកាសធាតុ។ បណ្តាប្រទេសក្នុងតំបន់ទន្លេមេគង្គ គឺងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ពីព្រោះការប្រែប្រួលរបបទឹកទន្លេ ការថយចុះទិន្នផលកសិកម្ម និងជលផល ការជ្រាបចូលនៃទឹកសមុទ្រ

កំណើនដង់ស៊ីតេប្រជាជន កង្វះខាតធនធានហិរញ្ញវត្ថុនិងបច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តពុំទាន់សមស្រប។ ឯកឧត្តមបានបញ្ជាក់ថា ប្រទេសកម្ពុជា បានជួបប្រទះនូវកំណើនទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះ ជាញឹកញាប់នាប៉ុន្មានឆ្នាំចុងក្រោយ ហើយបានជះឥទ្ធិពលយ៉ាងខ្លាំងដល់សុវត្ថិភាពស្បៀង ការរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ចសង្គម។

ឯកឧត្តមទេសរដ្ឋមន្ត្រី បានកត់សម្គាល់លទ្ធផលសិក្សាបែបវិទ្យាសាស្ត្រថ្មីៗនៃ របាយការណ៍ជាតិលើកទី២ ក្រោម UNFCCC ក្នុងនៅអំឡុងកន្លះទសវត្សចុងក្រោយនេះ សីតុណ្ហភាព និងរបបទឹកភ្លៀង នៅកម្ពុជាបានចាប់ផ្តើមប្រែប្រួលរួចមកហើយ។ ដោយឡែកការព្យាករណ៍សម្រាប់រយៈពេល៨០ឆ្នាំខាងមុខបានបង្ហាញថា សីតុណ្ហភាពនៅកម្ពុជា អាចនឹងបន្តកើនឡើងបន្ថែមទៀត ចំណែកឯកម្ពស់ទឹកភ្លៀងនៅរដូវប្រាំងក៏កាន់តែថយចុះ រដូវវស្សាអាចក្រមកដល់តែកម្ពស់ទឹកភ្លៀងអាចកើនឡើង។ ឯកឧត្តមបានបញ្ជាក់ថា កម្រិតប្រែប្រួលអាស្រ័យទៅតាមសេណារីយ៉ូនៃការបញ្ចេញ GHGs ។ វិស័យជាច្រើននៃសេដ្ឋកិច្ច សង្គមរបស់ជាតិនឹងត្រូវរងផលប៉ះពាល់ និងកិច្ចខំប្រឹងប្រែងកាត់បន្ថយការបញ្ចេញ GHGs របស់សហគមន៍អន្តរជាតិនឹងមានជាលទ្ធផលដោយផ្ទាល់ដល់កម្ពុជា។ កម្ពុជាត្រូវត្រៀមខ្លួនរស់នៅ ក្រោមសេណារីយ៉ូនៃការប្រែប្រួលអាកាសធាតុដែលតម្រូវនូវគោលនយោបាយថ្មី ផ្លាស់ប្តូររបៀបធ្វើផែនការ និងទម្លាប់អនុវត្តក្នុងគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច-សង្គម ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព។

ឯកឧត្តមបណ្ឌិត ម៉ុក មាអ៊ើត ផ្តល់សុន្ទរកថាស្វាគមន៍នៅសណ្ឋាគារអ៊ិនធឺកង់ទីណង់តាល់ (CCCA, ២០១១)

ឯកឧត្តមបានដៅបញ្ជាក់ថា RGC បានចាត់ទុកថា ការប្រែប្រួលអាកាសធាតុ ជាអាទិភាពជាតិសំខាន់ ហើយជាបណ្តើរៗបានបញ្ចូលបញ្ហានេះក្នុងគោលនយោបាយជាតិ និងផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងបញ្ចូលការងារប្រែប្រួលអាកាសធាតុនៅក្នុង NSDP បច្ចុប្បន្នកម្ម ២០០៩-២០១៣ សំដៅជម្រុញគ្រប់ស្ថាប័នពាក់ព័ន្ធ ឲ្យចូលរួមអនុវត្តនូវវិធានការឲ្យកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាពខ្ពស់ដើម្បីគាំទ្រការសម្រេចបាន គោលដៅអភិវឌ្ឍន៍សហសវត្សរ៍នានា ក្នុងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។ ឯកឧត្តមបានមានប្រសាសន៍ថា ការងារជាច្រើនដូចជាការកសាងសមត្ថភាពស្ថាប័ន និងបច្ចេកទេស ការងារស្រាវជ្រាវ ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ ការអប់រំផ្សព្វផ្សាយ ការអនុវត្ត UNFCCC ការអនុវត្តពិធីសារក្យូតូតាមរយៈ CDM ការអនុវត្តកម្មវិធីអភិវឌ្ឍបៃតងជាតិ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការងារសម្របសម្រួលរវាងបណ្តាក្រសួង-ស្ថាប័ន និង DPS ។ល។

ឯកឧត្តមបណ្ឌិត **ម៉ុក មាអ៊ើត** បានរំលឹកថា កម្ពុជាខ្វះចន្លោះក្នុងការយល់ដឹងជាសាធារណៈចំណេះដឹងបច្ចេកទេស ផលប៉ះពាល់ និងកាលានុវត្តភាពការប្រែប្រួលអាកាសធាតុ ក៏ដូចជាការសម្របសម្រួលការអនុវត្តវិធានការ។

វេទិកាជាតិ នេះក៏ដូចជាវេទិកា ដែលមានលក្ខណៈ ប្រហែលគ្នានេះនៅថ្ងៃខាងមុខទៀត មានសារសំខាន់ណាស់ ដើម្បីពិនិត្យវាយតម្លៃលើលទ្ធផលការងារ ដែលសម្រេចបាន ចែករំលែកព័ត៌មាន និងបទពិសោធន៍ល្អៗ បង្កើតឲ្យមានការសន្ទនា ប្រកបដោយន័យស្ថាបនា លើបញ្ហារៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ជម្រុញការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ និងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមស្ថាប័នរាជរដ្ឋាភិបាល DPs NGOs និង CSOs។

ឯកឧត្តមបានកត់សម្គាល់នូវវត្តមានអ្នកជំនាញការជាតិ អន្តរជាតិ ដែលធ្វើជាវាគ្មិន និងចូលរួមក្នុងការពិភាក្សាលើប្រធានបទយ៉ាងទូលំ-ទូលាយ និងការចូលរួមរបស់ក្រុមហ៊ុនឯកជន និង NGOs មួយចំនួនក្នុងការតាំងពិព័រណ៌ផលិតផលដែលមិនប៉ះពាល់អាកាសធាតុ។ ឯកឧត្តមបានសង្ឃឹមថា វត្តមានរបស់អ្នកចូលរួមទាំងឡាយ គឺជាសញ្ញាវិជ្ជមានប្រកបដោយការលើកទឹកចិត្ត ជាសក្ខីភាពបញ្ជាក់ពីការចាប់អារម្មណ៍ និងកង្វល់លើបញ្ហាប្រែប្រួលអាកាសធាតុ និងការបញ្ជាក់ពីឆន្ទៈ និងជំហររួមក្នុងការរួមចំណែកដោះស្រាយបញ្ហាប្រឈមនេះ ដើម្បីកសាងកម្ពុជាឲ្យមានលក្ខណៈបៃតងជាងមុន ធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងធានាការអភិវឌ្ឍដោយសមធម៌ និងចីរភាព នៅក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។ ជាទីបញ្ចប់ ឯកឧត្តម បានជូនពរដល់អ្នកចូលរួមទាំងឡាយនូវពុទ្ធពរទាំងបួនប្រការ និងសូមឲ្យវេទិកានេះទទួលបានលទ្ធផលដ៏មានផ្លែផ្កា៕

ភគ្គចាប់ផ្តើម

សហប្រធាន៖

១. ឯកឧត្តម **ចាយ សាមិត្ត** ប្រតិភូRGC ទទួលបន្ទុកជាអគ្គនាយកអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ (GDANCP)នៃ MoE

២. ឯកឧត្តម **ប៉ុន ណារិទ្ធិ** អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ(NCDM) និងជាសមាជិក NCCC

សហប្រធាន និងវាគ្មិនក្នុងវគ្គចាប់ផ្តើម (CCCA, ២០១១)

ឯកឧត្តម **ចាយ សាមិត្ត** បានមានប្រសាសន៍ផ្តើមថា យើងបានទទួលស្គាល់ថាការប្រែប្រួលអាកាសធាតុ ពិតជាមានការគម្រាមកំហែងធ្ងន់ធ្ងរទៅលើការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកម្ពុជា ក៏ដូចជាពិភពលោកទាំងមូល។ កម្ពុជាជាប្រទេសមួយ ដែលងាយរងគ្រោះបំផុតនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដោយសារសមត្ថភាពបន្សាំមានកម្រិត។ ដូច្នេះការយល់ដឹងពីមូលហេតុ ផលប៉ះពាល់ និងកាលានុវត្តភាពនៃការប្រែប្រួលអាកាសធាតុ មានសារសំខាន់ណាស់ក្នុងការរៀបចំផែនការបន្សាំដែលមានប្រសិទ្ធភាព។ ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ បានក្លាយជាបញ្ហាអាទិភាពមួយរបស់ RGC ហើយមានសមិទ្ធិផលជាច្រើនបាននឹងកំពុងសម្រេច ក្នុងអំឡុងប្រមាណទសវត្សរ៍នេះ។

ឯកឧត្តមបានបញ្ជាក់ថា NCCC នៅកម្ពុជាត្រូវបានបង្កើតឡើង ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ជាប្រធានកិត្តិយស និង CCD ជាលេខាធិការដ្ឋាន។ លោកក៏បានគូសបញ្ជាក់ថាកម្ពុជា ជាប្រទេសទី១ ដែលបានបញ្ចប់នូវរបាយការណ៍ NAPA និង SNC ស្តីពីសារពើភណ្ឌ GHGs ដែលរបាយការណ៍នេះនឹងត្រូវបានបញ្ចប់រួចរាល់ នាពេលខាងមុខនេះ។

បច្ចុប្បន្នភាពនៃព័ត៌មានវិទ្យាសាស្ត្រ ផលប៉ះពាល់ និងភាពងាយរងគ្រោះនៃការប្រែប្រួលអាកាសធាតុ

ដោយលោកMozaharul Alam

អ្នកសម្របសម្រួលការប្រែប្រួលអាកាសធាតុប្រចាំតំបន់អាស៊ី នងប៉ាស៊ីហ្វិកនៃ UNEP

បទបង្ហាញនេះ បានផ្តល់នូវព័ត៌មានថ្មីៗបំផុតអំពីវិទ្យាសាស្ត្រ ផលប៉ះពាល់ និងកាលានុវត្តភាពការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើរបាយការណ៍វាយតម្លៃលើកទី៤ របស់ IPCC និងលទ្ធផលការស្រាវជ្រាវទុកចិត្តបានផ្សេងទៀត។

លោក **Alam** បានសង្ខេបពីសញ្ញាណនៃកំណើនកម្តៅពិភពលោកមួយចំនួនដូចជា បម្រែបម្រួលសីតុណ្ហភាព បម្រែបម្រួលរបបទឹកភ្លៀង កំណើនកម្ពស់ទឹកសមុទ្រ និងព្រឹត្តិការណ៍ធ្ងន់ធ្ងរជាច្រើនទៀតតាំងពីថ្នាក់សកលដល់ថ្នាក់តំបន់។ សីតុណ្ហភាពមធ្យមនៅថ្នាក់តំបន់បានកើនឡើង ០,៧៦°C ក្នុងអំឡុងចាប់ពីឆ្នាំ ១៩០៦-២០០៥ ចំណែកឯសីតុណ្ហភាពជាមធ្យមនៅតំបន់អាស៊ីអាគ្នេយ៍ (SEA) បានកើនឡើងពី ០,១-០,៣°C ក្នុងមួយទសវត្សរ៍អំឡុងពេល៥០ឆ្នាំចុងក្រោយនេះ។ តាមការសង្កេតឃើញថា កំណើនសីតុណ្ហភាពមានភាពខុសគ្នា រវាងប្រទេសនីមួយៗ ដែលការប្រែប្រួលខ្ពស់បំផុត គឺនៅក្នុងប្រទេសសឹង្ហបុរី ដែលបណ្តាលពីកត្តានគរូបនីយកម្ម។

យោងទៅតាមទិន្នន័យប្រវត្តិសាស្ត្រពីឆ្នាំ ១៩៦០-២០០០ បានបង្ហាញថា របបទឹកភ្លៀងនៅតំបន់ SEA មានទំនោរថយចុះ ប៉ុន្តែការថយចុះរបបទឹកភ្លៀងប្រចាំឆ្នាំ ពុំដូចគ្នាគ្រប់ប្រទេសក្នុងតំបន់នោះទេដោយសារប្រទេសខ្លះបង្ហាញពីទំនោរថយចុះ និងប្រទេសខ្លះទៀតមានទំនោរកើនឡើងវិញ។ ប្រសិនបើមើលតាមរដូវ បានបង្ហាញថាភ្លៀងមូសុងមានការកើនឡើង ក៏ប៉ុន្តែក៏មានការថយចុះវិញនៅរដូវត្រជាក់។ លទ្ធផលបានបង្ហាញថា កម្ពស់ទឹកភ្លៀងប្រចាំឆ្នាំមិនមានការថយចុះខ្លាំងនោះទេបើគិតជាមាឌ ប៉ុន្តែបើគិតពីរយៈពេលវិញគឺ ភ្លៀងធ្លាក់ខ្លាំងក្នុងរយៈពេលខ្លី។ ដូច្នេះ នៅពេលភ្លៀងធ្លាក់ខ្លាំងប្រព័ន្ធលូបច្ចុប្បន្នមិនមានលទ្ធភាពគ្រប់គ្រាន់ នោះជំនន់ទឹកភ្លៀងនឹងកើតមាន។

កំណើនកម្ពស់ទឹកសមុទ្រ ដែលបានកត់សម្គាល់នៅ ១០០ឆ្នាំមុន បម្រែបម្រួលស្ថិតនៅក្នុងចន្លោះពី ១,៨ម.ម ទៅ ៣,១ម.ម ក្នុងមួយឆ្នាំ។ IPCC បានព្យាករណ៍ថានៅសតវត្សរ៍ខាងមុខនេះ កម្ពស់ទឹកសមុទ្រប្រហែលកើនឡើងពី ១៨ស.ម ទៅ ៥៩ស.ម។ បើផ្អែកតាមឯកសារវិទ្យាសាស្ត្រថ្មីៗ នៅចុងសតវត្សរ៍នេះ កម្ពស់ទឹកសមុទ្រនឹងកើនឡើងលើសពី ១ម ដែលមូលហេតុចម្បងៗគឺ ការរលាយដុំទឹកកក និងបម្រែបម្រួលចំណាំងថាមពលនៃផ្ទៃប៉ះផែនដី ហើយនៅ SEA នឹងកើនឡើងដល់ ៧០ស.ម នាឆ្នាំ ២១០០ និងកម្ពស់ទឹកសមុទ្រនៅកម្ពុជានឹងកើនឡើងពីចន្លោះ ០,១៨ម ដល់ ០,៥៦ម នាឆ្នាំ ២០៩០។ របកគំហើញចុងក្រោយបានបង្ហាញថាកម្ពស់ទឹកសមុទ្រនៅលើពិភពលោកកើនឡើងក៏ប៉ុន្តែថយចុះ ៦ម.ម ក្នុងឆ្នាំ២០១០ ដោយសារឥទ្ធិពល LaNiña។ បុព្វហេតុចម្បងៗដែលបង្កឲ្យមានជា កំណើនកម្ពស់ទឹកសមុទ្រ រួមមាន

កំណើនកម្តៅទឹក និងការរលាយនៃទឹកកក និងផ្ទាំងទឹកកក និងមូលហេតុផ្សេងៗទៀត។

សញ្ញាណនៃព្រឹត្តិការណ៍ធ្ងន់ធ្ងរក្រោមរូបភាពជាកម្តៅរលក ភ្លៀងខ្លាំង និងទឹកជំនន់ គ្រោះរាំងស្ងួត និងព្យុះសង្ឃរាត្រូវបានកើតមានឡើង។ ការកើនឡើងនូវចំនួនថ្ងៃ និងយប់ក្តៅ ភ្លៀងខ្លាំង និងទឹកជំនន់ និងគ្រោះរាំងស្ងួតត្រូវបានកត់សម្គាល់ទាំងថ្នាក់សកល និងតំបន់។ បម្រែបម្រួលនេះ គឺអាស្រ័យលើធាតុអាកាសក្នុងឆ្នាំ El Niño និងមិនមែន El Niño។ បច្ចុប្បន្ននេះ បើមើលលើព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរនៅគ្រប់ទសវត្សរ៍ ចំនួនព្រឹត្តការណ៍ធ្ងន់ធ្ងរបានកើនឡើងទ្វេដង។ ទាំងនេះ គឺជានិន្នាការដែលកំពុងកើតមាននៅកម្រិតសកល។

អ្នកវិទ្យាសាស្ត្របានព្យាករណ៍ពីអនាគតថា កំហាប់ GHGs នៅក្នុងបរិយាកាសនឹងមានការកើនឡើង ដោយគ្មានទំនោរថយចុះឡើយ ចំពោះកំហាប់ឧស្ម័នកាបូនិច ដោយសារការបញ្ចេញនឹងបន្តកើនឡើង នៅលើពិភពលោក។ ដូច្នេះ បញ្ហាទៅអនាគត គឺពាក់ព័ន្ធនឹងកំណើនសីតុណ្ហភាព និងបម្រែបម្រួលរបបទឹកភ្លៀង កំណើនកម្ពស់ទឹកសមុទ្រ និងថាតើបញ្ហាទាំងអស់នេះទាក់ទងនឹង បម្រែបម្រួលព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរដោយរបៀបណា? សីតុណ្ហភាពពិភពលោកនៅអនាគតនឹងបន្តកើនឡើងពី ១,៨°C ទៅ ៥,៤°C និងតំបន់ SEA នឹងកើនឡើងក្នុងចន្លោះពី ២°C ទៅ ៥°C នៅចុងសតវត្សរ៍ និង ១°C នៅ ៣០ឆ្នាំ ខាងមុខនេះ។ ការរកឃើញគន្លឹះមួយក្នុង តំបន់អាស៊ីប៉ាស៊ីហ្វិច បានបង្ហាញថា ការប្រែប្រួល គឺមានលក្ខណៈស្រដៀងគ្នា ប៉ុន្តែមិនដូចគ្នាទេ។ បម្រែបម្រួលសីតុណ្ហភាពនៅកម្ពុជា នាចុងសតវត្សរ៍គឺ ១,៥-៤៣°C ដែលផ្ទុយពីការព្យាករណ៍ជាសកលថា បម្រែបម្រួលស្ថិតក្នុងចន្លោះពី១,៨-៥,៤°C។ បើតាមការព្យាករណ៍ សីតុណ្ហភាពនឹងកើនឡើងប៉ុន្តែវាប្រែប្រួលតាមប្រទេស និងមានលក្ខណៈស្រដៀងគ្នានៅពេលអនាគត។

សញ្ញាណចម្បងមួយ នៃភាពមិនប្រក្រតី គឺចំនួនថ្ងៃក្តៅខ្លាំងជាងគេ។ ចំនួនថ្ងៃក្តៅខ្លាំងជាង ៣០°C នឹងកើនឡើងទ្វេដងនៅចុងសតវត្សរ៍ បើធៀបទៅនឹងការអង្កេតបច្ចុប្បន្ន។ បើតាមការព្យាករណ៍នេះបានបង្ហាញថា ការកើនឡើងចំនួនថ្ងៃភ្លៀង និងភ្លៀងខ្លាំងនឹងកើនឡើងពេលអនាគត និងស្រដៀងគ្នា។ បម្រែបម្រួលនេះនឹងបណ្តាលផលវិបាកទៅលើ ប្រព័ន្ធផលិតកម្ម ដូចជាកសិកម្មជាដើម។

នៅបណ្តាប្រទេស មានរយៈកម្ពស់ខ្ពស់បានបង្ហាញថា ធនធានទឹកនឹងមានច្រើន ប៉ុន្តែនឹងថយចុះនៅតំបន់ក្តៅ។ នៅឯតំបន់វាលទ្បាច់ភាពមិនប្រាកដប្រជានឹងកើតមានកាន់តែខ្លាំង។ ភាពលំបាក ដែលអ្នកវិទ្យាសាស្ត្រកំពុងប្រឈមមុខនោះគឺ ការពិភាក្សាពីបម្រែបម្រួលនៃកម្ពស់ទឹកភ្លៀង ជាពិសេសសីតុណ្ហភាពអាកាសធាតុមូសុងដោយសារភាពមិនប្រាកដប្រជាខ្ពស់។

លោក Alam ពន្យល់ថា កំណើនសីតុណ្ហភាពកាន់តែខ្ពស់ ផលប៉ះពាល់កាន់ខ្លាំងផងដែរ។ ក្នុងករណីធនធានទឹក ប្រសិនសីតុណ្ហភាពប្រែប្រួល ១°C នោះប្រជាជនច្រើនជាង ១កោដិ នាក់នៅលើពិភពលោកនឹងប្រឈមមុខនឹងកង្វះខាតទឹកប្រើប្រាស់។ ចំពោះស្ថានប្រព័ន្ធវិញ បើសីតុណ្ហភាពប្រែប្រួល ៣°C នឹងមានភាពប្រែ ប្រួលយ៉ាងខ្លាំងលើមុខងាររបស់ស្ថានប្រព័ន្ធ។ ក៏ប៉ុន្តែ កម្រិតនៃការប្រែប្រួលដូចគ្នាពេលខ្លះវាមិន អាចបណ្តាលឲ្យមានបញ្ហាដូចគ្នាចំពោះវិស័យផ្សេងទៀតនោះទេ។ ប្រសិនបើសីតុណ្ហភាពប្រែប្រួល ៣°C នឹងមានផលប៉ះពាល់ខ្លាំងទៅលើបរិស្ថាន ច្រើនជាងផ្នែកគុណភាពអាហារ និងទឹក។ សហគមន៍អ្នកវិទ្យាសាស្ត្របង្ហាញពីភាពស្មុគស្មាញនៃការប្រែប្រួលអាកាសធាតុ និងចាំបាច់ចំពោះអ្នកធ្វើគោលនយោបាយដើម្បីពិចារណាពី មូលហេតុនានាថាហេតុអ្វីបាន

ជា ការប្រែប្រួលអាកាសធាតុមានសារសំខាន់។ លោកក៏បានបង្ហាញផងដែរថា កំណើនសីតុណ្ហភាព អាចបណ្តាលឲ្យមាននូវការប្រែប្រួលការរំហួត ហើយនឹងប៉ះពាល់ដល់ ការប្រែប្រួលកម្រិតទឹកភ្លៀង និងតំហាយចុះនូវលំហូរទឹក។ ការថយចុះលំហូរទឹក មិនត្រឹមតែទាក់ទឹងនឹងវិស័យកសិកម្មប៉ុណ្ណោះទេ ប៉ុន្តែក៏ទាក់ទងនឹងថាមពលវារីអគ្គីសនីផងដែរ។ ផលវិបាកពាក់ព័ន្ធនឹងការកើនឡើងកម្ពស់ទឹកសមុទ្រ គឺការផ្តត់ផ្តង់កសិកម្ម តំបន់ឆ្នេរ សម្រាប់អ្នកប្រើប្រាស់នៅតំបន់នោះ។ ការប្រែប្រួលនេះ មានលក្ខណៈស្រដៀងគ្នាទៅ នឹងការប្រែប្រួលក្នុងវិស័យធនធានទឹកផងដែរ ដែលបង្កគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួតមាន ការកើនឡើង និងធ្វើឲ្យទិន្នផលដំណាំធ្លាក់ចុះ។ ការកើនឡើងកម្ពស់ទឹកសមុទ្រ នឹងធ្វើឲ្យបាត់បង់ដី ដែលអាចដាំដំណាំបានកាន់តែច្រើន ដោយសារ [១] ទឹកលិច និង [២] ការកើនឡើងនូវជាតិប្រៃទាំងក្នុងដី និងទឹក។ ក្នុងវិស័យសុខាភិបាល ករណីជម្ងឺគ្រុនឈាម និងការរាលដាលនៃជម្ងឺឆ្លងតាមទឹកបានកើតមានក្នុង តំបន់គួរឲ្យកត់សម្គាល់។ តាមរយៈការសិក្សារបស់ ADB បានបង្ហាញថា ផ្លែខ្ចខាតពី ការប្រែប្រួលអាកាសធាតុមានការកើនឡើងតាមពេលវេលា ហើយអត្រាមរណៈពេលអនាគតក៏នឹងកើនឡើងផងដែរ។

ជម្រើសបន្សាំចំពោះ វិស័យនីមួយៗត្រូវបានលើកឡើង ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ វិស័យធនធានទឹកអាចអនុវត្តបាន តាមរយៈការបង្កើនការអភិរក្សធនធានទឹក ការគ្រប់គ្រងធនធានទឹក តាមបែបចម្រុះ បំពាក់ប្រព័ន្ធផ្តល់ព័ត៌មានជាមុន និងការកែលម្អប្រព័ន្ធធារាសាស្ត្រ មានប្រសិទ្ធភាពជាងមុន។ ចំពោះវិស័យកសិកម្ម ត្រូវការចាំបាច់ព័ត៌មានអាកាសធាតុប្រសើរជាងមុន ការស្រាវជ្រាវ និងអភិវឌ្ឍន៍ពូជដំណាំធន់នឹងកម្តៅ ។ ចំពោះវិស័យព្រៃឈើ ត្រូវពង្រឹងប្រព័ន្ធផ្តល់ព័ត៌មានជាមុន និងកម្មវិធីបង្កើនការយល់ដឹង ដើម្បីត្រៀមបង្ការភ្លើងឆេះព្រៃ។ ចំពោះវិស័យសុខាភិបាល គឺការពង្រឹងប្រព័ន្ធផ្តល់ព័ត៌មានជាមុនពីការផ្ទុះជម្ងឺ ការអង្កេតសុខភាព និងយុទ្ធនាការបង្កើនការយល់ដឹង និងកម្មវិធីបង្ការជម្ងឺឆ្លង។ ការវិនិយោគ ការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ គឺជាជម្រើស សម្រាប់វិស័យហេដ្ឋារចនាសម្ព័ន្ធ។ បញ្ហាប្រឈមមួយនៅក្នុងវិធានការបន្សាំ គឺការចំណាយ និងផលចំណេញពីការបន្សាំដែលទាក់ទងទៅនឹងជម្រើសនានាសម្រាប់អ្នកសម្រេចចិត្តខាងគោលនយោបាយត្រូវតែដឹងប្រសិនបើយើងគ្មានចំណាត់ការអ្វីទេនោះ ថាតើផលប៉ះពាល់ពាក់ព័ន្ធការប្រែប្រួលអាកាសធាតុ ពេលអនាគតមានអ្វីខ្លះ? តើនឹងត្រូវចំណាយប៉ុន្មានតាមរយៈជម្រើសសកម្មភាពមួយណា? ជាងនេះទៀត កង្វះខាតព័ត៌មាន និងចំណេះដឹងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបនៃប្រព័ន្ធធម្មជាតិនឹងការប្រែប្រួលអាកាសធាតុភាពមិនគ្រប់គ្រាន់នៃការសិក្សាពី ទំនាក់ទំនងរវាងជម្រើសបន្សាំ និងការកាត់បន្ថយនៅមានកម្រិតប្រព័ន្ធត្រួតពិនិត្យ និងការស្រាវជ្រាវអាកាសធាតុ និងការ ឆ្លើយតបនឹងការប្រែប្រួអាកាសធាតុ នៅជាបញ្ហាប្រឈមនៅក្នុងបន្សាំ។

លោក Alam បានផ្តល់ឧទាហរណ៍ពីផលប៉ះពាល់នៃការកាត់បន្ថយការបញ្ចេញ GHGs ជាមួយនឹងសេនារីយ៉ូផ្សេងៗ។ ផលប៉ះពាល់នៃការកាត់បន្ថយការបញ្ចេញGHGs ៥០% នៅឆ្នាំ២០៥០ (គឺការកាត់បន្ថយ៣% ក្នុងមួយឆ្នាំ) សីតុណ្ហភាពនឹងកើនឡើង២,៤°C។ ប្រសិនបើកាត់បន្ថយការបញ្ចេញ GHGs ៨០% នោះសីតុណ្ហភាពនឹងកើនឡើងទាបជាង ២°C ។ ប្រសិនបើការកាត់បន្ថយឧស្ម័ន ៥០% និង ៨០% ត្រូវបានពន្យាពេល ផលប៉ះពាល់ពាក់ព័ន្ធនឹងកើតមានឡើងកាន់តែខ្លាំងនៅពេលអនាគត។ វិធី និងពេលណា ដែលកម្រិតកើនឡើងខ្ពស់

បំផុតនឹងកើតឡើង គឺជាបញ្ហាគន្លឹះក្នុងការពិភាក្សាស្តីពីការប្រែប្រួលអាកាសធាតុ ដែលសហគមន៍ពិភពលោកកំពុងឆ្លើយតបលើវិធានការកាត់បន្ថយ ដែលមានការពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ និងមានភាពពាក់ព័ន្ធជាមួយនឹងផលប៉ះពាល់។

ក្នុងន័យកាលានុវត្តភាព លោក Alam បានបញ្ជាក់ពីទស្សនៈថា ជាដំបូងត្រូវមានអាទិភាពខ្ពស់ក្នុងរបៀបវារៈ នយោបាយ និងការទទួលស្គាល់ការពាក់ព័ន្ធជាមួយការអភិវឌ្ឍតាមរយៈ ការបញ្ចូលអ្នកកសាងគោលនយោបាយ និងអ្នកធ្វើការសម្រេចចិត្ត។ ទីពីរ ត្រូវបង្កើតជាស្ថាប័នថ្មី ដើម្បីសម្របសម្រួលកិច្ចការប្រែប្រួលអាកាសធាតុ។ ទីបី ត្រូវមានការបែងចែងហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាព និងចុងក្រោយគឺ ដំណើរការអភិវឌ្ឍឆ្ពោះទៅរកសមាហរណកម្មវិស័យផ្សេងៗគ្នា ដែលមានលក្ខណៈពហុវិស័យ ដើម្បីរៀបចំធ្វើផែនការ និងការដោះស្រាយ បញ្ហាប្រែប្រួលអាកាសធាតុប្រកបដោយប្រសិទ្ធភាព។

ចីរភាពនៃបរិស្ថាន ការកាត់បន្ថយគ្រោះមហន្តរាយ និងការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាអន្តរទំនាក់ទំនង ដែលត្រូវការពិចារណានៅក្នុងកម្រិតពហុវិស័យ។

ចុងក្រោយនៃបទបង្ហាញលោកបានផ្តល់ជាសារគន្លឹះបីរួមមាន៖

- កម្រិតផលប៉ះពាល់ធ្ងន់ធ្ងរពុំអាចជៀសវាងបានទេ ទោះបីជាមានវិធានការកាត់បន្ថយក៏ដោយ
- វិធានការ ដែលមានប្រយោជន៍ជាច្រើនដើម្បីពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងធាតុអាកាសធ្ងន់ធ្ងរមានរួចអាចរៀនបានច្រើនពីបទពិសោធន៍ និងចំណេះដឹង
- ការបញ្ចូលវិធានការបន្សាំក្នុងការអភិវឌ្ឍនឹងអាចជួយទាំងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ។

បច្ចុប្បន្នភាពអំពីការអនុវត្តថ្មីៗ និងគំនិតផ្តួចផ្តើមសំខាន់ៗលើការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា

*ដោយលោក **អ៊ុយ ភាម៉ាល***
ប្រធានការិយាល័យសារពើភ័ណ្ឌ និងកាត់បន្ថយ
ឧស្ម័នផ្ទះកញ្ចក់ MoE

បទបង្ហាញរបស់ លោក **ភាម៉ាល** បានរាយការណ៍នូវការរីកចម្រើនរបស់ប្រទេសកម្ពុជាក្នុងការកសាងសមត្ថភាពស្ថាប័ន ការបង្ហាប់ការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការតាមវិស័យ និងផែនការថ្នាក់ជាតិ និងការអនុវត្តគំនិតផ្តួចផ្តើមការងារប្រែប្រួលអាកាសធាតុសំខាន់ៗនានា។

លោក **ភាម៉ាល** បានបកស្រាយថា CCCA គឺជាកម្មវិធីមួយដែលផ្តួចផ្តើមដោយពហុម្ចាស់ជំនួយដូចជា EU UNDP DANIDA និង SIDAដែលមានថវិកាសរុបចំនួន៨,៩លានដុល្លាអាមេរិកសម្រាប់រយៈពេលអនុវត្តន៍ពីឆ្នាំ ២០១០ - ២០១២។ គោលបំណងចម្បងនៃ CCCA គឺដើម្បីធានា រាល់សកម្មភាពការប្រែប្រួលអាកាសធាតុនៅកម្ពុជា ជាការងារជាតិ ដឹកនាំ និងអនុវត្តន៍ស្របតាមអាទិភាពនៃការអភិវឌ្ឍជាតិ និងសម្របសម្រួល និងអនុវត្តប្រកបដោយប្រសិទ្ធភាព។ លោកក៏បានបញ្ជាក់ពីលទ្ធផលសំខាន់ៗទាំងបីរបស់ CCCA ដែលរួមមាន៖

- ការសម្របសម្រួលការបង្កើតនូវគោលនយោបាយនិងការបញ្ចូលការប្រែប្រួលអាកាសធាតុ

- វេទិកាគ្រប់គ្រងចំណេះដឹង ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ ការអប់រំ និងព័ត៌មាន និង
- ការគ្រប់គ្រងមូលនិធិ (រាប់បញ្ចូលទាំងថវិកាគម្រោង)

គំនិតផ្តួចផ្តើមមួយទៀត គឺ PCCR ដែលផ្តល់មូលនិធិដោយ WB ADB NDF និង RGC ដែលមានគោលបំណងដូចជា៖

ដំណាក់កាលទី១៖ ការវាយតម្លៃ និងការពង្រឹងស្ថាប័ន ឲ្យត្រៀមខ្លួនសម្រាប់គម្រោង និង យកចិត្តទុកដាក់ទៅលើវិស័យអាទិភាព ដូចជា ការអភិវឌ្ឍធនធានទឹក កសិកម្ម ឬ ធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធជនបទ។

ដំណាក់កាលទី២៖ ការអនុវត្តកម្មវិធីយុទ្ធសាស្ត្រតាមរយៈគម្រោងបណ្តាក់ទុន ដែលមានចំនួន៧ផ្នែក (កំណែទម្រង់នយោបាយ ការកសាងសមត្ថភាពស្ថាប័ន និងការបណ្តាក់ទុនមូលដ្ឋាន) នៅក្នុងវិស័យអាទិភាពទាំងបី។

ថវិកាដំណាក់កាលទី១មាន ១,៥លានដុល្លាអាមេរិក និងថវិកាសម្រាប់ការអនុវត្តនៅក្នុងដំណាក់កាលទី២មាន ៥០លានដុល្លាអាមេរិកជាជំនួយ និងជាឥណទានសម្បទាន ៣៦ លានដុល្លាអាមេរិក។ ប៉ុន្តែ រយៈពេលនៃការអនុវត្តគម្រោងពុំទាន់មានភាពប្រាកដប្រជានៅឡើយទេ។

ជាចុងក្រោយ លោកបានរៀបរាប់អំពីគម្រោងមួយចំនួន ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដែលបានអនុវត្តន៍នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានដោយស្ថាប័នផ្សេងៗ ដូចជា OA និង JCCI ជាដើម។ គម្រោងមានស្រាប់បានបែងចែកជាបីប្រភេទដូចជា ការបន្សាំ ការកាត់បន្ថយ និងការស្រាវជ្រាវនិងការអភិវឌ្ឍ។ លោកបានធ្វើការកត់សំគាល់ថា ចំនួនគម្រោងដែលបានបង្ហាញនេះ មិនមែនជាទិន្នន័យបច្ចុប្បន្នភាពចុងក្រោយនោះទេ ដូច្នេះចំនួនគម្រោងជាក់ស្តែងដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុអាចមានច្រើនជាងនេះ។

បទបង្ហាញអំពីលទ្ធផលសំខាន់ៗនៃរបាយការណ៍ជាតិលើកទី២

*ដោយលោកបណ្ឌិត **ង៉ិន ពន្លក** អគ្គនាយករង GDANCP និងជាប្រធានលេខាធិការដ្ឋានមូលនិធិប្រែប្រួលអាកាសធាតុ CCCA/MoE*

បទបង្ហាញនេះផ្តល់នូវសេចក្តីសង្ខេបអំពីសារពើភ័ណ្ឌ GHGs ឆ្នាំ២០០០ លទ្ធផលនៃការវិភាគការកាត់បន្ថយ GHGs និងការវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំ ក៏ដូចជាព័ត៌មានផ្សេងៗទៀតដែលមាននៅក្នុង SNC របស់កម្ពុជានៅក្រោម UNFCCC។

លោកបណ្ឌិត **ង៉ិន ពន្លក** បានបញ្ជាក់ថា កម្ពុជា ដែលជាភាគីមួយរបស់ UNFCCC មានការប្តេជ្ញាចិត្តនឹងធ្វើរបាយការណ៍ ដាក់ជូនទៅ CoP(ដោយយោងលើមាត្រា១២របស់UNFCCC) ស្តីពី [១] ការបញ្ចេញឧស្ម័នតាមប្រភព និងដកចេញដោយអាងស្តុកនូវ GHGs ទាំងអស់ និង [២] វិធានការជាតិដើម្បីកាត់បន្ថយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។របាយការណ៍នេះត្រូវបានហៅផ្លូវការថា "របាយការណ៍ជាតិលើកទី២ (SNC) " ដែលរាល់ចំណាយក្នុងការរៀបចំរបាយការណ៍នេះ គឺទទួលបានហិរញ្ញប្បទានពេញលេញ ផ្ទុយពីប្រទេសអភិវឌ្ឍ ដែលត្រូវរៀបចំរបាយការណ៍ ជាកាតព្វកិច្ចដោយប្រើប្រាស់ថវិកាផ្ទាល់ខ្លួន។

លោកបណ្ឌិត **ង៉ិន ពន្លក** បានពន្យល់ថា សារពើភណ្ឌ GHGs គឺជាការប៉ាន់ស្មានប្រភពនៃការបញ្ចេញ និងអាងស្តុកពីវិស័យដែលពាក់ព័ន្ធ ដូចជា វិស័យថាមពល កសិកម្ម ការប្រែប្រួលការប្រើប្រាស់ដីធ្លី និងព្រៃឈើ និងសំណល់ដែលផ្តោតលើសារធាតុពុលសំខាន់ៗ ដូចជា CO_2 CH_4 និង N_2O។ លទ្ធផលនៃសារពើភ័ណ្ឌ GHGs នៅឆ្នាំគោល ២០០០ បានបង្ហាញថា

LUCF បញ្ចេញ CO_2 ច្រើនជាងគេ ហើយវិស័យព្រៃឈើក៏អាចស្រូបយកនូវ CO_2e តាមរយៈការធ្វើរស្មីសំយោគ។ វិស័យព្រៃឈើនេះអាចស្រូបយកការបញ្ចេញ CO_2 សរុបចំនួន ២៤.៥៦៥,៦៧ $GgCO_2e$ ខណៈវិស័យកសិកម្មបញ្ចេញប្រមាណ ២១.១១០,៨២$GgCO_2e$ វិស័យថាមពលបញ្ចេញ ៣.៤៤៣,១៤$GgCO_2e$ និងវិស័យសំណល់បញ្ចេញបរិមាណតិចជាងគេគឺ ២២៩,២៤ Gg CO_2e។ លោកបណ្ឌិតក៏បានធ្វើការប្រៀបធៀបពីការបញ្ចេញប្រចាំឆ្នាំសម្រាប់បុគ្គលម្នាក់ៗ នៅក្នុងវិស័យថាមពល រវាងប្រទេសកម្ពុជា ជាមួយនឹងបណ្តាប្រទេសមួយចំនួនថា ទោះបីជា ការបញ្ចេញសរុបមានការកើនឡើង ក៏ប៉ុន្តែការបញ្ចេញសម្រាប់បុគ្គលម្នាក់ៗនៅកម្ពុជា គឺមាន ០,៣tCO_2e។ បរិមាណនេះនៅទាបនៅឡើយ ខណៈប្រទេសថៃ ៣,៥tCO_2e ប្រទេសវៀតណាម ១tCO_2e ប្រទេសអាល្លឺម៉ង់១០tCO_2e និងសហរដ្ឋអាមេរិក ១៩tCO_2e។

កម្ពុជា គឺជាប្រទេស DC ពឹងផ្អែកស្ទើរទាំងស្រុងលើវិស័យកសិកម្ម និងងាយរងគ្រោះខ្លាំង ពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ។ នៅក្នុងរបាយការណ៍ SNC ក៏មានការវាយតម្លៃពីប្រវត្តិ និងអនាគតនៃការប្រែប្រួលអាកាសធាតុនៅក្នុងកម្ពុជាការធ្វើផែនទីនៃភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យ គន្លឹះ ដូចជាកសិកម្ម ធនធានទឹក ព្រៃឈើ តំបន់ឆ្នេរ និងសុខាភិបាល ដោយប្រើប្រាស់នូវម៉ូដែលអាកាសធាតុកម្រិតតំបន់ (PRECISE) រួមជាមួយនឹងម៉ូដែល GCM ។ ផ្អែកតាមរបកគំហើញក្នុង SNC លោកបណ្ឌិតបានអះអាងថា ឃុំភាគច្រើននៅកម្ពុជាត្រូវបានកម្រិតពី ងាយរងគ្រោះទៅ ងាយរងគ្រោះខ្លាំង ដោយសារភាពទន់ខ្សោយនៃសេដ្ឋកិច្ច សង្គម លក្ខខណ្ឌហេដ្ឋារចនាសម្ព័ន្ធ ជាមួយនឹងដង់ស៊ីតេប្រជាជនខ្ពស់។ ការវាយតម្លៃភាពងាយរងគ្រោះកម្រិតឃុំ បង្ហាញថា ភាពងាយរងគ្រោះនៃសហគមន៍ នៅជុំវិញទន្លេមេគង្គ និងបឹងទន្លេសាប កំពុងមានការកើនឡើង ដែលបណ្តាលមកពីការកើនចំនួនប្រជាជនដ៏ឆាប់រហ័ស។ ជាងនេះទៀត ប្រសិនជាពុំមានការធ្វើឲ្យប្រសើរឡើងនូវ វិស័យសេដ្ឋកិច្ច-សង្គម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទេនោះ ភាពងាយរងគ្រោះនេះ ទំនងនឹងបន្តកើនឡើងដោយសារសំពាធរបស់ប្រជាជន។ សីតុណ្ហភាពបានកើនឡើងជាលំដាប់ចាប់ពីឆ្នាំ ១៩៦០ - ២០០០ ហើយការព្យាករណ៍សីតុណ្ហភាពមធ្យមនៅឆ្នាំ ២០៩៩ នឹងកើនឡើង ក្នុងចន្លោះពី ០,០១៣ទៅ០,០៣៦°C ។ ជាមួយនឹងស្ថានភាពនេះ តំបន់ឥសាននៃកម្ពុជានឹងជួបប្រទះនូវភាពរាំងស្ងួតនៅរដូវប្រាំង ខណៈតំបន់ជុំវិញបឹងទន្លេសាបនឹងមានភ្លៀងធ្លាក់ច្រើន ហើយអាចមានទឹកជំនន់។ លោកបណ្ឌិតបានសន្និដ្ឋានផងដែរថា របបទឹកភ្លៀងនៅពេលអនាគតនឹងបន្តប្រែប្រួល អាស្រ័យសេណារីយ៉ូការបញ្ចេញ។ ការបំភាយតាមទម្លាប់ធម្មតា លក្ខខណ្ឌនៃការបញ្ចេញកម្រិតខ្ពស់ (SRESA2) នឹងជះឥទ្ធិពលដល់កម្ពុជាក្នុងទ្រង់ទ្រាយធំ ខណៈលក្ខខណ្ឌនៃការបញ្ចេញតិច (SRESA1) នឹងជះឥទ្ធិពលតិចជាង បើធៀបនឹង SRESA2 ។ លទ្ធភាពការកាត់បន្ថយការបញ្ចេញ GHGs ក្នុងពិភពលោកនឹងមានការជាប់ពាក់ព័ន្ធខុសៗគ្នាលើកម្ពុជា។
លោក បណ្ឌិតបានបន្ថែមថា ដើម្បីឆ្លើយតបនឹងការប្រែប្រួលនេះ គឺត្រូវបង្កើតឲ្យមាននិងអនុវត្តគម្រោងសិក្សា និងសាកល្បងអំពីការបន្សាំនៃថ្នាក់មូលដ្ឋាន។

លោកបណ្ឌិតបានបកស្រាយពី ការកាត់បន្ថយ GHGs នៅក្នុងវិស័យមួយចំនួន ដូចជាវិស័យថាមពល ការដឹកជញ្ជូនកសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដីធ្លី (AFOLU) ។ ចំពោះវិស័យថាមពល និងការដឹកជញ្ជូន ជម្រើសនៃការកាត់បន្ថយ អាចជាប្រសិទ្ធភាពថាមពលវារីអគ្គីសនី ថាមពលពន្លឺព្រះអាទិត្យ ឧស្ម័នកម្ម និងការ

បង្កើតអគ្គីសនីរួម រថយន្តអគ្គីសនី ចង្ក្រានប្រសិទ្ធភាព និងឡជីវឧស្ម័នជាដើម។ ចំពោះវិស័យនេះ ការកាត់បន្ថយការបញ្ចេញនៅឆ្នាំ ២០៥០ត្រូវបានប៉ាន់ស្មានថា១៧% បើធៀបនឹងលក្ខខណ្ឌគោល ៣.៨៧៧ $GgCO_2e$។ ក្នុងវិស័យ AFOLU ជម្រើសនៃការកាត់បន្ថយអាចធ្វើតាមរយៈ ការគ្រប់គ្រងលាមកសត្វជីវឧស្ម័ន ការប្តូរពីជីធម្មតាទៅជាជីស៊ុលផាត ការបង្ហូរទឹកចេញនៅរដូវវស្សា ការធ្វើជីកំប៉ុស្តិ៍ពីសំណល់ឡជីវឧស្ម័ន ការគ្រប់គ្រងដំណាំកសិ-រុក្ខកម្ម ការដាំព្រៃឈើឡើងវិញ និង REDD+។ ប្រសិនជម្រើសបច្ចេកទេសទាំងអស់ ត្រូវបានអនុវត្ត បរិមាណនៃការបញ្ចេញនឹងត្រូវបានកាត់បន្ថយ ៣២.៥២១$GgCO_2e$ នៅក្នុងវិស័យកសិកម្ម និងសំរូបសុទ្ធកើនឡើង ២០.៥៤៥ $GgCO_2e$ នៅក្នុងវិស័យ LUCF ។

នៅទីបញ្ចប់លោកបណ្ឌិត បានបញ្ជាក់ពីឧបសគ្គនិងភាពខ្វះចន្លោះដែលរាជរដ្ឋាភិបាលប្រឈមមុខក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដែលបណ្តាលមកពីបញ្ហាធនធានមនុស្ស ការយល់ដឹងនៅមានកម្រិត កង្វះខាតទិន្នន័យ ការស្រាវជ្រាវ ការវិភាគ បច្ចេកវិទ្យាធនធានហិរញ្ញវត្ថុ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រ។ ទោះយ៉ាងណាក្តី កាលានុវត្តភាពសម្រាប់អនុវត្តវិធានការបន្ស៊ាំ និងការកាត់បន្ថយ ចាត់ទុកថាមានកម្រិតខ្ពស់តាមរយៈការបង្កើនហិរញ្ញប្បទាន សម្រាប់ការប្រែប្រួលអាកាសធាតុ (យន្តការរហ័ស GEF AF LDCF ទ្វេភាគី ផ្នែកឯកជន...) ការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះការអភិវឌ្ឍបៃតងបានបន្សុីជាមួយការកាត់បន្ថយការបំភាយឧស្ម័ន CDM និង REDD+។

សំណួរ និងចម្លើយ

សកម្មភាពសាកសួរសំណួរពីអ្នកចូលរួម (CCCA, 2011)

លោក **ឈួស សីហា** នៃក្រុមហ៊ុន SAK បានបង្ហាញអំពី ចំណាប់អារម្មណ៍លើបទបង្ហាញទាំងអស់ ប៉ុន្តែលោកចង់បាននូវការបកស្រាយបន្ថែមពីនិយមន័យនៃ GHGs និងការគ្រប់គ្រងដីសម្រាប់ដាំណាំស្រូវ តើយើងអាចកត់សម្គាល់ឬមានវិធីសាស្ត្រអ្វីខ្លះដើម្បីរក្សាទឹកក្នុងដីឲ្យបានគ្រប់គ្រាន់នៅរដូវប្រាំង រហូតពេលប្រមូលផលបាន? ដោយសារព្រឹត្តិការណ៍មិនប្រក្រតីនាពេលថ្មីៗនេះ ជាពិសេស ទឹកជំនន់បានធ្វើឲ្យវាលស្រែរបស់គាត់ក្នុងខេត្តកំពង់ធំ(ស្ទើរជិតបានប្រមូលផលទៅហើយ)ខូចខាតទាំងអស់។ ដូច្នេះតើអ្វីជាសូចនាករនៃសញ្ញាបង្ហាញជាមុន ពីទឹកជំនន់? តើស្ថាប័នណាអាចផ្តល់នូវព័ត៌មានបែបនេះ?

លោក **អ៊ុយ ភាម៉ាល** បានអះអាងថា ពាក្យឧស្ម័នផ្ទះកញ្ចក់ (GHGs) នៅមានការភាន់ច្រលំចំពោះសាធារណជន។ GHGs សំខាន់ៗរួមមាន CH_4 CO_2 N_2O SF_6 ជាដើម បញ្ចេញមកពីសកម្មភាពមនុស្ស ដូចជា ការដឹកជញ្ជូន ឧស្សាហកម្ម និងកសិកម្មជាដើម។ កាលពីមុន GHGs ប្រភេទខ្លះត្រូវបានហៅថា ឧស្ម័នផ្ទះបៃតង ប៉ុន្តែ MoE បានឲ្យឈ្មោះថាជា "ឧស្ម័នផ្ទះកញ្ចក់" ហើយឥឡូវនេះ ត្រូវបានប្រើជាទូទៅ។ ពិភពលោកនេះ ព័ទ្ធជុំវិញទៅដោយស្រទាប់បរិយាកាស ហើយ GHGs ត្រូវបានបញ្ចេញទៅក្នុងបរិយាកាស កម្តៅ (កាំរស្មីពណ៌ក្រហម) ត្រូវ

បានស្រូបដោយ GHGs ដែលធ្វើឲ្យផែនដីមានកម្តៅកើនឡើង។ ដូច្នេះវាត្រូវបាន គេហៅថា GHGs ។ ដូចនេះ កំហាប់ GHGs កាន់តែច្រើនឡើងនៅក្នុងបរិយាកាស ជាកត្តាជម្រុញឲ្យកម្តៅផែនដីកាន់តែកើនឡើងជាទូទៅ។ លោកបណ្ឌិត **ង៉ិន ពន្លក** បានឆ្លើយតបនឹងសំណួរទី២ថា MoE ពុំមានសមត្ថកិច្ចលើការរក្សាទឹកក្នុងដីទេ។ វាអាស្រ័យលើប្រភេទដី ឬភូគម្ភគីមីរូបនៃដីខុសៗគ្នា ដូច្នេះ លោកបណ្ឌិត បានណែនាំឲ្យទៅពិភាក្សាជាមួយជំនាញការនៅក្នុងផ្នែកនេះ។ សូចនាករសម្គាល់នៅពេលមាន ព្រឹត្តិការណ៍មិនប្រក្រតីដូចជា ទឹកជំនន់ ឬគ្រោះរាំងស្ងួត ដែលនឹងកើតឡើងនោះ វាអាស្រ័យលើការប្រមូលព័ត៌មាន ពិសេសទិន្នន័យ ឬព័ត៌មានឧតុនិយម ដែលអាចរក និងជឿទុកចិត្តបាន។ ទាក់ទងនឹងបញ្ហានេះ MAFF និង MoWRAM គឺជាស្ថាប័នគួរទាក់ទង ដោយក្រសួងទាំងពីរមានតួនាទី និងទំនួលខុសត្រូវដោយផ្ទាល់ក្នុងបរិបទការងារនេះ។

លោក **Khter Uzaman Sano** មកពី *អង្គការសង្គ្រោះផែនដីកម្ពុជា* ដោយផ្អែកតាមបទពិសោធន៍របស់លោក គម្រោងត្រូវតែកសាងភាពធន់ ក្នុងន័យភាពធន់ទៅនឹងមហន្តរាយ និងអាកាសធាតុ។ លោកបន្ថែមថានៅដំណាក់កាលបញ្ចប់គម្រោងពុំមានសូចនាករណាដើម្បីកំណត់ថាតើគម្រោងនោះមានភាពធន់ ឬគ្មាននោះទេ?

លោកបណ្ឌិត **ង៉ិន ពន្លក** បានបញ្ជាក់ថាដើម្បីកំណត់ថាគម្រោងមួយមានភាពធន់ ឬគ្មាន អាស្រ័យថាទិន្នន័យ ឬព័ត៌មានឧតុនិយមអាចរក និងអាចជឿទុកចិត្តបានក្នុងកម្រិតណា។ មានន័យថា ដំបូងទិន្នន័យគោលពីធាតុអាកាសដែលអាចទុកចិត្តបានត្រូវតែប្រមូលជាមួយនឹងការព្យាករណ៍ទៅអនាគតតួយ៉ាងដូចជា កម្រិតទឹកភ្លៀងជាដើម។

លោក **Khter Uzaman Sano** មកពី *អង្គការសង្គ្រោះផែនដីកម្ពុជា* មានប្រសាសន៍ថា ការបញ្ជ្រាបយេនឌ័រ ជាបញ្ហាសំខាន់មួយដោយលោក **Sano** បានផ្តល់ជាឧទាហរណ៍ផ្អែកលើបទពិសោធន៍របស់លោក ក្នុងការដាក់ស្ត្រី៥0% ក្នុង តួនាទីធ្វើការសម្រេចចិត្ត នៅស្ថាប័នតូចមួយ។ លទ្ធផលបានបង្ហាញយ៉ាងច្បាស់ថា វាអាចដំណើរការ ក្នុងសហគមន៍បង្វិលមូលនិធិដើម្បីកសាងភាពធន់នឹងមហន្តរាយ និងការប្រែប្រួលអាកាសធាតុ។ អ្វីគួរឲ្យភ្ញាក់ផ្អើលនោះគឺ ហេតុអ្វីបានជា គ្មានវាគ្មិនជាស្ត្រីសោះនៅក្នុងវគ្គនេះ? តើនេះមានន័យថា គ្មានស្ត្រីមានសមត្ថភាពទេឬ?

លោកបណ្ឌិត **ង៉ិន ពន្លក** គូសបញ្ជាក់ថា ជាការពិតណាស់ នេះគឺជាបញ្ហាមួយនៅក្នុងចំណោមបញ្ហាផ្សេងៗ ដែលត្រូវបានលើកយកមកពិចារណាយ៉ាងហ្មត់ចត់។ ជាក់ស្តែងមានសមាជិក NCCC ជាស្ត្រី ដែលជាតំណាងមកពី MoWA ។ នេះបង្ហាញពីការយកចិត្តទុកដាក់យ៉ាងខ្លាំងរបស់ RGC ទៅលើការបញ្ជ្រាបយេនឌ័រ ជាពិសេសពាក់ព័ន្ធនឹងគម្រោងកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុនេះ។

លោក **Khter Uzaman Sano** មកពី *អង្គការសង្គ្រោះផែនដីកម្ពុជា* មានប្រសាសន៍ថា យោងតាមការលើកឡើងរបស់លោក បណ្ឌិត **ង៉ិន ពន្លក** នូវពាក្យ "ការធានារ៉ាប់រងអាកាសធាតុ" លោកត្រូវការការបកស្រាយបន្ថែមអំពីអត្ថន័យនៃពាក្យបច្ចេកទេសនេះ ដោយផ្តល់ឧទាហរណ៍ទាក់ទងនឹងការធានារ៉ាប់រងនៅពេលយើងទិញការធានារ៉ាប់រង យើងត្រូវបង់ថវិកាដូចជាការធានារ៉ាប់រងរថយន្ត ឬសុខភាព។ ចំណែកឯសហគមន៍ ដែលគ្មានថវិកាគ្រប់គ្រាន់សម្រាប់ទិញអាហារផងនោះ តើគេអាចចំណាយទៅលើការធានារ៉ាប់រងនេះបានយ៉ាងដូចម្តេច? តើអ្នកណាជាអ្នករ៉ាប់រងការចំណាយនេះ?

លោកបណ្ឌិត **ឥន ពន្លក** ជឿជាក់ថា ការធានារ៉ាប់រងការប្រែប្រួលអាកាសធាតុទើបតែស្ថិតក្នុងចំណុចចាប់ផ្តើមប៉ុណ្ណោះ ដូច្នេះ វាគ្មានអ្វីនឹងបកស្រាយពីសហគមន៍ក្រីក្រ ដូចជាកម្ពុជានោះទេ។ វានឹងត្រូវការពេលវេលាច្រើនឆ្នាំ ឬក៏ច្រើនទសវត្សរ៍ ដើម្បីមើលពីការរីកចម្រើនរបស់វា ដោយសារបញ្ហានេះត្រូវការការសិក្សាបន្ថែមឲ្យបានស៊ីជម្រៅ។ ជាធម្មតា ដំណើរការធានារ៉ាប់រង ការប្រែប្រួលអាកាសធាតុនឹងត្រូវការការចែករំលែកចំណាយ និងផលប្រយោជន៍រវាងប្រជាជន និងក្រុមហ៊ុនធានារ៉ាប់រង។ ឧទាហរណ៍ កសិករកម្ពុជាអាចបង់ប្រាក់មួយចំនួនទៅឲ្យក្រុមហ៊ុនធានារ៉ាប់រង ដើម្បីទាញយកផលប្រយោជន៍ពីការសងការខូចខាត ក្នុងករណីមានគ្រោះមហន្តរាយធម្មជាតិកើតឡើង និងការបំផ្លាញដំណាំ។ ទោះជាយ៉ាងណាក្តី វាក៏នៅតែជាបញ្ហាប្រឈម ចំពោះក្រុមហ៊ុនធានារ៉ាប់រង ពីព្រោះពួកគេនឹងមិនហ៊ានទទួលយកនូវហានិភ័យ និងការខាតបង់ថវិកាក្នុងកិច្ចសន្យាធានារ៉ាប់រងបែបនេះទេ។

វគ្គស្របតួ ទី១

បន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ- ភាពជៀតជ័យ ការប្រឈម និងមេរៀនទទួលបាន

សហប្រធាន៖

១. លោក **កែន សេរីរដ្ឋា** អគ្គនាយករង GDANCP/MoE

២. លោក **Koen Everaert** អនុព័ន្ធទទួលបន្ទុកសហប្រតិបត្តិការ ប្រតិភូ EU ប្រចាំនៅកម្ពុជា

លោក **រដ្ឋា** បានបញ្ជាក់ថា យើងដឹងហើយថា ការបន្សុំនឹងការប្រែប្រួលអាកាសធាតុជាកិច្ចការសំខាន់មួយ ដើម្បីរួមចំណែកកាត់បន្ថយផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុដែលកំពុងកើតឡើងសព្វថ្ងៃ និងពង្រឹងសមត្ថភាពធន់នឹងផលប៉ះពាល់នាពេលអនាគត។ ការពិភាក្សាថ្ងៃនេះ នឹងមើលលើកាលានុវត្តភាពការកសាងសមត្ថភាពមនុស្ស និងក្របខណ្ឌការងារដើម្បីដោះស្រាយផលប៉ះពាល់នានានៃការប្រែប្រួលអាកាសធាតុ។

ស្ថានភាពនៃការអនុវត្តកម្មវិធីសកម្មភាពជាតិបន្សុំនឹងការប្រែប្រួលអាកាសធាតុ

ដោយលោកបណ្ឌិត ***ហេង ចាន់ឆឿន***
អនុប្រធាន CCD/ MoE

លោកបណ្ឌិត **ចាន់ឆឿន** បានលើកឡើងពីការរៀបចំឯកសារកម្មវិធី NAPA ដែលផ្តល់មូលនិធិដោយ GEF តាមរយៈ UNDP ដោយអនុលោមទៅតាមការសម្រេចក្នុងCoP7។ របាយការណ៍ NAPA លើកទី ១ ត្រូវបានបញ្ចប់ក្នុងខែមីនាឆ្នាំ២០០៥ និងអនុម័តដោយ RGC នៅឆ្នាំបន្ទាប់ (តុលា ២០០៦)។ NAPA ជាកម្មវិធីសកម្មភាពជាតិ និងសកម្មភាពអាទិភាពដែលដោះស្រាយតម្រូវការ និងកង្វល់ជាបន្ទាន់របស់កម្ពុជា ដើម្បីបន្សុំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យសំខាន់ៗដូចជា កសិកម្ម ធនធានទឹក តំបន់ឆ្នេរ និងសុខភាពមនុស្ស។

ការកំណត់អត្តសញ្ញាណ និងការកំណត់អាទិភាពនូវគម្រោងក្រោមកម្មវិធីNAPA ត្រូវបានធ្វើយ៉ាងត្រឹមត្រូវដោយពិភាក្សាជាមួយអ្នកពាក់ព័ន្ធ (កម្រិតជាតិ និងខេត្ត) និងស្របជាមួយទិសដៅអភិវឌ្ឍប្រកបដោយចីរភាពរបស់កម្ពុជា និងអាទិភាពនៃការអភិវឌ្ឍរបស់ RGC និងកត្តាដែលពាក់ព័ន្ធផ្សេងៗទៀត។ សកម្មភាពគម្រោង NAPA បានបែងចែកជាបីប្រភេទសំខាន់ៗដូចជា ការកសាងសមត្ថភាព/វគ្គបណ្តុះបណ្តាល ការលើកកម្ពស់ការយល់ដឹង/ការអប់រំនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ។ ក្នុងចំណោមគម្រោងទាំង ៣៩ របស់ NAPA មានគម្រោងចំនួន ២០

បានចាត់ជាគម្រោងមានអាទិភាពខ្ពស់ (ដែលត្រូវការទឹកប្រាក់ប្រមាណ ១២៨.៨៥០.០០០ ដុល្លា សហរដ្ឋអាមេរិក)។

នាពេលបច្ចុប្បន្ននេះ មានគម្រោង និងកម្មវិធីមួយចំនួនបាន នឹងកំពុងអនុវត្ត ហើយរួមចំណែកលើកម្មវិធី NAPA។ តួយ៉ាងដូចជាការអំពាវនាវឲ្យដាក់សំណើស្រាវជ្រាវពី CCCA TF ដែលមានគម្រោងចំនួន៨ (៦០គម្រោងបានផ្តល់ឯកសារដំបូង) ត្រូវបានអនុម័តថានឹងផ្តល់ជំនួយមានដូចជា ការកសាងផែនការបន្សាំ និងភាពធន់នៅតំបន់ឆ្នេរការលើកកម្ពស់ការគ្រប់គ្រងទឹក និងកសិកម្ម ដែលធន់នឹងអាកាសធាតុនៅក្នុងគម្រោងទីជនបទកម្ពុជា PPCR និងកិច្ចផ្តួចផ្តើមបន្សាំនឹងការប្រែប្រួលអាកាសធាតុ (មូលនិធិធនាគារពិភពលោក)។ លើសពីនេះទៀត មានគម្រោងថ្នាក់តំបន់ទន្លេមេគង្គទាក់ទងនឹងការប្រែប្រួលអាកាសធាតុ ដែលកំពុងអនុវត្តនៅខេត្តព្រៃវែង។

គម្រោងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម (គម្រោងអនុវត្តក្រោមកម្មវិធីNAPA)

*ដោយលោក **ហុក គីមឆួន** ប្រធានគម្រោងថ្នាក់ជាតិ អង្គភាពគាំទ្រគម្រោង MAFF*

លោក **ហុក គីមឆួន** បានផ្តល់នូវសេចក្តីសង្ខេប និងស្ថានភាពនៃគម្រោងដែលអនុម័តក្រោមកម្មវិធី NAPA ស្តីពីការលើកកម្ពស់ការគ្រប់គ្រងធនធានទឹក ដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងការប្រកបរបរកសិកម្ម នៅតំបន់ជនបទកម្ពុជា ដែលជាគម្រោងមានរយៈពេល៤ ឆ្នាំ ហើយបានអនុវត្តតាំងពីឆ្នាំ២០១០ មកនៅតំបន់គោលដៅ ខេត្តព្រះវិហារ និងខេត្តក្រចេះ។ ថវិកាជំនួយសរុប៣.០៩០.៣៥០ ដុល្លាអាមេរិក ដែលផ្តល់ដោយ LDCF UNDP និង RGC។ គោលបំណងចម្បងនៃគម្រោងនេះ គឺការកាត់បន្ថយភាពងាយរងគ្រោះរបស់ វិស័យកសិកម្មនៅកម្ពុជា ដែលជាហេតុនាំឲ្យមានបម្រែបម្រួលធនធានទឹក។ លទ្ធផលរំពឹងទុកសំខាន់ៗរបស់គម្រោងមានដូចជា៖

- កសាងសមត្ថភាពក្នុងស្ថាប័នមូលដ្ឋានលើការគ្រប់គ្រងផលប៉ះពាល់លើវិស័យកសិកម្មធនធានទឹក
- ការកាត់បន្ថយផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ តាមរយៈជម្រើសបន្សាំដែលសមស្របនៅកម្រិតមូលដ្ឋាន
- ធ្វើឡើងវិញនៅតំបន់ដែលងាយរងគ្រោះផ្សេងទៀត ដោយប្រើមេរៀនដែលបានរៀននិងបទពិសោធន៍ដែលមានស្រាប់

លោក **គីមឆួន** បានបន្ថែមថាលក្ខណៈនៃគម្រោងនេះមានភាពខុសប្លែកបន្តិច ដោយសារវាធ្វើទៅតាមប្រព័ន្ធវិមជ្ឈការ និងសហវិមជ្ឈការរបស់រដ្ឋាភិបាល ដូច្នេះថ្នាក់ជាតិគ្រាន់តែរៀបចំគោលការណ៍ណែនាំទាក់ទងនឹងការធ្វើរបាយការណ៍ជាដើម។ ចំណែកថ្នាក់ក្រោមជាតិមានទំនួលខុសត្រូវក្នុងការគ្រប់គ្រងថវិកា និងគម្រោង។ នៅថ្នាក់ជាតិ ការងារនេះត្រូវបានគ្រប់គ្រងដោយ MAFF ក្រោមការគាំទ្រពី UNDP ហើយនៅថ្នាក់ខេត្ត គឺនៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលខេត្ត ដូច្នេះរាល់កិច្ចសន្យាទាំងអស់នឹងត្រូវធ្វើជាមួយរដ្ឋបាលខេត្ត។ គម្រោងនេះនឹងផ្តល់ការគាំទ្រ ចាប់ពីថ្នាក់ឃុំ (កសិករ) ដល់ថ្នាក់ស្រុក ក្រោមកិច្ចសហការជាមួយនឹង CARDI និងអង្គការសង្គ្រោះសត្វព្រៃកម្ពុជា។

លោក **គីមឆួន** បានលើកយកសមិទ្ធិផលសំខាន់ៗ ដែលសម្រេចបានមកបង្ហាញ ដូចជាក្រុមប្រឹក្សាឃុំ និងកសិករបានយល់ដឹងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើការប្រកបរបរកសិកម្ម។ បន្ទាប់មកកម្មវិធីវិនិយោគឃុំនៃស្រុកគោលដៅត្រូវបានបញ្ចូលពីបញ្ហាការ

ប្រែប្រួលអាកាសធាតុ។ ជាមួយភាពជោគជ័យមេរៀនមួយចំនួនត្រូវបានលើកឡើងដែរ ដូចជាការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាអន្តរវិស័យដែលត្រូវការ ការសម្របសម្រួលជាអន្តរវិស័យដំណោះស្រាយបានកំណត់ (កសិកម្ម ធារា-សាស្ត្រ និងយេនឌ័រ) ជាយន្តការដោះស្រាយរយៈពេលខ្លីជាជាងវិធានការបន្សាំ ជម្រុញការលើកកម្ពស់ការយល់ដឹង របស់មន្ត្រីរដ្ឋាភិបាលមន្ត្រីគម្រោង និងកសិករ អំពីការប្រែប្រួលអាកាសធាតុ។ ការបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងនីតិវិធីការងារនៃប្រព័ន្ធវិមជ្ឈការ និងសហវិមជ្ឈការ។

កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា

*ដោយលោក **ស៊ុំ ឆី** ប្រធាននាយកដ្ឋាន CCD និងជាអ្នកសម្របសម្រួលគម្រោងការអភិវឌ្ឍគោលនយោបាយប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងចំណេះដឹងរបស់កម្មវិធី CCCA នៃ MoE*

គោលដៅចម្បងនៃបទបង្ហាញនេះ បានផ្តោតទៅលើសេចក្តីសង្ខេបអំពីកម្មវិធី CCCA។

លោក **ស៊ុំ ឆី** បានថ្លែងថា CCCA គឺជាគំនិតផ្តួចផ្តើមរបស់ពហុម្ចាស់ជំនួយ ដែលមានវិធានមូលនិធិបែបច្នៃប្រឌិត និងទូលំទូលាយក្នុងការឆ្លើយតបនឹងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ កម្មវិធីនេះ ត្រូវបានចាប់ផ្តើមឆ្នាំ២០០៧ ក្រោមការផ្តើមគំនិតដោយ EU ក្នុងការបង្កើតសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុសកល ដើម្បីគាំទ្រដល់ LDCs និងប្រទេសកោះតូចៗ (SISs) ក្នុងការឆ្លើយតបនឹងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។

នាពេលបច្ចុប្បន្ននេះ CCCATF ត្រូវបានគ្រប់គ្រងបណ្តោះអាសន្នដោយ UNDP ហើយនឹងធ្វើការផ្ទេរជាបណ្តើរៗ រហូតរដ្ឋាភិបាលអាចគ្រប់គ្រង និងមានភាពជាម្ចាស់ការពេញលេញ។ ក្រោមការគាំទ្រជាថវិកា ពីសំណាក់ EU SIDA DANIDA និងUNDP កម្មវិធីនេះមាន ថវិកាសរុបចំនួន ៨,៩ លានដុល្លាសហរដ្ឋអាមេរិក និងមានសុពលភាពសម្រាប់រយៈពេល៣ឆ្នាំ។ កម្មវិធីនេះបច្ចុប្បន្នបាន និងកំពុងអនុវត្ត ដោយ CCD នៃ MoE តាំងនាមឲ្យ NCCC ។

លោកក៏បានរៀបរាប់ពីគោលបំណងទូទៅរបស់ CCCA គឺដើម្បីបង្កើតប្រសិទ្ធភាពសម្របសម្រួល និងអនុវត្តយុទ្ធសាស្ត្រសកម្មភាពការងារការប្រែប្រួលអាកាសធាតុ នៅក្នុងប្រទេសកម្ពុជា ដើម្បីឲ្យការងារប្រែប្រួលអាកាសធាតុត្រូវបានដឹកនាំដោយជាតិ និងត្រូវបានអនុវត្តស្របតាមអាទិភាពអភិវឌ្ឍជាតិ។

លោកក៏បានបកស្រាយពីលទ្ធផល និងវឌ្ឍនភាពចម្បងៗរបស់ CCCA ផងដែរ។ លទ្ធផលទី១ គឺការពង្រឹងសមត្ថភាពរបស់ NCCC ក្នុងការសម្របសម្រួលបង្កើត នយោបាយ អភិវឌ្ឍសមត្ថភាព ផ្សព្វផ្សាយព័ត៌មាន និងធ្វើប្រជាមតិ និងតាមដានការអនុវត្តយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុថ្នាក់ជាតិ។ ចំពោះការរីកចម្រើនវិញ មានដូចជា ក្រុមការងារបច្ចេកទេសប្រែប្រួល អាកាសធាតុមួយ ត្រូវបានបង្កើតឡើងដោយស្របតាមរបៀបវារៈ CoP16 និង CSOs។ លើសពីនេះ លោកក៏បានបន្ថែមពីលទ្ធផលមួយរបស់កម្មវិធីក្នុងការផលិតនូវឯកសារទស្សនទាននិងផែនទី បង្ហាញផ្លូវនៃ CCCSP និងមាគ៌ាឆ្ពោះទៅរកការពង្រឹងការផ្សព្វផ្សាយស្តីពីការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុតាមការផ្សព្វផ្សាយរបាយការណ៍ KAP (ចំណេះដឹង ឥរិយាបទ និងការអនុវត្ត) និងការបង្ហោះកម្មវិធីជជែកពិភាក្សាស្តីអំពីការប្រែប្រួលអាកាសធាតុជាច្រើននៅលើកញ្ចក់ទូរទស្សន៍ ជាពិសេស ការផ្តល់នូវការគាំទ្របច្ចេកទេសដល់អ្នកពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ។ លទ្ធផលចុងក្រោយ ដើម្បីគាំទ្រដល់ការកសាងសមត្ថភាពប្រែប្រួលអាកាសធាតុដែលបានផ្តល់ជាមូលនិធិរួចមកហើយតាមរយៈ

ការអំពាវនាវ ឲ្យមានការដាក់ពាក្យស្នើសុំថវិកា លើកទី១ របស់ CCCATF ដែលត្រូវបានបើកនាចុងខែកុម្ភៈនិងត្រូវបានអនុម័តដោយCCCATF។

លោក **ស៊ុំ ឆី** បានបន្តែមថា ជំហានបន្ទាប់របស់កម្មវិធីនឹងអភិវឌ្ឍCCCSP ជាមួយបណ្តាក្រសួងពាក់ព័ន្ធនានា ក៏ដូចជាការរៀបចំវាយតម្លៃសមត្ថភាព និងការអប់រំការប្រែប្រួលអាកាសធាតុរបស់ CCDNCCC និងការអភិវឌ្ឍការអប់រំ ការយល់ដឹង យុទ្ធសាស្ត្រ និងផែនការសកម្មភាព។ លោកក៏បានបន្តែមទៀតថា ការអំពាវនាវឲ្យមានការដាក់ពាក្យស្នើគម្រោងលើកទី២ អាចនឹងបើកនៅចុងឆ្នាំ២០១១ ឬដើមឆ្នាំ ២០១២។

គម្រោងការរៀបចំយុទ្ធសាស្ត្រកម្មវិធីសាកល្បងសម្រាប់ភាពធន់នឹងអាកាសធាតុដំណាក់កាលទី១នៅកម្ពុជា

*ដោយលោក **មាស សុផល** អគ្គនាយករង GDANCP នៃ MoE*

គោលបំណងរួមនៃបទបង្ហាញនេះគឺដើម្បីផ្តល់នូវសេចក្តីសង្ខេបពីការអនុវត្ត និងវឌ្ឍនភាពនៃគម្រោង PPCR នៅកម្ពុជា។

លោក **មាស សុផល** បានបញ្ជាក់ថា ក្នុងដំណាក់កាលទី១របស់គម្រោង គឺដើម្បីវាយតម្លៃ និងពង្រឹងភាពត្រៀមខ្លួនជាស្រេចរបស់ស្ថាប័នសម្រាប់ PPCR/SPCR ដែលផ្តោតសំខាន់លើវិស័យអាទិភាព ៣ សំខាន់ៗរួមមាន ធនធានទឹក កសិកម្ម/ធនធានធម្មជាតិ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជនបទ។ ចំណែកឯដំណាក់កាលទី ២ របស់គម្រោងវិញ គឺផ្តោតទៅលើការអនុវត្តនៃកម្មវិធីយុទ្ធសាស្ត្ររបស់ SPCR ដែលបានកំណត់ទិសដៅលើ វិស័យអាទិភាព ៣ ផ្សេងទៀតរួមមាន ក្របខណ្ឌគោលនយោបាយ ការកសាងសមត្ថភាពស្ថាប័ន និងការអនុវត្តគម្រោងវិនិយោគ។

គោលបំណងរយៈពេលយូរ របស់គម្រោង PPCR មានចំនួន ៣ សំខាន់ៗរួមមាន៖

- ចំណេះដឹង (ក្របខណ្ឌបន្សាំ ការវាយតម្លៃពងាយរងគ្រោះនិងភាពបន្សាំ ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅតាមបែបសហគមន៍ និងភាពបន្សាំ និងភាពបន្សាំផ្អែកលើស្ថានប្រព័ន្ធ)
- ការពង្រឹងសមត្ថភាព
- ការវិនិយោគ

ដំណាក់កាលទី ២ របស់គម្រោង PPCR ត្រូវបានអនុម័តដោយអនុគណៈកម្មាធិការនៃ PPCR នៅក្នុងថ្ងៃទី២៨ ខែមិថុនា នៅក្នុងទីក្រុងខេបថោនប្រទេសអាហ្វ្រិកខាងត្បូង។ លោកបានបញ្ជាក់ផងដែរថា គម្រោងនេះបានទទួលទឹកប្រាក់ចំនួន ៥០ លានដុល្លា សហរដ្ឋអាមេរិក ជាហិរញ្ញប្បទានឥតសំណង និង ៣៦លានដុល្លា សហរដ្ឋអាមេរិកជាឥណទានសម្បទាន ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ ADB។ គម្រោងនេះ នឹងជ្រើសរើសក្រុមហ៊ុន ប្រឹក្សាយោបល់ដើម្បីបង្ក្រាបភាពធន់នឹងអាកាសធាតុដល់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិតាមរយៈការបន្សាំ ការធ្វើផែនការ និងផ្សព្វផ្សាយតាមបែបវិទ្យាសាស្ត្រ ដើម្បីធានាបានថា ដំណាក់កាលទី១ នៃគម្រោងត្រូវបានសម្របសម្រួលបានល្អ ជាមួយនឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។

ជាកិច្ចបញ្ចប់ លោកក៏បានស្នើសុំឲ្យមានកិច្ចសហការឲ្យបានស៊ីជម្រៅថែមទៀតពីក្រសួង NGOs វិស័យឯកជន និងស្ថាប័នអប់រំពាក់ព័ន្ធនានាក្នុងដំណាក់កាលនៃការអនុវត្តគម្រោង។

ការប្រែប្រួលអាកាសធាតុ និងសុខភាព

*ដោយលោក **ភុល ហេរ៉ូ** អនុប្រធាននាយកដ្ឋានការពារ សុខភាព MoH*

ការវាយតម្លៃពី ការប្រែប្រួលអាកាសធាតុ និងសុខភាព ត្រូវបានដឹកនាំដោយនាយកដ្ឋានការពារសុខភាពនៃ MoH និងសម្របសម្រួលដោយ ទីប្រឹក្សាសុខភាពសាធារណៈនៃអង្គការសុខភាពពិភពលោក (WHO)។ គោលដៅរួមនៃការវាយតម្លៃនេះ គឺដើម្បីកសាងសមត្ថភាព និងពង្រឹងប្រព័ន្ធសុខភាពនៅក្នុងប្រទេសនិង ថ្នាក់តំបន់ ដើម្បីការពារសុខភាពមនុស្សពីហានិភ័យដែលមានបច្ចុប្បន្ន និងបានព្យាករណ៍ថានឹងអាចកើតឡើងដោយសារការប្រែប្រួលអាកាសធាតុ។

លោក **ភុល ហេរ៉ូ** បានបង្ហាញថា កម្ពុជាជាប្រទេសមួយ ដែលងាយរងគ្រោះជាខ្លាំងពីផលប៉ះពាល់ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ហើយបន្ទុកជម្ងឺបច្ចុប្បន្ន ដែលងាយកើតឡើងដោយសារ កត្តាអាកាសធាតុមានកម្រិតខ្ពស់។ ផលប៉ះពាល់ចម្បងៗនៃការប្រែប្រួលអាកាសធាតុ មកលើសុខភាពនៅកម្ពុជាដែលត្រូវបានធ្វើអត្តសញ្ញាណថាកម្រិតខ្ពស់ខ្លាំង រួមមាន ជម្ងឺឆ្លង សន្តិសុខស្បៀង ជម្ងឺឆ្លងតាមទឹក អាហារនិងផលវិបាកផ្នែកសុខភាពបណ្តាលមកពីបាតុភូតធាតុអាកាសកំណាច។

វិធីសាស្ត្រ ដែលអនុវត្តក្នុងការវាយតម្លៃនេះ ត្រូវបានកែសម្រួលពីគោលការណ៍ណែនាំរបស់ WHO សម្រាប់ធ្វើការវាយតម្លៃគុណភាពបឋមក្នុងតំបន់ដែលមានធនធានខ្សត់ខ្សោយ។ ជំហាននានា ដែលអនុវត្តក្នុងការវាយតម្លៃរួមដូចជា ដើម្បីកំណត់នូវ អត្តសញ្ញាណអ្នកពាក់ព័ន្ធនានា ការអធិប្បាយអំពីបន្ទុកដែលបច្ចុប្បន្នលើផ្នែកសុខភាពដែលងាយរងឥទ្ធិពលអាកាសធាតុ ដែលរួមបញ្ចូលទាំងក្រុមប្រជាជន និងតំបន់នានា ដែលងាយរងគ្រោះបំផុត និងនិន្នាការរបស់វា នៅពេលអនាគត។ លើសនេះទៅទៀត ក៏មានការប៉ាន់ស្មានអំពីបន្ទុកអវិជ្ជមាន បន្ថែមដែលអាចកើតមានចំពោះសុខភាពបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងការកំណត់អត្តសញ្ញាណ និងការចាត់ជាអាទិភាពនូវសុខភាពសាធារណៈ និងការអន្តរាគមន៍ ថែទាំសុខភាពដើម្បីកាត់បន្ថយបន្ទុកខាងផ្នែកសុខភាព ដែលអាចនឹងកើតមានទៅអនាគត និងយុទ្ធសាស្ត្រតាមដាន វាយតម្លៃបន្ទុកផ្នែកសុខភាព ដែលងាយរងឥទ្ធិពលពីកត្តាអាកាសធាតុ និងអន្តរាគមន៍នានា ដើម្បីដោះស្រាយបន្ទុកទាំងនេះដោយ ធានាឲ្យមានប្រសិទ្ធភាព ជាបន្តក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

លោក **ភុល ហេរ៉ូ** បានបង្ហាញផងដែរថា ការប្រឈមចម្បងៗដែលបានលើកឡើងក្នុងការអនុវត្តវាយតម្លៃ រួមមាន កង្វះខាតសមត្ថភាពសម្រាប់វាយតម្លៃការស្រាវជ្រាវ និងការផ្លាស់ប្តូរព័ត៌មានទាក់ទងអំពីហានិភ័យខាងផ្នែកសុខភាពដែលងាយរងឥទ្ធិពលពីកត្តាអាកាសធាតុ ព្រោះភាពខ្វះខាតទិន្នន័យ និងសមត្ថភាពស្រាវជ្រាវ។ លើសពីនេះដែរ ប្រធានបទអំពីការប្រែប្រួលអាកាសធាតុ គឺជាកិច្ចការអន្តរវិស័យ ប៉ុន្តែវាជាគំនិតថ្មីមួយចំពោះ វិស័យសុខាភិបាល ដែលតម្រូវនូវការបណ្តុះបណ្តាលបន្ថែមពីសក្តានុពលពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ លើសុខភាព។ កម្មវិធី NAPA បានធ្វើអត្តសញ្ញាណគម្រោងបន្ទាំចំនួន៣៩ប៉ុន្តែមានការយល់ឃើញថា បញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គឺជាកង្វល់ខាងផ្នែកបរិស្ថាន ជាជាងខាងផ្នែកអភិវឌ្ឍ ឬសុខាភិបាល។

នៅក្នុងយុទ្ធសាស្ត្របន្ទាំនឹងការប្រែប្រួលអាកាសធាតុ ការលុបបំបាត់ជម្ងឺឆ្លងតាមទឹកដែលត្រូវបានកំណត់ជាអាទិភាពលំដាប់ទី២ ត្រូវបានរាប់បញ្ចូលទាំង កិច្ចសហប្រតិបត្តិការអន្តរជាតិ ការអង្កេតនិងការស្រាវជ្រាវ ការកម្ចាត់ប្រភពចម្លង ការត្រៀមបង្ការការរាតត្បាត ការវិភាគរោគសញ្ញា និងការព្យាបាលនៅក្នុងដំណាក់កាលដំបូងនៃជម្ងឺ។ ចំពោះក្នុងផ្នែកនៃជម្ងឺដែលឆ្លងតាមទឹក និងចំណីអាហារ យុទ្ធសាស្ត្របន្ទាំអាទិភាពលំដាប់ទី១ ត្រូវបានផ្តល់ទៅលើការធ្វើឲ្យប្រសើរឡើងនៃការផ្គត់ផ្គង់ និងការទទួលបាន

ទឹក និងការធ្វើឲ្យប្រសើរឡើងផ្នែកអនាម័យ។ ចំណែកឯអាទិភាពទី២ និងទី៣ ត្រូវបានផ្តោតទៅលើការអប់រំ និងការព្យាបាលជាបន្តបន្ទាប់។

បញ្ហាប្រឈមអនាគត អាចនឹងមានទាំងឥទ្ធិពលដោយផ្ទាល់ និងប្រយោលលើសុខភាពប្រជាជន តាមរយៈបាតុភូតធាតុអាកាសកំណាចកំណើនអសន្តិសុខស្បៀង និងទឹក ភាពក្រីក្រ និងការរំខានដល់ហេដ្ឋារចនាសម្ព័ន្ធ និងបញ្ហាសុខភាព។ ការទទួលខុសត្រូវលើការកាត់បន្ថយផលប៉ះពាល់ផ្នែកសុខភាព ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ គួរតែត្រូវបានចែករំលែក ក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាលទាំងអស់ ហើយរាល់បញ្ហាទាក់ទងនឹងសុខភាព គួរតែត្រូវបានចាត់ទុកជាកិច្ចការអន្តរវិស័យនៃការអភិវឌ្ឍប្រកបដោយចីរភាព ដែលគួរតែត្រូវបានបញ្ជ្រាបទៅក្នុងរាល់គោលនយោបាយសាធារណៈ និងដំណើរការនៃការសម្រេចចិត្តទាំងអស់។

មាគ៌ាឆ្ពោះទៅមុខ គួរតែយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចជា ការបង្កើតក្របខណ្ឌស្ថាប័ន ដើម្បីសម្របសម្រួលរាល់ការឆ្លើយតបនានា ការបង្កើតរបៀបវារៈស្រាវជ្រាវមួយ ការបង្កើនតួនាទី និងសមត្ថភាពក្នុង MoH ដើម្បីអាចដោះស្រាយការប្រឈមនានានៃការប្រែប្រួលអាកាសធាតុ និងសុខភាព និងការចាប់ផ្តើមចាត់ជាអាទិភាព និងការអនុវត្តជម្រើសបន្សាំនានា។

ការប្រែប្រួលអាកាសធាតុ និងសន្តិសុខស្បៀង៖ បរិបទប្រទេសកម្ពុជា

*ដោយ **ឯកឧត្តម ស្រ៊ុន ជារិទ្ធិ** អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ នៃទីស្តីការគណៈរដ្ឋមន្ត្រី*

បទបង្ហាញនេះបានធ្វើការពិនិត្យឡើងវិញនូវផលប៉ះពាល់ជាសក្តានុពលនៃការប្រែប្រួលអាកាសធាតុលើ សន្តិសុខស្បៀង នៅប្រទេសកម្ពុជា និងយុទ្ធសាស្ត្របន្សាំរបស់ក្រុមប្រឹក្សាអភិវឌ្ឍវិស័យកសិកម្ម និងជនបទ (CARD) ក្នុងការដោះស្រាយបញ្ហានោះ។

ឯកឧត្តម **ស្រ៊ុន ជារិទ្ធិ** បានបង្ហាញនូវសេចក្តីសង្ខេបពីទិដ្ឋភាពបច្ចុប្បន្ននៃភាពងាយរងគ្រោះរបស់កម្ពុជា ដោយសារការប្រែប្រួលអាកាសធាតុ។ ភាពងាយរងគ្រោះ សំដៅទៅលើភាពងាយរងការប៉ះទង្គិច ភាពងាយខូចខាត និងសមត្ថភាពបន្សាំ។ ភាពងាយរងការប៉ះទង្គិចអាចមានក្នុងទម្រង់ជាភាពរាំងស្ងួតទឹកជំនន់ និងព្យុះស៊ីក្លូនជាដើម។ ឯកឧត្តម ក៏បានលើកឡើងផងដែរថា នៅពេលមានភាពងាយរងការប៉ះទង្គិច វានឹងបង្កឲ្យមានការខូចខាត ដូច្នេះយើងត្រូវពិនិត្យមើលសមត្ថភាពបន្សាំទៅនឹងឥទ្ធិពលទាំងនោះ ដើម្បីដោះស្រាយបញ្ហាឲ្យបានល្អ ។ កម្ពុជា ជាប្រទេសមួយ ដែលងាយរងគ្រោះដោយសារឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ ប៉ុន្តែឥទ្ធិពលទាំងនោះ គឺកម្រើកមានណាស់។

កម្ពុជា ជាប្រទេសមួយដែលងាយខូចខាតដោយសារតែការប្រែប្រួលអាកាសធាតុសម្រាប់ហេតុផលពីរទៅបីយ៉ាង។ សេដ្ឋកិច្ចរបស់កម្ពុជាពុំទាន់មានលក្ខណៈចម្រុះគ្រប់គ្រាន់ឡើយដែលវាត្រូវពឹងផ្អែកយ៉ាងធ្ងន់ទៅលើ វិស័យមួយចំនួនប៉ុណ្ណោះ។ ឧទាហរណ៍ ៨០% នៃប្រជាជនកម្ពុជាមានជីវភាពរស់នៅ អាស្រ័យនឹងផលិតផលស្រែដែលផ្តល់ទិន្នផលទាប និងបច្ចេកទេសទាន់ភាពសម្បូរបែបនៅឡើយ។ ផលិតកម្មស្រែភាគច្រើនពឹងផ្អែកលើទឹកភ្លៀង ហើយបើសិនមានឥទ្ធិពលពីការប្រែប្រួលអាកាសធាតុកើតមានឡើង នោះប្រជាជននឹងប្រឈមមុខនឹង អសន្តិសុខស្បៀងជាមិនខាន។ ប្រភពសេដ្ឋកិច្ចផ្សេងទៀត ដែលអាចពឹងផ្អែកបានត្រូវបានទទួលមកពី ធនធានព្រៃឈើ និងជលផល ដែលពួកវាជាប្រភពដ៏សំខាន់នៃប្រាក់ចំណូល និងចំណីអាហាររបស់ប្រជាជនក្រីក្រ ប៉ុន្តែធនធានទាំងនោះ ប្រហែលជាទទួលរងនូវឥទ្ធិពល តាមរយៈការប្រើប្រាស់ដែលមិនប្រកបដោយចីរភាព។

សន្តិសុខស្បៀងសំដៅទៅលើភាពអាចរកបាន ភាពទទួលបាន និងការប្រើប្រាស់ស្បៀង។ ឯកឧត្តមក៏បានបញ្ជាក់ផងដែរថា ការប្រែប្រួលអាកាសធាតុនិងសន្តិសុខស្បៀង មានឥទ្ធិពលទៅវិញទៅមក។ ការប្រែប្រួលអាកាសធាតុ ជាលទ្ធផលបណ្តាលឲ្យមានជា អសន្តិសុខស្បៀង ហើយអសន្តិសុខស្បៀងធ្វើឲ្យប្រជាជនមានភាពងាយរងគ្រោះនឹងការប្រែប្រួលអាកាសធាតុ។

ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ អាចធ្វើឲ្យចំនួនសត្វល្អិតបំផ្លាញដំណាំមានការកើនឡើង ដែលអាចបង្កឲ្យមានការថយចុះនូវផលិតភាពកសិកម្ម ប៉ះពាល់ទិន្នផលត្រី ធ្វើឲ្យទឹកក្រោមដីនៅតំបន់ឆ្នេរមានអំបិល ដោយសារការជ្រៀតចូលនៃទឹកសមុទ្រ និងការរួមចំណែកធ្វើឲ្យមានការកើនឡើងជម្ងឺ បណ្តាលមកពីទឹក ដូចជា ជម្ងឺរាគរូស ជាដើម។

ជាកិច្ចបញ្ចប់ ឯកឧត្តម **ស្រ៊ុន ជារិទ្ធិ** បានលើកឡើងយុទ្ធសាស្ត្របន្សាំចំពោះផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើសន្តិសុខស្បៀង ដោយផ្តល់ឲ្យកសិករជាមួយប្រព័ន្ធគ្រប់គ្រងទឹកឲ្យសមស្រប និងមានប្រសិទ្ធិភាព ជាពិសេសប្រព័ន្ធប្រមូលនិងស្តុកទឹក ភាពទទួលបានគ្រាប់ពូជ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ នៅខណៈការជំរុញធនាគារធញ្ញជាតិតាមភូមិ និងការធ្វើ**ពិពិធ**កម្មប្រព័ន្ធកសិកម្ម ដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ការសិក្សាស្រាវជ្រាវអំពី ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើសន្តិសុខស្បៀង និងអាហារូបត្ថម្ភ គួរធ្វើឡើង និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវដល់អ្នកពាក់ព័ន្ធ ដែលធ្វើឲ្យពួកគេមានចំណេះដឹងអំពីបញ្ហា និងយុទ្ធសាស្ត្របន្សាំប្រកបដោយប្រសិទ្ធភាព។

តាមរយៈ CARD RGC បានរៀបចំកសាងនិងអនុម័តយុទ្ធសាស្ត្រជាតិគាំពារសង្គមសម្រាប់ជនងាយរងគ្រោះនិងជនក្រីក្រ។ ក្នុងចំណោមកម្មវិធី និងសកម្មភាពទាំងនោះ កម្មវិធីការងារសាធារណៈបានផ្តល់នូវឱកាសរកប្រាក់ចំណូលនិងស្ថាបនានូវហេដ្ឋារចនាសម្ព័ន្ធ ដែលចាំបាច់ផ្តល់ជូនដល់ប្រជាពលរដ្ឋក្រីក្រ។ លើសពីនេះក៏មានការផ្ទេរសាច់ប្រាក់ដល់ ជនងាយរងគ្រោះដើម្បីការពារកង្វះអាហារូបត្ថម្ភ និងការបាត់បង់ឱកាសអប់រំ។ ការផ្តល់ការធានារ៉ាប់រងសម្រាប់កសិករ ដើម្បីការពារនូវការខូចខាតផលដំណាំដែលបណ្តាលមកពីគ្រោះធម្មជាតិ និងបរាជ័យនៃការដាំដុះផលដំណាំ ក្នុងការកាត់បន្ថយផលប៉ះពាល់នៃទឹកជំនន់ និងគ្រោះរាំងស្ងួតក៏ត្រូវបានគិតគូរពិចារណា។

សំណួរ និងចម្លើយ

លោក **សុខ ពិសិដ្ឋ** មកពី MoWA បានសួរថា តើ CCCATF មានថវិកាសម្រាប់ការអភិវឌ្ឍសមត្ថភាពសម្រាប់ស្ថាប័ន ឬអាជ្ញាធរពាក់ព័ន្ធនានាដែរឬទេ?

លោកបណ្ឌិត **ហេង ចាន់ធឿន** បានទទួលស្គាល់ថា វាជាការពិតណាស់ដែលCCCATF បានបើកទូលាយដល់គ្រប់ស្ថាប័នពាក់ព័ន្ធទាំងអស់ទាំង NGOs និងវិស័យឯកជនអាចដាក់ពាក្យស្នើសុំបាន។ ជាក់ស្តែងក្នុងដំណាក់កាល ១ មានសំណើគម្រោងខ្លី (Concept Note) ចំនួន ៦០ បានដាក់ជូនគណៈកម្មាធិការរបស់ CCCATF សម្រាប់ធ្វើការវាយតម្លៃ។ ក្រោយមកមានសំណើគម្រោងខ្លីចំនួន ១០ ត្រូវបានជ្រើសរើស សម្រាប់ការអភិវឌ្ឍបន្ថែម ទៅជាសំណើគម្រោងពេញលេញ និងដាក់ជូនគណៈកម្មាធិការម្តងទៀត។ ជាលទ្ធផល សំណើគម្រោងចំនួន ៨ ត្រូវបានសម្រេចផ្តល់ហិរញ្ញប្បទានសម្រាប់ការអនុវត្តគម្រោងជាផ្លូវការ សម្រាប់ឆ្នាំនេះ។

លោក **ឌួង សារ៉ាក់** មកពី IFC ចង់បានន្ូវព័ត៌មានលម្អិតទាក់ទងនឹងការបន្សុទ្ធពូជស្រូវ ដោយសួរថា តើគម្រោងធ្លាប់បានធ្វើសកម្ម

ភាពអ្វីខ្លះទាក់ទងនឹងការបន្សុទ្ធព្រៃជស្រូវនេះដែរទេ?

លោក **ហុក គឹមឆួន** បានឆ្លើយតបថា MAFF បាននិងកំពុងធ្វើការយ៉ាងជិតស្និទ្ធជាមួយ CARDI ក្នុងការពិសោធន៍សាកល្បងពីប្រភេទផ្សេងៗរបស់ស្រូវ។ បន្ទាប់ទទួលបានជោគជ័យពីការពិសោធន៍ CARDI នឹងផ្តល់ការគាំទ្រទាំងផ្នែកបច្ចេកវិទ្យា និងហិរញ្ញវត្ថុក្នុងការលើកទឹកចិត្តដល់ការចូលរួមរបស់កសិករ។

លោកបណ្ឌិត **Geoffrey Blate** មកពី **WWF** មានចម្ងល់ថា តើនៅពេលអនាគតមានការសិក្សាពី ចីរភាពនៃការប្រើប្រាស់ទឹកក្រោមដីសម្រាប់ប្រព័ន្ធធារាសាស្ត្រដែរឬទេ?

លោក **ហុក គឹមឆួន** បញ្ជាក់ថាប្រព័ន្ធធារាសាស្ត្រទឹកក្រោមដី មិនមាននៅក្នុងវិសាលភាពនៃការសិក្សារបស់គម្រោងនេះទេ ប៉ុន្តែមានការសាងសង់អាងស្តុកទឹកសម្រាប់ធារាសាស្ត្រ។

លោក **ម៉ែន ប៊ុណ្ណារ៉ា** ពី CI មានចម្ងល់ថា តើមានឯកសារត្រូវបានបោះពុម្ពផ្សាយអ្វីខ្លះទាក់ទងនឹងមេរៀនទទួលបាន ពីការប្រែប្រួលអាកាសធាតុនៅប្រទេសកម្ពុជា?

លោកបណ្ឌិត **ហេង ចាន់ធឿន** បាននិយាយថា របាយការណ៍ស្តីពី "**ការខាយតម្លៃជនបទដែលងាយរងគ្រោះ**" ដែលបង្ហាញពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ ទៅលើកសិករ និងប្រជាជនក្រក្រី បានបោះពុម្ពផ្សាយរួចហើយ។ ជាងនេះទៀត ប័ណ្ណផ្សព្វផ្សាយអំពីការប្រែប្រួលអាកាសធាតុ សម្រាប់លើកកម្ពស់ការយល់ដឹងសម្រាប់ប្រជាជនមូលដ្ឋាន និងការបង្ហាញពីជម្រើសបន្សុំបានរៀបចំរួច ហើយវានឹងត្រូវបានអភិវឌ្ឍបន្ថែមជាឯកសារមេរៀន។ លើសពីនេះ ការចងក្រងឯកសារស្តីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុក៏ត្រូវបានកំពុងរៀបចំ ក្រោមសហប្រតិបត្តិការរវាង MoE និង MoWA ។

លោក **ហ៊ាវ ខាសនា** មកពីក្រុមហ៊ុន ម៉ុង រិទ្ធី បានសួរពីគោលគំនិតរបស់ RGC ក្នុងការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលកម្ពុជាកំពុងប្រឈម?

លោក **ស៊ុំ ធី** បានឆ្លើយថា ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ អាចធ្វើបានតាមមធ្យោបាយពីរ គឺការកាត់បន្ថយ និងការបន្សុំ។ ឧទាហរណ៍ ចំពោះការបន្សុំ វាអាចអនុវត្តបានតាមរយៈការផ្លាស់ប្តូរប្រភេទស្រូវដែលអាចបន្សុំ និងលូតលាស់បានល្អ ក្នុងលក្ខណៈអាកាសធាតុពេលបច្ចុប្បន្ន។ ការកសាងនូវហេដ្ឋារចនាសម្ព័ន្ធដូចជាផ្លូវ ឬស្ពាន ដែលអាចធន់នឹងសេណារីយ៉ូការប្រែប្រួលអាកាសធាតុ គួរយកចិត្តទុកដាក់។

លោក **ហ៊ាវ ខាសនា** មកពីក្រុមហ៊ុន ម៉ុង រិទ្ធី បានលើកសំណួរថា តើរាល់គម្រោងដែលធ្លាប់បានអនុវត្ត និងនឹងត្រូវអនុវត្តមានផែនការធ្វើជាមួយវិស័យឯកជនដែរឬទេ?

លោក **មាស សុជល** បានបញ្ជាក់ថា យុទ្ធសាស្ត្ររបស់ RGC លើការអភិវឌ្ឍមិនអាចព្រងើយកន្តើយពី ការចូលរួមរបស់វិស័យឯកជននោះឡើយ។ ឧទាហរណ៍ ការវិនិយោគឯកជន RGC ជាធម្មតាតែងគិតគូរពីការចូលរួមរបស់ផ្នែកឯកជនក្នុងវិស័យសំខាន់ទាំង៣ គឺហេដ្ឋារចនាសម្ព័ន្ធជនបទ កសិកម្ម និងធារាសាស្ត្រ។

លោក *Liam Fee* មកពី UN-HABITAT បានសួរថា តើទិន្នន័យនៃការវាយតម្លៃសុខភាពអាចរកបានទេ ហើយធ្វើយ៉ាងដូចម្តេចដើម្បីទទួលបានទិន្នន័យទាំងនោះ?

លោក **ភុល ហេរ៉ូ** បានបំភ្លឺថា ការវាយតម្លៃសុខភាពបានធ្វើឡើង ក្រោមសហប្រតិបត្តិការ ជាមួយអ្នកជំនាញមកពីប្រទេសអូស្ត្រាលី

ហើយការវិភាគទិន្នន័យដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ WHO។ ការប្រែប្រួលអាកាសធាតុ មានផលប៉ះពាល់ទៅលើសុខភាពចំនួន៤ ផ្នែកចម្បងៗ ដែលបានធ្វើអត្តសញ្ញាណ រួមមាន ជម្ងឺឆ្លង សន្តិសុខស្បៀង ជម្ងឺឆ្លងតាមទឹក និងអាហារ និងផលវិបាកខាងផ្នែកសុខភាព។ ចំពោះរបាយការណ៍ និងទិន្នន័យអាចរកបានតាមការស្នើសុំ។

លោកបណ្ឌិត *Kien Tran-Mai* មកពី MRC ចង់ដឹងថាតើ លោក **ភុល ហេរ៉ូ** មានទិន្នន័យទាក់ទងនឹងសុខភាពសាធារណៈ ដែលបានចុះបញ្ជីមានរយៈពេលប៉ុន្មានឆ្នាំ? តើមានការសិក្សាទំនាក់ទំនងរវាងទិន្នន័យសុខភាព ជាមួយទិន្នន័យឧតុនិយមដែរឬទេ? ព្រោះវាមានសារសំខាន់ណាស់ក្នុងការបញ្ជាក់បែបបរិមាណវិស័យ ពីទំនាក់ទំនងរវាងប៉ារ៉ាម៉ែត្រសុខភាព និងអាកាសធាតុ។

លោក **ភុល ហេរ៉ូ** បានមានប្រសាសន៍ថា ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ លើសុខភាព ជាបញ្ហាត្តិថ្មីមួយ ហើយមន្ត្រីរបស់ MoH ភាគច្រើន ការយល់ដឹងមានកម្រិតពីបញ្ហានេះ។ ទោះបីជាយ៉ាងណាក៏ដោយ MoH បន្តសហការជា មួយក្រសួងពាក់ព័ន្ធ ដូចជា MoWRAM និង MAFF ដើម្បីធ្វើការសិក្សាបន្ថែមពីការប្រែប្រួលអាកាសធាតុដោយត្រូវគិតទាំងពីប្រវត្តិ និងការព្យាករណ៍ទៅអនាគត។

លោក **សំ ចាន់ធី** មកពី SEI បានសួរថា អ្វីខ្លះអាចនឹងត្រូវបានអនុវត្តលើទម្រង់នៃការប្រើប្រាស់ដីធ្លី ដើម្បីធានាបានសន្តិសុខស្បៀងឲ្យបានត្រឹមត្រូវ ដោយមិនបង្កផលប៉ះពាល់ដល់បរិស្ថាន?

ឯកឧត្តម **ស្រ៊ុន ជារិទ្ធិ** បានបញ្ជាក់ថា ការធ្វើផែនការប្រើប្រាស់ដីធ្លីបានល្អ គឺជាចម្លើយពីព្រោះដើម្បីផ្តល់ទិន្នផលបានល្អ ដំណាំត្រូវការប្រភេទដីមួយជាក់លាក់ ដែលត្រូវនឹងប្រភេទដំណាំនោះ។ បើសិនប្រភេទដីមិនសមស្របនឹងដំណាំទេ ត្រូវតែផ្លាស់ប្តូរទីកន្លែងផ្សេងទៀត ។

ភគ្គស្របតា ទី១

ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ស្ថានភាព ការរីកចម្រើន មេរៀនទទួលបាន ភាពខ្វះចន្លោះផ្នែកគោលនយោបាយ និងអនុសាសន៍

សហប្រធាន៖

១. ឯកឧត្តមបណ្ឌិត ***សាត សាមី*** រដ្ឋលេខាធិការ MIME និងជាអនុប្រធានNCCC

២. ឯកឧត្តម ***ឆេង គីមស៊ុន*** ប្រតិភូ RGC ទទួលបន្ទុកជាប្រធានFA

ស្ថានភាពនិងចក្ខុវិស័យនៃទីផ្សារកាបូនស្ម័គ្រចិត្ត

*ដោយអ្នកស្រី **Marion Verles** នាយកប្រតិបត្តិក្រុមហ៊ុនណិចស៊ីសកាបូនសម្រាប់អភិវឌ្ឍន៍*

បទបង្ហាញនេះ បានផ្តល់នូវព័ត៌មានអំពីសាវតានៃការកកើត VCM និងពិនិត្យឡើងវិញនូវស្ថានភាព និងចក្ខុវិស័យរបស់វានៅក្នុងស្រុក និងលើពិភពលោក ហើយផ្តល់នូវអនុសាសន៍គោលនយោបាយមួយចំនួន សម្រាប់ឲ្យកម្ពុជាត្រៀមខ្លួនក្នុងការចូលរួម VCM ពេលអនាគត។

អ្នកស្រី Verles បានរៀបរាប់ថា Nexus ជាសហគមន៍នៃប្រតិបត្តិករមិនសំដៅប្រាក់កម្រៃលើការអភិវឌ្ឍ ដែលនឹងបន្តរួមចំណែកការកាត់បន្ថយភាពក្រីក្រ និងការបំភាយGHGs តាមរយៈ ការបង្កើត ច្រកចូលហិរញ្ញប្បទានអាកាសធាតុដើម្បីអនុវត្តន៍គម្រោងអាកាសធាតុប្រកបដោយសមភាព និងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងភាពត្រឹមត្រូវ តម្លាភាព និងភាពទទួលខុសត្រូវ។ Nexus ក៏ផ្តល់ជូនផងដែរនូវមូលនិធិសម

ស្រប សម្រាប់ការផ្សព្វផ្សាយទ្រង់ទ្រាយធំអំពីបច្ចេកវិទ្យាកាបូនកម្រិតទាប ដែលគាំទ្រជនក្រីក្រ។ លើសពីនេះNexus ជាវេទិកាភាពជាដៃគូដល់ប្រតិបត្តិករ ដែលប្រកបដោយការទទួលខុសត្រូវ រាប់បញ្ចូលទាំងក្រុមហ៊ុនឯកជន គ្រឹះស្ថាន ឬបុគ្គលឯកជននានា។

អ្នកស្រីបានកំណត់និយមន័យ ហិរញ្ញប្បទានកាបូនថា គឺជាការផ្ទេរនូវធនធានពីប្រទេសអភិវឌ្ឍទៅ DCs ដើម្បីចំណាយលើការឆ្លើយតបនឹងផលប៉ះពាល់ពី ការប្រែប្រួលអាកាសធាតុ។ ហិរញ្ញប្បទានកាបូនអាចទទួលបានពី ពាណិជ្ជកម្មឥណទានការបញ្ចេញឧស្ម័នCDM ការអនុវត្តរួមគ្នា (JI) និងVCM។ ជាទូទៅ VCM សមស្របនឹងហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងទីផ្សារជាប់កាតព្វកិច្ច។ ភាពខុសគ្នាមួយចំនួនរវាង CDM និង VCM។ ជាគោលការណ៍ VCM មានភាពបត់បែនជាងក្នុងការអនុវត្ត បើធៀបនឹង CDM ឧទាហរណ៍ដូចជាដំណើរការមិនស្មុគស្មាញនៅក្រោមពិធីសារក្យូតូ មានកំហិតតិចពី UNFCCC បទដ្ឋានផ្សេងៗ និងរយៈពេលនៃដំណើរការចុះឈ្មោះខ្លី និងថោកជាង។ បន្ថែមលើនេះទៀត VCM អាចជាការស្ម័គ្រចិត្ត ឬមានអាណត្តិ និងអាចអនុវត្តបានទាំងប្រទេសដែល ផ្តល់សច្ចាប័ន និងមិនផ្តល់សច្ចាប័នលើពិធីសារក្យូតូ។ អ្នកស្រីបង្ហាញទិន្នន័យសំខាន់មួយចំនួនទៅលើកំណើន VCM ដែលបានបង្ហាញថា ១៣១ $MtCO_2e$ ត្រូវបានធ្វើពាណិជ្ជកម្មនៅក្នុងឆ្នាំ២០១០ កើនឡើង ៣៥% ធៀបនឹងឆ្នាំ ២០០៩ និងតម្លៃជាមធ្យមគឺ ៦ដុល្លា អាមេរិក/tCO_2e។

អ្នកស្រី ក៏បានរៀបរាប់ពីគម្រោង VCM មានស្រាប់ និងកំពុងអនុវត្តនៅកម្ពុជា រួមមាន GERES ICS (VCS) NBP/SNV ឡជីវឧស្ម័នតាមផ្ទះ (VGS) REDD នៅឧត្តរមានជ័យ (CCB និង VCS) និងចម្រោះទឹក (VGS)។ អ្នកស្រីបានបញ្ជាក់ថា យន្តការថ្មីដែលអនុវត្តក្នុងVCM ប្រហែលជាត្រូវបានទទួលយកដោយ CDM ក្នុងពេលប៉ុន្មានឆ្នាំខាងមុខទៀត។ VCM អាចក្លាយជាកាលានុវត្តភាពល្អសម្រាប់កម្ពុជា ជាពិសេសសម្រាប់វិស័យកសិកម្ម និងព្រៃឈើ។ ទោះជាយ៉ាងណា ក៏ការទាក់ទាញការបណ្តាក់ទុនពីសំណាក់វិស័យឯកជន ការគិតគូរផលចំណេញដល់ជនក្រីក្រ កង្វះវិធីសាស្ត្រសម្រាប់គម្រោងប្រើប្រាស់ដីធ្លី និងភាពប្រាកដប្រជាពី តម្លាភាព និងភាពត្រឹមត្រូវ គឺសុទ្ធតែជាបញ្ហាប្រឈមដែលត្រូវតែពិចារណា។

អ្នកស្រីបានផ្តល់យោបល់ថា អនាគត VCM អាចនឹងមានភាពប្រសើរឡើង។ និន្នាការចម្បងបីដែលឃើញក្នុង VCM ដោយសារទីផ្សារជាប់កាតព្វកិច្ចបច្ចុប្បន្នដាក់កម្រិតដល់ LCDs ហើយ VCM ត្រូវបានរំពឹងទុកថានឹងរីកដុះដាលនៅក្នុង DCs ការអនុវត្តយន្តការពាណិជ្ជកម្មក្នុងស្រុកនឹងកើនឡើង និងការកើនឡើងនូវចំណង់របស់ក្រុមហ៊ុនឯកជន មិនមែនជាប្រធានបទដែលឈានទៅដល់កាបូនណឺត ឬអាកាសធាតុល្អទេ។ ទោះជាយ៉ាងណាក៏ដោយ ហានិភ័យនៃភាពមិនប្រាកដប្រជាអាចនៅតែកើតមាន។

ទីផ្សារកាបូនជាប់កាតព្វកិច្ច៖ ពិធីសារក្យូតូឈានទៅយន្តការទីផ្សារថ្មីៗ

*ដោយអ្នកស្រី **Akiko Fukui***
ជំនួយការស្រាវជ្រាវនៃក្រុមយន្តការទីផ្សារ អង្គការ IGES

យន្តការក្យូតូសំខាន់ៗ ដែលមានក្រោមទីផ្សារជាប់កាតព្វកិច្ច និងស្ថានភាពរបស់វាត្រូវបានវាយតម្លៃ និងសក្តានុពលយន្តការទីផ្សារនាពេលអនាគតក៏ត្រូវបានលើកមកពិភាក្សាផងដែរ (ពិធីសារក្យូតូក្រោយឆ្នាំ ២០១២ REDD+ និងសំណើសំខាន់ៗមួយចំនួនរបស់ភាគីជាសមាជិក UNFCCC)។

យោងទៅតាមរបាយការណ៍ WB អ្នកស្រី Fukui បានបង្ហាញថា ក្នុងចន្លោះពេលពីឆ្នាំ

២០០៨-២០១១ ពិធីសារក្យូតូត្រូវការCERsចំនួន ១៣៩២ $MtCO_2$ ក៏ប៉ុន្តែការផ្គត់ផ្គង់ CERs ជាក់ស្តែងក្នុងឆ្នាំ ២០១០ បានត្រឹមតែ ៥០០Mt CO_2 ដែលជិតស្មើនឹង១/៣នៃតម្រូវការរបស់ពិធីសារក្យូតូ។ លើសពីនេះ ទិន្នន័យរបស់ IGES បានបង្ហាញថា ចំនួនចុះឈ្មោះក្នុង CDM និងបរិមាណ CERs បានកើតឡើងឆាប់រហ័សពីចុងឆ្នាំ ២០១០។

មេរៀន ដែលទទួលបានអាចយកមកពិចារណាសម្រាប់ជំហានបន្ទាប់ គឺរបាយមិនស្មើគ្នានៃប្រភេទគម្រោង និងប្រទេស ឧទាហរណ៍ ៥៦% នៃគម្រោង CDM ត្រូវបានអនុវត្តនៅប្រទេសចិន ហើយគម្រោងវារីអគ្គីសនី និងថាមពលខ្យល់គ្របដណ្តប់ប្រមាណ ៥២% នៃគម្រោងសរុប។ ជាងនេះទៀត មិនអាចគ្របដណ្តប់វិធានការកាត់បន្ថយ បានពេញលេញដោយសារសកម្មភាពគម្រោង និងកម្មវិធីនៅមានកម្រិត។ បញ្ហាចុងក្រោយ គឺដំណើរការចុះបញ្ជីគម្រោង និងចេញឥណទានមានការលំបាក និងត្រូវការរយៈពេលវែង។ ដូចនេះ បញ្ហាទាំងអស់នេះមានភាពចាំបាច់ ក្នុងការធ្វើឲ្យប្រសើរឡើង ដើម្បីផ្តល់ជាឱកាសក្នុងការកាត់បន្ថយចំណាយ និងបន្តសកម្មភាពកាត់បន្ថយដែលចាំបាច់។

ដោយពិធីសារក្យូតូនឹងត្រូវផុតកំណត់នឆ្នាំ២០១២ ដូចនេះ ការលើកកម្ពស់ CDM និងយន្តការទីផ្សារថ្មីត្រូវបាន និងកំពុងពិចារណាសម្រាប់ក្រោយឆ្នាំ២០១២។ យន្តការទីផ្សារអាចពិភាក្សាតាមចរន្តពីរដូចជា៖ AWG-ពិធីសារក្យូតូ (ក្រុមការងារពិសេស ស្តីពីការប្តេជ្ញាបន្ថែមទៀតសម្រាប់ភាគីក្នុងឧបសម្ព័ន្ធI ក្រោមពិធីសារក្យូតូ) និង AWG-LCA (ក្រុមការងារពិសេសស្តីពីសកម្មភាពសហប្រតិបត្តិការរយៈពេលវែង នៅក្រោមអនុសញ្ញានេះ)។

អ្នកស្រីបានណែនាំពីធាតុផ្សំ ដែលអាចមាននៅក្នុងយន្តការទីផ្សារថ្មី ដោយផ្អែកលើការពិភាក្សានៅក្នុង AWG-LCA និងការដាក់ជូនពីបណ្តាភាគីកាលពីចុងខែកុម្ភៈ ។ ដើម្បីពង្រីកសកម្មភាព ត្រូវការសមាសភាគជាច្រើន ដូចជាសកម្មភាពកាត់បន្ថយ តាមគោលនយោបាយសមស្របជាតិ (NAMA) យន្តការសកម្មភាពតាមវិស័យដូចជា គមនាគមន៍ និងថាមពល និងយន្តការថ្មីមួយទៀត គឺ REDD+។ ឥណទានត្រូវបានចេញក្រោយពេលសកម្មភាពកាត់បន្ថយបានអនុវត្ត ហើយគ្មានការជាកពិន័យក្នុងករណីមានការបញ្ចេញឧស្ម័នលើស។ ជាឧទាហរណ៍ ប្រទេសកូរ៉េបានស្នើការបង្កើតយន្តការឥណទាន NAMA។ នៅខណៈការធ្វើពាណិជ្ជកម្មការបូនត្រូវបានបែងចែកជាមុន និងក្នុងករណីការបញ្ចេញឧស្ម័នលើស អង្គភាព ឬក្រុមហ៊ុននោះត្រូវទិញឥណទានការបូនពីប្រទេសណា ដែលសម្រេចតាមគោលដៅ និងនៅសល់បរិមាណនៃការបញ្ចេញឧស្ម័ន។ នៅក្នុងបរិបទអភិបាលកិច្ច រួមមានប្រព័ន្ធវិមជ្ឈការ និងសហវិមជ្ឈការ។ ចំពោះរដ្ឋាភិបាលវិមជ្ឈការ ក្រុមប្រឹក្សាផ្តល់យោបល់ស្នើដោយ EU ហើយមានលក្ខណៈស្រដៀងគ្នាទៅនឹងក្រុមប្រឹក្សាប្រតិបត្តិ CDM ដែលមានអាជ្ញាធរ ដើម្បីបង្កើតជាវិធាន និងសម្រេចលើការធានាឥណទាន។ នៅក្រោមយន្តការទ្វេភាគី និងឯកត្តោភាគី រដ្ឋាភិបាលនៃប្រទេសនីមួយៗមានអំណាច ហើយប្រព័ន្ធនេះត្រូវបានគេរំពឹងថានឹងធ្វើឡើង ដោយផ្អែកលក្ខខណ្ឌជាក់លាក់របស់ប្រទេសនីមួយៗ។

ស្ថានភាពយន្តការទីផ្សារបច្ចុប្បន្ន កំពុងមានភាពរីកចម្រើន ដោយមានភាគីចំនួន ២២ បានផ្តល់ជាគំនិតទៅលើយន្តការទីផ្សារថ្មីកាលពីខែកុម្ភៈ ឆ្នាំ២០១១ និងការសម្រេចក្នុងការបង្កើតយន្តការទីផ្សារមួយ ឬច្រើន។ យន្តការទីផ្សារថ្មីនេះ នឹងមានតម្រូវការក្រោយឆ្នាំ២០១២ហើយសង្ឃឹមថា នៅពេលអនាគតវិធានការ សម្រាប់ការគាំទ្រដល់សកម្មភាពកាត់បន្ថយ នៅបណ្តា

DCs នឹងមានភាពបត់បែន និងមានប្រសិទ្ធភាពជាងមុន

ស្ថានភាពបច្ចុប្បន្ននៃយន្តការអភិវឌ្ឍន៍ស្អាតនៅប្រទេសកម្ពុជា

*ដោយលោក**អ៊ុយ ភាម៉ាល**ប្រធានការិយាល័យសារពើភ័ណ្ឌ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ MoE*

លោក **ភាម៉ាល** បានធ្វើបទបង្ហាញពីស្ថានភាពបច្ចុប្បន្ននៃការអនុវត្តគម្រោង CDM នៅកម្ពុជា ដោយសង្ខេបពីសារតាដែលទាក់ទង CDM ស្ថានភាពបច្ចុប្បន្ននៃCDM និងសកម្មភាពទៅអនាគតសម្រាប់កម្ពុជា។

កម្ពុជាបានផ្តល់សច្ចាប័នដល់ UNFCCC នៅឆ្នាំ១៩៩៥ បានចុះហត្ថលេខាពិធីសារក្យូតូនៅឆ្នាំ២០០២ និងបង្កើតការិយាល័យប្រែប្រួលអាកាសធាតុ និងស្ថាប័នទទួលបន្ទុក CDM នៅឆ្នាំ ២០០៣។ ទាំងនជាចំណុចចាប់ផ្តើមដែលធ្វើឲ្យគម្រោង CDM អាចអនុវត្តបាននៅកម្ពុជា។ ក្នុងការអនុវត្ត CDM ប្រទេសនៅក្នុងឧបសម្ព័ន្ធ I អាចវិនិយោគលើគម្រោងដែលអាចកាត់បន្ថយការបញ្ចេញ GHGs នៅក្នុងប្រទេស ដែលមិនស្ថិតក្នុងឧបសម្ព័ន្ធ I ហើយទទួលបានការកាត់បន្ថយឧស្ម័នដែលបានបញ្ជាក់ (CERs) ដែលអាចរាប់បញ្ចូលក្នុងគោលដៅគម្រោងកាត់បន្ថយរបស់ប្រទេសឧបសម្ព័ន្ធIចំណែកDCs នឹងទទួលបានផលប្រយោជន៍ តាមរយៈការវិនិយោគ និងបន្ទេរបច្ចេកវិទ្យាពីប្រទេសជឿនលឿន។ ការប្រើយន្តការបត់បែននៃពិធីសារក្យូតូក្នុងបំណងកាត់បន្ថយការបញ្ចេញ GHGs តាមរយៈ JI (ប្រទេសឧបសម្ព័ន្ធ I និងប្រទេសឧបសម្ព័ន្ធ II) CDM (ប្រទេសឧបសម្ព័ន្ធ I និងប្រទេសមិនស្ថិតក្នុងឧបសម្ព័ន្ធI) និងពាណិជ្ជកម្មការបំភាយ (ប្រទេសឧបសម្ព័ន្ធ I និងប្រទេសឧបសម្ព័ន្ធ II)។ ក៏ប៉ុន្តែនៅកម្ពុជាមានតែ CDM ដែលអាចអនុវត្តបាន។

តាមគោលការណ៍ CDM គឺ [១] ការចូលរួមដោយស្ម័គ្រចិត្តពីភាគីដែលពាក់ព័ន្ធ [២] មានលក្ខណៈពិតប្រាកដ អាចវាស់វែងបាន និងមានផលប្រយោជន៍រយៈពេលវែង ទាក់ទងនឹងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ [៣] ការកាត់បន្ថយការបញ្ចេញ GHGs គឺជាបន្ថែមលើគម្រោងទាំងឡាយណា ដែលអាចកើតឡើងក្នុងករណីអវត្តមានគម្រោង CDM និង [៤] ទទួលបានការអភិវឌ្ឍប្រកបដោយចីរភាព។

មានលក្ខណៈវិនិច្ឆ័យចម្បងបួន សម្រាប់គម្រោង CDM ដែលអនុវត្តនៅកម្ពុជារួមមាន៖

- កិច្ចការពារ និងកែលម្អបរិស្ថាន
- ការបង្កើនប្រាក់ចំណូល និងលើកស្ទួយជីវភាព
- ការផ្ទេរបច្ចេកវិទ្យា
- ផលប្រយោជន៍សេដ្ឋកិច្ច

កម្ពុជាជាប្រទេសមួយនាំមុខគេ បើធៀបទៅនឹង DPs ផ្សេងទៀត ដោយមានគម្រោង CDM ចុះបញ្ជីចំនួន ៥ ត្រឹមខែកញ្ញា ឆ្នាំ២០១១ (គម្រោងចំនួន ៥ ក្នុងចំណោមគម្រោង ២១)។ លោក **ភាម៉ាល** បានរាយការណ៍ថា គម្រោង CDM មានស្រាប់នៅកម្ពុជា រួមមាន ជីវឧស្ម័ន ថាមពលវារីអគ្គីសនី ការប្រើប្រាស់សំណល់/ឧស្ម័នកម្តៅ និងជីវម៉ាស់។

លោក **ភាម៉ាល** បានបញ្ជាក់ថា ចំនួនកិច្ចសន្យា សម្រាប់ការអភិវឌ្ឍគម្រោង CDM មានការកើនឡើងគួរឲ្យកត់សម្គាល់ក្នុងឆ្នាំនេះ។ នាពេលថ្មីៗនេះ ក្រោមកិច្ចសហប្រតិបត្តិការរវាងក្រសួងបរិស្ថាន និង IGES បានសិក្សារៀបចំព័ត៌មានគោល សម្រាប់បណ្តាញអគ្គីសនីរាជធានីភ្នំពេញ និងស្តង់ដាគោលសម្រាប់អនុវត្តជាមួយនឹងប្រព័ន្ធឧស្ម័នកម្ម ដោយប្រើអង្កាម ក្នុងចេតនា ដើម្បីបង្កើនគម្រោង CDM ដែលទាក់ទងនឹងវិស័យនេះ។

ជាចុងបញ្ចប់លោកបានរៀបរាប់ពីសកម្មភាពបន្តនាពេលអនាគត ដើម្បីពង្រីកការអភិវឌ្ឍគម្រោង CDM នៅកម្ពុជា ដែលរួមមាន៖

- ពង្រឹងការលើកកម្ពស់ការយល់ដឹង
- បន្តស្រាវជ្រាវ និងកំណត់គម្រោង និងដៃគូដែលមានសក្តានុពលបន្ថែមទៀត
- រៀបចំ និងសិក្សាពីលទ្ធភាពគម្រោង
- ពង្រឹងកម្មវិធីស្រាវជ្រាវ និងការអភិវឌ្ឍនៃសកម្មភាព និងយន្តការទីផ្សារកាបូនថ្មីៗផ្សេងទៀត និង
- ពង្រីកបណ្តាញជាមួយដៃគូ ដែលមានសក្តានុពលសម្រាប់ហិរញ្ញប្បទាន ការបណ្តាក់ទុន ការសម្របសម្រួល ការអនុវត្តជម្រើសកាត់បន្ថយឈ្មុះ-ឈ្មុះ។

គម្រោងថាមពលពីអង្កាម ANGKOR BIOCOGEN

ដោយលោក Adisorn Chieu នាយកគ្រប់គ្រងក្រុមហ៊ុនអង្គរ Bio-Cogeneration

លោក **Chieu** បានផ្តល់បទបង្ហាញពីភាពជោគជ័យនៃការអនុវត្តគម្រោង CDM ដែលផលិតថាមពលអគ្គីសនី ដោយប្រើប្រាស់អង្កាមចេញពីរោងម៉ាស៊ីនកិនស្រូវនៅកម្ពុជា។ គម្រោង CDM មួយអាចផលិតអគ្គីសនីបានរហូតដល់ ២MW ។ គម្រោងនេះមានសកម្មភាពចម្បងពីរគឺ៖

១.បញ្ចៀសការបញ្ចេញឧស្ម័នមេតាន ពីការបំបែកតាមបែបជីវសាស្ត្រនៃអង្កាមដែលចាក់ចោលក្នុងករណីអវត្តមានគម្រោង CDM នេះ

២. ជំនួសការប្រើប្រាស់ឥន្ធៈហ្វូស៊ីល ប្រេងម៉ាស៊ូតសម្រាប់បង្កើតថាមពលនៅក្នុងរោងម៉ាស៊ីនកិនស្រូវផ្ទាល់

លោកក៏បានបង្ហាញពីតួលេខមួយចំនួនអំពីបរិមាណនៃការកាត់បន្ថយការបញ្ចេញឧស្ម័នប្រចាំឆ្នាំពីគម្រោង CDM នេះផងដែរ។ បរិមាណកាត់បន្ថយការបញ្ចេញឧស្ម័ន CO_2 គឺ ៣.៧២៩ tCO_2 ស្មើនឹងការកាត់បន្ថយ ៦,៧៤% ធៀបនឹងការបញ្ចេញឧស្ម័នគោល ៥៥.៣៤៩ tCO_2។

លោកក៏បានពន្យល់ពី សកម្មភាពនានារបស់គម្រោង ចាប់តាំងពីដំណាក់កាលចាប់ផ្តើមរហូតរោងចក្រមានដំណើរការ ដោយប្រើប្រាស់ឯកសារវីដេអូ។ ដំណាក់កាលដំបូង គម្រោងបានប្រឹក្សាជាមួយប្រជាជនមូលដ្ឋាន មុនចាប់ផ្តើមការសាងសង់ នៅក្នុងឆ្នាំ២០០៦ ដែលសម្ភារៈតម្លើងរោងចក្រអគ្គីសនីភាគច្រើន ផលិតនៅប្រទេសថៃ និងដឹកជញ្ជូនមកកម្ពុជាដោយរថយន្ត។

លោកបានកត់សម្គាល់ថា នេះគឺជាលើកទី១ នៅលើពិភពលោក ដែលប្រើប្រាស់បច្ចេកវិទ្យា TORBED ដើម្បីដុតអង្កាម។ ជាលទ្ធផលអង្កាម ដែលឆេះសព្វថ្ងៃត្រូវបានបំលែងជាស៊ីលីកាគ្មានទ្រង់ទ្រាយពិតប្រាកដ។ អ្វីដែលគួរឲ្យចាប់អារម្មណ៍នោះគឺ ផេះស៊ីលីកាគ្មានទ្រង់ទ្រាយពិតប្រាកដនេះ ជាធាតុផ្សំយ៉ាងសំខាន់ដើម្បីផលិតបានជាបេតុងរឹងមាំល្អ។ លោកក៏បានផ្តល់ជាយោបល់ដ៏មានសារសំខាន់ថា CDM អាចធ្វើឲ្យគម្រោងទទួលបានជោគជ័យ ពីព្រោះបើគ្មាន CDM ទេ គ្មាននរណាម្នាក់ហ៊ានវិនិយោគទុនលើគម្រោងនេះដែរ។ បន្ថែមពីនេះ អ្នកវិនិយោគទុនអាចទទួលបានផលចំណេញ តាមរយៈការលក់ CERs។

ចុងក្រោយ លោកបានលើកអនុសាសន៍សំខាន់ៗលើគោលការណ៍CDM រួមមាន៖

- ភាពបត់បែនបាននៃការផ្ទៀងផ្ទាត់ ព្រោះរោងចក្រខ្លះអាចមានសេចក្តីលំអិតខ្លះខុសពីគម្រោងដំបូង
- ភាពបត់បែនកាន់តែខ្លាំងនៅក្នុងអំឡុងពេលចាប់ផ្តើមនៃដំណាក់កាលទទួលឥណទាន ដូចជាការអនុញ្ញាតឲ្យកែប្រែ

ពេលចាប់ផ្តើមដំណាក់កាលឥណទាន លើសពីមួយដង។

ផែនទីបង្ហាញផ្លូវអំពីកម្មវិធីREDD+ របស់ប្រទេសកម្ពុជា

*ដោយលោកបណ្ឌិត **កែវ អូម៉ាលីស***
អនុប្រធាននាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ FA/MAFF

បទបង្ហាញនេះបានពន្យល់ពី សារតាំងណើរការ គោលបំណង ផ្នែកសំខាន់ៗ អ្នកដើរតួនាទីសំខាន់ៗ ស្ថានភាពនាពេលបច្ចុប្បន្ន និងជំហានបន្ទាប់នៃផែនទីបង្ហាញផ្លូវ REDD+ របស់ប្រទេសកម្ពុជា។

លោកបណ្ឌិត **អូម៉ាលីស** បានកំណត់និយមន័យ REDD+ ជាកម្មវិធីមួយដែលនាំមកចំណូលថវិកាបន្ថែមពីវិស័យព្រៃឈើ តាមរយៈការការពារព្រៃឈើ ដោយមានប្រទេសដែលបានបញ្ចេញឧស្ម័នខ្ពស់ជាអ្នកទិញឥណទានកាបូន។ REDD+ គ្របដណ្តប់សកម្មភាពចម្បងៗចំនួនប្រាំដូចជា៖

- កាត់បន្ថយការបញ្ចេញឧស្ម័ន ពីការកាប់ព្រៃឈើ
- កាត់បន្ថយការបញ្ចេញឧស្ម័ន ពីការរិចរិលព្រៃឈើ
- អភិរក្សអាងស្តុកកាបូនព្រៃឈើ
- ការគ្រប់គ្រងព្រៃឈើដោយចីរភាព និង
- បង្កើនអាងស្តុកកាបូនព្រៃឈើ

REDD+ រួមចំណែកកាត់បន្ថយនូវផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ពីការកាប់ព្រៃឈើ និងការរិចរិលព្រៃឈើ ដែលរួមចំណែកប្រហែលជា ១៧% នៃការបញ្ចេញឧស្ម័នសរុបលើពិភពលោក។ REDD+ មានសារសំខាន់សម្រាប់ការអនុវត្តនៅកម្ពុជា ដោយទី១ REDD+ ស្របជាមួយគោលនយោបាយនិងទិសដៅរបស់ RGC ពិសេសការប្តេជ្ញាចិត្តរក្សាគម្របព្រៃឈើ។ ទី២ REDD+ ជាផ្នែកមួយស្ថិតក្រោម UNFCCC និងជាចុងក្រោយ REDD+ នឹងផ្តល់នូវការគាំទ្រផ្នែកសេដ្ឋកិច្ច សង្គម និងបរិស្ថាន ជាពិសេសការអភិរក្សព្រៃឈើ និងសត្វព្រៃ។

បើក្រឡេកមើលទៅស្ថានភាព REDD+ នៅពិភពលោកវិញ លោកបណ្ឌិត**អូម៉ាលីស** បានរាយការណ៍ថា REDD+ ត្រូវបានអនុម័តនៅក្នុង CoP13 CoP15 និង CoP16 នៅក្រោម UN FCCC។ ស្ថិតក្រោមក្របខណ្ឌការងារនេះ ប្រទេសអភិវឌ្ឍបានសន្យា និងផ្តល់នូវជំនួយរាប់លានដុល្លាអាមេរិកដល់ DCs តាមរយៈយន្តការទ្វេភាគី និងពហុភាគី។ ទោះបីយ៉ាងនេះក៏ដោយ យន្តការហិរញ្ញវត្ថុ នៅតែមិនទាន់ច្បាស់លាស់។ បច្ចុប្បន្ននេះ កម្ពុជាទទួលបានថវិកាពីរ ឬបីលានដុល្លាអាមេរិក ពីប្រទេសអភិវឌ្ឍន៍ ដើម្បីការអនុវត្ត REDD+នេះ។

នៅកម្ពុជាយន្តការ REDD+ ត្រូវបានបញ្ចូលក្នុងគោលនយោបាយជាច្រើន ដូចជា NSDP (២០០៩-២០១៣) និងកម្មវិធីព្រៃឈើជាតិ (២០១០-២០២៩)។ កម្ពុជាបានក្លាយជាសមាជិក FCPF ខែមីនា ឆ្នាំ២០០៩ UNREDD ខែតុលា ឆ្នាំ២០០៩ និងភាពជាដៃគូក្នុងកម្មវិធី REDD+ ខែឧសភា ឆ្នាំ២០១០។ ថ្មីៗនេះមានគម្រោងចំនួន៣ កំពុងអនុវត្ត ដែលស្ថិតនៅខេត្តឧត្តរមានជ័យ មណ្ឌលគីរី (កែវសីមា) និងតំបន់ភ្នំក្រវាញភាគខាងត្បូង។ លើសពីនេះ ផែនទីបង្ហាញផ្លូវស្តីពី REDD+ ត្រូវបានអភិវឌ្ឍ។

ផែនទីបង្ហាញផ្លូវREDD+ត្រូវបានកំណត់ជាផែនការរៀបចំ និងគ្រប់គ្រងដំណើរការត្រៀមលក្ខណៈពីកម្មវិធី REDD+ សម្រាប់រយៈពេល ៣-៥ឆ្នាំ។ នេះគឺជាជំហានដំបូងឆ្ពោះទៅរកការបង្កើតយុទ្ធសាស្ត្រជាតិស្តីពី REDD+ នៅកម្ពុជា និងអាចជាឯកសារយោងស្វែងរកថវិកាជំនួយ។

ក្រុមការងាររៀបចំផែនទីបង្ហាញផ្លូវ មាន MAFF MoE ក្រសួងរៀបចំដែនដី នគរូបនីយកម្ម

និងសំណង់ ដែលមាន RECOFTC និងមូលនិធិផ្លូចផ្តើមការងារប្រែប្រួលអាកាសធាតុCLINTON ចូលរួមជាអ្នកអង្កេត។ ប្រភពមូលនិធិចម្បងៗ បានមកពី FAO UNDP និង UNEP។ លោកបណ្ឌិតបានបន្ថែមទៀតថា នៅក្នុងដំណើរការបង្កើតផែនទីបង្ហាញផ្លូវនេះ សិក្ខាសាលាពិគ្រោះយោបល់ និងកិច្ចពិភាក្សាមិនផ្លូវការជាមួយតំណាងសង្គមស៊ីវិល និងជនជាតិដើមភាគតិចក៏បានអនុវត្តផងដែរ។

ផែនទីបង្ហាញផ្លូវនេះ បានបញ្ចប់នៅឆ្នាំ ២០១០ ហើយឥឡូវឈានមកដល់ដំណាក់កាលអនុវត្តផែនទីបង្ហាញផ្លូវនេះ នៅក្នុងអំឡុងឆ្នាំ ២០១១-២០១៤ ហើយរំពឹងទុកថានឹងអនុវត្ត REDD+ ពេញលេញចាប់ពីឆ្នាំ២០១៥។

លោកបណ្ឌិត **អូម៉ាលីស** ក៏បានសង្ខេបពីផ្នែកសំខាន់ៗ ដែលមាននៅក្នុងផែនទីបង្ហាញផ្លូវ REDD+ចំនួន ៦ ដូចជា៖

- ការត្រៀមលក្ខណៈគ្រប់គ្រង REDD+
- ការពិគ្រោះយោបល់ និងការចូលរួមពីអ្នកពាក់ព័ន្ធ
- ការជ្រើសរើសយុទ្ធសាស្ត្រជាតិស្តីពី REDD+
- ក្របខណ្ឌអនុវត្តន៍
- ការបង្កើតកម្រិតការបញ្ចេញឧស្ម័នគោលពីព្រៃឈើ និង
- ការបង្កើតប្រព័ន្ធត្រួតពិនិត្យ

លោកបណ្ឌិត ក៏បានផ្តល់នូវស្ថានភាពថវិកាជំនួយដល់សកម្មភាព REDD+ នៅកម្ពុជាផងដែរ។ ឧទាហរណ៍ ថវិកាចំនួន ១០លានដុល្លាអាមេរិកបានពីរដ្ឋាភិបាលជប៉ុន ២លានដុល្លាអាមេរិកពី JICA (សម្រាប់រយៈពេល ៥ ឆ្នាំ) ៣លានដុល្លាអាមេរិកពី UNREDD និង ៣.៦លានដុល្លាអាមេរិកពី FCPF (សម្រាប់រយៈពេល ៣ឆ្នាំ)។

ជម្រើសគោលនយោបាយសម្រាប់REDD+ នៅតំបន់ការពារធម្មជាត

*ដោយលោក **David Ashwell** ជំនាញការឯករាជ្យ*

គោលបំណងនៃបទបង្ហាញនេះ គឺផ្តោតលើលទ្ធផលនៃករណីសិក្សាថ្មីៗ ដែលបានរៀបចំដោយមជ្ឈមណ្ឌលសម្រាប់គោលនយោបាយខ្យល់ស្អាត(ការគិតពីអាងស្តុកតាមបែបWashington) ស្តីពីជម្រើសគោលនយោបាយសម្រាប់ការអនុវត្ត REDD+ ក្នុងតំបន់ការពារធម្មជាតិ។

លោក **Ashwell** បានលើកឡើងថា កម្ពុជា មានតំបន់ព្រៃឈើដ៏ស្រស់ស្អាតជាច្រើន និងមានប្រព័ន្ធតំបន់ការពារធម្មជាតិដ៏ធំ ដែលគ្របដណ្តប់ប្រហែលជា ២៥% នៃផ្ទៃប្រទេស ដែលធំល្មមនឹងអាចហៅថា ប្រព័ន្ធតំបន់ការពារធម្មជាតិខ្នាតអន្តរជាតិ។ ក្នុងឆ្នាំ២០០៧ គម្រោងគ្រប់គ្រងជីវចម្រុះ និងតំបន់ការពារធម្មជាតិបានត្រួតពិនិត្យឡើងវិញពី ភាពតំណាងនៃជីវចម្រុះ ហើយជាទូទៅមានលក្ខណៈល្អ ពីព្រោះមានប្រភេទព្រៃឈើជាច្រើនជាតំណាង រួមទាំងប្រភេទសត្វ ដែលមានសារសំខាន់ជាអន្តរជាតិសម្រាប់ការអភិរក្ស ដែលស្ថិតក្នុងតំបន់ការពារធម្មជាតិទាំងនោះ។ ប៉ុន្តែភាពខ្វះចន្លោះមួយចំនួនត្រូវបានកំណត់ ដូចជា ព្រៃស្រោងស្ងួត ស្ថានប្រព័ន្ធតំបន់ថ្មកំបោរ តំបន់ទំនាបលិចទឹកស្ទឹងសែន និងស្ថានប្រព័ន្ធដែនកោះ និងសមុទ្រ។ យោងទៅតាមរបាយការណ៍ត្រួតពិនិត្យ អាចសន្និដ្ឋានបានថា កម្ពុជាមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីអភិរក្សជីវចម្រុះជាតិ ដែលមានដោយសារតែវាត្រូវបានបែងចែកជា តំបន់ស្នូល និងតំបន់អភិរក្ស និងគាំទ្រដោយតំបន់គ្រប់គ្រងបន្ថែម។

ការបែងចែកជាតំបន់គ្រប់គ្រងទាំងនោះ រួមមាន តំបន់ស្នូល តំបន់អភិរក្ស តំបន់ប្រើប្រាស់ច្រើនយ៉ាង និងតំបន់សហគមន៍មូលដ្ឋាន ដែលនឹងត្រូវបកស្រាយដូចខាងក្រោម៖

តំបន់ស្នូល៖ ជាតំបន់មានគុណតម្លៃខ្ពស់ខាងអភិរក្សប្រភេទសត្វ និងរុក្ខជាតិកម្រ ជិតផុតពូជ ងាយរងគ្រោះ និងរងការគម្រាម កំហែង និងប្រព័ន្ធអេកូឡូស៊ីដែលផុយស្រួយ។

តំបន់អភិរក្ស៖ ជាតំបន់មួយនៅជាប់នឹងតំបន់ស្នូល ដែលមានតម្លៃសម្រាប់ការអភិរក្សធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី ទីជម្រាល និងតំបន់ទេសភាពធម្មជាតិ។

តំបន់ប្រើប្រាស់ច្រើនយ៉ាង៖ ជាតំបន់មួយដែលមានគុណតម្លៃខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដែលជាប្រយោជន៍ដោយផ្ទាល់សម្រាប់គោលបំណងនៃការគ្រប់គ្រង និងការអភិរក្ស PAs ។

តំបន់សហគមន៍មូលដ្ឋាន៖ ជាតំបន់ដែលបម្រើការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់សហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិច។ លោកជឿជាក់ថា FA អាចមានយន្តការបែងចែកជាតំបន់ស្រដៀងគ្នានេះដែរ។

លោក Ashwell បានអះអាងថា តំបន់ការពារធម្មជាតិប្រហែលជា ៥១% បានរងការខូចខាត ដោយផលប៉ះពាល់នានា ព្រមទាំងងាយរងគ្រោះដោយសារការរំខាន និង ៥៧% ស្ថិតនៅទីតាំងដាច់ស្រយាលជាតំបន់ ដែលព្រៃឈើទទួលការរំខានខ្ពស់។ គោលនយោបាយពណ៌ខៀវបានរៀបរៀងរួចរាល់ ហើយអាចជាជម្រើសគោលនយោបាយ ដែលបង្ហាញពីរបៀបអភិវឌ្ឍតំបន់ការពារធម្មជាតិ គាំទ្រដល់កម្មវិធី REDD ជាតិ។ ក្រសួងបរិស្ថានបានប្រើលទ្ធផលនេះ ជាជំនួយសម្រាប់ដំណើរការរៀបចំផែនទីបង្ហាញផ្លូវ។ សមាសធាតុរបស់គោលនយោបាយពណ៌ខៀវ គួរតែមាន៖

- គោលការណ៍រួម
- ធាតុសំខាន់ៗនៃគោលនយោបាយ
- ឧបសគ្គ និងការប្រឈម និង
- គោលការណ៍ណែនាំសម្រាប់អនុវត្ត

លោក Ashwell បានចែករំលែកលទ្ធផលអំពី ការវិភាគតម្លៃឱកាសការប្រើប្រាស់ដីកសិកម្មក្នុងតំបន់ឆ្នេរ។ លទ្ធផលបានបង្ហាញថា ជា មធ្យមសម្រាប់ការពារស្តុកកាបូន គឺស្ថិតចន្លោះ ពី៥ ទៅ ១២,៥ដុល្លាអាមេរិក/តោន ដើម្បីទូទាត់តម្លៃទីផ្សារនៃផលិតផល ពោត សណ្តែកសៀង និងស្រូវ។ តម្លៃនេះ គឺខ្ពស់ជាងតម្លៃភាគច្រើននៃ VCM បច្ចុប្បន្ន និងតម្លៃទីផ្សារជាប់កាតព្វកិច្ចដែលទំនងអាចផ្តល់ហិរញ្ញវត្ថុខ្ពស់ជាងសម្រាប់ប្រទេសមួយ។ ក្រៅពីនេះ ផលចំណូលបន្ថែមអាចបាន តាមរយៈការបង្កើនអាងស្តុកកាបូន តាមរយៈការស្តារព្រៃឈើឡើងវិញ។

បន្ទាប់មកសមាសធាតុចម្បងៗនៃគោលនយោបាយត្រូវបានពន្យល់លម្អិតខាងក្រោម៖

[១] គោលការណ៍សម្រាប់បង្កើតគោលនយោបាយ៖ កម្មវិធី REDD+ គួរតែរក្សា និងពង្រឹងគុណតម្លៃកាបូន និងជីវចម្រុះនៅក្នុងតំបន់ការពារធម្មជាតិ និងព្រៃការពារ គួរជាអាទិភាពព្រៃធម្មជាតិក្នុងតំបន់ការពារធម្មជាតិ រាប់បញ្ចូលទាំងព្រៃចំណាស់ និងព្រៃរិចរិល ដែលជាអាងស្តុកកាបូន កាត់បន្ថយការប្រែប្រួលអាកាសធាតុ អន្តរកម្មរវាង REDD និង CBD គួរត្រូវបានពង្រឹង ដើម្បីគ្រប់គ្រងតំបន់តំបន់ការពារធម្មជាតិនៅថ្នាក់ជាតិ ស្រុក និងកម្រិតមូលដ្ឋាន បញ្ចូលយុទ្ធសាស្ត្រស្តានប្រព័ន្ធ ដែលមានគោលបំណងធានាការពារតំបន់ទេសភាព ជាមួយនឹងការភ្ជាប់គ្នារវាងតំបន់ធម្មជាតិនានា។

[២] ធាតុគោលនយោបាយ រួមមានប្រព័ន្ធដែនការជាតិស្តីពី តំបន់ការពារធម្មជាតិ (NPASP) ការស្តារតំបន់ព្រៃរិចរិលឡើងវិញ ការចាត់ជាតំបន់គ្រប់គ្រង ការធ្វើវិមជ្ឈការ និងរចនាសម្ព័ន្ធមូលនិធិ។

ដែនការ NPASP គួរតែចាត់ជាអាទិភាពតម្រូវការកិច្ចការពារ កំណត់អត្តសញ្ញាណ ការគម្រាមកំហែងដល់តំបន់ការពារធម្មជាតិនីមួយៗ ដែលមាននាពេលបច្ចុប្បន្ន និងទំនងជានឹងកើត

មាននាពេលអនាគត និងការបញ្ចូលនូវប្រព័ន្ធទាំងអស់ កំណត់អត្តសញ្ញាណការគម្រាមកំហែង ចំពោះតំបន់ការពារនីមួយៗ ប្រើប្រាស់ការកំណត់តំបន់គ្រប់គ្រងជាវិធាន ដើម្បីរួមបញ្ចូលកម្រង ដែលមានប្រសិទ្ធភាពការធ្វើផែនការ និងការអនុវត្តនៅថ្នាក់តំបន់ និងថ្នាក់ជាតិ (ប្រហែលជាអាចបន្តយថ្លៃចំណាយ)។

ការស្ដារព្រៃឈើតំបន់ប្រើប្រាស់ច្រើនយ៉ាងនៃព្រៃឈើរិចរិល និងបន្ទាប់បន្សំសមស្របសម្រាប់ការស្ដារ និងការបង្កើតឡើងវិញនូវតំបន់ព្រៃឈើធម្មជាតិ ប្រព័ន្ធគ្រប់គ្រងពាក់កណ្ដាលធម្មជាតិ(កសិរុក្ខកម្មផ្អែកលើប្រព័ន្ធអ៊ីប្រ៊ីត) និងប្រព័ន្ធគ្រប់គ្រងខ្លាំងក្លា (កសិរុក្ខកម្មឡូត៍ព្រៃឈើជាមួយនឹងវនប្បកម្ម)។

ការប្រៀបធៀបប្រព័ន្ធកំណត់តំបន់ជាមួយនឹងគោលបំណង REDD+ បានបកស្រាយដូចខាងក្រោម៖

<u>ប្រើប្រាស់ការកំណត់តំបន់</u> ជាវិធានដើម្បីរួមបញ្ចូលកម្រង ដែលមានប្រសិទ្ធភាពការ ធ្វើផែនការ និងការអនុវត្តនៅថ្នាក់តំបន់ និងថ្នាក់ជាតិដើម្បីការពារ និងពង្រឹងអាងស្តុកកាបូន។

<u>តំបន់ប្រើប្រាស់ច្រើនយ៉ាង</u> រាប់បញ្ចូលទាំងតំបន់កេរមរតក និងវប្បធម៌ជាតិ តំបន់ទេសចរណ៍ធម្មជាតិ តំបន់អភិរក្សសត្វព្រៃ តំបន់សេវាកម្មបម្រើការកំសាន្ត តំបន់ស្ដារស្ថានភាពជីវសាស្ត្រឡើងវិញជាដើម ហើយការពង្រឹងអាងស្តុកកាបូន អាចផ្តល់នូវផលចំណេញសេដ្ឋកិច្ចសម្រាប់ការប្រើប្រាស់ដី នៅក្នុងតំបន់ប្រើប្រាស់ច្រើនយ៉ាង ដែលគាំទ្រគុណតម្លៃការអភិរក្ស និងសហប្រយោជន៍ផ្សេងទៀត។

<u>ការចាត់ជាអាទិភាពសម្រាប់វិនិយោគលើការស្ដារឡើងវិញ៖</u> ទីមួយ ប្រព័ន្ធកំណត់តំបន់គ្រប់គ្រង ផ្តល់នូវឱកាសសម្រាប់ពង្រឹងអាងស្តុកកាបូនក្រោមក្របខណ្ឌការងារ REDD តាមរយៈការពង្រឹងអាងស្តុកកាបូនក្នុងតំបន់ព្រៃមិនរិចរិល នៅក្នុងតំបន់ស្នូល តំបន់អភិរក្ស និងការស្ដារព្រៃឈើឡើងវិញ និងការរក្សាទុកព្រៃឲ្យលូតលាស់ឡើងវិញអាចផ្តោតលើតំបន់ស្នូល តំបន់អភិរក្ស និងតំបន់ប្រើប្រាស់ច្រើនយ៉ាង ប្រព័ន្ធគ្រប់គ្រងបែបនេះត្រូវកំហិតត្រឹម តំបន់ប្រើប្រាស់ច្រើនយ៉ាង និងតំបន់សហគមន៍មូលដ្ឋាន។ ទីពីរ តំបន់ដែលរិចរិលខ្លាំង និងមិនអាចស្ដារឡើងវិញបាន គួរតែពិចារណាដាក់នៅក្រៅតំបន់ការពារធម្មជាតិ។

<u>វិមជ្ឈការ៖</u> លោក Ashwell ពោលថា REDD+ មិនមែនជាដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានទេ។ តែសម្រាប់តម្រូវការរយៈពេលវែង ដើម្បីធានានូវចីរភាព ត្រូវមានការវិនិយោគលើការកសាងសមត្ថភាពខាងស្ថាប័ន ការចាត់ចែង និងការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិ ដូចជា ភូមិ ឃុំ និងស្រុក ។ ភាពបរាជ័យនឹងនាំមកនូវការខូចខាតផលប្រយោជន៍ជាក់ស្តែង និងប៉ះពាល់ដល់អ្នកពាក់ព័ន្ធទាំងអស់។ ការបែងចែកផលប្រយោជន៍តម្រូវឲ្យ <u>ទីមួយ</u> ផលចំណេញពីការអភិរក្សព្រៃឈើត្រូវបានបែងចែកស្មើគ្នា និងតម្លាភាពទៅអ្នកដែលចូលរួមការងារនេះ <u>ទីពីរ</u> ការប្រើប្រាស់គុំនូនផលចំណូលទ្វេគុណដើម្បីទ្រទ្រង់ការចិញ្ចឹមជីវិតដោយចីរភាព និងការវិនិយោគលើពេលវេលា និងធនធានរបស់សហគមន៍លើសកម្មភាពប្រើប្រាស់ដែលមានចីរភាព និង <u>ទីបី</u> ការទទួលបានឥណទានកាបូនជាទៀតទាត់មានសារសំខាន់ណាស់សម្រាប់អ្នកពាក់ព័ន្ធទាំងអស់។

<u>រចនាសម្ព័ន្ធមូលនិធិ</u> មានដៃនកំណត់ខ្លះក្នុងការបញ្ចូលគ្នារវាងមូលនិធិ សម្រាប់អភិរក្ស ក្រោមអនុសញ្ញាស្តីពីជីវចម្រុះនិង REDD+។ ប្រការនេះ គួរធានានូវភាពស៊ីសង្វាក់គ្នាក្នុងការគ្រប់គ្រងតំបន់តំបន់ការពារធម្មជាតិ និងអាចអនុវត្តបានតាមរយៈកម្រង ឬតាមតំបន់តំបន់ការពារធម្មជាតិនីមួយៗ ឬតំបន់ធំជាងនេះ ឧទាហរណ៍ នៅទិសឥសាននៃប្រទេសកម្ពុជា។

លើសពីនេះ យុទ្ធសាស្ត្រ REDD ថ្នាក់ជាតិ ដែលរួមមានវត្តបំណងផ្សេងៗ (ឧទាហរណ៍ ជីវចម្រុះ ការអភិវឌ្ឍនៅមូលដ្ឋានជនជាតិដើម)នឹងកាន់តែមានការទាក់ទាញទឹកចិត្តពីសំណាក់ម្ចាស់ជំនួយអន្តរជាតិ និងទំនងអាចទទួលការគាំទ្រមូលនិធិបន្ថែម។

[៣] ឧបសគ្គ និងការប្រឈមនានា ត្រូវបានលើកមកពិភាក្សាក្នុងកម្រិតពីរផ្សេងគ្នា គឺ កម្រិតម៉ាក្រូ និងកម្រិតមីក្រូ។ កម្រិតម៉ាក្រូផ្តោតទៅលើ ការគ្រប់គ្រង ការគម្រាមកំហែង ការកសាងផែន ការប្រើប្រាស់ដីនៅថ្នាក់ជាតិ និងតំបន់ព្រំប្រទល់ និងការពង្រឹងច្បាប់មិនទាន់បានស៊ីជម្រៅ។ ខណៈកម្រិតមីក្រូ ផ្តោតលើការគ្រប់គ្រងធនធាន សមត្ថភាពឆ្លើយតបនៅមានកម្រិត សម្រាប់ដោះស្រាយបញ្ហា និងកង្វះខាតការតាមដានដោយភាគីទីបី។

[៤] គោលការណ៍ណែនាំការអនុវត្តគោលនយោបាយ វាមានសារសំខាន់ណាស់ក្នុងការប្រើប្រាស់រចនាសម្ព័ន្ធវិមជ្ឈការ ដើម្បីអនុវត្តនៅថ្នាក់ក្រោមជាតិ។ ទាក់ទងនឹងបញ្ហានេះ នាយករដ្ឋមន្ត្រីបានស្នើឲ្យក្រសួងពាក់ព័ន្ធរិះរកវិធី ដែលធ្វើឲ្យរាល់គម្រោងទាំងអស់ចុះសម្រុងគ្នា នៅអាជ្ញាធរថ្នាក់ក្រោមជាតិ ដែលនេះគឺជា ឱកាសមួយដ៏គួរឲ្យចាប់អារម្មណ៍។ ប៉ុន្តែ វានឹងជាបញ្ហាប្រឈមសម្រាប់អ្នកអនុវត្ត ដោយសារតែការផ្តល់សេវាកម្មផ្តោតទៅលើអ្វីដែលជារូបីយ៍ ដូចជាផ្លូវថ្នល់ សាលារៀន និងសេវាកម្មសុខ ភាព ខណៈការគ្រប់គ្រងធនធានធម្មជាតិវិញ ស្មុគស្មាញ ដែលប្រជាជនត្រូវយល់ព្រមលើមុខងារអ្វី ដែលគាត់ចង់ឲ្យមានក្នុងការគ្រប់គ្រងធនធានធម្មជាតិក្នុងសហគមន៍។ គោលការណ៍ណែនាំបច្ចេកទេស ការបង្កើតក្របខណ្ឌអេកូឡូស៊ីមានសារសំខាន់ សម្រាប់ការចាត់ថ្នាក់ព្រៃឈើ ពីព្រោះថា ចំណាត់ថ្នាក់បច្ចុប្បន្នមានភាពទូលំទូលាយ និងមានប្រភេទព្រៃឈើច្រើន។ ប្រសិនបើយើងត្រូវការស្តារព្រៃឈើឡើងវិញ តម្រូវការកែសម្រួលចំណាត់ថ្នាក់ព្រៃឈើឡើងវិញ ដើម្បីជាមូលដ្ឋានក្នុងការកំណត់យុទ្ធសាស្ត្រសមស្របសម្រាប់ការស្តារព្រៃឈើឡើងវិញ។ ជាមួយនេះ តម្រូវការខ្លាំង ក្នុងការបង្កើនមុខងារប្រព័ន្ធព័តមានភូមិសាស្ត្រ និងព្រំដែនសមហេតុផលនៃតំបន់ការពារធម្មជាតិ និងតំបន់គ្រប់គ្រងដែលអាចទទួលស្គាល់ និងប្រតិបត្តិបាន។

សំណួរ និងចម្លើយ

លោកស្រី **ឌឹម កល្យាណី** អនុប្រធានមន្ទីរនៃមន្ទីរបរិស្ថានខេត្តព្រះសីហនុ បានសួរទៅក្រុមហ៊ុន Angkor Cogen អំពីការពង្រឹង និងពង្រីកប្រតិបត្តិការនៅកន្លែងផ្សេងទៀត នៅក្នុងប្រទេសកម្ពុជា ដោយសារភាពសម្បូរអង្កាមនៅស្ទើរគ្រប់ទីកន្លែង។

អ្នកចូលរួមឆោទជាសំណួរ (CCCA, ២០១១)

លោក ***Adisorn Chieu*** បានឆ្លើយតបថា មានក្រុមហ៊ុនមួយបាន និងកំពុងអនុវត្តគម្រោង (នីតិវិធីបំលែងជាឧស្ម័ន) សម្រាប់រោងចក្រថាមពលតូចមួយ នៅខេត្តព្រះសីហនុ ដោយប្រើប្រាស់អង្កាម ឬអុស និងសមត្ថភាពរបស់វាប្រហែលជា ២០០MW ។

លោកស្រី **អ៊ឹម ផល្លី** មកពី NGO Forum បានផ្តល់អនុសាសន៍ថា ការពិគ្រោះយោបល់អំពី REDD+ គួររាប់បញ្ចូលឲ្យបានទូលំទូលាយ ជាពិសេសជនជាតិភាគតិច ដែលជាអ្នកការពារព្រៃឈើ។ លើសពីនេះទៀត សម្ភារៈអប់រំគួរតែត្រូវបានបកប្រែជាភាសាជាតិ និងគួររចនា ឬរៀបចំដោយបញ្ចូលរូបភាព ដែលអាចយល់បានដោយជនជាតិដើម ដែលចូលរួមក្នុងកិច្ចអភិរក្សព្រៃឈើ និងក្នុងការអភិវឌ្ឍផែនទីបង្ហាញផ្លូវ REDD។

លោកបណ្ឌិត **កែវ រ៉ូម៉ាលីស** បានឆ្លើយតបថា ក្នុងដំណើរការអភិវឌ្ឍផែនទីបង្ហាញផ្លូវ REDD កម្ពុជាត្រូវបានចាត់លំដាប់លេខ ១ ដោយវិទ្យាស្ថានធនធានពិភពលោក។ នៅក្នុងដំណាក់កាលដំបូងនៃការអនុវត្តផែនទីបង្ហាញផ្លូវ REDD យើងក៏បានគិតគូរដែរពីការចូលរួម និងពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។ លោកបណ្ឌិត ក៏បានយល់ស្របទាំងស្រុង ជាមួយនឹងសំណូមពរលើការរចនា និងរៀបចំសម្ភារៈអប់រំផ្សព្វផ្សាយ ដោយបញ្ចូលរូបភាពងាយៗយល់ដល់ជនជាតិភាគតិច និងសហគមន៍មូលដ្ឋានដែលមិនអាចអានបាន។ បន្ថែមលើក្រុមការងារផែនទីបង្ហាញផ្លូវថ្នាក់ជាតិ ជនជាតិភាគតិច និង CSOs បានមានវត្តមានជាតំណាងនៅក្នុងក្រុមប្រឹក្សាយោបល់ ដែលចូលរួមនៅក្នុងការរៀបចំសម្ភារៈអប់រំនេះបានបង្ហាញថា ថ្នាក់ក្រោមជាតិមិនអាចញែកដាច់ចេញពីថ្នាក់ជាតិបានឡើយ។

លោក **ឈួស សីហា** មកពីក្រុមហ៊ុន SAK បានសួរថា ប្រសិនបើក្រុមហ៊ុនចង់ដាំព្រៃឈើដើម្បីលក់ជាឥណទានកាបូន តើក្រុមហ៊ុនត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណពីអាជ្ញាធរ ឬក្រសួងណា (MoE ឬ MAFF)ដែរ?

ឯកឧត្តម **ឆេង គីមស៊ុន** បានផ្តល់យោបល់ថា ការដាំព្រៃឈើ និងការលក់ឥណទានកាបូនស្ថិតក្នុង CDM ដែលវាមានសក្តានុពលសម្រាប់វិស័យថាមពល ខណៈវិស័យព្រៃឈើ REDD+ គឺជាជម្រើសមួយ។ ប្រសិនបើគម្រោងស្ថិតក្នុងតំបន់ការពារធម្មជាតិទាំង ២៣ កន្លែងដូច្នេះ ក្រុមហ៊ុនត្រូវទាក់ទង MoE ជាស្ថាប័នទទួលបន្ទុក ចំណែកតំបន់ក្រៅនោះ ត្រូវទាក់ទងជាមួយនឹង FA ។

ថ្ងៃទី២៖ ថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១១

សុន្ទរកថាគមន៍

*ដោយ**លោក** Peter J. Brimble*
សេដ្ឋកិច្ចវិទូជាន់ខ្ពស់នៃ ADB

លោក **Petter J. Brimble** បានសម្តែងការស្វាគមន៍ ចំពោះអ្នកចូលរួមទាំងឡាយ និងមានប្រសាសន៍ថា ការប្រែប្រួលអាកាសធាតុ គឺជាការប្រឈមមួយ ក្នុងចំណោមការប្រឈមចម្បងៗចំពោះមនុស្សជាតិ។ កម្ពុជា បាននិងកំពុងជួបប្រទះផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដែលបណ្តាលពីការប្រែប្រួលអាកាសធាតុ ដូចជា ព្យុះកេតសាណា និងគ្រោះទឹកជំនន់ ដែលកើតមាននៅទូទាំងប្រទេស។

លោកបានលើកឡើងថាភាពពុំអនុគ្រោះជាក់ស្តែងនៃការប្រែប្រួលអាកាសធាតុ គឺថាអ្នកក្រនឹងរងគ្រោះជាងគេ។ ក្នុងនាម LDCs កម្ពុជាងាយរងគ្រោះជាខ្លាំង ដោយសារផលប៉ះពាល់ទាំងនេះ។ ដូច្នេះ ADB ផ្តល់ការគាំទ្ររបស់ខ្លួនដល់កម្ពុជា។ អាទិភាពចំបងមួយនៃយុទ្ធសាស្ត្ររបស់ ADB ឆ្នាំ ២០២០ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គឺផ្តល់ការគាំទ្រដល់បណ្តាប្រទេសជាសមាជិករបស់ ADB ដែលរាប់បញ្ចូលទាំងប្រទេសកម្ពុជា ហើយបានកំណត់អត្តសញ្ញាណអាទិភាពប្រតិបត្តិចំនួនប្រាំ ដើម្បីដោះស្រាយទាំងការកាត់បន្ថយការបញ្ចេញ GHGs និងការបន្សាំ រួមមានការពង្រីកថាមពលស្អាត លើកទឹកចិត្តការអភិវឌ្ឍទីក្រុង និងដឹកជញ្ជូនប្រកបដោយ

ចីរភាព ពង្រឹងសម្របកាបូន តាម រយៈការប្រើដី ដែលមានចីរភាពព្រៃឈើ និងកសិកម្មលើក កម្ពស់ការអភិវឌ្ឍ ដែលធន់នឹងអាកាសធាតុ និង ការពង្រឹងស្ថាប័ន អភិបាលកិច្ចគោលនយោ បាយ និងសមត្ថភាព ដើម្បីដោះស្រាយការប្រែ ប្រួលអាកាសធាតុ។

លោក **Petter J. Brimble** ក៏បាននិយាយ ដែរថា ADB បាននិងកំពុងគាំទ្រដល់ RGC ក្នុង វិស័យផ្សេងទៀតដោយផ្តល់អត្ថប្រយោជន៍យ៉ាង ច្រើនដល់ផ្នែកអាកាសធាតុ និងការអភិវឌ្ឍ។ គម្រោងនោះរួមមាន គម្រោងថាមពលកកើត ឡើងវិញ និងប្រសិទ្ធភាពថាមពល ប្រព័ន្ធដឹក ជញ្ជូនសាធារណៈ ការអភិវឌ្ឍទីក្រុងសមស្រប នឹងអាកាសធាតុ បង្កើនសម្របកាបូន និងការ អភិរក្សជីវចម្រុះ។ លើសពីនេះទៀត ផ្នែកលើ យុទ្ធសាស្ត្រភាពដៃគូក្នុងប្រទេសសម្រាប់ឆ្នាំ២០ ១១-២០១៣ADB នឹងជួយកម្ពុជាដូចជា៖

- បញ្ហាបការប្រឈមនៃការប្រែប្រួលអា កាសធាតុក្នុងការវិភាគវិស័យ និងការ កសាងផែនការ និងការបង្កើតគម្រោង
- បន្តបង្កើតអភិក្រមល្អជាងមុនសម្រាប់ ការអភិរក្សធនធានអាងបឹងទន្លេសាប
- សម្របសម្រួលកម្មវិធីថ្នាក់ជាតិ និងអនុ-តំបន់អំពីការប្រែប្រួលអាកាសធាតុ និង បរិស្ថាន និង
- ស្វែងរកហិរញ្ញវត្ថុ ពីប្រភពខាងក្នុង និង ខាងក្រៅ ដើម្បីគាំទ្រដល់សកម្មភាព ប្រែប្រួលអាកាសធាតុក្នុងគម្រោងថ្មីៗ និងគម្រោងដែលមានស្រាប់

លោក **Brimble** បានបញ្ចប់សុន្ទរកថា ជាមួយនឹងជំនឿយ៉ាងមុតមាំថា វេទិកាជាតិនេះ នឹងផ្តល់ឱកាសដើម្បីបង្កើនចំណេះដឹងអំពីបញ្ហា ប្រែប្រួលអាកាសធាតុនៅកម្ពុជា ជាពិសេសការ បន្សាំ ការកាត់បន្ថយ ការអភិវឌ្ឍនិងផ្ទេរបច្ចេក-វិទ្យា ការកសាងសមត្ថភាព និងហិរញ្ញប្បទាន។ លោកក៏សង្ឃឹមផងដែរថា វេទិកានេះនឹងជួយ កៀរគរ និងពង្រឹងការគាំទ្របន្ថែមពីDPs នានា។

សុន្ទរកថាស្វាគមន៍

ដោយ ***ឯកឧត្តម ស៊ុយ សែម***
រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល

ឯកឧត្តម **ស៊ុយ សែម** បានថ្លែងក្នុង សុន្ទរកថារបស់ឯកឧត្តមថា ការប្រែប្រួលអា កាសធាតុបាននឹងកំពុង ក្លាយជាការគម្រាម កំហែងមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម តាម រយៈស្ថានភាពគ្រោះធម្មជាតិជាបន្តបន្ទាប់។

ឯកឧត្តមបានបញ្ជាក់ថា RGC បានប្តេជ្ញា ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈ វិធានការបន្សាំ និងការកាត់បន្ថយការបញ្ចេញ GHGs ដូចបានចែងយ៉ាងច្បាស់ក្នុងយុទ្ធសាស្ត្រ ចតុកោណដំណាក់កាលទី២ និងNSDP បច្ចុប្បន្ន កម្ម ២០០៩-២០១៣។ លើសពីនេះ កម្ពុជា បាន និងកំពុងអនុវត្តការងារសំខាន់ៗជាច្រើនពាក់ព័ន្ធ នឹងការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាព បច្ចេកទេសជាតិ ការបញ្ចូលការងារប្រែប្រួល អាកាសធាតុទៅក្នុងផែនការជាតិ និងផែនការ តាមវិស័យនានា។

ឯកឧត្តមក៏បានមានប្រសាសន៍ថា ការ អភិវឌ្ឍវិស័យថាមពល ពិសេសថាមពលអគ្គិស នី ជាវិស័យអាទិភាពមួយរបស់ RGC ដើម្បីធា នាដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយ RGC បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា លើ ការអភិវឌ្ឍក្នុងវិស័យនេះ ដោយព្យាយាមកាត់ បន្ថយ ផលប៉ះពាល់ត្រឹមកម្រិតទាបបំផុត។

ទោះបីជាកម្ពុជា បានចូលជាសមាជិក នៃពិធីសារក្យូតូ កម្ពុជាពុំមានជាប់កាតព្វកិច្ច កាត់បន្ថយការបញ្ចេញ GHGs ឡើយក្នុងនាមជា DC ។ ក៏ប៉ុន្តែ កម្ពុជាបានចូលរួមយ៉ាងសកម្មក្នុង ការកាត់បន្ថយការបញ្ចេញ GHGs តាមរយៈការ ជម្រុញការផលិត និងប្រើប្រាស់ធនធានថាម ពលកកើតឡើងវិញ និងការជម្រុញលើកទឹកចិត្ត

ការអភិវឌ្ឍបច្ចេកវិទ្យាថាមពលស្អាត។ ការប្រឹងប្រែងនេះ កម្ពុជា អាចកាត់បន្ថយការបញ្ចេញ GHGs ប្រមាណ ៥៧០ពាន់តោនក្នុងមួយឆ្នាំ ជាមួយគម្រោង CDM ចំនួន៧ ក្នុងវិស័យថាមពលកកើតឡើងវិញ។ តាមរយៈ CDM អាចផ្តល់ជាឱកាសដល់ DCs ដូចជាកម្ពុជា ដើម្បីសហការជាមួយប្រទេសអភិវឌ្ឍ ក្នុងបន្ទេរបច្ចេកវិទ្យាសមស្រប ស្អាតមិនប៉ះពាល់បរិស្ថាន ក្នុងការកាត់បន្ថយការបញ្ចេញ GHGs ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។ ឯកឧត្តមក៏បានគូសបញ្ជាក់ថា ជម្រើសកាត់បន្ថយការបញ្ចេញ GHGs អាចទទួលយកបានទាំងផ្នែកសង្គម និងនយោបាយ។

ឯកឧត្តមក៏បានលើកឡើងពីអនុសាសន៍សំខាន់ៗ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ សម្រាប់ធ្វើការពិភាក្សាក្នុងវេទិកាជាតិដូចជា៖

- ការអភិវឌ្ឍបៃតង និងទស្សនៈទានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
- ទីផ្សារថាមពលកកើតឡើងវិញ
- ស្ថានភាពការអភិវឌ្ឍផែនការសកម្មភាពថ្នាក់ជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- គំនិតផ្តួចផ្តើមបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់MRC
- បទពិសោធន៍ថ្នាក់តំបន់និងអន្តរជាតិក្នុងការអនុវត្តសកម្មភាពបន្សាំប្រកបដោយប្រសិទ្ធភាព
- គោលនយោបាយឥណទានកាបូននិងការសម្របសម្រួលប្រសិទ្ធភាពជំនួយ
- ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុពេលអតីតកាលលើជីវចម្រុះនិងវិធានការឆ្លើយតបការប្រែប្រួលអាកាសធាតុលើជីវចម្រុះនិង
- ផលប៉ះពាល់ការប្រែប្រួលអាកាសធាតុនិងការឆ្លើយតបតាមគំនិតយេនឌ័រ

ជាចុងក្រោយ ឯកឧត្តម សង្ឃឹមយ៉ាងមុតមាំថា អ្នកចូលរួមទាំងអស់ដែលមានវត្តមានក្នុងវេទិកាថ្ងៃនេះ នឹងចូលរួមយ៉ាងសកម្មក្នុងការពិភាក្សា ពិគ្រោះយោបល់ និងផ្តល់អនុសាសន៍ល្អៗ ក្នុងការរួមចំណែកគ្រប់គ្រងការប្រែប្រួលអាកាសធាតុប្រកបដោយជោគជ័យ និងសម្រេចបានជាផ្លែផ្កា។

ភគ្គស្របតា ទី២

បន្សុំនៅនឹងការប្រែប្រួលអាកាសធាតុ-ស្ថានភាព ជោគជ័យ ការប្រឈម និងមេរៀនទទួលបាន

សហប្រធាន:

១. លោក **កែន សេរីរដ្ឋា** អគ្គនាយករង GDANCP/MoE

២. លោក **Koen Everaert** អនុព័ន្ធទទួលបន្ទុកសហប្រតិបត្តិការប្រតិភូ EUប្រចាំនៅកម្ពុជា

ផែនការសកម្មភាពជាតិនៃយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ

*ដោយ**លោក សុទ្ធ តឹមភុលមុនី** អនុប្រធាននាយកដ្ឋានត្រៀមរៀបចំ និងបណ្តុះបណ្តាលនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ*

បទបង្ហាញនេះ បានផ្តោតជាសំខាន់លើកិច្ចខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្នុងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយអាកាសធាតុ ដែលរួមមាន ស្ថានភាពនៃការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់ DRR ដោយផ្តោតជាសំខាន់លើការឆ្លើយតបដោយសហគមន៍ និងមេរៀនទទួលបាន។

លោក **សុទ្ធ តឹមភុលមុនី** បានបកស្រាយដោយសង្ខេបថា គ្រោះមហន្តរាយអាចប៉ះពាល់

ទៅលើកិច្ចខំប្រឹងប្រែង ក្នុងការសម្រេចគោលដៅអភិវឌ្ឍសហស្សវត្សកម្ពុជា និងមានឥទ្ធិពលលើហិរញ្ញវត្ថុសាធារណៈ ដែលអាចនឹងធ្វើឲ្យប្រាក់ចំណូលកាន់តែទាប បង្កើនការចំណាយជាពិសេសការចំណាយរបស់ RGC ដើម្បីឆ្លើយតបនឹងបញ្ហាទាំងនោះ។ គ្រោះមហន្តរាយអាចមានផលប៉ះពាល់ ដោយផ្ទាល់ដល់សហគមន៍ និងកម្រិតជីវភាពរបស់ប្រជាជន ដែលអាចរំខានដល់ដំណើរការអភិវឌ្ឍ ឬជម្រុញឲ្យដំណើរអភិវឌ្ឍមានការពន្យាពេល ឬអាចលុបចោល។

ការពិតណាស់ កម្ពុជាធ្លាប់បានជួបប្រទះគ្រោះមន្តរាយដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ជម្ងឺរាតត្បាត ខ្យល់ព្យុះ រន្ទះបាញ់ ភ្លើងឆេះ ព្រៃគ្រោះថ្នាក់ចរាចរណ៍ គ្រាប់មីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះជាដើម។

លោក **សុទ្ធ គឹមកុលមុនី** បានពន្យល់ពីទស្សនវិស័យរបស់ NCDM ក្នុងការដឹកនាំការគ្រប់គ្រងគ្រោះមហន្តរាយ នៅកម្ពុជា ដើម្បីកសាងសហគមន៍ ដែលធន់នឹងគ្រោះមហន្តរាយធម្មជាតិ ដោយអនុលោមទៅតាមក្របខណ្ឌសកម្មភាពហាយហ្គោ (Hyogo Framework for Action-HFA)។

គោលបំណងស្នូលជាយុទ្ធសាស្ត្រទាំងប្រាំរបស់ NCDM រួមមាន៖

- ពង្រឹងប្រព័ន្ធគ្រប់គ្រងគ្រោះមហន្តរាយ
- ការអភិវឌ្ឍធនធានមនុស្ស និងសមត្ថភាពស្ថាប័ន
- ការពង្រឹងប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ
- ការពង្រឹងសមត្ថភាពត្រៀមរៀបចំ និងឆ្លើយតបគ្រោះមហន្តរាយ និង
- ការរួមបញ្ចូលគោលគំនិតការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ នៅក្នុងគោលនយោបាយយុទ្ធសាស្ត្រ និងផែនការរបស់ RGC នៅគ្រប់វិស័យ និងគ្រប់លំដាប់ថ្នាក់

ដោយការកំណត់យកHFA ជាក្របខណ្ឌការងាររួម ការកំណត់អត្តសញ្ញាណកម្មនៃ DRR ដែលបានចាត់ជាអាទិភាពក្នុងប្រទេសកម្ពុជា។ ក្របខណ្ឌទីមួយ គឺធានាឲ្យបានថា DRR គឺជាបញ្ហាអាទិភាពនៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ដើម្បីសម្រេចន្ធវគោលបំណងនេះ ការបង្កើតគោលនយោបាយ និងនីតិកម្មគាំទ្រ DRR រួមទាំងការបង្កើត និងពង្រឹងការសម្របសម្រួល DRR ថ្នាក់ជាតិ ឬ "វេទិកា DRR ជាតិ" ត្រូវតែបានអនុវត្ត។ ការធ្វើសមាហរណកម្ម DRR ទៅក្នុងផែនការនិងគោលនយោបាយអភិវឌ្ឍន៍ជាតិ និងការរក្សាទុកធនធានឲ្យបានសមស្រប សម្រាប់ DRR នៅថ្នាក់ជាតិ គឺជាតម្រូវការដ៏ចាំបាច់។

ក្របខណ្ឌការងារទីពីរ គឺការពង្រឹងការគ្រប់គ្រង DRR នៅថ្នាក់ក្រោមជាតិ និងមូលដ្ឋាន ដែលអាចអនុវត្តបានតាមរយៈវិមជ្ឈការ DRR ទាំងក្នុងការទទួលខុសត្រូវ និងធនធានរួមទាំងការលើកកម្ពស់ការអនុវត្តកម្មវិធី DRR នៅថ្នាក់មូលដ្ឋាន។

ក្របខណ្ឌការងារទីបី នៃការកំណត់ការវាយតម្លៃ និងតាមដានត្រួតពិនិត្យហានិភ័យនៃមុខសញ្ញាគ្រោះថ្នាក់ និងការធ្វើឲ្យប្រសើរឡើងនៃប្រព័ន្ធផ្តល់ព័ត៌មានជាមុន សកម្មភាពដែលត្រូវការរួមមាន៖

- ការធ្វើការវាយតម្លៃហានិភ័យ នៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន
- ការបង្កើតប្រព័ន្ធព័ត៌មានគ្រប់គ្រងគ្រោះមហន្តរាយ
- ការបង្កើតប្រព័ន្ធផ្តល់ព័ត៌មានជាមុនពីគ្រោះថ្នាក់ផ្សេងៗ ដែលអាចជួយផ្តល់ព័ត៌មានដល់ប្រជាពលរដ្ឋ អាចដឹងអំពីហានិភ័យគ្រោះមហន្តរាយ និង
- ការសហប្រតិបត្តិការជាមួយអន្តរជាតិ និងថ្នាក់តំបន់លើគំនិតផ្តួចផ្តើម DRR

ក្របខណ្ឌទីបួន គឺការប្រើប្រាស់ចំណេះដឹង និងការអប់រំដើម្បីបង្កើតជាទម្លាប់សុវត្ថិភាពភាពធន់ និងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ។

ក្របខណ្ឌទីប្រាំ គឺការបញ្ចូល DRR នៅក្នុងគោលនយោបាយ និងកម្មវិធីរបស់ក្រសួងរដ្ឋាភិបាល ដែលពាក់ព័ន្ធ និងដើម្បីពង្រឹងការត្រៀមខ្លួនជាស្រេច សម្រាប់ឆ្លើយតបនឹងបញ្ហានៃគ្រោះមហន្តរាយគ្រប់កម្រិតទាំងអស់ ប្រកបដោយប្រសិទ្ធភាព។

ចុងបញ្ចប់លោក **សុទ្ធ គីមភុលមុនី** បានថ្លែងថា ការគ្រប់គ្រងគ្រោះមហន្តរាយ និងការអភិវឌ្ឍគឺជាការងារួម ប៉ុន្តែការអភិវឌ្ឍដោយរួមបញ្ចូលជាមួយការគ្រប់គ្រងគ្រោះ មហន្តរាយ គឺជាការអភិវឌ្ឍប្រកបដោយចីរ ភាព។

គំនិតផ្តួចផ្តើមក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មាការទន្លេមេគង្គ៖ ខ្លឹមសារណែនាំសម្រាប់បន្សាំថ្នាក់តំបន់

*ដោយបណ្ឌិត **Kien Tran-Mai***
មន្ត្រីកម្មវិធីប្រែប្រួលអាកាសធាតុនៃ MRC

លោកបណ្ឌិត Kien Tran-Mai បានធ្វើការចែករំលែកនូវបទពិសោធន៍ គំនិតផ្តួចផ្តើមបន្សាំទូទាំងអាងទន្លេមេគង្គ ដែលមានចំណងជើងថា "គំនិតផ្តួចផ្តើមបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ"។ បទបង្ហាញរបស់គាត់ផ្តោតលើចំណុច ៥សំខាន់ៗ រួមមាន៖

- ការប្រែប្រួលអាកាសធាតុ និងការប្រឈមក្នុងការអភិវឌ្ឍពីទស្សនវិស័យនៃតំបន់ទន្លេមេគង្គ
- ការបង្ហាញពីគម្រោងគំនិតផ្តួចផ្តើមបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មការទន្លេមេគង្គ (MRC CCAI)
- សកម្មភាពដំបូងខ្លះៗរបស់គម្រោង និង
- កិច្ចសហការ និងភាពជាដៃគូនៅក្នុងតំបន់

ដោយផ្អែកទៅលើទស្សនៈវិស័យ ពីការប្រែប្រួលអាកាសធាតុ និងការប្រឈមនៃការអភិវឌ្ឍ លោកបណ្ឌិត**Kien Tran-Mai** បានសង្កត់ធ្ងន់ថា ពុំមានប្រទេសណាមួយអាចដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ប្រកបដោយប្រសិទ្ធភាពនោះទេ បើគ្មានយុទ្ធសាស្ត្រការគាំទ្រពីថ្នាក់តំបន់ដើម្បីរៀបចំផែនការ និងសកម្មភាពបន្សាំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិនោះ ដែលទាំងនេះ គឺជាតួនាទី និងការប្រឈមរបស់ MRC CCAI។

លោកបណ្ឌិត ក៏បានលើកឡើងខ្លះៗដែរពីការសិក្សាស្តីពី ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់អាងទន្លេមេគង្គ ដែលសិក្សាដោយ CSIRO។ ការសិក្សានេះបានផ្តោតលើការថយចុះនៃកម្ពស់ទឹកភ្លៀង នៅភាគខាងត្បូងនៃអាងទន្លេ និងការកើនឡើងនៃទឹកជំនន់នៅតំបន់ទាំងអស់នៃអាងទន្លេ ជាពិសេសភាគខាងក្រោមនៃអាងទន្លេ។

លោកបណ្ឌិត **Kien Tran-Mai** ក៏បានសង្កត់ធ្ងន់ដែរពីផលប៉ះពាល់ ដែលបណ្តាលមកពីការអភិវឌ្ឍ ជាពិសេស រោងចក្រវារីអគ្គិសនីនៅតាមបណ្តោយទន្លេមេគង្គ និងការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់អាងទន្លេមេគង្គ ដែលបញ្ហាទាំងនោះ រួមមាន៖

- ការកើនឡើងកាន់តែញឹកញាប់ និងខ្លាំងនៃគ្រោះមហន្តរាយទឹកជំនន់ ព្យុះទីហ្វុង ភាពរាំងស្ងួត និងភ្លើងឆេះព្រៃ
- ការប្រែប្រួលលំហូរទឹក គុណភាព និងបរិមាណទឹករបស់ទឹកទន្លេ

- ការប្រែប្រួលនូវកំទេចកំណសារធាតុចិញ្ចឹម សណ្តានរបស់ទន្លេ និងពាម
- ការប្រែប្រួលសេវាកម្មស្តានប្រព័ន្ធ ជាពិសេសតំបន់ដីសើម និងជីវចម្រុះ
- កត្តាសេដ្ឋកិច្ច ពិសេសកសិកម្ម ជលផល និងហេដ្ឋារចនាសម្ព័ន្ធ
- ជីវភាពរបស់ប្រជាជនក្រីក្រ និងក្រុមអ្នកទន់ខ្សោយ (ស្ត្រី កុមារ មនុស្សចាស់ជរា និងក្រុមជនជាតិភាគតិច)
- តំបន់ទំនាបលិចទឹកទន្លេមេគង្គនិងតំបន់ទន្លេសាប ដែលប៉ះពាល់ដោយសារការអភិវឌ្ឍខ្សែទឹកខាងលើ និងការកើនឡើងកម្ពស់ទឹកសមុទ្រ

MRC CCAI ជាកិច្ចផ្តួចផ្តើមសហប្រតិបត្តិការថ្នាក់តំបន់នៃបណ្តាប្រទេស នៅក្នុងអាងទន្លេមេគង្គក្រោម ដែលមានគោលដៅគាំទ្រដល់ប្រទេសនានា ក្នុងការបន្សាំទៅនឹងផលប៉ះពាល់ និងការប្រឈមថ្មីៗ តាមរយៈការកែលម្អលើការកសាងផែនការ អនុវត្ត និងការសិក្សា។ កម្មវិធីនេះ ជាកិច្ចផ្តួចផ្តើមរយៈពេលវែងមួយ ដែលមានរយៈពេលជិត ១៧ ឆ្នាំគិតចាប់ពីឆ្នាំ ២០០៩ ដល់ឆ្នាំ ២០២៥ ហើយមានបីដំណាក់កាល បានន័យថា មួយដំណាក់កាលមានរយៈពេល ៥ឆ្នាំ។ កម្មវិធីនេះ មានគោលបំណងចម្បងៗចំនួន ៤ រួមមាន៖

- ការកសាងផែនការ និងអនុវត្តកិច្ចការបន្សាំនឹងការប្រែប្រួលអាកាសធាតុ
- ការកែលម្អសមត្ថភាពដើម្បីគ្រប់គ្រងនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- យុទ្ធសាស្ត្រ និងផែនការសម្រាប់បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ
- ការផ្តោះប្តូរ កិច្ចសហការ និងការសិក្សារៀនសូត្រនៅថ្នាក់តំបន់

លោកបណ្ឌិត **Kien Tran-Mai** ក៏បានសង្កត់ធ្ងន់ថា MRCCCAI មិនត្រឹមធ្វើការដោយផ្ទាល់ ជាមួយគណៈកម្មាធិការទន្លេមេគង្គជាតិប៉ុន្តែ កំពុងទាក់ទងនឹងកិច្ចផ្តួចផ្តើមអន្តរវិស័យជាមួយនឹងវិស័យ ឬកម្មវិធីផ្សេងៗទៀត ដូចជាការគ្រប់គ្រង និងការកាត់បន្ថយគ្រោះទឹកជំនន់ ការគ្រប់គ្រងភាពរាំងស្ងួត វារីអគ្គិសនី ជលផល កសិកម្ម ធារាសាស្ត្រ ជាដើម។ នេះគឺជាកិច្ចខំប្រឹងប្រែងរួមគ្នា ដើម្បីជួយបណ្តាប្រទេសជាសមាជិក និងសហគមន៍របស់ពួកគេ។

គម្រោងនេះ ត្រូវបានអនុវត្តតាមអភិក្រមសន្តមិយមមួយ ដែលមានជំហានក្នុងការកសាងផែនការបន្សាំ លំដាប់នៃការកសាងផែនការអភិវឌ្ឍ និងវិស័យអភិវឌ្ឍន៍នានា ផ្សេងៗគ្នា។ បញ្ហាយេនឌ័រក៏បានគិតគូរ ពិចារណាពីសារសំខាន់ក្នុងការបញ្ចូលទៅក្នុង គ្រប់ជំហានទាំងអស់នៃគ្រប់វិស័យដោយមិន ត្រឹមតែទទួលស្គាល់ និងប្រមូលព័ត៌មានចាប់តាំងពី ការចាប់ផ្តើមនោះទេ ថែមទាំងឲ្យមានការចូលរួមពីស្ត្រីនៅគ្រប់លំដាប់ថ្នាក់ និងជំហាន ទាំងអស់ដើម្បីធានាថា តួនាទីរបស់ពួកគេត្រូវ បានរាប់បញ្ចូលក្នុងដំណើរការបន្សាំ។ លើសពីនេះ ការចូលរួមយ៉ាងសកម្មពីសំណាក់ស្ថាប័នពាក់ព័ន្ធនៅក្នុងកម្មវិធីនានា រួមបញ្ចូលទាំងការប្រឹក្សាយោបល់ថ្នាក់ជាតិ និងតំបន់ អ្នកជំនាញការជាតិ និងមកពីប្រទេសតាមដងទន្លេមេគង្គ និងកម្មវិធីផ្សេងៗទៀត របស់ MRC ជាមួយដៃគូក្នុងតំបន់ គឺសុទ្ធតែបានគិតគូរ និងយកចិត្ត ដាក់។

កន្លងមក MRC CCAI បានធ្វើការងារជាច្រើនទាក់ទងនឹងការបង្កើនការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ ពិសេសទាក់ទង់នឹងការបង្កើតភាពយន្តគំនូរជីវចល និងប័ណ្ណផ្សព្វផ្សាយគ្រប់ភាសានៃបណ្តាប្រទេសជាសមាជិក។សកម្មភាពផ្តួចផ្តើមមួយចំនួនបានអនុវត្តដោយ MRC CCAI សម្រាប់ជាគម្រោងអនុវត្តបង្ហាញបឋម ស្តីពីការបន្សាំនៅកម្រិតមូលដ្ឋាននៅក្នុងប្រទេសនី

មួយៗ ជាគម្រោងសាកល្បងនៅទូទាំងអាងទន្លេមេគង្គ ដើម្បីកំណត់ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើតំបន់ដីសើម និងជីវចម្រុះ និងការវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ជាឧទាហរណ៍ល្អបំផុត គឺការសិក្សាពី ការជ្រៀតចូលទឹកប្រៃនៅក្នុងដីសណ្តរទន្លេមេគង្គផ្នែកខាងក្រោម ដោយការធ្វើម៉ូដែលពីផលិតផលស្រូវ និងដំណាំផ្សេងៗទៀតនាពេលអនាគត។ របាយការណ៍ស្តីពី គម្រោងសាកល្បងនៅទូទាំងអាងទន្លេ ពីផលប៉ះពាល់ការប្រែប្រួលអាកាសធាតុ និងការវាយតម្លៃភាពងាយរងគ្រោះមកលើ ជីវចម្រុះនិងតំបន់ដីសើមនៅផ្នែកខាងក្រោមទន្លេមេគង្គ នឹងត្រូវបោះពុម្ពផ្សព្វផ្សាយនាពេល ឆាប់ៗខាងមុខនេះ។

ជាចុងបញ្ចប់នៃបទបង្ហាញ លោកបណ្ឌិត **Kien Tran-Mai** បានសង្កត់ធ្ងន់ថា MRC CCAI មើលឃើញថា ការបង្កើតជាដំបូងនូវបណ្តាញថ្នាក់តំបន់នៃការអនុវត្តបង្ហាញ ដែលសហការគ្នាជាមួយដៃគូនៅថ្នាក់ជាតិ និងតំបន់ ពិតជាមានសារសំខាន់ណាស់ ក៏ដូចជា គម្រោងអនុវត្តបង្ហាញផ្សេងៗគ្នា ដែលមានការសហការតាមមូលដ្ឋានជាមួយដៃគូនៅថ្នាក់ជាតិ និងតំបន់។ MRC CCAI បន្តការអនុវត្តគម្រោងសាកល្បងផ្សេងៗទៀត ដែលអនុវត្តតាមរយៈកម្មវិធី របស់ MRC ។ វិស័យពីរសំខាន់ដែល MRC CCAI កំពុងព្យាយាមធ្វើគឺ ផែនការសកម្មភាព និងយុទ្ធសាស្ត្របន្សាំថ្នាក់តំបន់ទន្លេមេគង្គ ដើម្បីទ្រទ្រង់ក្របខណ្ឌការងារថ្នាក់ជាតិ និងគោលការណ៍ណែនាំនានា និងក្រុមការងារមេគង្គ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលមានភាពស្រដៀងទៅនឹងក្រុមការងារថ្នាក់តំបន់នៃអន្តរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ។

ឱបសគ្គ និងការលុះត្តភាពសម្រាប់ការបន្សាំប្រកបដោយប្រសិទ្ធភាព

ដោយលោក Alex Heikens ទីប្រឹក្សាផ្នែកគោលនយោបាយការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ នៃការិយាល័យ UNDP ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក

បទបង្ហាញនេះ បានធ្វើការពិភាក្សាអំពីបទពិសោធន៍ថ្នាក់តំបន់ និងអន្តរជាតិ ក្នុងការអនុវត្តសកម្មភាពបន្សាំ ដោយផ្តោតលើឧបសគ្គ មេរៀនទទួលបាន ការអនុវត្តល្អៗ អនុសាសន៍គោលនយោបាយសំខាន់ៗ ដែលកម្ពុជាអាចទទួលបានអត្ថប្រយោជន៍។

លោក **Alex Heikens** បានចាប់ផ្តើមនូវបទបង្ហាញ ដោយរំលឹកដល់អ្នកចូលរួមថា យុទ្ធសាស្ត្របន្សាំ ដែលទទួលបានពីអាស៊ីបានចាប់ផ្តើមរយៈពេល៥ឆ្នាំមកហើយ។ មេរៀនទទួលពីការបន្សាំមាន កត្តាប្រឈមចម្បងៗនៃការពង្រីកការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលបានអនុវត្តនៅអាស៊ី ហើយការអនុវត្តនៃយុទ្ធសាស្ត្របន្សាំនេះ ត្រូវការការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់មិនត្រឹមតែរាជរដ្ឋាភិបាលនោះទេថែមទាំង CSOs និងវិស័យវិនិយោគឯកជនផងដែរ។ ការយល់ច្បាស់ពីមេរៀន ដែលទទួលពី ការបន្សាំនឹងការប្រែប្រួលអាកាសធាតុពេលប៉ុន្មានឆ្នាំនេះ មិនមែនជាការងាយស្រួលនោះទេ ដោយសារការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាអន្តរវិស័យ។

ការបន្សាំ គឺផ្តោតលើសមត្ថភាពស្ថាប័នមូលដ្ឋាន និងការអនុវត្តជាក់ស្តែងថ្នាក់មូលដ្ឋានថ្នាក់ស្រុក និងភូមិ ព្រោះជាទូទៅ សមត្ថភាពនៅមូលដ្ឋាននៅមានកម្រិត ហើយតួនាទី និងការទទួលត្រូវរបស់ពួកគេមិនច្បាស់លាស់។ ដូច្នេះវាមាន ការចាំបាច់ការពង្រីកការសម្របសម្រួលថ្នាក់ជាតិ។ ឧទាហរណ៍ គម្រោង SCCF/GEF "ស្តីពីការកសាងផែនការ និងសកម្មភាពជាយុទ្ធសាស្ត្រ ដើម្បីពង្រឹងភាពធន់នឹងអាកាសធាតុរបស់សហគមន៍តាមជនបទ" ដែលកំពុងរៀបចំ

នៅឥណ្ឌូនេស៊ី ដែលបានបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងស្តាប់នសំខាន់ៗ នៅថ្នាក់ស្រុក និងខេត្ត។ សារសំខាន់មួយទៀតសម្រាប់ការបន្សុំ គឺការប្រើប្រាស់នូវប្រព័ន្ធរបស់ប្រទេសក្នុងការអនុវត្តគម្រោងបន្សុំការប្រែប្រួលអាកាសធាតុនានា។ វិធីសាស្ត្រជាចម្បង គឺដើម្បីធ្វើការគិតពិចារណាឡើងវិញ ពីការអនុវត្តគម្រោងតាមបៃបប្រពៃណី និងការចាប់ផ្តើមក្នុងការដោះស្រាយភាពទន់ខ្សោយ នៅក្នុងប្រព័ន្ធរបស់ប្រទេស ពិសេសក្នុងផ្នែកនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកំណែទម្រង់អភិបាលកិច្ច។

ជាចុងបញ្ចប់ លោកបានបញ្ជាក់ថា ការបញ្ជ្រាបការបន្សុំនឹងការប្រែប្រួលអាកាសធាតុក្នុងការអភិវឌ្ឍនៅមូលដ្ឋាន តាមរយៈការកសាងផែនការ ការលើកគម្រោងថវិកា និងបទបញ្ញត្តិ ដើម្បីធានាថាមានជាស្រេចនូវ ប្រព័ន្ធមូលដ្ឋានដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗ ដល់សហគមន៍ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុប្រកបដោយចីរភាព គឺពិតជាមានភាពចាំបាច់។

ឧបសគ្គក្នុងការបន្សុំឲ្យមានប្រសិទ្ធភាព- ទស្សនទានពីរបាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ ២០១១

*ដោយបណ្ឌិត **Richard Friend***
វិទ្យាស្ថានសម្រាប់អន្តរភាពសង្គម និងបរិស្ថាន (ISET)

បទបង្ហាញនេះ បានផ្តល់នូវទិដ្ឋភាពរួមនៃលទ្ធផលសិក្សាស្រាវជ្រាវរបស់របាយការណ៍អភិវឌ្ឍន៍មនុស្សកម្ពុជាឆ្នាំ២០១១ ដែលរួមមានការប្រឈមចម្បងៗនៃការប្រែប្រួលអាកាសធាតុ គោលការណ៍នៃសកម្មភាព និងកាលានុវត្តភាព និងហានិភ័យនៅកម្ពុជា។

លោកបណ្ឌិត **Richard Friend** បានរំលេចពីភាពមិនប្រាកដប្រជា និងហានិភ័យនៃការអភិវឌ្ឍ និងការប្រែប្រួលអាកាសធាតុ។ មនុស្ស គឺជាមជ្ឈមណ្ឌលនៃការអភិវឌ្ឍ ហើយការអភិវឌ្ឍ ត្រូវមានការក្រឡេកក្រោយមើលពីខ្លឹមសារ និងគោលដៅនៃការអភិវឌ្ឍ។ នៅក្នុងរយៈពេលពី ២០ ទៅ៣០ ឆ្នាំខាងមុខ យើងប្រហែលជាក្រឡេកមើលថា តើអ្វីខ្លះបានផ្លាស់ប្តូរ ឬប្រែប្រួលដែលស្តែងចេញមកពី ដំណើរការនៃការអភិវឌ្ឍ។ អ្វីយើងត្រូវការនាពេលនេះ គឺជាវិធីសាស្ត្រថ្មីៗ ដើម្បីសម្រេចបានការអភិវឌ្ឍ និងវិធីដោះស្រាយជាមួយនឹងភាព មិនប្រាកដប្រជា និងហានិភ័យកម្រិតខ្ពស់ដែលពាក់ព័ន្ធ។

ក្នុងការគិតគូរពីការបន្សុំ និងវិធីសាស្ត្រក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ យើងប្រហែលជាគិតគូរអំពី ភាពធន់ទ្រាំ និងគោលការណ៍ជាមូលដ្ឋានរបស់វា។ ជាមូលដ្ឋានយើងត្រូវការឲ្យមានការកសាងផែនការ និងការធ្វើសេចក្តីសម្រេចជាយុទ្ធសាស្ត្រ ដែលអនុញ្ញាតឲ្យមានការយល់ដឹងជាមុន និងតាមបៃបផែននៃការចូលរួមដោយត្រូវបានរាប់បញ្ចូលក្នុងកិច្ចការប្រែប្រួលអាកាសធាតុ និងការពិចារណាអំពីអេកូឡូស៊ីជាស្នូលនៃការអភិវឌ្ឍ។ លើសពីនេះទៀត យើងត្រូវតែគិតគូរ ពិចារណាពីការជម្រុញឲ្យមានស្តាប់ន ដែលបន្សុំនិងអាចបត់បែនបាននៅគ្រប់ទិដ្ឋភាពទាំងអស់នៃការអភិវឌ្ឍ ហើយមានភាពប្រាកដថា មានជម្រើសមិនស្តាយក្រោយ ដែលហៅថា "សុវត្ថិភាពចាកផុតពីបរាជ័យ"។

ភាពងាយរងគ្រោះនៃកម្ពុជា ចំពោះការប្រែប្រួលអាកាសធាតុដោយសារភាពទន់ខ្សោយខាងទ្រព្យសកម្ម និងសិទ្ធិនៃការប្រើប្រាស់របស់ប្រជាជននៅជនបទ សមត្ថភាពបន្សុំ បច្ចេកវិទ្យា ហិរញ្ញវត្ថុ សមត្ថភាពមនុស្សមានកម្រិត ឧបសគ្គខាងស្តាប់នភាពទន់ខ្សោយខាង អភិបាលកិច្ច និងសេចក្តីសម្រេចចិត្ត។ តើធ្វើយ៉ាងណាដើម្បីពង្រឹងទ្រព្យសកម្ម និងសិទ្ធិនៃការប្រើប្រាស់របស់ប្រជាជន? ចម្លើយ គឺការពង្រឹងកិច្ច

ការពារសង្គម DRR និងការពង្រឹងសិទ្ធិទទួលបានទ្រព្យសកម្ម ដែលមានប្រសិទ្ធភាព ដូចជា ដីធ្លី ទឹក ព្រៃឈើ ជាដើម។

ជាធម្មតា តម្រូវការសម្រាប់សកម្មភាពមូលដ្ឋាន គឺចាំបាច់ណាស់ក្នុងដំណើរការ ព្រោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ នឹងកើតមានមកលើ ថ្នាក់មូលដ្ឋាន ដែលត្រូវការសកម្មភាពក្នុងកម្រិតផ្សេងៗគ្នា ដែលមានទាំងកម្រិតមូលដ្ឋាន ជាតិ និងតំបន់។

ការទទួលបានព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុគឺ សំខាន់ខ្លាំងណាស់សម្រាប់ការយល់ដឹងបន្ថែម ហើយប្រភពព័ត៌មានដែលអាចទុកចិត្តបានអាចមានច្រើន។ ដើម្បីធានាបានថា ប្រជាជនទទួលបាននូវព័ត៌មានលម្អិត ព័ត៌មានត្រូវតែអាចរកបានជាសាធារណៈ និងអ្នកដែលប៉ះពាល់ទាំងអស់គួរតែចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត សម្រាប់ជាលទ្ធផលដែលមានភាពស្មើភាពគ្នា និងមានសមធម៌។

ជាចុងបញ្ចប់ លោកបណ្ឌិត **Richard Friend** បានបង្ហាញថា ក្នុងការបង្ការ និងកែតម្រូវសម្រាប់ហានិភ័យ នៃការប្រែប្រួលអាកាសធាតុត្រូវបង្កើតក្របខណ្ឌច្បាប់ ប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើតស្តង់ដាជុំវិញការបំពុលខ្យល់ ឬការប្រែប្រួលការប្រើប្រាស់ដីធ្លីជាដើម។ បន្ថែមពីនេះ ការស្វែងរកនូវយន្តការនានាដើម្បីធានាឲ្យមានគណនេយ្យភាព និងតម្លាភាពក៏ត្រូវបានរាប់បញ្ចូលក្នុងការបង្ការ និងការកែតម្រូវសម្រាប់ហានិភ័យនៃការប្រែប្រួលអាកាសធាតុផងដែរ។

សំណួរ និងចម្លើយ

លោក **ខែន ទីរៈ** មកពីមន្ទីរបរិស្ថានខេត្តកំពត បានសួរថា តើពាក្យ "ការបង្ការ" អាចត្រូវប្រើជំនួសពាក្យ "ការកាត់បន្ថយ" បានដែរឬទេ?

លោក **សុទ្ធ គីមភុលមុនី** បានបកស្រាយថាពាក្យ "ការបង្ការ" មិនអាចប្រើក្នុងបរិបទគ្រោះមហន្តរាយធម្មជាតិបានទេ ពីព្រោះគ្រោះមហន្តរាយដូចជា ព្យុះ រញ្ជួយដី ជាដើម មិនអាចបង្ការបានទេ។ ផ្ទុយទៅវិញពាក្យថា "ការកាត់បន្ថយ" អាចត្រូវបានប្រើនៅក្នុងបរិបទគ្រោះមហន្តរាយ ពីព្រោះវាមានន័យថា ជាការព្យាយាមកាត់បន្ថយផលប៉ះពាល់ធ្ងន់ធ្ងរនៃគ្រោះមហន្តរាយឲ្យទាបបំផុត តាមលទ្ធភាពដែលអាចធ្វើទៅបានតាមរយៈប្រព័ន្ធប្រាប់ព័ត៌មានជាមុន។

លោកស្រី **ឈឹម រមណី** មកពី CDRI បានបញ្ចេញកង្វល់ ថាតើគ្រោះមហន្តរាយដែលបានបង្កដោយការប្រែប្រួលអាកាសធាតុ និងដោយធម្មជាតិ អាចត្រូវបានញែកចេញពីគ្នាបានយ៉ាងដូចម្តេច?

លោក **សុទ្ធ គីមភុលមុនី** បានថ្លែងថា ដោយសារការប្រែប្រួលអាកាសធាតុបង្កឲ្យមានគ្រោះមហន្តរាយដូច្នេះ បើសិនផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ត្រូវបានកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយ នឹងអាចកាត់បន្ថយបានផងដែរ។ ដូច្នេះ ការរួមបញ្ចូល DRR និង CCCA ក៏ត្រូវបានគិតគូរពិចារណាផងដែរ ពីព្រោះគម្រោងទាំងពីរ ធ្វើការនៅក្នុងវិស័យតែមួយ។ ឥឡូវនេះ ការរួមបញ្ចូលនូវ DRR និង CCCA បាននឹងកំពុងស្ថិតក្នុងការពិចារណាដោយសារវាមានលក្ខណៈស្រដៀងគ្នា។

លោក **តូច ច័ន្ទត្រីះស្ងា** មកពី MEF បានស្នើថា ប្រព័ន្ធប្រកាសអាសន្ន គួរតែមានដើម្បីផ្តល់ព័ត៌មានឲ្យប្រជាជនបានដឹងមុន អំពីគ្រោះមហន្តរាយធម្មជាតិ។

លោក **សុទ្ធ គីមភុលមុនី** បានពន្យល់ថា ពេលថ្មីៗនេះ RGC កំពុងតែព្យាយាមធ្វើទំនើបកម្មប្រព័ន្ធប្រកាសអាសន្ននេះ តែការងារនេះអាចអនុវត្តបាន លុះត្រាណាមានការចូលរួមពីពហុភាគីពាក់ព័ន្ធ។ DRR គឺជាឧបករណ៍សម្របសម្រួលមួយ ហើយភាគីពាក់ព័ន្ធនីមួយៗ

មានការទទួលខុសត្រូវផ្សេងៗគ្នា ដើម្បីបញ្ជាបព័ត៌មានពីថ្នាក់ជាតិទៅដល់ថ្នាក់មូលដ្ឋាន។

លោក **Aaron Watson** ទីប្រឹក្សាបច្ចេកទេសមកពី WOMEN ចង់ដឹងថា តើនៅពេលអនាគតរចនសម្ព័ន្ធរបស់ CCCA អាចនឹងមានថ្នាក់ក្រោមជាតិ ដូចជា DRR ដែរឬទេ?

លោក **សុទ្ធ គឹមភុលមុនី** បានឆ្លើយតបវិញថា ជាការពិតណាស់ ការរួមបញ្ចូល DRR និង CCCA កំពុងស្ថិតនៅក្នុងដំណាក់ការគិតគូរពិចារណា។

លោក **ភុប ម៉ាត់** ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានចម្ងល់ថា ហេតុអ្វីបានជាការធ្វើឲ្យប្រសើរឡើងនៃ "ប្រព័ន្ធប្រមូលទិន្នន័យ" មិនត្រូវបានបញ្ចាក់ក្នុងយុទ្ធសាស្ត្រ "DRR" ពីព្រោះថា ប្រព័ន្ធនេះនៅកម្ពុជាមានកម្រិតនៅឡើយ?

លោក **សុទ្ធ គឹមភុលមុនី** ទទួលស្គាល់ថា នៅក្នុងយុទ្ធសាស្ត្រ "DRR" បានប្រើពាក្យថា "ការពង្រឹង" ។ ក្នុងនេះ មានន័យថារាល់ការងារទាំងអស់នឹងត្រូវបានអនុវត្តរួមគ្នាជាមួយនឹងការចូលរួមគ្រប់កម្រិតទាំងអស់។ ជាឧទាហរណ៍ MOWRAM កំពុងព្យាយាមក្នុងការទទួលបានព័ត៌មានឧតុនិយម ដែលអាចទុកចិត្តបាន ហើយនិងធ្វើទំនើបកម្មនៃព័ត៌មានទាំងនោះ ដើម្បីផ្តល់ព័ត៌មានដល់សាធារណៈជនឲ្យទាន់ពេលវេលា។

លោក **យ៉ក់ សុទ្ធិរិទ្ធ** មកពីស្ថានទូតចក្រភពអង់គ្លេស ដោយយោងលើយុទ្ធសាស្ត្រ "DRR" បានសួរថាតើ NCDM មានផែនការក្នុងការវាយតម្លៃចំណាយនៃការខូចខាតដោយសារគ្រោះមហន្តរាយធម្មជាតិដែរឬទេ? បើសិនមានតើការប៉ាន់ប្រមាណចំណាយ លើការខូចខាតដោយទឹកជំនន់នៅកម្ពុជាក្នុងរយៈពេល២ ឬ៣ សប្តាហ៍កន្លងមកនេះខូចខាតអស់ប៉ុន្មានដែរ?

លោក **សុទ្ធ គឹមភុលមុនី** បានឆ្លើយតបថា ការវាយតម្លៃចំណាយនៃការខូចខាតត្រូវបានធ្វើឡើងជាក្រុម។ នៅពេលថ្មីៗនេះ NCDM បាននឹងកំពុងធ្វើការជាមួយកាកបាទក្រហមជាតិនៃកម្ពុជាក្នុងការប៉ាន់ស្មានចំណាយការខូចខាតនិងតម្រូវការឆ្លើយតប។ លើសពីនេះ NCDM បាននឹងកំពុងធ្វើការរួមគ្នាជាមួយក្រសួងពាក់ព័ន្ធទាំងអស់ ដូចជា MAFF MoH MOWRAM ជាដើម ដើម្បីដោះស្រាយនូវកិច្ចការនេះ។

លោក **ហាស ចាន់ដេត** មកពី MEF បានស្នើសុំឲ្យមានការបញ្ជាក់បន្ថែមពី អត្ថន័យនៃពាក្យវិមជ្ឈការនៃការទទួលខុសត្រូវ និងធនធានរបស់ក្រុមការងារ។ លោកក៏បានសួរបន្ថែមផងដែរថា តើក្រុមការងារទទួលខុសត្រូវទាំងក្នុងការគ្រប់គ្រងកិច្ចការ និងធនធានហិរញ្ញវត្ថុដោយខ្លួនរបស់ពួកគេផ្ទាល់ ហើយតើប្រភពធនធានហិរញ្ញវត្ថុនោះបានមកពីណា?

លោក **សុទ្ធ គឹមភុលមុនី** បានពន្យល់ថា ក្រុមការងារទទួលខុសត្រូវទាំងការគ្រប់គ្រងកិច្ចការងារ និងធនធានហិរញ្ញវត្ថុដោយខ្លួនឯង។ ប៉ុន្តែការបែងចែកថវិកាសម្រាប់ក្រុមការងារនោះគឺមិនទាន់មាននៅឡើយទេ។ ចំពោះប្រភពនៃធនធានហិរញ្ញវត្ថុ វាអាចទទួលបានតាមរយៈប្រភពផ្សេងៗគ្នាដូចជាការប្រមូលថវិកាជាដើម។

លោក **ណុប ម៉ូលីន** មកពី Danish Church Aid/ Christianity Aid (DCA/CA) មានចម្ងល់ថា តើគម្រោង CCAI មានធ្លាប់ធ្វើការងារជាមួយដៃគូផ្សេងៗទៀត ដូចជា CSOs ឬរដ្ឋាភិបាលក្នុងទស្សនវិស័យកសាងសមត្ថភាពដែរឬទេ?

លោកបណ្ឌិត **Kien Tran-Mai** បានឆ្លើយតបថា MRC បាននឹងកំពុងធ្វើការជាមួយរាជរដ្ឋាភិបាល និង CSOs ឧទាហរណ៍ដូចជា សម្ព័ន្ធ

ភាពស្ត្រី សម្ព័ន្ធភាពយុវជន សមាគមកសិករ នៅក្នុងប្រទេសជាដៃគូនីមួយៗ។

លោក **ណុប ម៉ូលីន** មកពី DCA/CA មានចម្ងល់ថា ថាតើ MRC មានលទ្ធភាពចំពោះការធ្វើការងារបន្ថែមទៀតជាមួយបណ្តាញដែលមានស្រាប់នៅថ្នាក់តំបន់ដែរទេ?

លោកបណ្ឌិត **Kien Tran-Mai** បាននិយាយថា MRC បាននឹងកំពុងធ្វើការជាមួយបណ្តាញមានស្រាប់ក្នុងតំបន់ ដូចជា វេទិកាចំណេះដឹងបន្សុំ បណ្តាញបន្សុំអាស៊ីប៉ាស៊ីហ្វិច អង្គការអាងទន្លេជាដើម។

លោក **ភុប ម៉ាត់** ពីសាកលវិទ្យាល័យភូមិន្ទភ្នំពេញមានចម្ងល់ថា តើ MRC ដោះស្រាយយ៉ាងណា ជាមួយនឹងភាពមិនប្រាកដប្រជានៃភាពងាយរងគ្រោះ និងការវាយតម្លៃហានិភ័យដើម្បីធ្វើការឲ្យការអនុវត្តកាន់តែមានប្រសិទ្ធភាពនៅក្នុងជំហាននីមួយៗនៃការអនុវត្តគម្រោងទាក់ទងនឹងការប្រែប្រួលអាកាសធាតុ?

លោកបណ្ឌិត **Kien Tran-Mai** បានថ្លែងថា ភាពមិនប្រកដប្រជា គឺជាបញ្ហាប្រឈមដ៏ធំមួយក្នុងចំណោមការប្រឈមផ្សេងៗទៀត នៅក្នុងកិច្ចការងាររបស់ពួកគាត់។ ប៉ុន្តែ MRC កំពុងព្យាយាមឲ្យអស់ពីលទ្ធភាពក្នុងការកាត់បន្ថយភាពមិនប្រាកដប្រជាឲ្យបានទាបតាមរយៈការធ្វើឲ្យកាន់តែប្រសើរឡើង និងការធ្វើទំនើបកម្មនៃម៉ូឌែលជាប្រចាំ និងការធ្វើការជាមួយអ្នកជំនាញការបច្ចេកវិទ្យានានា។ MRC បាននឹងកំពុងព្យាយាមធ្វើការរួមគ្នាជាមួយដៃគូដែលមានស្រាប់ក្នុងគោលបំណងចែករំលែកចំណេះដឹង និងវិធីសាស្ត្រ និងធ្វើបច្ចុប្បន្នភាព និងថែទាំនូវឧបករណ៍ដែលកំពុងប្រើប្រាស់។ ហេតុដូច្នេះមានការជឿជាក់ថា កម្រិតនៃភាពមិនប្រាកដប្រជាអាចនឹងត្រូវបានកាត់បន្ថយ ខណៈពេលដែលភាពប្រាកដប្រជា និងភាពទុកចិត្តបាននៃការព្យាករណ៍របស់ម៉ូឌែល ត្រូវបានធ្វើឲ្យកាន់តែប្រសើរឡើង។

លោកស្រីបណ្ឌិត **ម៉ាក់ សុណាថ** ទីប្រឹក្សារបស់ MRC មានចម្ងល់ថា បើសិន MRC ប្រើប្រាស់ទិន្នន័យប្រវត្តិសាស្ត្រ ដើម្បីព្យាករណ៍ពីគ្រោះមហន្តរាយពេលអនាគត នៅក្នុងកម្រិតនៃភាពជឿជាក់គ្រប់គ្រាន់ ដើម្បីឲ្យប្រជាជនអាចយល់ដឹងបានច្បាស់ពីគ្រោះមហន្តរាយនោះ តើព័ត៌មាននេះមានការផ្សព្វផ្សាយដែរទេ?

លោកបណ្ឌិត **Kien Tran-Mai** បាននិយាយថា ជាការពិតណាស់ MRC បានកំពុងធ្វើការជាមួយសេណារីយ៉ូ ៦ ផ្សេងៗគ្នា នៅក្នុងការប្រមូលទិន្នន័យឬព័ត៌មានដើម្បីបង្កើតម៉ូឌែលព្យាករណ៍អនាគត ដែលអាចជឿទុកចិត្តបាន។ លើសពីនេះផងដែរ MRC បានបង្កើតគម្រោងមួយ ដែលហៅថា"គម្រោងទទួលស្គាល់ព័ត៌មាន (IAP)" ដែលមានទីតាំងនៅក្នុងប្រទេសកម្ពុជាផ្ទាល់តែម្តង។ គោលដៅចម្បងរបស់ IAP គឺដើម្បីបង្រួបបង្រួម និងប្រមូលព័ត៌មានដែលអាចអនុវត្តបាន និងបង្កើតការសិក្សា ក្នុងនាមជាប្រទេសសមាជិក ជាមួយនូវបច្ចេកវិទ្យាចុងក្រោយបំផុត និងក្រុមម៉ូឌែល ដែលមានបច្ចេកទេសខ្ពស់។

កញ្ញា **Alice Burke** មកពីកាសែត Cambodia Daily ចង់ឲ្យមានការបញ្ជាក់ខ្លះៗអំពីគម្រោងទំនប់ថា តើមានផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ បើសិនជាគម្រោងទំនប់ទាំងអស់នោះកើតមានឡើង?

លោកបណ្ឌិត **Kien Tran-Mai** បានពន្យល់ថា វាមានភាពលំបាកក្នុងការព្យាករណ៍ពីព្រោះ លោកមិនច្បាស់ថា តើរាល់គម្រោងទាំងអស់នឹងត្រូវបានអនុវត្ត ឬអត់។ គម្រោងខ្លះត្រូវបានផ្អាករួចជាស្រេចទៅហើយ ហើយនឹង

កំពុងរង់ចាំការសិក្សាបន្ថែម ក្នុងគោលបំណងកាត់បន្ថយផលប៉ះពាល់ដល់កម្រិតមួយ ដែលអាចទទួលបាន។

លោក **ម៉ែន ប៊ុណ្ណារ៉ា** ពី CI មានសំណួរថា តើ "ការបញ្ចូលថ្នាក់ក្រោមជាតិ (Integrated Sub-national Level)" អាចមានប្រសិទ្ធភាពកាន់តែប្រសើរឡើងបានយ៉ាងដូចម្តេចក្នុងការធ្វើការងារ និងការគ្រប់គ្រងថវិកាសម្រាប់គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ?

លោក Alex Heikens បានឆ្លើយថាវាអាស្រ័យលើប្រព័ន្ធរដ្ឋបាលមូលដ្ឋាន ដែលគេកំពុងដោះស្រាយជាមួយ ដូច្នេះ អ្វីដែលពួកគេត្រូវធ្វើគឺ ធ្វើការជាមួយរដ្ឋាភិបាលមូលដ្ឋាន។

លោកបណ្ឌិត **Kien Tran-Mai** មានចំណាប់អារម្មណ៍អំពី ការប្រឈម ឬផលលំបាកនានា ក្នុងការដោះស្រាយជាមួយកិច្ចការក្រុមការងារកម្រិតខ្ពស់ ដូចជាកម្រិតតំបន់ ឬអន្តរជាតិ នៅក្នុងដំណើរការចរចា។

លោក **Alex Heikens** បានឆ្លើយតបថា ការប្រឈមនេះ អាចបានឃើញក្នុងដំណើរការនៃការចរចារវាងកម្រិតប្រទេសនីមួយៗ នៅក្នុងតំបន់ ដើម្បីស្វែងរកការយល់ដឹងបន្ថែមពីចំណាប់អារម្មណ៍របស់ប្រទេសនីមួយៗ នៅក្នុងការដោះស្រាយ បញ្ហាបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ បញ្ហាបច្ចេកទេស និងនយោបាយ គឺជា បញ្ហាប្រឈមចម្បងៗ ដែលត្រូវគិតពិចារណាផងដែរ។

លោក **សុខ ពិសិដ្ឋ** មកពី MoWA បានសួរបន្ថែមពីនិយមន័យរបស់ "ទ្រព្យប្រជាជន" និងរបៀបដែល"ទ្រព្យប្រជាជន" អាចត្រូវបានកសាងសម្រាប់ការឆ្លើយតបនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

លោកបណ្ឌិត **Rechard Friend** បានពន្យល់ថា "ទ្រព្យប្រជាជន" ជាធម្មតាអាចញែកជាប្រភេទផ្សេងៗគ្នា។ ទ្រព្យធនធានធម្មជាតិ សំដៅទៅលើដី ទឹក ព្រៃឈើ និងជលផល។ ទ្រព្យប្រជាជនសំដៅទៅលើជំនាញ ចំណេះដឹង និងព័ត៌មានជាដើម។ ទ្រព្យរូបវន្ត សំដៅទៅលើផ្លូវ សាលារៀន និងមន្ទីរពេទ្យ។ ទ្រព្យសេដ្ឋកិច្ច សំដៅទៅលើប្រាក់ចំណូល និងទីផ្សារ។ ទ្រព្យសង្គម សំដៅទៅលើក្រុមជួយខ្លួនឯង ក្រុមសហគមន៍ និងបណ្តាញ។ នៅពេលគិតពីទ្រព្យត្រូវគិតពីវិធី ដែលមនុស្សអាចបង្វែរទ្រព្យទាំងអស់នេះទៅជាផលប្រយោជន៍។

លោកបណ្ឌិត **Kien Tran-Mai** មកពី MRC បានសួរបណ្ឌិត Richard ឲ្យពន្យល់បន្ថែមពីអត្ថន័យ "សុវត្ថិភាពចាកផុតពីភាពបរាជ័យ"?

លោកបណ្ឌិត **Richard Friend** បានពន្យល់ថា "សុវត្ថិភាពចាកផុតពីភាពបរាជ័យ" ត្រូវបានប្រើ នៅពេលដែលផលប៉ះពាល់កើតមានពីគម្រោងមួយ ឬជាប់ពាក់ព័ន្ធនឹងការបរាជ័យ ប៉ុន្តែ គម្រោងនោះត្រូវតែគ្រប់គ្រងឲ្យបានត្រឹមត្រូវដើម្បីឲ្យមានសុវត្ថិភាព។

លោកបណ្ឌិត **R. Taber Hand** មកពីអង្គការតំបន់ដីសើមមានចម្ងល់ថា តើក្នុងការអនុវត្តគម្រោងនៅកម្ពុជា មានការគិតពិចារណាលើចំនួន និងរបាយអាយុរបស់ប្រជាជនដែរឬទេ?

លោកបណ្ឌិត **Richard Friend** បាននិយាយថាចំនួន និងរបាយអាយុរបស់ប្រជាជននៅកម្ពុជា ជាទូទៅភាគច្រើន គឺយុវជន ហើយចំនួនយុវជននេះ គឺជាបញ្ហាប្រឈមមួយ ដែលយើងត្រូវគិតពីទីផ្សារការងារ ការអប់រំ និងបញ្ហាផ្សេងៗទៀត។ បញ្ហាប្រឈមចំពោះមុខ គឺអសមភាពរវាងប្រជាជននៅក្នុងសង្គម និងភាពក្រីក្រ។ ដូចច្នេះ អ្វីដែលកំពុងអនុវត្តឥឡូវនេះ

គឺកំពុងព្យាយាមមើលពី ការប្រែប្រួលអាកាសធាតុក្នុងទស្សនវិស័យផ្សេងគ្នា និងរកដំណោះស្រាយបច្ចេកវិទ្យាសមស្រប ដើម្បីជំនះនឹងបញ្ហាទាំងនោះ ហើយត្រូវផ្តល់ព័ត៌មានដល់សាធារណជនជាមុន។

លោក **ខែន ឌីរៈ** ពីមន្ទីរបរិស្ថាន ខេត្តកំពតបានសួរ Dr. Richard ឲ្យជួយបកស្រាយឃ្លា "ប្រសិទ្ធភាពស្តង់ដាច្បាប់"។

លោកបណ្ឌិត Richard Friend បានឆ្លើយថា ប្រទេសជាច្រើនជុំវិញពិភពលោកកំពុងពុះពារយ៉ាងខ្លាំង ជាមួយនឹងពាក្យ ប្រសិទ្ធភាពស្តង់ដាច្បាប់នេះ។ ជាឧទាហរណ៍ ការបង្កើតស្តង់ដានៃការបំពុលនៅក្នុងប្រទេសមួយឲ្យមានប្រសិទ្ធភាព តែការដាក់ស្តង់ដានោះដើម្បីអនុវត្តជាធរមាន គឺជាបញ្ហាប្រឈមមួយដ៏ធំ។ ជារួមមកប្រទេសជាច្រើនកំពុងតែប្រឈមមុខជាមួយបញ្ហានេះ ហើយវាគ្រាន់តែជាកត្តាពេលវេលាប៉ុណ្ណោះក្នុងការដោះស្រាយបញ្ហានេះ។

ភគ្គស្របគ្នាទី ២

ការកាត់បន្ថយការប្រែប្រួលអាកាសធាតុៈ ស្ថានភាព ការរីកចម្រើន មេរៀនទទួលបាន ភាពខ្វះចន្លោះផ្នែកគោលនយោបាយ និងអនុសាសន៍

សហប្រធានៈ

១. **ឯកឧត្តមបណ្ឌិត សាត សាមី** រដ្ឋលេខាធិការនៃ MIME និងជាអនុប្រធាន NCCC

២. **ឯកឧត្តម ឆេង គីមស៊ុន** ប្រតិភូ RGC ទទួលបន្ទុកជាប្រធាន FA

ការអភិវឌ្ឍបៃតង ការអភិវឌ្ឍដែលបញ្ចេញកាបូនទាប

ដោយលោកស្រី Aneta Nikolova មន្ត្រីកិច្ចការបរិស្ថានផ្នែកបរិស្ថាន និងការអភិវឌ្ឍនៃអង្គការ UNESCAP

បទបង្ហាញនេះ បានធ្វើការពិនិត្យលើទស្សនទាននៃការអភិវឌ្ឍបៃតង ទំនាក់ទំនងរបស់វាជាមួយនឹងការប្រែប្រួលអាកាសធាតុ និងកត្តា ដែលជម្រុញដល់ការអនុវត្តប្រកបដោយជោគជ័យនៃទស្សនទាននេះនៅកម្ពុជា។

ដំបូងលោកស្រី Nikolova បានបញ្ជាក់ថា ការអភិវឌ្ឍបៃតង មិនត្រឹមតែជាយុទ្ធសាស្ត្រនៃការកាត់បន្ថយប៉ុណ្ណោះទេ ប៉ុន្តែក៏ជាយុទ្ធសាស្ត្រនៃការបន្សាំផងដែរ។ បច្ចុប្បន្ននេះ ព្រំប្រទល់រវាងការបន្សាំ និងការកាត់បន្ថយ មិនអាចចែកឲ្យដាច់ពីគ្នាបានទេ។ ប្រសិនយើងអនុវត្តការបន្សាំជាមួយប្រពលកាបូនទាប និងពុំមានប្រសិទ្ធភាពធនធានយើងនឹងប្រឈមជាមួយនឹងបញ្ហា។

ការវិភាគពី ស្ថានភាពទូទៅនៅអាស៊ី បង្ហាញថា តំបន់ប៉ាស៊ីហ្វិកកំពុងស្ថិតក្នុងវឌ្ឍនភាពដ៏ឆាប់រហ័ស។ តំបន់នេះត្រូវការកំណើនសេដ្ឋកិច្ចយ៉ាងលឿន ដែលអាចជាប្រយោជន៍ដល់ការកាត់បន្ថយភាពក្រីក្រ និងភាពអត់ឃ្លានរបស់ប្រជាជននៅក្នុងតំបន់។ ប៉ុន្តែការអភិវឌ្ឍបែបនេះក៏ជាប់ពាក់ព័ន្ធជាមួយផលវិបាកផ្សេងៗទៀតផងដែរ ដូចជា ការលើសពីសមត្ថភាពផ្ទុកនៃបរិស្ថានធម្មជាតិ អសមភាពនៃការបែងចែកផលចំណេញ ទទួលបានកិច្ចការពារពីសង្គមមិនគ្រប់គ្រាន់ ការកើនឡើងនូវភាពគ្មានការងារធ្វើ និងភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច ។ លើសពីនេះទៀត នៅក្នុងតំបន់នេះ ងាយនឹងរងគ្រោះដោយសារការប៉ះទង្គិចពីខាងក្រៅ ដោយសារតែកំណើនសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ ពឹងផ្អែកយ៉ាងខ្លាំងលើការនាំចេញ។ ដូច្នេះ ការគិតគូរពីឱកាសខាងក្នុងគឺ មានសារសំខាន់ណាស់ និង ដើម្បីលើកកម្ពស់សក្តានុពលនៃការប្រើប្រាស់របស់ប្រជាជន។ តំបន់នេះក៏ងាយនឹងរង

គ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ មហន្តរាយធម្មជាតិ និងការប្រែប្រួលតម្លៃម្ហូបអាហារ ប្រេងឥន្ធនៈ និងធនធានផ្សេងៗទៀត សម្រាប់ផលិតកម្ម។ អ្នកស្រីក៏បានចែងផងដែរថា ហានិភ័យ និងភាពមិនប្រាកដប្រជាក្នុងតំបន់ហាក់ដូចជាមានកម្រិតខ្ពស់ ហើយកង្វះខាតធនធានសម្រាប់ផលិតកម្មគឺជាបញ្ហាមួយផ្សេងទៀតដែលតំបន់នេះកំពុងប្រឈមមុខ។

ផលិតផលកសិកម្មទទួលផលប៉ះពាល់ខ្លាំងជាងគេពីការប្រែប្រួលអាកាសធាតុ ហើយផលប៉ះពាល់វិស័យនេះ ជះឥទ្ធិពលខ្លាំងដល់ជីវភាពរស់នៅនៃប្រជាជន ។ ដូច្នេះពិភពលោកទាំងមូល ត្រូវការសេដ្ឋកិច្ចពិតប្រាកដថ្មីមួយ ។ តំបន់របស់យើងបានស្នើឡើងនូវ យុទ្ធសាស្ត្រថ្មីដើម្បីធ្វើឲ្យមាន ការរីកចម្រើនផ្នែកសេដ្ឋកិច្ច ហើយយុទ្ធសាស្ត្រនេះ អាចធ្វើឲ្យតំបន់នេះមានធនធានសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ចមិនប៉ះពាល់បរិស្ថាន និងការអភិវឌ្ឍប្រកបដោយចីរភាព។ កត្តាទាំងអស់នេះ មានបង្ហាញនៅក្នុងឯកសារបោះពុម្ពផ្សាយផ្សេងៗសិក្សាដោយ ESCAP ADB និង UNEP។ អ្នកស្រីក៏សម្តែងនូវសេចក្តីរីករាយផងដែរ ដែលឮថា ADB នឹងធ្វើការងារផ្តោតការអភិវឌ្ឍធនធាន និងគោលនយោបាយនៅក្នុងប្រទេសកម្ពុជា។ តំបន់អាស៊ីប៉ាស៊ីហ្វិកប្រើប្រាស់ធនធាន និងថាមពលច្រើនជាងគេបំផុត។ ប្រភពថាមពលភាគច្រើន មិនកកើតឡើងវិញទេ ដូច្នេះនាំឲ្យមានការបញ្ចេញឧស្ម័នច្រើន។ អ្នកស្រីក៏បានបង្ហាញផងដែរពីក្រាហ្វិចនៃការកើនឡើងការប្រើប្រាស់សម្ភារៈ ក្នុងស្រុកនៅក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងអំឡុងពេល (១៩៧០-២០០៥) ដែលលើសពីតំបន់ផ្សេងៗទៀតនៅលើពិភពលោក។ យោងតាមក្រាហ្វិកអំពីប្រពលភាពកាបូនធៀបនឹង GDP ក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិកបង្ហាញថា តំបន់នេះប្រើប្រាស់ធនធានបីដង ច្រើនជាងតំបន់ផ្សេងៗទៀតនៅលើពិភពលោក។

តំបន់អាស៊ីប៉ាស៊ីហ្វិក ក៏ប្រឈមមុខនឹងឧបសគ្គច្រើនទៀតដូចជា តំបន់មានផលិតភាពតិចតួច ធនធានទឹកមានកំណត់ និងដង់ស៊ីតេប្រជាជនខ្ពស់។ តំបន់នេះក៏អាចប្រឈមនឹងបញ្ហាមួយចំនួន ដូចជា ដំណាំពុំមែនជាអាហារអត្រាភាពអត់ឃ្លានខ្ពស់ និងសុខភាព និងផលិតភាពស្ថានប្រព័ន្ធកំពុងតែធ្លាក់ចុះ។ ដើម្បីដោះស្រាយបញ្ហាទាំងនេះ គឺត្រូវមើលលើគុណភាពនៃការលូតលាស់ផ្នែកសេដ្ឋកិច្ច ក្នុងលក្ខណៈចម្រុះ ដែលគិតគូរទាំង គុណភាពសេដ្ឋកិច្ច គុណភាពអេកូឡូស៊ី និងគុណភាពសង្គម។ នេះគឺអ្វីដែលជា សំណើនៃកំណើនសេដ្ឋកិច្ចបៃតង។ គំរូនៃការអភិវឌ្ឍបច្ចុប្បន្ន ដែលយើងកំពុងចម្លង និងអនុវត្តតាម ក្នុងតំបន់នេះនឹងមិនមានចីរភាពទេជាមួយនឹងបញ្ហា ដែលមានក្នុងតំបន់នោះ។ ជាងនេះទៀត យើងមិនបានដើរ ក្នុងទិសដៅត្រឹមត្រូវទេ ព្រោះយើងត្រូវមើលទស្សនទាននៃការអភិវឌ្ឍបៃតង នៃរចនាសម្ព័ន្ធ សេដ្ឋកិច្ចមើលឃើញ និងរចនាសម្ព័ន្ធសេដ្ឋកិច្ចមើលមិនឃើញផងដែរ។

អ្នកស្រីបានឆ្លើយទៅនឹងសំណួរ ដែលប្រជាជនភាគច្រើនសួរថា តើការអភិវឌ្ឍបៃតងអាចអនុវត្តបាននៅក្នុង DCs ដែរឬទេ? អ្នកស្រីបានបកស្រាយថា ការអភិវឌ្ឍបៃតងមិនមែនគ្រាន់តែពីថវិកា និងបច្ចេកវិទ្យាប៉ុណ្ណោះទេ ក៏ប៉ុន្តែជាការប្តេជ្ញាខាងនយោបាយ និងក្របខណ្ឌការងារគោលនយោបាយផងដែរ។ ឧទាហរណ៍ក្នុងឆ្នាំ២០០៨ កម្ពុជា គឺជាប្រទេស ដែលនាំមុខគេក្នុងចំណោម DCs ក្នុងការបង្កើតផែនទីបង្ហាញផ្លូវការអភិវឌ្ឍបៃតង ដែលផែនទីបង្ហាញផ្លូវនេះ ត្រូវបានបង្កើតឡើងក្រោមកិច្ចសហប្រតិបត្តិការជាមួយក្រសួងពាក់ព័ន្ធ និងដឹកនាំដោយ MoE ហើយត្រូវបានបង្ហាញជូនទៅ នាយករដ្ឋមន្ត្រី។ អ្វីដែលយើងត្រូវធ្វើឥឡូវនេះគឺជា ការវាស់ ស្ទង់សេដ្ឋកិច្ចឡើងវិញ ដោយបង្កើតគ្រឿងម៉ាស៊ីននៃការអភិវឌ្ឍបៃតង និងបម្លែងពីការប្រើ

ប្រាស់ធនធានច្រើន ទៅជាការសន្សំសំចៃធនធាន និងការបង្កើតទីផ្សារការងារ។ វិធានគន្លឹះនោះ គឺការប្រើប្រាស់ពន្ធបៃតង និងកំណែទម្រង់ថវិកា ដើម្បីកំណត់ការប្រើប្រាស់ធនធានលើសកម្រិត។

អ្នកស្រីក៏បានបង្ហាញពី ភាពជោគជ័យមួយចំនួន ដែលបានមកពីការអភិវឌ្ឍបៃតង ឧទាហរណ៍ដូចជា គម្រោង "សំរាមជាមាស-ប្រាក់" នៅប្រទេសបង់ក្លាដែស សិរីសង្កា និងវៀតណាម។ គម្រោង "ប្រព័ន្ធជួលចង្កៀងប្រើថាមពលព្រះអាទិត្យ" នៅប្រទេសឡាវ ឧបត្ថម្ភធនលើប្រេងឥន្ធនៈ នៅប្រទេសឥណ្ឌូនេស៊ី TukTuk ប្រើពន្លឺព្រះអាទិត្យនៅប្រទេសថៃ និងថាមពលវារីអគ្គីសនីមីក្រូ ដែលមិនត្រូវការអាងស្តុកដើម្បីផលិតអគ្គីសនី ។ល។

ទីផ្សារថាមពលកកើតឡើងខាងក្នុងកម្ពុជា៖ ផ្នាំឲស្រូបថាមពលពន្លឺព្រះអាទិត្យ និងបច្ចេកវិទ្យាថាមពលខ្យល់

*ដោយអ្នកស្រី **Margaret Jane Ryan** ក្រុមហ៊ុនខ្មែរសូឡា*

បទបង្ហាញនេះ បានធ្វើការពិនិត្យឡើងវិញ ដោយផ្អែកលើទស្សនៈរបស់វិស័យឯកជនពីការវិវឌ្ឍស្ថានភាពនាពេលបច្ចុប្បន្ន ឧបសគ្គ និងចក្ខុវិស័យ នៃទីផ្សារផ្នាំងស្រូបថាមពលពន្លឺព្រះអាទិត្យ និងបច្ចេកវិទ្យាថាមពលខ្យល់នៅកម្ពុជា។

អ្នកស្រី **Ryan** បានបញ្ជាក់ថា ក្រុមហ៊ុនខ្មែរសូឡា ជាក្រុមហ៊ុនតូចមួយ ដែលបង្កើតឡើងក្នុងឆ្នាំ ១៩៩៧ និងធ្វើការជាមួយនឹងផលិតផលថាមពលព្រះអាទិត្យ។ អ្នកស្រីបានរៀបរាប់ដោយសង្ខេបពី សនិទានភាព ដែលក្រុមហ៊ុននេះចាប់ដំណើរការនៅកម្ពុជា ដូចជាថាមពលពន្លឺព្រះអាទិត្យ រួមចំណែកកាត់បន្ថយការប្រើឥន្ធនៈហ្វូស៊ីល និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ អាចបង្កើនជីវភាពរស់នៅដល់អ្នករស់តំបន់ដែលគ្មានថាមពលអគ្គីសនីប្រើប្រាស់។ ថាមពលព្រះអាទិត្យ មានភាពសម្បូរបែប និងអាចប្រើប្រាស់បានពេញមួយឆ្នាំ ហើយប្រជាជនមានសមត្ថភាពក្នុងការថែទាំប្រព័ន្ធ។ ដោយសារកង្ហារដើរ ដោយថាមពលខ្យល់មិនអាចដំណើរការបានល្អនៅកម្ពុជា ដូចនេះ ទីផ្សារថាមពលខ្យល់ក៏អវត្តមានដែរ ។

អ្នកស្រីក៏បានពន្យល់ទៀតពី ឧបសគ្គចំពោះការពង្រីកទីផ្សារថាមពលព្រះអាទិត្យ នៅកម្ពុជាកាលពីឆ្នាំ១៩៩៧ ។ ឧបសគ្គជាចម្បងៗរួមមាន៖ ការយកពន្ធនាំចូល (៣៥%) កង្វះខាតការយល់ដឹងជាសាធារណៈ កង្វះខាតទិន្នន័យគ្រប់គ្រាន់ កង្វះខាតធនធានមនុស្ស ដែលមានសមត្ថភាពគ្រប់គ្រាន់ ដើម្បីរក្សាសេវាកម្ម ជាពិសេសនៅតំបន់ជនបទ ដែលប្រព័ន្ធត្រូវបានតម្លើង និងលទ្ធភាពទទួលយកបានរបស់ប្រជាជនមូលដ្ឋាន។

អ្នកស្រី បានសម្តែងនូវភាពរីករាយទៅលើការរីកចម្រើនរយៈពេល១០ឆ្នាំនេះ ដោយពន្ធនាំចូលត្រូវបានធ្លាក់ចុះពី ៣៥% មកត្រឹម ៧% ដែលជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់វិស័យឯកជន និង MIME ។ លើសពីនេះទៅទៀត មានជំនួយពីបណ្តាប្រទេសមួយចំនួន ដូចជាប្រទេសជប៉ុន ប្រទេសហូឡង់ ប្រទេសបារាំង និងសហរដ្ឋអាមេរិក ដើម្បីចីរភាព និងអប់រំពូកគេ (ខ្មែរសូឡា) ទាក់ទងនឹងវិស័យនេះ ព្រោះពូកគេចាប់ផ្តើមដោយមិនដឹងអ្វីទាំងអស់។

អ្នកស្រី **Ryan** លើកជាសំណួរឡើងថា តើយើងបានបង្កើតទីផ្សារផលិតជាផលិតផលដែលគ្មានអ្នកណាដឹងពី ផលិតផលនោះសោះ ហើយព្យាយាមបញ្ចុះបញ្ចូលប្រជាជន ដើម្បីទទួលយកផលិតផលនេះ ក្នុងអំឡុងពេលមួយដ៏វែង? អ្នកស្រីបានឆ្លើយតបថា វាអាចជាបន្សំគ្នារវាងបញ្ហា ព្រោះនៅពេលដែលប្រជាជនមិនដឹង

ពីថាមពលពន្លឺព្រះអាទិត្យនឹងសូរអំពីវា។ ឆ្លុះបញ្ចាំងអំពីបញ្ហានេះឃើញថា ចំនួនក្រុមហ៊ុនថាមពលពន្លឺព្រះអាទិត្យ នៅក្នុងសៀវភៅលឿងមានការកើនឡើងពីចំនួន៣ នៅឆ្នាំ១៩៩៨ រហូតដល់ចំនួន១៣ នៅឆ្នាំ២០១១។

អ្នកស្រីបានបញ្ជាក់ទៀតថា MIME ស្ថិតនៅក្រោមការដឹកនាំរបស់ ឯកឧត្តមបណ្ឌិត **សាត សាមី** បានបង្កើត និងបង្កបរិយាកាសអំណោយផលដល់ម្ចាស់ជំនួយនានា ចូលមកធ្វើការនៅក្នុងវិស័យនេះជាច្រើនឆ្នាំហើយ។ មានប្រពល ភាពសិក្ខាសាលានៃការអប់រំ និងទស្សនកិច្ចសិក្សាជាច្រើនត្រូវបានរៀបចំ ដើម្បីណែនាំពីខ្មែរសូឡា ពីប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះ និងវិធីដែលទីផ្សារបានអភិវឌ្ឍនៅបណ្តាប្រទេសនានា។ ជាការពិត ខ្មែរសូឡាគ្មានគំនិតក្នុងការអភិវឌ្ឍប្រព័ន្ធពន្លឺព្រះអាទិត្យនៅតាមផ្ទះនោះទេ ពីព្រោះគំនិតដំបូងរបស់ខ្មែរសូឡា គឺមានបំណងផ្តត់ផ្តង់ទៅលើទីផ្សារ NGOs ប៉ុណ្ណោះ។

លើសនេះទៀត អ្នកស្រីបានបកស្រាយពីទីផ្សារបីប្រភេទផ្សេងទៀតនៅកម្ពុជា ដូចជាទូរគមនាគមន៍ NGOs និងប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះ។

ក្នុងវិស័យទូរគមនាគមន៍ អ្នកស្រីក៏បានផ្តល់ជាឧទាហរណ៍ថា ចំពោះប្រជាជន ដែលចូលចិត្តប្រើប្រាស់ទូរទស្សន៍ពណ៌ និងទូរស័ព្ទចល័ត ឥឡូវនេះខ្មែរសូឡាអាចផ្តល់ជូនបានជាមួយនឹងប្រព័ន្ធពន្លឺព្រះអាទិត្យ ដែលអាចប្រើបានជាមួយបច្ចេកវិទ្យាទាំងនោះ។ ឧទាហរណ៍ផ្សេងទៀតដូចជា ប្រព័ន្ធអ៊ីប៊ីត ដែលប្រើជាមួយប៉មទូរគមនាគមន៍នៅជនបទ ជាមួយការវិភាគពីចំណាយ និងផលចំណេញនៃការប្រើប្រាស់ឥន្ធនៈ និងប្រព័ន្ធពន្លឺព្រះអាទិត្យ។

អ្នកស្រីបានបញ្ជាក់ថា វិស័យ NGOs មានចំណែកទីផ្សារពន្លឺព្រះអាទិត្យដ៏ធំមួយ និងជាទូទៅ NGOs ប្រើប្រាស់ថាមពលពន្លឺព្រះអាទិត្យកន្លែងណា ដែលគ្មានបណ្តាញអគ្គិសនីសាធារណៈ។ អ្នកស្រីបានបកស្រាយដោយសង្ខេប អំពីឧទាហរណ៍ពីររបស់ NGOs ដែលបានភ្ជាប់បណ្តាញនេះគឺជា គម្រោងសាលារៀនជនបទ ដែលដំណើរការដោយ Kernie Krisher របស់កាសែត TheCambodia Daily និងអង្គការទស្សនៈពិភពលោក ក្រោមភាពជាដៃគូជាមួយ MoEYS។ អ្នកស្រីបន្ថែមទៀតថា ការគ្រប់គ្រងប្រព័ន្ធពន្លឺព្រះអាទិត្យ បានដំណើរការយ៉ាងល្អជាមួយនឹង NGOs ដោយគ្រាន់តែត្រូវការការប្រឹក្សាយោបល់ម្តងម្កាល ជាមួយខ្មែរសូឡា តែប៉ុណ្ណោះ។

ចុងបញ្ចប់ អ្នកស្រីបានចែករំលែកនូវបទពិសោធន៍នៃទីផ្សារពន្លឺព្រះអាទិត្យ នៅក្នុងខេត្តបាត់ដំបង។ ខ្មែរសូឡាបានបង្កើតការិយាល័យថ្មីក្នុងខេត្តបាត់ដំបង នៅឆ្នាំ២០០៤ ដែលប្រើប្រាស់នូវលទ្ធផល ដែលត្រឹមត្រូវ និងអាចទទួលយកបានពីការស្ទាបស្ទង់មតិទីផ្សារ នៅទីនោះ អ្នកស្រីបានធ្វើការកត់សម្គាល់ថា ចំនួននៃការទិញប្រព័ន្ធពន្លឺព្រះអាទិត្យតាមផ្ទះបានកើនឡើងគួរឲ្យកត់សម្គាល់ និងតម្រូវការទូរទស្សន៍ពណ៌ក៏កើនឡើងផងដែរ។ ទោះបីយ៉ាងនេះក៏ដោយ នីតិវិធីនៃការបង់ថ្លៃ និងការអនុវត្តនៅតំបន់ផ្សេង ដោយប្រើគំរូខេត្តបាត់ដំបង ត្រូវការការពិចារណាបន្ថែមទៀត។

ភាពជាដៃគូផ្នែកថាមពល និងបរិស្ថាននៅតំបន់មេគង្គៈ ឧទាហរណ៍អំពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុថ្នាក់តំបន់

*ដោយអ្នកស្រី **Kati Veijonen** អគ្គកុងស៊ុល ស្ថានទូតហ្វាំងឡង់ប្រចាំនៅក្រុងបាងកក*

គោលបំណងនៃបទបង្ហាញនេះគឺ ធ្វើការចែករំលែកបទពិសោធន៍ គំនិតផ្តួចផ្តើមក្នុងអនុតំបន់ទន្លេមេគង្គមានចំណងជើងថា "កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថាននៅក្នុងតំបន់

មេគង្គ" ដើម្បីលើកកម្ពស់ការអភិវឌ្ឍថាមពលប្រកបដោយចីរភាព និងការកាត់បន្ថយ GHGs។

អ្នកស្រី **Veijonen** បាននិយាយថា ដោយការអនុវត្តកម្មវិធីប្រកបដោយជោគជ័យ ដែលផ្តួចផ្តើមឡើងនៅតំបន់អាមេរិកកណ្តាល ចាប់តាំងពីឆ្នាំ២០០២មក កម្មវិធីនេះបានយកមកអនុវត្តបន្ត ក្នុងតំបន់ផ្សេងៗទៀតលើពិភពលោក ដោយអនុលោមទៅតាមលក្ខខណ្ឌ និងតម្រូវការមូលដ្ឋាន។ កម្មវិធីទាំងនេះរួមមាន កម្មវិធីភាពជាដៃគូខាងថាមពល និងបរិស្ថាន (EEP) មេគង្គ EEP អាហ្វ្រិកខាងត្បូង និងខាងកើតចាប់ផ្តើមឆ្នាំ២០១០ និងថ្មីនេះ EEP នៅប្រទេសឥណ្ឌូនេស៊ី និងអាមេរិក ខាងត្បូងក៏បានចាប់ផ្តើមដំណើរការផងដែរ។ គោលបំណងរបស់កម្មវិធី EEP នៅតំបន់មេគង្គគឺ ដើម្បីរួមចំណែកបង្កើនការទទួលបានថាមពល និងសេវាកម្មថាមពលនិងការកាត់បន្ថយការបញ្ចេញ GHGs ។ លទ្ធផលរំពឹងទុកនៃកម្មវិធីនេះ គឺតាមរយៈសកម្មភាពរបស់ EEP គ្រួសារនៅជនបទ ជីវភាពរស់នៅរបស់ប្រជាជន និង SMEs នឹងអាចទទួលបាននូវសេវាកម្ម និងបច្ចេកវិទ្យាថាមពលកកើតឡើងវិញប្រសើរជាងមុន។ កម្មវិធី EEP តំបន់មេគង្គគ្របដណ្តប់លើប្រទេសកម្ពុជា ឡាវ ថៃ និងវៀតណាម និងខេត្តចំនួនពីរនៅប្រទេសឥណ្ឌូនេស៊ី។

អ្នកស្រីបានបញ្ជាក់ថា នាពេលបច្ចុប្បន្ននេះ កម្មវិធី EEP តំបន់មេគង្គដំណាក់កាលទី ១ អនុវត្តបានពាក់កណ្តាល ហើយកម្មវិធីនេះឧបត្ថម្ភដោយ ក្រសួងការបរទេសនៃប្រទេសហ្វាំងឡង់ និង NDF ដែលមានថវិកាសរុប ចំនួន ៧,៩លានអឺរ៉ូ សម្រាប់រយៈពេលបីឆ្នាំ (២០១០-២០១២)។ សមាសធាតុចម្បងៗរបស់ EEP តំបន់មេគង្គ គឺរួមចំណែកក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលគាំទ្រដល់គោលនយោបាយជាតិ ច្បាប់ និងក្របខណ្ឌការងារស្ថាប័ន គាំទ្រការអភិវឌ្ឍថាមពលកកើតឡើងវិញ សំណល់ជាថាមពល ប្រសិទ្ធភាព ថាមពល និងទីផ្សារថាមពល។

ជាធម្មតា EEP មានការប្រកាសទទួលសំណើគម្រោងពីរដងក្នុងមួយឆ្នាំ ដែលមកទល់ពេលនេះ ការបើកទទួលសំណើរបានចំនួន បីដងហើយ។ អ្នកដែលមានសិទ្ធិដាក់ពាក្យសុំបានគឺអាចមកពីស្ថាប័នគ្រប់ប្រភេទ លើកលែងតែបុគ្គលឯកជន និងអង្គការផ្តល់មូលនិធិផ្សេងទៀតដូចជា អង្គការអន្តរជាតិ និងមូលនិធិផ្តល់ជំនួយ មិនអាចដាក់ពាក្យសុំដើម្បីទទួលមូលនិធិនេះបានទេ។ គម្រោងដែលដាក់ស្នើសុំត្រូវតែជាគម្រោងដៃគូ។ ដូច្នេះ ត្រូវតែមានដៃគូយ៉ាងហោចណាស់ចាប់ពីពីរឡើងទៅ។

ចំណែកឯវិស័យបច្ចេកទេស ដែលកម្មវិធីផ្តោតជាសំខាន់គឺ ថាមពលកកើតឡើងវិញ (ជាឧទាហរណ៍ ជីវម៉ាស់ ជីវឥន្ធនៈ ជីវឧស្ម័ន ប្រសិទ្ធភាពថាមពល)។ សកម្មភាពគម្រោងដែលអាចដាក់សំណើបានត្រូវជា៖

- គម្រោងសាកល្បង
- គម្រោងអនុវត្តបង្ហាញ
- ការសិក្សាពីលទ្ធភាព
- ការកសាងសមត្ថភាព/វគ្គបណ្តុះបណ្តាល
- យុទ្ធសាស្ត្រ/ការសិក្សាពីគោល-នយោបាយ

ទោះបីយ៉ាងនេះការសិក្សាពីយុទ្ធសាស្ត្រ និងគោលនយោបាយ ត្រូវដាក់ស្នើតាមរយៈការសម្របសម្រួលថ្នាក់ជាតិតែប៉ុណ្ណោះ។ មានការដាក់កម្រិតផ្នែកបច្ចេកទេសខ្លះលើគម្រោងដែលនឹងត្រូវដាក់សុំមូលនិធិ រាប់បញ្ចូលទាំងគម្រោងដែលផលិតជីវឥន្ធនៈសម្រាប់នាំចេញ និងថាមពលវារី អគ្គីសនីតិចជាង ១០MW មិនអាចដាក់ពាក្យសុំបានទេ ដោយសារតែផលប៉ះពាល់បរិស្ថាន និងបញ្ហាសុវត្ថិភាពថាមពលអុស។ ដំណើរការជ្រើសរើសគម្រោងក៏ត្រូវបានធ្វើការ

ពន្យល់ដែរ ចាប់តាំងពីការដាក់សំណើគម្រោង រហូតដល់ការធ្វើកិច្ចសន្យា ហើយដំណើរការវាយតម្លៃគម្រោង ត្រូវបានធ្វើដោយអ្នកវាយតម្លៃឯករាជ្យ។

អ្នកស្រីក៏បានសង្ខេបពី លទ្ធផលនៃការប្រកាសទទួលសំណើគម្រោង ទាំងបីលើកកន្លងមក ដែលមានសំណើគម្រោងចំនួន១៦២ ១០៥ និង ១០៥ បានដាក់នៅតាមការប្រកាសទទួលលើកទី១ ទី២ និងទី៣។ ទោះជាយ៉ាងណាក៏ដោយ មានតែគម្រោងចំនួន ៦ (ការប្រកាសលើកទី១) ១០ គម្រោង (ការប្រកាសលើកទី២) និង១៤គម្រោង (ការប្រកាសលើកទី៣) ត្រូវបាននិងកំពុងអនុវត្ត និងធ្វើកិច្ចសន្យា។ គម្រោងបានជ្រើសរើស គ្របដណ្តប់នូវ រាល់ផ្នែកបច្ចេកទេស ហើយគម្រោងចំនួនពាក់កណ្តាល គឺជាគម្រោងសាកល្បង។ មូលនិធិអតិបរមា សម្រាប់ការប្រកាសលើកទី១ មានចំនួន ៤០០.០០០ EUR និងសម្រាប់ការប្រកាសលើកទី២ និងទី៣ចំនួន ២០០.០០០ EUR។

អ្នកស្រីក៏បានផ្តល់ជាឧទាហរណ៍នៃគម្រោង EEP តំបន់មេគង្គនៅកម្ពុជា ដែលបាននិងកំពុងអនុវត្តរាប់បញ្ចូលទាំង គម្រោងសន្សំសំចៃថាមពលនៅខេត្តសៀមរាប គម្រោងបង្កើនការទទួលបានថាមពលពន្លឺព្រះអាទិត្យសម្រាប់អគ្គីសនីជនបទ និងគម្រោងថាមពលសម្រាប់ភូមិបណ្តែតទឹក។

អ្នកស្រី ក៏បានរាយការណ៍ថា កម្មវិធីដំណាក់កាលទី១ នេះគឺ ស្ថិតនៅពាក់កណ្តាលនៃការអនុវត្ត។ ចំណែកឯដំណាក់កាល ទី ២ (២០១៣-២០១៥) កំពុងស្ថិតក្នុងដំណាក់កាលធ្វើផែនការ។ សង្ឃឹមថានឹងមានការប្រកាសទទួលសំណើគម្រោងលើកទី៤ទៀត ដែលនឹងត្រូវចាប់ផ្តើមនៅចុងឆ្នាំនេះ ឬដើមឆ្នាំក្រោយ ប្រសិនបើដំណាក់កាលទី ២ត្រូវបានអនុម័ត។

គោលនយោបាយកាបូន៖ បទពិសោធន៍ថ្នាក់តំបន់ និងពិភពលោក ឱបសគ្គសម្រាប់ការបន្ថយការបញ្ចេញឧស្ម័នផៅកម្ពុជា និងសំណើខាងការឆ្លើយតប

*ដោយលោកបណ្ឌិត **Thanak De Lopez** នាយកគ្រប់គ្រង Ecofia*

បទបង្ហាញនេះ បានផ្តោតជាសំខាន់លើគំរូគោលនយោបាយឥណទានកាបូន ដែលទទួលជោគជ័យទាក់ទងភាពជាកម្មសិទ្ធិ ពន្ធដារការគ្រប់គ្រងជាដើម និងការពិភាក្សាអំពីឧបសគ្គ មេរៀនទទួលបាន ការអនុវត្តល្អ និងអនុសាសន៍ពីគោលនយោបាយសំខាន់ៗ ដែលកម្ពុជាអាចទទួលបានផលប្រយោជន៍។

លោកបណ្ឌិត **Thanak** បានធ្វើការបកស្រាយថា ដោយសារវិបត្តិហិរញ្ញវត្ថុពិភពលោកធ្ងន់ធ្ងរ នោះនឹងមានថវិកាតិចតួច ដើម្បីទិញឥណទានកាបូន ហើយប្រទេសមួយចំនួននឹងមានការលំបាកក្នុងការឆ្លងឲ្យផុតពីនីតិកម្ម ដើម្បីទប់ស្កាត់ការបញ្ចេញ GHGs ដែលមិនអាចទទួលយកនៅក្នុងន័យនយោបាយ។ ប្រទេសជាច្រើនដូចជា សហរដ្ឋអាមេរិក ជប៉ុន និងសហគមន៍អឺរ៉ុប ដែលធ្លាប់ទិញឥណទានកាបូនពីកម្ពុជា នឹងគ្មានថវិកាគ្រប់គ្រាន់ សម្រាប់ទិញកាបូនទេ ពីព្រោះពួកគេ ផ្តោតសំខាន់លើការបង្កើតទីផ្សារការងារ និងការធ្វើឲ្យប្រសើរឡើងលើវិស័យសេដ្ឋកិច្ច ដែលនេះគឺជា ឧបសគ្គមួយនៅក្នុងទីផ្សារកាបូន។ ការចរចាជាអន្តរជាតិមានការរីកចម្រើនតិចតួច ឆ្ពោះទៅជាបង្កើតយន្តការថ្មីសម្រាប់ពិធីសារក្យូតូ។ ដំណាក់កាលនៃការប្តេជ្ញាចិត្តលើកដំបូងនៃពិធីសារក្យូតូ នឹងបញ្ចប់នៅចុងឆ្នាំ២០១២ ហើយអនាគតនៃពិធីសារក្យូតូនៅពុំទាន់ច្បាស់លាស់ និងគ្មានកិច្ចព្រមព្រៀងផ្នែកុងនៅឡើយ។

លោកបណ្ឌិត Thanak បានចង្អុលបញ្ជាក់ថា ទីផ្សារមិនចូលចិត្តភាពមិនប្រាកដ

ប្រជាទេ ក្រោយការលូតលាស់រយៈពេល ៥ឆ្នាំ មក តម្លៃសរុបនៃទីផ្សារកាបូនពិភពលោកនៅ ទ្រឹងក្នុងឆ្នាំ២០១០ ហើយទំហំ និងតម្លៃគម្រោង ក្នុងការប្រតិបត្តិការទីផ្សារ បានធ្លាក់ចុះ ៥០% សម្រាប់ CERs ។

ទីផ្សារកាបូន ជាទីផ្សារអ្នកទិញ។ CDM នឹងមានការលំបាកបន្តិចបន្តួចនៅចុងឆ្នាំ២០១២ ដោយសារតម្រូវការ និងការផ្គត់ផ្គង់មានកម្រិត ទាប។ បញ្ហាប្រឈមមួយទៀត គឺមានគម្រោង CDM ថ្មីមួយចំនួនប៉ុណ្ណោះបានចាប់ផ្តើម ព្រោះ អ្នកទិញចង់បាន CERs ដែលមានតម្លៃទាប ហានិភ័យទាប និងបានចេញ CERs រួចហើយ។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅមាន ឱកាសការទូទាត់កាបូនប្រកបដោយគុណភាពពី កម្ពុជា។ ក្រោយឆ្នាំ២០១២ ការទូទាត់ក្នុង LDCs (រួមទាំងប្រទេសកម្ពុជា) អាចនៅមានសុពល ភាពសម្រាប់ EU ETS (បានន័យថា EU នៅតែ មានសិទ្ធិទិញកាបូនពីកម្ពុជា)។ លើសពីនេះទៅ ទៀត គម្រោងថាមពលស្អាតពី LDCs នៅតែជា ទំនិញយ៉ាងកម្រ ប៉ុន្តែអ្នកទិញខ្លះដែលប្រកាន់ ក្រមសីលធម៌នៅតែតាមស្វែងរក និងការទូទាត់ កាបូន ដែលមានគុណភាពខ្ពស់ពី LDCsអាច ទទួលបានតម្លៃខ្ពស់។

លោកបណ្ឌិត Thanak បាននិយាយថា មិនគួរ មើលស្រាលលើ VCM ទេព្រោះ៖

- អ្នកទិញគ្មានកាតព្វកិច្ចផ្លូវច្បាប់ ដើម្បី ទូទាត់ការបញ្ចេញរបស់ខ្លួនប៉ុន្តែសម្រេច ចិត្តទិញឥណទានកាបូនដោយស្ម័គ្រចិត្ត
- ទីផ្សារតូចធៀបនឹងទីផ្សារជាប់កាតព្វកិច្ច (តិចជាង ១ភាគរយ) ប៉ុន្តែបំណែកនៃទី ផ្សារនៃកាបូនជាប់កាតព្វកិច្ច ដែលមាន បទពិសោធន៍នឹងការលូតលាស់លឿន (ច្រើនជាង ៣០% ឆ្នាំ ២០០៩-២០១០) និង
- ការកើនឡើងយ៉ាងលឿននៃឥណទានពី REDD ដែលផ្តល់ឱកាសដល់កម្ពុជា

លោកបណ្ឌិត Thanak បានផ្តល់ជា ឧទាហរណ៍មួយចំនួននៃគម្រោង CDM និង គោលនយោបាយកាបូនក្នុងប្រទេសចិន និង វៀតណាម។ ក្នុងប្រទេសចិន រដ្ឋាភិបាលចិន មានធនធាន សម្រាប់កាត់បន្ថយការបញ្ចេញ ហើយអ្នកអភិវឌ្ឍគម្រោង គឺជាម្ចាស់លើការកាត់ បន្ថយការបញ្ចេញ ចំណែកចំណូលពី CERs គឺ ជាកម្មសិទ្ធរបស់រដ្ឋាភិបាល និងអ្នកអភិវឌ្ឍន៍ គម្រោង (ការចែករំលែកផលចំណូលពី CERs ដើម្បីគាំទ្រដល់សកម្មភាពក្នុងវិស័យប្រៃប្រួលអា កាសធាតុ)។ ប្រទេសវៀតណាម បានផ្តល់នូវ ការលើកទឹកចិត្តយ៉ាងខ្លាំងដល់គម្រោង CDM ដូចជា ការកាត់រំលួសនៃទ្រព្យ ការលើកលែង ពន្ធនាំចូល ការលើកលែងការហូតពន្ធការប្រើ ប្រាស់ដី និងការឧបត្ថម្ភធនលើផលិតផលដែល ប្រើប្រាស់ដោយគម្រោង។ អ្នកអភិវឌ្ឍគម្រោង ជាម្ចាស់ CERs ត្រូវតែចុះបញ្ជីពីចំណូលការចាត់ ចែង និងការលក់ CERs ជាមួយនឹងមូលនិធិ ការពារបរិស្ថានវៀតណាម (VEPF) ។ VEPF ប្រមូលកម្រៃពីការលក់ CERs (១,២ ទៅ ២%) និងត្រូវបង់ប្រាក់កម្រៃនេះទាំងអស់ មុននឹងផ្ទេរ CERs ។

ចំពោះគម្រោងកាបូននៅកម្ពុជា លោក បណ្ឌិតបានពិពណ៌នាអំពីគម្រោង CDM និងការ ទូទាត់ការបូនស្មគ្រ័ចិត្តដែលមានស្រាប់។ លោក បណ្ឌិតបានបញ្ជាក់ថា នៅក្នុងបរិបទ VCM គឺ គ្មានលក្ខខណ្ឌផ្លូវច្បាប់ សម្រាប់អ្នកអភិវឌ្ឍន៍ គម្រោង ដើម្បីជូនដំណឹងទៅ DNA នោះទេ ហើយមកទល់ពេលនេះ យ៉ាងហោចណាស់ មានគម្រោងចំនួន ៤ ដែលបាន និងកំពុងអនុវត្ត នៅកម្ពុជា រាប់បញ្ចូលទាំងគម្រោងចង្រ្កានកែ លម្អប្រសិទ្ធភាពឡជីវឧស្ម័ន ឧស្ម័នកម្ម អង្កាម និងសហគមន៍ព្រៃឈើ។ ដូចបានឃើញមក ហើយ មានតុល្យភាពល្អរវាងទីផ្សារជាប់កាតព្វ កិច្ច និង VCM ដូច្នេះមិនត្រូវយកចិត្តទុកដាក់តែ

ទៅលើ CDM នោះទេ ព្រោះក៏ អាចមានឱកាសច្រើនផងដែរក្នុង VCM។

គម្រោងភាគច្រើន ផ្តុំតែនៅក្នុងប្រទេសឧស្សាហកម្ម ដែលការផលិតឥណទានកាបូនមានតម្លៃថោក។ ចំណែកឯការផលិតឥណទានកាបូននៅកម្ពុជា និងនៅបណ្តា LDCs ផ្សេងៗទៀតមានតម្លៃថ្លៃ។ ដូច្នេះសក្តានុពលគម្រោងកាបូននៅកម្ពុជារួមមាន គម្រោងវិមជ្ឈការខ្នាតតូច ដែលពាក់ព័ន្ធនឹងការចំណាយលើផ្នែកគ្រប់គ្រង និងរដ្ឋបាល នៅក្នុងមួយខ្នាតនៃឥណទានផលិតបាន។

លោកបណ្ឌិត Thanak ក៏បានផ្តល់នូវការវិភាគពីភាពខ្លាំង និងភាពខ្វះចន្លោះនៃបរិបទការទូទាត់កាបូននៅកម្ពុជា។ ភាពខ្លាំងគឺ មានរចនាសម្ព័ន្ធអភិបាលកិច្ច CDM (DNA ដំណើរការបានល្អ ដោយមាននីតិវិធីច្បាស់លាស់) មានកំណើននៃការចាប់អារម្មណ៍ពី NGOs ក្នុងស្រុក និងក្រុមហ៊ុនឯកជន គ្មានការយកពន្ធពីឥណទានកាបូន ដែលផលិតបាននៅកម្ពុជា អ្នកអភិវឌ្ឍន៍គម្រោង គឺជាម្ចាស់លើឥណទានកាបូន។ លោកបានផ្តល់អនុសាសន៍ ករណីសិក្សាពីប្រទេសវៀតណាម និងចិនមានលក្ខណៈស្មុគស្មាញក្នុងការអនុវត្តតាម ប៉ុន្តែសម្រាប់កម្ពុជាមានលក្ខណៈសម្បត្តិល្អ ព្រោះមាននីតិវិធីច្បាស់លាស់។

ទោះបីជាយ៉ាងនេះក៏ដោយ ក៏នៅមានចន្លោះប្រហោងមួយចំនួនដូចជា៖

- គ្មានក្របខណ្ឌច្បាប់ជាតិច្បាស់លាស់សម្រាប់ឥណទានកាបូន
- ការយល់ដឹងមានកំណត់ពីបច្ចេកវិទ្យាសម្រាប់ថាមពលដោយចីរភាព (ថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល) និងការស្រូបកាបូនពីព្រៃឈើ
- សមត្ថភាព និងបទពិសោធន៍មានកម្រិតក្នុងការអភិវឌ្ឍគម្រោងទូទាត់កាបូន
- គ្មានហិរញ្ញប្បទានឯកជន សម្រាប់អ្នកអភិវឌ្ឍគម្រោង (ការយល់ដឹងនៅមានកម្រិតក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ)
- គ្មានហិរញ្ញប្បទានសារធារណៈ សម្រាប់ការអភិវឌ្ឍគម្រោង (ជំនួយការបណ្តាក់ទុន។ល។)
- ការគាំទ្រពីសាធារណៈមានកំណត់ដល់ការអភិវឌ្ឍគម្រោង (ការគាំទ្រមិនមែនជាសាច់ប្រាក់)

ផ្នែកចុងក្រោយបទបង្ហាញ លោកបានសង្ខេបអំពី ការអនុវត្តដែលត្រូវពិចារណាចំពោះគោលនយោបាយឥណទានកាបូនជាតិ ដែល RGC មានបំណងនឹងបង្កើត។ លោកបណ្ឌិតបានផ្តល់នូវឧទាហរណ៍ ចំនួន៣ (ដែលរួមមានគម្រោងកសិដ្ឋានចិញ្ចឹមជ្រូក Chruk Skome ព្រៃឈើ Prei Reul និងទំនប់វារីអគ្គីសនីទឹកឈូ) ដែលជាគម្រោងមានស្រាប់ក្នុងកម្ពុជាដែលឆ្លើយតបទៅនឹងសំណួរថា "តើអ្នកណាជាម្ចាស់ឥណទានកាបូន?" ឧទាហរណ៍ទាំងនេះ បានបង្ហាញពីកម្រិតនៃការចូលរួមនៃអ្នកពាក់ព័ន្ធ ជាមួយនឹងលក្ខណៈស្មុគស្មាញខុសៗគ្នា ក្នុងការអនុវត្តគម្រោងនីមួយៗ។ លោកបានបញ្ជាក់ថា ភាពជាម្ចាស់នៃ CERs អាចខុសគ្នាពី ប្រទេសមួយទៅប្រទេសមួយ អាស្រ័យលើច្បាប់ក្នុងស្រុករបស់ប្រទេស។ ករណីប្រទេសកម្ពុជា ការបកស្រាយបំភ្លឺអំពី សិទ្ធិរបស់អ្នកចូលរួមនៅក្នុងគម្រោង អាចផ្តល់ទំនុកចិត្តដល់អ្នកវិនិយោគជឿជាក់ថា គម្រោង CDM អាចអនុវត្តបានប្រកបដោយសុវត្ថិភាពនៅកម្ពុជា។ បច្ចុប្បន្ននេះ នៅក្រោមក្របខណ្ឌច្បាប់អន្តរជាតិ មានការសន្មត់ថា កម្ពុជាមានអធិបតេយ្យភាពលើការកាត់បន្ថយ GHGs ដែលអាចទទួលបានពីគម្រោង CDM ក៏ដូចជា CERs ផងដែរ។ ដោយអវត្តមាននៃច្បាប់ក្នុងស្រុក គេអាចសន្មត់ថាសិទ្ធិទាំងនេះត្រូវបានផ្ទេរទៅឲ្យអ្នកចូលរួមក្នុង

គម្រោង CDM តាមរយៈការអនុម័តគម្រោងពី DNA ។

លោកបណ្ឌិត ក៏បានចោទជាសំណួរថា "តើគោលនយោបាយក្នុងស្រុកបែបណា ដែលគាំទ្រដល់គម្រោងទូទាត់កាបូននៅកម្ពុជា?" លោកបានបញ្ជាក់ថា វាមានការលំបាកក្នុងការអភិវឌ្ឍគម្រោងទូទាត់កាបូន ដែលអាចផ្តល់ផលចំណេញ ទន្ទឹមនឹងផ្តល់ផងដែរនូវអត្ថប្រយោជន៍សម្រាប់ការអភិវឌ្ឍដោយចីរភាព និងការយកពន្ធគម្រោង ការទូទាត់កាបូន (CDM និងVCM)។ ប៉ុន្តែ ត្រូវការបកស្រាយបំភ្លឺនូវបញ្ហាមួយចំនួនដូចខាងក្រោម៖

- ការលើកទឹកចិត្តខាងសារពើពន្ធ ការលើកលែងពន្ធ (ពន្ធលើចំណូល ពន្ធលើតម្លៃបន្ថែម ពន្ធលើការលក់ឥណទាន) និងពន្ធលើការនាំចូល
- ការឧបត្ថម្ភធន និងការអនុគ្រោះពិសេសសម្រាប់គម្រោងផ្តល់អត្ថប្រយោជន៍អភិវឌ្ឍដោយចីរភាពគួរជាបញ្ជីអាទិភាពដែរឬទេ? និង
- តើចំណូល CERs/VERs ទ្រព្យគម្រោង និងចំណូលពីជំនួញត្រូវជាប់ពន្ធឬទេ? តើគួរតែមានការអនុគ្រោះពន្ធដែរឬទេ?

បន្ថែមពីលើនេះទៀត តួនាទីរដ្ឋាភិបាលក្នុងការគាំទ្រដល់ការទូទាត់កាបូននៅកម្ពុជាមានដូចជា៖

- ការផ្តល់លទ្ធភាពក្នុងការទទួលបានទិន្នន័យ ដែលមានស្រាប់ដោយឥតគិតថ្លៃអំពីផលិតកម្មថាមពល និងសារពើភណ្ឌាព្រៃឈើ
- ទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត
- ចែករំលែកបទពិសោធន៍អំពីសកម្មភាពទូទាត់កាបូន
- ជម្រុញសកម្មភាពទូទាត់កាបូនជាមួយអ្នកទិញ និងអ្នកវិនិយោគទុនបរទេស
- ផ្តល់ការបញ្ជាក់ជំហរផ្លូវការរបស់រដ្ឋាភិបាលពាក់ព័ន្ធនឹងគោលនយោបាយពីកាបូន

ចុងក្រោយ លោកបណ្ឌិតបានសន្និដ្ឋានថា លុះត្រាតែមានគោលនយោបាយឥណទានកាបូន ទើបអាចសម្រេចបាន ព្រោះយន្តការពឹងផ្អែកលើបរិបទទីផ្សារទូលំទូលាយខាងសេដ្ឋកិច្ច និងការវិនិយោគនៅកម្ពុជា ការពិគ្រោះយោបល់ជាមួយក្រុមហ៊ុនអភិវឌ្ឍន៍ក្នុងស្រុក និងអ្នកពាក់ព័ន្ធនានាអំពីផ្នែកសំខាន់ៗនៃគោលនយោបាយកាបូនអាចផ្តល់ជាមូលដ្ឋានតាបបែបផែននៃការចូលរួមសម្រាប់ច្បាប់នានាទៅអនាគត និងភាពលំអិតនៃនីតិកម្មកាបូន ការបកស្រាយបំភ្លឺអំពីការយកពន្ធ និងសិទ្ធជាម្ចាស់ឲ្យបានសមស្របគឺមានសារសំខាន់ណាស់។

សំណួរ និងចម្លើយ

លោក **សុខ ពិសិដ្ឋ** មកពី MoWA បានសួរពីភាពខុសគ្នារវាងការអភិវឌ្ឍបៃតង និងសេដ្ឋកិច្ចបៃតង។

លោកស្រី **Aneta Nikolova** បានបញ្ជាក់ថា ពាក្យទាំងពីរនេះ ពុំមានភាពខុសគ្នាច្រើនទេ។ ភាពខុសគ្នានោះគឺ ការអភិវឌ្ឍបៃតងមានប្រភពដំបូងនៅក្នុងតំបន់របស់យើងមុននឹងបានក្លាយជាសេដ្ឋកិច្ចបៃតង។ សេដ្ឋកិច្ចបៃតងព្យាយាមឲ្យមានការចូលរួមពីប្រទេសអភិវឌ្ឍន៍ដែលកំពុងគ្រប់គ្រងលើការលូតលាស់លើវិស័យសេដ្ឋកិច្ចរបស់គេ ជាពិសេស ក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុ ពីព្រោះពួកគេមានឱកាសតិចតួចប៉ុណ្ណោះដើម្បីការលូតលាស់។ ទស្សនទាននៃការអភិវឌ្ឍបៃតង បាននឹងកំពុងមានសន្ទុះកើនឡើងដោយសារមហិច្ឆិតារបស់DCs ឧទាហរណ៍ប្រទេសក្នុងតំបន់នេះ ចង់សម្រេចបាននូវអត្រា

កំណើន GDP ប្រចាំឆ្នាំពី ៨-១០%។ មធ្យោបាយដើម្បីធ្វើឲ្យការអភិវឌ្ឍសេដ្ឋកិច្ច ដែលអាចធ្វើទៅបាន និងមានចីរភាព គឺជាវត្ថុបំណងចម្បងនៃយុទ្ធសាស្ត្រការអភិវឌ្ឍបៃតង ដែលទស្សនទាននេះ បានកើតឡើងតាំងពីឆ្នាំ២០០៧ មកម្ល៉េះ និងកើតមានឡើងជាដំបូងនៅសារធារណរដ្ឋកូរ៉េ។ ប្រទេសកូរ៉េ ជាអ្នកដឹកនាំអភិវឌ្ឍសេដ្ឋកិច្ចបៃតងនៅក្នុងតំបន់។ ដូច្នេះ គ្មានភាពខុសគ្នាច្រើនទេ នៅក្នុងន័យសេដ្ឋកិច្ចបៃតង ដែលកំពុងស្វែងរកដំណោះស្រាយ ក្នុងការកាត់បន្ថយភាពក្រីក្រ ព្រោះបើគ្មានដំណោះស្រាយចំពោះភាពក្រីក្រទេនោះ មានន័យថា គ្មានភាគីពាក់ព័ន្ធណាចូលរួម នៅក្នុងសេដ្ឋកិច្ចបៃតងនេះដែរ។ វាគ្រាន់តែបង្កើតជាមូលដ្ឋានរវាង DCs និងប្រទេសអភិវឌ្ឍន៍ប៉ុណ្ណោះ។

លោក **ឡៀក សេង** នាយកអង្គការ WWF ប្រចាំនៅកម្ពុជា បានលើកសំណួរជាច្រើន ដែលជាដំបូងលោកថា ការផ្ទេរមធ្យោបាយនៃការអភិវឌ្ឍសេដ្ឋកិច្ចបច្ចុប្បន្ន ដែលផ្អែកលើប្រេងឥន្ធនៈហ្វូស៊ីល និងបច្ចេកវិទ្យាចាស់ៗនឹងត្រូវចំណាយខ្ពស់ ហើយត្រូវការការប្តេជ្ញាចិត្តខាងនយោបាយ និងវិស័យឯកជនដើម្បីធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធ ជាមួយរាជរដ្ឋាភិបាល និងដៃគូដទៃទៀត ដើម្បីទទួលបានការអភិវឌ្ឍបៃតង ឬសេដ្ឋកិច្ចបៃតង។ ប៉ុន្តែចំពោះស្ថានភាពបច្ចុប្បន្ននៅកម្ពុជា ឬនៅក្នុងតំបន់ GMS តើត្រូវយកអ្វីមកជំនួសឲ្យបច្ចេកវិទ្យាចាស់ៗ នៅពេលដែលការអភិវឌ្ឍសេដ្ឋកិច្ចបច្ចុប្បន្នពឹងផ្អែកយ៉ាងខ្លាំងលើ បច្ចេកវិទ្យាទាំងនោះ ស្របគ្នានឹងការរក្សាការអភិវឌ្ឍសេដ្ឋកិច្ចក្នុងតំបន់ និងក្នុងប្រទេសនោះ?

សំណួរទីពីរ តើពេលណាដែលទស្សនទានការអភិវឌ្ឍបៃតង/សេដ្ឋកិច្ចបៃតង នឹងត្រូវបានទទួលយកដោយវិស័យឯកជន ឬក្រុមហ៊ុនណាមួយ ដើម្បីធ្វើឲ្យការរីកចម្រើននៃសេដ្ឋកិច្ចបៃតង និងការអភិវឌ្ឍបៃតងនៅក្នុងតំបន់?

សំណួរទីបី តើរដ្ឋាភិបាលត្រូវធ្វើអ្វីខ្លះដើម្បីឲ្យមានការអភិវឌ្ឍបៃតង ដោយសារត្រូវចំណាយខ្ពស់លើការលើកកម្ពស់ការអភិវឌ្ឍបៃតង និងវិស័យឯកជនប្រហែលជាមិនព្រមទទួលយកទេ?

សំណួរទីបួន នៅពេលដែលនិយាយអំពីកំណែទម្រង់ព័ន្ធអេកូឡូស៊ី ដែលនឹងត្រូវយកពន្ធទៅលើផលិតផលមួយចំនួន ការបង់ថ្លៃសេវាកម្មបរិស្ថាន ដែលអាចយកពន្ធលើផលិតផលមួយដែលផលិតពីធនធាន តើអ្នកស្រីឃើញមានភាពជាប់ទាក់ទងជាមួយនឹងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលក្នុងកាត់បន្ថយភាពក្រីក្រដែរឬទេ?

អ្នកស្រី **Aneta Nikolova** បានឆ្លើយទៅនឹងមធ្យោបាយឈប់ប្រើប្រេងឥន្ធនៈហ្វូស៊ីល ថាជម្រើសមួយ គឺត្រូវសិក្សាពីការចំណាយនៃការប្រើប្រាស់ប្រេងឥន្ធនៈហ្វូស៊ីល ក្នុងប្រទេសមួយ និងមើលថា តើវិស័យណាមួយ ដែលប្រើប្រាស់ច្រើនជាងគេ និងត្រូវកាត់បន្ថយយ៉ាងដូចម្តេច និងការសន្សំសំចៃពីការមិនទិញឥន្ធនៈហ្វូស៊ីល។ ហិរញ្ញប្បទានខ្នាតតូច មានសារសំខាន់ណាស់ជាឧទាហរណ៍ ករណីសិក្សានៅ បង់ក្លាដេស (Shati) ដែលផ្តោតលើបរិក្ខាផ្គត់ផ្គង់ថាមពលសម្រាប់អ្នកភូមិ និងគម្រោងមួយ ដែល អនុវត្តយ៉ាងជោគជ័យនៅកម្ពុជា គឺគម្រោងជីវឧស្ម័ន។ ចំពោះតំបន់ដែលគ្មានថាមពលប្រើប្រាស់ ការបញ្ចេញរវាងជីវឧស្ម័ន CH_4 ថាមពល ព្រះអាទិត្យ ថាមពលខ្យល់ និងប្រភេទថាមពលកកើតឡើងវិញដទៃទៀត អាចក្លាយជាដំណោះស្រាយមួយដ៏ប្រសើរ។

ឆ្លើយតបនឹងការទទួលយករបស់ វិស័យឯកជន និងមធ្យោបាយដែលរដ្ឋាភិបាលដោះស្រាយជាមួយបញ្ហានេះ អ្នកស្រីបានលើកឡើងថា ការអភិវឌ្ឍបៃតង គឺជាអន្តរកម្មរវាងត្រីភា គី

ដែលមានរដ្ឋាភិបាលជាអ្នកដឹកនាំវិស័យឯក ជន និងភាគីពាក់ព័ន្ធផ្សេងទៀតត្រូវផ្តល់ការគាំទ្រ។

តើអ្វីទៅជាមូលដ្ឋាន? មូលដ្ឋាន គឺជា វិធានសេដ្ឋកិច្ច ជាឧទាហរណ៍ការឧបត្ថម្ភធន សម្រាប់ប្រទេសឲ្យប្រើប្រាស់ឥន្ធនៈហ្វូស៊ីល។ នៅក្នុងស្ថានភាពជាក់ស្តែង ឥន្ធនៈដែលនាំចូល មានតម្លៃខ្ពស់ ប៉ុន្តែលក់នៅក្នុងតម្លៃសមស្រប ដោយសារតែវត្តមាននៃការឧបត្ថម្ភធន។ ដូច នេះ មានមធ្យោបាយជាច្រើន ដែលអាចលុបបំ បាត់ការប្រើប្រាស់ប្រេងឥន្ធនៈហ្វូស៊ីលបាន មាន ដូចជា យានយន្តប្រើពន្លឺព្រះអាទិត្យ និងថ្នាំង គំនូរពន្លឺព្រះអាទិត្យ (solar paint) ដែលបច្ចេក វិទ្យានេះ មានតម្លៃថោក។ វិស័យឯកជននឹងចាប់ ផ្តើមទិញនៅពេលគេរិភាគលើធនធានដែលពួក គេកំពុងប្រើប្រាស់នោះមានតម្លៃថ្លៃ ។ ជាឧទា ហរណ៍ ក្រុមហ៊ុនស្បែកមួយ នៅប្រទេសចិន ដែលទទួលបានជោគជ័យ ដោយសារក្រុមហ៊ុន នេះ បានកាត់បន្ថយរាល់ការប្រើប្រាស់ធនធាន ធម្មជាតិនៅក្នុងដំណើរការផលិតកម្មទាំងស្រុង។ គេបានធ្វើសវនកម្មនៅគ្រប់ដំណាក់ទាំងអស់នៃ ខ្សែសង្វាក់ផលិតកម្ម។ គេបានកាត់បន្ថយថ្លៃ ចំណាយផលិតកម្ម និងផលចំណេញពីការសន្សំ សំចៃកាបូន គេបានប្រើប្រាស់ថវិកាទាំងនេះក្នុង ការសាងសង់រោងចក្រ នៅតំបន់ផ្សេងទៀតនៅ អាស៊ី។ នៅពេលដែលធនធានត្រូវបានកំណត់ ថ្លៃសមស្រប វាមិនមែនត្រឹមតែជាការចំណាយ លើសេវាកម្មបរិស្ថានប៉ុណ្ណោះទេ ប៉ុន្តែរួមទាំង ការចំណាយក្នុងតម្លៃដ៏ត្រឹមត្រូវមួយផងដែរ។

អ្វីៗដែលប្រើប្រាស់នៅក្នុងប្រទេស DCs គឺសុទ្ធតែមានការឧបត្ថម្ភធន ហើយនិន្នាការនៃ ការឧបត្ថម្ភធននេះត្រូវតែធ្វើការត្រួតពិនិត្យឡើង វិញ។ការបង្កើតពន្ធបរិស្ថាន ដោយមិនបន្ថែម តម្លៃអ្វីមួយទៅលើនរណាម្នាក់នោះ ប៉ុន្តែយក ថ្លៃសម្រាប់ការប្រើប្រាស់ធនធានជាក់ស្តែង តែ ប៉ុណ្ណោះ។ ប្រការនេះ អាចលើកទឹកចិត្តដល់ ក្រុមហ៊ុន និងអ្នកប្រើប្រាស់ ឲ្យកាត់បន្ថយការ ប្រើប្រាស់របស់ពួកគេ ឧទាហរណ៍ មិនទុកម៉ា ស៊ីនត្រជាក់បើកចោល នៅពេលសម្រាកអាហារ ថ្ងៃត្រង់។ ការអនុវត្តក៏បានធ្វើផងដែរ នៅក្នុង អគារ អ.ស.ប។ ឧទាហរណ៍មួយ នៅប្រទេសម៉ា ឡេស៊ី នៅពេលគេនិយាយថា រាជរដ្ឋាភិបាល ត្រូវកាត់បន្ថយការប្រើប្រាស់អគ្គីសនី ឲ្យបាន ២០% គេគិតគូរពីបញ្ហានេះយ៉ាងខ្លាំង។ ដូច្នេះ នេះគឺជា អ្វីមួយដែលយើងត្រូវគិតដល់។ នៅ ពេលយើង កំណត់តម្លៃជាក់ស្តែងនៃធនធាន ពេលនោះ ការសន្សំសំចៃធនធានក្លាយទៅជា ការលើកទឹកចិត្តនិងការប្រព្រឹត្តតាមបែបធម្មជាតិ ព្រោះថា ហេតុអ្វីបានជាត្រូវខ្ជះខ្ជាយនូវអ្វីដែល មានតម្លៃ។ យើងត្រៀមជួយ RGC ដើម្បីអនុវត្ត ផែនទីបង្ហាញផ្លូវការអភិវឌ្ឍបៃតងនេះ។

លោកស្រី **ឌឹម កល្យាណី** អនុប្រធាន មន្ទីរបរិស្ថាន ខេត្តព្រះសីហនុ មានចង្ងល់ទាក់ ទងនឹងការកាត់បន្ថយ GHGs នៅកម្ពុជា និង ការនាំចូលនូវយានយន្តចាស់ៗ ដែលបញ្ចេញនូវ សារធាតុពុលជាច្រើនក្នុងបរិយាកាស។ តើអាជ្ញា ធរ ឬស្ថាប័ននានា ដោះស្រាយការបញ្ចេញ ដោយរបៀបណា?

ឯកឧត្តម **ឆេង គឹមសុន** បានផ្តល់ បញ្ជាក់ថា ចំពោះ DCs ការរាស់វែងនូវកម្រិតនៃ ការអភិវឌ្ឍប្រទេសរបៀបណានោះ គឺដោយ ផ្អែក លើសូចនាករកាបូនបញ្ចេញ ដែលអាច បញ្ជាក់ ជាទូទៅថា ប្រទេសកាន់តែអភិវឌ្ឍ កម្រិតនៃការបញ្ចេញ GHGs ក៏កាន់តែច្រើន ដែរ។ នេះគឺជាមោទនភាពរបស់ប្រទេសកម្ពុជា ដែលមានការរីកចម្រើន ឬមានការអភិវឌ្ឍទើប នាំឲ្យមានការនាំចូលយានយន្តចាស់ៗកើនឡើង ប៉ុន្តែការអភិវឌ្ឍ របស់កម្ពុជាមានកម្រិត ដូច្នេះ ទើបយានយន្ត ចាស់ៗមានតម្រូវការខ្ពស់។

លោកស្រី Aneta Nikolova បានពន្យល់ ពី សកម្មភាពមួយចំនួន ដែលគួរតែចាប់ផ្តើម នោះ គឺការផ្លាស់ប្តូរយានយន្តចាស់ៗ ទៅជា

យានយន្តប្រើអគ្គីសនី និងការទាញយកផលប្រយោជន៍ពីពន្លឺព្រះអាទិត្យ ដោយបង្កើតនូវស្ថានីយសាកនៅក្នុងទីក្រុងភ្នំពេញ។ ប្រទេសចិន ផលិតម៉ាស៊ីនប្រើថាមពលអគ្គីសនី ជាច្រើន ហើយប្រទេសនេះ មានកិច្ចព្រមព្រៀងជាមួយ ASEAN ដែលមានកម្ពុជាជាសមាជិក។ ប្រការនេះអាចបង្កើតទីផ្សារការងារ សហគ្រាស និងអភិវឌ្ឍជំនាញថ្មីៗ។ ការផ្លាស់ប្តូរឡាន និងម៉ូតូគឺជាកាលានុវត្តភាពមួយដ៏ធំ ហើយតាមរយៈការផ្លាស់ប្តូរនេះ ការបំពុលនឹងត្រូវបានកាត់បន្ថយគួរឲ្យកត់សម្គាល់ និងអាចជួយកាត់បន្ថយករណីជម្ងឺមហារីកនាពេលអនាគតផងដែរ។ តួយ៉ាង នៅប្រទេសថៃ បានបង្ហាញថា ៨៥% នៃករណីមហារីក គឺកើតឡើងមិនត្រឹមទាក់ទងនឹងសួតប៉ុណ្ណោះទេ ថែមទាំងថ្លើម និងលំពែង ដែលបណ្តាលមកពី ការបំពុលខ្យល់ពីចរាចរណ៍/ការដឹកជញ្ជូន។ ដូច្នេះ គឺជាបញ្ហាធ្ងន់ធ្ងរ ដែលគួរឲ្យយកចិត្តទុកដាក់។

លោកបណ្ឌិត **ង៉ិន ពន្លក** បានឆ្លើយតបនឹងការផ្តល់យោបល់របស់ អ្នកស្រី **Aneta Nikolova** ខាងលើ ដែលបានពន្យល់ថា ទស្សនទានការអភិវឌ្ឍបៃតង បានមកដល់កម្ពុជាកាលពី ២ ទៅ ៣ឆ្នាំមុនមកម្លេះ តាមរយៈការគាំទ្រពី UNESCAP និងជំនួយថវិកាចំនួន២លានដុល្លាអាមេរិក ពីរដ្ឋាភិបាលកូរ៉េ ដើម្បីគាំទ្រដល់ការអនុវត្ត។ លោកបណ្ឌិតគិតថា មនុស្សភាគច្រើនមិនទាន់យល់ច្បាស់ អំពីទស្សនទាននេះទេ។ បន្តមកទៀត លោកបណ្ឌិត **ពន្លក** បានផ្តល់យោបល់ថា ចំពោះបច្ចេកវិទ្យាសមស្របណាមួយ ដែលអាចអនុវត្តបាន ត្រូវតែជាបច្ចេកវិទ្យាដែលបានបញ្ជាក់ អាចទទួលយកបាន ទាំងផ្នែកវប្បធម៌ និងនយោបាយ មិនប៉ះពាល់ដល់បរិស្ថាន និងអាចអនុវត្តបាននៅក្នុងន័យសេដ្ឋកិច្ច។ ផ្នែកលើកគ្នាទាំងនេះ ថាមពលកកើតឡើងវិញ អាចត្រូវបានបែងចែកជា ពីរក្រុម គឺក្រុមដែលអាចប្រកួតប្រជែងបាន នៅលើទីផ្សារ ដូចជាថាមពលកកើតឡើងវិញទ្រង់ទ្រាយធំ ឬឡជីវឧស្ម័ន និងក្រុមដែលមិនអាចចូលទីផ្សារ ដោយសារវាមិនអាចប្រកួតប្រជែងបាន ដូចជាវារីអគ្គីសនីខ្នាតតូច ថាមពលពន្លឺព្រះអាទិត្យជាដើម។ ប្រសិនបើយើងពិនិត្យមើលលើ ប្រទេសអភិវឌ្ឍប្រេងឥន្ធនៈហ្វូស៊ីល មានភាគរយខ្ពស់ក្នុងទីផ្សារជាឧទាហរណ៍ សហរដ្ឋអាមេរិក ចំណែកឯថាមពលកកើតឡើងវិញមានភាគរយទាប ដែលមានប្រមាណ ១,៥% ប៉ុណ្ណោះ។ ដូច្នេះ យើងត្រូវទទួលយកនូវការអភិវឌ្ឍបៃតង ជាមួយនឹងការប្រុងប្រយ័ត្នព្រោះកម្ពុជាជាប្រទេសកំពុងអភិវឌ្ឍមួយ។ លោកបណ្ឌិតគិតថា គឺជាគំនិតល្អក្នុងការនិយាយពី ប្រព័ន្ធពន្លឺព្រះអាទិត្យដាក់ពីលើ យានយន្ត និងវាមិនអាចអនុវត្តបានក្នុងន័យពាណិជ្ជកម្ម បើទោះបីជាមានការប្រកួតប្រជែងប្រចាំឆ្នាំទាក់ទងនឹងការអភិវឌ្ឍពីប្រពន្ធ័ពន្លឺព្រះអាទិត្យក៏ដោយ។

អ្នកស្រី **Aneta Nikolova** បានឆ្លើយតបទៅលោកបណ្ឌិត **ង៉ិន ពន្លក** ដោយការលើកឡើងម្តងទៀតថា ការអភិវឌ្ឍបៃតងមិនមែនអំពីថវិកា ឬបច្ចេកវិទ្យាទេ តែការអភិវឌ្ឍបៃតង គឺជាគំរូនៃការអភិវឌ្ឍ ដែលនឹងត្រូវបានស្វែងរក។ អ្នកស្រីបានពន្យល់ ដោយផ្តល់ជាឧទាហរណ៍ថា ប្រសិនបើប្រទេសមួយមានជនបទច្រើនដូចនេះ ត្រូវគិតពិចារណាពី គំរូនៃការអភិវឌ្ឍជនបទ។ បញ្ហានៅកម្ពុជា គឺមានប្រជាជនរ៉ាយប៉ាយ នៅក្នុងសហគមន៍ជនបទ ហើយពួកគេគ្មានអគ្គីសនីប្រើប្រាស់ទាល់តែសោះ។ គ្មានភ្លើងប្រើប្រាស់ និងពួកគាត់មិនអាចសិក្សាបានទេ។ ដូច្នេះ ការស្វែងរកដំណោះស្រាយថាមពល សម្រាប់ប្រជាជនមូលដ្ឋាន គឺជាការចាំបាច់។ រោងចក្រធ្យូងថ្ម ឬនុយក្លេអ៊ែរខ្នាតធំ មិនចាំបាច់ សម្រាប់ប្រជាជនមូលដ្ឋានទេ ដោយសារតែនៅសហគមន៍មានជីវឧស្ម័ន ដែលអាចផ្តល់ពន្លឺបាន។ អ្នកស្រីបានសំណូមពរថា វាមានសារសំខាន់ណាស់

ដែលត្រូវស្វែងរកដំណោះស្រាយនៅកម្រិតមូលដ្ឋានជាជាងការថតចម្លងគំរូធំៗ។

លោកបណ្ឌិត **ឆិន ពន្លក** បាននិយាយថា លោកបណ្ឌិត Thanak បានផ្តល់ឧទាហរណ៍ល្អៗពីវិធីសាស្ត្រ សម្រាប់ប្រទេសនានាក្នុងការកំណត់នូវឥណទានកាបូន នៅក្នុងទីផ្សារជាប់កាតព្វកិច្ចរបស់ CDM ។ លោកបណ្ឌិត ចាប់អារម្មណ៍ចង់ដឹងបន្ថែមទៀត ព្រោះទីផ្សារកាបូនកំពុងតែមានការលូតលាស់។ នៅប្រទេសកម្ពុជា យើងបានឮអំពីគម្រោង VCM មួយចំនួនដែរ។ ដូច្នេះ តើប្រទេសដូចជាកម្ពុជា អាចទទួលយកនូវទីផ្សារនេះបានដូចម្តេច? តើរដ្ឋាភិបាលនឹងមានសិទ្ធិអ្វីខ្លះ ក្នុងការកំណត់ឥណទានកាបូនដែលបញ្ចេញសម្រាប់ VCM នេះ?

លោកបណ្ឌិត Thanak បានបញ្ជាក់ថា លោកបានព្យាយាមយ៉ាងខ្លាំងក្នុងការស្វែងរកថា តើគម្រោង VCM នៅកម្ពុជាដំណើរយ៉ាងដូចម្តេច។ មានគម្រោងជាច្រើន ដែលបានចុះបញ្ជីនៅMoE ប៉ុន្តែមានអ្នកអភិវឌ្ឍន៍គម្រោងផ្សេងទៀតកំពុងអភិវឌ្ឍគម្រោងរបស់គេ ដោយធ្វើទៅតាម VCM ហើយក្នុងករណីនេះ មិនមានភាពចាំបាច់ក្នុងការជូនដំណឹងដល់រដ្ឋាភិបាលទេ ដោយសារតែគ្មានច្បាប់ក្នុងស្រុក។ រដ្ឋាភិបាលអាចត្រូវការនូវការអះអាងខ្លះៗអំពី អ្នកអភិវឌ្ឍគម្រោង VCM នៅដំណាក់កាលចុងក្រោយ ដើម្បីជម្រាបដល់រដ្ឋាភិបាល ដូច្នេះ រដ្ឋាភិបាលអាចមានគំនិតខ្លះថា តើអ្នកណាកំពុងតែធ្វើអ្វី នេះគឺជាតម្រូវការតិចបំផុតនៅក្នុង VCM ។ ក្នុងករណីទីផ្សារជាប់កាតព្វកិច្ច គឺជាការពិចារណាទី២នៃគម្រោង CDM អ្នកអភិវឌ្ឍន៍គម្រោងត្រូវជូបរដ្ឋាភិបាល។ នៅកម្ពុជា ត្រូវការអភិវឌ្ឍន៍ក្របខណ្ឌស្តុគ្រស្មាញនានា សម្រាប់គម្រោងកាបូនស្ម័គ្រចិត្ត ដែលជាទំនួលខុសត្រូវរបស់រដ្ឋាភិបាល និងអ្នកពាក់ព័ន្ធថ្នាក់ជាតិ ហើយគ្មានអ្វីដែលហាមឃាត់កម្ពុជាក្នុងការធ្វើបែបនេះទេ។ មានស្តង់ដាមួយចំនួន ដែលបាន និងកំពុងប្រើប្រាស់ ឧទាហរណ៍ ស្តង់ដា WWF ការផ្តល់ដំណឹងទៅ DNA គឺមានកម្រិតទាបបំផុតនៅពេលគេកំពុងអនុវត្ត គម្រោងកាបូនស្ម័គ្រចិត្ត។ អ្នកទិញកាបូនខ្លះត្រូវការឲ្យគម្រោងកាបូនស្ម័គ្រចិត្តដែលមានលិខិតមិនជំទាស់ពីរដ្ឋាភិបាល។

លោកស្រី **ជឹម កល្យាណី** មកពីមន្ទីរបរិស្ថាន ខេត្តព្រះសីហនុ បានសួរទាក់ទងនឹងគោលនយោបាយជាតិ ពីវិធានការរដ្ឋាភិបាលប្រើដើម្បីកាត់បន្ថយការបញ្ចេញGHGs? អ្នកស្រីក៏បានសំណូមពរថា រដ្ឋាភិបាលគួរដំណើរការរថយន្តក្រុងសម្រាប់ និស្សិត ឬអ្នកធ្វើដំណើរផ្សេងទៀត ព្រោះវាអាចនឹងជួយកាត់បន្ថយការបញ្ចេញ GHGs បើធៀបការប្រើប្រាស់យានយន្តឯកជន។

ឯកឧត្តម **សាត សាមី** បានអះអាងថា ជាការពិត រដ្ឋាភិបាលមិនបានព្រងើយកន្តើយទេទាក់ទងនឹង ប្រព័ន្ធដឹកជញ្ជូនសាធារណៈ នោះ។ ជាក់ស្តែងនៅទីក្រុងភ្នំពេញ គម្រោងរថយន្តក្រុងបានចាប់ផ្តើម និងដាក់ឲ្យសាកល្បងម្តងហើយ ក្រោមកិច្ចសហការពី JICA ប៉ុន្តែគម្រោងនោះបានបរាជ័យហើយ។ យ៉ាងណាក៏ដោយ គំនិតនេះ នឹងជាការរួមចំណែកយ៉ាងខ្លាំងក្នុងផែនការនាពេលអនាគត។

លោក **ឈួស សីហា** មកពីក្រុមហ៊ុន SAK បានសួរថា តើភាពខុសគ្នារវាងទីផ្សារជាប់កាតព្វកិច្ច និង VCM មានអ្វីខ្លះ? បើនិយាយអំពី គោលនយោបាយលើកលែងពន្ធ តើមានប្រទេសណាមួយអភិវឌ្ឍទីផ្សារកាបូនដោយគ្មានការលើកលែងពន្ធដែរឬទេ?

លោកបណ្ឌិត Thanak បានពន្យល់ថា ជាមូលដ្ឋាន ទីផ្សារជាប់កាតព្វកិច្ចបានមកពី ពិធីសារក្យូតូ ដូច្នេះប្រជាជន ដែលកំពុងទិញឥណទានកាបូននោះ គឺដោយសារតែពួកគេត្រូវតែ

ទិញឥណទានកាបូន។ ពួកគេត្រូវតែទៅទិញពីប្រទេសផ្សេងៗ និងអ្នកទិញក៏ផ្សេងៗ។ ចំពោះ VCM ក្រុមហ៊ុន ស្ថាប័ន ឬបុគ្គលឯកជនអាចទិញឥណទានកាបូន ប៉ុន្តែគ្មានតម្រូវការផ្លូវច្បាប់ដល់មនុស្ស ឬស្ថាប័ននោះឲ្យធ្វើដូច្នេះឡើយ។ ពួកគេទិញឥណទានកាបូន ដោយសារតែការឲ្យតម្លៃរបស់បុគ្គលចំពោះបរិស្ថាន។ ទីផ្សារស្ម័គ្រចិត្តនៅមានតូច ប៉ុន្តែដំណើរការរបស់វាមានភាពរលូន។ ប្រទេសដែលមានគម្រោងច្រើន ដូចជាប្រទេសចិន ឥណ្ឌា ប្រាកដជាមានប្រភេទនៃការលើកលែងពន្ធ ឬតម្លៃលើ CERs ។ ប៉ុន្តែ វាអាស្រ័យផងដែរលើ អាទិភាពរបស់រដ្ឋាភិបាល។ ឧទាហរណ៍ ប្រទេសចិន ព្រៃឈើជាអាទិភាពនៃការអភិវឌ្ឍដោយចីរភាព ដូចនេះ ការផ្តល់ការលើកទឹកចិត្ត ជាមួយនឹងពន្ធទាប លើវិស័យនេះត្រូវបានគិតគូរ ប៉ុន្តែប្រសិនបើគេគិតថា គម្រោងមិននាំមកនូវ ការអភិវឌ្ឍដោយចីរភាពទេ នឹងមានការបន្ថែមតម្លៃពន្ធដ៏សមស្របមួយ។

វគ្គស្របភ្លា ទី៣

ការផ្តល់ហិរញ្ញប្បទានប្រៃប្រួលអាកាសធាតុ

សហប្រធាន៖

១.**ឯកឧត្តម ស្រ៊ុន តារា** អនុរដ្ឋលេខាធិការ MEF និងជាសមាជិក NCCC

២.**អ្នកស្រី Elisabeth Folkunger** អ្នកឯកទេសខាងបរិស្ថាន
និងការប្រែប្រួលអាកាសធាតុSIDA

ការសម្របសម្រួល និងប្រសិទ្ធភាពជំនួយ

*ដោយលោក **រស់ សាលីន** ប្រធាននាយកដ្ឋានគោលនយោបាយ និងសម្របសម្រួលជំនួយក្រុម CDC*

បទបង្ហាញនេះ បានធ្វើការពិភាក្សាអំពីការរីកចម្រើននៃ ការលើកកម្ពស់ប្រសិទ្ធភាពជំនួយ ដោយផ្តោតសំខាន់លើការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

លោក **សាលីន** បានថ្លែងថា ចាប់តាំងពីការបោះឆ្នោតជាតិលើកទីមួយមក ជំនួយសហប្រតិបត្តិការ មានការកើនឡើងគួរឲ្យកត់សំគាល់ស្មើរគ្រប់វិស័យ ជាពិសេសវិស័យសង្គមកិច្ច។ គាត់បានបញ្ជាក់ថា មានឯកសារបោះពុម្ពអំពី "ការគ្រប់គ្រងជំនួយសហប្រតិបត្តិការ នៅក្នុងប្រទេសកម្ពុជា" (ឆ្នាំ២០០៥) ដែលបានបង្ហាញយ៉ាងច្បាស់ ពីការទទួលខុសត្រូវរបស់ក្រសួងពាក់ព័ន្ធ របស់រដ្ឋាភិបាលក្នុងការអនុវត្តជំនួយសហប្រតិបត្តិការនេះ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិដើរតួជា ច្រកការទូតក្នុងដំណើរការចរចារវាងកម្ពុជា និង DPs។ MEF មានតួនាទីរៀបចំនូវ ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចរយៈពេលមធ្យម និងឥណទានសម្បទាន និង MoP មានតួនាទីរៀបចំនូវ ផែនការជាតិនានា។ ឧទាហរណ៍ NSDP (បច្ចុ ប្បន្នកម្ម ២០០៩-២០១៣) ដោយមានការសហ ការជាមួយក្រសួងនិងភ្នាក់ងារផ្សេងៗទៀត ក្នុងការរៀបចំផែនការវិនិយោគសាធារណៈសម្រាប់រយៈពេល ៣ឆ្នាំ។ តួនាទីរបស់គណៈកម្មាធិការស្តារ និងអភិវឌ្ឍកម្ពុជានៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CRDB/CDC) គឺគ្រប់គ្រង និងសម្របសម្រួលជំនួយការអភិវឌ្ឍជាផ្លូវការ (ODA) តាមរយៈគោលនយោបាយជាតិ យន្តការ និងឧបករណ៍ដែលទាក់ទងនឹងការគ្រប់គ្រងជំនួយ ហើយក្រសួងពាក់ព័ន្ធរៀបចំយុទ្ធសាស្ត្រ តាមវិស័យការវិនិយោគសាធារណៈនឹងដើរតួនាទីភ្នាក់ងារអនុវត្ត។ រាល់យន្តការ ត្រូវតែស្របជាមួយនឹងផែនការអភិវឌ្ឍជាតិទាំងមូលដើម្បីការគាំទ្រ និងសម្រេចបាននូវយុទ្ធសាស្ត្រចតុកោណ ជាតិដំណាក់កាលទី២។

លោក **សាលីន** បានថ្លែងថា រាល់យន្តការទាំងអស់ ត្រូវបានអនុវត្តដោយផ្អែកឯកសារ

គោលនយោបាយជាក់លាក់ រួមមានក្របខណ្ឌ
សម្រាប់ការគ្រប់គ្រងជំនួយសហប្រតិបត្តិការ
ដែលបានកំណត់នូវតួនាទីរបស់រដ្ឋាភិបាល និង
DPs និងផែនការសកម្មភាព (HAR) រយៈពេល
៥ឆ្នាំ ដែលត្រូវបានអនុវត្តពីឆ្នាំ២០០៦ រហូតដល់
២០១០ ដែលឆ្លុះបញ្ចាំងពី ការធ្វើសុខដុមកម្ម
រវាងរាជរដ្ឋាភិបាល និង DPs រវាង DPs និង
DPs ការតម្រឹមជំនួយពី DPs ជាមួយអាទិភាព
របស់រដ្ឋាភិបាល និងការបំពេញការងារ ដោយ
ផ្តោតទៅលើលទ្ធផល ជាជាងផ្តោតទៅលើការ
ដាក់សម្ពាធព DPs។ តួនាទី និងការទទួលខុស
ត្រូវរបស់ក្រសួងនីមួយៗ ក៏ត្រូវបានពិភាក្សានៅ
ក្នុងផែនការសកម្មភាពនេះផងដែរ។

យន្តការកម្រិតសកលឆ្នាំ២០០៥ សេចក្តី
ថ្លែងការទីក្រុងប៉ារីសត្រូវបានកំណត់ ដែលក្នុង
នោះ ដៃគូទាំងអស់ត្រូវអនុលោមតាមលក្ខខណ្ឌ
ខាងក្រោម៖ មានសុខដុមនីយកម្ម ការយល់ដឹង
ផ្នែកតាមអាទិភាពរដ្ឋាភិបាល ភាពជាម្ចាស់ មាន
ន័យថា ការប្រើប្រាស់ឧបករណ៍ដែលមានស្រាប់
និង លទ្ធផលតាមសកម្មភាព ។ ប្រសិទ្ធភាព
ជំនួយ ត្រូវបានវាយតម្លៃជារៀងរាល់ពីរឆ្នាំម្តង
សម្រាប់ប្រទេសដៃគូទាំងអស់។

ចំពោះយន្តការត្រួតពិនិត្យ វេទិកាសហ
ប្រតិបត្តិការដើម្បីអភិវឌ្ឍកម្ពុជា (CDCF) ត្រូវ
ប្រារព្ធធ្វើឡើងនៅរៀងរាល់១៨ខែ ដែលមាន
នាយករដ្ឋមន្ត្រីជាប្រធាន។ វេទិការយៈពេល ០២
ថ្ងៃនេះ នឹងពិភាក្សាពី វឌ្ឍនភាពនៃការអនុវត្ត
NSDP យន្តការកៀរគរធនធាន និងការពង្រឹង
គណនេយ្យភាពទ្វេទិស។ ក្រសួងពាក់ព័ន្ធនឹង
ធ្វើបទបង្ហាញពីផែនការនីមួយៗ និងយុទ្ធសាស្ត្រ
របស់ខ្លួនដើម្បីឲ្យ DPs ដឹងកាន់តែច្បាស់ពីអ្វី
ដែលជាអាទិភាពរបស់រាជរដ្ឋាភិបាល និងអ្វីជា
អាទិភាពសំខាន់ៗរបស់ DPs ។

លើសពីនេះទាក់ទងយន្តការគណនេយ្យ
ភាពទ្វេទិស អ្វីដែលសម្រេចបាននៅកម្រិតជាតិ
ឬតាមវិស័យ នឹងត្រូវបង្ហាញដល់ DPs និង
ក្រសួងពាក់ព័ន្ធនានា។ វេទិកានេះ នឹងផ្តល់ជា
គំនិតដល់ DPs ឲ្យយល់កាន់តែច្បាស់ថា តើ
ជំនួយសហប្រតិបត្តិការនោះត្រូវប្រើប្រាស់ និង
គ្រប់គ្រងយ៉ាងដូចម្តេច ដឹងពីលទ្ធផលដែល
សម្រេចបាន និងអ្វីខ្លះជាចន្លោះប្រហោង ដែល
តម្រូវឲ្យមានដំណោះស្រាយរួម នៅក្នុងគោល
នយោបាយថ្នាក់ជាតិនឹងត្រូវ បានគេលើកយក
មកពិភាក្សាផងដែរ ដោយមានការចូលរួមពីអ្នក
ពាក់ព័ន្ធទាំងអស់។

យន្តការមួយទៀត គឺកិច្ចប្រជុំគណៈ
កម្មាធិការសម្របសម្រួលរដ្ឋាភិបាល និងម្ចាស់
ជំនួយ "GDCC" ដែលត្រូវប្រារព្ធធ្វើឡើងនៅ
រៀងរាល់០៤ខែម្តងដែលដឹកនាំដោយឧបនាយក
រដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃ MEF ។ វេទិកានេះនឹងតាម
ដានលើ កិច្ចព្រមព្រៀងនៅក្នុង យន្តការ ទី១
(GDCF) ដែលបានអនុម័តនូវសូចនាករតាម
ដានរួមគ្នា។ ក្រសួងពាក់ព័ន្ធ ដែលទទួលជំនួយ
ឧបត្ថម្ភពី DPs បានកំណត់សូចនាករដែលមាន
ចំនួន២០។ សូចនាករទាំងនេះ មានលក្ខណៈ
ខុសប្លែកគ្នាទៅតាមបណ្តាក្រសួង អាស្រ័យតាម
វិស័យជាក់លាក់ ដែលជាទូទៅអាចមានមួយ
ឬពីរសូចនាករសម្រាប់វិស័យនីមួយៗ ដូចជា
MoEYS និង MoH ក៏មានសូចនាករសម្រាប់
ក្រសួងខ្លួនដែរ។ រដ្ឋាភិបាល និង DPs ព្រម
ព្រៀងគ្នាក្នុងការកំណត់ឲ្យបានពីសូចនាករដែល
អាចធ្វើបាន និងអនុវត្តក្នុងបរិបទប្រទេសកម្ពុជា
បច្ចុប្បន្ន។ ជាគោលការណ៍ DPs ផ្តល់ជំនួយមក
ដោយអមជាមួយនឹងសូចនាករ ដែលតម្រូវឲ្យ
ក្រសួងនីមួយៗត្រូវអនុវត្តឲ្យសម្រេចបាននូវសូច
នាករទាំងនោះ។ បញ្ហាអន្តរវិស័យ (យេនឌ័រ
និងការប្រែប្រួលអាកាសធាតុ) នឹងត្រូវលើកមក
ពិភាក្សាផងដែរក្នុងវេទិកានេះ ដើម្បីឲ្យប្រាកដ
ថា កិច្ចការអន្តរវិស័យទាំងនេះ អាចអនុវត្តបាន
លើគ្រប់វិស័យពាក់ព័ន្ធនានា។ តើ MoE NCCC
និងភ្នាក់ងារ ដែលពាក់ព័ន្ធមានតួនាទីអ្វីខ្លះ? តើ
យន្តការសម្របសម្រួល ត្រូវធ្វើដោយរបៀប

ណា? ជាឧទាហរណ៍ បទពិសោធន៍ជាមួយនឹងយេនឌ័រ និងការសិក្សាអប់រំ។ គម្រោងនេះមានក្រុមការងារបច្ចេកទេស (TWG) ខ្លួនឯង និងអនុក្រុម ដោះស្រាយបញ្ហាតាមវិស័យដែលមានរដ្ឋមន្ត្រីដើរតួជាជនបង្គោល។ បញ្ហាកំពុងផុសឡើងដូចជា គ្រោះមហន្តរាយធម្មជាតិ វិបត្តិសេដ្ឋកិច្ចសកលលោក និងបញ្ហាផ្សេងៗទៀត ក៏ជាប្រធានបទសម្រាប់ពិភាក្សាក្នុងអង្គប្រជុំនេះផងដែរ។

TWG នៅតាមក្រសួងនីមួយៗ គឺជាក្រុមស្នូល ដែលទទួលខុសត្រូវលើការអនុវត្តការត្រួតពិនិត្យ និងរាយការណ៍ពីវឌ្ឍនភាពនានា ដែលទាក់ទងនឹង HAR និងធ្វើរបាយការណ៍ទៅក្នុងកិច្ចប្រជុំទាំងពីរខាងលើ។ ជាធម្មតាគេចាត់TWG នេះជាអនុក្រុម ឬក្រុម ដែលមានសមាជិកប្រមាណ៣០នាក់ មកពីបណ្តាក្រសួងពាក់ព័ន្ធនានា។

លោក **សាលីន** និយាយបន្តទៀតថា គេនៅមិនទាន់ច្បាស់នៅឡើយថា MoE អាចមាន TWG ដាច់ដោយឡែកដែរ ឬយ៉ាងណាទេ? ព្រោះការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាអន្តរវិស័យ ដែលតម្រូវឲ្យមានយន្តការមួយច្បាស់លាស់ ហើយមានភាពងាយស្រួលក្នុងការធ្វើការជាមួយ DPs និងស្របទៅនឹងយន្តការដែលមានស្រាប់។

លោកបានបញ្ជាក់ដែរថា ក្នុងវេទិកាទាំងនេះ សំណើ និងការផ្តល់យោបល់ពីភាគីទាំងពីរ គឺពី DPs និងរាជរដ្ឋាភិបាល នឹងត្រូវបានលើកឡើងផងដែរ ដើម្បីស្វែងរកនូវដំណោះស្រាយនានាដែលអាចអនុវត្តនូវជំនួយសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាព ដែលនេះជាបុព្វហេតុធ្វើឲ្យជំនួយសហប្រតិបត្តិការ សម្រាប់កម្ពុជាមានការកើនឡើងជាលំដាប់។

លោក **សាលីន** បានថ្លែងថា បច្ចុប្បន្ននេះ យើងកំពុងអនុវត្តអភិក្រមផ្អែកលើកម្មវិធី ដែលបានកែសម្រួលឲ្យសមស្របទៅនឹងបរិបទរបស់កម្ពុជា។ អភិក្រមទាំងនេះ ផ្តល់នូវជម្រើសសម្រាប់ DPs ឲ្យគាំទ្រដល់កម្ពុជាតាមរយៈការផ្តល់ជាមូលនិធិ មូលនិធិជាចង្កោម ឬគម្រោងដាច់ៗពីគ្នា។ ប៉ុន្តែគម្រោងទាំងនេះត្រូវគាំទ្រដល់ការអភិវឌ្ឍតាមវិស័យ ឧទាហរណ៍កម្មវិធី NAPA ហើយគម្រោងទាំងនេះត្រូវស្របទៅនឹងសូចនាករដែលបានកំណត់។ ថ្មីៗនេះវិស័យជាច្រើនបាន និងកំពុងអនុវត្ត ដោយអនុលោមតាមអភិក្រមនេះ ដូចជាគម្រោងនៅក្នុងវិស័យជលផល និងយេនឌ័រ។

ជាចុងក្រោយ លោក **សាលីន** បានពន្យល់ពីទិន្នន័យ ODA ដែលគេប្រើប្រាស់សម្រាប់ គ្រប់គ្រងការបែងចែកមូលនិធិដល់ការអភិវឌ្ឍតាមវិស័យនីមួយៗនៅកម្ពុជា ទាំងជំនួយចុងក្រោយដល់ការប្រែប្រួលអាកាសធាតុ។

ហិរញ្ញវត្ថុសម្រាប់ការបន្សាំ

*ដោយលោកស្រី **ភាណា សោភ័ណ** ទីប្រឹក្សាគោលនយោបាយថ្នាក់តំបន់ អង្គការអុកស្វាមអាមេរិក*

បទបង្ហាញនេះ បានពិភាក្សាសំខាន់លើស្ថានភាពបច្ចុប្បន្ននៃហិរញ្ញវត្ថុ សម្រាប់ការកាត់បន្ថយ និងការបន្សាំ ពីតម្រូវការ និងការផ្គត់ផ្គង់របស់ប្រទេស LDCs។

បទបង្ហាញ លោកស្រី **សោភ័ណ** ភាគច្រើនដកស្រង់ចេញពីរបាយការណ៍មួយ ដែលមានឈ្មោះ "ភាពជាម្ចាស់លើការបន្សាំ" របស់អង្គការអុកស្វាម ដែលបកស្រាយអំពីហិរញ្ញប្បទាន សម្រាប់ការបន្សាំនៅក្នុងប្រទេសចំនួន០៦ ដែលមានកម្ពុជានៅក្នុងនោះផងដែរ។

ជាបឋម លោកស្រី បានបង្ហាញពីមូលហេតុថា ហេតុអ្វីបានជាប្រទេសជាច្រើន ជាពិសេស LDCs ត្រូវការហិរញ្ញប្បទាន សម្រាប់ការបន្សាំ។ ដោយផ្អែកទៅលើកិច្ចព្រមព្រៀង និងកិច្ចប្រជុំ CoP ក្នុងនោះ LDCs/DCs ទាមទារនូវទឹកប្រាក់ចំនួន ១០០ពាន់លានដុល្លា អាមេរិក

ប្រចាំឆ្នាំ ពីប្រទេសអភិវឌ្ឍន៍ ដើម្បីគាំទ្រដល់ LDCs/DCs ក្នុងការបន្សុំទៅនឹងការប្រែប្រួលអាកាសធាតុ ដែលថវិកានឹងប្រើប្រាស់សម្រាប់ដោះស្រាយបញ្ហានានា ដូចជា គ្រោះមហន្តរាយធានារ៉ាប់រងលើផលិតភាពកសិកម្ម (ឧទាហរណ៍ ការធានារ៉ាប់រងដំណាំ) និងការកសាងហេដ្ឋារចនាសម្ព័ន្ធ (ការបង្ការការជ្រៀតចូលនៃទឹកសមុទ្រ និងការគ្រប់គ្រងទឹកជំនន់) ជាដើម។ កម្ពុជាបានកំណត់គម្រោងចំនួន ៣៩ ដែលមានគម្រោងអាទិភាពចំនួន ២០ ស្ថិតនៅក្រោមកម្មវិធី NAPA ប៉ុន្តែ ការកសាងសមត្ថភាពបន្សុំនៅមូលដ្ឋានមិនបានបញ្ចូលនៅឡើយទេ។

លោកស្រីបានសង្កត់ធ្ងន់ថា មកទល់នឹងពេលនេះ មានថវិកាប្រហែលជា ២ពាន់លានដុល្លា អាមេរិក ប៉ុណ្ណោះបានផ្តល់នៃចំនួនថវិកាសរុបដែលបានសន្យាប្រហែលជា៣២ពាន់លានដុល្លាអាមេរិកនោះ។ បន្ថែមទៀត ការបែងចែកថវិកាការប្រែប្រួលអាកាសធាតុ ពុំមានតុល្យភាពទេរវាងការបន្សុំ និងការកាត់បន្ថយ ដោយទឹកប្រាក់ចំនួនតែ ១៤% ប៉ុណ្ណោះត្រូវបានផ្តល់ឲ្យសម្រាប់ការបន្សុំ ដែលចំនួននេះមានកម្រិតតិចតួចណាស់បើប្រៀបធៀបទៅនឹងចំនួន ៧៩% សម្រាប់ការកាត់បន្ថយ។

លោកស្រី **សោភ័ណ** ក៏បានលើកផងដែរពីភាពខ្វះខាតនូវមូលនិធិ ដែលមានស្រាប់ដោយសារខ្វះភាពដឹកនាំច្បាស់លាស់ ឬខ្វះការសម្របសម្រួលឲ្យបានគ្រប់គ្រាន់ ព្រមទាំងខ្វះការចូលរួម និងគណនេយ្យភាពចំពោះ CSOs និងសហគមន៍ ដែលងាយរងគ្រោះ ជាពិសេសស្ត្រី។ ទាំងនេះ គឺជាមូលហេតុនាំឲ្យការប្រើមូលនិធិទាំងនេះ ពុំមានប្រសិទ្ធភាព។

GCF គឺជាយន្តការហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុដែលបានទទួលស្គាល់ប៉ុន្តែ មូលនិធិនេះនៅមិនទាន់លេចចេញជារូបរាងនៅឡើយ។ GCF ផ្តល់នូវសក្តានុពល ក្នុងការបង្កើតអភិក្រមថ្មីៗ សម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុ នៅកម្រិតសកល។ ភាពទទួលខុសត្រូវ តម្លាភាព និងភាពជាម្ចាស់របស់ប្រទេស គឺជាលក្ខខណ្ឌនៅក្នុង GCFនេះ។

គណនេយ្យភាព គឺសំដៅលើរដ្ឋាភិបាល និងភ្នាក់ងារអន្តរជាតិ ដែលទទួលបន្ទុកក្នុងការបែងចែកធនធាន សម្រាប់ការបន្សុំឲ្យមានភាពត្រឹមត្រូវ និងសមធម៌។

តម្លាភាព គឺជាដំណើរការនៃការសម្រេចធ្វើពីរបៀបគ្រប់គ្រងមូលនិធិបន្សុំ និងការបែងចែក ដែលត្រូវតែមានតម្លាភាព និងមានការចូលរួមរបស់សហគមន៍មូលដ្ឋាន។

ភាពជាម្ចាស់របស់ប្រទេស គឺជាការចូលរួមរបស់រដ្ឋាភិបាលរបស់ប្រទេស និងសហគមន៍មូលដ្ឋានយ៉ាងពេញលេញ នៅក្នុងដំណើរការរៀបចំ និងអនុវត្តកម្មវិធី និងគម្រោងបន្សុំនានា។ ដើម្បីសម្រេចគោលដៅពី ភាពជាម្ចាស់របស់ប្រទេស ហិរញ្ញប្បទានពីGCF គួរផ្អែកលើ៖

- យុទ្ធសាស្ត្រនៅថ្នាក់ជាតិ
- ការទទួលបានមូលនិធិដោយផ្ទាល់ ពីអង្គភាពថ្នាក់ជាតិ ដែលបង្កើតឡើង និងដឹកនាំដោយរដ្ឋាភិបាល
- ការចូលរួមឲ្យបានទូលំទូលាយ និងប្រកបដោយអត្ថន័យពីសំណាក់សង្គមស៊ីវិល និងថ្នាក់សហគមន៍
- គណនេយ្យភាពពេញលេញ ចំពោះ CSOs និងសហគមន៍ដែលងាយរងគ្រោះ ក្នុងការកំណត់ឲ្យបាននូវការបើក និងប្រើមូលនិធិ
- សមភាពយេនឌ័រ និងការដឹកនាំរបស់ស្ត្រីនៅក្នុងការអភិវឌ្ឍ និងអនុវត្តយុទ្ធសាស្ត្រជាតិ
- ដំណើរការវាយតម្លៃ និងការតាមដានរឹងមាំ ការអនុវត្តហិរញ្ញវត្ថុនៃការប្រែប្រួលអាកាសធាតុ ដែលរួមមានការចូលរួមពេញលេញពីសំណាក់អ្នកពាក់ព័ន្ធនានា

- តម្លាភាពពេញលេញ ទាក់ទងមូលនិធិ និងផែនការជាក់លាក់សម្រាប់កម្មវិធី និងសកម្មភាពជាក់លាក់

តើដំណើរការអ្វីខ្លះ ដែលអាចដំណើរការបាននៅកម្ពុជា? លោកស្រី **សោភ័ណ** បានលើកឡើងថា វេទិកានេះ ផ្តល់នូវឱកាសល្អមួយដោយកម្ពុជា កំពុងរៀបចំខ្លួនសម្រាប់ការបង្កើតផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ ដើម្បីដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។ លោកស្រីបន្តទៀតថា ដើម្បីទទួលបាននូវការបន្សាំប្រកបដោយប្រសិទ្ធភាព បញ្ហាប្រឈម ដែលត្រូវដោះស្រាយនោះ គឺសមត្ថភាពរបស់ស្ថាប័នក្នុងការគ្រប់គ្រង រៀបចំ និងអនុវត្តផែនការ។ កម្ពុជាពេលនេះមានកម្មវិធី២ចម្បងៗ គឺ CCCA និង PPCR ដែលជាឱកាសសម្រាប់កម្ពុជា ដែលមានហិរញ្ញប្បទានទុកចិត្តខ្លួនឯង ដូចប្រសាសន៍របស់ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ដែលបានលើកឡើង។

លោកស្រី **សោភ័ណ** បានបញ្ជាក់ទៀតថា កម្ពុជា គឺជាប្រទេសតែមួយគត់ដែលជម្រុញឲ្យមានការចូលរួមពី CSOs ដូចជាក្នុង PPCR ដែលគ្មានប្រទេសណាអនុវត្តតាមទេ ជាពិសេសនៅ DCs។ យេនឌ័រ ក៏បញ្ជាដែលមានការយកចិត្តទុកដាក់ខ្ពស់នៅកម្ពុជា តាមរយៈបទបង្ហាញនានា ដែលបានបង្ហាញនៅក្នុងវេទិកានេះ ដូចនេះជាសញ្ញា ដែលបញ្ជាក់ថា កម្ពុជាកំពុងធ្វើដំណើរក្នុងវិថីមួយដ៏ត្រឹមត្រូវ។

ជាទីបញ្ចប់ លោកស្រីបានរៀបរាប់អំពីករណីសិក្សានានា ដែលទាក់ទងបញ្ហាយេនឌ័រ និងការចូលរួម។ គម្រោងទាំងនោះមាន សមធម៌សុខភាព និងមូលនិធិពិភពលោក សំដៅដល់ការគ្រប់គ្រងមូលនិធិ តាមបែបផែននៃការចូលរួម CSOs និងទីផ្សារគាំទ្រអ្នកក្រីក្រតាមរយៈ ការផ្តល់អំណាចទៅដល់សហគមន៍ និងមជ្ឈមណ្ឌលជលផលពិភពលោក ដែលផ្តោតលើការកសាងសមត្ថភាព។

សំណួរ និងចម្លើយ

លោក **យ៉ាក់ សុទ្ធិរិទ្ធ** មកពីស្ថានទូតចក្រភពអង់គ្លេស បានសួរលោក **សាលីន** ឲ្យជួយបកស្រាយបន្ថែមអំពីរបៀបក្នុងការគ្រប់គ្រង និងសម្របសម្រួលនៅក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ។

លោក **រស់ សាលីន** បានបកស្រាយថា ជាការពិត ជំនួយសហប្រតិបត្តិការសម្រាប់ការប្រែប្រួលអាកាសធាតុ និងយន្តការដែលមានស្រាប់បាននិងកំពុងអនុវត្ត ប៉ុន្តែមិនទាន់អនុវត្តនៅក្នុងទ្រង់ទ្រាយធំនៅឡើយទេ នៅកម្ពុជា។ មកទល់នឹងបច្ចុប្បន្ននេះ CDC ទើបតែទទួលបាន ODA ពីម្ចាស់ជំនួយផ្សេងៗតាមធម្មតា ហើយវាគ្រាន់តែជាចំណុចចាប់ផ្តើមតែប៉ុណ្ណោ។ ក្រៅពីនេះ TWG ពុំទាន់បង្កើតឡើងនៅឡើយ ហេតុនេះ យើងមិនអាចប្រើប្រាស់ជាការពិគ្រោះយោបល់គោលនយោបាយ ដើម្បីចរចាជាមួយម្ចាស់ជំនួយក្នុងដំណាក់កាលនេះបានទេ។

លោក Alex Heikens មកពីមជ្ឈមណ្ឌលតំបន់អាស៊ី-ប៉ាស៊ីភិចនៃ UNDP បានលើកជាសំណួរថា តើការផ្តល់ហិរញ្ញប្បទានសម្រាប់ការប្រែប្រួលអាកាសធាតុ នឹងត្រូវផ្តល់តាមរយៈ ODA ឬនឹងត្រូវផ្តល់ដល់កម្ពុជានៅក្នុងទម្រង់មួយផ្សេងទៀតពី ODA ។

លោក **រស់ សាលីន** ឆ្លើយតបថា CDC បានស្នើសុំជំនួយពី DPs ដើម្បីអភិវឌ្ឍលេខកូដទិន្នន័យរបស់ ODA និងបញ្ចូលវាទៅក្នុងប្រព័ន្ធ Online ដើម្បីឲ្យម្ចាស់ជំនួយបំពេញនូវព័ត៌មានលម្អិតនៃ ODA ដែលផ្តល់ដោយកម្ពុជា។ ប៉ុន្តែវាគ្រាន់តែជាចំណុចចាប់ផ្តើម សម្រាប់កម្ពុជា ហើយ CDC ពុំទាន់បានលើកយកប្រធានបទស្តីពី ហិរញ្ញវត្ថុសម្រាប់ការប្រែប្រួលអាកាសធាតុ

ទៅក្នុងកិច្ចពិភាក្សា ជាមួយម្ចាស់ជំនួយនៅឡើយ។

លោក **សុវណ្ណនី** មកពីមន្ទីរបរិស្ថានខេត្តរតនៈគីរី បានលើកជាចម្ងល់ថា ហេតុអ្វីបានក្នុងចំណោមគម្រោងអាទិភាពទាំង ២០ នៃកម្មវិធី NAPA មានតែគម្រោងចំនួន០២ប៉ុណ្ណោះ ត្រូវបានគេអនុវត្ត?

លោក **រស់ សាលីន** ឆ្លើយតបថា កង្វះខាងថវិកា ជាបញ្ហាដែលធ្វើឲ្យគម្រោងទាំងនោះពុំអាចអនុវត្តបាន។ លោកបានផ្តល់ជាយោបល់ថា MoE អាចជាស្ថាប័នដែលអាចទទួលបានព័ត៌មានបន្ថែមទាក់ទងនឹងបញ្ហានេះ។

លោក **សុវណ្ណនី** បន្តសំណួរថា ហេតុអ្វីបានជាពុំមានកិច្ចសហប្រតិបត្តិការរវាង NGOs និងស្ថាប័នរាជរដ្ឋាភិបាល នៅក្នុងការចែករំលែកព័ត៌មាន?

លោក **រស់ សាលីន** និយាយឲ្យដឹងថា មានមូលហេតុជាច្រើន ដែលយើងអាចធ្វើការជាមួយគ្នាបានក្នុងការចែករំលែកព័ត៌មានគ្នាទៅវិញទៅមក ប៉ុន្តែជាក់ស្តែងយើងបរាជ័យក្នុងការធ្វើបែបនេះ។

ភគ្គស្របតួា ទី៣

បញ្ហាអន្តរវិស័យនៃការប្រែប្រួលអាកាសធាតុ

សហប្រធានៈ

១. លោក ម៉ែន មុន្នីរក្ស ជាអនុប្រធាននាយកដ្ឋានអនុសញ្ញាអន្តរជាតិនិងជីវចម្រុះនៃ MoE

២. ឯកឧត្តម គុល ភឌ្ឍនា ជាសមាជិក NCCC និងជាអគ្គនាយករងនៃ CNMC

ឯកឧត្តម **ភឌ្ឍនា** បានសង្កត់ធ្ងន់ថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាអន្តរវិស័យ ដែលទាមទារឲ្យមានការចូលរួមពីគ្រប់វិស័យ ក្នុងការដោះស្រាយបញ្ហា ដូចទៅនឹងប្រសាសន៍ដែលបានលើកឡើងដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងទេសរដ្ឋមន្ត្រី។ សកម្មភាពចម្បងចំនួនពីរ ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ គឺការបន្សាំ និងការកាត់បន្ថយ។ ឯកឧត្តមបានគូសបញ្ជាក់ផងដែរថា អភិក្រមនៃការរួមបញ្ចូលគ្នា គឺជាវិធីសាស្ត្រមួយដ៏ពេញនិយម និងមានប្រសិទ្ធភាពក្នុងបរិបទនៃការអភិវឌ្ឍប្រកបដោយចីរភាព និងល្អបំផុតសម្រាប់ការឆ្លើយតបនឹងផល ប៉ះពាល់បណ្តាលពីការប្រែប្រួលអាកាសធាតុ។

ជីវចម្រុះ និងការប្រែប្រួលអាកាសធាតុ

*ដោយបណ្ឌិត **Geoffrey Blate** ជាទីប្រឹក្សាជាន់ខ្ពស់សម្រាប់ការអភិរក្សទេសភាព និងការប្រែប្រួលអាកាសធាតុនៃកម្មវិធីមហាអនុតំបន់ទន្លេមេគង្គ WWF*

បទបង្ហាញនេះ បានផ្តោតសំខាន់ទៅលើភស្តុតាងជាក់លាក់នៃផលប៉ះពាល់បណ្តាលមកពីការប្រែប្រួលអាកាសធាតុពីមុន ដែលធ្លាប់កើតលើជីវចម្រុះរបស់កម្ពុជា ក្រោមសេណារីយូនៃការប្រែប្រួលអាកាសធាតុផ្សេងទៀត ព្រមទាំងបកស្រាយផងដែរពី ផលប៉ះពាល់ជាសក្តានុពលនៃវិធានការឆ្លើយតប ការប្រែប្រួលអាកាសធាតុមកលើជីវចម្រុះ និងតំបន់ជាអាទិភាពសម្រាប់ការសិក្សាស្រាវជ្រាវទៅអនាគត និងអនុសាសន៍នយោបាយចម្បងៗមួយចំនួន។

លោកបណ្ឌិត Blate ចាប់ផ្តើមដោយផ្តល់និយមន័យនៃពាក្យ ជីវចម្រុះ ថាជាជីវិតនៅលើផែនដី ដែលមិនត្រឹមតែជាប្រភេទផ្សេងៗ នៃរុក្ខជាតិ សត្វទេ ថែមទាំងលំដាប់ថ្នាក់នៃក្រុម និងមុខងារផងដែរ។ ជីវចម្រុះនៅកម្ពុជា និងតំបន់ទន្លេមេគង្គមានភាពសម្បូរបែបមិនធម្មតា។ ជីវចម្រុះតំបន់ទន្លេមេគង្គ គឺជាតំបន់មានជីវចម្រុះសម្បូរជាងគេលំដាប់ទីពីរ នៅលើពិភពលោក ហើយជាតំបន់ ដែលសម្បូរត្រីទឹកសាបច្រើនជាងគេ និងជាប្រភពនៃសន្តិសុខស្បៀង និងទឹកសម្រាប់ប្រជាជន៦០លាននាក់ នៅក្នុងអាងទន្លេ

នេះ។ គួរឲ្យកត់សម្គាល់ផងដែរថា កម្ពុជា ពឹងផ្អែកទៅលើជីវចម្រុះ និងសេវាកម្មស្ថានប្រព័ន្ធ ដើម្បីផ្គត់ផ្គង់ជីវភាពរស់ នៅរបស់ប្រជាជន និងសេដ្ឋកិច្ច។ ជីវចម្រុះនៅ កម្ពុជាបានទទួលរងនូវការគម្រាមកំហែង មិនត្រឹមតែបណ្តាលមកពីឥទ្ធិពលនៃការប្រែ ប្រួលអាកាសធាតុ ក៏ប៉ុន្តែតាមរយៈការប្រមាញ់ និងការទាញយកលើសកម្រិត។

មកទល់នឹងបច្ចុប្បន្ននេះ ពុំទាន់មានការសិក្សាពីផលប៉ះពាល់ ដែលបានសង្កេតឃើញថាបានកើតមានលើជីវចម្រុះនៅកម្ពុជា ទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅឡើយ និងគ្មានឯកសារបង្ហាញច្បាស់លាស់ ដោយសារកង្វះខាតការសិក្សាការតាមដាន និងការសិក្សាស្រាវជ្រាវរយៈពេលវែង ដែលផ្តោតចំគោលដៅ។ ការប្រឈម ការកំណត់អត្ត សញ្ញាណសូចនាករនៃការប្រែប្រួលអាកាសធាតុ ត្រូវបានធ្វើឡើងនៅក្នុងប្រព័ន្ធបើកចំហតែប៉ុណ្ណោះ។

សក្តានុពលផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវចម្រុះ គឺប៉ះពាល់ដោយផ្ទាល់ទៅលើប្រភេទសត្វ រុក្ខជាតិ និងតាមរយៈការផ្លាស់ប្តូរស្ថានប្រព័ន្ធ និងប៉ះពាល់ដល់ប្រភេទទាំងនេះ ដែលរស់នៅតំបន់តូចៗ និងកំណត់ប្រភេទ ដែលពុំសូវរ៉ាយប៉ាយតាមកន្លែងនានា ប្រភេទដែលមានតែនៅលើកំពូលភ្នំ និងតាមកោះទាបៗ ប្រភេទដែលពឹងផ្អែកលើលក្ខខណ្ឌរស់នៅជាក់លាក់ និងប្រភេទដែលមានសីរៈសាស្ត្រពុំសូវធន់នឹងការប្រែប្រួលនានា។

លោកបណ្ឌិត Blate បានលើកផងដែរអំពី ផលប៉ះពាល់សក្តានុពលខ្លះៗនៃការប្រែប្រួលអាកាសធាតុទៅលើជីវចម្រុះ។ លោកបានបញ្ជាក់ថា ប្រភេទល្មួន និងកង្កែប គឺជា ប្រភេទដែលងាយទទួលរងផលប៉ះពាល់ធ្ងន់ធ្ងរ ពីការប្រែប្រួលអាកាសធាតុនៅតំបន់ SEA ដែលរួមទាំងកម្ពុជា ព្រោះប្រភេទទាំងនោះងាយរងឥទ្ធិពលពីការប្រែប្រួលនៃសីតុណ្ហភាព។ ការថយចុះនូវវិសាលភាពព្រៃឈើ និងការប្រែក្លាយពីព្រៃស្រោងទៅជាព្រៃល្បោះ ដែលអាចបន្សាំបានប្រសើរ ជាមួយនឹងការប្រែប្រួលអាកាសធាតុ។

តំបន់ដីសើម ក៏ងាយរងគ្រោះផងដែរ ព្រោះអាចធ្វើឲ្យជម្រៅបឹងកាន់តែរាក់ និងរំហួតលឿនជាងមុន។ តំបន់ដីសើម ដែលនៅដាច់ស្រយ៉ាលងាយស្លូត និងបាត់បង់ពីតំបន់ធម្មជាតិលឿនជាងតំបន់ដីសើម ដែលតភ្ជាប់នឹងទន្លេ។

ភ្លើង មានទំនោរធ្វើឲ្យអាកាសធាតុស្ងួត និងមានសីតុណ្ហភាពក្តៅជាមុន។ នៅក្នុង SEA សេដ្ឋកិច្ចរបស់កម្ពុជា គឺងាយរងគ្រោះជាងគេ ដោយប្រទេសនេះពឹងផ្អែកស្ទើរទាំងស្រុងទៅលើវិស័យជលផល។ ប្រសិនបើសេដ្ឋកិច្ចទីផ្សារភ្ជាប់ខ្លាំងទៅនឹងវិស័យជលផល នោះនឹងមានប្រជាជនជាច្រើនពឹងផ្អែកលើជលផល ហើយសក្តានុពលនៃផលប៉ះពាល់ជាអវិជ្ជមាន នៃការប្រែប្រួលអាកាសធាតុ លើចីរភាពនៃវិស័យនេះក៏ខ្ពស់ផងដែរ។ សក្តានុពលផលប៉ះពាល់ផ្សេងៗទៀតទៅលើជីវចម្រុះ គឺការប្រែប្រួលនៅក្នុងស្ថានប្រព័ន្ធ ការកើនឡើងនៃប្រភេទក្រៅស្រុក និង/ឬប្រភេទធន់ អសន្តិសុខស្បៀងសម្រាប់ប្រជាជន ដែលពឹងផ្អែកលើកសិកម្ម ជលផល និងអនុផលព្រៃឈើ។

លោកបណ្ឌិត Blate បានលើកបង្ហាញពីវិធានការបន្សាំ និងការកាត់បន្ថយមួយចំនួនដែលគួរយកមកគិតគូរពិចារណា ដូចមានរាយខាងក្រោម៖

- កាត់បន្ថយភាពនៅដាច់ពីគ្នា និងធ្វើឲ្យមានការផ្សារភ្ជាប់គ្នានៃទីជម្រក ដើម្បីអនុញ្ញាតឲ្យប្រភេទសត្វ និងរុក្ខជាតិ បន្សាយពូជក្រោមលក្ខខណ្ឌខុសៗគ្នា
- រៀបចំផែនការតំបន់ទេសភាព ដើម្បីឲ្យមានការតភ្ជាប់គ្នានៃទីជម្រក សម្រាប់ជីវចម្រុះសំខាន់ៗ

- ប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធទន់ ឬតាមបែបធម្មជាតិដែលអាចបន្សាំទៅនឹងការប្រែប្រួលអាកាធាតុ
- រួមបញ្ចូលស្ថានប្រព័ន្ធ និងសហគមន៍នានាទៅក្នុងការសាងផែនការបន្សាំ និងផែនការអភិវឌ្ឍន៍

REDD អាចជាជម្រើសមួយដ៏ល្អសម្រាប់ការបន្សាំ ដើម្បីធានាភាពធន់នឹងប្រព័ន្ធ និងកាត់បន្ថយនូវបញ្ហាសាកលលោក។ ក្នុងទស្សនវិស័យកម្រិតតំបន់ កិច្ចសហប្រតិបត្តិការមានសារៈសំខាន់ក្នុងការអនុវត្ត REDD ប្រកបដោយប្រសិទ្ធភាព តាមរយៈការគ្រប់គ្រងការលេច ឬការបាត់បង់កាបូន ឆ្លងប្រទេស។

សក្តានុពលផលប៉ះពាល់ ដែលបណ្តាលមកពីសកម្មភាពមនុស្សលើជីវចម្រុះ ហាក់ដូចជាមានទំហំធំជាងផលប៉ះពាល់ដោយផ្ទាល់ ពីការប្រែប្រួលអាកាសធាតុទៅលើជីវចម្រុះ។ ជាការសំខាន់ណាស់ក្នុងការពិចារណា អំពីទស្សនវិស័យគ្រប់ជ្រុងជ្រោយ និងបញ្ជៀសការបន្សាំមិនត្រឹមត្រូវចំពោះ ប្រព័ន្ធចម្រុះជីវសាស្ត្រដោយផ្តល់នូវភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

វិស័យជាអាទិភាពសម្រាប់ការស្រាវជ្រាវទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងជីវចម្រុះ គួរផ្តោតលើ៖

- ផលប៉ះពាល់មកលើភាពពេញលេញ និងសេវានៃស្ថានប្រព័ន្ធនៅថ្នាក់ជាតិ និងតំបន់ពីការអភិវឌ្ឍ ដែលបានគ្រោងទុក និងការអនុវត្តសាកល្បងពី ម្រើសនានាសម្រាប់ជំនួសហេដ្ឋារចនាសម្ព័ន្ធរូបវន្ត
- សមត្ថភាពបន្សាំនៃក្របខណ្ឌស្ថាប័ន
- វិស័យដែលត្រូវកែប្រែគោលនយោបាយដើម្បីផ្តល់លក្ខខណ្ឌអំណោយផល និងបង្ក្រាបការបន្សាំ និងការកាត់បន្ថយនៃការប្រែប្រួលអាកាសធាតុ
- បង្កើតអភិក្រមចម្រុះក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ
- ការកំណត់អត្តសញ្ញាណនៃតម្រូវការសមត្ថភាពសម្រាប់អភិវឌ្ឍអភិក្រមចម្រុះក្នុងការកសាងផែនការប្រើប្រាស់ដីធ្លី

លោកបណ្ឌិត **Blate** បានលើកឡើងពីមូលហេតុសំខាន់ៗ ដែលតម្រូវឲ្យមានអភិក្រមចម្រុះ រួមមាន៖

- ស្ថានប្រព័ន្ធ និងសហគមន៍ ដែលងាយរងគ្រោះ កំពុងប្រឈមនឹងហានិភ័យបណ្តាលមកពីការប្រែប្រួលអាកាសធាតុ និងសម្ពាធផ្សេងៗទៀត
- ហេដ្ឋារចនាសម្ព័ន្ធ "រឹង" មានច្រើន ប៉ុន្តែមានហានិភ័យក្នុងការវិនិយោគ
- លើកកម្ពស់ឲ្យមានដំណោះស្រាយ នៅមូលដ្ឋាន ដើម្បីបង្កើនភាពធន់របស់មនុស្ស និងស្ថានប្រព័ន្ធដែលពួកគេពឹងអាស្រ័យ
- លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធធម្មជាតិ។ នេះមិនមែនបានន័យថា បំភ្លេចនូវហេដ្ឋារចនាសម្ព័ន្ធរឹងទេ ពីព្រោះ វាមានភាពចាំបាច់ក្នុងករណីខ្លះ ប៉ុន្តែ ហេដ្ឋារចនាសម្ព័ន្ធទន់ត្រូវយកចិត្តទុកដាក់ជាប្រចាំ

ចុងបញ្ចប់ លោកបណ្ឌិត ក៏បានផ្តល់ជាអនុសាសន៍គោលនយោបាយសំខាន់ៗ ដែលរួមមាន៖

- គាំទ្រនូវជម្រើសផ្សេងៗ ដើម្បីជំនួសឲ្យហេដ្ឋារចនាសម្ព័ន្ធរឹង ព្រោះហេដ្ឋារចនាសម្ព័ន្ធធម្មជាតិ តែងផ្តល់ភាពធន់បានល្អ។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធធម្មជាតិមិនត្រឹមផ្តល់នូវភាពធន់ទេ ថែមទាំងជាជម្រើសដ៏ល្អ សម្រាប់ការបន្សាំ និងការកាត់បន្ថយ

- គោលនយោបាយ ផែនការ និងហេដ្ឋារចនាសម្ព័ន្ធ ត្រូវតែមានន័យភាពបត់បែន ដោយសារតែហានិភ័យ និងភាពមិនប្រាកដប្រជានៃការព្យាករណ៍ អំពីការប្រែប្រួលអាកាសធាតុ
- ការធ្វើផែនការ និងការសម្របសម្រួលត្រូវធ្វើឡើងជាអន្តរវិស័យ ហើយចាំបាច់ត្រូវមានភាពជាដៃគូ រវាងវិស័យនានា ដើម្បីសិក្សា និងអនុវត្តសកម្មភាពបន្ត
- បង្កើតឲ្យមានលក្ខខណ្ឌអំណោយផលដែលគាំទ្រ (រួមបញ្ចូលទាំងការកែលម្អអភិបាលកិច្ច) ដើម្បីឲ្យមានវិធាននានាសម្រាប់ការបន្សាំ និងការកាត់បន្ថយប្រកបដោយភាពជោគជ័យ
- ប្តេជ្ញាធ្វើឲ្យបាននូវកិច្ចសហប្រតិបត្តិការថ្នាក់តំបន់ ដើម្បីដោះស្រាយរាល់ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងឥទ្ធិពលពីការអភិវឌ្ឍ

យេនឌ័រ និងការប្រែប្រួលអាកាសធាតុ

*ដោយអ្នកស្រី **Annaka Peterson***
ជាអ្នកសម្របសម្រួលកម្មវិធីថ្នាក់តំបន់នៃ OA

បទបង្ហាញនេះ បានធ្វើការពិភាក្សាទៅលើ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការឆ្លើយតប តាមរយៈទស្សនវិស័យយេនឌ័រ និងផ្តល់មេរៀនទទួលបានពីថ្នាក់តំបន់ សម្រាប់ការរៀបចនូវផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយមានការគិតគូរអំពីយេនឌ័រ។

អ្នកស្រី ***Peterson*** បានបញ្ជាក់ថា លទ្ធផលនៃការសិក្សាមួយចំនួន បានរកឃើញថា ចំនួនស្ត្រីបានស្លាប់ច្រើនជាងបុរស នៅពេលដែលគ្រោះមហន្តរាយកើតមានឡើង ដោយសារតែ កម្រិតខុសគ្នានៃភាពងាយរងគ្រោះ។ ភាព ងាយរងគ្រោះរបស់ស្ត្រីនៅក្នុងស្ថានភាពខ្លះ បណ្តាលមកពី តួនាទីរបស់ស្ត្រីនៅក្នុងសង្គមដោយផ្ទាល់ ហើយវិសមភាពយេនឌ័រ មានចំណងទាក់ទងនឹងភាពងាយរងគ្រោះ និងហានិភ័យ។ ការកើនឡើងគ្រោះធម្មជាតិ និងការប៉ះទង្គិចការប្រែប្រួលអាកាសធាតុ អាចធ្វើឲ្យមានវិសមភាពយេនឌ័រកើនឡើង។ នៅកម្ពុជា អត្រានៃការបោះបង់ចោលការសិក្សារបស់ក្មេងស្រី គឺច្រើនជាងក្មេងប្រុស ដើម្បីរួមចំណែកក្នុងការរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារ ហើយនេះជាវិធីសាស្ត្រមួយដែលតែងតែកើតមាន ពេលគ្រួសារកំពុងមានគំនាបសង្កត់ ឬការប៉ះទង្គិច។ ការគិតគូរពីសមភាពយេនឌ័រ និងការប្រែប្រួលអាកាសធាតុ អាចជះឥទ្ធិពលដល់ប្រសិទ្ធភាពក្នុងកិច្ចខិតខំប្រឹងប្រែង ឆ្លើយតបការប្រែប្រួលអាកាសធាតុ។ ឧទាហរណ៍ នៅកម្ពុជា កិច្ចអន្តរាគមន៍ដ៏សំខាន់មួយដែលគួរធ្វើនោះ គឺការផ្តល់នូវព័ត៌មានអំពីស្ថានភាពអាកាសធាតុដល់ប្រជាជន ជាពិសេសប្រជាជន ដែលរស់នៅតំបន់ជនបទ ហើយជាពិសេសស្ត្រី។ ជាក់ស្តែងចំនួនបុរសដែលអាចទទួលបាន ឬដឹងព័ត៌មាន ពីប្រព្រឹត្តិការណ៍នៃការប្រែប្រួលអាកាសធាតុ មានរហូតដល់ ៦៦% ចំណែកស្ត្រីវិញមានប្រមាណតែ ៦% ប៉ុណ្ណោះ។ ព័ត៌មានទាំងនេះ មានសារសំខាន់ណាស់ ព្រោះប្រជាជនអាចឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុបាន ប្រសិនបើកម្រិតនៃការទទួលបានព័ត៌មានកើនឡើង។

អ្នកស្រី លើកជាសំណួរថា "ហេតុអ្វីការប្រែប្រួលអាកាសធាតុ ប៉ះពាល់ទៅលើស្ត្រីខ្លាំងជាង?" ជាទូទៅ ការប៉ះទង្គិចនេះបណ្តាលមកពីវិសមភាព និងភាពខុសគ្នាយេនឌ័រ ដែលមានស្រាប់។ នៅលើពិភពលោក ស្ត្រីមាន ចំនួនដល់ទៅ ៧៧% ក្នុងចំណោមអ្នកក្រីក្រមានលទ្ធភាពទទួលបាន និងអំណាចគ្រប់គ្រងតិចតួចលើធនធាន សេវាកម្ម និងការសម្រេចចិត្តនានា។ ស្ត្រីហាក់មានភាពសកម្មក្នុងវិស័យ ដែល

ងាយទង្គិចខ្លាំង ដោយសារការប្រែប្រួលអាកាសធាតុផងដែរ។

ស្ត្រីក្នុងប្រទេសកម្ពុជា មានតួនាទីយ៉ាងសំខាន់នៅក្នុងវិស័យកសិកម្ម។ ស្ត្រីចំនួន៧១% ពឹងផ្អែកលើវិស័យកសិកម្មជាចម្បង សម្រាប់ការផ្គត់ផ្គង់លើជីវភាពរស់នៅក្នុងគ្រួសារ ប៉ុន្តែវិស័យនេះក៏ងាយរងគ្រោះបំផុតពីការប្រែប្រួលអាកាសធាតុផងដែរ។ ជាមួយគ្នានេះដែរ ស្ត្រីក៏ជាតួអង្គមួយដ៏សំខាន់ ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្មនេះផងដែរ ប៉ុន្តែការទទួលបានសេវាកម្មពីវិស័យ កសិកម្មនេះ គឺមានត្រឹមតែ ១០% ប៉ុណ្ណោះ។ ទាំងបុរស និងស្ត្រីអាចមាននូវនាទីបន្ថែមក្នុងការធានាឲ្យមាននូវសន្តិសុខស្បៀង ប៉ុន្តែ ស្ត្រីដើរតួយ៉ាងសំខាន់ក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងការធានាបាននូវអាហារូបត្ថម្ភ។ តួនាទីសំខាន់មួយទៀតរបស់ស្ត្រី គឺការទៅយក និងប្រមូលទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ ហើយជាទូទៅ ត្រូវចំណាយរយៈពេលពី១ ទៅ២ ម៉ោងក្នុងមួយថ្ងៃ និង៤ ម៉ោងក្នុងមួយថ្ងៃនៅរដូវក្តៅ។

អ្នកស្រីបានបញ្ជាក់ថា នៅកម្ពុជាការប្រែប្រួលអាកាសធាតុនឹងមានន័យថា ស្ត្រីនឹងត្រូវប្រឈមនឹង៖

- សម្ពាធកើនឡើងបង្កមកពីការប្រែប្រួលអាកាសធាតុក្នុងការស្វែងរកវិធីផ្សេងៗ ដើម្បីចិញ្ចឹមគ្រួសារ ក៏ដូចជាការប្រមូលធនធានធម្មជាតិ និងស្វែងរកចំណូលផ្សេងពីការធ្វើស្រែចំការ
- ភាពប្រកួតប្រជែងកើនឡើង នៅក្នុងការទទួលបានទឹក និងធនធានធម្មជាតិដទៃទៀត ដែលមានន័យថា ស្ត្រីត្រូវចំណាយពេលច្រើនជាងមុន ក្នុងការប្រមូលធនធានទាំងនេះសម្រាប់គ្រួសារ
- ទទួលរងឥទ្ធិពលអវិជ្ជមានលើសុខភាព និងកំណើនទំនួលខុសត្រូវក្នុងនាមជាអ្នកមើលថែគ្រួសារ ពេលដែលប្រឈមនឹងការប៉ះទង្គិច

អ្នកស្រី ក៏បានលើកឡើងនូវឧទាហរណ៍ចំនួន២ របស់គម្រោង NAPA ដែលផ្តោតសំខាន់ទៅលើវិស័យយេនឌ័រនៅកម្ពុជា។ គម្រោង ទី១ គឺគម្រោងស្តារអាងធារាសាស្ត្រ សម្រាប់ការប្រើប្រាស់ពហុបំណងនៅខេត្តតាកែវ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងនូវ សមត្ថភាពស្តុកទឹកសម្រាប់ការប្រើប្រាស់ផ្សេង រួមទាំងប្រព័ន្ធធារាសាស្ត្រ ការផ្គត់ផ្គង់ទឹកសម្រាប់ទីប្រជុំជន និងជីវចម្រុះ។ គម្រោងទី២ ជាគម្រោងស្តារព្រៃកោងកាងដោយសហគមន៍ និងការប្រើប្រាស់ធនធានធម្មជាតិដោយចីរភាពនៅខេត្តកំពត កែប និងខេត្តកោះកុង ដើម្បីធ្វើឲ្យមានស្ថេរភាពច្រាំងសមុទ្រ កាត់បន្ថយការជ្រៀបចូលនៃទឹកសមុទ្រ និងការសឹករេចរឹលតំបន់ឆ្នេរ និងដើម្បីការពារតំបន់ឆ្នេរពីខ្យល់ព្យុះនានា។ គម្រោង NAPA ត្រូវបានរៀបចំឡើង ដើម្បីគាំទ្រដល់ការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ នៅកម្ពុជា។ ដើម្បីធានាថាបុរស និងស្ត្រីអាចទទួលបាននូវអត្ថប្រយោជន៍ពីគម្រោង គឺយើងត្រូវប្រើអតិក្រមយេនឌ័រជាចាំបាច់។ ការបញ្ចូលយេនឌ័រ នៅក្នុង NAPA ចាំបាច់ត្រូវធ្វើ៖

- ការវាយតម្លៃ និងការវិភាគលើ ហានិភ័យ និងភាពងាយរងគ្រោះ ត្រូវតែពិចារណាពីភាពខុសគ្នារវាងបុរស និងស្ត្រីពេលដែល NAPA ផ្តោតលើផលប៉ះពាល់រួមពីការប្រែប្រួលអាកាសធាតុ
- លក្ខណៈវិនិច្ឆ័យសម្រាប់ការចាត់ជាអាទិភាព និងការជ្រើសរើសគម្រោងគួរតាប់បញ្ចូលសមភាពយេនឌ័រ
- សម្របសម្រួលឲ្យមានការចូលរួម និងធ្វើជាតំណាងពីសំណាក់បុរស និងស្ត្រីក្នុងដំណើរការ និង
- កែលម្អគម្រោងមុននឹងយកទៅអនុវត្ត។

ការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុរបស់យេនឌ័រគួរតែមានរួមបញ្ចូលទាំងគោលការណ៍បញ្ជាបយេនឌ័រ ដែលរួមមានទាំងការពង្រឹងសមភាពយេនឌ័រ និងការជម្រុញការផ្តល់អំណាចដល់ស្ត្រី។ ត្រូវបញ្ចូលយេនឌ័រទៅក្នុងគ្រប់វិស័យនៃកម្មវិធីគម្រោង និងវដ្តនៃនយោបាយទាំងអស់ រួមមាន គោលបំណងនៃការសិក្សា ការតាមដាន និងការវាយតម្លៃ។ វិសមភាពយេនឌ័រ គឺជាឫសគល់ចម្បងនៃភាពងាយរងគ្រោះទៅនឹងការប្រែប្រួលអាកាសធាតុ ហេតុនេះ កិច្ចខិតខំប្រឹងប្រែងលើការបន្សាំ គួរតែគិតគូរសំខាន់ទៅលើបញ្ហាសង្គម ព្រមទាំងបញ្ហារូបវន្តដូចជាប្រព័ន្ធធនធានទឹកជាដើម។

សំណួរ និងចម្លើយ

អ្នកស្រី **ឈឹម រមណី** មកពី CDRI បានថ្លែងថា នៅក្នុងទស្សនទានបរិស្ថាន គ្មានអ្វីដែលមិនគិតថ្លៃនោះទេ អ្វីៗទាំងអស់សុទ្ធតែមានតម្លៃរបស់វា។ តើមានសំណងសម្រាប់ការបាត់បងលើធនធានជីវចម្រុះ និងធនធានធម្មជាតិ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ ឬទេ? តើមានគោលនយោបាយណាមួយ បកស្រាយពីសំណងលើការបាត់បង់ទាំងនេះដែរ ឬទេ?

លោកបណ្ឌិត **Geoffrey Blate** បកស្រាយថា នាពេលបច្ចុប្បន្ននេះ ពុំទាន់មានគោលនយោបាយជាសាកលណាមួយនៅឡើយទេទាក់ទងនឹងអ្វី ដែលអ្នកស្រីបានលើកឡើងនោះទេ។ ដូចដែលបានដឹងហើយ ពិធីសារក្យូតូ គឺជាក្របខណ្ឌពិភពលោកមួយ ដែលគេបង្កើតឡើង ប៉ុន្តែពុំមានរៀបរាប់ពីសំណងនៅក្នុងនោះទេ។ ទោះជាយ៉ាងនេះក្តី នៅកិច្ចប្រជុំទីក្រុងកូប៉េនហាក់ ប្រទេសជាច្រើនបានប្តេជ្ញាដោយគោរពតាម REDD ការបន្សាំ ការផ្ទេរបច្ចេកវិជ្ជា និងការកសាងសមត្ថភាព។ ដូច្នេះ យន្តការទាំងអស់នេះ អាចយកមកអនុវត្ត ដើម្បីការពារការបាត់បង់ជីវចម្រុះ ប៉ុន្តែមិនមែនជាលក្ខណៈសំណងទេ។

លោកស្រី **ង៉ឹម កល្យាណី** អនុប្រធានមន្ទីរបរិស្ថាន ខេត្តព្រះសីហនុ សំណូមពរឲ្យមានការបកស្រាយបន្ថែមពីពាក្យ ហេដ្ឋារចនាសម្ព័ន្ធ រឹង ទន់ និងធម្មជាតិ។

លោកបណ្ឌិត **Blate** បានឆ្លើយតបថា ក្នុងបរិបទ ការបន្សាំការប្រែប្រួលអាកាសធាតុមានជម្រើសជាច្រើន ឧទាហរណ៍ ការសាងសង់ទំនប់សម្រាប់ការពារទឹកជំនន់ ការជីកអណ្តូង ឬការសាងសង់អាងស្តុកជាជម្រើសសម្រាប់គ្រោះរាំងស្ងួត ឬសាងសង់ជញ្ជាំងសមុទ្រ ដើម្បីការពារខ្សាច់ព្រុះ ដែលទាំងអស់នេះ គេហៅថាហេដ្ឋារចនាសម្ព័ន្ធរឹង។ ជាទូទៅ ហេដ្ឋារចនាសម្ព័ន្ធរឹង ចំណាយខ្ពស់ និងមានហានិភ័យនៃការបរាជ័យ និងភាពមិនប្រាកដប្រជាខ្ពស់នៅថ្ងៃអនាគត។ ដូចនេះ គេអាចងាកមករកហេដ្ឋារចនាសម្ព័ន្ធទន់ និងធម្មជាតិជាជម្រើស ដែលហេដ្ឋារចនាសម្ព័ន្ធទន់សំដៅលើនយោបាយ ការធានារ៉ាប់រង ការកំណត់តំបន់ ការធ្វើផែនការប្រើប្រាស់ដីធ្លី និងការកំណត់ផលប៉ះពាល់ (ជាធាតុមួយនៃភាពងាយរងគ្រោះ)។ ហេដ្ឋារចនាសម្ព័ន្ធទន់ គឺជាជំហានដំបូងមុននឹងឈានទៅដល់ការវិនិយោគខ្ពាតធំ លើហេដ្ឋារចនាសម្ព័ន្ធរឹង។ ហេដ្ឋារចនាសម្ព័ន្ធធម្មជាតិ ជាភាពធន់ដែលកើតមានដោយសារការធ្វើអន្តរទំនាក់ទំនងរវាងស្ថានប្រព័ន្ធដ៏ធំនៅកម្ពុជា ជាមួយនឹងតំបន់ផ្សេងទៀត ដែលនេះ គឺជាអត្ថប្រយោជន៍មួយនៃហេដ្ឋារចនាសម្ព័ន្ធធម្មជាតិ។

លោក **គង់ គីមសេង** មកពី IUCN លើកឡើងថា អ្វីដែលគាត់បានឃើញតាមរយៈការធ្វើបទបង្ហាញឃើញថា គោលនយោបាយ ការធ្វើផែនការ និងហេដ្ឋារចនាសម្ព័ន្ធត្រូវតែមានភាពបត់បែនដើម្បីបន្សាំទៅនឹងការប្រែប្រួល

អាកាសធាតុ។ ផ្ទុយទៅវិញ លោកបែរជាយល់ថា ការធ្វើបែបនេះត្រូវចំណាយច្រើន តើគេមានវិធីណាមួយ ដើម្បីធ្វើឲ្យវាមានលក្ខណៈបត់បែន និងចំណាយទាប ហើយជាវិធានការមួយដែលមានចីរភាព?

លោកបណ្ឌិត **Blate** ពន្យល់ថា ការព្យាករណ៍អំពីផលប៉ះពាល់ នៃការប្រែប្រួលអាកាសធាតុទៅអនាគត គឺមានភាពមិនប្រាកដប្រជា ប៉ុន្តែភាពបត់បែន គឺជាអ្វីដែលយើងត្រូវគិតគូរ។ ជាឧទាហរណ៍ ការសាងសង់ទំនប់នៅកន្លែងមួយ ប៉ុន្មានឆ្នាំក្រោយមកដោយសារមានការផ្លាស់ប្តូរ ផ្នែកគោលនយោបាយ ឬបញ្ហាបរិស្ថានផ្សេងៗនោះទំនប់ត្រូវបានឃើញថាវាជាបញ្ហា។ ដូចនេះ ជម្រើសដែលយើងជ្រើសរើសនានាគួរតែគ្មានការស្តាយក្រោយ។ គ្រប់គម្រោងដែលមានប្រសិទ្ធភាព ចំណាយទាប និងរៀបចំដោយមានការចូលរួម ពីសហគមន៍ និងមិនប៉ះពាល់ដល់បរិស្ថាន គឺសុទ្ធតែគិតពីអភិក្រមនៃហេដ្ឋារចនាសម្ព័ន្ធធម្មជាតិ។

ឯកឧត្តម **គល់ ឥន្ទ្រា** បានផ្តល់ជាយោបល់ថា ភាពបត់បែន គឺមានន័យថា ការធ្វើផែនការ និងយុទ្ធសាស្ត្រនានាត្រូវតែរលូន និងអាចបត់បែនទៅតាមស្ថានភាពជាក់ស្តែង។

លោក **សុខ ពិសិដ្ឋ** មកពី MoWA និយាយថា យេនឌ័រ និងការប្រែប្រួលអាកាសធាតុ ជាកិច្ចការអន្តរវិស័យ ដូច្នេះ តើគេមានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ដើម្បីកំណត់ឲ្យបាននូវប្រជាជនដែលងាយរងគ្រោះ ឧទាហរណ៍ ស្ត្រី?

អ្នកស្រី **Annaka Peterson Carvalho** ឆ្លើយតបនឹងសំណួរថា គេមានក្របខណ្ឌផ្សេងៗសម្រាប់វិនិច្ឆ័យលើភាពងាយរងគ្រោះ និងហានិភ័យ។ អ្នកស្រីមិនបាននិយាយចំពោះតែបញ្ហាជាក់លាក់ណាមួយទេ ប៉ុន្តែគ្រាន់តែចង់ឲ្យបុគ្គលគ្រប់រូប បានយល់កាន់តែច្បាស់ពីគោលការណ៍បញ្ជ្រាបយេនឌ័រ ក្នុងការអនុវត្តការវាយតម្លៃភាពងាយរងគ្រោះ និងហានិភ័យនៅទីកន្លែងណា និងពេលណាដែលស្ត្រី និងបុរសមានភាពងាយរងគ្រោះប៉ុណ្ណោះ។

អ្នកស្រី **ឈឹម រមណី** មកពី CDRI សួរថា តើមានយុទ្ធសាស្ត្រទប់ស្កាត់អ្វីខ្លះដែលអាចជួយឲ្យស្ត្រីទទួលបាននូវស្បៀង ដើម្បីធានានូវសន្តិសុខស្បៀងនៅក្នុងគ្រួសារ នៅពេលដែលមានការប្រែប្រួលអាកាសធាតុកើតឡើង?

អ្នកស្រី **Annaka Peterson Carvalho** បញ្ជាក់ថា នៅកម្ពុជា ប្រជាជនបានជួបគ្រោះមហន្តរាយជាញឹកញាប់ ដូចជាគ្រោះរាំងស្ងួត និងទឹកជំនន់តិចតួចជាដើម។ ប្រជាជនប្រើប្រាស់នូវយុទ្ធសាស្ត្រផ្សេងៗក្នុងការឆ្លើយតបនឹងបញ្ហាទាំងនេះ ដូចជា ការប្រមូលអនុផលព្រៃឈើ ឬធនធានធម្មជាតិផ្សេងទៀត ដែលយកមកធ្វើជាអាហារបាន ឬបំលាស់ទីទៅរកការងារធ្វើ។ បញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ និងយុទ្ធសាស្ត្រទប់ស្កាត គឺនិយាយពីការកើនឡើងនូវការកៀបសង្កត់ ភាពញឹកញាប់នៃការកៀបសង្កត់ និងការប៉ះទង្គិច ហើយនឹងលទ្ធភាពទទួលបាននូវធនធានផ្សេងៗ ដែលស្ត្រីពឹងផ្អែក ដើម្បីគាំទ្រដល់គ្រួសារ នៅអំឡុងពេលដែលការកៀបសង្កត់កើតមាន។

លោកបណ្ឌិត **Blate** ក៏បានឆ្លើយតបទៅនឹងការប្រើប្រាស់ធនធានធម្មជាតិ របស់ស្ត្រីថាទាំងនេះហើយជាមូលហេតុពិតប្រាកដ ដែលតម្រូវឲ្យមាននូវដំណោះស្រាយរួមគ្នាដោយសារតែបញ្ហានៃការកៀបសង្កត់ គ្រោះមហន្តរាយ និងបញ្ហាផ្សេងៗទៀត ជម្រុញឲ្យគ្រួសារនានា នឹងងាយទៅរកប្រព័ន្ធធម្មជាតិ ដែលជាលទ្ធផលគឺធ្វើឲ្យប្រព័ន្ធធម្មជាតិ កាន់តែមានការរេចរឹលហើយទីបញ្ចប់ ពួកគេនឹងពុំមានប្រព័ន្ធទាំងនេះដើម្បីការពារពួកគេឡើយ។

លោកបណ្ឌិត **Kien Tran-Mai** មកពី MRC បានលើកជាយោបល់ខ្លះៗ ចំពោះបទបង្ហាញរបស់អ្នកស្រី **Annaka** ថា វិធីសាស្ត្រដ៏ល្អទាក់ទងនឹងការប្រើប្រាស់អភិក្រម ដែលមានស្រាប់ដូចជា NAPA ដើម្បីឆ្លើយតទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ ប៉ុន្តែហេតុអ្វីបានជាមិនគិតគូរពីវិធីជួយដល់ MoWA ក្នុងការបញ្ចូលបញ្ហាយេនឌ័រ ទៅក្នុងការប្រែប្រួលអាកាសធាតុ និង DRR ដែលនេះអាចជាក្របខណ្ឌមួយដ៏ប្រសើរសម្រាប់ប្រទេសទាំងមូល។ តើមានប្រតិកម្មបែបណាខ្លះពីអ្នកអនុវត្តគម្រោង NAPA លើបញ្ហានេះ?

អ្នកស្រី **Annaka Peterson Carvalho** តបថា វាពិតជាមានសារសំខាន់ណាស់ ដែល NCCC បានបោះជំហានមួយសំខាន់ទាក់ទងនឹងបញ្ហានេះ ដោយបានប្រជុំពិភាក្សា ជាមួយ MoWA កាលពីខែតុលា ឆ្នាំ២០១០ ហើយអ្នកស្រីគិតថា នេះគឺជាកិច្ចខិតខំប្រឹងប្រែងដ៏ខ្លាំងក្លា ដោយសហការជាមួយ MoWA ក្នុងការគាំទ្រដល់ការបញ្ចូលបញ្ហាយេនឌ័រទៅក្នុងយុទ្ធសាស្ត្រនៃការប្រែប្រួលអាកាសធាតុ យុទ្ធសាស្ត្រតាមវិស័យ និងការងារបច្ចុប្បន្នរបស់ MoWA ។ វាក៏ជាចំណុចចាប់ផ្តើមមួយសំខាន់ ក្នុងការរួមបន្សុំរវាងយេនឌ័រ និងការប្រែប្រួលអាកាសធាតុ។ ទាក់ទងនឹងប្រតិកម្ម របស់អ្នកអនុវត្តន៍គម្រោង NAPA គឺថាមិនទាន់មានប្រតិកម្ម ឬមតិយោបល់អ្វីទេ ព្រោះអ្វីដែលអ្នកស្រីលើកឡើងគ្រាន់តែជាឧទាហរណ៍ប៉ុណ្ណោះ។

ភគ្គពេញអង្គ៖ ការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ

សហប្រធាន៖

១. **ឯកឧត្តម ស្ថុន តារា** អនុរដ្ឋលេខាធិការ MEF និងជាសមាជិក NCCC

២. **លោកស្រី** Sophie Baranes នាយិការង UNDP ប្រចាំនៅកម្ពុជា

ពិធីប្រកាសគម្រោងដែលបានជ្រើសរើសនៅក្រោមការប្រកាសទទួលសំណើគម្រោងលើកទី១នៃ CCCATF

*ដោយ**លោកបណ្ឌិត ងិន ពន្លក** អគ្គនាយករង GDANCP និងជាប្រធានលេខាធិការដ្ឋាន CCCA TF នៃ MoE*

លោកបណ្ឌិត **ពន្លក** បានផ្តល់នូវសេចក្តីសង្ខេបពីសាវតារបស់ CCCA ដែល CCCA គឺជាកម្មវិធីមួយ ដែលចាប់ផ្តើមនៅ ខែកុម្ភៈ ឆ្នាំ ២០១០ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងមហន្តរាយពីហានិភ័យនៅកម្ពុជា។ គោលបំណងគឺពង្រឹងសមត្ថភាពរបស់ NCCC ដើម្បីបំពេញតាមអាណត្តិ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងធ្វើឲ្យក្រសួងពាក់ព័ន្ធ និង CSOs អនុវត្តនូវសកម្មភាព ជាអាទិភាព ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដែលផ្តោតជាសំខាន់លើ៖ ការកសាងសមត្ថភាព និងពង្រឹងស្ថាប័នដើម្បីត្រៀមខ្លួន និងកាត់បន្ថយហានិភ័យពីការប្រែប្រួលអាកាសធាតុ និងជួយសហគមន៍ដែលងាយរងគ្រោះដោយផ្ទាល់ តាមរយៈការពង្រឹងភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិផ្សេងៗទៀត។

ម្យ៉ាងវិញទៀត CCCATF គឺជាសម្បទានហិរញ្ញប្បទាន ដើម្បីគាំទ្រសកម្មភាពនៅក្រោមសកម្មភាព CCCA ដែលគាំទ្រថវិកាដោយ EU Sida Danida និង UNDP។ CCCA TF គ្រប់គ្រងដោយ MoE ក្នុងនាម NCCC និងគ្រប់គ្រងផ្នែករដ្ឋបាលដោយ UNDP ។ CCCA TF មានគោលបំណងក្នុងការគាំទ្រដល់ក្រសួងដែលពាក់ព័ន្ធសំខាន់ៗ/ភ្នាក់ងារ និង CSOs ដោយផ្តោតជាសំខាន់លើ ការកសាងសមត្ថភាព ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។ វាក៏បំពេញ

បន្ថែមលើកម្មវិធីស្របគ្នាមួយ គឺកម្មវិធី PPCR ដែលចាត់ចែងដោយWB/ADB ដែលផ្តល់មូលនិធិដោយផ្ទាល់ទៅវិស័យសំខាន់ៗ សម្រាប់អនុវត្តសកម្មភាពសម្រាប់ពង្រឹងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។

លោកបណ្ឌិត **ពន្លក** បានរាយការណ៍ថា ការប្រកាសទទួលសំណើគម្រោងលើកទី ១បានចាប់ផ្តើមក្នុងខែកុម្ភៈ ឆ្នាំ២០១១។ CCCATF ជម្រុញឲ្យមាន គម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យសំខាន់ៗ ដែលស្របនឹងអាទិភាពជាតិ ដែលមានស្រាប់ ដូចជាវិស័យកសិកម្ម ព្រៃឈើ ជលផល ធនធានទឹក ឧតុនិយម ហេដ្ឋារចនាសម្ព័ន្ធ និងសុខភាព។ ជាលទ្ធផលគម្រោងចំនួន ៨ ត្រូវបានអនុម័តក្នុងចំណោមឯកសារគម្រោងខ្លីចំនួន ៦០ ដែលបានដាក់ពាក្យ ដែលគម្រោងទាំងនោះគ្របដណ្តប់លើខេត្តដែលងាយរងគ្រោះភាគច្រើន និងគ្របដណ្តប់លើបញ្ហាតាមវិស័យ និងអន្តរវិស័យ។

ជាទីបញ្ចប់ លោកបណ្ឌិត បានសន្និដ្ឋានថា កម្ពុជាត្រូវការបង្កើនសមត្ថភាពស្រូបយកធនធានទាំងនេះ និង CCCATF មាននាទីជាជំហាននាំមុខ ឆ្ពោះទៅបង្កើតយន្តការផ្តល់មូលនិធិកាន់តែមានលក្ខណៈអចិន្ត្រៃ សម្រាប់កម្ពុជា ការឯកភាពគ្នារវាងDPs និងសម្បទានហិរញ្ញវត្ថុពហុម្ចាស់ជំនួយ ដើម្បីផ្តល់ជាធនធានសម្រាប់សកម្មភាពការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ អនាគតនៃ TF គួរតែបង្កើតឡើងដោយផ្អែកលើគោលការណ៍សំខាន់ៗដូចជា ភាពជាម្ចាស់របស់ជាតិ ភាពជាតំណាងនៃអ្នកពាក់ព័ន្ធ ការកសាងទំនុកចិត្ត តម្លាភាព ប្រកបដោយ វិជ្ជាជីវៈ គណនេយ្យភាព គុណ្យភាព ការប្រកួតប្រជែង ប្រសិទ្ធិភាព និងប្រសិទ្ធិផល។

សុន្ទរកថាចំណាប់អារម្មណ៍របស់បេក្ខជនទទួលជ័យលាភលើកទី១

លោកស្រីបណ្ឌិត ***អៅ សុជីវី*** *អគ្គនាយករងរដ្ឋបាលជលផល MAFF*

លោកស្រីបណ្ឌិត **សុជីវី** បានបកស្រាយថា វិស័យជលផលនៅប្រទេសកម្ពុជាដើរតួយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងសម្រាប់ជីវភាពរស់នៅរបស់ប្រជាជន។ លោកស្រីបណ្ឌិត ក៏បានបញ្ជាក់ផងដែរថា ការយល់ដឹងពីវិធានការទប់ស្កាត់នឹងការប្រែប្រួលអាកាសធាតុ ដែលមានផលប៉ះពាល់ទៅលើវិស័យជលផលនេះ ពិតជាមានសារសំខាន់ណាស់។ ដូច្នេះហើយទើបរដ្ឋបាលជលផល (FiA) បានធ្វើការខិតខំប្រឹងប្រែង រិះរកនូវវិធានការទប់ស្កាត់ និងស្វែងរកយុទ្ធសាស្ត្រធ្វើយ៉ាងណា ដើម្បីកាត់បន្ថយនិងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យជលផលនេះដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិរបស់យើងឲ្យមានចីរភាព។ អាស្រ័យហេតុដូច្នេះហើយ ទើប FiA នៅក្នុងកំឡុងខែកុម្ភៈ បានចាប់ផ្តើមយកចិត្តទុកដាក់លើការសហការ និងរៀបចំគម្រោងស្នើសុំមួយចំនួនដាក់ទៅដៃគូពាក់ព័ន្ធ ជាពិសេស CCCA TFសំណាងល្អសំណើគម្រោងរបស់យើងក៏បានជាប់ក្នុងចំណោមអ្នកដែលទទួលគម្រោងបានចំនួន ៨។ លើសពីនេះទៀត យើងបានព្យាយាមធ្វើការសិក្សាស្រាវជ្រាវ និងសហការជាមួយដៃគូផ្សេងៗ ទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ ដើម្បីធ្វើការជម្រុញទប់ស្កាត់ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យជលផលនេះផងដែរ។ នៅក្នុងនោះគម្រោងរបស់ FiA ដែលយើងបានដាក់ស្នើសុំទៅក្នុង ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ មានគោលបំណងកសាងសមត្ថភាព ដើម្បីធ្វើសមាហរណកម្មសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យជលផល

នៅកម្ពុជា ដែលមានគោលបំណងចម្បង៣ ។ គោលបំណងទីមួយ គឺដើម្បីលើកកម្ពស់ការយល់ដឹងអំពីកត្តានាំឲ្យមានការកកើតនៃការប្រែប្រួលអាកាសធាតុ និងផលប៉ះពាល់របស់វាមកលើស្ថានប្រព័ន្ធវារីជាតិ និងសហគមន៍នេសាទ ដែលពឹងផ្អែកលើធនធានធម្មជាតិទាំងនេះដើម្បីឆ្លើយតបនឹងតម្រូវការនៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុនេះនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ថ្នាក់សហគមន៍ និងអ្នកពាក់ព័ន្ធនានា។ គោលបំណងទី២ គឺដើម្បី កសាងសមត្ថភាពរបស់មន្ត្រី FiA គ្រប់ជាន់ថ្នាក់ ពីថ្នាក់ជាតិ រហូតដល់ថ្នាក់ក្រោមជាតិ និងអ្នកគ្រប់គ្រងធនធានធម្មជាតិ នៅតាមសហគមន៍ នេសាទ និង DPs នានា ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការធ្វើសមាហរណកម្មគោលនយោបាយផែនការយុទ្ធសាស្ត្រ និងសេចក្តីណែនាំផ្សេងៗ។ ត្រង់ចំណុចនេះ គឺយើងនឹងធ្វើផែនការយុទ្ធសាស្ត្រមួយ សម្រាប់វិស័យជលផល ដើម្បីធ្វើការបន្សាំ និងកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដែលជះឥទ្ធិពលទៅលើវិស័យជលផល។ គោលបំណង ទី៣ គឺដើម្បីបង្ហាញនូវវិធានការសមស្រប និងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យជលផល។

លោកស្រីបណ្ឌិត បានបន្ថែមទៀតថា គម្រោងនេះនឹងត្រូវបានអនុវត្ត ដោយមានការសហការរវាង FiA និងWorld Fish Centre ។ មុននឹងបញ្ចប់ លោកស្រីបណ្ឌិតបានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ CCCATF និងម្ចាស់ជំនួយនានា ដែលជំនួយនេះ គឺជាការឆ្លើយតបទាន់ពេលវេលាសម្រាប់វិស័យជលផល ដើម្បីធ្វើការទប់ទល់នឹងការប្រែប្រួលអាកាសធាតុ។

សុន្ទរកថាចំណាប់អារម្មណ៍របស់បេក្ខជនទទួលជ័យលាភលើកទី១

ដោយលោក ***ជា សារិទ្ធ*** *ប្រធានអង្គការ WOMEN*

លោក **ជា សារិទ្ធ** បានទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុ ពិតជាមានផលប៉ះពាល់យ៉ាងខ្លាំង លើការរស់នៅរបស់ប្រជាជនគ្រប់រូប ជាពិសេសនៅតាមជនបទ។ យើងបានយល់ដឹងច្រើនអំពី ការគំរាមកំហែង ដែលបណ្តាលមកពី ការកើនឡើងនូវសីតុណ្ហភាព ការកើនឡើងនូវកម្ពស់ទឹកសមុទ្រ និងការប្រែប្រួលរបបទឹកភ្លៀងជាដើម។ រដ្ឋាភិបាល CSOs ព្រមទាំងសហគមន៍ខ្លួនឯងបានរៀបចំ ផែនការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅតែជារឿងថ្មីថ្មោង ដែលយើងកំពុងតែខិតខំព្យាយាមរួមគ្នាដោះស្រាយ។ សមាគមនារីអភិវឌ្ឍន៍សេដ្ឋកិច្ច និងអនាម័យ (WOMEN) ជាអង្គការក្នុងស្រុកមួយ បង្កើតឡើងតាំងពីឆ្នាំ ១៩៩៣ ដែលភាគច្រើនធ្វើការងារពាក់ព័ន្ធនឹង បញ្ហាជម្ងឺអេដស៍។ លោកសង្ឃឹមថា គម្រោងប្រែប្រួលអាកាសធាតុថ្មីដែល WOMEN ទើបតែទទួលបាននឹងអនុវត្តបានប្រកបដោយជោគជ័យ ជាមួយនឹងលទ្ធផល ដែលគួរឲ្យពេញចិត្តដូចបណ្តាគម្រោងកន្លងមក។ គម្រោងថ្មី ដែលវាយតម្លៃ និងសម្រេចផ្តល់នូវហិរញ្ញប្បទាននោះ គឺមានចំណងជើងថា "រួមគ្នាដោះស្រាយការប្រែប្រួលអាកាសធាតុនៅព្រៃវែង" ដែលនឹងកសាងនូវវិធីសាស្ត្រការប្រែប្រួលអាកាសធាតុ នៅខេត្តព្រៃវែងជាលក្ខណៈពហុវិស័យ ដែលមានការចូលរួមរវាងអាជ្ញាធរខេត្ត និងសហគមន៍ក្នុងការពង្រឹងសមត្ថភាព ការសម្របសម្រួលឲ្យបានប្រសើរឡើងនូវការទំនាក់ទំនងសន្ទនា និងធ្វើឲ្យប្រសើរឡើងនូវការយល់ដឹងរបស់ភាគីពាក់ព័ន្ធទាំងអស់ចូលរួមក្នុងការគ្រប់គ្រងធនធានធម្មជាតិ និងដំណើរការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ គម្រោងនឹងធ្វើការផងដៃរជាមួយ មន្ទីរដែលពាក់ព័ន្ធដូចជា កសិកម្ម ជលផល បរិស្ថាន ដើម្បីជួយដល់ប្រជាជនសហគមន៍ក្នុងការលើកកម្ពស់ការយល់ដឹងអំពី បច្ចេកទេស និងបន្សាំទៅនឹង

ការប្រែប្រួលទាំងនេះ។ លោកបានបញ្ជាក់ថា WOMEN នឹងធ្វើការផងដែរ ជាមួយក្រុមមនុស្ស ដែលងាយរងគ្រោះបំផុត ដូចជា ប្រជាជនក្នុងតំបន់គោលដៅ ដែលក្រីក្រ សហគមន៍នេសាទ ប្រជាជនក្រីក្រ ស្ត្រីភេទ យុវជន និងសហគមន៍ទូទៅ ដើម្បីលើកកម្ពស់ការភ្ញាក់រលឹកចូលរួមការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

សុន្ទរកថាចំណាប់អារម្មណ៍

ដោយលោកស្រី Kristina Kuhnel, Minister Counsellor និងជានាយិកាអង្គការ SIDA

លោកស្រី **Kuhnel** បានលើកឡើងថា យើងបានដឹងហើយថា ផលប៉ះពាល់ជាអវិជ្ជមាននៃការប្រែប្រួលអាកាសធាតុបាន និងកំពុងកើនឡើង ដូចដែលបានបញ្ជាក់នៅថ្នាក់សកល ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។ ប៉ុន្តែទន្ទឹមនឹងនេះការប្រកួតប្រជែងពីផលប្រយោជន៍ដែលបណ្តាលមកពី ឥទ្ធិពលអវិជ្ជមានពីវិបត្តិសេដ្ឋកិច្ចសកលលោកថ្មីៗនេះ អាចជាការប្រឈមនឹងវឌ្ឍនភាពក្នុងវិស័យនេះ និងការប្តេជ្ញាចិត្តជាអន្តរជាតិ ដើម្បីប្រយុទ្ធប្រឆាំង និងការកម្រិតផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

យ៉ាងណាក៏ដោយ ស្ថានភាពនៅកម្ពុជា និង DCs ផ្សេងទៀត គឺថាស្ត្រី និងបុរសត្រូវតែឆ្លើយតបនឹងបន្ទុំ ទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនេះ និងត្រូវតែចាត់វិធានការដោះស្រាយឥឡូវនេះ ទោះបីជាពុំមានភាពប្រាកដប្រជានៅថ្នាក់សកលក៏ដោយ។ គ្រោះទឹកជំនន់ នៅកម្ពុជានាពេលថ្មីៗនេះ អាចជាសញ្ញាណនៃបញ្ហាអ្វីមួយ ដែលអាចក្លាយជាបទដ្ឋានពិភពលោកមួយ នៃការប្រែប្រួលអាកាសធាតុ។ យើងសួរទៅដៃគូសហការណ៍ថា "តើពួកគេរីករាយនឹងចូលរួមនៅក្នុងគំនិតផ្តួចផ្តើមដូចជា CCCA ដែរទេ?" ការផ្តួចផ្តើមនេះអាចបង្ហាញពីសកម្មភាពជាក់លាក់នានា ដូចដែលយើងបានឃើញថ្ងៃនេះ និងការកសាងសមត្ថភាពស្ថាប័ន ការបង្កើតប្រព័ន្ធ និងយន្តការសម្របសម្រួល ដែលមាន RGC ជាអ្នកដឹកនាំក្នុងការផ្តល់នូវការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុកម្រិតជាតិ។

លោកស្រី ក៏បានបង្ហាញពីវឌ្ឍនភាពនៅក្នុងឆ្នាំនេះ ដែល CCCA កំពុងជម្រុញលើកទឹកចិត្ត ដោយបានបោះជំហានទៅមុខយ៉ាងសំខាន់ក្នុងការអនុម័តផ្តល់ហិរញ្ញប្បទាន ដល់គម្រោងចំនួន ៨ ដូចដែលបានឃើញក្នុងថ្ងៃនេះស្រាប់។ យើងកំពុងចាប់ផ្តើមដំណើរការនេះ ហើយឥឡូវនេះយើងអាចវិនិយោគក្នុងប្រព័ន្ធ ដែលជាកម្មសិទ្ធិរបស់ជាតិ ដែលហៅថា មូលនិធិត្រាស់ ។ មូលនិធិនេះ អាចធានានូវការកើនឡើងនូវភាពសុខុដុមរម្យនា និងការសម្របសម្រួល ក្នុងចំណោមក្រសួងពាក់ព័ន្ធ និង CSOs ក៏ដូច ជាគាំទ្រ ដល់ការបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធី និងផែនការតាមវិស័យ និងអន្តរជាតិ។

សមាសធាតុជំនួយនៃកម្មវិធីមានមុខងារជាកាតាលីករមួយយ៉ាងសំខាន់។ គម្រោងជាច្រើន បានចូលរួមដោះស្រាយជាមួយបញ្ហាធ្ងន់ធ្ងរនានា ដូចដែលបានឃើញនៅថ្ងៃនេះ ដូចជាការកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុសម្រាប់កសិដ្ឋានខ្នាតតូច ការបញ្ចូលសកម្មភាពប្រែប្រួលអាកាសធាតុទៅតាមវិស័យ របស់រដ្ឋាភិបាល ការបង្កើនការយល់ដឹងពីការប្រែប្រួលអាកាសធាតុ និងវិធីដោះស្រាយជាមួយនឹងគ្រោះថ្នាក់ ដែលបណ្តាលមកពីការប្រែប្រួលអា

កាសធាតុ។ យើងជាដៃគូសហការ រំពឹងនឹងបន្ត កិច្ចសហការជាមួយ RGC UNDP CSOs និង វិស័យឯកជន ដើម្បីធានាថាកម្មវិធីនឹងទទួលបានជោគជ័យ។

ជាចុងក្រោយ ក្នុងនាមតំណាងស្ថានទូតប្រទេសស៊ុយអែត គណៈប្រតិភូ EU និង Danida អ្នកស្រីសូមសំដែងនូវការអបអរសាទរដល់គម្រោងទាំង ៨ ដែលអាចទទួលបានថវិកានៅថ្ងៃនេះ។ យើងនឹងចាំមើលនូវការអនុវត្តគម្រោងទាំងនោះ ហើយអ្វីដែលសំខាន់នោះគឺលទ្ធផលនានាពីគម្រោង ជាបទពិសោធន៍បានមកពីកម្រិតមូលដ្ឋាន ដែលនឹងអាចបង្កើននូវកម្រិតជីវភាព និងជីវិតរបស់ប្រជាជនក្រីក្រ ក្រុមស្ត្រី បុរស និងកុមារ ដែលងាយរងគ្រោះនៅកម្ពុជា។ សូមថ្លែងអំណរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។

អ្នកទទួលជ័យលាភីពីការប្រកាសទទួលសំណើលើកទី១ (CCCA, 2011)

សេចក្តីណែនាំអំពី CCCATF

ដោយអ្នកស្រី Reiko Kurihara ជាអ្នករដ្ឋបាលមូលនិធិ CCCA នៃ MoE

អ្នកស្រី **Reiko Kurihana** បញ្ជាក់ថា CCCATF ជាយន្តការសាកល្បង ដើម្បីការត្រៀមលក្ខណៈឆ្ពោះទៅរកសង្គមមួយ ដែលធននឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ហើយថ្ងៃនេះ អ្នកស្រីបង្ហាញពីមូលនិធិនេះ បន្ថែមទៀតទៅកាន់បេក្ខជនមានបំណងចង់ស្នើសុំ។

មូលនិធិ CCCATF មានគោលបំណងសំខាន់ លើការកសាងការត្រៀមលក្ខណៈ តាមរយៈការចែករំលែកចំណេះដឹង និងការបញ្ជ្រាបបញ្ហាប្រែប្រួលអាកាសធាតុ ទៅក្នុងវិស័យនានា ដើម្បីឲ្យមានយល់ដឹងកាន់តែច្បាស់ និងទូលំទូលាយពីបញ្ហានេះ។ CCCA ជួយដល់ការសម្របសម្រួលភាពជាដៃគូក្នុងចំណោមរដ្ឋាភិបាល និង CSOs នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ និងការត្រៀមលក្ខណៈរបស់កម្ពុជា ក្នុងការទទួលបានហិរញ្ញប្បទាន និងការអនុវត្តកិច្ចការប្រែប្រួលអាកាសធាតុ។

ជាគោលការណ៍ CCCATF តែងគាំទ្រដល់ការត្រៀមលក្ខណៈទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ស្របតាមអាទិភាពរបស់ជាតិ ស្វែងយល់ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ក្រោមរូបភាពជាផ្នែកមួយនៃការអភិវឌ្ឍ និងការកសាងសមត្ថភាព ព្រមជាមួយនឹងភាពជាម្ចាស់របស់ជាតិ។

CCCATF នឹងផ្តល់ហិរញ្ញប្បទានដល់គម្រោងនានា ដែលមានគោលដៅអភិវឌ្ឍសមត្ថភាព និងពង្រឹងស្ថាប័ន ដែលគាំទ្រដល់កម្មវិធី NAPA NSDP បច្ចុប្បន្នកម្ម និងCCCSP និងគម្រោងនានា ដែលជួយសម្របសម្រួល និងធានាឲ្យមានការចូលរួមពិចារណាពីការប្រែប្រួលអាកាសធាតុ ទៅក្នុងគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ និងកម្មវិធីជាតិ ។ មូលនិធិនឹងផ្តល់ហិរញ្ញប្បទានផងដែរ ចំពោះគម្រោងដែលប្រឹងប្រែងធ្វើការរួមបញ្ចូលការពិចារណា ពីការប្រែប្រួលអាកាសធាតុ ទៅក្នុងសកម្មភាពបញ្ជ្រាបដទៃទៀត សម្រាប់កិច្ចការអន្តរវិស័យផ្សេងទៀត និងគម្រោងនានាដែលនឹងលើកកម្ពស់ការយល់ដឹង និងការត្រៀមលក្ខណៈក្នុងរដ្ឋាភិបាល និងក្នុងសង្គមជារួម និងគម្រោងដែលរួមចំណែកក្នុងការបង្កើត និងអនុវត្តវេទិកា

ចំណេះដឹង និងការរៀនសូត្រ ស្តីពីការប្រែប្រួលអាកាសធាតុ។

អ្នកស្រី ក៏បានរៀបរាប់យ៉ាងច្បាស់ពីដំណើរការនៃការដាក់សំណើគម្រោង ដោយថាបេក្ខជន ដែលមានចំណាប់អារម្មណ៍ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ដែលអាចមកពីស្ថាប័នរដ្ឋាភិបាលតែឯង ឬក្រោមរូបភាពជាដៃគូជាមួយ CSOs ។ ផ្ទុយមកវិញ CSOs ឬក៏អង្គការអន្តរជាតិ ត្រូវតែធ្វើឡើងក្រោមរូបភាពជាដៃគូជាមួយស្ថាប័នរដ្ឋាភិបាល។ ទំហំនៃការផ្តល់មូលនិធិ សម្រាប់គម្រោងនីមួយៗ សម្រាប់បេក្ខជនមកពីស្ថាប័នរដ្ឋាភិបាល អាចទទួលបានរហូតដល់ ៣០០.០០០ដុល្លាអាមេរិក និង១៥០.០០០ដុល្លាអាមេរិក សម្រាប់អ្នកដាក់ពាក្យស្នើសុំមកពី CSOs ហើយរយៈពេលគម្រោងនឹងត្រូវបានកំណត់ នៅពេលប្រកាសទទួលសំណើគម្រោងម្តងៗ។

អ្នកស្រី **Reiko kurihana** ស្នើឡើងថាគម្រោងនីមួយៗគួរតែស្វែងរកហេតុផលពាក់ព័ន្ធនឹងកិច្ចការងាររបស់ខ្លួន ជាជាងធ្វើអ្វីដែលថ្មី ឬគម្រោងដែលជាជំនាញ និងចាត់ទុកការប្រែប្រួលអាកាសធាតុជាហានិភ័យមួយក្នុងចំណោមហានិភ័យផ្សេងទៀត ដែលគម្រោមកំហែងដល់អាយុជីវិតរបស់យើង និងមិនត្រូវចាត់ទុកការប្រែប្រួលអាកាសធាតុនេះនៅដាច់ពីបញ្ហាដទៃទៀតឡើយ។

សំណួរ និងចម្លើយ

បណ្ឌិត កៅ សុជីវី សួរសំណួរនៅក្នុងវគ្គពេញអង្គ (CCCA, ២០១១)

លោកស្រីបណ្ឌិត **កៅ សុជីវី** មកពី FiA មានចម្ងល់ថា តើអ្នកដែលទទួលបានជោគជ័យនៅក្នុងវគ្គទី ១ នៃ CCCATF នឹងអាចដាក់ពាក្យសំណើគម្រោងនៅវគ្គក្រោយទៀតបានដែរឬទេ?

លោកបណ្ឌិត **ង៉ិន ពន្លក** បានប្រកាសថា ជាគោលការណ៍ គ្មានការហាមឃាត់ក្នុងការដាក់ពាក្យសំណើគម្រោងនៅវគ្គបន្ទាប់នោះទេ។ ជាការអនុវត្ត ការជ្រើសរើសបេក្ខជន គឺអាស្រ័យជាដំបូង លើគុណភាពនៃសំណើគម្រោង និងភស្តុតាង ដើម្បីបញ្ជាក់ថាសមត្ថភាពរបស់បេក្ខជនក្នុងការគ្រប់គ្រងលើបញ្ហានៃការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដែលស្ថិតក្នុងវិស័យអាទិភាពរបស់ RGC។

លោក **សុខ ពិសិដ្ឋ** មកពី MoWA និង **លោក** Paulo Lopes មកពី NEXUS បានលើក

ជាសំណួរស្រដៀងទាក់ទងនឹងលក្ខណៈវិនិច្ឆ័យ ដើម្បីវាយតម្លៃគម្រោងនៅក្រោម CCCATF?

អ្នកស្រី **Reiko Kurihara** បញ្ជាក់ថា គោលការណ៍ណែនាំពន្យល់យ៉ាងលំអិតពីវិស័យនានាដែល CCCATF កំពុងស្វែងរក ឬពិនិត្យដូចជាភាពជាម្ចាស់របស់ជាតិ ការកសាងសមត្ថភាព និងចីរភាពនៃសកម្មភាពគម្រោងនោះ។ ជាទូទៅមានលក្ខណៈវិនិច្ឆ័យចំនួន ៦ ឬ ៧ ត្រូវបានប្រើនៅក្នុងដំណើរការវាយតម្លៃ។ បេក្ខជនដែលបានបដិសេធន៍ នឹងទទួលបានលិខិតមួយ ដែលពន្យល់ពីភាពខ្សោយ និងខ្លាំងនៃសំណើគម្រោងនីមួយៗ។ ចំណុចគោលពីរដែល CCCA ត្រូវការ គឺ ភាពជាដៃគូមានន័យថាបេក្ខជនត្រូវតែមានដៃគូប្រកបដោយគុណភាពនិងចីរភាពនៃគម្រោង។

ថ្ងៃទី៣ៈ ថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១

សុន្ទរកថាស្វាគមន៍

*ដោយលោក **Rafael Dochao Moreno** ភារៈធារីនៃប្រតិភូសហភាព អឺរ៉ុបប្រចាំនៅកម្ពុជា*

លោក **Rafael Dochao Moreno** បានកត់សម្គាល់ថា SNFCC នេះជាកាលានុវត្តភាពដ៏វិសេសវិសាលមួយសម្រាប់អ្នកជំនាញការ និងអ្នកតាក់តែងគោលនយោបាយ ដើម្បីពិភាក្សា និងចែករំលែកព័ត៌មានអំពីការបន្សាំនិងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ លោកក៏បានលើកឡើងពីតួនាទីដ៏សំខាន់របស់ EU ថាជាកម្លាំងចលករដ៏សំខាន់មួយក្នុងកិច្ចផ្លួយផ្តើមការប្តេជ្ញាមួយ ក្នុងកិច្ចចរចារបស់ UNFCCC ក្នុងឆ្នាំ ១៩៩៩ និងពិធីសារក្យូតូនៅឆ្នាំ១៩៩៧។ លើសពីនេះ លោកបានមានប្រសាសន៍ថា EU ជាអ្នកនាំមុខគេក្នុងពិភពលោកលើសកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុជាពិសេសក្នុងការកាត់បន្ថយការបញ្ចេញ GHGs ។ ការប្តេជ្ញាចិត្តកាត់បន្ថយការបញ្ចេញឧស្ម័នកំពុងកើនឡើងជាបន្តបន្ទាប់ និងត្រូវបានជឿជាក់ថាការកាត់បន្ថយនេះនឹងកើនឡើងពី ៨០% ទៅ ៩៥% មុនឆ្នាំ ២០៥០។ លោកបានបញ្ជាក់ថាចំណាប់អារម្មណ៍ចំបងរបស់ EU គឺធ្វើជាអ្នកស្ម័គ្រចិត្ត និងធ្វើសកម្មភាពយ៉ាងសកម្ម ដើម្បីទប់ទល់ការប្រែប្រួលអាកាសធាតុ និងគាំទ្រដល់ការអភិវឌ្ឍបៃតង ដើម្បីបញ្ចៀសគ្រោះថ្នាក់ ដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ ហើយផ្តល់ដល់ EU នូវយុទ្ធសាស្ត្រសន្សំសំចៃការប្រើប្រាស់ថាមពល សន្តិសុខថាមពល ការងារថ្មីៗភាពប្រកួតប្រជែងជាអន្តរជាតិ គុណភាពខ្យល់ និងសុខភាពដែលល្អជាងមុន។

លោក ក៏បានសង្កត់ធ្ងន់ថា កិច្ចព្រមព្រៀងកាន់គុន ជាជោគជ័យមួយនៃការប្រយុទ្ធជាសកល នឹងការប្រែប្រួលអាកាសធាតុ ដែលកំណត់គោលដៅសហគមន៍អន្តរជាតិ រក្សាកំណើនសីតុណ្ហភាពក្រោម២°C ធៀបនឹងកម្រិតមុនសម័យឧស្សាហកម្ម។

បន្ថែមពីនេះទៀត ក្នុងនាម EU លោកជឿថា កិច្ចប្រជុំដែលកៀកនឹងមកដល់នៅទីក្រុងឌួបានចាប់ពីថ្ងៃ២៨ ខែវិច្ឆិកា ដល់ថ្ងៃ៩ ខែធ្នូ ឆ្នាំ ២០១១ គឺជាកាលានុវត្តភាពសំខាន់មួយដើម្បីសម្រេចបាននូវវឌ្ឍនភាពការងារ ក្នុងការដាក់ចេញវិធានការពហុភាគី ទប់ទល់ការប្រែប្រួលអាកាសធាតុ ដែលអាចនាំឲ្យឈានទៅមុខមួយជំហានទៀតតាមរយៈការអនុវត្តតាមការសម្រេចចិត្តក្នុងទីក្រុងកាន់គុន និងការឆ្លើយតបនឹងបញ្ហានានាពុំទាន់បានដោះស្រាយនៅកាន់គុន។

របបបម្រែបម្រួលអាកាសធាតុអន្តរជាតិនាពេលអនាគតក៏សំខាន់ផងដែរសម្រាប់កម្ពុជា ចំពោះហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ។ វានឹងកំណត់ការអនុវត្ត មូលនិធិអាកាសធាតុបៃតងថ្មី និងការគាំទ្រ ដែលមូលនិធិអាកាសធាតុបៃតងនេះ នឹងផ្តល់ដល់កម្ពុជា ក្នុងមូលបទសំខាន់ៗ នៃសកម្មភាពអាកាសធាតុ។ ជា

ឧទាហរណ៍ កម្ពុជាបាននឹងកំពុងទទួលបាន GCF ពីក្រុម EU ដើម្បីអនុវត្តគំនិតផ្តួចផ្តើមធំៗ ជាងគេចំនួន២ ស្តីពីការប្រែប្រួលអាកាសធាតុ នៅក្នុងកម្ពុជា គឺ CCCA និង PPCR ។

លោកក៏បានលើកឡើងថា "កិច្ចពិគ្រោះយោបល់ជាយុទ្ធសាស្ត្រស្តីពី DRR និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ" ជាកាលានុវត្តភាពសំខាន់ សម្រាប់កម្ពុជាក្នុងការកសាងស្ពានភ្ជាប់រវាងកិច្ចខិតខំប្រឹងប្រែង DRR ជាមួយកិច្ចខិតខំប្រឹងប្រែងលើកកម្ពស់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការស្វែងយល់ឲ្យបានប្រសើរ អំពីវិសាលភាពនៃការគ្រប់គ្រងគ្រោះ មហន្តរាយនាពេលបច្ចុប្បន្ននេះ ដើម្បីឆ្លុះបញ្ចាំងពីតម្រូវការបន្សាំនាពេលអនាគត។ ជាចុងបញ្ចប់ លោកបានស្នើឡើងថា ទំនួលខុសត្រូវជាសមូហភាពត្រូវធ្វើឡើងសម្រាប់ទាំងអស់គ្នា សកម្មភាពកាត់បន្ថយត្រូវធ្វើឡើងជាសមូហភាព និងសកម្មភាពបន្សាំត្រូវតែចាប់ផ្តើមពីឥឡូវនេះតទៅ។

សុន្ទរកថាគមន៍

*ដោយឯកឧត្តម **រស់ សីលវ៉ា** អគ្គលេខាធិការរង នៃMEF*

ឯកឧត្តម **រស់ សីលវ៉ា** បានថ្លែងសេចក្តីកោតសរសើរចំពោះ MoE ដែលបានរៀបចំ SNFCC និងបានថ្លែងអំណរអរគុណដល់UNDP EU និង DPs ផ្សេងទៀតចំពោះការឧបត្ថម្ភគាំទ្រ រាល់កម្មវិធីស្តីពី ការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

ឯកឧត្តមបានសង្កត់ធ្ងន់ថា វេទិកានេះមានសារសំខាន់ណាស់ សម្រាប់ផ្តល់ឱកាសដល់អ្នកសិក្សាស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យនេះ បានធ្វើការសិក្សាស្វែងយល់បន្ថែមពី ការប្រែប្រួលអាកាសធាតុ។

ឯកឧត្តមក៏បានមានប្រសាសន៍ថា វេទិកានេះត្រូវបានរៀបចំឡើង ចំពេលប្រទេសជាច្រើនលើពិភពលោក រួមទាំងកម្ពុជា កំពុងជួបប្រទះគ្រោះមហន្តរាយធម្មជាតិ ដែលជាផលប៉ះពាល់បង្កពីការប្រែប្រួលអាកាសធាតុ ដែលធ្វើឲ្យខាតបង់ដល់វិស័យសេដ្ឋកិច្ច-សង្គម ការបាត់បង់អាយុជីវិតមនុស្ស និងសត្វ។ ដោយទទួលស្គាល់បញ្ហាប្រែប្រួលអាកាសធាតុ RGC មានឆន្ទៈនយោបាយ និងការប្តេជ្ញាចិត្តយ៉ាងមុតមាំ ដោយបានផ្តល់សច្ចាប័នលើ UNFCCC ឆ្នាំ១៩៩៥ ចូលជាសមាជិកពិធីសារក្យូតូ នៅឆ្នាំ២០០២ ព្រមទាំងចូលជាសមាជិកពិធីសារផ្សេងៗទៀត ក្នុងគោលបំណងបង្កើនកិច្ចសហប្រតិបត្តិការជា មួយប្រទេសនានាក្នុងតំបន់ និងអន្តរជាតិ ដើម្បីកៀរគរប្រភពធនធាន និងបច្ចេកទេសសម្រាប់សកម្មភាពទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ក្រៅពីនេះ RGC បាននិងកំពុងខិតខំប្រឹងប្រែងរៀបចំគោលនយោបាយនិងផែនការយុទ្ធសាស្ត្រដោយផ្តោតលើ ការបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុក្នុងវិស័យពាក់ព័ន្ធ ព្រមទាំងអនុវត្តគម្រោងអាទិភាពសំខាន់ៗ ពិសេសការលើកកម្ពស់ការគ្រប់គ្រងទឹក និងកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅជនបទគម្រោងការប្រែប្រួលអាកាសធាតុ និងសុខភាព ព្រមទាំងយន្តការកាត់បន្ថយការបញ្ចេញ GHGs និងយន្តការទីផ្សារថ្មីៗ ក៏ដូចជាការពង្រឹងការបន្សាំតាមសហគមន៍ តាមរយៈសហគមន៍ កសិកម្មដែលមានស្រាប់។ ទោះយ៉ាងនេះក្តី រាល់កម្មវិធីនិងការងារទាំងអស់ ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុមានទំហំធំធេង ដែលទាមទារការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសក្នុងផ្នែកថវិកា និងបច្ចេកទេស។

ជាទីបញ្ចប់ ឯកឧត្តម **សីលវ៉ា** មានការជឿជាក់ថា វេទិកានេះនឹងផ្តល់ឲ្យរាជរដ្ឋាភិបាលនូវបទពិសោធន៍ និងអនុសាសន៍ថ្មីៗនិងជាក់

ស្តែងទាក់ទងនឹងការប្រែប្រួលអាកាសធាតុដើម្បីធានាបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។

វគ្គពេញអង្គ៖ ក្របខ័ណ្ឌគោលនយោបាយប្រែប្រួលអាកាសធាតុ៖ ជំណើរឆ្ពោះទៅកាន់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅ កម្ពុជា

សហប្រធាន៖

១. លោក **Douglas Broderick** តំណាង UN ប្រចាំនៅកម្ពុជា
២. ឯកឧត្តម **នុត ច័ន្ទសុខា** អនុរដ្ឋលេខាធិការនៃ MoP

គោលនយោបាយនិងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ៖ បទពិសោធន៍អន្តរជាត និងបទពិសោធន៍ក្នុងតំបន់

*ដោយលោក **Valdemar Holmgren** ប្រធានទីប្រឹក្សាបច្ចេកទេស CCCA នៃMoE*

បទបង្ហាញនេះ បានបង្ហាញនូវទិដ្ឋភាពទូទៅនៃបទពិសោធន៍ថ្នាក់តំបន់ និងអន្តរជាតិក្នុងការរៀបចំ និងអនុវត្តន៍ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយប្រែប្រួលអាកាសធាតុ។

លោក **Holmgren** បាននាំយកមកនូវបទពិសោធន៍ពីប្រទេសផ្សេងៗ ក្នុងការរៀបចំយុទ្ធសាស្ត្រ និងផែនការសកម្មភាពប្រែប្រួលអាកាសធាតុ ដែលអាចគាំទ្រដល់ការកសាងនយោបាយប្រែប្រួលអាកាសធាតុ តាមរយៈការដកស្រង់ពីមេរៀនដែលទទួលបាន ទម្រង់រចនាសម្ព័ន្ធយុទ្ធសាស្ត្រ និងផែនការសកម្មភាពនានាតាមរយៈការពិនិត្យលើ គោលនយោបាយនៃការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនានានៃបណ្តាប្រទេស នៅអាស៊ីត្រូវបានបកស្រាយរួមមាន បង់ក្លាដេស ឥណ្ឌា ហ្វីលីពីន វៀតណាម និងថៃ។ ការពិនិត្យមើលស្ថានភាពនៃ CCSAP ក្នុងប្រទេសនីមួយៗ ចាប់ផ្តើមពីឈ្មោះ និងរយៈពេលរបស់ CCSAP ក៏ដូចជាស្ថាប័នដែលទទួលខុសត្រូវក្នុងការអនុវត្ត។

ជាដំបូង លោកបានចាប់ផ្តើមលើកឡើងពីប្រទេសបង់ក្លាដែស។ បង់ក្លាដែសបានរៀបចំនូវ CCSAP បានយ៉ាងរហ័ស ដោយសារប្រទេសប្រឈមនឹងការលំបាកច្រើន។ ប្រទេសនេះ ជាប្រទេសនៅតំបន់ទំនាប មានប្រជាជនច្រើន និងមានបញ្ហាច្រើនទាក់ទងនឹងធនធានទឹក និងមានការកើនឡើងនៃកម្ពស់ទឹកសមុទ្រ។ ជាការគួរឲ្យចាប់អារម្មណ៍CCSAP របស់ប្រទេសនេះ ត្រូវបានប្រើប្រាស់ដោយប្រទេសជាច្រើនដោយយោងទៅលើរចនាសម្ព័ន្ធ និងបរិបទនៃប្រទេសនីមួយៗ។ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនេះ មានសុពលភាពពីឆ្នាំ ២០០៨ ដល់ឆ្នាំ២០១៨ ដែលសម្របសម្រួល ដោយក្រសួងបរិស្ថាន និងព្រៃឈើនៃប្រទេសបង់ក្លាដែស ដែលស្ថិតនៅក្រោមគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលស្រដៀងនឹងកម្ពុជាដែរ។ CCSAP នៃប្រទេសបង់ក្លាដែសត្រូវបានអនុម័តស្ទើរទាំងស្រុងពីផែនការសកម្មភាពក្រុងបាលី ដោយប្រើប្រាស់វាជាគោលការណ៍ណែនាំ សម្រាប់ផែនការយុទ្ធសាស្ត្រ។ ផែនការសកម្មភាពនេះមាន ៦ជំពូក ផ្តោតលើសន្តិសុខស្បៀង កិច្ចការពារសង្គម និងសុខភាព ការគ្រប់គ្រងទូលំទូលាយលើគ្រោះមហន្តរាយ ហេដ្ឋារចនាសម្ព័ន្ធ ការគ្រប់គ្រងចំណេះដឹង និងការស្រាវជ្រាវ ការកាត់បន្ថយ និងការអភិវឌ្ឍកាបូនទាប ការកសាងសមត្ថភាព និងការពង្រឹងស្ថាប័នជាដើម។ មូលនិធិជាតិមួយត្រូវបានបង្កើតឡើងផងដែរ ដើម្បីផ្តល់មូលនិធិសម្រាប់ការអនុវត្ត CCSAP ។ ការអនុវត្តនឹងត្រូវធ្វើតាមវិស័យនានា និងជំពូកទាំង១៦ ត្រូវបានរៀបចំ និងបំបែកជាកម្មវិធីចំនួន ៣៧ ដែលវិស័យនីមួយៗ ត្រូវទទួលខុសត្រូវលើការងារនោះ។

នៅឥណ្ឌា CCSAP ត្រូវបានគេស្គាល់ថា ជា ផែនការសកម្មភាពស្តីពីការប្រែប្រួលអាកាសធាតុ។ អំឡុងពេលអនុវត្តន៍គឺចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៧ និងស្ថិតនៅក្រោម ក្រុមប្រឹក្សានាយករដ្ឋមន្ត្រី ទទួលបន្ទុកការប្រែប្រួលអាកាសធាតុ។ ផែនការសកម្មភាពត្រូវបានបំបែកជាបេសកម្ម ឬយុទ្ធសាស្ត្រចំនួន៨ ដើម្បីសម្រេចបាននូវគោលបំណង និងអាទិភាពនៃការប្រែប្រួលអាកាសធាតុ ដែលត្រូវបានកំណត់ដូចជា៖ ថាមពលព្រះអាទិត្យ បង្កើនប្រសិទ្ធភាពថាមពល ទីជម្រកដែលមានចីរភាព បញ្ហាទឹក ចីរភាពនៃស្ថានប្រព័ន្ធ Himalayan ធ្វើឲ្យប្រទេសឥណ្ឌាជាតំបន់បៃតង ចីរភាពនៃកសិកម្ម និងចំណេះដឹងយុទ្ធសាស្ត្រ ពីការប្រែប្រួលអាកាសធាតុ។ រចនាសម្ព័ន្ធគួរឲ្យចាប់អារម្មណ៍នោះគឺមានក្រុមការងារពហុវិស័យ រាប់បញ្ចូលទាំងក្រសួងហិរញ្ញវត្ថុ គណៈកម្មការផែនការ អ្នកជំនាញការឧស្សាហកម្ម និង CSOs ។ របៀបវារៈនៃការប្រែប្រួលអាកាសធាតុនៅឥណ្ឌា គឺជាផ្នែកមួយនៃស្ថាប័នជាតិដ៏ធំមួយ ដើម្បីគាំទ្រដល់ការរៀបចំសកម្មភាពអនុវត្តនានា។ CSOs មានតួនាទីសំខាន់នៅក្នុងផែនការសកម្មភាពជាតិស្តីពីការប្រែប្រួលអាកាសធាតុបស់ឥណ្ឌា ប៉ុន្តែការអនុវត្តវិញត្រូវបានផ្តល់សិទ្ធដល់វិស័យនីមួយៗ។ ក្រុមពហុវិស័យ ផ្តល់ជាគោលការណ៍ណែនាំនានាពីរបៀបដែលវិស័យនីមួយៗត្រូវរៀបចំការងារនេះយ៉ាងដូចម្តេច។ ផែនការជាតិរបស់ឥណ្ឌាស្តីពីការប្រែប្រួលអាកាសធាតុ ផ្តោតជាសំខាន់ដូចគ្នាទាំងការបន្សាំ និងការកាត់បន្ថយដោយយកចិត្តទុកដាក់លើថាមពល និងការគ្រប់គ្រងធនធានធម្មជាតិ។

នៅហ្វីលីពីន CCSAPត្រូវបានចាត់ទុកជាក្របខ័ណ្ឌការងារយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដែលមានរយៈពេលអនុវត្តន៍ពីឆ្នាំ២០១០ ដល់ឆ្នាំ២០២២ និងតាំងនៅកន្លែងគណៈកម្មាធិការប្រែប្រួលអាកាសធាតុ/ការិយាល័យប្រធានាធិបតី ដែលជាស្ថាប័នកម្រិតខ្ពស់បំផុត។ វាផ្តល់ជាគោលការណ៍ណែនាំ សម្រាប់កម្មវិធីប្រែប្រួលអាកាសធាតុថ្នាក់ជាតិ ដែលមានលទ្ធផលសំខាន់ៗ តាមវិស័យ ឬយុទ្ធសាស្ត្រ។ វិស័យមួយ ដែលគួរឲ្យចាប់អារម្មណ៍គឺ ការរួមបញ្ចូល ឬរៀបរាប់ពីថាមពលទាំងអស់ពីការកាត់បន្ថយ និងការបន្សាំ និងផ្នែកសំខាន់មួយទៀតគឺកម្មវិធីនៃការគ្រប់គ្រងគ្រោះហានិភ័យ ជាអន្តរវិស័យ។ ដោយផ្អែកលើក្របខណ្ឌពេលវេលានៃការអនុវត្ត វាគួរតែផ្តល់នូវផែនការសកម្មភាពជាតិច្បាស់លាស់ពីរដ្ឋាភិបាលមូលដ្ឋាន ដែលអាចកំណត់បានពី វិធីសាស្ត្រនានាក្នុងការដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ។ ជាលទ្ធផល ផែនការសកម្មភាពជាតិនឹង ផ្តល់ជាគោលការណ៍ណែនាំ សម្រាប់ការងារថ្នាក់មូលដ្ឋាននៅហ្វីលីពីន ដែលរាប់បញ្ចូលទាំងគោលការណ៍ណែនាំពីរបៀបចាប់ផ្តើមការងារ នៅថ្នាក់ក្រោមជាតិ ដែលគួរត្រូវបានគ្រប់គ្រងយ៉ាងដូចម្តេច និងរបៀបនៃដំណើរការវិនិយោគ សម្រាប់ការប្រែប្រួលអាកាសធាតុគួរតែអនុវត្តដូចម្តេច។

នៅវៀតណាមមានកម្មវិធីគោលដៅជាតិបានបង្កើតឡើងនៅឆ្នាំ២០០៨ (ស្ថិតក្រោមកំណែទម្រង់) ដឹកនាំដោយក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទ។ កម្មវិធីនេះត្រូវបានផ្តោតជាសំខាន់លើ ការដោះស្រាយនឹងគ្រោះទឹកជំនន់នៅតំបន់ដីសណ្តទន្លេមេគង្គ ដែលរួមមានទាំងវិធានការបន្សាំ និងការកាត់បន្ថយ។ ដំណាក់កាលបន្ទាប់មក ត្រូវបានគេហៅថា "យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុប្រទេសវៀតណាម" ដែលត្រូវផ្អែកលើផែនការបន្សាំជាតិ បូកនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍កាបូនទាប ដែលចែងអំពីគោលនយោបាយ និងកម្មវិធីពាក់ព័ន្ធ ប៉ុន្តែដាច់ពីគ្នាដើម្បីដោះស្រាយនឹងបញ្ហានៃការប្រែប្រួលអាកាសធាតុ។ ទោះជាការកើនឡើងនៃកម្ពស់ទឹកសមុទ្រគឺជាបញ្ហាអាទិភាព ប៉ុន្តែវៀតណាមបាន

ទទួលស្គាល់ពី សារសំខាន់នៃការដោះស្រាយទាំងនេះទៅតាមវិស័យនីមួយៗ។

នៅថៃ CCSAP ត្រូវបានហៅថា ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ (CCSP) ។ ផែនការនេះមានអណត្តិពី ឆ្នាំ២០០៨ ដល់ ឆ្នាំ ២០១២ ដែលសម្របសម្រួលដោយ ក្រសួងធនធានធម្មជាតិ និងបរិស្ថាន ហើយស្ថិតនៅក្រោមការិយាល័យគោលនយោបាយធនធានធម្មជាតិ និងផែនការ ។ ប្រទេសថៃបានបញ្ចូលការងារនៃវិស័យទាំងនេះ ទៅក្នុងផែនការអភិវឌ្ឍន៍ និងសេដ្ឋកិច្ចជាតិពីមុន និងបច្ចុប្បន្ន។ ការប្រែប្រួលអាកាសធាតុ ត្រូវបានគេស្គាល់យ៉ាងច្បាស់ថាជាផ្នែកមួយយ៉ាងសំខាន់នៃរបៀបវារៈអភិវឌ្ឍន៍ជាតិ ។ នៅក្នុងប្រទេសថៃ យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុត្រូវបានដាក់ជាយុទ្ធសាស្ត្ររង ដាច់ដោយឡែកពីគ្នាចំនួន ៦ ដែលរួមមាន៖ មានការអភិវឌ្ឍសមត្ថភាព សម្រាប់ទាំងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកាត់បន្ថយភាពងាយរងគ្រោះ លើកកម្ពស់សកម្មភាព កាត់បន្ថយ GHGs គាំទ្រដល់ការស្រាវជ្រាវ និងការអភិវឌ្ឍស្តីពីការបន្សាំនិងការកាត់បន្ថយ លើកកម្ពស់ការយល់ដឹង និងការចូលរួមជាសាធារណៈ និងគាំទ្រដល់កិច្ចសហប្រតិបត្តិការជាអន្តរជាតិ។ សកម្មភាពទាំងនេះ គ្របដណ្តប់ទាំងការបន្សាំ និងការកាត់បន្ថយ និងបញ្ចូលបញ្ហាជនបទ និងទីក្រុង ទៅក្នុងយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ ។ យុទ្ធសាស្ត្ររងនីមួយៗ មានគោលបំណងរបស់វា ដើម្បីណែនាំកម្មវិធី កម្មវិធីរងជាក់លាក់ណាមួយ ហើយយុទ្ធសាស្ត្រនីមួយៗ ក៏មានផែនការសកម្មភាពផ្ទាល់ខ្លួនផងដែរ។ យុទ្ធសាស្ត្រទាំងនេះត្រូវបានកែសម្រួលទៅជា ផែនការមេរយៈពេល ១០ឆ្នាំ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលរាប់បញ្ចូលទាំងកសិកម្ម ឧស្សាហកម្ម និងថាមពល សុខភាព ហេដ្ឋារចនាសម្ព័ន្ធ និងទេសចរណ៍។

ជាសេចក្តីសន្និដ្ឋាន លោក **Holmgren** បានសរុបនូវចំណុចសំខាន់ៗថា៖

- ភាគច្រើននៃផែនការយុទ្ធសាស្ត្រ (SAPs) ត្រូវបានបន្សុីជាមួយនឹងផែនការអភិវឌ្ឍន៍ជាតិនានា
- SAPs ទាំងអស់ត្រូវអនុវត្តដោយមានការរួមបញ្ចូលពីថ្នាក់មូលដ្ឋាន តាមរយៈភ្នាក់ងារតាមវិស័យនិមួយៗ
- SAPs ខ្លះរាប់បញ្ចូលទាំងសមសភាគនានានៃការស្រាវជ្រាវ ដែលរួមបញ្ចូលទៅក្នុងការកសាង SAPs ហើយ SAPs ទាំងអស់ត្រូវមានការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពស្ថាប័ន
- គ្មានគំរូណា ដែលប្រសើរជាងសម្រាប់អនុវត្តតាមបានក្នុងការកសាង CCCSP នោះទេ ដូចនេះ បទពិសោធន៍នានាពីប្រទេសផ្សេងៗគឺពិតជាត្រូវការចាំបាច់។

យ៉ាងណាក៏ដោយ បទពិសោធន៍ ឬមេរៀននានាពី SAPs ដែលបានបង្ហាញ អាចយកមកធ្វើជាមូលដ្ឋានសម្រាប់ការបង្កើត CCCSP នៅកម្ពុជាដូចជា៖

- ពីប្រទេសថៃ ក្នុងការបង្កើត និងការអភិវឌ្ឍ CCSP ទៅក្នុងផែនការមេនៃការប្រែប្រួលអាកាសធាតុ ដោយមានចែងពីការចញ្ចឹមជីវិតនៅជនបទ និង DRR
- ពីប្រទេសឥណ្ឌា ក្នុងការលើកកម្ពស់ការយល់ដឹងជាសាធារណៈ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលជាការគាំទ្រការកសាង និងការអនុវត្ត CCCSP
- ពីប្រទេសវៀតណាម ក្នុងការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ តាមវិស័យ និងខេត្តនានាទៅក្នុងផែនការអភិវឌ្ឍ
- ពីប្រទេសបង់ក្លាដែសក្នុងការបង្កើតមូលនិធិជាតិ សម្រាប់ការប្រែប្រួលអាកាស

ធាតុ ការដាក់ឲ្យប្រតិបត្តិការ និងការស្វែងរកការគាំទ្រដល់មូលនិធិនេះ

- ពីប្រទេសហ្វីលីពីន ក្នុងការទទួលស្គាល់ភាពបំពេញគ្នានៃការកាត់បន្ថយ និងការបន្សាំក្នុងការអនុវត្ត CCCSP ។

គោលនយោបាយតាមវិស័យ ដែលពាក់ព័ន្ធនឹងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា

*ដោយលោក **ឡាយ ឃីម** ជំនួយការនាយកា និងជាប្រធានក្រុមបរិស្ថាន និងថាមពល UNDP*

បទបង្ហាញនេះ បានធ្វើការវិភាគលើកម្មវិធី និងគោលនយោបាយតាមវិស័យ និងអន្តរវិស័យដែលមានស្រាប់ ដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងផ្តល់នូវបច្ចុប្បន្នភាពនៃការរៀបចំ CCCSP តាមវិស័យ។

លោក **ឃីម** បានបង្ហាញថាក្នុងការវិភាគគោលនយោបាយតាមវិស័យ បានពិនិត្យជាសំខាន់លើចំណុចចំនួនបួនដូចជា៖ អន្តរាគមន៍តាមវិស័យក្នុង NAPA និង SNC ភាពស៊ីគ្នា និងភាពពាក់ព័ន្ធជាមួយ NAPA SNC ឬ CHDR ស្តីពីការប្រែប្រួលអាកាសធាតុ ការទទួលស្គាល់គោលនយោបាយ និងការផ្តល់អនុសាសន៍គោលនយោបាយ។ វិស័យសំខាន់នៃការវិភាគគោលនយោបាយរួមមាន វិស័យកសិកម្ម និងធនធានទឹក សុខភាព DRR វិមជ្ឈការ និងសហវិមជ្ឈការ ព្រៃឈើ ជលផល ដីធ្លី និងថាមពល។

ចំពោះវិស័យកសិកម្ម និងធនធានទឹក ត្រូវបានកំណត់ជា វិស័យអាទិភាពនៅក្នុងកម្មវិធី NAPA ដែលក្នុងគម្រោងអាទិភាពចំនួន២០ ក្នុងចំណោមគម្រោងចំនួន ៣៩ ដែលបានកំណត់នៅក្នុង NAPA គឺទាក់ទងនឹងវិស័យនេះ។ គម្រោងទាំងនេះ ផ្តោតជាចម្បងលើអន្តរាគមន៍មិនស្តាយក្រោយ មានន័យថាគម្រោងមានគោលបំណងរួមចំណែក ក្នុងការកាត់បន្ថយភាពក្រីក្រ ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ដូចជា ការគ្រប់គ្រងធនធានទឹក ការការពារដំណាំ ការយល់ដឹងជាសារធារណៈ ផលិតភាពកសិកម្ម និងលទ្ធភាពទទួលបានទឹក។ល។

យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងធនធានទឹក (SAW) (២០០៦-២០១០) បានទទួលស្គាល់ពីផលប៉ះពាល់ពី ការប្រែប្រួលអាកាសធាតុមកលើកសិកម្ម ហើយយុទ្ធសាស្ត្រនេះមានគោលដៅកាត់បន្ថយភាពក្រីក្រ សន្តិសុខស្បៀង និងការអភិវឌ្ឍសេដ្ឋកិច្ច តាមរយៈការបង្កើននូវផលិតភាពកសិកម្ម និងការគ្រប់គ្រងធនធានទឹកឲ្យមានប្រសិទ្ធិភាព។ ផែនការសកម្មភាព និងកម្មវិធី ដែលបានស្នើឡើងនេះត្រូវបានចាត់ទុកថាជាអន្តរាគមន៍មិនស្តាយក្រោយ និងពាក់ព័ន្ធនឹង NAPA។ យុទ្ធសាស្ត្រចំនួនបីត្រូវបានស្នើឡើងនៅក្នុង SAW ដែលរួមចំណែកដល់ការអភិវឌ្ឍភាពធន់ក្នុងកសិកម្ម ធនធានទឹកភ្ជាប់ជាមួយស្ថានប្រព័ន្ធកសិកម្ម ការគ្រប់គ្រងទីជម្រាល និងការកសាងផែនការអាងទន្លេ។ យុទ្ធសាស្ត្រទាំងនេះមានសារសំខាន់សម្រាប់វិស័យទាំងនោះ ដើម្បីកសាងសមត្ថភាពបន្សាំ ដែលមានភាពប្រសើរជាងមុន ប្រសិនបើយុទ្ធសាស្ត្រទាំងនេះត្រូវបានយកមកអនុវត្តយ៉ាងទូលំទូលាយ និងស៊ីជម្រៅនោះ។ SAW បានស្នើឡើងនូវអនុសាសន៍មួយចំនួនដូចជា៖

- ដើម្បីសិក្សា និងវាយតម្លៃផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុទៅលើទឹកលើដី និងក្រោមដី ការព្យាករណ៍ពីដំណាំ និងធ្វើផែនការតាមរដូវ
- ព្យាករណ៍ពីផលប៉ះពាល់លើកសិកម្ម និងចាត់វិធានការនានា ដើម្បីកាត់បន្ថយហេតុប៉ះពាល់ជាអវិជ្ជមាន
- អន្តរាគមន៍ ដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពជាមួយនឹងការត្រៀម

លក្ខណៈសម្រាប់គ្រោះមហន្តរាយដោយបង្កើត និងអនុវត្តវិធានការត្រៀមបង្ការគ្រោះមហន្តរាយដែលផ្តោតលើកសិកម្ម។

NAPA បានកំណត់វិស័យសុខាភិបាលថាជាវិស័យសំខាន់មួយ ក្នុងចំណោមវិស័យចំនួន៥ សម្រាប់ការកាត់បន្ថយភាពងាយរងគ្រោះរបស់ប្រជាជន។ គម្រោងចំនួន៤ ក្នុងចំណោមគម្រោងអាទិភាពចំនួន២០ ដែលបានកំណត់នៅក្នុង NAPA គឺទាក់ទងនឹងវិស័យសុខាភិបាល ដោយផ្តោតទៅលើផលិតកម្មថ្នាំសម្លាប់កណ្តាចង្រៃ ការកសាងសម្បទាសុខភាព ការផ្តល់ទឹកស្អាតនៅតំបន់ ដែលមានហានិភ័យខ្ពស់នៃរោគគ្រុនចាញ់ និងការអប់រំពីជំងឺគ្រុនចាញ់ និងយុទ្ធនាការសំអាតជម្រកមូស។ ផែនការយុទ្ធសាស្ត្រសុខភាព (២០០៨-២០១៥) ទទួលស្គាល់ថា ការបំពុលបរិស្ថាន និងការប្រែប្រួលអាកាសធាតុពិភពលោក ពិតជាជះឥទ្ធិពលដល់សុខភាពមនុស្ស ដែលត្រូវតែពង្រឹងនិងបង្កើនគុណភាពបរិស្ថាន ការកាត់បន្ថយហានិភ័យបរិស្ថាន និងកំណត់ពី ធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ គោលនយោបាយសុខភាពជាតិ ក៏បានទទួលស្គាល់ ពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងបរិស្ថានមកលើសុខភាពមនុស្ស ដែលជម្រុញឲ្យមានការកសាងគោលនយោបាយសុខភាពជាតិ និងផែនការសកម្មភាពសុខភាពបរិស្ថានជាតិ (NEHAP) ។ NEHAP មានគោលបំណងការពារសុខភាពមនុស្ស និងពិចារណាពីបរិស្ថាន ជាពិសេសនៅក្នុងស្ថានភាព ដែលប្រទេសកម្ពុជាមានការអភិវឌ្ឍសេដ្ឋកិច្ច និងឧស្សាហកម្មយ៉ាងឆាប់រហ័សនេះ។ នៅក្នុងផែនការសកម្មភាពនេះ គេបានកំណត់ក្រុមការងារថ្នាក់ជាតិ សម្រាប់ប្រធានចំនួន៧ ដែលរាប់បញ្ចូលទាំងការប្រែប្រួលអាកាសធាតុការបំផ្លាញស្រទាប់អូសូន និងការប្រែប្រួលស្ថានប្រព័ន្ធ។ NEHAP បានស្នើឲ្យដោះស្រាយចំនងទាក់ទងនឹងផលប៉ះពាល់រវាង សុខភាពបរិស្ថាន ដែលបណ្តាលមកពី ការប្រែប្រួលអាកាសធាតុថ្នាក់តំបន់ និងសកលលោក។

ចំពោះ DRR ត្រូវបានគេទទួលស្គាល់ ថាជាបញ្ហាអន្តរវិស័យនៅក្នុង NAPA និងត្រូវបានចាត់ជាអាទិភាពសម្រាប់ការត្រៀមបង្ការ និងការឆ្លើយតបទៅនឹងគ្រោះមហន្តរាយ។ ផែនការសកម្មភាពយុទ្ធសាស្ត្រជាតិ សម្រាប់ការកាត់បន្ថយគ្រោះមហន្តរាយ (SNAP-DRR) (២០០៨-២០១៣) មានចក្ខុវិស័យ ដើម្បីកសាងសហគមន៍មួយ ដែលមានភាពធន់នឹងគ្រោះមហន្តរាយធម្មជាតិស្របតាមក្របខណ្ឌសកម្មភាព Hyogo និងគ្របដណ្តប់លើប្រធានបទមួយចំនួន ដែលទាក់ទងនឹង ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ រាប់បញ្ចូលទាំងការបញ្ចូលការកាត់បន្ថយគ្រោះមហន្តរាយទៅក្នុងការអភិវឌ្ឍគោលនយោបាយ និងផែនការជាតិ តាមវិស័យ និងតាមមូលដ្ឋាន។ SNAP-DRR បានស្នើឡើងឲ្យមានការបន្សាំជាមួយនឹង NAPA ដោយការកំណត់អត្តសញ្ញាណ និងគាំទ្រសកម្មភាព និងគម្រោងរួមដើម្បីដោះស្រាយភាពងាយរងគ្រោះ និងគ្រោះថ្នាក់របស់សហគមន៍។

ចំពោះវិមជ្ឈការ និងសហវិមជ្ឈការ មិនត្រូវបានលើកឡើងនៅក្នុង NAPAទេ។ ប៉ុន្តែវាគឺផ្នែកមួយនៃការអនុវត្តគម្រោងទាំង ៣៩ ដែលបានកំណត់ដោយ NAPA ដែលត្រូវតែអនុវត្តដោយក្រសួងជំនាញ និងមន្ទីរពាក់ព័ន្ធនៅថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិបានទទួលស្គាល់តួនាទីថ្នាក់ក្រោមជាតិ ក្នុងការចូលរួមក្នុងការអភិវឌ្ឍជាតិ និងទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាអន្តរវិស័យ។ កម្មវិធីនេះចែងថា ការប្រែប្រួលអាកាសធាតុចាំបាច់ត្រូវតែបញ្ចូលទៅក្នុង ផែនការគ្រប់គ្រង

ក៏ដូចជាការផ្តល់សេវាកម្មរបស់អាជ្ញាធរថ្នាក់មូលដ្ឋាន។ ជាងនេះទៀតក្របខណ្ឌ សម្រាប់ការកសាងសមត្ថភាពវាយតំលៃនៅថ្នាក់ក្រោមជាតិ សម្រាប់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក៏បានលើកឡើងនៅក្នុងកម្មវិធីនេះដែរ។ ការកំណត់អត្តសញ្ញាណ និងផ្ទេរមុខនាទីដំបូង ដែលរួមទាំងមុខងារសមស្របពីបញ្ហាប្រែប្រួលអាកាសធាតុទៅក្រុមប្រឹក្សាអាជ្ញាធរថ្នាក់មូលដ្ឋាននីមួយៗ (SNA) និងផ្តល់ជាអនុសាសន៍លើគោលការណ៍ណែនាំ និងនីតិវិធីក្នុងការកសាង ការបង្ហាបការប្រែប្រួលអាកាសធាតុនៅគ្រប់ SNA និងរៀបចំវគ្គបណ្តុះបណ្តាលនានាក៏ដូចជាបង្កើតប្រព័ន្ធ សាកល្បងសម្រាប់ការវាយតម្លៃការខូចខាតលើបរិស្ថាននៅ SNA ។

ចំពោះវិស័យជលផល ក៏ត្រូវបានកំណត់នៅក្នុងNAPA ផងដែរ ប៉ុន្តែមិនសូវលម្អិតទេ។ ទាក់ទងទៅនឹងវិស័យនេះ យុទ្ធសាស្ត្រមួយហៅថា សេចក្តីព្រាងក្របខណ្ឌផែនការយុទ្ធសាស្ត្រសម្រាប់ វិស័យជលផល (DSPFF) (២០១០-២០១៩) គឺជាឯកសារមូលដ្ឋានសម្រាប់វិស័យជលផល ដើម្បីធ្វើឲ្យប្រសើរឡើងនូវដំណើរការគ្រប់គ្រងអភិរក្ស និងអភិវឌ្ឍន៍ធនធានជលផលប្រកបដោយចីរភាព ដើម្បីរួមចំណែកក្នុងការធានានូវសន្តិសុខស្បៀង និងសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម។ DSPFF ទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុ គឺជាការគំរាមកំហែងមួយមកលើវិស័យជលផល និងទទួលស្គាល់ពីសារសំខាន់នៃការយល់ដឹងបានត្រឹមត្រូវ ពីផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ដែលអាចកើតចេញពីការប្រែប្រួលអាកាសធាតុ។ DSPFFបានចែងពី សារសំខាន់នៃការអនុវត្តក្របខណ្ឌនេះស្របជាមួយនឹងវិមជ្ឈការ និងសហវិមជ្ឈការ និងសង្កត់ធ្ងន់ពី សារសំខាន់នៃការដោះស្រាយបញ្ហានៃការប្រែប្រួលអាកាសធាតុ និងបង្ហាបបញ្ហាការប្រែប្រួលអាកាសធាតុ តាមរយៈគោលនយោបាយ ច្បាប់ និងស្ថាប័ន។

ចំពោះវិស័យព្រៃឈើ ត្រូវបានបញ្ចូលដោយផ្នែកនៅក្នុង NAPA ដែលភាគច្រើនទាក់ទងនឹងសហគមន៍កសិ-រុក្ខកម្ម នៅក្នុងតំបន់ទីជម្រាលដែលបាត់បង់ព្រៃឈើ និងតំបន់ឆ្នេរ និងការអភិរក្សដីតាមបែបសហគមន៍។ កម្មវិធីព្រៃឈើជាតិ (២០១០-២០២៩) បានកំណត់ទស្សនវិស័យ សម្រាប់ប្រទេសកម្ពុជាសម្រាប់រយៈពេល ២០ឆ្នាំ នៃការគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព និងបានស្នើនូវកម្មវិធីមួយ សម្រាប់ចីរភាពហិរញ្ញវត្ថុតាមរយៈអភិក្រមដែលផ្អែកលើ REDD ដើម្បីប្រមូលមូលនិធិពីព្រៃឈើ និងកាបូន។ កម្មវិធីនេះ ក៏គាំទ្រដល់ការតស៊ូមតិ ដើម្បីការពារសិទ្ធិរបស់សហគមន៍មូលដ្ឋាន និងសារសំខាន់នៃការគ្រប់គ្រងធនធានធម្មជាតិ តាមបែបវិមជ្ឈការ។ គោលនយោបាយមួយទៀតគឺ ផែនទីបង្ហាញផ្លូវ REDD+ (២០១០) ដែលជាឯកសារគោល សម្រាប់ត្រៀមខ្លួនរបស់កម្ពុជា ដើម្បីរកមូលនិធិនានាពីការគ្រប់គ្រងព្រៃឈើ និងឥណទានកាបូន។ ដើម្បីគាំទ្រដល់គោលនយោបាយនេះ កម្ពុជាបានបង្កើតនូវយុទ្ធសាស្ត្រ REDD+ និងក្រុមការងារ REDD ជាតិ។ ផែនទីបង្ហាញផ្លូវនេះ អាចជាឧទាហរណ៍ល្អមួយ សម្រាប់វិស័យផ្សេងទៀតក្នុងការកសាងផែនទីបង្ហាញផ្លូវតាមវិស័យ សម្រាប់ផែនការសកម្មភាពបញ្ហាបការប្រែប្រួលអាកាសធាតុ។

កម្មវិធីសកម្មភាពជាតិដើម្បីការគ្រប់គ្រងដីប្រកបដោយចីរភាព(SLM) (ដូចជាដីកសិកម្ម និងព្រៃឈើ) (២០១១-២០២០) កំពុងត្រូវបានរៀបចំក្រោមការគាំទ្រពី UNDP។ កម្មវិធីសកម្មភាពនេះ មានចក្ខុវិស័យរយៈពេល១០ឆ្នាំលើការគ្រប់គ្រងដីកសិកម្មដោយចីរភាព និងកែលម្អការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ការវិភាគ ពីចំណងទាក់ទង រវាងការប្រើប្រាស់ដីដោយចីរភាព និងការប្រែប្រួលអាកាសធាតុ និងការវិភាគពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើវិស័យកសិកម្ម។ កម្មវិធីនេះ ក៏បាន

ស្នើឡើងឲ្យមានអភិក្រមទីជម្រាល សម្រាប់ការគ្រប់គ្រងដីដោយចីរភាព ដែលមានការពាក់ព័ន្ធទៅនឹងការបន្សាំ និងការកាត់បន្ថយនៅកម្រិតកសិដ្ឋាន និងតំបន់ទេសភាព។

នៅក្នុងវិស័យថាមពល របាយការណ៍ SNC គឺជាឯកសារមួយ ដែលផ្តល់ជាអនុសាសន៍លើជម្រើសនានាក្នុងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ ក្នុងវិស័យថាមពលកកើតឡើងវិញ។ សេចក្តីព្រាងវិស័យថាមពលកម្ពុជាទទួលស្គាល់ពី ផលប៉ះពាល់នៃការកើនឡើងកម្តៅពិភពលោក និងការប្រែប្រួលអាកាសធាតុ និងការតស៊ូមតិ សម្រាប់ការអភិវឌ្ឍប្រភពថាមពលកកើតឡើងវិញដូចជា៖ ជីវម៉ាស់ ថាមពលព្រះអាទិត្យ និងវារីអគ្គីសនីខ្នាតតូច សម្រាប់ការផ្គត់ផ្គង់អគ្គីសនី សម្រាប់ការប្រើប្រាស់នៅក្នុងឧស្សាហកម្ម ពាណិជ្ជកម្ម និងតាមលំនៅដ្ឋាន។ ផែនទីបង្ហាញផ្លូវអភិវឌ្ឍន៍បៃតង (២០០៩) ដែលរៀបចំដោយ MoE បានកំណត់ថាមពលកកើតឡើងវិញ ជាចំណុចទទួលបានមួយនៃចំណុចទទួលបានទាំង៧ ដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវ។ ក្នុងនេះដែរក៏មានការវិភាគកត្តាជម្រុញឲ្យមានការអភិវឌ្ឍបៃតង ការកំណត់លំនាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចបៃតង និងស្នើឲ្យមានអន្តរាគមន៍រយៈពេលខ្លី (២-៥ឆ្នាំ) រយៈពេលមធ្យម (៥-១០ឆ្នាំ) និងរយៈពេលវែង (១០-២០ឆ្នាំ)។

លោក **ឡាយ ឃីម** បានលើកឡើងថា ការចាត់ជាអាទិភាពតាមវិស័យគឺជា ទំនួលខុសត្រូវរបស់ NCCC។ លទ្ធផលរំពឹងទុករួមមាន៖

- យុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុតាមវិស័យ/ផែនទីបង្ហាញផ្លូវស្តីពីការប្រែប្រួលអាកាសធាតុ រួមជាមួយផែនការអនុវត្ត ដែលបានរៀបរៀងឡើងសម្រាប់ណែនាំដល់ការវិនិយោគ
- ចាត់អាទិភាពតាមវិស័យពីបញ្ហាការប្រែប្រួលអាកាសធាតុ និងជម្រើសសម្រាប់ការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុត្រូវបានកំណត់
- ការវាយតម្លៃតាមវិស័យនៃការប្រែប្រួលអាកាសធាតុ ដែលបានអនុម័តដោយរដ្ឋមន្ត្រី/ប្រធានស្ថាប័ន
- គោលបំណងជាយុទ្ធសាស្ត្រ និងសកម្មភាពតាមវិស័យ ដែលបានឆ្លុះបញ្ចាំងនៅក្នុង CCCSP និងការចូលរួមរបស់អ្នកពាក់ព័ន្ធត្រូវបានពង្រឹង

នៅក្នុងលទ្ធផល និងអភិក្រម CCCA ផ្តល់ថវិកាប្រហែលជា ២៥.០០០ដុល្លាអាមេរិក ដល់វិស័យជាអាទិភាពសំខាន់ៗ ដើម្បីបង្កើតផែនទីបង្ហាញផ្លូវតាមវិស័យ ដោយផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។

ដើម្បីរៀបចំផែនទីបង្ហាញផ្លូវ ត្រូវមើលទៅលើគុណភាពនៃការធ្វើផែនការ និងការប្រើប្រាស់អភិក្រម ដែលផ្អែកលើការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។ CCCA នឹងផ្តល់ថវិកា ២៥.០០០ដុល្លាអាមេរិក ដោយផ្អែកលើលទ្ធផលរំពឹងទុកចំនួនពីរ គឺ [១] ផែនទីបង្ហាញផ្លូវសម្រាប់ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុតាមវិស័យ និង[២] ផែនការមានការចូលរួមពីអ្នកពាក់ព័ន្ធ។

នៅចុងបញ្ចប់ លោក **ឡាយ ឃីម** បានទទួចថា ផែនទីបង្ហាញផ្លូវតាមវិស័យរបស់វិស័យអាទិភាពគួរតែត្រូវបានប្រើប្រាស់ សម្រាប់កម្មវិធីឬគម្រោងក្រោយៗទៀត។ វាគឺជាការលើកទឹកចិត្តដល់វិស័យទាំងឡាយណាដែលត្រៀមខ្លួនជាស្រេចក្នុងការរៀបចំយុទ្ធសាស្ត្រនានា ទៅតាមការអភិវឌ្ឍតាមវិស័យនីមួយៗរបស់ខ្លួន។

ដំណើរឆ្ពោះទៅកាន់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា

*ដោយលោក **ស៊ុំ ឆី** ប្រធាននាយកដ្ឋាន CCD និងជាអ្នកសម្របសម្រួលថ្នាក់ជាតិ សម្រាប់ការអភិវឌ្ឍ*

បទបង្ហាញនេះ បានផ្តល់នូវប្រវត្តិ សនិទានភាព គោលបំណង និងមាតិកាព្រាងនៃ CCCSP និងផែនទីបង្ហាញផ្លូវសម្រាប់អនុវត្ត។ បទបង្ហាញនេះ បានសង្កត់ធ្ងន់ ជាពិសេសនូវការបង្ហាញពីបញ្ហត្តិរបស់ CCCSP និងក្របខណ្ឌគោលការណ៍របស់ CCCSP ព្រមជាមួយនឹងផែនទីបង្ហាញផ្លូវផងដែរ។

លោក **ស៊ុំ ឆី** ចាប់ផ្តើមដោយលើកឡើងពីការប្រឈមថា កម្ពុជាមិនមានគោលនយោបាយ ឬផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ ដែលមានលក្ខណៈទូលំទូលាយ ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅឡើយទេ។ ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយពីមុនៗ សម្រាប់ការប្រែប្រួលអាកាសធាតុ ត្រូវបានធ្វើឡើងដោយផ្អែកលើគម្រោងតែប៉ុណ្ណោះ ហើយនៅពេលដែលគម្រោងបញ្ចប់ លទ្ធផលដែលបានរកឃើញ ពុំត្រូវបានគេអនុវត្តបន្ត ឬប្រើប្រាស់ទេ ដែលនេះជាសញ្ញាណនៃភាពមិនមានចីរភាព។ ជាលទ្ធផលការបង្កើត CCCSP ត្រូវបានគេគិតថា គឺជាសមិទ្ធិផលដ៏សំខាន់មួយសម្រាប់ CCCA ។

លោក **ឆី** បានបញ្ជាក់ផងដែរពីសនិទានភាពសម្រាប់ CCCSP ថា ការបង្កើត CCCSP គឺស្របគ្នានឹង NSDP (បច្ចុប្បន្នកម្ម ២០០៨-២០១៣) ដែលបានបញ្ជាក់ថា កម្ពុជាត្រូវតែបង្កើតឲ្យមាន ផែនការយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់ការប្រែប្រួលអាកាសធាតុ។ លើសពីនេះ ផែនការយុទ្ធសាស្ត្រនេះ ក៏ស្របគ្នានឹងការប្តេជ្ញារបស់កម្ពុជាក្រោម UNFCCC ក៏ដូចជាសេចក្តីសម្រេចរបស់ CoP រួមទាំងកម្មវិធីការងារ Nairobi ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងកិច្ចព្រមព្រៀងកាន់គុន ដែលស្នើសុំឲ្យកម្ពុជា បង្កើតនូវផែនការបន្សាំជាតិនេះឡើង។

ការបង្កើតឲ្យមាន ផែនការយុទ្ធសាស្ត្រនេះ ចាំបាច់ត្រូវមានក្របខណ្ឌជាមគ្គុទេសក៍សម្រាប់សម្របសម្រួលកិច្ចការអន្តរវិស័យ និងឱកាសសម្រាប់ការប្រែប្រួលអាកាសធាតុ។ ដូចមានចែងក្នុងកិច្ចព្រមព្រៀងកាន់គុន នៃប្រទេសនៅក្នុងឧបសម្ព័ន្ធ I សន្យាឧបត្ថម្ភថវិកាចំនួន ៣០ពាន់លាន ដុល្លាអាមេរិចក រហូតដល់ឆ្នាំ ២០១២ ហើយចាប់ពី ២០១២-២០២០ នឹងឧបត្ថម្ភថវិកាចំនួន ១ពាន់លានដុល្លា អាមេរិក ក្នុងមួយឆ្នាំៗសម្រាប់ DCs និងប្រទេសដែលងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ។ ឆ្លើយតបទៅនឹងឱកាសដ៏ល្អនេះ តម្រូវឲ្យមានផែនការយុទ្ធសាស្ត្រ និងផែនការដែលអាចឲ្យផលបានសម្រាប់ការអនុវត្តនៅថ្នាក់ជាតិ ដើម្បីបង្គ្រប់លក្ខខណ្ឌ សម្រាប់ចាប់យកមូលនិធិពី UNFCCC បាន។

លោក **ស៊ុំ ឆី** ក៏បានបញ្ជាក់ផងដែរថា CCCSP ក៏មានតួនាទីសំខាន់ដែរក្នុងការប្រែប្រួលអាកាសធាតុ។ កម្មវិធីនេះ ជួយដល់កម្ពុជាជាពិសេស NCCC ឲ្យត្រៀមលក្ខណៈចំពោះផលប៉ះពាល់ប្រែប្រួលអាកាសធាតុ ថ្នាក់តំបន់ និងសកល និងអាចជួយដល់កម្ពុជា ក្នុងការត្រៀមចាប់យកឱកាសឧបត្ថម្ភគាំទ្រ ជាសកលសម្រាប់គំនិតផ្តួចផ្តើម ដែលស្ថិតនៅក្រោម UNFCCC ។

គោលការណ៍គន្លឹះនៃការបង្កើត CCCSP ត្រូវបានបង្កើតឡើង ដោយយោងតាមសេចក្តីប្រកាសលេខ ៥៣៣ ចុះថ្ងៃទី៧ ខែមេសា ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីគាំទ្រដល់ការរៀបចំបង្កើត និងបញ្ជៀសនូវភាពត្រួតស៊ីគ្នានៃការទទួលខុសត្រូវ និងភាពមិនស៊ីសង្វាក់គ្នា។ គោលការណ៍ណែនាំដែលគេស្គាល់ថាជា ផែនទីបង្ហាញផ្លូវសម្រាប់ CCCSP នោះត្រូវបានពិនិត្យដោយ ក្រុមការងារបច្ចេកទេសការប្រែប្រួលអាកាសធាតុនៅថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១១។ សេចក្តីព្រាង CCCSP បានបញ្ចូន

ទៅដល់ NCCC និងបានអនុម័តនៅថ្ងៃទី០៤ ខែ សីហា ឆ្នាំ២០១១ ដោយមានការកែសម្រួលតិចតួច។

វិសាលភាព CCCSP គ្របដណ្តប់នូវចំណុចមួយចំនួនដូចជា៖

- បញ្ចូល ឬបន្ថែមនិយមន័យនៃ CCCSP ទៅក្នុងយុត្តិកម្ម និងគោលការណ៍ណែនាំសំខាន់ៗ
- បញ្ជីនៃគ្រោះថ្នាក់/ហានិភ័យអាកាសធាតុ និងការប្រែប្រួលអាកាសធាតុក្នុងកម្ពុជាដើម្បីកំណត់អាទិភាពវិស័យងាយរងគ្រោះ និងអនុវិស័យនានា
- ការឆ្លើយតបទៅនឹងគោលនយោបាយការប្រែប្រួលអាកាសធាតុ
- យុទ្ធសាស្ត្រតាមវិស័យសម្រាប់ការបន្សាំជាពិសេសវិស័យអាទិភាពនិងអនុវិស័យ
- យុទ្ធសាស្ត្រកាត់បន្ថយសម្រាប់វិស័យពាក់ព័ន្ធ ដូចជាវិស័យថាមពល និងមិនមែនថាមពល ជាពិសេសវិស័យព្រៃឈើ
- យុទ្ធសាស្ត្រ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់របស់អាកាសធាតុ និងឱកាសសម្រាប់កិច្ចការអន្តរវិស័យ
- យុទ្ធសាស្ត្រហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ និងយន្តការហិរញ្ញប្បទានដែលបានស្នើឡើង។

លោកបានបន្តទៀតថា វិស័យអាទិភាពត្រូវបានគេកំណត់ ប៉ុន្តែវានឹងត្រូវពិនិត្យឡើងវិញដើម្បីកំណត់ថាតើគួរបញ្ចូលក្នុង CCCSP យ៉ាងណា។ នៅក្នុងវិស័យទាំងអស់នោះ នឹងទទួលបានមូលនិធិគាំទ្រពី UNDP សម្រាប់ការចំណាយ លើការប្រឹក្សាយោបល់ សម្រាប់ផែនការយុទ្ធសាស្ត្រនីមួយៗ។

អភិក្រមនៃការអនុវត្តសម្រាប់ CCCSP ចាប់ផ្តើមពីការពិនិត្យឡើងវិញ និងសំយោគឯកសារតាមវិស័យ និងថ្នាក់ជាតិ ដែលមានស្រាប់និងពាក់ព័ន្ធទៅនឹង ការប្រែប្រួលអាកាសធាតុ ដើម្បីរៀបចំសេចក្តីព្រាង CCCSP ។ សេចក្តីព្រាង ដែលបានរៀបចំឡើងផ្តោតសំខាន់លើចក្ខុវិស័យបេសកកម្ម និងគោលបំណងត្រូវដាក់ជូនទៅ NCCC ដើម្បីអនុម័ត។ នៅក្នុង CCCSP ក៏ធ្វើការកំណត់នូវគោលជំហររបស់ កម្ពុជាស្តីពីការប្រែប្រួលអាកាសធាតុក្នុងបរិបទ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបចីរភាព និងការប្រើប្រាស់ធនធានធម្មជាតិដោយមានសនិទានភាព។ ជាងនេះទៀត ការវិភាគគោលនយោបាយការប្រែប្រួលអាកាសធាតុតាមវិស័យក្នុងវិស័យចម្បងៗ ត្រូវបានរួមបញ្ចូលផងដែរ ក្នុងផែនការយុទ្ធសាស្ត្រ នេះ។

ចុងក្រោយ លោក **ឆ៊ី** បានសង្ខេបពីការបញ្ចូលវិស័យពាក់ព័ន្ធនានា រួមមានអន្តរក្រសួង និងវិស័យឯកជននៅក្នុងការបង្កើត CCCSP ថាជា គន្លឹះឆ្ពោះទៅរកភាពជោគជ័យ តាមរយៈការបង្កើតភាពជាម្ចាស់នៃ CCCSP ។ វិស័យអាទិភាពរបស់ CCCSP នឹងត្រូវបានគេលើកមកពិភាក្សាក្នុងសិក្ខាសាលាប្រឹក្សាយោបល់ យ៉ាងទូលំទូលាយនៅពេលខាងមុខនេះ ដើម្បីរៀបចំកសាងនូវ CCCSP។ ចំណែកឯសកម្មភាពផ្សេងទៀតនឹងចាប់ផ្តើមបន្ទាប់ពីវេទិកាជាតិនេះ។

ខ្លឹមសារសំខាន់ៗពាក់ព័ន្ធនឹងកិច្ចចរចាការប្រែប្រួលអាកាសធាតុនាពេលថ្មីៗនេះ

ដោយលោក ***Mozaharul Alam***

អ្នកសម្របសម្រួលការប្រែប្រួលអាកាសធាតុប្រចាំតំបន់ UNEP

បទបង្ហាញនេះបានបង្ហាញជូននូវការវិវត្តចុងក្រោយនៃកិច្ចចរចាការប្រែប្រួលអាកាសធាតុបញ្ហាចំបងៗ ដែលត្រូវពិភាក្សាក្នុងCoP ១៧ នៅទីក្រុងឌូបាន និងលទ្ធផល ដែលអាចទទួលបានពី CoP ១៧។

លោក **Mozahurul Alam** បានចាប់ផ្តើមជាមួយនឹងសារគារបស់ UNFCCC ដែល

បានបង្កើតឡើងនៅថ្ងៃទី ០៩ ខែឧសភា ឆ្នាំ ១៩៩២ នៅទីក្រុងញូវយ៉ក បន្ទាប់ពីរយៈពេល ៥ឆ្នាំនៃការគិតពិចារណាពីការប្រែប្រួលអាកាសធាតុ នៅក្នុងកិច្ចប្រជុំពេញអង្គនៃ អ.ស.ប នៅឆ្នាំ ១៩៨៨។ ក្រោយពីការអនុម័តនៃ UNFCCC ការចរចារនៅតែដំណើរការតាមគោលការណ៍នៃការព្រមព្រៀង ដែលរាល់ការសម្រេចចិត្តទាំងអស់គឺចូលរួមរវាងភាគីទាំងអស់ ដោយមិនត្រូវការបោះឆ្នោត ហេតុដូចនេះអាចមានការប្រើប្រាស់សិទ្ធវេតូ។

គោលបំណងចំបងរបស់ UNFCCC គឺដើម្បីទប់ស្កាត់ការរំខាន ដែលបង្កគ្រោះថ្នាក់ដោយមនុស្សមកលើប្រព័ន្ធអាកាសធាតុ។ ស្ថានប្រព័ន្ធនឹងអាចបន្សាំបាន ដោយធម្មជាតិទៅនឹងការប្រែប្រួលអាកាសធាតុ ធានាថាផលិតកម្មស្បៀងនឹងមិនរងការគម្រាមកំហែង និងអាចឲ្យមាន ការបន្តអភិវឌ្ឍន៍សេដ្ឋកិច្ច ដោយចីរភាព។ ការកំណត់អត្តសញ្ញាណនៃការរំខាន ដែលបង្កគ្រោះថ្នាក់ដោយមនុស្ស គឺជាការប្រឈមដែលត្រូវមានការព្រមព្រៀងដោយប្រព័ន្ធនយោបាយ ក្នុងដំណើរការនៃការចរចារ ព្រោះប្រទេសអភិវឌ្ឍន៍មានគំនិតមួយ ហើយប្រទេសផ្សេងទៀតក៏មានគំនិតផ្សេងទៀតដែរ។

គោលការណ៍នានា ដែលត្រូវបានព្រមព្រៀងដោយ UNFCCC រួមមាន៖

- ការទទួលខុសត្រូវរួម ប៉ុន្តែដាច់ដោយឡែកពីគ្នា ទៅតាមសមត្ថភាពរៀងៗខ្លួន ក្នុងការឆ្លើយតបនឹង ការប្រែប្រួលអាកាសធាតុនៅពេលដែលការប្រែប្រួលអាកាសធាតុ គឺជាការប្រឈមរួមគ្នា
- DCs ត្រូវការការពិចារណា ពិសេសលើតម្រូវការជាក់លាក់ និងកាលៈទេសៈពិសេស
- ភាគីនានាត្រូវចាត់វិធានការការពារទុកជាមុន ក្នុងន័យដែលភាពមិនប្រាកដប្រជាមិនគួរត្រូវបានប្រើប្រាស់ជាការដោះសារសម្រាប់ការមិនចូលរួមនោះទេ
- សិទ្ធិក្នុងការអភិវឌ្ឍប្រកបដោយចីរភាព
- សហការណ៍គ្នាដើម្បីលើកកម្ពស់ប្រព័ន្ធសេដ្ឋកិច្ចអន្តរជាតិ

លោក **MozahurulAlam** បានលើកឡើងថា ពិធីសារក្យូតូបានកំណត់គោលដៅជាបឋមក្នុងការកាត់បន្ថយ GHGs រហូតដល់៥,២% តាមរយៈយន្តការបត់បែននានា ដូចជា ការកាត់បន្ថយការបំភាយ ជាឯកតា (ERU) នៅក្រោមមាត្រា ៦ CDM នៅក្រោមមាត្រា ១២ និងសកម្មភាពមិននៅក្រោមគម្រោង នៅក្រោមមាត្រា ១៧។

ផែនការសកម្មភាពក្រុងបាលីឆ្នាំ ២០០៧ គឺជាបង្គោលមួយ នៅក្នុងកិច្ចខិតខំប្រឹងប្រែងនេះ។ សហគមន៍ពិភពលោកទទួលស្គាល់ និងត្រូវការការសម្រេចចិត្តយ៉ាងទូលំទូលាយ និងសកម្មភាពនានា ក្នុងការឆ្លើយតបនឹងការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាការចូលរួមរបស់ប្រទេសអភិវឌ្ឍន៍និងLCDs។ ផែនការសកម្មភាពបាលីមានមូលដ្ឋានគ្រឹះសំខាន់ៗចំនួនប្រាំគឺ៖

១. ចក្ខុវិស័យរួមសម្រាប់សកម្មភាពសហប្រតិបត្តិការរយៈពេលវែង
២. បង្កើនសកម្មភាពការកាត់បន្ថយ នៅថ្នាក់ជាតិ/អន្តរជាតិ
៣. បង្កើនសកម្មភាពលើការបន្សាំ
៤. បង្កើនសកម្មភាពលើការអភិវឌ្ឍ និងបន្ទេរបច្ចេកវិទ្យាដើម្បីគាំទ្រដល់សកម្មភាពកាត់បន្ថយ និងការបន្សាំ
៥. បង្កើនសកម្មភាពលើការផ្តល់ធនធាន ហិរញ្ញវត្ថុ និងការវិនិយោគ ដើម្បីគាំទ្រដល់ សកម្មភាពកាត់បន្ថយ និងការបន្សាំ និងកិច្ចសហប្រតិបត្តិការផ្នែកបច្ចេកវិទ្យា

បញ្ហាប្រឈមជាចំបងនៃផែនការសកម្ម ភាពក្រុងបាលីទៅនឹងកិច្ចព្រមព្រៀងកូប៉េនហាក់ សម្រាប់សហគមន៍ពិភពលោក នោះគឺការរំពឹង ទុកខ្ពស់ពេកនៅក្នុងកិច្ចប្រជុំនៅ ទីក្រុងកូប៉េន ហាក់ ក្នុងការផ្តល់នូវការធ្វើសេចក្តីសម្រេចជា កញ្ចប់ និងយ៉ាងទូលំទូលាយ ប៉ុន្តែលទ្ធផលនៃ កិច្ចប្រជុំពុំបានផ្តល់ដូចអ្វីដែលរំពឹងទុកនោះទេ។ លទ្ធផលចម្បងៗចំនួនពីរ ដែលទទួលបានពី កិច្ចប្រជុំនេះគឺ ការអនុវត្តបង្ហាញពីចូលរួមពុំធ្លាប់ មាន ពីថ្នាក់ដឹកនាំពិភពលោក និងការចូលរួមពី មន្ត្រីនយោបាយថ្នាក់ខ្ពស់បំផុតពីប្រទេសនានា។ សមាសភាគសំខាន់ៗរបស់កិច្ចព្រមព្រៀងកូប៉េន ហាក់ គឺ៖

- គោលដៅនៃការកាត់បន្ថយការបញ្ចេញ សម្រាប់ភាគីក្នុងឧបសម្ព័ន្ធ I ប្តេជ្ញាដើម្បី កាត់បន្ថយ GHGs ប្រមាណ ១៧% ដូចដែលទាមទារដោយ IPCC និងការ សន្យាកាត់បន្ថយប្រមាណជា ២៥-៤០% នៅឆ្នាំ២០២០ ធៀបនឹងឆ្នាំគោល១៩៩០ ដើម្បីរក្សាកំណើនសីតុណ្ហភាពឲ្យទាប ជាង២ °C។
- NAMA របស់ DCs ដែលប្រទេសនានា បានស្នើឡើងជា គោលដៅសម្រាប់ការ កាត់បន្ថយ ប៉ុន្តែប្រទេសមិននៅក្នុង ឧបសម្ព័ន្ធ I នឹងអនុវត្តសកម្មភាពកាត់ បន្ថយរបស់ខ្លួនដោយស្ម័គ្រចិត្ត
- ការប្តេជ្ញាចិត្តពីប្រទេសអភិវឌ្ឍន៍ ក្នុងការ ផ្តល់នូវធនធានហិរញ្ញវត្ថុ និងបច្ចេកវិទ្យា ចំនួន ៣០ពាន់លានដុល្លា អាមេរិក សម្រាប់រយៈពេលបីឆ្នាំខាងមុខសម្រាប់ DCs ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែង ការកាត់បន្ថយ និងបន្សាំរបស់ DCs និង ការសន្យាផ្តល់ ១០០ពាន់លាន ដុល្លា អាមេរិកក្នុងមួយឆ្នាំរហូតដល់ឆ្នាំ២០២០ សម្រាប់ការប្តេជ្ញាចិត្តរយៈពេលវែង
- ការបង្កើតស្ថាប័ន និងរចនាសម្ព័ន្ធអភិ បាលកិច្ច ដើម្បីបង្កើតជា GCF កូប៉េន ហាក់។ បន្ទាប់មក អគ្គលេខាធិការដ្ឋាន អ.ស.ប បានបង្កើតក្រុមការងារជាន់ខ្ពស់ មួយសម្រាប់ចាត់ចែងលើមូលនិធិ ១០០ ពាន់លានដុល្លាអាមេរិក រហូតដល់ឆ្នាំ ២០២០ ដើម្បីបង្កើតជា យន្តការក្នុងការ ប្រើប្រាស់មូលនិធិនោះ ជាពិសេស សម្រាប់គម្រោងការពារកសិកម្ម និងហេ ដ្ឋារចនាសម្ព័ន្ធ និងស្នើឲ្យមានយុទ្ធ សាស្ត្រនានា សម្រាប់ជម្រុញឲ្យមានការ វិនិយោគលើវិស័យថាមពលកកើតឡើង វិញ និងបច្ចេកវិទ្យាស្អាតនៅក្នុងបណ្តា ប្រទេសក្រីក្រ។

កិច្ចព្រមព្រៀងកាន់គុន បានផ្តល់នូវយន្ត ការសំខាន់ៗចំនួន៥ រួមមាន៖ មូលនិធិបៃតង បច្ចេកវិទ្យា ការកាត់បន្ថយ REDD និងការ បន្សាំ។ ចំណុចសំខាន់ៗក្នុងការបង្កើតមូលនិធិ បៃតង ចាំបាច់ត្រូវបង្កើតនូវទម្រង់ការនៃការ ដំណើរការ ដែលបង្កើតឲ្យមាននូវគណៈកម្មាធិ ការបណ្តោះអាសន្ន ដើម្បីដោះស្រាយបីបញ្ហា ប្រឈមនានា នៃការកំណត់ប្រភពនានា នៃការ ផ្តល់មូលនិធិ។ សមាសធាតុពីរនៅក្នុងយន្តការ បច្ចេកវិទ្យាដូចជា គណៈកម្មាធិការបច្ចេកវិទ្យា និងមជ្ឈមណ្ឌល និងបណ្តាញបច្ចេកវិទ្យា។ គណៈកម្មាធិការបច្ចេកវិទ្យា គឺដើម្បីផ្តល់ជា គោលការណ៍ណែនាំ និងការគាំទ្រផ្នែកបច្ចេក ទេស ដល់មជ្ឈមណ្ឌលបច្ចេកវិទ្យា។ ចំពោះ បញ្ហាមិនទាន់សម្រេច ឬដោះស្រាយដែលត្រូវ ការយកចិត្តទុកដាក់នោះ គឺអនាគតនៃពិធីសារ ក្យូតូ ទិដ្ឋភាពខាងផ្លូវច្បាប់នៃលទ្ធផលផែនទី បង្ហាញផ្លូវក្រុងបាលី កិច្ចសន្យាតាមផ្លូវច្បាប់ និង របៀបកាត់បន្ថយគំលាតនៃការបញ្ចេញ ដែល ទាំងអស់នេះ គឺជាបញ្ហាចម្បងៗនៅក្នុងកិច្ចប្រជុំ កាន់គុន។

កិច្ចចរចារការប្រែប្រួលអាកាសធាតុមានលក្ខណៈស្មុគ្រស្មាញ ដោយសារមានស្ថាប័នច្រើនដែលមានសមាសធាតុច្រើន។ ស្ថាប័នជាច្រើនស្ថិតនៅក្រោម UNFCCC ហើយពួកគេមានអន្តរទំនាក់ទំនងជាមួយគ្នា នៅក្នុងកិច្ចពិភាក្សា និងនៅពេលចរចារ។ ស្រដៀងគ្នានេះដែរ នៅក្នុងដំណើរការនៃការចរចារមានការបែងចែកជាក្រុមសំខាន់ៗជាច្រើនផ្នែកដូចជា G77 &ចិន LDCs EU OPEC ជាដើម។

នៅក្នុងកិច្ចព្រមព្រៀងកូប៉េនហាក់ មានការសន្យាកាត់បន្ថយ GHGs ដែលប្រទេសមួយចំនួនបានធ្វើកិច្ចសន្យា។ ជាដំបូងមានប្រទេសចំនួន ១០៦ បានគាំទ្រដល់កិច្ចព្រមព្រៀងកូប៉េនហាក់ និងបានកើនឡើងដល់ ១១៧ នៅពេលដែលសមាជិកចំនួន៧២ មានផែនការជាក់លាក់របស់ជាតិ សម្រាប់កាត់បន្ថយការបញ្ចេញ និងអាចកាត់បន្ថយការបញ្ចេញដល់ពីចន្លោះ ៥៩,៧ ទៅ ៥១,៥ ពាន់លានតោន នៅឆ្នាំ២០២០។ ផ្ទុយទៅនេះ មូលនិធិចំនួន៥០ពាន់លានដុល្លា សហរដ្ឋអាមេរិក សម្រាប់ការកាត់បន្ថយអាចនឹងកាត់បន្ថយការបញ្ចេញមកត្រឹមកម្រិត ៥៨ពាន់លានតោន។

ក្នុងសេណារីយ៉ូ BAU ការបញ្ចេញឧស្ម័ននឹងកើនដល់ ៥៥,៦៥ $GtCO_2e$ ហើយនៅក្នុងសេណារីយ៉ូរក្សាកំណើនសីតុណ្ហភាពត្រឹម ២°C នោះការបញ្ចេញឧស្ម័នត្រូវត្រឹមតែ៥៥$GtCO_2e$។ ក្នុងន័យ សក្តានុពលការកាត់បន្ថយការបញ្ចេញតាមកិច្ចសន្យានៅក្នុងកិច្ចព្រមព្រៀងកូប៉េនហាក់ បើតាមសេណារីយ៉ូ BAU នឹងមាន ១០៥៥ppm គិតជាមាឌនៃCO_2e នៅឆ្នាំ២១០០ បើធ្វើតាមការសន្យាកម្រិតទាប នោះកំហាប់នឹងស្មើនឹង ៥៩០ ppm ចំណែកការសន្យាកម្រិតខ្ពស់នឹងមានកំហាប់ស្មើនឹង ៤៨៧ ppm គិតជាមាឌនៃ CO_2e។ ចំពោះការវិនិយោគទុនដើម្បីកាត់បន្ថយការបញ្ចេញ GHGs ត្រូវការមូលនិធិសម្រាប់កាត់បន្ថយជាច្រើនប្រមាណជា ២០០ពាន់លានដុល្លាអាមេរិក។

លោក **Mozahurul Alam** បាននិយាយថា យើងកំពុងគ្រោងឈានដល់កម្រិតណា គឺអាស្រ័យលើ តើមានវិធីកាត់បន្ថយបែបណាខ្លះសម្រាប់ពេលអនាគត។ មានបញ្ហាសំខាន់ពីរគឺ ការកាត់បន្ថយ នឹងកើតឡើងឆាប់រហ័សកម្រិតណា និងនៅពេលដែលកម្រិតខ្ពស់បំផុតកើតឡើង។ គម្លាតដោយគ្មានចំណាត់ការ (BAU) នឹងបញ្ចេញ ១២$GtCO_2e$ នៅពេលផ្លាស់ប្តូរពី BAU ទៅការសន្យាដោយគ្មានលក្ខខណ្ឌ (មហិច្ឆតាកម្រិតទាប) នឹងកាត់បន្ថយបាន ៣$GtCO_2e$ ហើយបើ រំកិលពីការសន្យាដោយគ្មានលក្ខខណ្ឌទៅការសន្យាមានលក្ខខណ្ឌ (មហិច្ឆតាកម្រិតខ្ពស់) នឹងកាត់បន្ថយពី២ ទៅ៣$GtCO_2e$។ ជាមួយនឹងក្របខណ្ឌការធានា ឲ្យមានបទវិធានគឺងតែងជុំវិញការប្រើប្រាស់ដី/ការគណនា លើការប្រើប្រាស់ព្រៃឈើ និងឯកតានៃការបញ្ចេញដែលលើសនឹងកាត់បន្ថយពី ១ ទៅ២$GtCO_2e$។ ការកាត់បន្ថយសរុបអាចប្រហែលជា ៧$GtCO_2e$ នៅពេលដែលគម្លាតដែលនៅសល់មានត្រឹមតែ ៥$GtCO_2e$។ ជម្រើសចម្បងៗសម្រាប់កាត់បន្ថយគម្លាតមានដូចជា៖

- បង្កើនមហិច្ឆតានៅក្នុងចំណុចគោលដៅរបស់ប្រទេសនីមួយៗ ជាពិសេសប្រទេសអភិវឌ្ឍន៍
- គោលដៅការបញ្ចេញថ្នាក់ជាតិរបស់ DCs ដែលអនុវត្តបានល្អជាង
- ការកាត់បន្ថយក្នុងវិស័យនានាដែលមិនមានការគិតនៅក្នុងចំណុចគោលដៅជាតិ ឧទាហរណ៍ ផ្នែកអាកាសចរណ៍អន្តរជាតិ និងនាវាចរសមុទ្រ
- សកម្មភាពបំពេញបន្ថែមឲ្យសំខាន់ៗ សម្រាប់ការដោះស្រាយកត្តាអាកាសធាតុដែលមានអាយុកាលខ្លី ឧទាហរណ៍ កាបូនខ្មៅ អូសូននៅ

មណ្ឌលអាកាសរចល់ និងឧស្ម័ន ផ្សេងៗ ទៀតដូចជា HCFCs HFCs ។ល។

សេចក្តីពង្រាងគោលជំហររបស់កម្ពុជា ស្រមាប់ដំណើរឆ្ពោះទៅកាន់ខួបទាន អាហ្រ្វិកខាងត្បូង

*ដោយលោក **ស៊ុំ ឆី** ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជាអ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ សម្រាប់ការអភិវឌ្ឍន៍គោលនយោបាយប្រែប្រួលអាកាសធាតុនិងការគ្រងគ្រងចំណេះដឹងនៃ MoE*

បទបង្ហាញនេះ បានចង្អុលបង្ហាញពីពង្រាងគោលជំហររបស់កម្ពុជានៅក្នុង CoP១៧ ដែលនឹងត្រូវបានបង្ហាញ និងពិភាក្សានៅក្នុងកិច្ចប្រជុំក្នុងខែវិច្ឆិកាឆ្នាំនេះ។

លោក **ស៊ុំ ឆី** បានលើកឡើងថា វេទិកាលើកទី២នេះនឹងផ្តល់នូវលទ្ធផលបន្ថែម ដើម្បីពង្រឹងគោលជំហររបស់កម្ពុជា ឆ្ពោះទៅកាន់ CoP១៧ ក្នុងទីក្រុងឌូបាន។ មានបញ្ហាសំខាន់ៗជាច្រើននឹងត្រូវបានពិភាក្សាក្នុងព្រឹត្តការណ៍ខាងមុខនេះ ដែលក្នុងនោះពិធីសារក្យូតូ ក៏ជាប្រធានបទក្នុងការពិភាក្សានៅ CoP១៧ ផងដែរអំពីជោគវាសនារបស់វានៅក្រោយឆ្នាំ២០១២។

លោក **ស៊ុំ ឆី** បានបង្ហាញ និងបកស្រាយពីពង្រាងគោលជំហររបស់កម្ពុជា ដែលរួមមាន៖ ការបន្សាំ និងមធ្យោបាយពាក់ព័ន្ធសម្រាប់ការអនុវត្តន៍ការកាត់បន្ថយ និងមធ្យោបាយពាក់ព័ន្ធ សម្រាប់ការអនុវត្តធនធានហិរញ្ញវត្ថុ ការអភិវឌ្ឍ និងការផ្ទេរបច្ចេកវិទ្យា និងការកសាងសមត្ថភាព។

ដើម្បីជាការចាប់ផ្តើម លោក **ស៊ុំ ឆី** បានបញ្ជាក់ថា ការបន្សាំ និងមធ្យោបាយពាក់ព័ន្ធសម្រាប់ការអនុវត្តន៍ ក៏ដូចជាការកាត់បន្ថយ និងមធ្យោបាយពាក់ព័ន្ធសម្រាប់ការអនុវត្ត ត្រូវតែមានការយកចិត្តទុកដាក់ស្មើៗគ្នាសម្រាប់របបអាកាសធាតុនាពេលអនាគត។ កម្ពុជាស្វាគមន៍នូវក្របខណ្ឌបន្សាំ ដែលបានបង្កើតឡើងនៅក្រុងកាន់គុន និងមាត្រាទាំងឡាយស្តីពីដំណើរការសម្រាប់ DCs ដើម្បីបង្កើត និងអនុវត្តផែនការបន្សាំជាតិ (NAP) ដើម្បីដោះស្រាយ មិនត្រឹមតែសកម្មភាពបន្ទាន់ភ្លាមៗ រយៈពេលខ្លីប៉ុណ្ណោះទេ ប៉ុន្តែទាំងសកម្មភាពរយៈពេលវែង និងមធ្យមផងដែរ នៅតាមមូលដ្ឋានជាក់ស្តែង និងការកំណែទម្រង់គោលនយោបាយ ដើម្បីគាំទ្រសកម្មភាពទាំងនេះ។ NAP គួរតែផ្អែកលើអាទិភាពរបស់ប្រទេស និងមានភាពបត់បែនសម្រាប់ការកែសម្រួល។ CoP១៧ ត្រូវអនុម័តគោលការណ៍ណែនាំ និងគំរូនានាដែលអនុញ្ញាតិឲ្យ LDCs បង្កើត និងអនុវត្ត NAPសម្រាប់រយៈពេលវែង និងមធ្យម។ កម្ពុជា គាំទ្រដល់គណៈកម្មាធិការបន្សាំ ដែលបង្កើតក្រោមសមត្ថកិច្ចនៃ CoP និងអំពាវនាវឲ្យមានការអនុវត្តឆាប់រហ័សនៅទីក្រុងឌូបាន។ ការអនុវត្តសកម្មភាពបន្សាំគួរតែមានការបំពេញចំណាយទាំងស្រុង ដោយពុំចាំបាច់តម្រូវឲ្យមានតម្លៃបន្ថែម ឬថវិកាបដិភាគ ដែលសុទ្ធតែជាការប្រឈមចំពោះ DCs ឧទាហរណ៍ គម្រោងGEF នៅកម្ពុជា។ យន្តការបន្សាំសម្រាប់ DCs គួរតែត្រូវបានបង្កើតក្នុងន័យ GCF និងមជ្ឈមណ្ឌលបន្សាំអន្តរជាតិ និងមជ្ឈមណ្ឌលបន្សាំថ្នាក់តំបន់គួរតែត្រូវបានបង្កើត ដើម្បីផ្តល់ការគាំទ្រនិងធាតុចូល សម្រាប់ការយល់កាន់តែប្រសើរពី បញ្ហាទាក់ទងនឹងផលប៉ះពាល់ភាពងាយរងគ្រោះ និងផលប៉ះពាល់នឹងការប្រែប្រួលអាកាស ធាតុ។

ចំពោះការកាត់បន្ថយ កម្ពុជាគាំទ្រការប្តេជ្ញាចិត្តលើកទីពីររបស់ពិធីសារក្យូតូ នៅខណៈដែលប្រទេសផ្សេងទៀត ចង់ឲ្យមានយន្តការផ្សេងទៀត។ ភាគីនៅក្នុងឧបសម្ព័ន្ធ I ទាំងអស់ត្រូវមានកាតព្វកិច្ចតាមផ្លូវច្បាប់ ក្នុងការកាត់បន្ថយ ឬសកម្មភាពបន្ថែម ដោយពិចារណាផងដែរពីគោលការណ៍នៃអនុសញ្ញា ដើម្បីកាត់បន្ថយ

ការបញ្ចេញ GHGs យ៉ាងហោចណាស់ក្រោម ៤០% នៅក្រោមកម្រិតឆ្នាំ១៩៩០ គិតរហូតដល់ឆ្នាំ២០២០ និងយ៉ាងហោចណាស់ក្រោម ៩៥% នៅក្រោមកម្រិតឆ្នាំ១៩៩០ គិតរហូតដល់ឆ្នាំ ២០៥០ ដើម្បីប្រាកដថា កំហាប់ GHGs និងអាវ៉ូ សូលស្ថិតនៅក្រោម ៣៥0ppm CO_2e និង កំណើនសីតុណ្ហភាពនៅក្រោម១,៥°C។ ការប្តេ ជ្ញាដើម្បីកាត់បន្ថយត្រូវតែអាចវាស់វែងបាន អាច រាយការណ៍បាន និងអាចផ្ទៀងផ្ទាត់បាន (MRV) ដែលស្របតាមយន្តការកាតព្វកិច្ច ដូចដែលបាន អនុម័តដោយភាគីនីមួយៗ។ ភាគីមិននៅក្នុងឧប សម្ព័ន្ធ I ត្រូវចាត់វិធានការកាត់បន្ថយ ដោយ ស្មគ្រ័ចិត្តស្របតាមគោលការណ៍ និងមាត្រា ដែលមានចែងក្នុងអនុសញ្ញានេះ។ ទោះបីជា យ៉ាងនេះក៏ដោយ DCs ភាគច្រើនគួរតែបង្ហាញ ឆន្ទៈដើម្បីកាត់បន្ថយការបញ្ចេញរបស់ខ្លួនដោយ ស្មគ្រ័ចិត្ត ដើម្បីរួមចំណែកក្នុងការសម្រេចគោល ដៅនៃការកាត់បន្ថយការបញ្ចេញ ជាសកល។ លើសពីនេះទៅទៀត កិច្ចខិតខំប្រឹងប្រែងកាត់ បន្ថយរបស់ DCS គួរតែជាការស្មគ្រ័ចិត្ត និងបាន ទទួលការគាំទ្រមូលនិធិពេញលេញ បច្ចេកវិទ្យា ហិរញ្ញប្បទាន និងការកសាងសមត្ថភាព ដែល គួរតែផ្តល់ដោយប្រទេសអភិវឌ្ឍន៍ ។ NAMA ដោយភាគីនៃ DCs គឺជាសកម្មភាពស្មគ្រ័ចិត្ត ដែលកំណត់ និងបង្កើតឡើង ដោយយកស្ថាន ភាពជាតិមកពិចារណា នៅក្នុងបរិបទនៃការអភិ វឌ្ឍប្រកបដោយចីរភាព និងអាចគាំទ្រតាមរយៈ ហិរញ្ញវត្ថុ បច្ចេកវិទ្យា និងការកសាងសមត្ថភាព ពីភាគីប្រទេសអភិវឌ្ឍន៍ ក្នុងភាព MRV ។ កម្ពុជា មើលឃើញថា ក្នុងអំឡុងប៉ុន្មានឆ្នាំកន្លងមកនេះ ការសម្រេចចិត្តពី REDD+ ត្រូវបានពន្យាពេល ទោះជាប្រទេសអភិវឌ្ឍន៍ និង DCs បានត្រៀម ខ្លួនជាស្រេចសម្រាប់ដំណើរការទៅមុខ។ កម្ពុជា ចង់ឃើញការសម្រេច នៅក្នុងកិច្ចពិភាក្សានានា និងជម្រុញឲ្យមានសកម្មភាព និងហិរញ្ញវត្ថុ REDD+ ឲ្យបានពេញលេញ។

ចំពោះធនធានហិរញ្ញវត្ថុ កម្ពុជាគាំទ្រការ ផ្តល់ជូនហិរញ្ញវត្ថុថ្មីបន្ថែម និងដែលអាចព្យា ករណ៍បានពីប្រភពសាធារណៈ ពីសំណាក់ភាគី នៅក្នុងឧបសម្ព័ន្ធ I មិនមែនមកពី ODA។ វិភាគ ទានពីភាគីនីមួយៗ ដែលមាននៅក្នុងឧបសម្ព័ន្ធ II គួរតែគិតពិចារណាផងដែរពីទំនួលខុសត្រូវជា ប្រវត្តិសាស្ត្រ និងគោលការណ៍នៃអនុសញ្ញា នេះ។ លោកបានបង្ហាញថា កន្លងមកមូលនិធិ ដែលត្រូវការសម្រាប់បន្សាំ និងការកាត់បន្ថយ ការប្រែប្រួលអាកាសធាតុ មិនត្រូវជាមូលនិធិ ជំនួយទេ ប៉ុន្តែជាការបេជ្ញាចិត្តដូចដែលបាន បញ្ជាក់នៅក្នុងអនុសញ្ញានេះ។ ឧទាហរណ៍ ការ ពង្រីកការប្តេជ្ញាចិត្ត សម្រាប់សកម្មភាពការប្រែ ប្រួលអាកាសធាតុ ត្រូវទទួលបានយ៉ាងហោច ណាស់ ១,៥% នៃGDP ប្រចាំឆ្នាំពីប្រទេសអភិ វឌ្ឍន៍នីមួយៗ និងក្នុងនោះ ៧0% នៃមូលនិធិ សរុបនេះត្រូវបែងចែក សម្រាប់សកម្មភាពបន្សាំ ។ កម្ពុជាស្វាគមន៍ការបង្កើត GCF និងអំពាវនាវ ឲ្យមានប្រតិបត្តិការបន្ទាន់ សម្រាប់មូលនិធិអា កាសធាតុនេះ។ ហិរញ្ញវត្ថុបដិភាគមិនគួរក្លាយ ជារបាំង ឬលក្ខខណ្ឌសម្រាប់ការទទួលបានមូល និធិនេះឡើយ។

ដើម្បីការអភិវឌ្ឍ និងបន្ទេរបច្ចេកវិទ្យា កម្ពុជា គាំទ្រឲ្យមានការវាយតម្លៃតម្រូវការបច្ចេក វិទ្យា ជាពិសេសតម្រូវការជាបន្ទាន់ដើម្បីការអភិ វឌ្ឍ និងបន្ទេរបច្ចេកវិទ្យាសម្រាប់ការបន្សាំក្នុង គ្រប់ភាគី DCs។ កម្ពុជាក៏ស្វាគមន៍ផងដែរនូវការ បង្កើតយន្តការបច្ចេកវិទ្យាអន្តរជាតិកាន់តែ ដំណើរការ នៅក្រោមសមត្ថកិច្ចរបស់ CoP ។ កម្ពុជា គាំទ្រនូវការបង្កើតគណៈកម្មការប្រតិបត្តិ ផ្នែកបច្ចេកវិទ្យា (TEC) និងមជ្ឈមណ្ឌល និង បណ្តាញបច្ចេកវិទ្យាអាកាសធាតុ (CTCN) គាំទ្រ ការផ្តល់នូវហិរញ្ញវត្ថុ និងការកសាងសមត្ថភាព ដែលចាំបាច់ និងភ្លាមៗ ដើម្បីអភិវឌ្ឍផែនការ សកម្មភាពជាតិស្តីពីបច្ចេកវិទ្យា រាប់បញ្ចូលទាំង តាមរយៈមជ្ឈមណ្ឌល និងបណ្តាញបច្ចេកវិទ្យា

អាកាសធាតុ និងគាំទ្រវិធានការជាក់លាក់ និងបន្ទាន់ ដើម្បីលុបបំបាត់របាំងដែលកើតចេញពីកម្មសិទ្ធិបញ្ញានៅក្នុង DCs និង LDCs ពីបច្ចេកវិទ្យាមិនប៉ះពាល់បរិស្ថាន។

ជាចុងក្រោយគឺ ការកសាងសមត្ថភាព កម្ពុជាគាំទ្រឲ្យមានការបង្កើនសកម្មភាព កសាងសមត្ថភាព ដើម្បីបង្កើនសមត្ថភាព និងលទ្ធភាពរបស់ DCs។ ការកសាងសមត្ថភាព គួរតែជាដំណើរការជាបន្តបន្ទាប់ស្របតាមតម្រូវការរបស់ប្រទេសនីមួយៗ ការចូលរួម និងដើម្បីពង្រឹងសកម្មភាព សម្រាប់ផ្នែកទាំងអស់នៃផែនការសកម្មភាពក្រុងបាលី។

សំណួរ និងចម្លើយ

លោក **Geoffrey Blade** ទីប្រឹក្សានៃការប្រែប្រួលអាកាសធាតុ កម្មវិធីទន្លេមេគង្គរបស់អង្គការWWF មានចម្ងល់ថាតើលោក Valdemar Holmgren មានបានសង្កេតលើផែនការសម្រាប់កិច្ចសហប្រតិបត្តិការអន្តរជាតិដែរឬទេ? ឧទាហរណ៍នៅប្រទេសឥណ្ឌា និងបង់ក្លាដេស ទើបតែចុះហត្ថលេខាលើកិច្ចព្រមព្រៀង សម្រាប់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ថ្នាក់តំបន់ ឬផែនទីបង្ហាញផ្លូវ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុរួមគ្នា។ បញ្ហានេះ ស្រដៀងទៅនឹងតំបន់មេគង្គដែរ ដូច្នេះវាគួរតែត្រូវបានពិចារណាក្នុងតំបន់។ រចនាសម្ព័ន្ធមានស្រាប់ដូចជានៅ MRC ADB កម្មវិធី GMS ដែលអាចផ្តល់ជា យន្តការឬក្របខណ្ឌ សម្រាប់កិច្ចសហប្រតិបត្តិការថ្នាក់តំបន់បាន។ ដូច្នេះលោកឆ្ងល់ថា ប្រសិនបើលោក **Valdemar Holmgren** អាចផ្តល់ជាយោបល់ទៅលើ កិច្ចសហប្រតិបត្តិការនេះ និងផលប្រយោជន៍ពីកិច្ចសហការប្រតិបត្តិការ ជាអន្តរជាតិស្តីពី ការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុមានអ្វីខ្លះ?

លោក **Valdemar Holmgren** បានទទួលស្គាល់ថា អ្វីដែលបានកើតឡើងនៅកម្ពុជា គឺមានភាពធ្ងន់ធ្ងរប្រហែលគ្នានឹង LDCs ជាមួយនឹងភាពដែលពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច-សង្គម ស្រដៀងគ្នា។ ទោះបីជាយ៉ាងនេះក៏ដោយ យុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុត្រូវតែចាប់ផ្តើមស្របនឹងអាទិភាពជាតិ ដើម្បីឲ្យស្របនឹងយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដែលប្រទេសនីមួយៗ មានជាបញ្ហាចម្បងៗ ដើម្បីដោះស្រាយនិងត្រូវការពេលវេលាបន្ទាន់ រយៈពេលមធ្យម ឬរយៈពេលវែង។ ដូច្នេះ ការសំខាន់ត្រូវមើលទៅលើអ្វីខ្លះដែលមានចែងក្នុងផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ឧទាហរណ៍ NSDP (បច្ចុប្បន្នកម្ម) នៅកម្ពុជា។ មានលក្ខណៈស្រដៀងគ្នាទៅនឹងប្រទេសជាច្រើន និងការទទួលស្គាល់ពីតម្រូវការនៃការប្រែប្រួលអាកាសធាតុ នៅក្នុងផែនការអភិវឌ្ឍជាតិ។ បញ្ហាជាអាទិភាពត្រូវបានកំណត់នៅកម្រិតថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ហើយដើម្បីយល់ឲ្យកាន់តែច្បាស់ថា បញ្ហាអ្វីខ្លះដែលចែករំលែកនៅថ្នាក់តំបន់។

យុទ្ធសាស្ត្រនេះ មិនត្រឹមតែស្របជាមួយនឹងយុទ្ធសាស្ត្រជាតិប៉ុណ្ណោះទេ ប៉ុន្តែវាស្របជាមួយនឹងយុទ្ធសាស្ត្រថ្នាក់តំបន់ និងអន្តរជាតិផងដែរ។ វិធីដ៏ឆាប់រហ័សបំផុតនោះ គឺចាប់ផ្តើមកំណត់នូវអាទិភាពជាតិ និងគោលនយោបាយជាតិ ដែលទាក់ទងនឹងគោលនយោបាយរបស់ដៃគូ ឬគោលនយោបាយថ្នាក់តំបន់ ឧទាហរណ៍ MRC ហើយជាផលល្អនោះគឺ បណ្តាញនេះដែលកើតមានរួចហើយនៅក្នុងតំបន់នេះ។

លោក **Alex Heikens** មកពីមជ្ឈមណ្ឌលតំបន់នៃ UNDP បានផ្តល់នូវយោបល់ខ្លះៗទៅលើបទបង្ហាញថា ប្រសិនបើមើលទៅលើវិសាលភាពនៅក្នុងតំបន់ មានបញ្ហាមួយចំនួនមានភាពចាំបាច់ ប៉ុន្តែនៅមានភាពខ្វះចន្លោះ។ យុទ្ធសាស្ត្រភាគច្រើន ពុំមានផែនការហិរញ្ញវត្ថុច្បាស់លាស់ តែគេអាចផ្តល់ជាតួលេខសរុបនៃការចំណាយ ប៉ុន្តែគេមិនអាចបញ្ជាក់ពីសូចនករនា

នាថា តើគេគ្រោងចល័ត និងផ្តល់នូវធនធានយ៉ាងណានោះទេ ហើយការអនុវត្តន៍វិញ ជាទូទៅពុំមានភាពច្បាស់លាស់ឡើយ ដោយផ្តោតលើវិស័យនានាតាមក្រសួង ឬរដ្ឋាភិបាលនៅមូលដ្ឋាន។ នេះគឺជាភាពខ្សោយនៃយុទ្ធសាស្ត្រទាំងនោះ ប៉ុន្តែអ្វីដែលមិនឃើញមាននៅក្នុងយុទ្ធសាស្ត្រភាគច្រើនទាំងនោះគឺ ក្របខណ្ឌតាមដាន។ នៅហ្វីលីពីន យុទ្ធសាស្ត្ររបស់គេគួរឲ្យចាប់អារម្មណ៍ ព្រោះវាមានភាពច្បាស់លាស់ក្នុងចំណុចភាគច្រើន ដូចនេះយើងគួរតែសិក្សាបន្ថែមទៀតពីករណីនៃប្រទេសនេះ ដោយក្របខណ្ឌផ្លូវច្បាប់ត្រូវបានបង្ហាញយ៉ាងច្បាស់ ហើយគេក៏បានបង្កើត ឬស្ថិតក្នុងដំណើរការបង្កើតមូលនិធិអាកាសធាតុជាតិដើម្បីគាំទ្រដល់ការអនុវត្តន៍នូវផែនការយុទ្ធសាស្ត្រនេះ។ គេគិតគួរពីបញ្ហាហិរញ្ញវត្ថុយ៉ាងហ្មត់ចត់។ មានចំណុចមួយចំនួនដែលត្រូវពិចារណា សម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់កម្ពុជា ដូចជា៖ ផែនការហិរញ្ញវត្ថុ សមាសធាតុនៃការអនុវត្ត និងក្របខណ្ឌតាមដាន ជាមួយនឹងការពិចារណាបន្ថែមខ្លះទៀត។

លោក **Valdemar Holmgren** បានសាទរជាមួយនឹងព័ត៌មានបន្ថែម ដែលផ្តល់ឲ្យដោយលោក **Alex** ថាកង្វះខាតផ្នែកហិរញ្ញវត្ថុនៅក្នុងផែនការយុទ្ធសាស្ត្រ គឺដោយសារភាពលំបាកនៅក្នុងការរៀបចំទិដ្ឋភាពហិរញ្ញវត្ថុ។ ប្រទេសជាច្រើន កំពុងព្យាយាមដោះស្រាយបញ្ហាហិរញ្ញវត្ថុនេះ ហើយនៅកម្ពុជាយើង ទើបតែចាប់ពិចារណាពីវិធីសាស្ត្រណាមួយ ដែលល្អបំផុតសម្រាប់កម្ពុជា។ CCCA បានបង្កើតគម្រោងគំរូ ដែលអាចជាគំរូដ៏រឹងមាំមួយ ហើយត្រូវការយន្តការផ្នែរដែលអាចក្លាយជាដំណើរហិរញ្ញប្បទានប្រែប្រួលអាកាសធាតុជាតិ។ វាចាំបាច់ណាស់ដែលយើងត្រូវគិតគូរបញ្ហានេះពីដំបូង ដើម្បីជៀសវាងការខាតបង់ពេលវេលា ដែលនេះជាអ្វីដែលគាត់ (Valdemar Holmgren) កំពុងធ្វើការនៅ CCCA ក្នុងនាមជាជំនាញការ។ នៅកម្ពុជាមានមូលនិធិរួចហើយ ប៉ុន្តែវាមិនទាន់ជាគំរូមួយ ដែលសមស្របក្នុងការអនុវត្តន៍គ្រប់គម្រោងទាំងអស់នោះទេ។ យើងក៏កំពុងធ្វើការលើមធ្យោបាយក្នុងការផ្ទេរហិរញ្ញប្បទានពីថ្នាក់ជាតិ ទៅថ្នាក់មូលដ្ឋាន ដើម្បីគាំទ្រដល់សកម្មភាពនានា ក្នុងការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ។

លោកស្រីបណ្ឌិត **ម៉ក់ សុឃន** អ្នកប្រឹក្សារបស់ MRC បានបញ្ជាក់ថា យោងទៅលើសុន្ទរកថារបស់លោក **Rafael Dochao Moreno** ថាការប្រែប្រួលអាកាសធាតុ គឺជាការព្រួយបារម្ភរបស់បុគ្គលគ្រប់រូប និងត្រូវតែរួមគ្នាក្នុងការកាត់បន្ថយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ ដូចនេះ បុគ្គលគ្រប់រូបគួរតែចូលរួមក្នុងការធ្វើផែនការយុទ្ធសាស្ត្រផងដែរ ដែលការចូលរួមនេះអាចធានាបានថា បុគ្គលគ្រប់រូបមានការប្តេជ្ញាចិត្ត និងគំនិតយោបល់របស់ពួកគេ ត្រូវបានគិតគូរ សម្រាប់ការបញ្ចូលទៅក្នុងផែនការយុទ្ធសាស្ត្រ។

លោក **Valdemar Holmgren** បានឆ្លើយតបថា លោកមានការជឿជាក់ថាប្រទេសទាំងអស់ក្នុងតំបន់ទន្លេមេគង្គទទួលបានការទាមទារពីវិស័យសាធារណៈ និងស្ថាប័ននានា ថាត្រូវតែឲ្យមានការចូលរួមពីអ្នកពាក់ព័ន្ធនានា។ គំនិតនេះ គឺច្បាស់ណាស់នៅកម្ពុជា ដោយសារតែការប្រែប្រួលអាកាសធាតុ ជះឥទ្ធិពលដល់ថ្នាក់មូលដ្ឋាន ដែលជាកន្លែងនៃគោលគំនិតទាំងនេះដែលត្រូវពង្រាង និងអនុវត្ត។ ឧទាហរណ៍ នៅប្រទេសថៃ ការអភិវឌ្ឍមានការចូលរួមពីសាធារណជន ក្នុងការបញ្ចេញមតិរបស់ខ្លួនក្នុងការបង្កើតយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុ និងការសម្រេចបាននូវផែនការមេ។

លោក **ខែន ទីរៈ** អនុប្រធានមន្ទីរបរិស្ថាន ខេត្តកំពត បានលើកឡើងថា លោក

Valdemar Holmgren បានផ្តល់ជាអនុសាសន៍ផ្សេងៗនៃ CCSP សម្រាប់កម្ពុជា ដែលយោងទៅករណីសិក្សាពីប្រទេសថៃ ឥណ្ឌា វៀតណាម ហ្វីលីពីន និងបង់ក្លាដេស។ ដោយសារតែស្ថានភាពប្រទេសខុសៗគ្នា ឧទាហរណ៍ សេដ្ឋកិច្ច និងការអប់រំ តើអ្នកគិតថាអនុសាសន៍ទាំងនេះសមស្របទៅនឹងបរិបទកម្ពុជាបច្ចុប្បន្នដែរឬទេ?

លោក Valdemar Holmgren បានលើកឡើងថា ជាការពិតណាស់ការងារចុងក្រោយ គឺការរៀបចំផែនការយុទ្ធសាស្ត្រ សម្រាប់កម្ពុជា ប៉ុន្តែ ការមើលទៅលើបទពិសោធន៍ ពីប្រទេសផ្សេងៗ គឺមានសារសំខាន់ណាស់ ដើម្បីយល់ពីធាតុចូលចម្បងៗ ស្តាប់ឥទ្ធិពលខុសត្រូវ រចនាសម្ព័ន្ធការងារថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលទាំងអស់នេះអាចត្រូវបានវិភាគ និងបកប្រែឲ្យស្រមទៅនឹងស្ថានភាពកម្ពុជា ទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ព្រោះកម្ពុជាទើបតែចាប់ផ្តើមរៀបចំយុទ្ធសាស្ត្ររបស់ខ្លួន។ ចាំបាច់ណាស់ក្នុងការធ្វើការ ជាមួយនឹងអ្វីដែលកម្ពុជាមានស្រាប់ ដូចជា ប្រព័ន្ធដែលគិតលើលក្ខខណ្ឌអភិបាលកិច្ច សមត្ថភាពស្ថាប័ន/ជំនាញការជាដើម។ ការបង្កើតក្រុមមូលដ្ឋាននៅកម្ពុជាឲ្យទទួលការងារគឺមានសារសំខាន់ណាស់ ដូចនៅឥណ្ឌាមានសេណារីយ៉ូខុសៗគ្នា ជាមួយនឹងប្រជាជនខ្ពស់ ការរីកចម្រើននៃសេដ្ឋកិច្ច និងសេដ្ឋកិច្ចសង្គម ប៉ុន្តែបញ្ហាការប្រែប្រួលអាកាសធាតុ តែងតែមានភាពដូចគ្នាដែលប៉ះពាល់ទៅលើកសិកម្ម លំហូរទឹកទន្លេ កម្ពស់ទឹក ទឹកជំនន់ និងគ្រោះរាំងស្ងួត។

លោក Christopher មូលនិធិអភិវឌ្ឍមូលធនរបស់ UN ប្រចាំទីក្រុងបាងកក បានលើកឡើងថា ជាទូទៅយុទ្ធសាស្ត្រសំដៅទៅលើអ្វីដែលត្រូវការអនុវត្ត ប៉ុន្តែអ្វីដែលអាចធ្វើឲ្យភាគីពាក់ព័ន្ធអាចអនុវត្តបាន និងអាចអនុវត្តបានដោយរបៀបណា? ទាក់ទងទៅនឹងហិរញ្ញប្បទាន គួរតែផ្តោតទៅលើយុទ្ធសាស្ត្រសម្រាប់កិច្ចសហការណ៍ជាមួយដៃគូ ព្រោះប្រភពមូលនិធិផ្សេងគ្នាបានមកពីដៃគូផ្សេងគ្នា ដូចនេះតើប្រភពហិរញ្ញប្បទានណាគួរប្រើ សម្រាប់ការងារអ្វី? ការណែនាំមួយចំនួន គឺត្រូវការពីយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល ដើម្បីឲ្យដឹងពិតប្រាកដពីអ្វីដែលត្រូវអនុវត្ត ជាមួយអ្នកណា និងកសាងយុទ្ធសាស្ត្រ និងផ្តល់ហិរញ្ញប្បទានសម្រាប់សកម្មភាពនោះ។

លោក Valdemar Holmgren ឆ្លើយតបទៅនឹងអ្វីដែលលោក Christopher បានលើកឡើងថា ទាំងនោះគឺជាសមាសធាតុនៃយុទ្ធសាស្ត្រ ឬផែនការសកម្មភាពនៅកម្ពុជាដែលត្រូវបានហៅថា CCCSP ។ តើសមាសធាតុទាំងនោះ នឹងត្រូវបានអនុវត្តយ៉ាងដូចម្តេច? បញ្ហានេះដំបូង គឺត្រូវធ្វើតាមគោលការណ៍ឯកភាពគ្នានៅគ្រប់លំដាប់ថ្នាក់ទាំងអស់នៃ អភិបាលកិច្ច ហើយនឹងមានកិច្ចប្រជុំពិគ្រោះយោបល់ រវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអ្វីដែលត្រូវអនុវត្តនៅតាមក្រសួងនានា ដើម្បីធានាថាក្រសួងនីមួយៗ ត្រូវឆ្លើយតបភ្លាមៗទៅនឹងរបៀបវារៈនៃការប្រែប្រួលអាកាសធាតុ។ យុទ្ធសាស្ត្រសម្រាប់ដៃគូនីមួយៗគឺ ដើម្បីកំណត់ថាក្រសួងណាត្រូវធ្វើជាមួយដៃគូណា។

តើយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុសម្រាប់កម្ពុជា ត្រូវតែមានការបញ្ជាក់ជាពិសេសឬផ្នែកនៃការងារ សម្រាប់ការកសាងភាពជាដៃគូដែរទេ? នេះត្រូវផ្អែកលើការបង្កើតឡើងឲ្យមាននូវគោលនយោបាយប្រែប្រួលអាកាសធាតុដែលទាក់ទងហើយច្បាស់លាស់ និងដែលមានភាពជឿជាក់បានពី DPs ក្នុងការធ្វើការជាមួយគ្នា។ វិធីសាស្ត្រនេះ កម្ពុជាអាចជ្រោតចូលទៅក្នុងហិរញ្ញប្បទានប្រែប្រួលអាកាសធាតុបាន។

លោក Geoffrey Blate មកពី WWF GMS តើការផ្តល់ឲ្យអ្វីដែលអាចធ្វើបានជាមួយនឹងរចនាសម្ព័ន្ធបច្ចុប្បន្ន ទៅតាមយន្តការដែល

CCCA បានបង្កើតឡើង ដើម្បីធានាថាផែនការគឺអាចបត់បែនបាន។ ដូចដែលបានឃើញរួចមកហើយថា ប្រហែលជាមានភាពមិនប្រាកដប្រជា និងប្រភេទនៃហានិភ័យជាច្រើនទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងបរិបទនៃការប្រែប្រួលអាកាសធាតុ មានសារសំខាន់ណាស់ក្នុងការធានាឲ្យមាននូវភាពបត់បែន ដូចនេះ តើវាជាអាទិភាពឬ?

លោក **Valdemar Holmgren** បាននិយាយថា ចំណុចដែលបានលើកឡើងដោយលោក Blate ពិតជាមានសារសំខាន់ណាស់ ដោយសារតែ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមិនដូចគ្នានៅពេលអនាគត (ឧទាហរណ៍ នៅឆ្នាំ២០១៣ ឬ២០១៥) ដូចដែលបានកើតឡើងនៅក្នុងឆ្នាំ២០១១ ។ ដូច្នេះ យន្តការដែលមានភាពបត់បែនបាន ពិតជាមានសារសំខាន់ ប៉ុន្តែចំពោះមូលហេតុនៃអភិបាលកិច្ចវិញ គឺវាមានលក្ខណៈសមហេតុផលផងដែរ ក្នុងការនិយាយថា ផែនការយុទ្ធសាស្ត្រការប្រែប្រួលអាកាសធាតុនឹងមានសុពលភាព ចំពោះរចនាសម្ព័ន្ធជាក់លាក់មួយ និងពេលវេលាកំណត់ណាមួយ ហើយតម្រូវឲ្យមានការកែតម្រូវ និងពិនិត្យឡើងវិញក្នុងករណីចាំបាច់។

លោក **Aren** មកពី WOMEN បានលើកឡើងថា លោក **ឡាយ ឃីម** បានកំណត់នូវវិស័យអាទិភាពជាច្រើន តើមានអភិក្រមណាមួយសម្រាប់សហប្រតិបត្តិការពហុវិស័យ និងថ្នាក់ក្រោមជាតិ ចំពោះបញ្ហាប្រែប្រួលអាកាសធាតុ?

លោក **ឡាយឃីម** បានឆ្លើយតបថា ការសម្របសម្រួលនៅថ្នាក់ក្រោមជាតិ គឺត្រូវធ្វើឡើងតាមរយៈ កម្មវិធីអភិវឌ្ឍប្រជាធិបតេយ្យ ហើយត្រូវការឲ្យមាននូវ យន្តការសម្របសម្រួលមួយនៅថ្នាក់ក្រោមជាតិ និងក្រុមប្រឹក្សាខេត្ត ស្រុកបន្ថែមទៅនឹងក្រុមប្រឹក្សាឃុំ។ ក្រុមប្រឹក្សាទាំងនេះ គឺជាយន្តការដើម្បីប្រមូលផ្តុំនូវវិស័យផ្សេងៗគ្នានៅថ្នាក់ក្រោមជាតិ និងដើម្បីសម្របសម្រួល និងកំណត់គោលនយោបាយ ឬផែនការនានា ក្រោមការត្រួតពិនិត្យដោយផ្ទាល់នៃអភិបាលខេត្ត។ យន្តការនេះមានរួចហើយ និងត្រូវបានអនុវត្ត ប៉ុន្តែចាំបាច់ត្រូវប្រើ និងពង្រឹងយន្តការនេះ សម្រាប់ការងារទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ នៅថ្នាក់ក្រោមជាតិបានទទួលស្គាល់ពី បញ្ហាប្រែប្រួលអាកាសធាតុ និងត្រូវការកម្មវិធីកសាងសមត្ថភាពបន្ថែមទៀត។

លោក **សុខ ពិសិដ្ឋ** មកពី MoWA បានផ្តល់យោបល់ថា គួរតែបញ្ចូលបញ្ហាយេនឌ័រទៅក្នុង CCCSP ព្រោះមិនឃើញមានការពិភាក្សានៅក្នុងបទបង្ហាញរបស់លោក **ឡាយ ឃីម** ។

លោក **ឡាយ ឃីម** បាននិយាយថា ទោះបីជា វិស័យយេនឌ័រមិនត្រូវបានបញ្ចូលក្នុងបទបង្ហាញរបស់លោកក៏ដោយ ប៉ុន្តែមិនមានន័យថា យេនឌ័រត្រូវបានព្រងើយកណ្តើយនោះទេ ហើយមានវិស័យជាច្រើនដូចជា ហេដ្ឋារចនាសម្ព័ន្ធ ការអភិរក្ស ការរិភាគគឺនៅមិនទាន់បានបញ្ចប់នៅឡើយទេ។ នៅពេលអភិវឌ្ឍផែនទីបង្ហាញផ្លូវតាមវិស័យ យើងនឹងមានកាលានុវត្តភាពសម្រាប់ការរិភាគនូវភាពខ្លាំង និងខ្សោយនៃវិស័យទាំងនោះ។

លោក **Manfred** អ្នកប្រឹក្សាបច្ចេកទេសរបស់ PPCR បានផ្តល់ជាយោបល់ជារួមទៅលើបទបង្ហាញទាំងអស់នៃវេទិកាទាំងពីរថ្ងៃកន្លងមកនេះថា នៅមានកង្វះខាតក្នុងការគិតគូរលើ ហេដ្ឋារចនាសម្ព័ន្ធ ដោយលោកសំដៅទៅលើហេដ្ឋារចនាសម្ព័ន្ធ ដែលខ្វះខាតធ្ងន់ធ្ងរ។ ឧទាហរណ៍ ប្រសិនបើយើងធ្វើដំណើរពីភ្នំពេញទៅសៀមរាបប្រមាណសប្តាហ៍មុនៗ យើងនឹងបានឃើញថា ផ្លូវថ្នល់ខ្វះខាតកាន់តែខ្លាំង ហើយប្រសិនបើ

ទឹកជំនន់នៅឆ្នាំក្រោយមានទំហំដូចឆ្នាំនេះ នោះយើងនឹងមិនអាចទៅដល់សៀមរាបតាមផ្លូវគោកទៀតទេ។ ប្រសិនបើយើងធ្វើដំណើរពីសៀមរាបទៅកំពង់ផ្អក គឺគ្មានផ្លូវធ្វើដំណើរទៅបានទេ។ កុមារ ឬក្មេងៗ មិនអាចទៅសាលារៀនបានដោយសារតែសាលាលិចទឹក ស្ត្រីមិនអាចទៅដល់មណ្ឌលសុខភាពទៀតទេ ព្រោះមណ្ឌលសុខភាពលិចទឹកអស់ដែរ។ ទាំងនេះគឺជាហេដ្ឋារចនាសម្ព័ន្ធ ហើយតម្លៃរបស់វាមិនមែនរាប់ម៉ឺនដុល្លា ឬ ២លានដុល្លានោះទេ។ ដូចនេះគឺចាំបាច់ក្នុងការផ្តល់នូវការវិនិយោគ សម្រាប់ហេដ្ឋារចនាសម្ព័ន្ធ ព្រោះវាគឺជាចំណុចកណ្តាលនៃការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ។ លោកមិនជឿថាយុទ្ធសាស្ត្រនានា ដែលចង់ចាត់វិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដោយគ្មានការគិតគូរពីហេដ្ឋារចនាសម្ព័ន្ធ និងហិរញ្ញវត្ថុ ដែលទាក់ទងនឹងបញ្ហានោះទេ។

លោក **ឡាយ ឃីម** យល់ស្របថា ហេដ្ឋារចនាសម្ព័ន្ធ គឺជាផ្នែកមួយដែលមានសារសំខាន់។ ប្រសិនបើក្រឡេកមើលទៅឯកសារ NAPA ប្រហែលជា ៧0% នៃសំណើគម្រោង គឺទាក់ទងទៅនឹងហេដ្ឋារចនាសម្ព័ន្ធ ឧទាហរណ៍ ការកសាងប្រព័ន្ធធារាសាស្ត្រ ការសាងសង់ទំនប់ជាដើម។ សំណើថវិកាប្រហែលជា១៣0 លានដុល្លា ភាគច្រើនទាក់ទងនឹងតម្លៃនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់កម្ពុជា។ ប៉ុន្តែប្រភពនៃមូលនិធិ សម្រាប់កសាងហេដ្ឋារចនាសម្ព័ន្ធសម្រាប់កម្ពុជាដើម្បីបន្សាំនឹងការប្រែប្រួលអាកាសធាតុនោះ នៅមិនទាន់ច្បាស់លាស់នៅឡើយ ដោយសារតែការកសាងហេដ្ឋារចនាសម្ព័ន្ធគឺត្រូវចំណាយខ្ពស់។

លោក **Khter Uzaman Sano** មកពីអង្គការសង្គ្រោះផែនដីកម្ពុជា បានសួរថា តើមានផែនការជាក់លាក់ ឬផែនការតាមបែបបរិមាណវិស័យណាមួយ ដើម្បីបញ្ចូលបញ្ហាយេនឌ័រទៅក្នុងគម្រោង ការគ្រប់គ្រង ឬបញ្ហានានានៃការប្រែប្រួលអាកាសធាតុ ជាឧទាហរណ៍ ការបញ្ចូលស្ត្រីប្រមាណ ១0% ឬ២0% នៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត។ នៅក្នុងបរិបទរបស់កម្ពុជា ចំនួនស្ត្រីសរុបគឺច្រើនជាងបុរស ប៉ុន្តែចំនួនស្ត្រីនៅក្នុងដំណើរការធ្វើការសម្រេចចិត្តមានតែ ៣% ប៉ុណ្ណោះ។

លោក **ឡាយ ឃីម** បាននិយាយថា ការបញ្ចូលបញ្ហាយេនឌ័រ UNDP បានជ្រើសរើសគម្រោងការប្រែប្រួលអាកាសធាតុចំនួន ៥ ដើម្បី បញ្ចូលបញ្ហាយេនឌ័រទៅក្នុងគម្រោងទាំងនោះ។ ដោយតម្រូវឲ្យគម្រោងនីមួយៗ ត្រូវមានផែនការភ្ជាប់នូវការបញ្ចូលបយេនឌ័រ ការកំណត់សកម្មភាព និងសូចនាករណ៍នៃវិស័យយេនឌ័រច្បាស់លាស់។ សង្ឃឹមថានៅឆ្នាំក្រោយ យើងនឹងមានមេរៀនទទួលបានល្អៗបន្ថែម ទាក់ទងនឹងគម្រោងបញ្ចូលបយេនឌ័រទាំងនោះ។

លោក **Khter Uzaman Sano** មកពីអង្គការសង្គ្រោះផែនដីកម្ពុជា បានបញ្ជាក់ថាលោកបានឮពាក្យថា "ភាពធន់" ត្រូវបានប្រើប្រាស់ចំនួន ៦១ដងហើយ។ តើអ្នកមានយន្តការណាមួយដើម្បីធានាថា កម្មវិធីបានរៀបចំឡើង និងអនុវត្តនោះនឹងក្លាយទៅជាគម្រោងភាពធន់ទេ?

លោក **ឡាយ ឃីម** បានឆ្លើយតបថា ដើម្បីធ្វើឲ្យគម្រោងមានភាពធន់នឹងការប្រែប្រួលអាកាសធាតុ ដំបូងយើងអនុវត្តគម្រោងគំរូ ស្តីពីការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ជាមួយនឹង MAFF ។ ដំណាក់កាលដំបូងនៃគម្រោងយើងបានរៀបចំការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះនៅតាមឃុំ និងក្រុមទទួលផលគោលដៅ ដើម្បីទទួលបានការយល់ឃើញរបស់ពួកគេស្តីពីភាពងាយរងគ្រោះ និងអ្វីដែលគេត្រូវការ ដើម្បីដោះស្រាយជាមួយភាពងាយរងគ្រោះនោះ។ នៅអំឡុងពេលអនុវត្តគម្រោង យើងគាំ

ទ្រព្វកគាត់ពីការអប់រំ កសាងហេដ្ឋារចនាសម្ព័ន្ធ ជាដើម។ នៅដំណាក់កាលបញ្ចប់គម្រោង យើងរៀបចំការវាយតម្លៃមួយទៀត ដោយប្រើវិធីសាស្ត្រដូចគ្នា។ តាមរយៈយុទ្ធសាស្ត្រនេះ យើងអាចប្រៀបធៀបពីភាពងាយរងគ្រោះមុន និងក្រោយការអនុវត្តគម្រោងថា តើវាមានភាពខុសគ្នាយ៉ាងដូចម្តេច។ មានវិធីសាស្ត្រជាច្រើនសម្រាប់បញ្ហា ដែលទាក់ទងនឹងភាពធន់នេះ។ ជាតួយ៉ាង PPCR មិនមែនជាគម្រោងបង្កើតថ្មីនោះទេ ប៉ុន្តែបញ្ចូលភាពធន់នឹងអាកាសធាតុទៅក្នុងកម្មវិធីរបស់ ADB ដែលមានស្រាប់។ នេះគឺជាគំរូមួយផ្សេងទៀត ហើយយើងត្រូវតែរង់ចាំមើលភាពជោគជ័យនៃដំណើរការនោះ។

លោក **Khter Uzaman Sano** មកពីអង្គការសង្គ្រោះផែនដីកម្ពុជា បានលើកឡើងថា ប្រសិនបើយើងចង់ឃើញ កម្ពុជាជាប្រទេសពណ៌បៃតងក្នុងនោះ UNDP គឺជាតួអង្គមួយដ៏សំខាន់ ក្នុងចំណោមតួអង្គជាច្រើនផ្សេងទៀត។ UNDP មានគម្រោងជាច្រើនជាមួយ រដ្ឋាភិបាល និង CSOs។ តើអ្នកមានផែនការណាមួយ ដើម្បីអភិវឌ្ឍគម្រោង ដែលស្ថិតនៅក្រោមកិច្ចសហប្រតិបត្តិការជាមួយ រដ្ឋាភិបាល និង CSOsដែរឬទេ?

លោក **ឡាយ ឃីម** បានឆ្លើយតបថា ការអភិវឌ្ឍបៃតង និងភាពជាដៃគូ រវាងរដ្ឋាភិបាល និង CSOs យើងបានធ្វើវារួចទៅហើយ តាមរយៈជំនួយខ្នាតតូចដល់ NGOs និងភ្នាក់ងាររដ្ឋាភិបាលមួយចំនួនជាឧទាហរណ៍ ។ កាលពីម្សិលមិញ លោកបណ្ឌិត **ងិន ពន្លក** បានបញ្ជាក់ថា មានភ្នាក់ងាររដ្ឋាភិបាលចំនួន ៦ និង NGOs ចំនួន ២ ទទួលបានជំនួយពី CCCA ។ លោកអាចធានាថា យើងបានធ្វើកិច្ចការបានយ៉ាងល្អចំពោះកិច្ចការក្នុងភាពជាដៃគូនេះ។

លោកស្រីបណ្ឌិត **ម៉ក់ សុឆាង** ជាអ្នកប្រឹក្សារបស់ MRC បានលើកឡើងថា ពុំឃើញមានបញ្ហាណាទាក់ទងនឹង MRC ទេក្នុងការរៀបចំផែនការយុទ្ធសាស្ត្រនោះ។ លោកស្រីបានសំណូមពរថា ផែនការយុទ្ធសាស្ត្ររបស់ MRC ដូចជា ការអភិវឌ្ឍអាងទន្លេមេគង្គ គម្រោងការគ្រប់គ្រងធនធានទឹកតាមបែបចម្រុះ យុទ្ធសាស្ត្រអភិវឌ្ឍអាងទន្លេមេគង្គ និងកម្មវិធីកាត់បន្ថយគ្រោះទឹកជំនន់ គួរតែត្រូវបានពិចារណាសម្រាប់ករណីកម្ពុជា ដោយសារតែកម្ពុជា គឺជាសមាជិកមួយរបស់ MRC ។ បន្ថែមពីនេះទៀត បញ្ហាឆ្លងដែនក៏ជាបញ្ហាមួយទៀតដែលគួរតែត្រូវបានពិចារណាផងដែរ។

លោក **ឡាយ ឃីម** បានយល់ស្របជាមួយនឹងយោបល់របស់បណ្ឌិត **សុឆាង** ថាការពិចារណាពី ផែនការថ្នាក់តំបន់ដែលមានស្រាប់គួរត្រូវបានអនុវត្ត ហើយលោកក៏បានបញ្ជាក់ផងដែរថា ឯកសាររបស់ MRC ត្រូវតែបានសិក្សាផងដែរ ដែលអាចផ្តល់ផលប្រយោជន៍សម្រាប់កម្ពុជា។

លោកស្រី **ជឹម កល្យាណី** អនុប្រធានមន្ទីរបរិស្ថាន ខេត្តព្រះសីហនុ បានលើកជាសំណួរចំនួនបីថា៖ ទី១ នៅក្នុងប្រព័ន្ធមជ្ឈការ និងសហវិមជ្ឈការ មានការយកចិត្តទុកដាក់លើសកម្មភាពបញ្ជ្រាប ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ។ ដូចនេះ នៅថ្នាក់ក្រោមជាតិ រាល់ផែនការទាំងអស់ ត្រូវតែមានសកម្មភាពទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ប៉ុន្តែ នៅមានការប្រឈមក្នុងអំឡុងពេលអនុវត្ត ដោយសារតែ កង្វះខាតនូវចំណេះដឹង និងបទពិសោធន៍នានា ទាក់ទងនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ លោកស្រីសំណូមពរឲ្យមានការគាំទ្រពីសហគមន៍ជាតិ និងអន្តរជាតិ ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល/សិក្ខាសាលា ដល់មន្ត្រីឲ្យមានចំណេះដឹងគ្រប់គ្រាន់ដើម្បីធ្វើផែនការដែល

ពាក់ព័ន្ធ។ ទី២ ការប្រែប្រួលគឺជាបញ្ហាសកល និងត្រូវការការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់។ នៅកម្ពុជា មានគោលនយោបាយតាមវិស័យ មានន័យថា ជាគោលនយោបាយសម្រាប់វិស័យនីមួយៗ។ អ្នកស្រីសំណូមពរឲ្យមានយុទ្ធសាស្ត្រចម្រុះបន្ថែមទៀតទៅលើ បញ្ហាការប្រែប្រួលអាកាសធាតុនេះ។ ទី៣ តើផែនការយុទ្ធសាស្ត្រអាចត្រូវបានរៀបចំឡើង ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុនៅក្នុងថ្នាក់តំបន់បានដែរឬទេ?

លោក **ឡាយ ឃីម** បានឆ្លើយតបនឹងសំណួរទី១ថា ជាក់ស្តែងការកសាងសមត្ថភាពនៅថ្នាក់ក្រោមជាតិ គឺជាផ្នែកមួយដែលផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំង។ ចំពោះសំណួរទី២ លោកយល់ស្របថា គំនិតដែលថាផែនការយុទ្ធសាស្ត្រគួរតែភ្ជាប់ជាមួយវិស័យផ្សេងទៀត និងតម្រូវឲ្យមានការសម្របសម្រួល ដើម្បីផ្សារភ្ជាប់នូវផែនការយុទ្ធសាស្ត្រ ប្រែប្រួលអាកាសធាតុ។ ចុងក្រោយ លោកសូមអរគុណ ចំពោះយោបល់ស្តីពីការពិចារណាផែនការថ្នាក់តំបន់ បច្ចុប្បន្នមានយន្តការចំនួនពីរ គឺ MRC និង GMS ជម្រុញឲ្យមាននូវផែនការ ពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុថ្នាក់តំបន់។

លោក **គង់ គីមស្រេង** មកពីអង្គការ IUCN បានចោទជាសំណួរចំនួនពីរ ដែលទី១ លោក **ឡាយ ឃីម** បានលើកឡើងថា វិស័យនីមួយៗ មានលទ្ធភាពនឹងទទួលបានមូលនិធិ ២៥.០០០ដុល្លា ដើម្បីធ្វើផែនការរបស់ខ្លួន។ តើលោកអាចបញ្ជាក់ឲ្យកាន់តែច្បាស់ថា តើនៅកម្រិតណាមួយ (ថ្នាក់ជាតិ ថ្នាក់ខេត្ត ឬថ្នាក់មូលដ្ឋាន) ដែលអាចទទួលបានមូលនិធិ និងសម្រាប់រយៈពេលប្រើប្រាស់មូលនិធិនោះ? ទី២ លោក **គង់ គីមស្រេង** មានបទពិសោធន៍ទាក់ទងនឹងបញ្ហាយេនឌ័រក្នុងខេត្តកោះកុង IUCN នៅក្នុងខេត្តនោះបានរៀបចំក្រុមជួយសង្គ្រោះស្ត្រី ប៉ុន្តែពាក់ព័ន្ធនឹងការធ្វើសេចក្តីសម្រេចចិត្ត ស្ត្រីមិនបានបញ្ចេញមតិទេ គឺមានតែបុរសទេ។ ដូចនេះ រាល់សកម្មភាពទាក់ទងនឹងការបង្ក្រាបស្ត្រី នៅក្នុងគម្រោងណាមួយ យើងគួរតែមានយន្តការមួយដែលអនុញ្ញាតិឲ្យមានមិនត្រឹមតែការចូលរួមប៉ុណ្ណោះទេ ប៉ុន្តែរួមទាំងការធ្វើសេចក្តីសម្រេចចិត្តផងដែរ។

លោក **ឡាយ ឃីម** បាននិយាយថា ថវិកា ២៥.០០០ដុល្លា សម្រាប់ វិស័យនីមួយៗ នោះ គឺសម្រាប់គាំទ្រដល់វិស័យនានា ឬអន្តរវិស័យជាក់លាក់ ដើម្បីរៀបចំផែនទីបង្ហាញផ្លូវក្នុងការដោះស្រាយ ការប្រែប្រួលអាកាសធាតុ។ ដូចនេះ វាអាស្រ័យលើវិស័យនីមួយៗ ក្នុងការសម្រេចចិត្តថា តើត្រូវពិគ្រោះយោបល់ជាមួយថ្នាក់ក្រោមជាតិ ឬអត់។ នេះគឺជាគំនិតផ្តួចផ្តើមដ៏ល្អមួយ សម្រាប់ការផ្តល់អំណាចដល់ស្ត្រីក្នុងការធ្វើការសម្រេចចិត្ត។

លោក **ឥន្ទ្រ ស៊ីឡាង** មកពី USAID បានលើកឡើងថា លោក **ឡាយ ឃីម** បានបញ្ជាក់ពីបញ្ហាសុខភាពដូចជា គ្រុនចាញ់ ផ្តាំពុលជីវសាស្ត្រ និងអនាម័យ ប៉ុន្តែតើមានការព្រួយបារម្ភណាមួយ ទាក់ទងនឹងអាហារូបត្ថម្ភកុមារ និងសន្តិសុខស្បៀង នៅក្នុងឯកសារនេះដែរឬទេ? ប្រសិនបើមាន តើមានអនុសាសន៍អ្វីខ្លះ ឬតើលោកអាចផ្តល់ជាយោបល់ផ្ទាល់ខ្លួនទៅលើបញ្ហានេះដែរ ឬទេ?

លោក **ឡាយ ឃីម** បាននិយាយថា NAPA មិនបានបញ្ជាក់ជាពិសេស លើបញ្ហាអាហារូបត្ថម្ភកុមារ ប៉ុន្តែភាគច្រើនចែងពីសន្តិសុខស្បៀង។ ដូច្នេះ វាអាស្រ័យលើវិស័យជាក់លាក់ ឬអន្តរវិស័យ ដែលកំពុងធ្វើការទៅលើគោលដៅជាក់លាក់នានា ដើម្បីសម្របសម្រួលជាមួយអ្នកទទួលផលគោលដៅថា តើវាមានទំនាក់ទំនងជាមួយនឹងកុមារ ឬស្ត្រីដែរទេ។

លោក **ហ៊ាវ ឥាសនា** មកពីក្រុមហ៊ុន MRT បានផ្តល់ជាយោបល់ថា រដ្ឋាភិបាល គឺជាអ្នកទទួលខុសត្រូវ ក្នុងការកសាងផែនការយុទ្ធសាស្ត្រជាមួយ DPs តែគួរតែពិចារណាពីទំនាក់ទំនងរវាងការប្រែប្រួលអាកាសធាតុ និងគ្រោះហានិភ័យថ្នាក់តំបន់ ដើម្បីបង្កើតជាផែនការយុទ្ធសាស្ត្រដែលអាចអនុវត្តបាននៅថ្នាក់តំបន់។ លោកក៏បានផ្តល់ជាអនុសាសន៍ថា ផែនការយុទ្ធសាស្ត្រគួរតែគិតគូរវិស័យឯកជនផងដែរ ព្រោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ មិនមែនត្រឹមតែប៉ះពាល់ដល់ ប្រជាជនមូលដ្ឋានប៉ុណ្ណោះទេ ប៉ុន្តែក៏មានវិស័យឯកជនផងដែរ។

លោក **ឡាយ ឃីម** ទទួលស្គាល់ពីគំនិតនៃកិច្ចសហការណ៍ថ្នាក់តំបន់ និងវិស័យឯកជន។ UNDP បានជួយគាំទ្រដល់ MAFF ក្នុងការរៀបចំឯកសារ NAP ហើយនៅក្នុងដំណាក់កាលរៀបចំ ក៏មានការពិគ្រោះយោបល់ជាមួយវិស័យឯកជនផងដែរ ទាក់ទងនឹងការគ្រប់គ្រងដីប្រកបដោយចីរភាព។

លោក **ណុប ប៉ូលីន** មកពី DCA/CA បានបញ្ជាក់ថា មានផែនការ និងយុទ្ធសាស្ត្រ ប៉ុន្តែគ្មានសកម្មភាពត្រួតពិនិត្យ ដែលអាចធានាថាមានការទទួលខុសត្រូវ និងគណនេយ្យភាពនៃអ្នកពាក់ព័ន្ធទាំងអស់។ នេះជាបញ្ហាសំខាន់ព្រោះប្រទេសអភិវឌ្ឍន៍ ដែលជាអ្នកដែលផ្តល់មូលនិធិ ក៏ចង់ឃើញរបៀបដែលថវិកាត្រូវបានគ្រប់គ្រង និងត្រួតពិនិត្យ ដោយធៀបនឹងលទ្ធផលនៃសកម្មភាពនានា នៅក្នុងផែនការយុទ្ធសាស្ត្រ។

លោក **ឡាយ ឃីម** បាននិយាយថា M&E ត្រូវតែជាសមាសធាតុមួយដ៏សំខាន់ នៅក្នុងផែនការយុទ្ធសាស្ត្រជាតិស្តីពី ការប្រែប្រួលអាកាសធាតុ និងគម្រោងតាមវិស័យ និងអន្តរវិស័យ ផងដែរ។

អ្នកស្រី **អ៊ឹម ផល្លី** មកពី NGO Forum បានផ្តល់ជាអនុសាសន៍មួយចំនួន ដោយផ្អែកលើសុន្ទរកថាបើករបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ឃឹម សែលី**។ អ្នកស្រីសំណូមពរឲ្យមានការបញ្ចូលកម្មវិធីអប់រំពី ការប្រែប្រួលអាកាសធាតុទៅក្នុងកម្មវិធីសិក្សា នៅតាមសាលា។ ចំណុចផ្សេងទៀតនោះគឺ គ្មានប្រព័ន្ធផ្តល់ព័ត៌មានជាមុន នៅក្នុងផែនការយុទ្ធសាស្ត្ររបស់ MoWRAM ។ មានប្រព័ន្ធផ្តល់ព័ត៌មានជាមុនពីទឹកជំនន់ ប៉ុន្តែគ្មានប្រព័ន្ធសម្រាប់គ្រោះរាំងស្ងួតទេ។ អ្នកស្រីបានអានឯកសារ PPCR ប៉ុន្តែគ្មានការបញ្ចូលនូវសកម្មភាព ទាក់ទងនឹងគ្រោះរាំងស្ងួតនៅក្នុងឯកសារនោះទេ។ ផែនការយុទ្ធសាស្ត្រ មិនមានភាពទូលំទូលាយទេ លុះត្រាណាតែ មានការបញ្ចូលផែនការអប់រំ សម្រាប់ថ្នាក់មូលដ្ឋាន ជាពិសេស ជម្រាបពួកគាត់ពីបញ្ហាសំខាន់ៗនានា ដែលអាចឲ្យពួកគាត់បន្សាំ និងរស់នៅបាន។ ផែនការអប់រំ គួរតែមានលក្ខណៈទូលំទូលាយ និងមានការបញ្ចូលទាំងតំបន់ដាច់ស្រយាល ជាពិសេស ក្រុមជនជាតិភាគតិច។ យោងទៅតាមបទពិសោធន៍របស់ NGO Forum ពាក់ព័ន្ធនឹងកម្មវិធីអប់រំ កន្លងមក ប្រជាកសិករ បានសំណូមពរឲ្យមានបញ្ចូលនូវបច្ចេកទេសផលិតកម្មកសិកម្ម នៅថ្នាក់មូលដ្ឋាន។

លោក **ស៊ុំ ធី** បានលើកឡើងថា ទាក់ទងនឹងកម្មវិធីអប់រំស្តី ពីការប្រែប្រួលអាកាសធាតុ MoE បានរៀបចំឯកសារគំរូជាមួយ អង្គការ PLAN អន្តរជាតិ ដើម្បីបញ្ជ្រាបការអប់រំ ស្តីពីការប្រែប្រួលអាកាសធាតុ ទៅក្នុងវិទ្យាល័យមួយចំនួនដូចជានៅ ស្រុកតំបែ ខេត្តកំពង់ចាម និងស្រុកសូត្រនិគម ខេត្តសៀមរាប។

អ្នកស្រី **Raffel** មកពីអង្គការកាបូន Nexus ដើម្បីការអភិវឌ្ឍ បានសួរថា ផែនការយុទ្ធសាស្ត្រ មានលក្ខណៈស្មុគស្មាញក្នុងការ

បញ្ចូលទៅក្នុងយុទ្ធសាស្ត្រតាមវិស័យ នៅតាមក្រសួងផ្សេងៗ ដូចនេះ អ្នកស្រីសូមឲ្យមានការបំភ្លឺបន្ថែមពីពេលវេលា សម្រាប់ផែនការយុទ្ធសាស្ត្រនេះ។ លើសពីនេះទៅទៀត ដោយកិច្ចប្រជុំនៅខ្ងុបាននឹងចាប់ផ្តើមនៅចុងឆ្នាំនេះលោកស្រីមានចម្ងល់ថា តើមានលទ្ធភាពនៃការចែករំលែកពង្រាងចុងក្រោយ ឬក៏ឯកសារគោលនយោបាយផ្សេងទៀតមុនចុងឆ្នាំនេះដែរឬទេ?

លោក **ស៊ុំ ឆី** បានឆ្លើយតបថា ផែនការយុទ្ធសាស្ត្រ ត្រូវបានរំពឹងថានឹងបញ្ចប់នៅត្រីមាសទី១នៃឆ្នាំ២០១២។ ប៉ុន្តែនឹងមានការពន្យាពេលខ្លះដោយសារតែដំណើរការអភិវឌ្ឍត្រូវការពេលវេលាច្រើន សម្រាប់ការពិគ្រោះយោបល់។ ដូចនេះលោកគិតថា ឯកសារនេះនឹងអាចបញ្ចប់នៅក្នុងត្រីមាសទី២នៃឆ្នាំ២០១២។

លោក **សុវណ្ណារី** មកពីមន្ទីរបរិស្ថានខេត្តរតនៈគីរី បានបង្ហាញពីចំណាប់អារម្មណ៍របស់គាត់ទៅលើការកាត់បន្ថយ GHGs សម្រាប់ DCs ឬ LDCs តើនៅពេលការកាត់បន្ថយត្រូវបានអនុវត្ត តើវាមានផលប៉ះពាល់ដល់ចំណូល/ថវិកាជាតិដែរ ឬទេ?

លោក **Mozaharul Alam** បាននិយាយថា ប្រសិនបើមើលទៅលើ សំណូមពរចម្បងៗនៃវិធានការណ៍ផ្សេងៗក្នុងការកាត់បន្ថយ GHGs ពីវិស័យនានា វិធានការណ៍ទាំងនោះ មិនមែនសម្រាប់កាត់បន្ថយផលិតកម្ម នៅក្នុងវិស័យទាំងនោះទេ ខណៈដែលមានការកាត់បន្ថយ GHGs។ ដូច្នេះ វិធានការណ៍ណាមួយ ដែលនឹងបញ្ចេញ GHGs ទោះបីជាវិស័យកសិកម្ម ឬឧស្សាកម្ម គឺមិនសម្របសម្រួលផ្នែកផលិតកម្មទេ ប្រសិនបើមានបែបនេះ នោះវានឹងមិនត្រូវបានជ្រើសរើសជាជម្រើសមួយ សម្រាប់ការកាត់បន្ថយតាមវិស័យទេ។

អ្នកស្រី **ឌឹម កល្យាណី** បានផ្តល់ជាយោបល់ថា ការកាត់បន្ថយផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ គួរតែត្រូវបានធ្វើដោយប្រទេសអភិវឌ្ឍន៍។ ជាងនេះទៀត អ្នកស្រីបានស្នើឲ្យអ្នកពាក់ព័ន្ធទាំងអស់ ពង្រឹងការអនុវត្តច្បាប់ស្តីពីការកាប់ព្រៃឈើ។

លោក **Mozaharul Alam** បានឆ្លើយតបថា ធាតុសំខាន់ៗនៃការចរចារ និងការដាក់សម្ពាធលើប្រទេសអភិវឌ្ឍន៍ គឺត្រូវបាននិងកំពុងដោះស្រាយដោយភ្នាក់ងារ UN ផ្សេងទៀត។ UNEP កំពុងព្យាយាមនាំប្រទេសហត្ថលេខីនៃការប្រែប្រួលអាកាសធាតុរួមបញ្ចូលគ្នា និងសម្របសម្រួលការចរចារ។ លោកគិតថា នៅថ្នាក់ជាតិ គេនឹងគោរពតាមការស្វែងរកការចូលរួម និងការពារព្រៃឈើ។

លោក **Geoffrey Blate** មកពី WWF បានផ្តល់យោបល់ពី គោលដៅនៃការកើនឡើងសីតុណ្ហភាព ២°C ថា ប្រសិនបើក្រឡេកមើលទៅលើការព្យាករណ៍នៃកំណើនសីតុណ្ហភាពសកលលោកត្រឹម ២°C នោះនឹងមានផលវិបាកធ្ងន់ធ្ងរជាច្រើន។ ទោះបីជាមានការលំបាកក្នុងការកាត់បន្ថយនៃការបញ្ចេញ ដែលអាចធ្វើឲ្យសីតុណ្ហភាពកើនឡើង ២°C នោះផែនការនៃការកាត់បន្ថយ គួរតែមានមហិច្ឆតាជាងនេះ ជាពិសេសប្រទេសអភិវឌ្ឍន៍។ ការកាត់បន្ថយកាន់តែខ្ពស់ នោះផលប៉ះពាល់កាន់តែតិច។ លោកបារម្ភថា គោលដៅនៃការកើនឡើង ២°C នឹងនៅតែបណ្តាលឲ្យមានផលប៉ះពាល់ ដែលមិនអាចទទួលយកបានសម្រាប់កម្ពុជា និងបណ្តាប្រទេសដែលងាយរងគ្រោះច្រើនទៀត ដោយសារភាពមិនប្រាកដប្រជានៅក្នុងការព្យាករណ៍។ លោកបានទទូចឲ្យបុគ្គលគ្រប់រូប ជម្រុញឲ្យអ្នកដឹកនាំនានាក្នុងការចរចារ ដោយមានជំនឿចិត្ត និងមានមហិច្ឆតាតាមលទ្ធភាព ដែលអាចនៅក្នុងកិច្ចប្រជុំទីក្រុងឌ្ងបាន។

លោក **Mozaharul Alam** យល់ស្របទាំងស្រុងជាមួយនឹងមតិរបស់លោក **Geoffrey Blate** ពីភាពមិនប្រាកដប្រជា ដូចនេះយើងត្រូវកំណត់គោលដៅឲ្យបានខ្ពស់ជាងនេះ។

លោក **វ៉ែន ខីរៈ** មកពីមន្ទីរបរិស្ថានខេត្តកំពត បានសួរថា តើមានយន្តការណាមួយសម្រាប់ប្រទេសនីមួយៗ ក្នុងការកាត់បន្ថយ GHGs ដែរទេ? តើមានប្រព័ន្ធត្រួតពិនិត្យដែរ ឬទេ? តើមូលនិធិពីម្ចាស់ជំនួយនានាមានគិតគូរលើការខូចខាតនានា ដែលកើតមាននៅកម្ពុជា ដូចជាទឹកជំនន់ និងខ្យល់ព្យុះជាដើមដែរ ឬទេ?

លោក **ស៊ុំ ឆី** បានឆ្លើយតបថា មានវិធីសាស្ត្រមួយក្នុងការធ្វើសារពើរភណ្ឌGHGs ហើយប្រទេសឧស្សាហកម្មមានកាតព្វកិច្ចក្នុងការរាយការណ៍ទៅលេខាធិការដ្ឋាន អ.ស.ប ស្តីពីប្រែប្រួលអាកាសធាតុរៀងរាល់ពីរឆ្នាំម្តង។ សារពើភ័ណ្ឌនឹងត្រួតពិនិត្យ ដោយអ្នកត្រួតពិនិត្យឯករាជ្យ ឬអ្នកជំនាញមកពី DCs ។ និយាយពីតុល្យភាពរវាងជំនួយ និងការបាត់បង់/ការខូចខាត គឺពុំមានយន្តការចរចារណាមួយនៅឡើយទេ។ មានគំនិតផ្តួចផ្តើមថ្មីមួយ កំពុងត្រូវបានពិភាក្សា នោះគឺ ការធានារ៉ាប់រងអាកាសធាតុ ឧទាហរណ៍ប្រសិនបើប្រទេសមួយជួបនឹងគ្រោះមហន្តរាយ និងការខូចខាតផ្សេងៗនោះ នឹងមានសំណងពីការខូចខាតនោះ ប៉ុន្តែការពិភាក្សាស៊ីជម្រៅ ឬក៏ការចរចារមិនទាន់បានប្រព្រឹត្តទៅនៅឡើយទេ។

លោក **Liam Fee** មកពី UN Habitat បានលើកឡើងថា ចំពោះការលំបាកលើលក្ខខណ្ឌសេដ្ឋកិច្ចសកលលោក ដូចជាវិបត្តិបំណុលនៅអឺរ៉ុបជាដើម តើវាប្រាកដសម្រាប់ LDCs ក្នុងការរំពឹងលើរាល់ហិរញ្ញប្បទាន មកពីប្រទេសនៅក្នុងឧបសម្ព័ន្ធ១ ដោយគ្មានការប្តេជ្ញាចិត្តពីLDCs ក្នុងការលើកឡើងពីហិរញ្ញប្បទានផ្ទាល់ខ្លួនដើម្បីដោះស្រាយបញ្ហាអាកាសធាតុ ផ្ទាល់ខ្លួននោះទេ ឬយ៉ាងណា? លោកបានផ្តល់ឧទាហរណ៍ ពីចក្រភពអង់គ្លេស ដែលជាការប្រហារផ្នែកនយោបាយដោយនាយករដ្ឋមន្ត្រី ក្នុងការប្តេជ្ញាចិត្តផ្តល់ហិរញ្ញប្បទានដ៏ច្រើន នៅក្នុងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ដូចនេះតម្រូវឲ្យ LDCs ប្តេជ្ញាចិត្តក្នុងការលើកឡើងនូវហិរញ្ញប្បទានរបស់ខ្លួន ដើម្បីចំណាយសម្រាប់វិធានការបន្ស៊ាំ និងការកាត់បន្ថយ ដែលត្រូវការក្នុងរយៈពេលវែង។ លោកយល់ស្របទាំងស្រុងថា គោលជំហរនៃការចរចារ គឺជាគោលដៅរួមរបស់ប្រទេសនៅក្នុងឧបសម្ព័ន្ធ I ប៉ុន្តែគ្មានគោលដៅរួមសម្រាប់ប្រទេសនៅក្នុងឧបសម្ព័ន្ធ II ទេ។ វាហាក់ដូចជាការលេងនៅទីវាលមិនស្មើភាព ហើយមានភាពអយុត្តិធម៌តិចតួច។ តើវាជាការពិតសម្រាប់ប្រទេសនៅក្នុងឧបសម្ព័ន្ធ I ដើម្បីយល់ព្រមនឹងការចងភ្ជាប់ពួកគេទៅនឹងគោលដៅ នៅពេលដែលប្រទេសនៅក្នុងឧបសម្ព័ន្ធ II មិនត្រូវបានចងភ្ជាប់ទៅនឹងគោលដៅនោះ?

លោក **ស៊ុំ ឆី** បានឆ្លើយថា ទាក់ទងនឹងមូលនិធិក្នុង LDCs ដើម្បីផ្តល់ជាហិរញ្ញប្បទានដល់សកម្មភាពនានា ទាក់ទងនឹងការប្រែប្រួលអាកាសធាតុ គឺពុំមានចែងពីការទទួលខុសត្រូវរបស់ LDCs ក្នុងការត្រៀមខ្លួនសម្រាប់ហិរញ្ញប្បទានផ្ទាល់ខ្លួនក្នុងការចរចារទេ ក៏ប៉ុន្តែ LDCs នីមួយៗ នឹងរៀបចំផែនការសកម្មភាពការប្រែប្រួលអាកាសធាតុ។ ប្រទេសមួយចំនួនបានបែងចែកថវិកាជាតិរបស់ខ្លួន ដើម្បីដោះស្រាយជាមួយនឹងបញ្ហាការប្រែប្រួលអាកាសធាតុ ដូចជាដែលមានស្រាប់នៅកម្ពុជា។ ទោះបីជាយ៉ាងណាក៏ដោយ ការបែងចែកថវិការបស់ប្រទេសកម្ពុជាមិនបានបែងចែកតាមប្រភេទច្បាស់លាស់ជាពិសេសមូលនិធិសម្រាប់ការប្រែប្រួលអាកាសធាតុនៅឡើយទេ។ វាបានបង្ហាញយ៉ាងច្បាស់ហើយនៅក្នុងការចរចារថា ប្រទេសអភិវឌ្ឍន៍ត្រូវតែផ្តល់ធនធានហិរញ្ញវត្ថុទៅឲ្យ DCs ។

លោក **យ៉ក់ សុទ្ធិរិទ្ធិ** មកពីស្ថានទូតអង់គ្លេសបានសួរសំណួរថា តើប្រទេសកម្ពុជាសហការណ៍ជាមួយ G៧៧ និង ASEAN យ៉ាងដូចម្តេចក្នុងការរៀបចំសម្រាប់កិច្ចប្រជុំនៅឌូបាននៅក្នុងខែធ្នូខាងមុខនេះ? តើការព្រមព្រៀងអ្វីខ្លះដែលកម្ពុជារំពឹងទុកថានឹងទទួលបានពីកិច្ចប្រជុំនៅទីក្រុងឌូបាន? ទាក់ទងទៅនឹង MRV ប្រសិនបើ MRV ត្រូវបានព្រមព្រៀងដោយប្រទេសជាច្រើន និងមានលក្ខណៈស្មុគ្រស្មាញ តើប្រទេសកម្ពុជាគិតគូរយ៉ាងដូចម្តេចដែរ ទាក់ទងទៅនឹងបញ្ហានេះ?

លោក **ស៊ុំ ឆី** បានឆ្លើយតបថា មុននឹងមានកិច្ចប្រជុំធំៗ ប្រទេស G៧៧ នីមួយៗអាចរៀបចំប្រជុំបម្រុងបាន ដើម្បីប្រមូលគំនិតពីប្រទេសជាសមាជិកនីមួយៗ រួចបង្កើតបានជាគោលជំហររួមមួយសម្រាប់ការចរចារ។ គួរឲ្យកត់សម្គាល់ថា កម្ពុជាគឺស្ថិតនៅក្នុងក្រុម LDCs និងក៏ជាផ្នែកមួយនៃ G៧៧ ដូចនេះ ជំហររបស់កម្ពុជាតែងតែស្របជាមួយ LDCs និង ប្រទេស G៧៧ + ចិន។ កិច្ចប្រជុំសម្របសម្រួលជាមួយបណ្តាប្រទេស ASEAN ក៏ត្រូវបានធ្វើឡើងផងដែរ។ ចំពោះវេទិកានៅទីក្រុងឌូបាន ប្រទេសឥណ្ឌូនេស៊ី និងវៀតណាមកំពុងប្រឹងប្រែងធ្វើការយ៉ាងខ្លាំងដើម្បីរៀបចំគោលជំហររបស់ASEAN និងសេចក្តីថ្លែងការណ៍ ដែលប្រទេសវៀតណាមនឹងត្រូវធ្វើ ក្នុងអំឡុងកិច្ចប្រជុំនៅទីក្រុងឌូបាននោះ។ ចំណែកឯ MRV វិញ គឺវាទាក់ទងទៅនឹងសកម្មភាពតាមដាននៃការកាត់បន្ថយ GHGs ហើយកម្ពុជា គ្មានកាតព្វកិច្ចក្នុងការកាត់បន្ថយ GHGs នោះទេ។ ប៉ុន្តែប្រសិនបើការអនុវត្ត NAMA គឺតម្រូវឲ្យមាននូវ MRV តែចំពោះការគាំទ្រផ្នែកហិរញ្ញវត្ថុត្រូវតែមកពីប្រទេសអភិវឌ្ឍន៍។

ការតាំងពិព័រណ៍

ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉ែត ទស្សនាការតាំងពិព័រណ៍ (CCCA, ២០១១)

ការតាំងពិព័រណ៍ ត្រូវបានតាំងបង្ហាញជាទូទៅសម្រាប់រយៈបីថ្ងៃនៃអង្គវេទិកា។ ការតាំងបង្ហាញនេះ ជាវេទិកាមួយ ដែលបង្ហាញពីការចូលរួមជាសាធារណៈក្នុងការរួមចំណែក នៅក្នុងការអភិវឌ្ឍប្រកបដោយចីរភាព ក្នុងបរិបទប្រែប្រួលអាកាសធាតុនៅកម្ពុជា តាមរយៈសកម្មភាពរបស់ពួកគេ។ ជាលទ្ធផលមានស្តង់ចំនួន ១៦ ដែលមានការចូលរួមពីសំណាក់ ស្ថាប័នរដ្ឋាភិបាល DPs NGOs និងវិស័យឯកជន បានតាំងបង្ហាញផលិតផលរបស់ពួកគេ ដែលទាក់ទងនឹងឧបករណ៍ក្នុងការលើកកម្ពស់ការយល់ដឹងពីការប្រែប្រួលអាកាសធាតុ បច្ចេកវិទ្យាដែលបញ្ចេញកាបូនទាប និងផលិតផលដែលមានប្រសិទ្ធភាពថាមពល។ ជាងនេះទៀត ក៏មានការតាំងបង្ហាញគំនូរ និងរូបផ្សេងផ្សេងៗ ដែលទាក់ទងនឹងបរិបទប្រែប្រួលអាកាសធាតុផងដែរ។

ពិធីបិទ

សុន្ទរកថាបិទ

ដោយឯកឧត្តម ***បណ្ឌិត ម៉ុក ម៉ារ៉ែត*** *ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធាន NCCC*

ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** បានមានប្រសាសន៍ថា ពីរឆ្នាំកន្លងនេះកម្ពុជាបានខិតខំព្យាយាមសម្រេចបាននូវសមិទ្ធផលជាទីមោទនៈ

ក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតប នឹងបញ្ហាប្រែប្រួលអាកាសធាតុ។ ឯកឧត្តម ក៏បានថ្លែងអំណរគុណចំពោះ កិច្ចខិតខំប្រឹងប្រែងរួមគ្នា យ៉ាងសកម្មរបស់សមាជិក សមាជិកាទាំងអស់ ក៏ដូចជាការផ្តល់វិភាគទានថ្មីៗក្នុងការជួយកម្ពុជាឆ្លើយតបនឹងអាទិភាពបន្ទាន់នានា ផ្នែកការប្រែប្រួលអាកាសធាតុ ដូចជាការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេស ការសម្របសម្រួល ការអនុវត្តគម្រោងជាក់ស្តែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការកៀរគរធនធាន ការអប់រំ និងលើកកម្ពស់ការយល់ដឹង និងការចរចាអន្តរជាតិ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ជាពិសេស ការរៀបចំសេចក្តីព្រាងឯកសារជំហររបស់កម្ពុជា សម្រាប់ត្រៀមចូលចរចានៅក្នុង CoP១៧ នៃបណ្តាប្រទេសជាសមាជិកអនុសញ្ញាប្រែប្រួលអាកាសធាតុ នៅទីក្រុងឌូបាននៃប្រទេសអាហ្វ្រិកខាងត្បូង នៅចុងឆ្នាំនេះ។

ឯកឧត្តមបានក្រើនរំលឹកថា អនាគតរបស់មនុស្សជាតិនឹងរងគ្រោះ ប្រសិនបើនៅតែបន្តធ្វើមិនដឹង មិនឮនូវគតិបណ្ឌិត ដែលថាការអភិវឌ្ឍ ដែលពឹងផ្អែកលើប្រេងឥន្ធនៈហ្វូស៊ីលពុំមានចីរភាព ហើយត្រូវតែបង្វែរទិសនៃការអភិវឌ្ឍទៅរកមាគ៌ាអភិវឌ្ឍន៍មួយ ដែលបៃតងជាងមុន ប្រើប្រាស់កាបូនទាប និងធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ។ ឯកឧត្តមបានរំលឹកបន្ថែមថាកម្ពុជាគឺជាអ្នករងគ្រោះដោយសារបញ្ហាដែលមិនមែនជាចំណែកមួយនៃមូលហេតុ។ ប៉ុន្តែកម្ពុជា ចង់ក្លាយជាផ្នែកមួយនៃដំណោះស្រាយពិភពលោកចំពោះបញ្ហានេះ និងជឿជាក់ថាអាចប្រែក្លាយរបិតិអាកាសធាតុឲ្យជាកាលានុវឌ្ឍភាពសម្រាប់ការអភិវឌ្ឍមួយ ដែលមានចីរភាពជាងមុន។

អ្នកចូលរួមនៅក្នុងកម្មវិធីបិទ (CCCA, 2011)

ជាមួយនឹងអាណត្តិផ្លូវច្បាប់ ដែលរាជរដ្ឋាភិបាលប្រគល់ឲ្យ NCCC ដែលមាន MoE ជាលេខាធិការដ្ឋាន ឯកឧត្តម **ម៉ុក ម៉ារ៉ែត** បានបញ្ជាក់ថា លេខាធិការដ្ឋាននេះត្រៀមខ្លួនជាស្រេច ដើម្បីបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការសម្របសម្រួល និងជម្រុញភាពជាដៃគូដោយសមធម៌ តម្លាភាព ប្រសិទ្ធភាព និងគួរឲ្យទុកចិត្ត។ NCCC ប្តេជ្ញាបង្កើត និងធានាឲ្យមានបរិស្ថានប្រកបមួយ ដែលតួអង្គប្រែប្រួលអាកាសធាតុទាំងអស់ អាចមានកាលានុវឌ្ឍភាពស្មើគ្នា ក្នុងការរួមចំណែកដោយពេញលេញ ក្នុងបូជនីយកិច្ចប្រែប្រួលអាកាសធាតុនេះ។

ជាទីបញ្ចប់ ឯកឧត្តម បានសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះអ្នកចូលរួមទាំងឡាយ ដែលបានចំណាយពេលចូលរួមក្នុងវេទិកាជាតិនេះ ដើម្បីផ្តល់នូវចំណេះដឹង ចែករំលែកបទពិសោធន៍ និងរួមចំណែកពិភាក្សាផ្តល់មតិយោបល់ដ៏មានតម្លៃ និងចំពោះតំណាងវិស័យឯកជន និងអង្គការជាតិ-អន្តរជាតិ និង NGOs ជាដៃគូមួយចំនួន ដែលបានចូលរួមតាំងពិព័រណ៌ផលិតផល ដែលជួយការពារអាកាសធាតុ និងជាពិសេស ចំពោះសមាជិកសមាជិការបស់ NCCC និងមន្ត្រីលេខាធិការដ្ឋាន រៀបចំវេទិកាទាំងអស់ ដែលខិតខំបំពេញការងារក្នុងការរៀបចំវេទិកាប្រកបដោយជោគជ័យ។

ឯកឧត្តម ក៏បានថ្លែងអំណរគុណ ជាពិសេស ចំពោះអ្នកឧបត្ថម្ភទាំងឡាយ ដែលបានផ្តល់ការ គាំទ្រផ្នែកថវិកាដល់ការរៀបចំអង្គវេទិកានេះ។

សន្និសីទសារព័ត៌មាន

ឯកឧត្តម បណ្ឌិត ម៉ុក ម៉ារ៉ែត
និងតំណាងម្ចាស់ជំនួយនៅក្នុងសន្និសីទសារព័ត៌មាន
(CCCA, 2011)

ការរៀបចំសន្និសីទសារព័ត៌មាននេះ គឺ ក្នុងគោលបំណងចែករំលែកនូវលទ្ធផលចម្បងៗ ដែលទទួលបានពី SNFCC ដោយមានការចូល រួមពីអ្នកសារព័ត៌មានជាតិ និងអន្តរជាតិជាច្រើន នាក់។ សន្និសីទសារព័ត៌មាននេះ បានចាប់ ប្រារព្ធធ្វើឡើងនៅថ្ងៃទី០៥ ខែតុលា ឆ្នាំ២០១១ វេលាម៉ោង ១៦:៤០ នាទីរសៀស នៅសណ្ឋាគារ អាំងទែរកុងទីណង់តាល់ ក្រោមការអញ្ជើញចូល រួមរបស់វាគ្មិនតំណាង RGC (MoE/NCCC) EU OA Sida និង UNDP ដោយមានឯឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ជាប្រធាន និងជាអ្នកតំណាងមកពី រាជរដ្ឋាភិបាលកម្ពុជា។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** មានប្រសាសន៍បើកសន្និសីទ ដោយ សង្ខេបពីសមិទ្ធិផលនៃ SNFCC ថា៖ ក្នុងថ្ងៃបើក វេទិកា ឯកឧត្តម **ឃឹម ឆៃលី** បានផ្តល់ជា អនុសាសន៍ចំនួន ០៦ សំខាន់ៗ ដែលផ្តោតលើ ការលើកទឹកចិត្ត ផលិតភាព ដំណោះស្រាយ ការប្រែប្រួលអាកាសធាតុ ជាពិសេសទៅលើការ រៀបចំគោលនយោបាយ និងផែនការយុទ្ធ សាស្ត្រការប្រែប្រួលអាកាសធាតុ ដែលផែនការ នេះតម្រូវឲ្យក្រសួង និងស្ថាប័នពាក់ព័ន្ធ ប្រើ ប្រាស់ផែនការ សម្រាប់ជាគោលនៃការបញ្ចូល ការប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការជាតិ និងវិស័យពាក់ព័ន្ធ។ បិតក្នុងកិច្ចប្រជុំបច្ចេកទេស បន្ទាប់នេះ មានបទបង្ហាញគួរឲ្យចាប់អារម្មណ៍ ដែលនិយាយពីការបន្សុំ និងការកាត់បន្ថយការ ប្រែប្រួលអាកាសធាតុ ដែលផ្តោតសំខាន់លើ ការប្រឈម ភាពជោគជ័យ មេរៀនដែលទទួល បាន គម្លាតគោលនយោបាយ និងអនុសាសន៍ នានាទៀត។ ក្នុងវេទិកានេះផងដែរ មានគម្រោង ចំនួន០៨ ត្រូវបានអនុម័តផ្តល់ថវិកាពី CCCA សម្រាប់ការប្រកាសទទួលសំណើគម្រោង លើក ទី១។ ការប្រកាសទទួលសំណើគម្រោងបន្ទាប់ ទៀតនឹងចាប់ផ្តើមនៅពេលឆាប់ៗខាងមុខនេះ។ កិច្ចពិភាក្សា លើការរៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ នៅកម្ពុជាត្រូវបានប្រព្រឹត្តទៅ ហើយសង្ឃឹមថា ផែនការនឹងត្រូវបានអនុម័ត នាពេលឆាប់ៗខាង មុខនេះ ដើម្បីឲ្យស្ថាប័នពាក់ព័ន្ធអាចប្រើប្រាស់ និងដើម្បីឆ្លើយតបទៅនឹង អនុសាសន៍របស់ឯក ឧត្តមឧបនាយករដ្ឋមន្ត្រី។ លទ្ធផលផ្សេងៗទៀត រួមមានកិច្ចពិភាក្សាលើ សេចក្តីព្រាងនៃជំហរ របស់កម្ពុជាក្នុងកិច្ចប្រជុំលើកទី ១៧ នៅទីក្រុង ឌូបាន ដែលនឹងប្រព្រឹត្តទៅក្នុងខែធ្នូ ឆ្នាំនេះ ហើយដែលនឹងដាក់ជូនរាជរដ្ឋាភិបាលដើម្បីអនុ ម័ត។ ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** សង្ឃឹមយ៉ាង មុតមាំថា សន្និសីទសារព័ត៌មានថ្ងៃនេះនឹងផ្តល់ នូវចម្លើយ ចំពោះសំណួរពាក់ព័ន្ធនឹងការប្រែ ប្រួលអាកាសធាតុនានា។ បន្ទាប់ពីនេះ ឯកឧត្តម បណ្ឌិតបានផ្តល់ឱកាសដល់ អ្នកសារព័ត៌មាន ចោទជាសំណួរដូចខាងក្រោម៖

អ្នកស្រី Ouk Savory មកពីវិទ្យុអាស៊ីសេរី បានលើកសំណួរចំនួនពីរ ពាក់ព័ន្ធនឹងការប្រែ ប្រួលអាកាសធាតុ។ តើមានចំណុចណាខ្លះ ដែល NCCC នឹងលើកមកពិភាក្សាក្នុងកិច្ចប្រជុំ

CoP១៧នៅទីក្រុងឌូបានខាងមុខនេះ? តើរាជរដ្ឋាភិបាល និង NGOs បានបញ្ជាបការប្រែប្រួលអាកាសធាតុទៅសហគមន៍មូលដ្ឋានដោយវិធីណា?

ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** បានឆ្លើយតបទៅនឹងសំណួរទី១ថា ក្នុងកិច្ចប្រជុំ CoP១៧ ប្រទេសកម្ពុជាក្នុងនាមជាសមាជិកនៃសន្ធិសញ្ញាប្រែប្រួលអាកាសធាតុ និងពិធីសារក្យូតូ បានផ្តោតទៅលើ [១] ការផ្ទេរហិរញ្ញប្បទានបៃតងពីប្រទេសឧស្សាហកម្មនានា [២] ការផ្ទេរបច្ចេកវិទ្យាពីប្រទេសអភិវឌ្ឍន៍ទៅ LDCs ជាពិសេសក្នុងការកាត់បន្ថយ GHGs ជាពិសេសទាក់ទងនឹងការប្រើប្រាស់ថាមពលកើតឡើងវិញ និងប្រសិទ្ធភាពថាមពល [៣] ការកសាងសមត្ថភាពដល់ប្រជាជនកម្ពុជា [៤] ស្នើសុំឲ្យប្រទេសអភិវឌ្ឍន៍ផ្តល់ការគាំទ្រ និងចាត់វិធានការយ៉ាងសកម្មលើយន្តការនៃការបន្សាំ។

ឆ្លើយតបទៅនឹងសំណួរទី២ ឯកឧត្តមបណ្ឌិត មានប្រសាសន៍ថា វាគឺជាផ្នែកមួយនៃផែនការយុទ្ធសាស្ត្រជាតិក្នុងការអប់រំ ឬបញ្ជាបការប្រែប្រួលអាកាសធាតុ ទៅសហគមន៍មូលដ្ឋាន ព្រមទាំងជួយពួកគាត់ឲ្យយល់ដឹងពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។ ទាំងនេះតម្រូវឲ្យមានការចូលរួមពីថ្នាក់ក្រោមជាតិ និងសហគមន៍ ដើម្បីសម្របសម្រួលសកម្មភាពនេះ និងឈានទៅដល់ការកាត់បន្ថយ តាមរយៈការកាត់បន្ថយការបញ្ចេញ GHGs និងការពារប្រភពបញ្ចេញ GHGs និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ជាមួយនឹងគម្រោងគាំទ្រដោយភាពជាដៃគូអភិវឌ្ឍន៍អន្តរជាតិ។

លោក **Rafael D. Moreno** អ្នកតំណាងមកពី EU បានបន្ថែមថាចំពោះការប្រែប្រួលអាកាសធាតុ សកម្មភាពកាត់បន្ថយរបស់យើងត្រូវរួមគ្នា ហើយសកម្មភាពបន្សាំ ត្រូវធ្វើនៅពេលនេះ។ លោកទទូចឲ្យមានការគិតគូរ និងអនុវត្តរួមគ្នាជាសាកល និងនៅប្រទេសផ្សេងទៀតដែលមិនមែនជា ហត្ថលេខីនៃពិធីសារក្យូតូ ជាពិសេសប្រទេសចិន រុស្ស៊ី និងប្រទេសឥណ្ឌាឲ្យគិតពីទំនួលខុសត្រូវរបស់ពួកគេ ចំពោះបញ្ហាទាំងអស់នេះ។

អ្នកស្រី **Sophie Baranes** អ្នកតំណាងមកពី UNDP បានសង្កត់ធ្ងន់ពីការពង្រឹងចំណេះដឹងរបស់ប្រជាជនមូលដ្ឋាន ស្តីពីការប្រែប្រួលអាកាសធាតុ លទ្ធភាពទទួលបានឯកសារ និងព័ត៌មានពីការប្រែប្រួលអាកាសធាតុ គឺពិតជាត្រូវការជាចាំបាច់។ CCD បច្ចុប្បន្នកំពុងរៀបចំយុទ្ធសាស្ត្រព័ត៌មាន អប់រំ និងការទំនាក់ទំនង ដើម្បីផ្ទេរចំណេះដឹង និងព័ត៌មានស្តីពីសក្តានុពលនៃឥទ្ធិពលពីការប្រែប្រួលអាកាសធាតុ ទៅទូទាំងប្រទេស។ សកម្មភាពទាំងនេះ តម្រូវជាចាំបាច់នូវការចូលរួមពីសំណាក់សង្គមស៊ីវិល។ ក្នុងយុទ្ធនាការនៃការបញ្ជាបចំណេះដឹងនេះ គេអាចនឹងផ្តល់ការងារដល់ប្រព័ន្ធផ្សព្វផ្សាយ កម្មវិធីសិក្សា និងសហគមន៍កសិករជាដើម។ លើសពីនេះ ថ្នាក់ក្រោមជាតិ រួមមាន ក្រុមប្រឹក្សាឃុំ/សង្កាត់ និងស្រុក/ខណ្ឌ ក៏មានតួនាទីសំខាន់ផងដែរ ក្នុងការចែករំលែកព័ត៌មានជាមួយសហគមន៍ពួកគេ ក្នុងការផ្តល់ព័ត៌មានជាមុន ពីគ្រោះមហន្តរាយ និងផលប៉ះពាល់រយៈពេលវែងពីការប្រែប្រួលអាកាសធាតុលើជីវភាពរស់នៅរបស់ពួកគេ។

លោក **Brian Lund** មកពី OA ទាក់ទាញចំណាប់អារម្មណ៍ របស់អ្នកសារព័ត៌មានដោយលោកលើកឡើងថា ធនធានហិរញ្ញប្បទាន សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ នឹងមានរហូតដល់ ១០០ពាន់លាន ដុល្លាអាមេរិកនៅឆ្នាំ២០២០ ហើយគួរតែមានសម្រាប់ប្រទេសទាំងឡាយណាដែលរងគ្រោះដោយការប្រែប្រួលអាកាសធាតុដូចជាកម្ពុជា។ លោកក៏បានឯកភាពទៅនឹងសារៈប្រយោជន៍នៃការលើកកម្ពស់ចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុផងដែរ ដែលប្រជាជនគួរតែយល់ដឹងឲ្យបាន

ទូលំទូលាយ ពីកត្តាដែលជះឥទ្ធិពលដល់ការរស់នៅរបស់ពួកគេ។

អ្នកស្រី **Elisabeth Folkunger** អ្នកតំណាងមកពី Sida បានផ្តល់យោបល់ថា នឹងមានប្រធានបទផ្សេងៗគ្នាជាច្រើន ដែលគេនឹងលើកយកមកពិភាក្សានៅក្នុងកិច្ចប្រជុំ CoP19 នៅទីក្រុងឌូបាន។ ប្រធានបទទាំងនោះ អាចនឹងរួមបញ្ចូលទាំងការតាមដានលទ្ធផលនៃផែនការសកម្មភាពក្រុងបាលី ជាពិសេសលើការកាត់បន្ថយ ការបន្សាំ ការផ្ទេរបច្ចេកវិទ្យា និងការបែងចែកហិរញ្ញប្បទានដែលមាន និងការបង្កើត GCF សម្រាប់ការប្រែប្រួលអាកាសធាតុ។ អ្នកស្រីផ្តល់ជាអនុសាសន៍យ៉ាងមុតមាំថា កម្ពុជាគួរតែមាន យន្តការប្រែប្រួលអាកាសធាតុខ្លួនឯងជាពិសេសជំនួយហិរញ្ញប្បទាន។

ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** មានប្រសាសន៍បន្តថា កម្ពុជាមិនកំពុងរង់ចាំនូវ GCF នោះទេ ព្រោះដំណើរការនៃចរចារនៅក្នុងកិច្ចប្រជុំ CoP បានប្រើប្រាស់ពេលអស់ជាច្រើនឆ្នាំមកហើយ និងកម្ពុជាកំពុងធ្វើការយ៉ាងសកម្មលើ ផែនការយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយ និងការបន្សាំដោយខ្លួនឯង និងដោយមានជំនួយឧបត្ថម្ភពី DPs។ ឧទាហរណ៍ MOWRAM បានរៀបចំឲ្យ មានយុទ្ធសាស្ត្រទាក់ទងនឹងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ រួចរាល់ហើយ ដោយបង្កើតនូវផែនការយុទ្ធសាស្ត្រមួយ ដើម្បីបញ្ចៀសការជន់លិចពីទឹកជំនន់។

លោក **អ៊ុយ ប៊ុនមី** មកពីទូរទស្សន៍ជាតិកម្ពុជា បានសួរសំណួរចំនួន០៣។ តើកម្ពុជាបានទទួលប្រយោជន៍អ្វីខ្លះពីកិច្ចខិតខំប្រឹងប្រែងលើការកាត់បន្ថយការបញ្ចេញ GHGs បើកម្ពុជាមិនមានកាតព្វកិច្ចក្នុងការកាត់បន្ថយនោះ? ទាក់ទងនឹងប្រព័ន្ធឥណទានកាបូន តើកម្ពុជាទទួលបានឥណទានកាបូន បានប៉ុន្មានហើយមកទល់នឹងបច្ចុប្បន្ននេះ? នៅថ្ងៃអនាគត តើកម្ពុជាមានផែនការនឹងដាំព្រៃឈើឡើងវិញដើម្បីទទួលបានឥណទានកាបូនកាន់តែច្រើន ដើម្បីការគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិដែរ ឬទេ?

ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** បានឆ្លើយតបនឹងសំណួរថា កម្ពុជាមិនមែនជាអ្នកបញ្ចេញ GHGs ខ្ពស់ដូចជាប្រទេសឧស្សាហកម្មនោះទេ ប៉ុន្តែសកម្មភាពកាត់បន្ថយ ត្រូវតែអនុវត្តរួមគ្នា ហើយសកម្មភាពបន្សាំ ត្រូវតែអនុវត្តនៅពេលនេះ ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ បន្ថែមពីនេះទៀត កម្ពុជាក៏បានទទួលប្រយោជន៍ជាច្រើនក្នុងការការពារបរិស្ថាន តាមរយៈការចូលរួមកាត់បន្ថយ GHGs ផងដែរ ជាពិសេសសព្រៃឈើ ធនធានធម្មជាតិ និងជីវចម្រុះ នៅកម្ពុជាអាចត្រូវបានការពារ។ ចំពោះមូលនិធិ រាជរដ្ឋាភិបាលបានកំណត់ ថានឹងប្រើប្រាស់មូលនិធិ ៥0% នៃមូលនិធិសរុបដើម្បីគាំទ្រដល់ ការអភិវឌ្ឍសហគមន៍មូលដ្ឋាន និងសកម្មភាពអភិរក្សផ្សេងៗ។ មូលនិធិនេះនឹងប្រើសម្រាប់ការលើកកម្ពស់ជីវភាពរស់នៅ របស់ប្រជាជនមូលដ្ឋាន ដែលរស់នៅជុំវិញតំបន់ព្រៃការពារ តាមរយៈគោលនយោបាយអភិវឌ្ឍន៍ជនបទ។ ចំពោះផែនការដាំព្រៃឈើឡើងវិញ វាប្រាកដណាស់ថា យើងនឹងអនុវត្តនូវសកម្មភាពនេះព្រោះវាស្របទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។ RGC នឹងប្រើប្រាស់ឥណទានកាបូន ដើម្បីដាំព្រៃឈើនៅតំបន់ណាដែលមានការសឹករិចរិលព្រៃឈើ។

លោក **គីម ឆៀង** អ្នកតំណាងមកពីបណ្តាញអប្សរា បានលើកជាសំណួរចំនួន០២។ នៅក្នុងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុកម្ពុជាទទួលបានគម្រោងចំនួន០៨ តើគម្រោងទាំងនោះ ទទួលបានមូលនិធិចំនួនប៉ុន្មាន និងបានមកពីណា? ទាក់ទងនឹងបញ្ហាប្រែប្រួលអាកាសធាតុ តើកម្ពុជានឹងមានសកម្ម

ភាពអ្វីខ្លះ ប្រសិនបើប្រទេសអភិវឌ្ឍន៍នៅតែពុំយល់ព្រមចុះហត្ថលេខាលើសន្ធិសញ្ញានោះ?

ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** បានឆ្លើយតបនឹងសំណួរថា ចំពោះគម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ ដែលបានអនុវត្តនៅកម្ពុជា សហការីរបស់ឯកឧត្តមនឹងឆ្លើយតបនឹងសំណួរនេះ។ ទាក់ទងនឹងសំណួរទី០២ ឯកឧត្តមមានប្រសាសន៍ថា នាពេលបច្ចុប្បន្ននេះ មានវេទិកាតស៊ូមតិដ៏ក្តៅគគុក ហើយមានការមិនឯកភាពគ្នាលើ គោលនយោបាយប្រែប្រួលអាកាសធាតុ ជាពិសេសនៅពេល ដែលពិធីសារក្យូតូនឹងត្រូវបញ្ចប់នៅក្នុងឆ្នាំ២០១២នេះ។ នៅតែមិនទាន់ប្រាកដនៅឡើយទេ ថាតើពិធីសារក្យូតូនឹងនៅតែបន្ត ឬយ៉ាងណាទេ។ កម្ពុជា និងប្រទេសជាសមាជិករបស់ G៧៧ នៅតែទាមទារឲ្យបន្តពិធីសារនេះ ដែលជម្រុញឲ្យប្រទេសឧស្សាហកម្មផ្តល់មូលនិធិ ផ្ទេរបច្ចេកវិទ្យា និងកសាងសមត្ថភាពសម្រាប់ DPs ។

អ្នកស្រី **Sophie Baranes** អ្នកតំណាងមកពី UNDP បានឆ្លើយតបនឹងសំណួរទី០១ខាងលើថា បច្ចុប្បន្នមានគម្រោងចំនួន០៨ ត្រូវបានអនុម័តដោយ CCCA ក្រោមការគ្រប់គ្រងដោយ MoE តំណាងឲ្យ NCCC ។ គម្រោងទាំងនោះគឺមានភាពពាក់ព័ន្ធនឹងវិស័យព្រៃឈើ ជលផល កសិកម្ម ការគ្រប់គ្រងធនធានទឹក ប្រព័ន្ធធារាសាស្ត្រខ្នាតតូច ការធ្វើផែនការទីក្រុង និងសមត្ថភាពមន្ត្រីរាជការថ្នាក់មូលដ្ឋាន។ ថវិកាសរុបចំនួន២លានដុល្លាអាមេរិក ត្រូវបានគេអនុម័តផ្តល់ដល់ គម្រោងទាំងនោះ ដែលគម្រោងនីមួយៗ ទទួលជំនួយចាប់ពី ២០០.០០០ដុល្លាទៅ៣០០.០០០ដុល្លាអាមេរិក។ មូលនិធិទាំងនេះមានប្រភពមកពី EU Sida DANIDA និង UNDP ។

ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ ១- កម្មវិធី

ថ្ងៃទី១	ថ្ងៃច័ន្ទ ទី០៣ ខែតុលា ឆ្នាំ២០១១
	កម្មវិធីបើកនៅវិមានសន្តិភាព
០៨.០០ – ០៨.៣០	• ការអញ្ជើញមកដល់ របស់ឯកឧត្តម លោកជំទាវ ឧកញ៉ា សមាជិក សមាជិកា ការអញ្ជើញមកដល់ របស់ភ្ញៀវជាតិ និងអន្តរជាតិ
០៨.៣០	• ការអញ្ជើញមកដល់របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
	ចាប់ផ្តើមកម្មវិធី
០៨.៣០	• ការប្រកាសរបៀបវារៈ នៃពិធីបើក • ការគោរពភ្លេងជាតិ នៃព្រះរាជាណាចក្រកម្ពុជា • សុន្ទរកថាស្វាគមន៍ដោយឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ • សុន្ទរកថាបើកវេទិកាជាតិដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា • ការអញ្ជើញនិវត្តរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី **យឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
១០.៣០	ការប្រកាសបិទពិធីបើកវេទិកាជាតិលើកទី ២ ស្តីពីការប្រែប្រួលអាកាសធាតុ
	កម្មវិធីពេលរសៀល
១២.៣០ – ១៣.៣០	ការចុះឈ្មោះ **<u>ទីកន្លែង ៖</u>** សណ្ឋាគារ អាំងទែកុងទីណង់តាល់
១៣.៣០– ១៣.៤០	ការប្រកាសរបៀបវារៈ:
១៣.៤០– ១៣.៥៥	សុន្ទរកថាស្វាគមន៍របស់លោក Douglas Broderick អ្នកសម្របសម្រួលរបស់កម្មវិធីសហប្រជាជាតិប្រចាំនៅកម្ពុជា
១៣.៥៥– ១៤.១០	សុន្ទរកថាស្វាគមន៍របស់ ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
	១. វគ្គចាប់ផ្តើម
	សហប្រធាន ៖
	១. ឯកឧត្តម ចាយ សាមិត្ត ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ (GDANCP) ក្រសួងបរិស្ថាន ២. ឯកឧត្តម ប៉ុន ណារិទ្ធិ អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះ

	មហន្តរាយ និងជាសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
១៤.១០–១៤.២៥	**បច្ចុប្បន្នភាពនៃព័ត៌មានវិទ្យាសាស្ត្រ ផលប៉ះពាល់ និងកាលានុវត្តភាពនៃការប្រែប្រួលអាកាសធាតុ** បទបង្ហាញនេះនឹងផ្តល់នូវព័ត៌មានថ្មីបំផុត អំពីវិទ្យាសាស្ត្រ ផលប៉ះពាល់ និងកាលានុវត្តភាពនៃការប្រែប្រួលអាកាសធាតុ ដោយផ្អែកលើរបាយការណ៍វាយតម្លៃលើកទី ៥ របស់ក្រុមប្រឹក្សាអន្តរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុ (IPCC) និងលទ្ធផលនៃការស្រាវជ្រាវគួរទុកចិត្តបានផ្សេងទៀត វាគ្មិន៖ លោក ***Mozaharul Alam*** អ្នកសម្របសម្រួលការប្រែប្រួលអាកាសធាតុប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក នៃកម្មវិធីបរិស្ថានសហប្រជាជាត (១៥នាទី)
១៤.២៥–១៤.៤៥	**បច្ចុប្បន្នភាពអំពីការអភិវឌ្ឍថ្មីៗ និងគំនិតផ្តួចផ្តើមសំខាន់ៗលើការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា** គោលបំណងនៃបទបង្ហាញនេះ គឺធ្វើការរាយការណ៍នូវការរីកចម្រើនរបស់ប្រទេសកម្ពុជាក្នុងការកសាងសមត្ថភាពស្ថាប័នរបស់ខ្លួន ការបញ្ជ្រាបការងារការប្រែប្រួលអាកាសធាតុទៅក្នុងផែនការតាមវិស័យ និងផែនការថ្នាក់ជាតិ និងការអនុវត្តន៍គំនិតផ្តួចផ្តើមការងារការប្រែប្រួលអាកាសធាតុសំខាន់ៗ វាគ្មិន៖ លោក អ៊ុយ កាម៉ាល ប្រធានការិយាល័យសារពើភ័ណ្ឌ និងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ក្រសួងបរិស្ថាន (២០នាទី)
១៤.៤៥–១៥.០៥	**បទបង្ហាញអំពីលទ្ធផលសំខាន់ៗ នៃរបាយការណ៍ជាតិលើកទី ២** បទបង្ហាញនេះនឹងផ្តល់នូវសេចក្តីសង្ខេបអំពីសារពើភ័ណ្ឌឧស្ម័នផ្ទះកញ្ចក់ឆ្នាំ ២០០០ លទ្ធផលនៃការវិភាគការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ និងការវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំ ក៏ដូចជាព័ត៌មានផ្សេងៗទៀត ដែលមាននៅក្នុងរបាយការណ៍ជាតិលើកទី ២របស់កម្ពុជានៅក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ វាគ្មិន៖ បណ្ឌិត ទិន ពន្លក អគ្គនាយករង GDANCP និងជាប្រធានលេខាធិការដ្ឋានមូលនិធិប្រែប្រួលអាកាសធាតុ CCCA ក្រសួងបរិស្ថាន (២០នាទី)
១៥.០៥– ១៥.៣៥	សំណួរ - ចម្លើយ (៣០ នាទី)
១៥.៣៥– ១៥.៥០	សម្រាកពិសារអាហារសម្រន់
១៥.៥០– ១៧.៣៥	វគ្គស្របគ្នា

វគ្គស្របគ្នាទី១៖

១. បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ - ជោគជ័យ ការប្រឈម និងមេរៀនទទួលបាន	២. ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ - ស្ថានភាពការរីកចម្រើន មេរៀនទទួលបាន ភាពខ្វះចន្លោះផ្អែកគោលនយោបាយនិងអនុសាសន៍
ទីន្លែង ៖ បន្ទប់ Ball Room II សណ្ឋាគារ អាំងទែកុងទីណង់តាល់	**ទីន្លែង ៖** បន្ទប់ Ball Room III សណ្ឋាគារ អាំងទែកុងទីណង់តាល់
សហប្រធាន៖	សហប្រធាន៖
១. លោក កែន សេរីរដ្ឋាអគ្គនាយករង GDANCP ក្រសួងបរិស្ថាន	១. ឯកឧត្តមបណ្ឌិត សាត សាមី រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និងជាអនុប្រធាន NCCC
២. លោក Koen Everaert អនុព័ន្ធទទួលបន្ទុក	

សហប្រតិបត្តិការប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា

១. ស្ថានភាព នៃការអនុវត្តកម្មវិធីសកម្មភាពជាតិបន្ទាន់នឹងការប្រែប្រួលអាកាសធាតុ (NAPA) និងគម្រោងបន្ទាន់នឹងការប្រែប្រួលអាកាសធាតុ សម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម (គម្រោងអនុវត្តក្រោម NAPA)

បទបង្ហាញនេះនឹងផ្តោតជាសំខាន់លើស្ថានភាពទូទៅនៃការអនុវត្តកម្មវិធី NAPAនាពេលបច្ចុប្បន្ន និងការរីកចម្រើននៃគម្រោងដែលអនុវត្តដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

វាគ្មិន (១៥នាទី) ៖

១. លោកបណ្ឌិត ហេង ចាន់ធឿន អនុប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន

២. លោក ហុក គឹមធួន ប្រធានគម្រោងថ្នាក់ជាតិ អង្គភាពគាំទ្រគម្រោង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

២.កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) និងកម្មវិធីសាកល្បងសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ (PPCR)

បទបង្ហាញនេះ នឹងអត្ថាធិប្បាយអំពីគោលបំណង សកម្មភាពសំខាន់ៗ ការរីកចម្រើន និងជំហានបន្ទាប់របស់គំនិតផ្តួចផ្តើមដ៏សំខាន់ទាំង២ នេះរួមមាន។

វាគ្មិន (១៥នាទី) ៖

១. លោក សុំ ធី ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជាអ្នកសម្របសម្រួលគម្រោងការអភិវឌ្ឍគោលនយោបាយប្រែប្រួលអាកាសធាតុនិងការគ្រងគ្រងចំណេះដឹងរបស់កម្មវិធី CCCA ក្រសួងបរិស្ថាន

២. លោក មាស សុផល អគ្គនាយករង GDANCP ក្រសួងបរិស្ថាន

៣. ការប្រែប្រួលអាកាសធាតុ និងសុខភាព

បទបង្ហាញនេះ នឹងផ្តល់នូវបច្ចុប្បន្នភាពចុងក្រោយបំផុត នៃគំនិតផ្តួចផ្តើមរបស់ ក្រសួងសុខាភិបាល/អង្គការសុខភាពពិភពលោក ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងវិស័យសុខា

២. ឯកឧត្តម ឆេង គីមស៊ុន ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ

១. ស្ថានភាព និងចក្ខុវិស័យនៃទីផ្សារកាបូនស្ម័គ្រចិត្ត

បទបង្ហាញនេះ នឹងផ្តល់នូវព័ត៌មានអំពីសាវតានៃការកកើតទីផ្សារកាបូនស្ម័គ្រចិត្ត និងពិនិត្យឡើងវិញនូវស្ថានភាព និងចក្ខុវិស័យរបស់វា នៅក្នុងស្រុក និងលើពិភពលោក ហើយនឹងផ្តល់នូវអនុសាសន៍ខាងគោលនយោបាយមួយចំនួន សម្រាប់ឲ្យកម្ពុជាត្រៀមខ្លួនក្នុងការចូលរួមក្នុងទីផ្សារកាបូនស្ម័គ្រចិត្ត នាពេលអនាគត។

វាគ្មិន៖ អ្នកស្រី***Marion Verles*** នាយកប្រតិបត្តិក្រុមហ៊ុនណិចស៊ុសកាបូនសម្រាប់អភិវឌ្ឍន៍(១០នាទី)

២. ទីផ្សារកាបូនជាប់កាតព្វកិច្ច៖ ពីពិធីសារក្យូតូឈានទៅយន្តការទីផ្សារថ្មីៗ

បទបង្ហាញនេះនឹងអធិប្បាយពីស្ថានភាពយន្តការក្យូតូសំខាន់ៗ ដែលមាននៅក្រោមទីផ្សារជាប់កាតព្វកិច្ច និងបង្ហាញអំពីយន្តការទីផ្សារនាពេលអនាគត ដែលមានសក្តានុពល(ពិធីសារក្យូតូក្រោយឆ្នាំ២០១២ ការកាត់បន្ថយការបញ្ចេញឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ (REDD+) សំណើសំខាន់ៗមួយចំនួនរបស់ភាគីជាសមាជិកអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ)

វាគ្មិន៖ អ្នកស្រី ***Akiko Fukui*** ជំនួយការស្រាវជ្រាវនៃក្រុមយន្តការទីផ្សារ អង្គការអាយចេស IGES (១០នាទី)

៣. ស្ថានភាពបច្ចុប្បន្ននៃយន្តការអភិវឌ្ឍស្អាត និងឧទាហរណ៍មួយនៃគម្រោងយន្តការអភិវឌ្ឍន៍ស្អាតនៅប្រទេសកម្ពុជា

បទបង្ហាញនេះនឹងធ្វើការសង្ខេប នូវស្ថានភាពនាពេលបច្ចុប្បន្ននៃការអនុវត្តគម្រោង CDM នៅកម្ពុជា ដោយលើកយកឧទាហរណ៍មួយនៃគម្រោង CDM ដែលកំពុងអនុវត្តមកបង្ហាញ (គម្រោង Angkor BioCogen)។

វាគ្មិន (១៥នាទី) ៖

១. លោក អ៊ុយ កាម៉ាល ប្រធានការិយាល័យសារពើភ័ណ្ឌនិងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ ក្រសួងបរិស្ថាន

	ភិបាល។ វាគ្មិន៖ លោក កុល ហៅរ៉ូ អនុប្រធាននាយកដ្ឋានការពារសុខភាព ក្រសួងសុខាភិបាល (១៥នាទី)
	៤. ការប្រែប្រួលអាកាសធាតុ និងសន្តិសុខស្បៀង៖ បរិបទប្រទេសកម្ពុជា បទបង្ហាញនេះ នឹងធ្វើការពិនិត្យឡើងវិញនូវផលប៉ះពាល់ ជាសក្តានុពលនៃការប្រែប្រួលអាកាសធាតុ លើសន្តិសុខស្បៀងនៅកម្ពុជា អនុសាសន៍ផ្នែកគោលនយោបាយដែលបានស្នើឡើង និងសកម្មភាពការងាររបស់ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD)ក្នុងការដោះស្រាយបញ្ហានេះ។ វាគ្មិន៖ ឯកឧត្តម ស៊ុន ដារិទ្ធិ អគ្គលេខាធិការរង នៃក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (CARD) នៃទីស្តីការគណៈរដ្ឋមន្ត្រី (១៥នាទី)
	២. លោក អាឌីសន ជូ នាយកគ្រប់គ្រងក្រុមហ៊ុនអង្គរ បាយអូ កូជេន កូអេលធីឌី
	៤. ផែនទីបង្ហាញផ្លូវអំពីកម្មវិធី REDD+ របស់ប្រទេសកម្ពុជា បទបង្ហាញនេះ នឹងពន្យល់ពីប្រវត្តិ ដំណើរការគោលបំណង ផ្នែកសំខាន់ៗ អ្នកដើរតួនាទី សំខាន់ៗ ស្ថានភាពនាពេលបច្ចុប្បន្ន និងជំហានបន្ទាប់នៃផែនទីបង្ហាញផ្លូវ REDD+ របស់ប្រទេសកម្ពុជា។ វាគ្មិន៖ លោកបណ្ឌិត កែវ អូម៉ាលីស អនុប្រធាននាយកដ្ឋានសត្វព្រៃ និងជីវចម្រុះ រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ (១៥នាទី)
	៥. ជម្រើសគោលនយោបាយសម្រាប់REDD+នៅតំបន់ការពារធម្មជាតិ គោលបំណងនៃបទបង្ហាញនេះ គឺផ្តោតលើលទ្ធផលនៃករណីសិក្សាថ្មីៗ ដែលបានរៀបចំដោយមជ្ឈមណ្ឌល សម្រាប់គោលនយោបាយខ្យល់ស្អាត ស្តីពីជម្រើសគោលនយោបាយ សម្រាប់ការអនុវត្ត REDD+ ក្នុងតំបន់ការពារធម្មជាតិ។ វាគ្មិន៖ លោក David Ashwell អ្នកជំនាញការឯករាជ្យ (១៥នាទី)
(បន្ទាប់ពីបទបង្ហាញនីមួយៗ នឹងមានកម្មវិធីសំណួរ-ចម្លើយរយៈពេល ១០ នាទី)	
១៧.៣៥ – ១៧.៤៥	ការសង្ខេប និងបិទកម្មវិធី
១៧.៤៥– ២០.០០	ពិធីជប់លៀងភេសជ្ជៈពេលល្ងាច **<u>ទីកន្លែង ៖</u>** អ៊ុមភឺរៀល ១(Imperial I) ជាន់ទី ៣ សណ្ឋាគារអាំងទែកុងទីណង់តាល់
ថ្ងៃទី២	**ថ្ងៃអង្គារ ទី០៤ ខែតុលា ឆ្នាំ២០១១**
០៧.៣០ –០៨.៤៥	ការចុះឈ្មោះ **<u>ទីកន្លែង ៖</u>** សណ្ឋាគារ អាំងទែកុងទីណង់តាល់
០៨.៤៥ – ០៩.១៥	ការចាប់ផ្តើមកម្មវិធី
	សុន្ទរកថាស្វាគមន៍ ដោយលោក Peter J. Brimble សេដ្ឋវិទូជាន់ខ្ពស់នៃធនាគារអភិវឌ្ឍន៍អាស៊ី
	សុន្ទរកថាស្វាគមន៍ ដោយឯកឧត្តម ស៊ុយ សែម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល
០៩.១៥ – ០៩.២៥	ការសង្ខេប នៃសកម្មភាពថ្ងៃទី ១ និងការជម្រាបជូន អំពីសកម្មភាពថ្ងៃទី ២
០៩.២៥ – ០៩.៤០	សម្រាកពិសារអាហារសម្រន់

០៩.៤០ – ១១.៤៥ វគ្គស្របគ្នា (បន្ត)	
<u>វគ្គស្របគ្នាទី២៖</u>	
1. បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ - ជោគជ័យ ការប្រឈម និងមេរៀនទទួលបាន **<u>ទីន្លែង ៖</u>** បន្ទប់ Ball Room II សណ្ឋាគារ អាំងទែកុងទីណង់តាល់	2. ការកាត់បន្ថយការប្រែប្រួលអាកាសធាតុ - ស្ថានភាព ការរីកចម្រើន មេរៀនទទួលបាន ភាពខ្វះចន្លោះផ្នែកគោលនយោបាយនិងអនុ-សាសន៍ **<u>ទីន្លែង ៖</u>** បន្ទប់ Ball Room III សណ្ឋាគារ អាំងទែកុងទីណង់តាល់
សហប្រធាន៖	សហប្រធាន៖
១. លោក កែន សេរីរដ្ឋាអគ្គនាយករង GDANCP ក្រសួងបរិស្ថាន ២. លោក Koen Everaert អនុព័ន្ធទទួលបន្ទុកសហប្រតិបត្តិការប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា	១. ឯកឧត្តមបណ្ឌិត សាត សាមី រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ជាអនុប្រធាន NCCC ២. ឯកឧត្តម ឆេង គីមស៊ុន ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលព្រៃឈើ
៥. ការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ (DRR) បទបង្ហាញនេះនឹងផ្តោតជាសំខាន់លើកិច្ចខិតខំប្រឹងប្រែងរបស់គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (NCDM) ក្នុងការឆ្លើយតបនឹងគ្រោះមហន្តរាយអាកាសធាតុ រួមមានស្ថានភាពនៃការអនុវត្តផែនការសកម្មភាពយុទ្ធសាស្ត្រថ្នាក់ជាតិសម្រាប់ DRR ដោយផ្តោតជាសំខាន់លើការឆ្លើយតបដោយសហគមន៍ និងមេរៀនទទួលបាន។ វាគ្មិន៖ លោក សុទ្ធ គឹមកុលមុនី អនុប្រធាននាយកដ្ឋានត្រៀមរៀបចំ និងបណ្តុះបណ្តាលនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ (២០ នាទី)	***៦. ការអភិវឌ្ឍបៃតង ការអភិវឌ្ឍដែលបំភាយកាបូនកម្រិតទាប*** បទបង្ហាញនេះនឹង ធ្វើការពិនិត្យនូវទស្សនទានការអភិវឌ្ឍបៃតង ទំនាក់ទំនងវាជាមួយនឹងការប្រែប្រួលអាកាសធាតុ និងកត្តាដែលជម្រុញដល់ការអនុវត្តប្រកបដោយជោគជ័យ នៃទស្សនទាននេះក្នុងប្រទេសកម្ពុជា។ វាគ្មិន៖ អ្នកស្រី Aneta Nikolova មន្ត្រីកិច្ចការ បរិស្ថាន ផ្នែកបរិស្ថាន និងការអភិវឌ្ឍនៃអង្គការ UNESCAP (២០ នាទី)
៦. គំនិតផ្តួចផ្តើម ក្នុងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មាការទន្លេមេគង្គ៖ ឧទាហរណ៍នៃគម្រោងបន្សាំថ្នាក់តំបន់ គោលបំណងនៃបទបង្ហាញនេះ គឺធ្វើការចែករំលែក នូវបទពិសោធន៍ នៃគំនិតផ្តួចផ្តើមបន្សាំទូទាំងអាងទន្លេមេគង្គ ដែលមានចំណងជើងថា "គំនិតផ្តួចផ្តើមបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ"។ វាគ្មិន៖ បណ្ឌិត Kien Tran-Mai មន្ត្រីកម្មវិធីប្រែប្រួលអាកាសធាតុ នៃគណៈកម្មាធិការទន្លេមេគង្គ (២០នាទី)	***៧. ទីផ្សារថាមពលកកើតឡើងវិញ ក្នុងប្រទេសកម្ពុជា៖ ផ្នាំងស្រូបថាមពលពន្លឺព្រះអាទិត្យ និងបច្ចេកវិទ្យាថាមពលខ្យល់*** បទបង្ហាញនេះ នឹងធ្វើការពិនិត្យឡើងវិញផ្នែកលើទស្សនៈរបស់វិស័យឯកជនអំពីការវិវត្ត ស្ថានភាពនាពេលបច្ចុប្បន្ន ឧបសគ្គ និងចក្ខុវិស័យនៃទីផ្សារផ្នាំងស្រូបថាមពលពន្លឺព្រះអាទិត្យ និងបច្ចេកវិទ្យាថាមពលខ្យល់ក្នុងប្រទេសកម្ពុជា។ វាគ្មិន៖ អ្នកស្រី Margaret Jane Ryan ក្រុមហ៊ុនខ្មែរសូឡា (១៥នាទី)

៧. ឧបសគ្គសម្រាប់ការបន្សាំប្រកបដោយប្រសិទ្ធភាព បទពិសោធន៍ថ្នាក់តំបន់ និងសកល និងអនុសាសន៍គោលនយោបាយសម្រាប់កម្ពុជា

បទបង្ហាញនេះ នឹងធ្វើការពិភាក្សាអំពីបទពិសោធន៍ថ្នាក់តំបន់ និងអន្តរជាតិ ក្នុងការអនុវត្តន៍សកម្មភាពបន្សាំដោយផ្តោតលើឧបសគ្គមេរៀនទទួលបានការអនុវត្តន៍ល្អបំផុត និងអនុសាសន៍គោលនយោបាយសំខាន់ៗ ដែលប្រទេសកម្ពុជាអាចទទួលបានអត្ថប្រយោជន៍។

វាគ្មិន (២០នាទី) ៖

១. លោក Alex Heikens ទីប្រឹក្សាផ្នែកគោលនយោបាយការប្រែប្រួលអាកាសធាតុ ថ្នាក់តំបន់នៃការិយាល័យ UNDP ប្រចាំតំបន់អាស៊ី និងប៉ាស៊ីហ្វិក

២. បណ្ឌិត Richard Friend វិទ្យាស្ថានសម្រាប់អន្តរភាពសង្គមនិងបរិស្ថាន ISET

៨. ភាពជាដៃគូផ្នែកថាមពល និងបរិស្ថាននៅតំបន់មេគង្គ៖ ឧទាហរណ៍ អំពីការកាត់បន្ថយការប្រែប្រួលអាកាសធាតុថ្នាក់តំបន់

គោលបំណងនៃបទបង្ហាញនេះ គឺធ្វើការចែករំលែកបទពិសោធន៍ នៃគំនិតផ្តួចផ្តើមក្នុង អនុតំបន់ទន្លេមេគង្គ ដែលមានចំណងជើងថា "កម្មវិធីភាពជាដៃគូផ្នែកថាមពល និងបរិស្ថានក្នុងតំបន់មេគង្គ" ដើម្បីលើកកម្ពស់ការអភិវឌ្ឍថាមពលនិរន្តរភាព និងការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់។

វាគ្មិន៖ អ្នកស្រី Kati Veijonen អគ្គកុងស៊ុលស្ថានទូតបហ្វាំងឡង់ ប្រចាំនៅក្រុងបាងកក (១៥នាទី)

៩. គោលនយោបាយកាបូន៖ បទពិសោធន៍ថ្នាក់តំបន់ និងពិភពលោកឧបសគ្គសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័ននៅកម្ពុជា និងសំណើវិធានការឆ្លើយតប

បទបង្ហាញនេះ នឹងផ្តោតជាសំខាន់ លើគំរូគោលនយោបាយឥណទានកាបូន ដែលមានជោគជ័យនិងសមស្របពាក់ព័ន្ធនឹងកម្មសិទ្ធិ ពន្ធដារ ការគ្រប់គ្រង។ល។ ហើយធ្វើការពិភាក្សាអំពីឧបសគ្គមេរៀនទទួលបាន ការអនុវត្តល្អបំផុតនិងអនុសាសន៍គោលនយោបាយសំខាន់ៗ ដែលកម្ពុជាអាចទទួលយកបាន។

វាគ្មិន៖ បណ្ឌិត Thanak De Lopez នាយកគ្រប់គ្រង Ecofia (១៥ នាទី)

(បន្ទាប់ពីបទបង្ហាញនីមួយៗនឹងមានកម្មវិធីសំណួរ-ចម្លើយរយៈពេល ១៥ នាទី)

១១.៤៥–១៣.៤៥ អាហារថ្ងៃត្រង់

ទីកន្លែង៖ អ៊ិមភីរៀល ១ (Imperial I) សណ្ឋាគារ អាំងទែកុងទីណង់តាល់

១៣.៤៥–១៤.៥៥ វគ្គស្របគ្នាទី ៣

ការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ	បញ្ហាអន្តរវិស័យនៃការប្រែប្រួលអាកាសធាតុ
ទីកន្លែង៖ បន្ទប់ Ball Room II សណ្ឋាគារ អាំងទែកុងទីណង់តាល់	**ទីកន្លែង៖** បន្ទប់ Ball Room III សណ្ឋាគារ អាំងទែកុងទីណង់តាល់
សហប្រធាន៖	សហប្រធាន៖
១. ឯកឧត្តម ស្រ៊ុន តារា អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិក NCCC	១. លោក ម៉ែង មុន្នីរក្ស អនុប្រធាននាយកដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវចម្រុះ ក្រសួងបរិស្ថាន
២. អ្នកស្រី Elisabeth Folkunger	២. ឯកឧត្តម គុល វឌ្ឍនា សមាជិក NCCC និងជាអគ្គនាយករង គណៈកម្មាធិការជាតិទន្លេមេគង្គ

អ្នកឯកទេសខាងបរិស្ថាន និងការប្រែប្រួលអាកាសធាតុ SIDA	កម្ពុជា

១. ការសម្របសម្រួល និងប្រសិទ្ធភាពជំនួយ បទបង្ហាញនេះ នឹងធ្វើការពិភាក្សាអំពីការរីកចម្រើននៃការលើកកម្ពស់ប្រសិទ្ធភាពជំនួយ ដោយផ្តោតសំខាន់លើការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ វាគ្មិន៖ លោក រស់ សាលីន ប្រធាននាយកដ្ឋានគោលនយោបាយ និងសម្របសម្រួលជំនួយ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (២០នាទី)	***១. ជីវចម្រុះ និងការប្រែប្រួលអាកាសធាតុ*** បទបង្ហាញនេះ នឹងផ្តោតលើតស្តុតាងដែលអាចទុកចិត្តបាននៃផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុ នាពេលអតីតកាល លើជីវចម្រុះក្នុងប្រទេសកម្ពុជា ផលប៉ះពាល់ជាសក្តានុពលលើជីវចម្រុះក្រោមសេណារីយ៉ូប្រែប្រួលអាកាសធាតុផ្សេងៗ ផលប៉ះពាល់ជាសក្តានុពលនៃវិធានការឆ្លើយតប ទៅនឹងការប្រែប្រួលអាកាសធាតុលើជីវចម្រុះ វិស័យអាទិភាពសម្រាប់ការស្រាវជ្រាវនាពេលអនាគត និងអនុសាសន៍ គោលនយោបាយសំខាន់ៗ។ វាគ្មិន៖ បណ្ឌិត Geoffrey Blate ទីប្រឹក្សាជាន់ខ្ពស់សម្រាប់ការអភិរក្សទេសភាព និងការប្រែប្រួលអាកាសធាតុ កម្មវិធីមហាអនុតំបន់ទន្លេមេគង្គ WWF (២០នាទី)
២. ហរិញ្ញវត្ថុសម្រាប់ការបន្សាំ បទបង្ហាញនេះនឹងធ្វើការពិភាក្សាពីស្ថានភាពនាពេលបច្ចុប្បន្ននៃការផ្តល់ហិរញ្ញវត្ថុសម្រាប់បន្សាំ ទាំងខាងផ្គង់ផ្គង់ និងខាងតម្រូវការ ជាពិសេសក្នុងប្រទេសដែលមានការអភិវឌ្ឍតិចតួច។ វាគ្មិន៖ លោកស្រី ភាណ សោភ័ណ ទីប្រឹក្សាគោលនយោបាយថ្នាក់តំបន់ អង្គការអ៊ុកស្វាមអាមេរិកាំង (២០នាទី)	***២. យេនឌ័រ និងការប្រែប្រួលអាកាសធាតុ*** បទបង្ហាញនេះ នឹងធ្វើការពិភាក្សាលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបតាមរយៈទស្សនវិស័យយេនឌ័រ និងផ្តល់មេរៀនទទួលបានពីថ្នាក់តំបន់ សម្រាប់ធ្វើការរៀបចំនូវវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដោយមានការគិតគូរអំពីយេនឌ័រ។ វាគ្មិន៖ អ្នកស្រី Annaka Peterson Carvalho អ្នកសម្របសម្រួលកម្មវិធីថ្នាក់តំបន់អង្គការអ៊ុកស្វាមអាមេរិកាំង (២០នាទី)
(បន្ទាប់ពីបទបង្ហាញនីមួយៗ នឹងមាន កម្មវិធីសំណួរ-ចម្លើយរយៈពេល ១៥ នាទី)	

១៤.៤៥–១៥.១០	សម្រាកពិសារអាហារសម្រន់
១៥.១០–១៦.២០	៤.វគ្គពេញអង្គ- ការផ្តល់ហិរញ្ញប្បទានប្រែប្រួលអាកាសធាតុ (បន្ត)
	សហប្រធាន៖
	១. ឯកឧត្តម ស្រ៊ុន តារា អនុរដ្ឋលេខាធិកា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិក NCCC
	២. លោកស្រី Sophie Baranes នាយិការង UNDP ប្រចាំប្រទេសកម្ពុជា

	១. ពិធីប្រកាសគម្រោង ដែលបានជ្រើសរើសនៅក្រោមការប្រកាសទទួលសំណើគម្រោងលើកទី១នៃមូលនិធិប្រែប្រួលអាកាសធាតុ CCCA ដោយលេខាធិការដ្ឋានមូលនិធិ CCCA ពិធីនេះនឹងណែនាំអំពីសារតារបស់មូលនិធិ CCCA និងបង្ហាញអំពីគម្រោងទទួលជំនួយថ្មីចំនួន ៨ ដែលបានជ្រើសរើសដោយមូលនិធិ CCCA ក្រោមការប្រកាសទទួលសំណើគម្រោងលើកទី១ វាគ្មិន (៣០ នាទី) ៖ ១. បណ្ឌិត ទិន ពន្លក អគ្គនាយករង GDANCP និងជាប្រធានលេខាធិការដ្ឋានមូលនិធិ CCCA ក្រសួងបរិស្ថាន ២. លោកស្រីបណ្ឌិត កៅ សុជីវី អគ្គនាយករងរដ្ឋបាលជលផល ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ៣. លោក ជាសារិទ្ធ ប្រធានអង្គការ WOMEN ៤. លោកស្រី **Kristina Kuhnel, Minister Counsellor** និងជានាយិកា អង្គការ SIDA
	២. សេចក្តីណែនាំអំពីមូលនិធិប្រែប្រួលអាកាសធាតុនៃសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា បទបង្ហាញនេះនឹងផ្តល់នូវការណែនាំឲ្យស្គាល់ អំពីមូលនិធិសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាដល់បេក្ខជន ដែលមានចំណាប់អារម្មណ៍។ វាគ្មិន៖ អ្នកស្រី Reiko Kurihara អ្នករដ្ឋបាលមូលនិធិ CCCA ក្រសួងបរិស្ថាន(២០នាទី)
	សំណួរ-ចម្លើយ (១៥ នាទី)
១៦.២០–១៦.៣០	ការសង្ខេប នៃសកម្មភាពថ្ងៃទី ២ និងការបិទកម្មវិធី

ថ្ងៃទី៣	ថ្ងៃពុធ ទី០៥ ខែតុលា ឆ្នាំ២០១១
០៧.៣០–០៨.៣០	ការចុះឈ្មោះ **<u>ទីកន្លែង</u> ៖** សណ្ឋាគារ អាំងទែកុងទីណង់តាល់
០៨.៣០–០៩.០០	ការចាប់ផ្តើមកម្មវិធី
	សុន្ទរកថាស្វាគមន៍លោក Rafael Dochao Moreno ភារៈធារីនៃប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា
	សុន្ទរកថាស្វាគមន៍ ឯកឧត្តម រស់ សីលវ៉ា អគ្គលេខាធិការរង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
០៩.០០–០៩.១០	ការសង្ខេបនៃសកម្មភាពថ្ងៃទី ២
០៩.១០–១០.០០	៥. វគ្គពេញអង្គ៖ ក្របខណ្ឌគោលនយោបាយប្រែប្រួលអាកាសធាតុ៖ ដំណើរឆ្ពោះទៅកាន់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា
	សហប្រធាន៖
	១. លោក Douglas Broderick តំណាង UN ប្រចាំនៅកម្ពុជា
	២. ឯកឧត្តម អ៊ូ ឱហាត រដ្ឋលេខាធិការ ក្រសួងផែនការ
	១. គោលនយោបាយ និងផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុ៖ បទពិសោធន៍

	អន្តរជាតិនិងបទពិសោធន៍ក្នុងតំបន់ បទបង្ហាញនេះ នឹងបង្ហាញនូវទិដ្ឋភាពទូទៅ នៃបទពិសោធន៍ថ្នាក់តំបន់និងអន្តរជាតិក្នុងការរៀបចំ និងអនុវត្តន៍ផែនការយុទ្ធសាស្ត្រ និងគោលនយោបាយ ប្រែប្រួលអាកាសធាតុ។ វាគ្មិន៖ លោក **Valdemar Holmgren** ប្រធានទីប្រឹក្សាបច្ចេកទេស សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុក្រសួងបរិស្ថាន(២០នាទី)
	សំណួរ - ចម្លើយ (២០នាទី)
១០.០០–១០.១៥	សម្រាកពិសារអាហារសម្រន់
១០.១៥–១១.០៥	***២. គោលនយោបាយតាមវិស័យ ដែលពាក់ព័ន្ធនឹងផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា៖ យុទ្ធសាស្ត្រវិស័យកសិកម្ម និងធនធានទឹកជលផល ថាមពល ព្រៃឈើ សុខភាព និងការគ្រប់គ្រងគ្រោះមហន្តរាយ*** បទបង្ហាញនេះនឹងធ្វើការវិភាគលើកម្មវិធី និងគោលនយោបាយតាមវិស័យ និងអន្តរវិស័យ ដែលមានស្រាប់ ពាក់ព័ន្ធនឹង ការប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា និងផ្តល់នូវបច្ចុប្បន្នភាពនៃការរៀបចំ CCCSP តាមវិស័យ។ វាគ្មិន៖ លោក ឡាយ ឃីម ជំនួយការនាយកា និងជាប្រធានក្រុមបរិស្ថាន និងថាមពល UNDP (២០ នាទី)
	សំណួរ - ចម្លើយ(៣០ នាទី)
១១.០៥-១១.៣៥	***៣. ដំណើរឆ្ពោះទៅកាន់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា (២០ នាទី)*** បទបង្ហាញនេះ នឹងផ្តល់នូវសារៈតា សនិទានភាព គោលបំណង និងមាតិកាព្រាងនៃ CCCSP និងផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្ត។ វាគ្មិន៖ លោក សុំ ធី ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជាអ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ សម្រាប់ការអភិវឌ្ឍន៍គោលនយោបាយប្រែប្រួលអាកាសធាតុ និងការគ្រងគ្រងចំណេះដឹងនៃកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ក្រសួងបរិស្ថាន (២០នាទី)
១១.៣៥–១១.៥៥	សំណួរ - ចម្លើយ(៣០ នាទី)
១១.៥៥–១៤.០០	អាហារថ្ងៃត្រង់ **<u>ទីកន្លែង ៖</u>** អ៊ិមភឺរៀល ១ (Imperial I) សណ្ឋាគារ អាំងទែកុងទីណង់តាល់
១៤.០០–១៥.២០	៥. វគ្គពេញអង្គ៖ ក្របខណ្ឌគោលនយោបាយប្រែប្រួលអាកាសធាតុ៖ ដំណើរឆ្ពោះទៅកាន់ការរៀបចំផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា
	សហប្រធាន៖
	១. លោក **Douglas Broderick** តំណាង UN ប្រចាំនៅកម្ពុជា
	២. ឯកឧត្តម នុត ច័ន្ទសុខា អនុរដ្ឋលេខាធិការ ក្រសួងផែនការ
	៤. ខ្លឹមសារសំខាន់ៗ ពាក់ព័ន្ធនឹងកិច្ចចរចាការប្រែប្រួលអាកាសធាតុនាពេលថ្មីៗនេះ បទបង្ហាញនេះ នឹងបង្ហាញជូននូវ ការវិវត្តចុងក្រោយនៃកិច្ចចរចាការប្រែប្រួលអាកាសធាតុ បញ្ហាចម្បងៗដែលត្រូវពិភាក្សា ក្នុងសន្និសីទនៃបណ្តាប្រទេសជាភាគីលើក

	ទី១៧ (CoP17) នៅទីក្រុងឌូបាន់ (Durban) និងលទ្ធផល ដែលអាចទទួលបានពី CoP១៧។ វាគ្មិន៖ លោក Mozaharul Alam អ្នកសម្របសម្រួលការប្រែប្រួលអាកាសធាតុ ប្រចាំតំបន់ UNEP (៣០នាទី)
	៥. ដំណើរឆ្ពោះទៅរក CoP១៧ នៅទីក្រុងឌូបាន់ ប្រទេសអាហ្វ្រិកខាងត្បូង៖ ជំហររបស់ប្រទេសកម្ពុជា បទបង្ហាញនេះ នឹងបង្ហាញជូន និងធ្វើការពិភាក្សាអំពីគោលជំហរកម្ពុជា ក្នុង CoP១៧។ វាគ្មិន៖ លោក សុំ ធី ប្រធាននាយកដ្ឋានប្រែប្រួលអាកាសធាតុ និងជាអ្នកសម្របសម្រួលគម្រោងថ្នាក់ជាតិ សម្រាប់ការអភិវឌ្ឍន៍គោលនយោបាយការប្រែប្រួលអាកាសធាតុនិងការគ្រងគ្រងចំណេះដឹង នៃកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ក្រសួងបរិស្ថាន (២០នាទី) សំណួរ - ចម្លើយ (២០នាទី)
15.20 – 15.35	ការសម្រាកពិសាអាហារសម្រន់
15.35 – 16.05	ការសង្ខេបនៃដំណើរការវេទិការយៈពេល ០២ ថ្ងៃ
16.05 – 16.20	ការបិទកម្មវិធី
	សុន្ទរកថាបិទអង្គវេទិការបស់ **ឯកឧត្តមបណ្ឌិត** ម៉ុក ម៉ាឌែត ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងបរិស្ថាន ប្រធានគណៈកម្មាធិការគ្រប់គ្រងការប្រែប្រួលអាកាសធាតុ។

ឧបសម្ព័ន្ធ ២ - សុន្ទរកថាបើក និងបិទ

សុន្ទរកថាបើក ថ្ងៃទី០១

របស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ***យឹម ឆៃលី***

តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ***ហ៊ុន សែន***

នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

- សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីសក្ការៈ
- ឯកឧត្តមលោកជំទាវ លោក លោកស្រី ភ្ញៀវជាតិនិងអន្តរជាតិ
- សមាជិកសមាជិកានៃអង្គវេទិកាទាំងមូល និងក្មួយៗសិស្សានុសិស្សនិស្សិតទាំងអស់ ជាទីមេត្រី

១. ថ្ងៃនេះខ្ញុំព្រះករុណា ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួមក្នុងពិធីបើកវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលជាព្រឹត្តិការណ៍ជាតិដ៏មានសារសំខាន់នៅក្នុងដំណើរការខិតខំប្រឹងប្រែងរបស់កម្ពុជា ដើម្បីឆ្លើយតបទៅនឹងបញ្ហាដ៏គម្រាមកំហែងនេះ។ ខ្ញុំព្រះករុណា ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ដល់ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ មកពីស្ថាប័ន ព្រឹទ្ធសភា រដ្ឋសភា បណ្តាក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ តំណាងអង្គទូតនៅព្រះរាជាណាចក្រកម្ពុជា អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន គ្រឹះស្ថានសិក្សា និងសមាជិកអង្គវេទិកាទាំងអស់ ដែលបានមកចូលរួមក្នុងវេទិកាជាតិនេះ សំដៅពិនិត្យវាយតម្លៃលើវឌ្ឍនភាព ដែលយើងសម្រេចបានចាប់ពីវេទិកាជាតិលើកទី១ មក និងពិភាក្សាកំណត់ទិសដៅអាទិភាពនាពេលអនាគត ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

២. យើងទាំងអស់គ្នាបានដឹងហើយថា ភស្តុតាងវិទ្យាសាស្ត្រ និងលទ្ធផលនៃការសិក្សាស្រាវជ្រាវថ្មីៗបានបង្ហាញថា ការប្រែប្រួលអាកាសធាតុកើតមានយ៉ាងពិតប្រាកដ ហើយអាចនាំឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរមកលើវិស័យ សេដ្ឋកិច្ច សង្គមកិច្ច និងបរិស្ថាន ដែលជាខឿនទ្រទ្រង់នូវអត្ថិភាព ការរីកចម្រើន និងនិរន្តរភាពនៃសង្គមជាតិ។ ការបន្តបញ្ចេញចោលយ៉ាងសន្ធឹកសន្ធាប់នូវឧស្ម័នផ្ទះកញ្ចក់នានា ជាពិសេសឧស្ម័នកាបូនិច ពីសកម្មភាពមនុស្ស នៅក្នុងវិស័យផលិតថាមពល ការដឹកជញ្ជូន កសិកម្ម ការកាប់ព្រៃឈើ ការចោលសំណល់ ។ល។ ជាពិសេសនៅបណ្តាប្រទេសឧស្សាហកម្មធំៗ បាននាំឲ្យមានការព្រួយបារម្ភបន្ថែមទៀត អំពីការប្រែប្រួលអាកាសធាតុ និងពីផលវិបាក ធ្ងន់ធ្ងរយៈពេលវែង សម្រាប់មនុស្សជាតិ។ ការឡើងកម្តៅភពផែនដី ការប្រែប្រួលរបបទឹក

ភ្លៀង ការឡើងកម្ពស់ទឹកសមុទ្រ ការកើតឡើងកាន់តែញឹកញាប់នូវព្រឹត្តិការណ៍អាកាសធាតុ មិនប្រក្រតី បានបង្កនូវការបាត់បង់ជីវិត ការខូចខាតផ្នែកសេដ្ឋកិច្ច និងបរិស្ថាន កាន់តែច្រើនឡើងដល់ប្រទេសនានានៅទូទាំងពិភពលោក។ នេះជាសក្តីភាពសបញ្ជាក់ថា បញ្ហាប្រែប្រួលអាកាសធាតុជាប់ពាក់ព័ន្ធ ដោយផ្ទាល់ និងដោយប្រយោល ជាមួយនឹងការអភិវឌ្ឍមនុស្ស ពោលគឺពុំមែនគ្រាន់តែជាបញ្ហាបរិស្ថានដាច់ដោយឡែកតែឯងនោះឡើយ។

៣. ប្រទេសក្រីក្រដែលមានការអភិវឌ្ឍតិចតួច ដូចជាប្រទេសកម្ពុជា គឺងាយរងគ្រោះបំផុតពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ ដោយសារតែបណ្តាប្រទេសទាំងនោះ មានសេដ្ឋកិច្ចពឹងផ្អែកខ្លាំងលើវិស័យកសិកម្ម ភាពក្រីក្ររបស់ប្រជាពលរដ្ឋ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តទន់ខ្សោយ ធនធានមនុស្ស និងហិរញ្ញវត្ថុមានកម្រិត និងកង្វះលទ្ធភាពទទួលបាននូវបច្ចេកវិទ្យាសមស្រប សម្រាប់ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ដោយឡែក រាជរដ្ឋាភិបាលកម្ពុជា បានទទួលស្គាល់យ៉ាងច្បាស់ពីបញ្ហាប្រែប្រួលអាកាសធាតុ នៅក្នុងដំណើរការស្តារ និងអភិវឌ្ឍប្រទេសជាតិ ក៏ដូចជាពីកាតព្វកិច្ចផ្នែកសីលធម៌របស់ខ្លួន ក្នុងនាមជាប្រទេសមួយ ដែលទទួលរងផលប៉ះពាល់ផងដែរពីការប្រែប្រួលអាកាសធាតុ ដោយយើងរួមចំណែកជាមួយសហគមន៍អន្តរជាតិ សំដៅដោះស្រាយបញ្ហាជាអាយុជីវិតរបស់មនុស្សជាតិក្នុងពិភពលោក។ ជាក់ស្តែង កម្ពុជាបានផ្តល់សច្ចាប័នដល់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ តាំងពីឆ្នាំ១៩៩៥ ហើយបានចូលជាសមាជិក ពិធីសារក្យូតូតាំងពីឆ្នាំ ២០០២។ យើងបានចាប់ផ្តើមបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ ទៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដោយផ្តោតជាពិសេសលើការជម្រុញការអនុវត្តបណ្តាគម្រោងបន្សាំនានានៅក្នុងកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាបរិស្ថានបានគ្របដណ្តប់សម្រាប់ការអនុវត្តយុទ្ធសាស្ត្រទាំងមូលនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ ដើម្បីកំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។ ជាងនេះទៅទៀត ការប្រែប្រួលអាកាសធាតុ បានក្លាយទៅជាអាទិភាពមួយ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ ដោយត្រូវបានដាក់បញ្ចូលយ៉ាងទូលំទូលាយទៅក្នុងវិស័យពាក់ព័ន្ធនានា។ ទាំងអស់នេះគឺជាសមិទ្ធផលដ៏ថ្លៃថ្លារបស់យើងទាំងអស់គ្នា ក្នុងកិច្ចខិតខំប្រឹងប្រែងដោះស្រាយបញ្ហាគម្រាមកំហែងនេះ។

៤. ឯកឧត្តមទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រី ក្រសួងបរិស្ថាន និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រង ការប្រែប្រួលអាកាសធាតុ បានរាយការណ៍លម្អិតអំពីលទ្ធផលការងារ ដែលកម្ពុជាសម្រេចបានក្នុងរយៈពេល២ ឆ្នាំកន្លងមកនេះនៅក្នុងកិច្ចខិតខំប្រឹងប្រែងអនុវត្តអនុសាសន៍នានា ដែលបានដាក់ចុះនៅក្នុងវេទិកាជាតិលើកទី ១ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី។ ពិនិត្យជារួម យើងសម្រេចបាននូវជោគជ័យគួរជាទីមោទនៈនៅក្នុងការកសាងសមត្ថភាពបច្ចេកទេស ការពង្រឹងស្ថាប័ន ការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការជាតិ និងតាមវិស័យពាក់ព័ន្ធ ការរួមវិភាគទានក្នុងកិច្ចចរចាអន្តរជាតិ ការកៀរគរធនធានសម្រាប់អនុវត្តវិធានការបន្សាំក៏ដូចជា វិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ល។ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរដោយស្មោះចំពោះ ឯកឧត្តមប្រធាន អនុប្រធានសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក្រសួងបរិស្ថាន ក៏ដូចជាបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់របស់រាជរដ្ឋាភិបាល ដែលបាន ខិតខំបំពេញការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងការសម្រេចបាននូវសមិទ្ធផលទាំងនេះ។ ជាមួយគ្នានេះដែរ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះដៃគូ

អភិវឌ្ឍន៍ ទាំងទ្វេភាគី និងពហុភាគី ព្រមទាំង អង្គការមិនមែនរដ្ឋាភិបាលនានា ដែលបានរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នា ដើម្បីអនុវត្តការងារប្រែប្រួលអាកាសធាតុយ៉ាងទូលំទូលាយ ចាប់តាំងពីថ្នាក់គោលនយោបាយ រហូតដល់ការអនុវត្តគម្រោងឆ្លើយតបថ្នាក់សហគមន៍ ដែលប្រការនេះសបញ្ជាក់ឲ្យឃើញនូវការទទួលស្គាល់ពីសារសំខាន់នៃកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុឲ្យមានប្រសិទ្ធភាព។

៥. ពិតមែនតែយើងបានសម្រេចជោគជ័យគួរជាទីមោទន:ក្តី តែយើងស្ថិតនៅលើកំណាត់ផ្លូវដ៏វែងឆ្ងាយមួយ ក្នុងការសម្រេចកសាងសង្គមមួយ ដែលបៃតងជាងមុន ធន់នឹងការប្រែប្រួលអាកាសធាតុ និងធានាបាននូវការអភិវឌ្ឍដោយសមធម៌និងចីរភាព ក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះ អនុញ្ញាតឲ្យខ្ញុំជូនជាអនុសាសន៍មួយចំនួន ដើម្បីជាមូលដ្ឋានក្នុងការពិចារណា ពិគ្រោះយោបល់ និងធ្វើសេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុទាំងនៅថ្នាក់ជាតិ ទាំងនៅកម្រិតអន្តរជាតិ។

ទី១ ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

កន្លងមក ការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា មានការពឹងផ្អែកលើការផ្គត់ផ្គង់ថវិកាពីប្រភពខាងក្រៅ ហើយអាទិភាពភាគច្រើនត្រូវបានកំណត់ដោយប្រភពម្ចាស់ជំនួយ គម្រោងទាំងនោះមានលក្ខណៈដោយឡែកៗពីគ្នា និងមិនស្ថិតនៅក្រោមយន្តការសម្របសម្រួលរួម ឬគោលនយោបាយជាតិ មួយឡើយ។ ប្រការនេះជាមូលហេតុធ្វើឲ្យមានភាពរាំរ៉ាយ ចំណាយមិនមានប្រសិទ្ធភាព ហើយមិនធានាបាននូវនិរន្តរភាព និងការពង្រឹងសមត្ថភាពស្ថាប័ន។ ការអនុម័ត និងដាក់ឲ្យអនុវត្តនូវកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងបន្ទាប់មកការផ្តល់អាទិភាពដល់ការងារប្រែប្រួលអាកាសធាតុ និងការបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុយ៉ាងទូលំទូលាយទៅក្នុងវិស័យពាក់ព័ន្ធនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម គឺជាជំហានវិជ្ជមានដ៏សំខាន់មួយនៅក្នុងដំណើរការរៀបចំផែនការរបស់កម្ពុជា។ ទន្ទឹមនេះ កម្ពុជាក៏ត្រូវខិតខំបន្ថែមទៀតដើម្បីរៀបចំឲ្យមានគោលនយោបាយឯកភាពមួយនៅថ្នាក់ជាតិ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ធ្វើជាគ្រឹះវិស័យ សម្រាប់ដឹកនាំសម្របសម្រួលការងារប្រែប្រួលអាកាសធាតុសំដៅឆ្លើយតបនឹងបញ្ហាដ៏ប្រឈមនេះនាពេលអនាគតឲ្យកាន់តែទូលំទូលាយ ស៊ីជម្រៅ និងចំទិសដៅ ។ គោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ត្រូវតែគាំទ្រដល់សរសេរសួស្តីទាំង៤ ជុំវិញអភិបាលកិច្ចល្អនៃយុទ្ធសាស្ត្រចតុកោណពោលគឺ៖ ការលើកស្ទួយវិស័យកសិកម្ម ការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការកសាងសមត្ថភាពនិងការអភិវឌ្ឍធនធានមនុស្ស និងការអភិវឌ្ឍផ្នែកឯកជននិងការងារ។

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ត្រូវទទួលខុសត្រូវក្នុងការសម្របសម្រួលដំណើរការរៀបចំឯកសារនេះ ដោយបង្កឱកាសឲ្យមានការចូលរួមយ៉ាងទូលំទូលាយពីបណ្តាក្រសួងស្ថាប័នពាក់ព័ន្ធ និងការពិគ្រោះយោបល់ជាមួយដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធនានា។ ផែនការនេះត្រូវផ្តល់អាទិភាពដល់វិស័យ ដែលជាឆ្អឹងខ្នងនៃការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដូចជា វិស័យកសិកម្ម ធនធានទឹក ជលផល ព្រៃឈើ តំបន់ការពារធម្មជាតិ ថាមពល ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ក៏ដូចជាបញ្ហាអន្តរវិស័យនានា រួមមានការពង្រឹងស្ថាប័នការកសាងធនធានមនុស្ស ការសិក្សាស្រាវជ្រាវ ការកៀរគរធនធានហិរញ្ញវត្ថុ ការអនុវត្តបច្ចេកវិទ្យាសមស្រប ការអប់រំ

និងលើកកម្ពស់ការយល់ដឹងពីបញ្ហាយេនឌ័រតាំងពីថ្នាក់ជាតិរហូតដល់ថ្នាក់ក្រោមជាតិ។ បណ្តាវិធានការអាទិភាពនានាត្រូវតែជា "ជម្រើសដ៏ល្អិតល្អន់ម៉ត់ចត់" ដែលគាំទ្រទាំងស្រុងដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្រ ហើយក៏ត្រូវកំណត់ជាអាទិភាពឡើង ដោយផ្អែកលើការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ ដែលមានគុណភាពខ្ពស់គួរឲ្យទុកចិត្តបាន និងមានការពិនិត្យផ្ទៀងផ្ទាត់ច្បាស់លាស់។ ឈរលើស្មារតីនេះ វាជាប្រការចាំបាច់ដែលក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់យកផែនការយុទ្ធសាស្ត្រនេះទៅប្រើប្រាស់ ដើម្បីជាមូលដ្ឋានក្នុងការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងផែនការតាមវិស័យ ដោយត្រូវបន្សុំគ្នាឲ្យសមស្របរវាងយុទ្ធសាស្ត្រ ដែលបានដាក់ចេញ និងសកម្មភាពដែលត្រូវអនុវត្ត។

ទី២ ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេស និងការសម្របសម្រួល

ដោយសារបញ្ហាប្រែប្រួលអាកាសធាតុមានចរិតពហុជំនាញ និងអន្តរវិស័យ ហើយមានការពាក់ព័ន្ធជាមួយនឹងតួនាទីភារកិច្ចរបស់ក្រសួង-ស្ថាប័នជាច្រើន ដូច្នេះចាំបាច់ត្រូវមានយន្តការសម្របសម្រួលថ្នាក់ជាតិ ដើម្បីដឹកនាំសម្របសម្រួលការរៀបចំគោលនយោបាយ បទប្បញ្ញត្តិផែនការ ការអនុវត្តការងារសិក្សាស្រាវជ្រាវ ការកៀរគរធនធាន កិច្ចសហប្រតិបត្តិការអន្តរក្រសួង និងអន្តរជាតិ។ ក្នុងន័យនេះ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុរួចហើយដោយផ្តល់ភារកិច្ចឲ្យក្រសួងបរិស្ថានទទួលបន្ទុកជាប្រធាន ហើយមានក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុអន្តរក្រសួងមួយជាសេនាធិការ។ គណៈកម្មាធិការនេះត្រូវបន្តពង្រឹងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ជាពិសេសការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ដែលជាការងារអាទិភាពបន្ទាន់ចំពោះមុខ។ ក្នុងន័យនេះ ខ្ញុំសូមអំពាវនាវឲ្យដៃគូអភិវឌ្ឍទាំងអស់ផ្តល់ការគាំទ្រ និងសម្របសម្រួលសហការឲ្យកាន់តែខ្លាំងក្លាថែមទៀត ជាមួយគណៈកម្មាធិការជាតិនេះ ដែលជាស្ថាប័នផ្លូវការថ្នាក់គោលនយោបាយរបស់រាជរដ្ឋាភិបាល ធ្វើយ៉ាងណាធានាឲ្យបាននូវភាពជាម្ចាស់ និងការឆ្លើយតបទៅនឹងតម្រូវការរបស់កម្ពុជាផ្ទាល់។ ជាមួយគ្នានេះដែរក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវរៀបចំជាអង្គភាពទទួលខុសត្រូវការងារប្រែប្រួលអាកាសធាតុទៅតាមអាណត្តិរបស់ខ្លួន និងពង្រឹងសមត្ថភាពបច្ចេកទេសរបស់មន្ត្រីរាជការទទួលបន្ទុកដោយធានាបាននូវការសម្របសម្រួលយ៉ាងជិតស្និទ្ធជាមួយយន្តការសម្របសម្រួលនៅថ្នាក់ជាតិ ទាំងផ្នែកគោលនយោបាយ និងផ្នែកបច្ចេកទេស ។ ម៉្យាងវិញទៀត យើងត្រូវចាប់ផ្តើមកសាងសមត្ថភាពស្ថាប័នថ្នាក់ក្រោមជាតិ ទាំងផ្នែកពង្រឹងស្ថាប័ន ទាំងផ្នែកបច្ចេកទេស ចាប់តាំងពីថ្នាក់រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌរហូតដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីឲ្យពួកគេអាចបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងដំណើរការធ្វើផែនការ និងអនុវត្តគម្រោងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ នៅថ្នាក់មូលដ្ឋាន។

កិច្ចការសំខាន់មួយទៀត ដែលត្រូវយកចិត្តទុកដាក់អនុវត្តគឺ ការពង្រឹងសមត្ថភាព និងការអនុវត្តសកម្មភាពស្រាវជ្រាវវិទ្យាសាស្ត្ររបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ វិទ្យាស្ថានស្រាវជ្រាវ និងគ្រឹះស្ថានសិក្សាអំពីការប្រែប្រួលអាកាសធាតុនៅកម្ពុជានាពេលអនាគត និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើវិស័យសំខាន់ៗ។

ទី៣ ការអនុវត្តគម្រោងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ

ការចរចាដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ក្នុងរយៈពេលប្រមាណជិតម្ភៃឆ្នាំចុងក្រោយនេះ ពោលគឺចាប់តាំងពីពេលដែលពិភពលោកបានអនុម័ត អនុសញ្ញាក្របខណ្ឌសហប្រជា

ជាតិស្តីពីការប្រែប្រួលអាកាសធាតុនៅឆ្នាំ១៩៩២ មកពុំបានផ្តល់នូវលទ្ធផលជាដុំកំភួន ដូចអ្វីដែលយើងបានរំពឹងទុកនោះទេ។ ពិតមែនតែមានការប្តេជ្ញាចិត្តម្តងហើយម្តងទៀត ក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ក្តី ក៏ការបញ្ចេញឧស្ម័នទាំងនេះចូលទៅក្នុងបរិយាកាសនៅតែបន្តកើនឡើងជាលំដាប់។ បណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធត្រូវប្រើផែនការយុទ្ធសាស្ត្រនេះ ដើម្បីបញ្ចូលការងារប្រែប្រួលអាកាសធាតុទៅក្នុងផែនការសកម្មភាពតាមវិស័យ ដែលខ្លួនទទួលខុសត្រូវ។ ជាការពិតនៅក្រោមសេណារីយ៉ូការប្រែប្រួលអាកាសធាតុនេះគឺ ការឆ្លើយតបចំពោះមុខរបស់យើង ដោយអនុវត្តបណ្តាវិធានការបន្ទាំដែលចាំបាច់ និងបន្ទាន់បំផុតនៅក្នុងវិស័យ ដែលជាអាទិភាពអភិវឌ្ឍន៍របស់ជាតិ មានជាអាទិ៍ វិស័យកសិកម្ម ធនធានទឹក ជលផល និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ក្នុងនេះ ខ្ញុំសូមគូសបញ្ជាក់លំអិតបន្តិចពីវិស័យកសិកម្ម ដោយសារតែយើងមានប្រជាជនជាង ៨០% រស់នៅតំបន់ជនបទ ហើយពឹងអាស្រ័យលើវិស័យកសិកម្មដើម្បីចិញ្ចឹមជីវិត។ ឆ្លងកាត់តាមបទពិសោធន៍នៃវិបត្តិសេដ្ឋកិច្ចពិភពលោកនាឆ្នាំ២០០៨ កម្ពុជាបានផ្តោតកាន់តែខ្លាំងថែមទៀតលើការអភិវឌ្ឍវិស័យកសិកម្ម ដែលជាវិស័យគន្លឹះមួយក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាជន និងការពង្រឹងសេដ្ឋកិច្ចជាតិ តាមរយៈការពង្រីកការនាំចេញ និងឧស្សាហកម្មកែច្នៃផលិតផលកសិកម្ម។ ប៉ុន្តែ វិស័យនេះងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដោយសារតែកសិកម្មរបស់យើងនៅពឹងផ្អែកលើទឹកភ្លៀងជាចម្បង។ ក្នុងន័យនេះ ត្រូវជម្រុញការអនុវត្តបណ្តាវិធានការបន្ទាំទាំងឡាយណាដែលគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណ ក៏ដូចជា កម្មវិធីសកម្មភាពជាតិបន្ទាំនឹងការប្រែប្រួលអាកាសធាតុ ដូចជាការលើកស្ទួយផលិតភាព ការបង្កើនផ្ទៃដីដាំដុះ ការបង្កើនរដូវដាំដុះ ពិពិធភាវូបនីយកម្ម។ល។ កម្ពុជាត្រូវផ្តល់អាទិភាពលើបណ្តាវិធានការបន្ទាំនានា ថ្នាក់សហគមន៍ ដែលប្រើប្រាស់បច្ចេកវិទ្យាសមស្រប ងាយអនុវត្ត ចំណាយតិចតែផ្តល់ប្រសិទ្ធភាពខ្ពស់ សម្រាប់សហគមន៍ និងតំបន់ភូមិសាស្ត្រ ដែលងាយរងគ្រោះបំផុត។

នៅក្នុងផ្នែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ត្រូវបន្តអនុវត្តនូវវិធានការឈ្នះ-ឈ្នះ ដែលគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព។ ដូចជា យុទ្ធនាការសន្សំសំចៃអគ្គិសនី និងប្រេងឥន្ធនៈ សកម្មភាពការពារ និងអភិរក្សព្រៃឈើនៅក្នុងតំបន់ការពារធម្មជាតិព្រៃបំរុង និងព្រៃការពារ ។ នៅក្នុងវិស័យព្រៃឈើត្រូវបន្តជម្រុញការអនុវត្តគម្រោងឥណទានកាបូន ដែលផ្តល់ប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ និងផលប្រយោជន៍ច្រើនយ៉ាងផ្នែកសង្គម និងបរិស្ថាន ជាពិសេស គម្រោងដែលជួយលើកកម្ពស់ជីវភាពសហគមន៍មូលដ្ឋាន។

ការអនុវត្តគម្រោងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ពិតជាមិនអាចទទួលបានជោគជ័យទេ ប្រសិនបើគ្មានការចូលរួមពីបណ្តាភាគីពាក់ព័ន្ធទាំងអស់។ យើងចាំបាច់ត្រូវពង្រឹងភាពជាដៃគូរវាងវិស័យសាធារណៈ និងឯកជន និងដៃគូអភិវឌ្ឍទាំងអស់ ដោយបង្កនូវបរិស្ថានប្រកបដោយសាមគ្គីភាពសម្រាប់ទាក់ទាញការវិនិយោគកាន់តែសកម្ម នៅលើគម្រោងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ទាំងគម្រោងបន្ទាំនឹងការប្រែប្រួលអាកាសធាតុ ទាំងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

ទី៤ ការកៀរគរធនធាន

ការឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ពុំអាចប្រព្រឹត្តិទៅបានប្រកបដោយប្រសិទ្ធភាពនោះទេ ប្រសិនបើគ្មានការគាំទ្រផ្នែកហិរញ្ញវត្ថុ។ ដោយអនុលោមតាមគោលការណ៍សំខាន់ៗនៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ កម្ពុជាបានខិតខំព្យាយាមជម្រុញ

ឲ្យបណ្តាប្រទេសអភិវឌ្ឍន៍ផ្តល់ថវិកាជូនប្រទេសកំពុងអភិវឌ្ឍន៍ ដូចអ្វីដែលគេបានសន្យា សម្រាប់ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ។ នៅក្នុងសេណារីយ៉ូសុទ្ធិនិយមមួយ ដែលបណ្តាប្រទេសឧស្សាហកម្មអនុវត្តតាមកិច្ចសន្យារបស់ខ្លួនក្នុងការផ្តល់ហិរញ្ញប្បទាន សម្រាប់ការឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុលើទឹកប្រាក់ ៣០ពាន់លានដុល្លា សម្រាប់ឆ្នាំ២០០៩-២០១៣ និង១០០ពាន់លានដុល្លាក្នុងមួយឆ្នាំ រហូតដល់ឆ្នាំ២០២០ យើងរំពឹងថា នឹងមានកំណើនន្យូវលំហូរហិរញ្ញវត្ថុសម្រាប់គាំទ្រការប្រែប្រួលអាកាសធាតុយ៉ាងគំហុកចូលទៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍ។ ដើម្បីឲ្យកម្ពុជាអាចចាប់យកឱកាសពេញលេញក្នុងការទទួលបាននូវការគាំទ្រហិរញ្ញវត្ថុនេះ ទាមទារឲ្យមាននូវការយល់ដឹងយ៉ាងច្បាស់អំពីយន្តការហិរញ្ញប្បទាននានា ក្រោមក្របខណ្ឌនៃអនុសញ្ញាប្រែប្រួលអាកាសធាតុ ហើយចាំបាច់ត្រូវកសាងសមត្ថភាពជាតិសមស្រប ទាំងផ្នែកស្ថាប័ន ទាំងផ្នែកបច្ចេកទេស ដើម្បីស្រូបយកជំនួយឲ្យបានជាអតិបរមា និងប្រើប្រាស់ឲ្យចំគោលដៅប្រកបដោយប្រសិទ្ធភាពខ្ពស់ ដោយធានាបាននូវប្រសិទ្ធភាព គណនេយ្យភាព តម្លាភាព ការគ្រប់គ្រងហានិភ័យបានល្អ និងការពិនិត្យតាមដានឲ្យបានគ្រប់គ្រាន់និងជិតដល់។ ក្នុងន័យនេះ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ត្រូវសហការជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងដៃគូអភិវឌ្ឍន៍សំខាន់ៗក្នុងការសិក្សា និងផ្តល់អនុសាសន៍ ដើម្បីរៀបចំនូវក្របខណ្ឌហិរញ្ញវត្ថុប្រែប្រួលអាកាសធាតុជាតិ ដែលអាចឆ្លើយតបទៅនឹងលក្ខខណ្ឌ ដែលបានរៀបរាប់ខាងលើ។ ជាអាទិភាពចំពោះមុខ ត្រូវពិចារណាលើការបង្កើតមូលនិធិប្រែប្រួលអាកាសធាតុជាតិមួយដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់របស់ជាតិ ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ហើយអាចបំពេញនាទីជាចំណុចចាប់ផ្តើមឯកភាពមួយ សម្រាប់ការចូលរួមរបស់ដៃគូអភិវឌ្ឍន៍នានាទាំងទ្វេភាគី និងពហុភាគី ក្នុងការផ្តល់ជំនួយមិនភ្ជាប់លក្ខខណ្ឌបំរើឲ្យការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា។ ខ្ញុំសូមឆ្លៀតឱកាសនេះ ថ្លែងអំណរគុណចំពោះដៃគូអភិវឌ្ឍន៍មួយចំនួន ដូចជាសហភាពអឺរ៉ុប ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ (Sida) ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក់ (Danida) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP) ដែលបានគាំទ្រការផ្តួចផ្តើមគំនិតរៀបចំនូវមូលនិធិប្រែប្រួលអាកាសធាតុ ដំណាក់កាលសាកល្បងមួយ សម្រាប់ផ្តល់ឱកាសឲ្យក្រសួង-ស្ថាប័ននានារបស់រាជរដ្ឋាភិបាលក្នុងភាពជាដៃគូជាមួយអង្គការសង្គមស៊ីវិល និងអង្គការអន្តរជាតិទទួលជំនួយឥតសំណង សម្រាប់ពង្រឹងការងារប្រែប្រួលអាកាសធាតុនៅក្នុងវិស័យពាក់ព័ន្ធជាអាទិភាពនានា។ ខ្ញុំក៏សូមអរគុណផងដែរ ចំពោះដៃគូអភិវឌ្ឍន៍ផ្សេងទៀត និងអង្គការសង្គមស៊ីវិលមួយចំនួន ដែលបាននិងកំពុងរួមចំណែកជាមួយរាជរដ្ឋាភិបាលកម្ពុជា ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។ ជាពិសេស សូមថ្លែងអំណរគុណដល់ រដ្ឋាភិបាលជប៉ុន តាមរយៈ JICA ដែលបានគាំទ្រជាក់ស្តែងដល់ក្រសួងធនធានទឹកនិងឧតុនិយម និងរដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការពង្រឹងសមត្ថភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យអាទិភាពទាំងពីរនេះ។

ទី៥ ការអប់រំ និងការលើកកម្ពស់ការយល់ដឹង

ការងារអប់រំ និងការលើកកម្ពស់ការយល់ដឹងស្តីពីការប្រែប្រួលអាកាសធាតុ គឺជាការវិនិយោគរយៈពេលវែងដ៏មានប្រសិទ្ធភាព ដើម្បីឲ្យសាធារណជន ជាពិសេស កូនចៅជំនាន់ក្រោយអាចត្រៀមខ្លួនបានសមស្របក្នុងការរស់នៅ បន្តការអភិវឌ្ឍខ្លួនគេផ្ទាល់ និងរួមចំណែកកសាងប្រទេសជាតិដោយចីរភាពនៅក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។ ខ្ញុំយល់ថា ក្រសួងអប់រំយុវជន និង

កីឡា ត្រូវសហការជាមួយក្រសួងបរិស្ថាន និងក្រសួង-ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ដើម្បីពិចារណាលើលទ្ធភាពនៃការបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីអប់រំ ទាំងក្នុងប្រព័ន្ធ ទាំងក្រៅប្រព័ន្ធ។ ជាមួយគ្នានេះ ត្រូវលើកកម្ពស់ការងារផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយព័ត៌មានចម្រុះបែប ដើម្បីឲ្យព័ត៌មានស្តីពីការប្រែប្រួលអាកាសធាតុ ជ្រួតជ្រាបដល់គ្រប់ស្រទាប់នៃមហាជន។ គួររៀបចំកម្មវិធីប្រឡងប្រណាំងជាប្រចាំ ដើម្បីជ្រើសរើស សម្រិតសម្រាំងរកបុគ្គល ឬស្ថាប័នឆ្នើម ក្នុងចំណោមមន្ត្រីរាជការ សិស្ស-និស្សិត សិល្បៈករ ក្រុមហ៊ុនឯកជន ឬសាធារណៈជនទូទៅ ដែលលេចធ្លោ អាចដើរតួជាគំរូឈានមុខក្នុងការងារប្រែប្រួលអាកាសធាតុ។

ទី៦ ការចរចាអន្តរជាតិដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ

ក្នុងនាមជា ភាគីនៃអនុសញ្ញាក្របខណ្ឌសហប្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ កម្ពុជាសូមគាំទ្រទាំងស្រុងនូវ ការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយផ្អែកលើគោលការណ៍សំខាន់ៗជាមូលដ្ឋាននៃអនុសញ្ញានេះ ជាអាទិ៍៖ គោលការណ៍ "ទទួលខុសត្រូវរួមគ្នា" តែក្នុងកម្រិតផ្សេងគ្នា តាមសមត្ថភាពរៀងៗខ្លួន តម្រូវការដោយឡែក និងស្ថានភាពពិសេសនៃបណ្តាភាគីប្រទេសកំពុងអភិវឌ្ឍន៍ ពិសេសបណ្តាប្រទេសដែលងាយរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ ព្រមទាំងសិទ្ធិរបស់ពួកគេក្នុងការជម្រុញការអភិវឌ្ឍដោយចីរភាព និងគោលការណ៍ "**ត្រៀមបង្ការជាមុន**"។ លើសពីនេះ ជំហរចរចាររបស់កម្ពុជា ត្រូវបានរៀបចំឡើង ដោយផ្សារភ្ជាប់ជាមួយជំហរនៃក្រុមប្រទេស G77 + ចិន និងក្រុមប្រទេសដែលមានការអភិវឌ្ឍតិចតួច។ គោលការណ៍ទាំងនេះ គឺជាមូលដ្ឋានគ្រឹះយ៉ាងសំខាន់ ដែលរាជរដ្ឋាភិបាលកម្ពុជា ប្រើប្រាស់ក្នុងការកំណត់ជំហររបស់ជាតិនៅក្នុងដំណើរការចរចាអន្តរជាតិ ដើម្បីដោះស្រាយបញ្ហាពិភពលោកដ៏ប្រឈមនេះ។

<u>ក. បន្សាំនឹងការប្រែប្រួលអាកាសធាតុ</u>

ការប្រែប្រួលអាកាសធាតុ បានដាក់បន្ទុកបន្ថែមទៀតមកលើបណ្តាប្រទេសក្រីក្រ ដោយសារតែបណ្តាប្រទេសទាំងនោះមានធនធានស្តួចស្តើងបំផុត សម្រាប់ឆ្លើយតបទៅនឹងបញ្ហា ដែលពួកគេពុំមែនជាអ្នកបង្កើតនេះ។ ហេតុនេះ ជំនួយសម្រាប់អនុវត្តវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុនៅបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច មិនត្រូវភ្ជាប់ជាមួយលក្ខខណ្ឌអ្វីទាំងអស់ ដោយអាស្រ័យលើតម្រូវការជាក់ស្តែងរបស់ប្រទេសទាំងនោះ ហើយមិនត្រូវនាំឲ្យប្រទេសទាំងនោះជាប់បំណុលកាន់តែច្រើនឡើយ។ កម្ពុជាសូមអះអាងឡើងវិញថា ការអនុវត្តកម្មវិធីសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ នៅតែជាការប្រឈមពិតប្រាកដមួយ នៅក្នុងបរិបទនេះ កម្ពុជាអំពាវនាវដល់ភាគីជាប្រទេសជឿនលឿនឲ្យផ្តល់វិភាគទានរបស់ខ្លួន សម្រាប់មូលនិធិប្រែប្រួលអាកាសធាតុបៃតង ដូចអ្វីដែលខ្លួនបានសន្យានៅទីក្រុងកូប៉េនហាក និងទីក្រុងកាន់គុន។

<u>ខ. ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់</u>

ប្រទេសទាំងអស់ ត្រូវតែចូលរួមនៅក្នុងការកាត់បន្ថយនូវការបញ្ចេញឧស្ម័នលើពិភពលោកឲ្យបានយ៉ាងហោចណាស់ ៨៥% ធៀបនឹងកម្រិតនៃការបញ្ចេញនៅឆ្នាំ១៩៩០ រហូតដល់ឆ្នាំ២០៥០ ដោយផ្អែកលើគោលគារណ៍ "**ទទួលខុសត្រូវរួមគ្នា តែក្នុងកម្រិតផ្សេងគ្នា**" និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងប្រវត្តិសាស្ត្រកន្លងមក។ បណ្តាប្រទេសជឿនលឿនគួរផ្តល់នូវធនធានហិរញ្ញវត្ថុ និងបច្ចេកវិទ្យាចាំបាច់ សម្រាប់ឲ្យបណ្តាប្រទេសកំពុងអភិវឌ្ឍ ចូលរួមក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ពាក់ព័ន្ធនឹងអនាគតនៃកិច្ចព្រមព្រៀងក្រោយពិធីសារក្យូតូ កម្ពុជាសូមគាំទ្រយ៉ាង

ពេញទំហឹងដល់បណ្តាសកម្មភាពកាត់បន្ថយបញ្ចេញឧស្ម័នផ្ទះកញ្ចក់ពីវិស័យព្រៃឈើ ដោយជម្រុញឲ្យមានការលើកទឹកចិត្តសមស្របប្រកបដោយយុត្តិធម៌ ការប្រកួតប្រជែង និងការពារផលប្រយោជន៍សហគមន៍មូលដ្ឋាន។ ជាមួយគ្នានោះ ការកែលម្អព្រៃឈើ ជាអាងស្រូបកាបូន មិនត្រូវធ្វើឲ្យប៉ះពាល់ដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ឡើយ។

<u>គ. ការផ្ទេរបច្ចេកវិទ្យា</u>

ទាំងវិធានការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ទាំងវិធានការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ពិតជាពុំអាចអនុវត្តបានជោគជ័យទេ ប្រសិនបើគ្មានការផ្ទេរបច្ចេកវិទ្យាទំនើប ទៅឲ្យប្រទេសកំពុងអភិវឌ្ឍ ជាពិសេសប្រទេសដែលមានការអភិវឌ្ឍតិចតួច ហើយដែលប្រការនេះមានចែងយ៉ាងច្បាស់នៅក្នុងមាត្រាទី៤ នៃអនុសញ្ញាប្រែប្រួលអាកាសធាតុ។ ប្រការនេះគឺជាដំណោះស្រាយឈ្នះ-ឈ្នះ សម្រាប់អាកាសធាតុពិភពលោក ពីព្រោះប្រទេសកំពុងអភិវឌ្ឍអាចចៀសវាងបាននូវវិធីអភិវឌ្ឍន៍សេដ្ឋកិច្ចតាមបែបប្រពៃណី តាមរយៈការបង្កើនប្រសិទ្ធភាពថាមពល កាត់បន្ថយការបំពុលបរិស្ថាន និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ហើយជាមួយគ្នានោះទ្រទ្រង់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមដោយចីរភាព។ ក្នុងន័យនេះ កម្ពុជាគាំទ្រដល់ការជម្រុញ និងលើកកម្ពស់កិច្ចសហប្រតិបត្តិការ នៅថ្នាក់ជាតិ និងអន្តរជាតិ លើការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា ដែលសមស្របមិនបំផ្លាញបរិស្ថានទៅឲ្យភាគីជាប្រទេសកំពុងអភិវឌ្ឍ ដើម្បីគាំទ្រដល់សកម្មភាពបន្សាំ និងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ការបំពេញបន្ថែមលើភាពខ្វះខាត ចាំបាច់ត្រូវចាត់វិធានការត្រួតពិនិត្យបន្ថែមទៀតសំដៅធានាថា បច្ចេកវិទ្យាដែលគ្មានគ្រោះថ្នាក់ដល់អាកាសធាតុ អាចផ្ទេរទៅឲ្យប្រទេសកំពុងអភិវឌ្ឍបាន។ ម៉្យាងវិញទៀត បណ្តាប្រទេសមានការអភិវឌ្ឍតិចតួច ក្រខ្សត់ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុ និងងាយទទួលរងគ្រោះ ដោយសារការប្រែប្រួលអាកាសធាតុ។ ហេតុនេះ ការផ្ទេរបច្ចេកវិទ្យាទៅឲ្យបណ្តាប្រទេសទាំងនេះ ត្រូវតែមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយយ៉ាងហោចណាស់ត្រូវរួមបញ្ចូលនូវ៖ គ្រឿងឧបករណ៍ បរិក្ខារ ជំនាញព័ត៌មានពាក់ព័ន្ធ ការកសាងសមត្ថភាព និងធនធានហិរញ្ញវត្ថុ។

<u>ឃ. ហិរញ្ញប្បទាន</u>

កម្ពុជា សូមអំពាវនាវឲ្យមានការសម្រេចទទួលបាននូវកិច្ចព្រមព្រៀងដោយយុត្តិធម៌មហិច្ឆិតា និងជាប់ជាកាតព្វកិច្ចផ្លូវច្បាប់ នៅក្នុងដំណើរការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយក្នុងនោះភាគីជាប្រទេសជឿនលឿនគួរផ្តល់នូវទឹកប្រាក់យ៉ាងហោចណាស់ចំនួន១,៥% នៃផលទុនជាតិសរុប (GDP) របស់ខ្លួនចេញពីប្រភពសាធារណៈជាចម្បង ដែលជាមូលនិធិថ្មីបន្ថែមលើការសន្យាក្រោមជំនួយអភិវឌ្ឍន៍ផ្លូវការ និងដែលអាចប៉ាន់ប្រមាណជាមុន ក្នុងនោះ៧0% ត្រូវតែលៃទុកសម្រាប់សកម្មភាពបន្សាំក្នុងបណ្តាប្រទេស ដែលមានការអភិវឌ្ឍតិចតួច សម្រាប់កម្មវិធីបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកសាងសមត្ថភាព និងការជម្រុញឲ្យផ្ទេរបច្ចេកវិទ្យា ដោយពុំមានភ្ជាប់នូវលក្ខខណ្ឌបដិភាគហិរញ្ញវត្ថុឡើយ។

ឯកឧត្តមលោកជំទាវ លោក លោកស្រីជាធិបតី!

សេដ្ឋវិទូនានាបានបញ្ជាក់នៅក្នុងរបាយការណ៍ "សេដ្ឋកិច្ចនៃការប្រែប្រួលអាកាសធាតុ" ថាការប្រែប្រួលអាកាសធាតុ គឺជាលទ្ធផលនៃបរាជ័យទីផ្សារដ៏ធំមួយនៃសម័យបច្ចុប្បន្ននេះ។ ការដកហូតធនធានធម្មជាតិ ផលិតកម្ម ការប្រើប្រាស់ ការបញ្ចេញចោល ទៅក្នុងបរិស្ថានធម្មជាតិវិញ រួមផ្សំជាមួយនឹងអវត្តមាននៃយន្តការ ដែលអាចឲ្យគេដាក់បញ្ចូលការខូចខាតបរិស្ថានទៅក្នុងថ្លៃដើមនៃ

ទំនិញ និងការរីកសាយយ៉ាងលឿននូវរបៀបធម៌ប្រើប្រាស់និយម នៅទូទាំងពិភពលោក ជាកម្លាំងចលករជម្រុញឲ្យមានការដកហូតធនធានធម្មជាតិ ជាពិសេសឥន្ធនៈហ្វូស៊ីល និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទៅក្នុងបរិយាកាសនៅក្នុងកម្រិតមួយ ដែលមិនធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រមនុស្សជាតិ។ បញ្ហាប្រឈមជាអាយុជីវិតនេះ គឺជាវិញ្ញាសាប្រវត្តិសាស្ត្រ សម្រាប់មនុស្សជាតិធ្វើការបញ្ជាក់ពីសមត្ថភាពរបស់ខ្លួនក្នុងការដោះស្រាយ ដើម្បីភាពរស់រានមានជីវិត និងការបន្តអារ្យធម៌របស់ខ្លួន។ បុគ្គលម្នាក់ៗ ស្ថាប័ននីមួយៗ ប្រទេសនីមួយៗ មានតួនាទីរៀងៗខ្លួន ក្នុងការដោះស្រាយបញ្ហានេះ អាស្រ័យទៅតាមការយល់ដឹង លទ្ធភាព សមត្ថភាព តួនាទី-ភារកិច្ច និងចំណែករបស់ខ្លួនក្នុងការបង្កឲ្យមានបញ្ហានេះ។ សម្រាប់កម្ពុជា យើងមានអាទិភាពចំពោះមុខជាច្រើន៖ ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ការងារបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងផែនការតាមវិស័យពាក់ព័ន្ធ ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាពបច្ចេកទេស ការរៀបចំមូលនិធិប្រែប្រួលអាកាសធាតុ ការកៀរគរធនធានសម្រាប់អនុវត្តគម្រោងបន្ទាំ និងគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ កិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលការងារការអប់រំ និងលើកកម្ពស់ការយល់ដឹង ការងារសិក្សាស្រាវជ្រាវ ការពង្រឹងតួនាទីផ្នែកឯកជន ការត្រៀមចូលរួមចរចាថ្នាក់អន្តរជាតិ។ល។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** មានការប្តេជ្ញាចិត្ត និងឆន្ទៈនយោបាយខ្ពស់ ក្នុងការខិតខំប្រឹងប្រែងរួមគ្នាជាមួយភាគីពាក់ព័ន្ធនៅគ្រប់លំដាប់ថ្នាក់ ចាប់ពីអង្គការជាតិ-អន្តរជាតិ រហូតដល់អង្គការមហាជននៅមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុ ដែលអាចធ្វើឲ្យអន្តរាយដល់វឌ្ឍនភាពឆ្ពោះទៅរកការសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ជាតិ។ ផលវិបាកនៃការមិនអើពើធ្វើសកម្មភាពនៅក្នុងកាលទេសៈដ៏ចាំបាច់នេះ មានទំហំធំធេងណាស់ ដែលតម្រូវឲ្យយើងត្រូវតែចាត់វិធានការចាប់ពីពេលឥឡូវនេះទៅដើម្បីធានានូវអនាគតមួយ ដែលមានភាពធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុនេះ។ នៅលើឆាកអន្តរជាតិ កម្ពុជាប្តេជ្ញាត្រៀមខ្លួនរួមចំណែកនៅក្នុងកិច្ចខិតខំប្រឹងប្រែងជាសកល ក្នុងការទទួលខុសត្រូវចំពោះជោគវាសនានៃមនុស្សជាតិ ដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយឈរលើស្មារតីនៃគោលការណ៍ចម្បងៗ របស់អនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ។ យើងសង្ឃឹមយ៉ាងមុតមាំថា ការប្តេជ្ញាចិត្តរបស់កម្ពុជា នឹងជម្រុញឲ្យមានការប្តេជ្ញាចិត្តដូចគ្នានេះពីដៃគូអភិវឌ្ឍន៍ទាំងអស់។

ខ្ញុំមានជំនឿជឿជាក់ថា អង្គវេទិកានារយៈពេលពីរថ្ងៃនេះនឹងផ្តល់នូវឱកាសដ៏ពិសេសសម្រាប់យើងទាំងអស់គ្នា ដើម្បីឆ្លុះបញ្ចាំងនូវសមិទ្ធផល ដែលសម្រេចបានកន្លងមក ស្វែងយល់រៀនសូត្រ និងពិភាក្សាលើប្រធានបទសំខាន់ៗនានាឈានទៅផ្តល់ជាអនុសាសន៍ជាក់ស្តែង ដែលជាប្រយោជន៍ក្នុងការកសាងព្រះរាជាណាចក្រមួយ ដែលបៃតងជាងមុន ធន់នឹងការប្រែប្រួលអាកាសធាតុ និងធានាបាននូវការអភិវឌ្ឍដោយសមធម៌ និងចីរភាព សម្រាប់ប្រជាពលរដ្ឋទូទៅ ក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

នៅទីបញ្ចប់ ខ្ញុំព្រះករុណា ខ្ញុំសូមប្រគេន និងជូនពរដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី ក្មួយៗសិស្សានុសិស្ស សមាជិកសមាជិកា នៃអង្គវេទិកាទាំងមូល សូមប្រកបដោយពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាង

ឃ្លាតឡើយ និងសូមប្រកាសបើកវេទិកាជាតិលើកទី ២ ស្តីពីការប្រែប្រួលអាកាសធាតុ ចាប់ពីពេលនេះតទៅ។

សូមអរព្រះគុណ និងសូមអរគុណ!

សុន្ទរកថាស្វាគមន៍ថ្ងៃទី០១

*របស់ ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន*
និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

- *សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គជាទីគោរពសក្ការៈ*
- *សូមគោរពឯកឧត្តម **ឃឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់*
- *ឯកឧត្តម លោកជំទាវ សមាជិកព្រឹទ្ធសភា រដ្ឋសភា ជាទីគោរព*
- *ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងសមាជិក សមាជិកា រាជរដ្ឋាភិបាលជាទីគោរព*
- *ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុជាទីគោរព*
- *ឯកឧត្តម លោកជំទាវ ឯកអគ្គរាជទូត អគ្គរដ្ឋទូត តំណាងស្ថានទូត ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល អង្គការមិនមែនរដ្ឋា ភិបាល និងវិស័យឯកជន ជាទីមេត្រី*
- *ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ សមាជិក សមាជិកានៃអង្គវេទិកាទាំង មូល ជាទីរាប់អាន*
- *ក្មួយៗសិស្សានុសិស្ស និងនិស្សិតទាំងអស់ជាទីស្រឡាញ់*

ជាបឋម ក្នុងនាមឲ្យគណៈរៀបចំកម្មវិធី និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ព្រមទាំងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវការគោរពកិច្ចស្វាគមន៍ និងសូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះវត្តមានរបស់ឯកឧត្តម **ឃឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងជាប្រធានកិត្តិយសនៃគណៈ
កម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុដែលឯកឧត្តមបានឆ្លៀតឱកាសដ៏មមាញឹកអញ្ជើញមកចូលរួមជាអតិបតី ក្នុងឱកាសបើកវេទិកាជាតិលើកទី ២ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលញុំាងឲ្យវេទិកានេះកាន់តែអធិកអធម។ ខ្ញុំសូមថ្លែងអំណរគុណដោយស្មោះចំពោះវត្តមានរបស់ ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងក្មួយៗសិស្សានុសិស្ស និងនិស្សិតទាំងអស់ ដែលបានអញ្ជើញមកចូលរួមក្នុងកម្មវិធីបើកវេទិកានេះ។

គណៈអធិបតីជាទីគោរព!

ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី!

បច្ចុប្បន្នមានការទទួលស្គាល់ជាទូទៅថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាពិភពលោកដ៏គម្រាមកំហែងមួយ ដែលនាំឲ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងខ្លាំង ដល់ការអភិវឌ្ឍសេដ្ឋកិច្ច-

សង្គមនៅព្រះរាជាណាចក្រកម្ពុជា ក៏ដូចជានៅបណ្តាលប្រទេសទាំងអស់ទូទាំងពិភពលោក។ នាបណ្តាឆ្នាំចុងក្រោយនេះ ប្រទេសនានាទូទាំងពិភពលោក ក៏ដូចជាប្រទេសកម្ពុជា បានជួបប្រទះនូវបាតុភូតធម្មជាតិមិនប្រក្រតីកាន់តែញឹកញាប់ និងធ្ងន់ធ្ងរជាងមុនដូចជា គ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះសង្ឃរា ។ល។ ដែលបង្កនូវផលប៉ះពាល់យ៉ាងខ្លាំងដល់ការផ្គត់ផ្គង់ទឹក ការធ្វើកសិកម្ម ហេដ្ឋារចនាសម្ព័ន្ធ សុវត្ថិភាពស្បៀងអាហារ អាយុជីវិត សុខភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសនៅជនបទ។ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់ សម្តេចតេជោនាយករដ្ឋមន្ត្រី តាមរយៈគណកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្រសួងបរិស្ថាន យល់ច្បាស់អំពីបញ្ហាអន្តរវិស័យដ៏គម្រាមកំហែងមួយនេះ។ ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុតាំងពីឆ្នាំ១៩៩៥ និងចូលជាសមាជិកពិធីសារក្យូតូនៅឆ្នាំ២០០២។ យើងបានរៀបចំរបាយការណ៍ជាតិលើកទី១ ស្តីពីការការប្រែប្រួលអាកាសធាតុ ក្រោមក្របខណ្ឌអនុសញ្ញាស្តីពីការប្រែប្រួលអាកាសធាតុ ហើយដាក់ជូនរបាយការណ៍នោះទៅកិច្ចប្រជុំកំពូលរបស់ប្រទេសជាសមាជិកអនុសញ្ញាឆ្នាំ២០០២។ នៅឆ្នាំ២០០៦ រាជរដ្ឋាភិបាល បានអនុម័តដាក់ឲ្យប្រើប្រាស់កម្មវិធីសកម្មភាពជាតិបន្ទាប់ទៅនឹងការប្រែប្រួលអាកាសធាតុ។ បណ្តាវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុយ៉ាងទូលំទូលាយត្រូវបានបញ្ជ្រាបទៅក្នុង ក្របខណ្ឌយុទ្ធសាស្ត្រចតុកោណ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សង្គមបច្ចុប្បន្នកម្ម ២០០៩-២០១៣។ ទាំងអស់នេះ គឺជាសឺគាពបញ្ជាក់នូវការប្តេជ្ញាចិត្តយ៉ាងខ្ពង់ខ្ពស់របស់រដ្ឋាភិបាល ក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់ និងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុឲ្យសមរម្យ និងទាន់ពេលវេលា ក៏ដូចជាការអនុវត្តន៍នូវកាលានុវត្តភាពពីបញ្ហានេះក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនក្នុងការអនុវត្តឆ្លើយតបនានា មានជាអាទិ៍ ការកសាងពង្រឹងសមត្ថភាពបច្ចេកទេស និងសមត្ថភាពស្ថាប័ន ការសិក្សាស្រាវជ្រាវ ការបញ្ជ្រាបបញ្ហាការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍ ការកៀរគរធនធានសម្រាប់អនុវត្តគម្រោងបន្ទាប់នឹងការប្រែប្រួលអាកាសធាតុ និងគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ បណ្តាគម្រោងក្របខណ្ឌយន្តការអភិវឌ្ឍន៍ស្អាតនៃពិធីសារក្យូតូ ការអប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងជាដើម។

ខ្ញុំសូមអនុញ្ញាតជម្រាបជូនអង្គវេទិកាមេត្តាជ្រាបថា នៅក្នុងរយៈពេលពីរឆ្នាំចុងក្រោយកន្លងទៅនេះ បន្ទាប់ពីបានទទួលនូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ សម្តេចតេជោ នៅក្នុងឱកាសពិធីបើកវេទិកាជាតិលើកទី១ ស្តីពីការប្រែប្រួលអាកាសធាតុ នាខែតុលា ឆ្នាំ២០០៩ ក្រសួងបរិស្ថាន ក្នុងនាមជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ បានខិតខំប្រឹងប្រែងសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដើម្បីរួមគ្នាអនុវត្តការងារឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ ហើយសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

1. គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលបានបង្កើតឡើងចាប់តាំងពីឆ្នាំ ២០០៦ បច្ចុប្បន្ននេះមានសមាជិកចំនួន២០ ក្រសួង-ស្ថាប័ន ដែលមានសម្តេចតេជោ ជាប្រធានកត្តិយស និងខ្ញុំបាទ ជាប្រធាន ហើយថ្មីៗនេះយើងបានបង្កើតក្រុមបច្ចេកទេសការងារប្រែប្រួលអាកាសធាតុអន្តរក្រសួងមួយ ដើម្បីជាសេនាធិការឲ្យគណៈកម្មាធិការជាតិនេះ។
2. នៅក្នុងសន្និសីទកំពូលលើកទី១៥ ស្តីពីការប្រែប្រួលអាកាសធាតុ នៅទីក្រុងកូបែនហាក ប្រទេសដាណឺម៉ាក នៅចុងឆ្នាំ២០០៩ កម្ពុជាបានបញ្ជូនគណៈប្រតិភូមួយក្រុមឲ្យទៅចូលរួម ដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ ណាំហុង** បានឡើងថ្លែងសុន្ទរកថាអំពីជំហររបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះការប្រែប្រួលអាកាសធាតុ ហើយបន្ទាប់មកនៅចុងខែមករា ឆ្នាំ២០១០ ព្រះរាជាណាចក្រកម្ពុជាបានផ្ញើលិខិតផ្តល់ការគាំទ្រដល់កិច្ចព្រមព្រៀងទីក្រុងកូបែនហាក ជូនលេខាធិការដ្ឋាននៃអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ព្រះរាជាណាចក្រកម្ពុជា ក៏បានបញ្ជូនគណៈប្រតិភូអន្តរក្រសួងចំនួន២២រូប ឲ្យទៅចូលរួមក្នុងសន្និសីទកំពូលលើកទី១៦ ដែលបានប្រព្រឹត្តទៅនៅចុងឆ្នាំ២០១០ នាទីក្រុងកាន់គុន ប្រទេសម៉ិកស៊ិចកូដងដែរ។
3. ក្រសួងបរិស្ថាន បានសហការជាមួយក្រសួងផែនការ និងបណ្តាក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម២០០៩-២០១៣ សម្រាប់ក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដើម្បីរួមគ្នាអនុវត្តក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។
4. ក្រសួងបរិស្ថានបានបង្កើត ***កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា*** ហើយបានដាក់ឲ្យដំណើរការជាផ្លូវការនៅចុងខែកុម្ភៈ ឆ្នាំ២០១០ ដែលកម្មវិធីនេះមានគោលបំណងជួយពង្រឹងសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងនាយកដ្ឋានប្រែប្រួលអាកាសធាតុនៃក្រសួងបរិស្ថាន ដែលជាលេខាធិការដ្ឋាន នៅក្នុងការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ ការអប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹង ព្រមទាំងការបង្កើត និងគ្រប់គ្រងមូលនិធិប្រែប្រួលអាកាសធាតុ។ កម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជានេះ មានថវិកាចំនួន ៨,៩លានដុល្លាអាមេរិក សម្រាប់រយៈពេលបីឆ្នាំ (២០១០-២០១២) ដែលផ្តល់ឲ្យដោយសហភាពអឺរ៉ុបចំនួន ៣,៣លានដុល្លា កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិចំនួន ៣លានដុល្លា អង្គការស៊ីដារបស់រដ្ឋាភិបាលស៊ុយអែតចំនួន ២,១លានដុល្លា និងអង្គការដានីដារបស់រដ្ឋាភិបាលដាណឺម៉ាកចំនួន ០,៥លានដុល្លា។ បច្ចុប្បន្ននេះ កម្មវិធីសម្ព័ន្ធភាពនេះកំពុងតែចាប់ផ្តើមដំណើរការរៀបចំផែនការយុទ្ធសាស្ត្រជាតិស្តីពីការប្រែប្រួលអាកាសធាតុ ដោយយើងរំពឹងថា ឯកសារនេះនឹងដើរតួនាទីជាត្រីវិស័យសម្រាប់ការងារឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុទាំងអស់

នៅកម្ពុជា។ ជាមួយគ្នានេះដែរ មូលនិធិប្រែប្រួលអាកាសធាតុក្រោមក្របខណ្ឌនៃសម្ព័ន្ធភាពនេះ បានត្រៀមផ្តល់ថវិកាជាលើកដំបូងរបស់ខ្លួនចំនួនប្រមាណជា ១,៨លានដុល្លាអាមេរិក ជូនដល់បណ្តាលក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់អនុវត្តគម្រោងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុចំនួន ៨ គម្រោង។

5. ក្រសួងបរិស្ថាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី កំពុងតែអនុវត្តកម្មវិធីសាកល្បងភាពធន់ទ្រាំនឹងអាកាសធាតុនៅកម្ពុជា ដោយបានរៀបចំកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់ទ្រាំនឹងអាកាសធាតុ ដែលនឹងប្រើប្រាស់ទឹកប្រាក់ ជំនួយឥតសំណងចំនួន ៣៦លានដុល្លាអាមេរិក និងប្រាក់កម្ចីសម្បទានចំនួនប្រមាណ ៥០-៥០ លានដុល្លាអាមេរិក សម្រាប់គាំទ្រការបញ្ចូលបការងារប្រែប្រួលអាកាសធាតុ ទៅក្នុងវិស័យសំខាន់ៗមួយចំនួន ដូចជា កសិកម្ម ធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។
6. ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ កំពុងអនុវត្តគម្រោង "បន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់លើកកម្ពស់ការគ្រប់គ្រងធនធានទឹក និងការប្រកបរបរកសិកម្ម" លើទឹកប្រាក់ប្រមាណ ៣ លានដុល្លា ដែលជាថវិកាពីមូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់ប្រទេស ដែលមានការអភិវឌ្ឍតិចតួច និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ។
7. ក្រសួងបរិស្ថានកំពុងចាប់ផ្តើមអនុវត្ត "កម្មវិធីវាយតម្លៃភាពងាយរងគ្រោះ និងបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុនៅតំបន់ឆ្នេរ ដោយផ្តោតលើការលើកកម្ពស់ជីវភាព និងប្រព័ន្ធអេកូឡូស៊ី" លើទឹកប្រាក់ប្រមាណ ១,៦លានដុល្លា ពីកម្មវិធីបរិស្ថានសហប្រជាជាតិ និងមូលនិធិបរិស្ថានពិភពលោក ហើយយើងកំពុងត្រៀមទទួលថវិកាបន្ថែមប្រមាណ ២,២លានដុល្លាទៀត ពីកម្មវិធីសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា ដើម្បីពង្រីកការអនុវត្តគម្រោងនេះ។
8. ក្រសួងបរិស្ថាន បានចុះហត្ថលេខានិយោគលើគម្រោងឥណទានកាបូនសម្រាប់ទីផ្សារស្ម័គ្រចិត្តលើផ្ទៃដីប្រមាណ ៥០០ ពាន់ហិកតា នៅដែនជម្រកសត្វព្រៃឱរ៉ាល់ និងភ្នំសំកុះ និងកំពុងសិក្សាពង្រាងកិច្ចសន្យានិយោគលើផ្ទៃដីប្រមាណ ៣៥០ ពាន់ហិកតា នៅឧទ្យានជាតិវីរជ័យ បូកគោ និងដែនជម្រកសត្វព្រៃបឹងពែរ។
9. រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន បាននឹងកំពុងសហការគ្នារៀបចំ និងអនុវត្តគម្រោងកាត់បន្ថយការបាត់បង់ និងរេចរឹលព្រៃឈើ រួមទាំងការគ្រប់គ្រងព្រៃឈើដោយនិរន្តរភាព ការអភិរក្សព្រៃឈើ និងការបង្កើនអាងស្តុកកាបូនក្នុងវិស័យព្រៃឈើ (REDD+) ដោយអនុលោមទៅតាមផែនទីបង្ហាញផ្លូវ ដែលបានរៀបចំរួចហើយ លើទឹកប្រាក់ ៣,៦ លានដុល្លា ពីអង្គការសហប្រជាជាតិ។
10. មកទល់បច្ចុប្បន្ន ក្រសួងបរិស្ថាន ក្នុងនាមជាស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍស្អាត បានអនុម័តគម្រោងយន្តការអភិវឌ្ឍស្អាតចំនួន ៧ ក្នុងវិស័យថាមពលកកើតឡើងវិញ ដែលជាគម្រោងវិនិយោគផ្នែកឯកជន អាចកាត់បន្ថយការបញ្ចោញឧស្ម័នផ្ទះកញ្ចក់ ប្រមាណ

៥៧០ ពាន់តោន ក្នុងមួយឆ្នាំ។ ក្នុងនោះគម្រោងចំនួន ៥ ត្រូវបានចុះបញ្ជីជាផ្លូវការរួច ហើយនៅអង្គការសហប្រជាជាតិ ដែលធ្វើឲ្យប្រទេសកម្ពុជាឈានមុខគេ ក្នុងចំណោមបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

11. នាពេលថ្មីៗនេះ ក្រសួងធនធានទឹក និងឧតុនិយម បានទទួលជំនួយពីរដ្ឋាភិបាលជប៉ុននៅក្រោមគំនិតផ្តួចផ្តើមតំបន់ទន្លេមេគង្គបៃតង សម្រាប់ការប្រែប្រួលអាកាសធាតុ (Green Mekong Initiative for Climate Change) ដែលមានទឹកប្រាក់ចំនួន ១១លានដុល្លាអាមេរិក សម្រាប់អនុវត្តកម្មវិធីធ្វើឲ្យប្រសើរឡើងសមត្ថភាពគ្រប់គ្រងគ្រោះមហន្តរាយ ដែលបណ្តាលមកពីការប្រែប្រួលអាកាសធាតុ។
12. ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល កំពុងតែបង្កើននូវការអនុវត្តគម្រោងជាច្រើន ដើម្បីពង្រឹងសន្តិសុខថាមពល និងរួមចំណែកកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ចូលក្នុងបរិយាកាស តាមរយៈការអនុវត្តគម្រោងប្រសិទ្ធភាពថាមពល និងគម្រោងថាមពលកកើតឡើងវិញ ដូចជាថាមពលវារីអគ្គិសនី ពន្លឺព្រះអាទិត្យ ជីវៈម៉ាស់ ជីវៈឧស្ម័ន និងគម្រោងផលិតកម្មស្អាតជាដើម។
13. ដើម្បីគាំទ្រដល់ការអភិវឌ្ឍដោយចីរភាព និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ឲ្យកាន់តែប្រសើរថែមទៀត ក្រសួងបរិស្ថានបានបង្កើតលេខាធិការដ្ឋានអភិវឌ្ឍន៍បៃតង ព្រមទាំងបានរៀបចំផែនទីបង្ហាញផ្លូវ និងបានចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់ជាមួយវិទ្យាស្ថានអភិវឌ្ឍន៍បៃតងពិភពលោកនៅដើមឆ្នាំ២០១១នេះ ដើម្បីកៀរគរថវិកាអនុវត្តគម្រោង ដែលគាំទ្រដល់ការអភិវឌ្ឍបៃតង និងបញ្ចេញកាបូនតិច។
14. ក្រសួងបរិស្ថាន បានសហការយ៉ាងជិតស្និទ្ធជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ក្នុងការលើកកម្ពស់ការយល់ដឹង អប់រំផ្សព្វផ្សាយ បណ្តុះបណ្តាល លើបញ្ហាទាក់ទងនឹងការប្រែប្រួលអាកាសធាតុ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាល សិក្ខាសាលាបណ្តុះបណ្តាល ការប្រើប្រព័ន្ធផ្សព្វផ្សាយនានា។ល។
15. ថ្មីៗនេះ កម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិប្រចាំកម្ពុជា ក្រោមកិច្ចសហការជាមួយក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានបោះពុម្ពផ្សាយនូវរបាយការណ៍អភិវឌ្ឍន៍មនុស្សនៅកម្ពុជាឆ្នាំ២០១១ ក្រោមចំណងជើងថា ការកសាភាពធន់ទ្រាំ: អនាគតនៃជីវភាពរស់នៅតាមជនបទនៅចំពោះមុខការប្រែប្រួលអាកាសធាតុ ដែលជាឯកសារវិភាគគោលនយោបាយឯករាជ្យមួយ ជាវិភាគទានក្នុងការគាំទ្រដល់ការរៀបចំគោលនយោបាយ និងផែនការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីជាទីគោរពដ៏ខ្ពង់ខ្ពស់!
ឯកឧត្តម លោកឧកញ៉ា លោកជំទាវ លោក លោកស្រី!

សមិទ្ធផលដូចដែលបានរៀបរាប់ជូនខាងលើ គឺជាផ្លែផ្កានៃកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ថ្នាក់ដឹកនាំ និងសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ មន្ត្រីជំនាញក្រសួងបរិស្ថាន ក្រោមការយកចិត្តទុកដាក់ជាប្រចាំ និងដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី។ ទោះជាយ៉ាងណាក្តី ការប្រែប្រួលអាកាសធាតុនឹងនៅតែបន្តជាបញ្ហាប្រឈមដ៏គម្រាមកំហែងមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ដែលអាចជះឥទ្ធិពលអវិជ្ជមានដល់កិច្ចខិតខំប្រឹងប្រែងក្នុងការអភិវឌ្ឍប្រទេសជាតិ ប្រសិនបើពុំមានការយកចិត្តទុកដាក់ក្នុងការឆ្លើយតបទៅនឹងផលប៉ះពាល់របស់វា ឲ្យបានទាន់ពេលវេលា និងសមស្របទេនោះ។ អាស្រ័យហេតុនេះ ដើម្បីជាគតិ និងជាមូលដ្ឋានសម្រាប់ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ក៏ដូចជាសម្រាប់ការរៀបចំគោលជំហរជាតិ ក្នុងការចរចាដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ និងការពិភាក្សា នាឱកាសវេទិកាជាតិក្នុងរយៈពេល ២ ថ្ងៃខាងមុខនេះ សំដៅរួមចំណែកកសាងប្រទេសជាតិឲ្យកាន់សំបូររុងរឿង ប្រកបដោយសុខសន្តិភាព ស្រស់បៃតងជាងមុន និងធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ ខ្ញុំបាទ និងអង្គវេទិកាទាំងមូល សូមអនុញ្ញាតគោរពអញ្ជើញ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី មេត្តាមានមតិសំណេះសំណាល ណែនាំ និងផ្តល់អនុសាសន៍ក្នុងពិធីបើកវេទិកាជាតិលើកទី២ស្តីពីការប្រែប្រួលអាកាសធាតុដ៏មហោឡារិកនេះដោយក្តីអនុគ្រោះ។

មុននឹងបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំសូមប្រគេនពរដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គនិងសូមគោរពជូនពរដល់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិ ក្មួយៗសិស្សានុសិស្ស និស្សិត សមាជិក សមាជិកានៃអង្គវេទិកាទាំងមូលសូមប្រកបដោយពុទ្ធិពរទាំងបួនប្រការ គឺអាយុ វណ្ណៈសុខៈ ពលៈ កុំបីឃ្លាងឃ្លាតឡើយ។

ខ្ញុំបាទសូមអនុញ្ញាតគោរពអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាថ្លែងសុន្ទរកថាបើកវេទិកាជាតិ លើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុ ដោយក្តីអនុគ្រោះសូមគោរពអញ្ជើញ។ សូមអរគុណ!

អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
United Nations in Cambodia

សុន្ទរកថាស្វាគមន៍ថ្ងៃទី០១

របស់លោក Douglas Broderick អ្នកសម្របសម្រួលរបស់កម្មវិធីសហប្រជាជាតិប្រចាំនៅកម្ពុជា

សូមគោរព!

- ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉ែត ប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រី ក្រសួងបរិស្ថាន
- ឯកឧត្តម
- ដៃគូអភិវឌ្ឍន៍
- ភ្ញៀវកិត្តិយសទាំងឡាយ
- លោក លោកស្រី ជាទីមេត្រី!

ជាបឋម ខ្ញុំសូមអបអរសារទគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលបានដឹកនាំការចាត់ចែងឲ្យមានព្រឹត្តិការណ៍ដ៏សំខាន់នេះ។

ក្នុងនាមក្រុមទីភ្នាក់ងារសហប្រជាជាតិ ខ្ញុំមានកិត្តិយស ដែលមានវត្តមាននៅទីនេះ នៅក្នុងវេលារសៀលនេះ ដើម្បីចូលរួមនៅក្នុងពិធីបើកវេទិកាជាតិលើកទីពីរស្តីពីការប្រែប្រួលអាកាសធាតុ។

ការពិភាក្សាថ្ងៃនេះ ផ្តោតលើបញ្ហាសំខាន់ៗមួយចំនួន ដែលរួមទាំងវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុផលប៉ះពាល់ និងកាលានុវត្តភាព ការវិវត្តថ្មីៗនៃការប្រែប្រួលអាកាសធាតុ និងកិច្ចផ្តួចផ្តើមសំខាន់ៗលើការងារប្រែប្រួលអាកាសធាតុនៅកម្ពុជា និងជោគជ័យ ការប្រឈម និងមេរៀននានាដែលទទួលបានស្តីពីការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ នៅពេលដែលយើងធ្វើឲ្យមានការរីកចម្រើនលើការអនុវត្តអនុសញ្ញាសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ។

ការប្រែប្រួលអាកាសធាតុ បង្កឲ្យមានផលប៉ះពាល់មកលើវិស័យទាំងអស់នៃសង្គមមនុស្ស។ នេះជាបាតុភូតសកលមួយ ហើយផលប៉ះពាល់របស់វាបង្ហាញឲ្យឃើញជាក់ស្តែង។

- ភ្លៀងធ្លាក់កាន់តែច្រើន បង្កឲ្យមានទឹកជំនន់នៅក្នុងតំបន់ជាច្រើន៖ សីតុណ្ហភាពកាន់តែក្តៅជាងមុនបាននាំឲ្យមានភ្លៀងកាន់តែច្រើននៅក្នុងតំបន់ខ្លះៗ ដែលអាចបង្កជាទឹកជំនន់។

- ភាពរាំងស្ងួតធ្ងន់ធ្ងរកាន់តែកើនឡើង៖ សីតុណ្ហភាពកាន់តែខ្ពស់ជាងមុនក៏បង្កឲ្យមានអត្រាខ្ពស់ជាងមុននៃរំហួតនិង ភាពរាំងស្ងួតកាន់តែច្រើនផងដែរ នៅក្នុងតំបន់ខ្លះៗលើពិភពលោក។
- ដំណាំក្លាយជាស្ងិតស្រពោន៖ កំណើនសីតុណ្ហភាព និងភាពរាំងស្ងួតធ្ងន់ធ្ងរនាំឲ្យមានការថយចុះនៃផលិតភាពដំណាំនៅជុំវិញពិភពលោក។ ការថយចុះផលិតភាពដំណាំអាចមានន័យថាខ្វះខាតស្បៀង ដែលនាំឲ្យមានផលប៉ះពាល់ជាច្រើនខាងផ្នែកសង្គម។
- ប្រព័ន្ធអេកូឡូស៊ីកំពុងប្រែប្រួល៖ នៅពេលដែលសីតុណ្ហភាពកើនឡើង ប្រភេទសត្វនានាអាចផ្លាស់ទីទៅរកទីជម្រក ដែលត្រជាក់ជាង បើពុំនោះទេត្រូវបាត់បង់ជីវិត។ ប្រភេទសត្វដែលងាយរងគ្រោះបំផុតរួមមាន ប្រភេទដែលជិតផុតពូជ ផ្កាថ្ម និងសត្វ ដែលរស់នៅតំបន់ប៉ូល។ ការឡើងកំដៅផែនដីក៏បានបង្កឲ្យមានការប្រែប្រួលពេលមកដល់នៃរដូវ និងរយៈពេលនៃរដូវដាំដំណាំផងដែរ។
- កំណើនកម្ពស់ទឹកសមុទ្រ៖ នៅក្នុងអំឡុងសតវត្សរ៍ទី២០ កម្ពស់ទឹកសមុទ្របានកើនឡើងប្រមាណ១៥ស.ម (ឬ៦អ៊ិញ) ដោយសារតែការរលាយផែនទឹកកក និងការរីកមាឌទឹកសមុទ្រដែលក្តៅជាងមុន។ ម៉ូដែលនានាព្យាករណ៍ថា កម្ពស់ទឹកសមុទ្រអាចកើនឡើងដល់៥៩ស.ម (ឬ២៣ អ៊ិញ) នៅក្នុងអំឡុងសតវត្សរ៍ទី២១ ដែលគម្រាមកំហែងដល់សហគមន៍នៅតំបន់ឆ្នេរតំបន់ដីសើម និងផ្កាថ្ម។
- សីតុណ្ហភាពនៃបឹងធំៗកំពុងកើនឡើងៗ៖ សីតុណ្ហភាពបឹងធំៗនៅទូទាំងពិភពលោកបានកើនឡើងយ៉ាងខ្លាំង។ កំណើនសីតុណ្ហភាពបាននាំឲ្យមានកំណើនការលូតលាស់នៃសារ៉ាយនានានៅក្នុងបឹង ដែលបង្កលក្ខខណ្ឌអំណោយផលសម្រាប់ពពួកប្រភេទដែលរាតត្បាតពីមជ្ឈដ្ឋានក្រៅ បង្កើតភាពខុសគ្នានៃកម្តៅនៅក្នុងជម្រៅខុសៗគ្នានៃបឹង និងធ្វើឲ្យទឹកក្នុងបឹងកាន់តែរឹង រាក់។
- សីតុណ្ហភាពក្តៅជាងមុនមានឥទ្ធិពលមកលើសុខភាពមនុស្ស៖ មានមនុស្សកាន់តែច្រើនឡើងដែលបានបាត់បង់ជីវិតដោយសាររលកកំដៅ និងការប៉ះទង្គិចកាន់តែច្រើនឡើងដោយសាររដូវបន្សាយលម្អងផ្កាមានរយៈពេលកាន់តែវែងជាងមុន។ ការប្រែប្រួលក៏ត្រូវបានសង្កេតឃើញផងដែរទាក់ទងនឹងរបាយកន្លែងរស់នៅរបស់សត្វ ដែលនាំមកជាមួយនូវជំងឺនានាដូចជា តាមរយៈសត្វមូស។

នៅកម្ពុជា ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ធ្វើឲ្យក្រុមមនុស្សងាយរងគ្រោះប្រឈមនឹងហានិភ័យ។ ក្រុមអ្នកក្រីក្រ និងក្រុមអ្នកងាយរងគ្រោះដទៃទៀត ដូចជា គ្រួសារដែលមានស្ត្រីជាមេគ្រួសារ កុមារ ជនជាតិដើម គឺជាអ្នកដែលរងគ្រោះខ្លាំងជាងគេ។ ព្រឹត្តិការណ៍អាកាសធាតុកំណាចដូចជា ទឹកជំនន់ និងគ្រោះរាំងស្ងួត ត្រូវបានគេទទួលស្គាល់រួចមកហើយថា ជាកត្តាចម្បងមួយ ដែលរួមចំណែកធ្វើឲ្យមានភាពក្រីក្រនៅកម្ពុជា។

ឯកឧត្តមលោក លោកស្រីជាទីមេត្រី!

ការស្វែងយល់អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនៅកម្រិតពិភពលោក និងកម្រិតប្រទេស និងដែលពឹងផ្អែកលើមេរៀនដែលទទួលបានពីគ្រោះមហន្តរាយកន្លងមកនៅកម្ពុជាមាន

សារសំខាន់ណាស់សម្រាប់យើង ដើម្បីអាចប្រយុទ្ធប្រឆាំងប្រកបដោយជោគជ័យទល់នឹងការប្រែប្រួលអាកាសធាតុ ទន្ទឹមនឹងជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ។

ខ្ញុំយល់ថាយើងមានកង្វល់ចម្បង២ចំនួនពីរ ដែលត្រូវដោះស្រាយប្រសិនបើយើងត្រូវជំនះការប្រឈមខាងអាកាសធាតុនៅកម្ពុជា។ ទីមួយ ត្រូវស្វែងយល់អំពីភាពងាយរងគ្រោះ ថាជាមធ្យោបាយដើម្បីត្រៀមរៀបចំយុទ្ធសាស្ត្រ សម្រាប់ធ្វើឲ្យរបរចិញ្ចឹមជីវិតនៅជនបទមានភាពធន់ទ្រាំ និងទីពីរត្រូវស្វែងរកវិធីនានា ដើម្បីផ្តល់ភាពអង់អាចដល់អ្នកក្រ និងអ្នកស្ថិតក្នុងស្ថានភាពជិតធ្លាក់ខ្លួនក្រីក្រ ដើម្បីទប់ទល់នឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។

ការប្រែប្រួលអាកាសធាតុសម្រាប់កម្ពុជា គឺជាការប្រឈមសំខាន់បំផុតមួយនៅក្នុងការអភិវឌ្ឍ។ កម្ពុជាមានភាពងាយរងគ្រោះជាខ្លាំង ដោយសារតែផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ។ ភាពងាយរងគ្រោះនេះមិនសុទ្ធតែកើតឡើងពីការរងឥទ្ធិពលខ្លាំងនោះឡើយ ប៉ុន្តែដោយសារតែសមត្ថភាពទាបសម្រាប់ការបន្សាំ និងសម្រាប់ការទប់ទល់។

សមត្ថភាពទាំងនេះអាច និងគួរតែពង្រឹងមិនត្រឹមតែជាផ្នែកមួយនៃការឆ្លើយតបទូលំទូលាយរបស់ជាតិទៅនឹងឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុប៉ុណ្ណោះទេ ប៉ុន្តែក៏ជាការពង្រឹងសមត្ថភាពរបស់ប្រទេសដើម្បីឆ្លើយតបទៅនឹងគ្រោះមហន្តរាយធម្មជាតិទាំងអស់ និងដើម្បីកាត់បន្ថយផលប៉ះពាល់នៃគ្រោះមហន្តរាយទាំងនោះមកលើអ្នកក្រ និងអ្នកដែលជិតធ្លាក់ខ្លួនក្រផងដែរ។

អភិក្រមល្អបំផុតសម្រាប់កសាងការចិញ្ចឹមជីវិតដែលធន់ទ្រាំនៅក្នុងបរិបទការប្រែប្រួលអាកាសធាតុគឺការបន្សាំដែលផ្តល់អត្ថប្រយោជន៍តាមរយៈការដោះស្រាយអាទិភាពនានានៃការអភិវឌ្ឍបច្ចុប្បន្ននេះ។ឧទាហរណ៍ការបង្កើតបណ្តាញសុវត្ថិភាពសង្គមនិងការកែលំអកិច្ចប្រឹងប្រែងកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយនឹងផ្តល់អត្ថប្រយោជន៍ផ្គាល់ស្របជាមួយគោលរបស់រាជរដ្ឋាភិបាល។

ទន្ទឹមនឹងនេះ ការធ្វើបែបនេះនឹងពង្រឹងភាពធន់ទ្រាំនៃប្រជាពលរដ្ឋ ដែលងាយរងគ្រោះផងដែរ ដែលជួយបង្កើនសមត្ថភាពរបស់ពួកគេ ដើម្បីឆ្លើយតបទៅនឹងផលប៉ះពាល់ ដែលអាចកើតចេញពីការប្រែប្រួលអាកាសធាតុ។

ប៉ុន្តែការធ្វើបែបនេះបាន ទាមទារឲ្យមានការពិនិត្យមើលគោលបំណងអភិវឌ្ឍន៍ សម្រាប់រយៈពេលវែងតាមរយៈទស្សនៈវិស័យថ្មីមួយ និងដែលគាំទ្រឲ្យមានការជជែកវែកញែកជាសាធារណៈប្រកបដោយការពិចារណា និងការយល់ដឹងជាមុន និងការធ្វើសេចក្តីសម្រេច ដែលអាចដោះស្រាយភាពមិនប្រាកដប្រជា និងហានិភ័យនានាដែលបង្កដោយការប្រែប្រួលអាកាសធាតុ។

ដោយសារការប្រែប្រួលអាកាសធាតុ គឺជាប្រភពមួយនៃភាពងាយរងគ្រោះ និងជាការគម្រាមកំហែងដល់ការរីកចម្រើននៃការអភិវឌ្ឍរបស់កម្ពុជា ប្រការសំខាន់គឺត្រូវយកចិត្តទុកដាក់ជាពិសេសដល់ភាពក្រីក្រ និងភាពងាយរងគ្រោះនៅជនបទ។ ដោយមានប្រជាពលរដ្ឋភាគច្រើនបំផុតជាអ្នកក្រីក្ររស់នៅតាមទីជនបទ និងដែលពឹងផ្អែកលើកសិកម្ម ការស្វែងយល់ និងការឆ្លើយតបទៅនឹងមូលហេតុជាឫសគល់នៃភាពក្រីក្រ និងភាពងាយរងគ្រោះមានសារសំខាន់ណាស់ ដើម្បីយល់ដឹងអំពីការពាក់ព័ន្ធនៃការអភិវឌ្ឍមនុស្សបណ្តាលពីការប្រែប្រួលអាកាសធាតុ និងសម្រាប់បង្កើតមធ្យោបាយដើម្បីកាត់បន្ថយឥទ្ធិពលទាំងនោះ។

បន្ថែមលើនេះ ប្រការសំខាន់គឺត្រូវដោះស្រាយរចនាសម្ព័ន្ធនៃភាពក្រីក្រ និងភាពងាយរងគ្រោះ ជាងផ្តោតតែលើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ខ្ញុំសូមស្នើឲ្យមានអនុសាសន៍

ចំនួនបីដើម្បីពង្រឹងភាពអង់អាចសម្រាប់ការរស់នៅរបស់អ្នកក្រ និងអ្នកជិតធ្លាក់ក្នុងភាពក្រីក្រ ដើម្បីទប់ទល់នឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ៖

- ទីមួយ តាមរយៈការបង្កើននូវការយល់ដឹង ចំណេះដឹង ព័ត៌មាន និងសមត្ថភាពរបស់អ្នកនៅជនបទដើម្បីកសាងផែនការ និងការធ្វើសេចក្តីសម្រេច
- ទីពីរ តាមរយៈការធានាថា ពលរដ្ឋក្រីក្រមានលទ្ធភាពប្រសើរជាងមុនក្នុងការទទួលបានគាំទ្រហិរញ្ញវត្ថុ និងបច្ចេកទេស និង
- ទីបី តាមរយៈការពង្រឹងសិទ្ធិរបស់អ្នកនៅជនបទ ទាក់ទងនឹងការទទួលបានព័ត៌មាន ដែលអាចទុកចិត្តបាន សិទ្ធិក្នុងការត្រួតត្រា និងការប្រើប្រាស់ធនធានធម្មជាតិដោយនិរន្តរភាព (ដូចជាទឹក ព្រៃឈើ ជលផល និងដីធ្លី) និងសិទ្ធិដើម្បីចូលរួមប្រកបដោយអត្ថន័យ នៅក្នុងការកសាងផែនការ និងការធ្វើសេចក្តីសម្រេច។

ឯកឧត្តមលោក លោកស្រី ជាទីមេត្រី!

អ.ស.ប បានចាត់ទុកការប្រែប្រួលអាកាសធាតុ ជាអាទិភាពខ្ពស់មួយនៅក្នុងរបៀបវារៈអភិវឌ្ឍន៍របស់ខ្លួន។ យើងមានការប្តេជ្ញាដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយគាំទ្រ និងជួយរាជរដ្ឋាភិបាលកម្ពុជាក្រោមកិច្ចសហការជិតស្និទ្ធជាមួយដៃគូអភិវឌ្ឍន៍សំខាន់ៗ សង្គមស៊ីវិល និងវិស័យឯកជន។

យើងនឹងបន្តផ្តល់ការគាំទ្រដល់រដ្ឋាភិបាល ដើម្បីកែលម្អការសម្របសម្រួល ពង្រឹងការយល់ដឹង និងការស្វែងយល់អំពីការប្រែប្រួលអាកាសធាតុ កៀរគរការគាំទ្របច្ចេកទេស និងហិរញ្ញវត្ថុ សម្រាប់ដោះស្រាយភាពខ្វះចន្លោះទាំងនេះ។

អ.ស.ប ក៏នឹងបន្តសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍នានា និងស្ថាប័នរដ្ឋាភិបាល ដើម្បីសម្រួលឲ្យមានការសន្ទនាគោលនយោបាយអំពីការប្រែប្រួលអាកាសធាតុ នៅក្នុងវិស័យខុសៗគ្នា និងក្នុងផ្នែកខុសៗគ្នាផងដែរ។

យុទ្ធសាស្ត្រអភិវឌ្ឍន៍បច្ចុប្បន្នរបស់អ.ស.ប បានកំណត់អត្តសញ្ញាណការប្រែប្រួលអាកាសធាតុ ថាជាអាទិភាពមួយ ហើយទីភ្នាក់ងារនានានៃអ.ស.ប កំពុងធ្វើការជាមួយគ្នាលើការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យខុសៗគ្នា។

ឧទាហរណ៍៖ FAO IFAD និងUNDP កំពុងធ្វើការលើការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុសម្រាប់កសិកម្ម និងធនធានទឹក និងគាំទ្រដល់ការសម្រួលឲ្យមានវេទិកាប្រចាំឆ្នាំ អំពីកសិកម្ម និងការប្រែប្រួលអាកាសធាតុ។

អង្គការ WFP និង IOM កំពុងធ្វើការជាមួយគ្នាលើការផ្តល់ជំនួយសង្គ្រោះបន្ទាន់ ពីគ្រោះមហន្តរាយនានា និងការត្រៀមបង្ការ។

WHO និង UNICEFF កំពុងធ្វើការលើផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើសុខភាព ជាពិសេស មកលើស្ត្រី និងកុមារ។

UNDP FAO និង UNEP កំពុងជម្រុញឲ្យមានការគ្រប់គ្រងព្រៃឈើ ដោយនិរន្តរភាព និងជួយកម្ពុជាត្រៀមខ្លួនសម្រាប់កាត់បន្ថយការបំភាយឧស្ម័នពីការបាត់បង់ព្រៃឈើ និងការរេចរឹលព្រៃឈើ។

UNIDO កំពុងធ្វើការលើប្រសិទ្ធភាពថាមពលនិង កាត់បន្ថយការបំភាយឧស្ម័ន។ ហើយអង្គការលំនៅស្ថាននៃអ.ស.បបាន និងកំពុងវាយតម្លៃភាពងាយរងគ្រោះ និងសមត្ថភាពបន្សុំនៅក្រុងព្រះសីហនុផងដែរ។

ឯកឧត្តមលោក លោកស្រីជាទីមេត្រី !

ខ្ញុំគិតថា យើងឯកភាពគ្នាថា ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ អាចបង្កជាការគម្រាមកំហែងជាច្រើនមកលើការរីកចម្រើននៃការអភិវឌ្ឍរបស់កម្ពុជា។

ឥឡូវនេះ កម្ពុជាត្រូវតែត្រៀមខ្លួនតាមរយៈការកសាងគោលនយោបាយស្ថាប័ន ចំណេះដឹង និងព័ត៌មានស្តីពីប្រែប្រួលអាកាសធាតុ។

កម្ពុជា ត្រូវតែបង្កើតយន្តការហិរញ្ញប្បទានរឹងមាំ និងប្រកបដោយប្រសិទ្ធភាពមួយ ដើម្បីស្រូបយក និងគ្រប់គ្រងការចំណាយលើការប្រែប្រួលអាកាសធាតុ។

ប្រការដែលសំខាន់ផងដែរគឺ ត្រូវពង្រឹងភាពអង់អាចរបស់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះជាពិសេស ជនក្រីក្រ និងជិតក្រីក្រ កុមារ និងយុវជន ជនជាតិដើម និងស្ត្រី ដើម្បីឲ្យមានចំណេះដឹងប្រសើរជាងមុន និងសមត្ថភាពដើម្បីលើកផែនការ និងធ្វើការសម្រេច ដែលទាក់ទងការចិញ្ចឹមជីវិតរបស់ពួកគេនៅចំពោះមុខការប្រែប្រួលអាកាសធាតុ។

ខ្ញុំជឿថា យើងអាច នឹងត្រូវធ្វើធ្វើសកម្មភាពពីឥឡូវនេះ ដើម្បីត្រៀមកម្ពុជាសម្រាប់ប្រឈមនឹងការលំបាកនានា និងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ។

អរគុណច្រើន!

សុន្ទរកថាស្វាគមន៍ថ្ងៃទី០១

*របស់ ឯកឧត្តមបណ្ឌិត **ម៉ុក ម៉ារ៉ែត** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងបរិស្ថាន*
និងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

សូមគោរពគណៈអធិបតី

- ឯកឧត្តម *Douglas Broderick* អ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា
- ឯកឧត្តម លោកជំទាវ ជាអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួង-ស្ថាប័នរាជធានី-ខេត្តពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងស្ថានទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន
- លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិ សមាជិក សមាជិកានៃអង្គវេទិកាទាំងមូល

ជាបឋម តាងនាមគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក៏ដូចជាក្រសួងបរិស្ថាន ខ្ញុំមានកិត្តិយស និងក្តីសោមនស្សរីករាយ ដោយបានចូលរួមធ្វើជាគណៈអធិបតី នៅក្នុងវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុដ៏អធឹកអធមនេះ។ ឆ្លៀតក្នុងឱកាសដ៏ថ្លៃថ្លានេះ ខ្ញុំសូមសំដែងការស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវត្តមាន ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិ ព្រមទាំងសមាជិក សមាជិកាទាំងអស់ ដែលបានឆ្លៀតពេលដ៏មមាញឹកអញ្ជើញមកចូលរួមក្នុងព្រឹត្តិការដ៏មានសារសំខាន់នេះ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី!

បច្ចុប្បន្នមានការទទួលស្គាល់ជាទូទៅថា ការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាប្រឈមដ៏គម្រាមកំហែងមួយ ដែលពិភពលោកកំពុងតែជួបប្រទះ។ របាយការណ៍លើកទី ៥ របស់ក្រុមការងារអន្តរដ្ឋាភិបាលស្តីពីការប្រែប្រួលអាកាសធាតុនៃអង្គការសហប្រជាជាតិ និងលទ្ធផលនៃការស្រាវជ្រាវវិទ្យាសាស្ត្រនាពេលចុងក្រោយនេះ បានអះអាងជាថ្មី ប្រកបដោយកម្រិតជាក់លាក់ខ្ពស់ជាងមុនថា សកម្មភាពមនុស្ស គឺជាមូលហេតុចម្បងនាំឲ្យមានការប្រែប្រួលអាកាសធាតុ។ បណ្តាប្រទេសនៅក្នុងតំបន់ទន្លេមេគង្គងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ដោយសារការប្រែប្រួលរបបទឹកទន្លេមេគង្គ ការថយចុះនូវទិន្នផលកសិកម្ម និងជលផល ការជ្រាបចូលនៃទឹកសមុទ្រ កំណើនដង់ស៊ីតេប្រជាជន កង្វះខាតធនធានហិរញ្ញវត្ថុ និងបច្ចេកទេស និងហេដ្ឋារចនាសម្ព័ន្ធរបវន្តពុំទាន់សមស្រប។ ជាក់ស្តែងប្រទេសកម្ពុជាយើងបានជួបប្រទះនូវកំណើនទឹកជំនន់ គ្រោះរាំងស្ងួត និងខ្យល់ព្យុះជាញឹកញាប់នាប៉ុន្មានឆ្នាំចុងក្រោយនេះ ហើយបញ្ហានេះបានជះឥទ្ធិពលយ៉ាងខ្លាំងដល់ សុវត្ថិភាព សុខៀង ការរស់នៅរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា។ នៅពេលដែលយើងកំពុងតែជួបជុំគ្នានេះ គ្រោះទឹកជំនន់ដ៏ធ្ងន់ធ្ងរកំពុងតែយាយីបណ្តាខេត្តជាច្រើនរបស់កម្ពុជា

ដែលបង្កឲ្យមានការបាត់បង់អាយុជីវិតប្រជាពលរដ្ឋ រាប់សិបនាក់ ខូចខាតទ្រព្យសម្បត្តិ ផលដំណាំ និងហេដ្ឋារចនាសម្ព័ន្ធរូបវន្តយ៉ាងធ្ងន់ធ្ងរ។

លទ្ធផលនៃការសិក្សាបែបវិទ្យាសាស្ត្រថ្មីៗ ដែលធ្វើឡើងក្រោមក្របខណ្ឌរបាយការណ៍ជាតិលើកទី២ ក្រោមអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ បានបង្ហាញថា ក្នុងអំឡុងកន្លះទស្សវត្សរ៍ចុងក្រោយនេះ សីតុណ្ហភាព និងរបបទឹកភ្លៀងនៅកម្ពុជាបានចាប់ផ្តើមប្រែប្រួលរួចទៅហើយ។ ដោយឡែកការព្យាករណ៍សម្រាប់រយៈពេល៨០ឆ្នាំខាងមុខ បានបង្ហាញថា នាពេលអនាគត សីតុណ្ហភាពនៅកម្ពុជា អាចនឹងបន្តកើនឡើងបន្ថែមទៀត ចំណែកឯកម្ពស់ទឹកភ្លៀងនៅរដូវប្រាំងកាន់តែថយចុះ នៅពេលដែលរដូវវស្សាអាចក្រមកដល់ តែកម្ពស់ទឹកភ្លៀងអាចកើនឡើង។ កម្រិតនៃការប្រែប្រួលនេះអាចផ្សេងៗគ្នា អាស្រ័យទៅតាមសេណារីយ៉ូនៃការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ នេះមានន័យថា វិស័យជាច្រើននៃសេដ្ឋកិច្ច-សង្គមរបស់ជាតិនឹងត្រូវរងផលប៉ះពាល់។ ចំណុចសំខាន់មួយទៀតគឺថា កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់របស់សហគមន៍អន្តរជាតិនឹងមានផលវិបាកដោយផ្ទាល់សម្រាប់កម្ពុជា។ ប្រការនេះបញ្ជាក់ថា កម្ពុជាត្រូវតែត្រៀមខ្លួនរស់នៅក្រោមសេណារីយ៉ូនៃការប្រែប្រួលអាកាសធាតុ ដែលតម្រូវឲ្យយើងមានគោលនយោបាយថ្មី ផ្លាស់ប្តូររបៀបធ្វើផែនការ និងទម្លាប់អនុវត្តនៅក្នុងគ្រប់ទិដ្ឋភាពនៃសេដ្ឋកិច្ច-សង្គម ដើម្បីធានាបាននូវការអភិវឌ្ឍដោយចីរភាពក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

រាជរដ្ឋាភិបាល បានចាត់ទុកការប្រែប្រួលអាកាសធាតុ ជាអាទិភាពជាតិដ៏សំខាន់ហើយជាបណ្តើរៗបានបញ្ចូលបញ្ហានេះទៅក្នុងគោលនយោបាយជាតិ និងផែនការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងផែនការ តាមវិស័យពាក់ព័ន្ធនានា ព្រោះថាការប្រែប្រួលអាកាសធាតុ គឺជាបញ្ហាអន្តរវិស័យ ពាក់ព័ន្ធដោយផ្ទាល់ជាមួយអាណត្តិរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធជាច្រើន។ ជាងនេះទៅទៀត រាជរដ្ឋាភិបាលបានបញ្ចូលការងារប្រែប្រួលអាកាសធាតុ ទៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ សំដៅជម្រុញឲ្យគ្រប់ស្ថាប័នពាក់ព័ន្ធ ចូលរួមអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ឲ្យបានកាន់តែទូលំទូលាយ និងមានប្រសិទ្ធភាពខ្ពស់ ដើម្បីគាំទ្រដល់ការសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហសវត្សរ៍នានា ក្នុងក្របខណ្ឌយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២។ យើងបាន និងកំពុងបំពេញការងារជាច្រើនដូចជា៖ ការកសាងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេស ការងារសិក្សាស្រាវជ្រាវ ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ ការអប់រំផ្សព្វផ្សាយ ការអនុវត្តអនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ ការអនុវត្តពិធីសារក្យូតូ តាមរយៈយន្តការអភិវឌ្ឍស្អាត ការអនុវត្តកម្មវិធីអភិវឌ្ឍន៍បៃតងជាតិ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការងារសម្របសម្រួលរវាងបណ្តាក្រសួង-ស្ថាប័ន និងដៃគូអភិវឌ្ឍន៍ ។ល។

ទោះជាយ៉ាងណាក្តី យើងនៅមានភាពខ្វះចន្លោះនៅក្នុងការយល់ដឹងជាសាធារណៈ ចំណេះដឹងបច្ចេកទេសអំពីផលប៉ះពាល់ និងកាលានុវត្តភាព ដែលអាចទទួលបានពីប្រែប្រួលអាកាសធាតុ ក៏ដូចជាការសម្របសម្រួលក្នុងការអនុវត្តវិធានការឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ក្នុងន័យនេះការរៀបចំវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុ ក៏ដូចជាវេទិកា ដូចគ្នានេះតទៅមុខទៀតជាទៀងទាត់មានសារសំខាន់ណាស់ ដើម្បីពិនិត្យវាយតម្លៃលើលទ្ធផលការងារ ដែលសម្រេចបាន ចែករំលែកព័ត៌មាន បទពិសោធន៍ល្អៗ បង្កើតឲ្យមានការសន្ទនាប្រកបដោយន័យស្ថាបនា លើបញ្ហារៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រជម្រុញការបញ្ចូលការងារប្រែ

ប្រែលអាកាសធាតុ និងដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលក្នុងចំណោមស្ថាប័នរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល។

ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី!

កាលពីព្រឹកម៉ិញនេះ យើងបានត្រងត្រាប់នូវសុន្ទរកថាប្រកបដោយអត្ថន័យរបស់ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី តំណាងដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានលើកឡើងពីកិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជា ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ ក្នុងនាមជាប្រទេស ដែលងាយរងគ្រោះដោយសារការប្រែប្រួលអាកាសធាតុ និងផ្តល់នូវអនុសាសន៍គោលនយោបាយសំខាន់ៗចំនួន ៦ ចំណុចពាក់ព័ន្ធនឹង៖ ការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ, ការពង្រឹងសមត្ថភាព និងការសម្របសម្រួលការអនុវត្តគម្រោងជាក់ស្តែង ការកៀរគរធនធាន ការអប់រំលើកកម្ពស់ការយល់ដឹង និងការចរចាអន្តរជាតិ ដែលទាំងអស់នេះ គឺជាធាតុចូលយ៉ាងសំខាន់ សម្រាប់គាំទ្រដល់ដំណើរការរបស់អង្គវេទិកាជាតិក្នុងរយៈពេលពីរថ្ងៃកន្លះខាងមុខនេះ។

ខ្ញុំមានសេចក្តីរីករាយ ដោយបានឃើញនូវវត្តមានរបស់អ្នកជំនាញការជាតិ អន្តរជាតិ ដែលនឹងធ្វើជាវាគ្មិន និងចូលរួម ក្នុងការពិភាក្សាលើប្រធានបទយ៉ាងទូលំទូលាយ ដូចជាវិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ ស្ថានភាពនៃការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា បន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ គោលនយោបាយប្រែប្រួលអាកាសធាតុ ហិរញ្ញប្បទានការប្រែប្រួលអាកាសធាតុ និងប្រធានបទពាក់ព័ន្ធនឹងបញ្ហាអន្តរវិស័យជាច្រើនទៀត។ ជាមួយគ្នានេះ ខ្ញុំក៏មានសេចក្តីរំភើបរីករាយ ដោយបានឃើញការចូលរួមយ៉ាងសកម្មពីសំណាក់ក្រុមហ៊ុនឯកជន និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ដែលបានមកចូលរួមតាំងពិពរណ៌ផលិតផល ដែលមិនប៉ះពាល់អាកាសធាតុ។ នេះជាសញ្ញាវិជ្ជមានមួយដែលបញ្ជាក់ថា វិស័យឯកជនកម្ពុជាកាន់តែយល់ច្បាស់ពីតួនាទីមិនអាចកាត់ផ្តាច់បានរបស់ខ្លួន ក្នុងការដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ហើយវាបង្ហាញពីកាលានុវត្តភាព ដែលអាចទទួលបានក្នុងកិច្ចខិតខំឆ្លើយតបនឹងបញ្ហានេះ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាទីមេត្រី!

ខ្ញុំមានជំនឿយ៉ាងមុតមាំថា នៅក្នុងពេល២ថ្ងៃខាងមុខនេះ សិក្ខាកាមទាំងអស់នឹងមានឱកាសទទួលបាននូវចំណេះដឹង បំណិនប្រសព្វ ព័ត៌មាន និងបទពិសោធន៍ដ៏មានប្រយោជន៍ជាច្រើន ក៏ដូចជាមានឱកាសចូលរួមក្នុងការពិភាក្សាលើប្រធានបទសំខាន់ៗនានា ធ្វើយ៉ាងណាប្រើប្រាស់ឲ្យអស់លទ្ធភាពនូវកាលានុវត្តដ៏កម្រ ដែលវេទិកានេះផ្តល់ឲ្យ ដើម្បីជាទុនបន្ថែមទៀតក្នុងការពង្រឹងសកម្មភាពឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។ វត្តមានរបស់ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ជាតំណាងមកពីគ្រប់ស្ថាប័នទាំងរដ្ឋាភិបាល ដៃគូ អភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល និងវិស័យឯកជន គឺជាសញ្ញាវិជ្ជមានប្រកបដោយការលើកទឹកចិត្ត ជាសក្ខីភាពបញ្ជាក់ថា យើងទាំងអស់គ្នាមានការចាប់អារម្មណ៍ និងកង្វល់រួមលើ បញ្ហាប្រែប្រួលអាកាសធាតុ ហើយក៏វាបញ្ជាក់ពីឆន្ទៈ និងជំហររួមគ្នាក្នុងការរួមចំណែកដោះស្រាយបញ្ហាប្រឈមនេះដើម្បីកសាង

កម្ពុជាមួយដែលបៃតងជាងមុន ធន់នឹងការប្រែប្រួលអាកាសធាតុ និងធានាបាននូវការអភិវឌ្ឍដោយសមធម៌ និងចីរភាពសម្រាប់ប្រជាពលរដ្ឋទូទៅក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

ជាទីបញ្ចប់ តាងនាមឲ្យគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក៏ដូចជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងបរិស្ថាន ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី សូមបានប្រកបដោយសិរីសួស្តីជ័យមង្គល វិបុលសុខ អាយុយឺនយូរ កំលាំងខ្លាំងក្លា និងប្រាជ្ញាឈ្លាសវៃ កុំបីឃ្លៀងឃ្លាតឡើយ។ សូមជូនពរឲ្យអង្គវេទិកាជាតិនេះ ប្រព្រឹត្តទៅដោយជោគជ័យ។

សូមអរគុណ!

សុន្ទរកថាស្វាគមន៍ថ្ងៃទី០២

របស់លោក Peter J. Brimble សេដ្ឋកិច្ចវិទូជាន់ខ្ពស់ និងជា OIC
នៃធនាគារអភិវឌ្ឍន៍អាស៊ីប្រចាំនៅកម្ពុជា

សូមគោរព !

- ឯកឧត្តមបណ្ឌិត ម៉ុក ម៉ារ៉េត ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងបរិស្ថាន
- លោក ដូក្លាស់ ប្រូដេរិក អ្នកសម្របសម្រួលនៃអ.ស.បប្រចាំនៅកម្ពុជា
- ថ្នាក់ដឹកនាំជាន់ខ្ពស់ និងមន្ត្រីក្រសួង/ស្ថាប័នជាតិ និងខេត្ត/ក្រុងនៃរាជរដ្ឋាភិបាលកម្ពុជា តំណាងអង្គទូត ដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល
- លោក លោកស្រី ជាទីមេត្រី!

ខ្ញុំរីករាយណាស់ដែលមានវត្តមាននៅទីនេះ ក្នុងថ្ងៃនេះ ដើម្បីថ្លែងសុន្ទរកថាស្វាគមន៍ ក្នុងនាមធនាគារអភិវឌ្ឍន៍អាស៊ី នៅក្នុងវេទិកាជាតិលើកទីពីរ ស្តីពីការប្រែប្រួលអាកាសធាតុ ដែលការចាត់ចែងឡើងនេះចំពេល និងមានសារសំខាន់បំផុត ដោយសារមានរយៈពេលមិនដល់៧សប្តាហ៍ខាងមុខនេះនឹងមាន សន្និសីទនៃភាគីក្រោមអនុសញ្ញាប្រែប្រួលអាកាសធាតុ (CoP១៧) នៅទីក្រុងឌូបាន។

ការប្រែប្រួលអាកាសធាតុ គឺជាការប្រឈមមួយក្នុងចំណោមការប្រឈមចម្បងៗចំពោះមនុស្សជាតិ។ នៅទីនេះក្នុងប្រទេសកម្ពុជា យើងបាន និងកំពុងជួបប្រទះផលប៉ះពាល់ប្រកបដោយមហន្តរាយបណ្តាលពីការប្រែប្រួលអាកាសធាតុ គ្រោះរាំងស្ងួត ទឹកជំនន់ និងព្រឹត្តិការណ៍អាកាសធាតុកំណាច ដែលកើតឡើងកាន់តែញឹកញាប់ និងកាន់តែខ្លាំងក្លា។ យើងទាំងអស់គ្នាបានដឹងអំពីការខូចខាតយ៉ាងធ្ងន់ធ្ងរបង្កឡើងកាលពីពីរឆ្នាំមុន ដោយសារព្យុះកេតសាណា ហើយសូម្បីតែកាលពីសប្តាហ៍មុននេះ ក៏បានបង្កដោយទឹកជំនន់ ដែលមាននៅទូទាំងប្រទេសនេះផងដែរ។

ការប្រែប្រួលអាកាសធាតុ ក៏ធ្វើឲ្យទិន្នផលកសិកម្មទាបជាងមុនផងដែរ កំណើនការប៉ះទង្គិចដោយសារកង្វះខាតទឹក និងការរាតត្បាតនៃជំងឺឆ្លង។ ក្នុងនាមជាប្រទេសអភិវឌ្ឍតិចតួច ដែលមានសមត្ថភាពបន្សុំទាប កម្ពុជាងាយរងគ្រោះជាខ្លាំង ដោយសារផលប៉ះពាល់ទាំងនេះ។ ភាពមិនអនុគ្រោះ ជាក់ស្តែងនៃការប្រែប្រួលអាកាសធាតុ គឺថាអ្នកក្រនឹងរងគ្រោះជាងគេ សូម្បីតែពួកគេរួមចំណែកត្រឹមតិចតួចប៉ុណ្ណោះនៅក្នុងបញ្ហានេះ។ ក្នុងនាមជាស្ថាប័នមួយ ដែលមានកង្វល់អំពីការលុបបំបាត់ភាពក្រីក្រ ធនាគារអភិវឌ្ឍន៍អាស៊ី មានការប្តេជ្ញាយ៉ាងជ្រាលជ្រៅ ដើម្បីជួយកម្ពុជានៅក្នុងការដោះស្រាយការប្រឈមនានានៃការប្រែប្រួលអាកាសធាតុ។

យុទ្ធសាស្ត្រឆ្នាំ២០២០ របស់ធានាគារអភិវឌ្ឍន៍អាស៊ី ទទួលស្គាល់និរន្តរភាពបរិស្ថាន ដែលរួមទាំងការប្រែប្រួលអាកាសធាតុថា ជាអាទិភាពមួយ ក្នុងចំណោមអាទិភាពស្នូលចំនួនប្រាំ នៅក្នុងការគាំទ្រដល់ប្រទេសនានាជាសមាជិករបស់យើង។ នៅក្នុងផ្នែកប្រែប្រួលអាកាសធាតុ ធានាគារ

អភិវឌ្ឍន៍អាស៊ីបានកំណត់អត្តសញ្ញាណអាទិភាពប្រតិបត្តិចំនួនប្រាំ ដើម្បីដោះស្រាយទាំងការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងការបន្សាំនៅក្នុងទ្រង់ទ្រាយចម្រុះមួយ។ អាទិភាពទាំងនោះរួមមាន៖ (១) ពង្រីកថាមពលស្អាត (២) លើកទឹកចិត្តឲ្យមានការអភិវឌ្ឍទីក្រុង ដែលសមស្របនឹងលក្ខខណ្ឌអាកាសធាតុ និងការដឹកជញ្ជូនដែលមាននិរន្តរភាព (៣) ពង្រឹងសម្រួបការបូនតាមរយៈការប្រើប្រាស់ដីធ្លី ដែលមាននិរន្តរភាពព្រៃឈើ និងកសិកម្ម (៤) លើកកម្ពស់ការអភិវឌ្ឍដែលធន់ទ្រាំនឹងអាកាសធាតុ និង (៥) ការពង្រឹងស្ថាប័នអភិបាលកិច្ច គោលនយោបាយ និងសមត្ថភាព ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ។ ធនាគារអភិវឌ្ឍន៍អាស៊ីផ្តល់ការគាំទ្ររបស់ខ្លួនដល់កម្ពុជានៅក្នុងវិស័យទាំងប្រាំនេះ។

រាជរដ្ឋាភិបាលកម្ពុជា បានអះអាងអំពីការប្តេជ្ញារបស់ខ្លួន ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ដោយផ្តល់សច្ចាប័នលើអនុសញ្ញាក្របខណ្ឌសហប្រជាជាតិ (UNFCCC) នៅឆ្នាំ១៩៩៥ និងចូលជាសមាជិកនៃពិធីសារក្យូតូនៅឆ្នាំ២០០២។ រដ្ឋាភិបាលបានរៀបចំកម្មវិធីសកម្មភាពជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ (NAPA) នៅចុងឆ្នាំ២០០៦។ NAPA និងរបាយការណ៍ជាតិលើកទីពីរសម្រាប់ UNFCCC ដែលបានបង្ហាញជូនពីថ្ងៃម្សិលមិញនេះ មានការបន្សុីគ្នាយ៉ាងជិតស្និទ្ធជាមួយគោលបំណងអភិវឌ្ឍន៍របស់កម្ពុជា ដែលមានចែងនៅក្នុង "យុទ្ធសាស្ត្រចតុកោណ ដើម្បីការរីកចម្រើន ការងារសមធម៌ និងប្រសិទ្ធភាព" ដែលបានអនុម័តនៅខែកក្កដាឆ្នាំ២០០៤ និងបានធ្វើបច្ចុប្បន្នភាពជំហានទី២ នៅខែកក្កដា ឆ្នាំ២០០៩។

លោក លោកស្រី ជាទីមេត្រី! អភិក្រមជាក់លាក់របស់ធនាគារអភិវឌ្ឍន៍អាស៊ីទាក់ទងនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា ឆ្លុះបញ្ចាំងយ៉ាងច្បាស់នៅក្នុងយុទ្ធសាស្ត្រភាព ដៃគូនៅក្នុងប្រទេសសម្រាប់ឆ្នាំ២០១១-២០១៣ ដែលបានរៀបរៀងឡើងក្រោមការពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ ជាមួយរាជរដ្ឋាភិបាលកម្ពុជា និងស្របជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្មឆ្នាំ២០០៩-២០១៣ និងដែលបានគាំទ្រដោយក្រុមប្រឹក្សាភិបាលនៃធនាគារអភិវឌ្ឍន៍អាស៊ីនៅថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១១។ យុទ្ធសាស្ត្រដៃគូប្រចាំប្រទេសកម្ពុជាចាត់ទុកបរិស្ថាន និងការប្រែប្រួលអាកាសធាតុ ថាជាការប្រឈមអន្តរវិស័យដ៏សំខាន់មួយសម្រាប់កម្ពុជា។ នៅកម្ពុជា ធនាគារអភិវឌ្ឍន៍អាស៊ីនឹង៖ (១) បញ្ជ្រាបការប្រឈមនានានៃការប្រែប្រួលអាកាសធាតុទៅក្នុងការវិភាគវិស័យ និងការកសាងផែនការ និងការបង្កើតគម្រោង (២) បន្តបង្កើតអភិក្រមល្អជាងមុនសម្រាប់ការអភិរក្សធនធាន នៅក្នុងអាងបឹងទន្លេសាប (៣) សម្របសម្រួលកម្មវិធីនៅថ្នាក់ជាតិ និងអនុតំបន់អំពីការប្រែប្រួលអាកាសធាតុ និងបរិស្ថាន និង (៤) ស្វែងរកហិរញ្ញវត្ថុពីប្រភពខាងក្នុង និងខាងក្រៅ ដើម្បីគាំទ្រដល់សកម្មភាពប្រែប្រួលអាកាសធាតុនៅក្នុងគម្រោងថ្មីៗ និងដែលមានស្រាប់។

ដូចដែលយើងបានឮពីម្សិលមិញ កម្មវិធីចម្បងពីរ ស្តីពីការប្រែប្រួលអាកាសធាតុ កំពុងអនុវត្តនៅកម្ពុជា៖ សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA) ដែលទទួលមូលនិធីពី EU UNDP DANIDA និង SIDA ដែលមានទឹកប្រាក់៨,៩លានដុល្លា និងកម្មវិធីសាកល្បងសម្រាប់ភាពធន់ទ្រាំនឹងអាកាសធាតុ (PPCR) ដែលទទួលថវិកា តាមរយៈមូលនិធិវិនិយោគអាកាសធាតុ ប្រមាណ

៨៧,៥លានដុល្លា។ កម្មវិធីទាំងពីរនេះជួយរដ្ឋាភិបាលដើម្បី (១) កសាងគោលនយោបាយប្រែប្រួលអាកាសធាតុសមស្រប (២) បញ្ជ្រាបកង្វល់អំពីការប្រែប្រួលអាកាសធាតុទៅក្នុងការអភិវឌ្ឍ ដែលរួមទាំងការលើកគម្រោងថវិកាសម្រាប់អន្តរាគមន៍លើការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ (៣) ធ្វើឲ្យសង្គមស៊ីវិល និងវិស័យឯកជនចូលរួមយ៉ាងសកម្មនៅក្នុង ការដោះស្រាយការប្រែប្រួលអាកាសធាតុនិង (៤) កសាងសមត្ថភាពស្ថាប័នសម្រាប់ការកសាងផែនការបន្សាំ ដោយផ្អែកលើវិទ្យាសាស្ត្រ។

កម្មវិធី PPCR កំពុងអនុវត្តជាពីរដំណាក់កាល៖ ដំណាក់កាលទីមួយគឺ ជំនួយឥតសំណងសម្រាប់ការត្រៀមរៀបចំ ដែលមានទឹកប្រាក់ ១,៥លានដុល្លា និងអនុវត្តដោយធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និង IFC ។ ដំណាក់កាលទី២ មានគោលដៅសម្រេចឲ្យបាននូវការកែទម្រង់ស៊ីជម្រៅលើការបញ្ជ្រាបហានិភ័យនៃការប្រែប្រួលអាកាសធាតុ និងភាពធន់ទ្រាំនៅក្នុងការកសាងផែនការអភិវឌ្ឍ។ ដំណាក់កាលនេះរួមមាន ការអនុវត្តគម្រោងចំនួន៨ លើផ្នែកកសិកម្ម ធនធានទឹក និងវិស័យហេដ្ឋារចនាសម្ព័ន្ធ ដែលមានថវិកាសរុប ៨៦លានដុល្លាអាមេរិក (ជំនួយឥតសំណងចំនួន ៥០លានដុល្លាអាមេរិក និង៣៦លានដុល្លាអាមេរិកជាកំចីអនុគ្រោះបំផុត) ពី CIF និងថវិកាបដិភាគបន្ថែមជិត៣០០លានដុល្លាពីធនាគារអភិវឌ្ឍន៍អាស៊ី។

ធនាគារអភិវឌ្ឍន៍អាស៊ីបាន និងកំពុងគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា នៅក្នុងវិស័យផ្សេងទៀតផងដែរ ដោយផ្តល់អត្ថប្រយោជន៍យ៉ាងច្រើនខាងផ្នែកអាកាសធាតុ និងការអភិវឌ្ឍ។ គម្រោងទាំងនេះរួមបញ្ចូលថាមពលកកើតឡើងវិញ និងប្រសិទ្ធភាពថាមពល ប្រព័ន្ធដឹកជញ្ជូនសាធារណៈដែលមាននិរន្តរភាព ដូចជា ផ្លូវដែក ការអភិវឌ្ឍទីក្រុង ដែលសមស្របនឹងអាកាសធាតុ ដូចជាបាត់ដំបងតាមរយៈការគ្រប់គ្រងសំណល់រឹង និងបង្កើនសម្ភូបកាបូន និងការអភិរក្សជីវចម្រុះនៅក្នុងខេត្តនានា និងដូចជា កោះកុងនិងមណ្ឌលគិរី។

លោក លោកស្រីជាទីមេត្រី! ខ្ញុំមានជំនឿមុតមាំថា វេទិកានេះនឹងផ្តល់ឱកាសដោយឡែកមួយដើម្បីផ្លាស់ប្តូរចំណេះដឹង ជំនាញ ព័ត៌មាន និងបទពិសោធន៍ដ៏មានប្រយោជន៍ តាមវិធីនានា ដើម្បីដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា ដែលទាក់ទងនឹងការបន្សាំការកាត់បន្ថយ ការអភិវឌ្ឍ និងផ្ទេរបច្ចេកវិទ្យា ការកសាងសមត្ថភាព និងហិរញ្ញប្បទាន។ ខ្ញុំសង្ឃឹមផងដែរថា វេទិកានេះនឹងជួយកៀរគរ និងពង្រឹងការគាំទ្របន្ថែមពីដៃគូអភិវឌ្ឍន៍នានា ដែលបានចូលរួមទីនេះនៅក្នុងថ្ងៃនេះ។

ខ្ញុំសូមថ្លែងអំណរគុណដល់លោក-លោកស្រី ទាំងអស់ដែលបានចូលរួម និងសូមជូនពរឲ្យមានការពិភាក្សាដោយជោគជ័យ។

សុន្ទរកថាស្វាគមន៍ថ្ងៃទី០២

*របស់ឯកឧត្តម **ស៊ុយ សែម** រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម‌រ៉ែ និង ថាមពល*

សូមគោរព:

- គណៈអធិបតី
- លោក Peter J. Brimble តំណាងធនាគារអភិវឌ្ឍន៍អាស៊ី
- ឯកឧត្តម លោកជំទាវ សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ
- ឯកឧត្តមលោកជំទាវ លោក លោកស្រី តំណាងស្ថានទូតប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងវិស័យឯកជន ជាទីគោរព
- លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិ នៃវេទិកាជាតិទាំងមូលជាទីមេត្រី!

ថ្ងៃនេះខ្ញុំមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែង ដោយបានមកចូលរួមក្នុងវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុដ៏អធឹកអធមនេះ។ តាងនាមឲ្យក្រសួងឧស្សាហកម្ម‌រ៉ែ និងថាមពល និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅបំផុតចំពោះ វត្តមានរបស់ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ដែលបានផ្លៀតពេលដ៏មមាញឹក អញ្ជើញមកចូលរួមក្នុងវេទិកាជាតិលើកទី២ដ៏មានសារសំខាន់នាថ្ងៃនេះ។

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា!

ការប្រែប្រួលអាកាសធាតុ បាននឹងកំពុងតែក្លាយជាការគម្រាមកំហែងមួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម និងអាចបណ្តាលឲ្យមានផលប៉ះពាល់ជាអវិជ្ជមានដល់កិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រទេសជាតិ។ ប្រធានបទនៃការគ្រប់គ្រងការប្រែប្រួលអាកាសធាតុកាន់តែមានសារសំខាន់ និងឆ្លើយតបទៅនឹងតម្រូវការរបស់ពិភពលោកបច្ចុប្បន្ន។ ស្ថានភាពគ្រោះធម្មជាតិដូចជា គ្រោះទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី បានកើតមានជាបន្តបន្ទាប់ក្នុងប្រទេសជាច្រើននៅលើពិភពលោក ដែលទាមទារឲ្យពិភពលោកទាំងមូលរួមដៃគ្នាដើម្បីមានវិធានការសមស្រប ក្នុងការកាត់បន្ថយដល់ការប្រែប្រួលអាកាសធាតុ។

រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់ សម្តេចអគ្គមហាសេនាបតីតេជោ ***ហ៊ុន សែន*** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានកិត្តិយសនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុកម្ពុជា បានយល់យ៉ាងច្បាស់អំពីបញ្ហានេះ ហើយ**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់នៅក្នុងពិធីបើកវេទិកាជាតិលើកទី១ ស្តីពីការប្រែប្រួលអាកាសធាតុនាឆ្នាំ២០០៩កន្លងមកនេះថា៖ ប្រធានបទ "ការប្រែប្រួលអាកាសធាតុ" បានលេចឡើងជាកត្តាដែលមិនអាចមើលរំលងបានឡើយនៅក្នុងរបៀបវារៈនៃការអភិវឌ្ឍជាតិ។

យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី២ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិបច្ចុប្បន្នកម្ម ២០០៩-២០១៣ បានចែងយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការឆ្លើយតបទៅនឹង

បញ្ហាប្រែប្រួលអាកាសធាតុ តាមរយៈវិធានការបន្សាំ និងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ក្នុងន័យនេះ កម្ពុជាបាន និងកំពុងអនុវត្តការងារសំខាន់ៗជាច្រើនពាក់ព័ន្ធនឹងការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេសជាតិ ជាពិសេសសមត្ថភាពរបស់គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបការងារប្រែប្រួលអាកាសធាតុទៅក្នុងផែនការជាតិ និងផែនការតាមវិស័យនានា។

ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា!

បើពិនិត្យលើវិស័យថាមពលអគ្គិសនីនៅប្រទេសកម្ពុជាយើង ដូចអង្គវេទិកាទាំងមូលបានជ្រាបហើយថា ថាមពលអគ្គិសនី គឺជាវិស័យអាទិភាពមួយ ដែលត្រូវបានទទួលការយកចិត្តទុកដាក់ពីរាជរដ្ឋាភិបាល ដើម្បីធានាដល់ការផលិតការផ្គត់ផ្គង់ ការប្រើប្រាស់ និងការគ្រប់គ្រងថាមពលអគ្គិសនី ធ្វើយ៉ាងណាឲ្យមានគុណភាព ប្រសិទ្ធភាព ចីរភាព និងតម្លាភាព។ ការជំរុញការលើកទឹកចិត្ត និងការអភិវឌ្ឍវិស័យនេះ គឺជាកូនសោរដ៏សំខាន់មួយ ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ហើយថាមពលអគ្គិសនីមិនមែនត្រូវការចាំបាច់ចំពោះតែវិស័យឧស្សាហកម្ម សិប្បកម្ម ពាណិជ្ជកម្ម កសិកម្ម និងអាជីវកម្មនានាប៉ុណ្ណោះទេ ប៉ុន្តែមានសារៈប្រយោជន៍ដ៏ធំធេងសម្រាប់ផ្តល់ជូនប្រជាជនគ្រប់រូបប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃទៀតផង។ ដូចនេះរាជរដ្ឋាភិបាលកម្ពុជាកំពុងយកចិត្តទុកដាក់ក្នុងការអភិវឌ្ឍវិស័យថាមពលអគ្គិសនី ដោយធ្វើយ៉ាងណាឲ្យមានផលប៉ះពាល់ដល់ការប្រែប្រួលអាកាសធាតុតិចបំផុតតាមដែលអាចធ្វើបាន។

ក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ និងជាសមាជិកនៃពិធីសារក្យូតូ កម្ពុជាពុំមានជាប់កាតព្វកិច្ចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ឡើយ។ ក៏ប៉ុន្តែ កន្លងមកកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តន៍បណ្តាគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។ ជាក់ស្តែង យើងបានជំរុញការប្រើប្រាស់ពីប្រភព និងធនធានថាមពលកកើតឡើងវិញ ដើម្បីបម្លែងថាមពលធម្មជាតិប្រភេទនេះឲ្យទៅជាថាមពលអគ្គិសនី ដែលយកមកប្រើប្រាស់ជំនួសការប្រើប្រាស់ប្រេងជាបណ្តើរៗ និងជាប្រយោជន៍ជម្រុញការលើកទឹកចិត្តដល់ការអភិវឌ្ឍបច្ចេកវិទ្យាថាមពលស្អាត និងជួយកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់។

តាមរយៈក្រសួងបរិស្ថាន ដែលជាស្ថាប័នជាតិទទួលបន្ទុកយន្តការអភិវឌ្ឍស្អាត កម្ពុជាបានអនុម័តគម្រោងយន្តការអភិវឌ្ឍស្អាតចំនួន៧ក្នុងវិស័យថាមពលកកើតឡើងវិញ ដែលជាគម្រោងវិនិយោគផ្នែកឯកជនអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ប្រមាណ ៥៧០ ពាន់តោន ក្នុងមួយឆ្នាំ ក្នុងពេលអនាគតនឹងមានគម្រោងជាច្រើនទៀតនឹងត្រូវអនុម័តជាគម្រោងយន្តការអភិវឌ្ឍស្អាត។

តាមរយៈយន្តការអភិវឌ្ឍស្អាត ដែលជាយន្តការមួយក្នុងចំណោមយន្តការទាំងបី នៃពិធីសារក្យូតូ ប្រទេសកំពុងអភិវឌ្ឍន៍អាចសហការជាមួយប្រទេសអភិវឌ្ឍន៍ ដើម្បីអនុវត្តបណ្តាគម្រោង ដែលអាចកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ហើយជាមួយគ្នានោះនឹងជួយជំរុញការអភិវឌ្ឍន៍ ដោយចីរភាពនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ទាំងនេះ។ ដំណោះស្រាយ ឈ្នះ-ឈ្នះបែបនេះ មានសារសំខាន់ណាស់ សម្រាប់បណ្តាប្រទេស ដូចជាកម្ពុជា ដែលត្រូវការវិនិយោគទុនបរទេស នៅក្នុងវិស័យបច្ចេកវិទ្យាសមស្រប ស្អាត និងមិនបំផ្លាញបរិស្ថាន ជាពិសេស ជម្រើសនៃការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅក្នុងវិស័យអាទិភាពមួយចំនួនដូចជា៖ វិស័យថាមពល ដឹកជញ្ជូន និងកសិកម្ម។

ការយល់ដឹងច្បាស់ ពីជម្រើសសម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ក្នុងវិស័យសំខាន់ៗទាំងនេះរបស់កម្ពុជានាពេលបច្ចុប្បន្ន និងទៅអនាគត គឺជាលក្ខខណ្ឌចាំបាច់សម្រាប់កំណត់ និងអនុវត្តគម្រោងកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ដោយស្ម័គ្រចិត្ត សំដៅរួមគ្នាទប់ស្កាត់ និងដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដែលកាន់តែមានភាពធ្ងន់ធ្ងរទៅៗជាលំដាប់។ ប្រការនេះត្រូវឲ្យមានការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រច្បាស់លាស់ និងប្រកបដោយភាពជាក់លាក់ខ្ពស់ស្តីពីជម្រើសជាសក្តានុពលនានា សម្រាប់កាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់នៅកម្ពុជា។ យ៉ាងណាមិញ យើងចាំបាច់ត្រូវចងចាំថា៖ បណ្តាជម្រើសក្នុងការកាត់បន្ថយការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ទាំងនោះត្រូវតែអាចទទួលយកបាន ទាំងផ្នែកសង្គម នយោបាយ មិនបំផ្លាញបរិស្ថាន និងមានប្រសិទ្ធិភាពសេដ្ឋកិច្ច។

អគ្គទេពិកាទាំងមូលជាទីមេត្រី!

វេទិកាជាតិលើកទី២ស្តីពីការប្រែប្រួលអាកាសធាតុនាថ្ងៃទីពីរនេះ នឹងធ្វើការពិភាក្សាផ្លាស់ប្តូរយោបល់និង អនុសាសន៍ពាក់ព័ន្ធនឹងប្រធានបទនៃការប្រែប្រួលអាកាសធាតុសំខាន់ៗដូចជា៖

1) ការអភិវឌ្ឍបៃតងនិង ទស្សន:ទានទាក់ទងនឹងការប្រែប្រួលអាកាសធាតុ
2) ទីផ្សារថាមពលកកើតឡើងវិញក្នុងប្រទេសកម្ពុជា
3) ស្ថានភាពនៃការអភិវឌ្ឍផែនការសកម្មភាពថ្នាក់ជាតិ សម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
4) គំនិតផ្តួចផ្តើមក្នុងការបន្សាំនឹងការប្រែប្រួលអាកាសធាតុរបស់គណៈកម្មាធិការជាតិទន្លេមេគង្គ
5) បទពិសោធន៍ថ្នាក់តំបន់ និងអន្តរជាតិក្នុងការអនុវត្តន៍សកម្មភាពបន្សាំ ប្រកបដោយប្រសិទ្ធភាព
6) គោលនយោបាយឥណទានកាបូន និងការសម្របសម្រួលប្រសិទ្ធភាពនៃជំនួយ
7) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុនាពេលអតីតកាលលើជីវចម្រុះ និងវិធានការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុលើជីវចម្រុះ
8) ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបតាមទស្សន:វិស័យរបស់យេនឌ័រ

ខ្ញុំសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញា ជាតំណាងក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធទាំងអស់ ដែលមានវត្តមានក្នុងវេទិកាថ្ងៃនេះ នឹងចូលរួមយ៉ាងសកម្មក្នុងការពិភាក្សាពិគ្រោះយោបល់ និងផ្តល់អនុសាសន៍ល្អៗក្នុងការរួមចំណែកគ្រប់គ្រងការប្រែប្រួលអាកាសធាតុប្រកបដោយជោគជ័យ និងសម្រេចបានផ្លែផ្កា។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញាទាំងអស់សូមបានប្រកបដោយ៖ សុខភាពល្អបរិបូរណ៌ អាយុយឺនយូរ កំលាំងខ្លាំងក្លា ប្រាជ្ញាឈ្លាសវៃ និងសម្រេចកិច្ចការអ្វីៗទទួលជោគជ័យគ្រប់ប្រការ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមជូនពរឲ្យវេទិកាជាតិលើកទី២នាថ្ងៃនេះប្រព្រឹត្តទៅដោយជោគជ័យ។

សូមអរគុណ!!

សុន្ទរកថាស្វាគមន៍ថ្ងៃទី០៣

របស់លោក Rafael Dochao Moreno ភារៈធារីនៃប្រតិភូសហភាពអឺរ៉ុបប្រចាំនៅកម្ពុជា

- ឯកឧត្តម លោកជំទាវ
- ភ្ញៀវជាតិ និងអន្តរជាតិ
- លោកស្រី អស់លោក ជាទីមេត្រី

តាងនាមប្រតិភូសហភាពអឺរ៉ុបប្រចាំប្រទេសកម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយ ក្នុងការថ្លែងសុន្ទរកថាស្វាគមន៍ នៅថ្ងៃបញ្ចប់នៃវេទិកាជាតិស្តីពីការប្រែប្រួលអាកាសធាតុលើកទី ២។ នៅក្នុងរយៈពេល ២ ថ្ងៃចុងក្រោយនេះ វេទិកាជាតិស្តីពីការប្រែប្រួលអាកាសធាតុនេះ គឺជាកាលានុវត្តភាពដ៏វិសេសវិសាលមួយ សម្រាប់ឲ្យអ្នកជំនាញការផ្នែកការប្រែប្រួលអាកាសធាតុ និងអ្នកតាក់តែងគោលនយោបាយនានាធ្វើការពិភាក្សាគ្នា ក៏ដូចជាចែករម្លែកព័ត៌មានអំពីការបន្សាំ និងការកាត់បន្ថយលើការប្រែប្រួលអាកាសធាតុ។ ការផ្តោតជាសំខាន់នៅថ្ងៃនេះគឺលើគោលនយោបាយ និងការចរចាជាអន្តរជាតិ។ ដូចដែលឯកឧត្តម លោកជំទាវ អស់លោក លោកស្រីទាំងអស់គ្នាបានជ្រាបហើយ សហភាពអឺរ៉ុបបាន និងកំពុងបំពេញតួនាទី ជាកម្លាំងចលករដ៏សំខាន់មួយនៅក្នុងកិច្ចចរចាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុនានា ដែលនាំទៅដល់ការបង្កើតឲ្យមាន កិច្ចព្រមព្រៀងស្តីពីសន្ធិសញ្ញាស្តីពីអាកាសធាតុរបស់សហប្រជាជាតិចំនួន២នោះគឺ អនុសញ្ញាក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុ (UNFCCC) នៅក្នុងឆ្នាំ១៩៩២ និងពិធីសារក្យូតូនៅក្នុងឆ្នាំ១៩៩៧។

សហភាពអឺរ៉ុប គឺជាអ្នកនាំមុខគេក្នុងពិភពលោកលើសកម្មភាព ដែលពាក់ព័ន្ធនឹងអាកាសធាតុ។ យើងកំពុងសម្រេចទៅតាមផែនការ ដើម្បីសម្រេចឲ្យបានតាមចំណុចដៅក្រុងក្យូតូរបស់យើង។ យើងបានប្រែក្លាយការប្តេជ្ញាចិត្ត២០% របស់យើងឲ្យក្លាយទៅជាច្បាប់។ យើងមានឆន្ទៈបង្កើនចំណុចដៅរបស់យើងដល់៣០% ហើយនេះអាចជាផ្នែកមួយនៃរយៈពេលនៃការប្តេជ្ញាចិត្តលើកទី២ក្រោមពិធីសារក្យូតូ។ យើងមានការប្តេជ្ញាចិត្ត ដើម្បីសម្រេចឲ្យបាននូវចំណុចដៅរយៈពេលវែងពោលគឺកាត់បន្ថយការបំភាយឧស្ម័ននៅក្នុងសហភាពអឺរ៉ុបឲ្យបានពី៨០ទៅ៩៥%នៅមុនឆ្នាំ២០៥០។ សហភាពអឺរ៉ុបកំពុងត្រួសត្រាយផ្លូវ ដែលលើកទឹកចិត្តប្រទេសផ្សេងទៀតឲ្យចូលរួមជាមួយខ្លួន។

មនុស្សមួយចំនួនប្រហែលជាមានការងឿងឆ្ងល់ថា តើមានកត្តាអ្វីខ្លះដែលជំរុញឲ្យសហភាពអឺរ៉ុបធ្វើសកម្មភាពស្មគ្រ័ចិត្តទាំងនេះ បើទោះបីជាមិនទាន់មានកិច្ចព្រមព្រៀងជាសកលថ្មីនៅឡើយក៏ដោយ។ ជាការពិត ចម្លើយគឺសាមញ្ញបំផុត៖ សកម្មភាពទប់ទល់នឹងការប្រែប្រួលអាកាសធាតុគឺដើម្បីប្រយោជន៍ផ្ទាល់ខ្លួនរបស់យើងទាំងអស់គ្នា។ អន្តរកាលទៅរកសេដ្ឋកិច្ច ដែលបញ្ចេញកាបូនទាប ត្រូវបានកំណត់យ៉ាងជាក់ច្បាស់ ថាជាកម្លាំងចលករដ៏សំខាន់មួយនៃកំណើនបៃតង ដូចជានៅក្នុងកញ្ចប់សង្គ្រោះក្រោយវិបត្តិជាដើម។ ក្រៅពីការបញ្ចៀសគ្រោះថ្នាក់បង្កឡើងដោយ ការប្រែប្រួលអាកាសធាតុ អត្ថប្រយោជន៍សម្រាប់សហភាពអឺរ៉ុប រួមមាន ការសន្សំសំចៃ ការប្រើប្រាស់ថាមពល សន្តិសុខថាមពល ការងារថ្មីៗ ភាពប្រកួតប្រជែងជាអន្តរជាតិ គុណភាពខ្យល់ និងសុខភាព។

ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាទីមេត្រី!

ខ្ញុំសូមត្រឡប់មករកប្រធានបទសម្រាប់ការពិភាក្សាក្នុងវេទិកានៅថ្ងៃនេះវិញ នោះគឺកិច្ចចរចាអន្តរជាតិស្តីពីការប្រែប្រួលអាកាសធាតុ។ ក្នុងខែធ្នូ ឆ្នាំ២០១០កិច្ចព្រមព្រៀងកាន់គុន គឺជាជោគជ័យមួយនៃការប្រយុទ្ធជាសកលទៅនឹងការប្រែប្រួលអាកាសធាតុ។ កិច្ចព្រមព្រៀងទាំងនេះ ដាក់ដំណើរការពហុភាគីស្តីពីអាកាសធាតុមករកផ្លូវដើមវិញ ហើយបញ្ជាក់ប្រាប់យើងទាំងអស់គ្នាថា សហគមន៍អន្តរជាតិពិតជាចង់ធ្វើសកម្មភាពពិតប្រាកដមែន។ កិច្ចព្រមព្រៀងទាំងនេះមានគោលដៅរួមមួយនោះគឺ ការរក្សាកំណើនសីតុណ្ហភាពឲ្យនៅក្រោម ២អង្សាសេ បើធៀបជាមួយនឹងកម្រិតមុនឧស្សាហកម្ម។ ដំណើរការថ្មីៗជាច្រើនត្រូវបានបង្កើតឡើងដើម្បីរួមចំណែកសម្រេចគោលដៅនេះ។

ឥឡូវនេះ កិច្ចប្រជុំនៅទីក្រុងឌូបាន ដែលជាចំណុចដៅបន្ទាប់ គឺកៀកនឹងមកដល់ហើយ (ថ្ងៃ២៨ ខែវិច្ឆិកា - ខែ៩ធ្នូ ឆ្នាំ២០១១)។ សហភាពអឺរ៉ុបជឿថា កិច្ចប្រជុំនៅឌូបាន គឺជាកាលានុវត្តភាពដ៏សំខាន់មួយ ដើម្បីសម្រេចបាននូវវឌ្ឍនភាពការងាររបស់យើង នៅក្នុងការដាក់ចេញនូវវិធានការពហុភាគី ដើម្បីទប់ទល់នឹងបម្រែបម្រួលអាកាសធាតុ។ ជាអកុសល ឌូបាននឹងមិនមែនជាកំណាត់ផ្លូវចុងក្រោយនោះឡើយ ប៉ុន្តែ យើងជឿជាក់ថា ការចរចានៅដំណាក់កាលនេះនឹងនាំឲ្យយើងទៅមុខមួយជំហានទៀត តាមរយៈការអនុវត្តទៅតាមការសម្រេចចិត្តក្នុងទីក្រុងកាន់គុន និងឆ្លើយតបទៅនឹងបញ្ហានានាដែលមិនទាន់បានដោះស្រាយនៅកាន់គុន ដូចជា៖

- ទីមួយ ទម្រង់ច្បាប់នៃរបបបម្រែបម្រួលអាកាសធាតុ ជាសកលនាពេលអនាគត គឺជាសំណួរដ៏សំខាន់មួយ និងជាចំណុចសកម្មភាពសម្រាប់ឌូបាន ដោយសាររបបអាកាសធាតុនាពេលបច្ចុប្បន្ននេះ នៅមិនទាន់មានភាពគ្រប់គ្រាន់នៅឡើយ។ យើងទាំងអស់គ្នាបានដឹងហើយថា ចំណុចដៅនៃពិធីសារក្យូតូនឹងបញ្ចប់ក្នុងឆ្នាំ២០១២ ដែលកៀកនឹងមកដល់នាពេលខាងមុខនេះ ដែលពិធីសារនេះ គ្របដណ្តប់លើការបំភាយឧស្ម័នតិចជាង៣0% - ហើយសហរដ្ឋអាមេរិច ចិន និងឥណ្ឌា មិនទាន់បានចូលរួមឡើយ។ គោលដៅចម្បងនៃសហភាពអឺរ៉ុប នៅជាក្របខណ្ឌប្រកបដោយមហិច្ឆតា មានភាពគ្រប់ជ្រុងជ្រោយ និងចងកាតព្វកិច្ចតាមផ្លូវច្បាប់ដោយគ្របដណ្តប់ដោយគ្រប់ភាគីទាំងអស់។ នេះគឺជាការធានាល្អបំផុតសម្រាប់ភាពប្រាកដប្រជាផ្នែកផ្លូវច្បាប់ និងភាពអាចព្យាករជាមុនបាន ការពឹងអាស្រ័យគ្នាទៅវិញទៅមករវាងប្រទេស និងប្រទេស និងជាសញ្ញានយោបាយដ៏ខ្លាំងក្លាមួយ ដែលបង្ហាញពីឆន្ទៈក្នុងការអនុវត្តសកម្មភាព។ សំណួរនេះត្រូវបានលើកយកមកពិភាក្សានៅកាន់គុន ប៉ុន្តែមិនទាន់បានបើកចំហនៅឡើយ។ សំណួរនេះនឹងត្រូវលើកយកមកពិភាក្សានៅឌូបានជាថ្មីម្តងទៀត។

- ទីពីរ តួនាទីនាពេលអនាគតរបស់ពិធីសារក្យូតូ គឺគ្រាន់តែជាផ្នែកមួយនៃការជជែកវែកញែកនេះតែប៉ុណ្ណោះ។ សហភាពអឺរ៉ុបបានភ្ជាប់ខ្លួនជាមួយនឹងប្រព័ន្ធទ្វេភាគីផ្នែកតាមវិធានត្រឹមត្រូវនោះគឺ ពិធីសារក្យូតូ ហើយយើងនៅតែទទួចឲ្យមានការរក្សា និងកែលម្អសមាសភាគសំខាន់ៗនៃពិធីសារក្យូតូនេះ សម្រាប់របបនាពេលអនាគតដូចជា តាមរយៈការពង្រីក និងការបន្តអភិវឌ្ឍន៍ការក្យូតូជាដើម និងតាមរយៈការយកវិធានរាយការណ៍របស់ក្យូតូមកដាក់ក្នុងការជជែកវែកញែកទូលំទូលាយរបស់យើងស្តីពី MRV (ការវាស់វែង ការរាយការណ៍ និងការផ្ទៀងផ្ទាត់) បន្ទាប់ពីកិច្ចព្រមព្រៀងកាន់គុន។ តែទោះជាយ៉ាងណាក្តី ក្យូតូទី២ ជាមួយនឹងសហភាពអឺរ៉ុប(ស្ទើរតែ) តែឯងអាចគ្របដណ្តប់លើការបំភាយឧស្ម័ន ជាសកលបានត្រឹមតែ

១១% តែប៉ុណ្ណោះ។ នេះមិនអាចចាត់ទុកថាជា "ជោគជ័យ" នៅក្នុងទីក្រុង Durban បាននោះទេ។ តើមានអ្វីកើតឡើងចំពោះការបំភាយឧស្ម័នក្នុងពិភពលោក៨៩% ទៀត?

នៅក្នុងបរិបទនេះ សហភាពអឺរ៉ុបបានគូសបញ្ជាក់សារជាថ្មីនូវគោលជំហររបស់ខ្លួន៖ សហភាពអឺរ៉ុបមានឆន្ទៈធ្វើការពិចារណាលើរយៈពេលក្បួតទី២ ប៉ុន្តែយើងគួរឯកភាពក្នុងខ្លួនបាន អំពីផែនទីបង្ហាញផ្លូវ និងក្របខណ្ឌពេលវេលាច្បាស់លាស់មួយ សំដៅសម្រេចឲ្យបាននូវក្របខណ្ឌគ្រប់ជ្រុងជ្រោយ និងរឹងមាំ និងចងកាតព្វកិច្ចតាមផ្លូវច្បាប់ ដោយមានការចូលរួមពីប្រទេសដែលបញ្ចេញឧស្ម័នច្រើនជាងគេទាំងអស់។ នេះគួរប្រើប្រាស់រចនាសម្ព័ន្ធក្បួតូ ជាមួយនឹងការកែលម្អបន្ថែមទៀត ជាមួយនឹងវិធានដែលនឹងឯកភាពនៅខ្លួនបាន។

ឯកឧត្តម លោកជំទាវ លោកស្រី អស់លោក ជាទីមេត្រី!

យើងទាំងអស់គ្នាដឹងថា ការរួមចំណែករបស់ប្រទេសកម្ពុជា ចំពោះការបំភាយឧស្ម័នផ្ទះកញ្ចក់នៅតិចតួចប៉ុណ្ណោះ ប៉ុន្តែកំពុងមានការកើនឡើង តែទោះជាយ៉ាងនេះក្តី កិច្ចចរចាជាអន្តរជាតិនៅតែមានសារសំខាន់យ៉ាងខ្លាំងសម្រាប់ ប្រទេសកម្ពុជា ដោយសារតែកិច្ចព្រមព្រៀងទាំងនោះនឹងកំណត់នូវរបបបម្រែបម្រួលអាកាសធាតុអន្តរជាតិនាពេលអនាគត និងយ៉ាងហោចណាស់ ចំពោះការផ្តល់ហិរញ្ញប្បទានដល់ការងារប្រែប្រួលអាកាសធាតុ មួយផ្នែកណាមួយនាពេលអនាគត។ អ្វីដែលសំខាន់សម្រាប់ប្រទេសកម្ពុជា មានដូចជា ការអនុវត្តមូលនិធិអាកាសធាតុបៃតងថ្មី និងការគាំទ្រដែលមូលនិធិអាកាសធាតុបៃតងនេះនឹងផ្តល់ដល់ប្រទេសកម្ពុជា ជាពិសេស មូលបទសំខាន់ៗនៃសកម្មភាពអាកាសធាតុ ដូចជា ការបន្សាំ REDD+ និងការកាត់បន្ថយជាដើម។

តាមពិតទៅ ក្រុមសហភាពអឺរ៉ុប បានចាប់ផ្តើមរួចទៅហើយនៅក្នុងការផ្តល់មូលនិធិដ៏ច្រើនដល់ប្រទេសកម្ពុជា ដើម្បីឆ្លើយតបទៅនឹងបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ តាមរយៈការប្រមូលផ្តុំធនធានរបស់ខ្លួន ក្នុងគំនិតផ្តួចផ្តើមបម្រែបម្រួលអាកាសធាតុធំៗជាងគេចំនួន២ នៅក្នុងប្រទេសកម្ពុជា៖ "សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (ដាណឺម៉ាក គណៈកម្មការសហគមន៍អឺរ៉ុប និងស៊ុយអែត) និង "កម្មវិធីសាកល្បងភាពធន់ទៅនឹងអាកាសធាតុ" (ដាណឺម៉ាក អាល្លឺម៉ង់ អេស្ប៉ាញ និងចក្រភពអង់គ្លេស)។ គំនិតផ្តួចផ្តើមសំខាន់ៗទាំងពីរនេះ ត្រូវបានបង្ហាញរួចហើយនៅក្នុងរយៈពេល ២ ថ្ងៃដំបូងនៃវេទិកានេះ ដូច្នេះខ្ញុំសូមមិនលើកឡើងម្តងទៀតឡើយ។

ប៉ុន្តែអ្វីដែលខ្ញុំសូមលើកឡើងគឺ បើតាម "កិច្ចពិគ្រោះយោបល់ជាយុទ្ធសាស្ត្រស្តីពីការកាត់បន្ថយហានិភ័យនៃគ្រោះមហន្តរាយ និងការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ" ដែលបានរៀបចំឡើងកាលពីពេលថ្មីៗនេះ ដោយប្រតិភូសហភាពអឺរ៉ុប បញ្ហាប្រឈម និងកាលានុវត្តភាពសំខាន់សម្រាប់ប្រទេសកម្ពុជា គឺអាស្រ័យលើការកសាងស្ពានភ្ជាប់ រវាងកិច្ចខិតខំប្រឹងប្រែងគ្រប់គ្រងហានិភ័យនៃគ្រោះមហន្តរាយ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែង ដើម្បីលើកកម្ពស់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ចាំបាច់ត្រូវមានការស្វែងយល់ឲ្យបានប្រសើរអំពីវិសាលភាព ដែលការគ្រប់គ្រងគ្រោះមហន្តរាយនាពេលបច្ចុប្បន្ននេះ បានឆ្លុះបញ្ចាំងពីតម្រូវការបន្សាំនាពេលអនាគត និងធ្វើការវាយតម្លៃថា តើចាំបាច់ត្រូវមានការផ្លាស់ប្តូរអ្វីខ្លះ ដើម្បីដោះស្រាយគ្រោះភ័យ ដែលអាចកើតមាននាពេលអនាគត។ ដូច្នេះយើងទាំងអស់គ្នាត្រូវបំពេញទំនួលខុសត្រូវជាសមូហភាពរបស់យើង៖ មិនថា

ចាស់ ក្មេង មាន ក្រ យើងត្រូវខិតខំឲ្យអស់ពីសមត្ថភាព ដោយសារយើងពុំមានជម្រើសអ្វីឡើយ ពាក់ព័ន្ធជាមួយនឹងការប្រែប្រួលអាកាសធាតុនេះ៖

សកម្មភាពបន្ទូរបន្តយត្រូវធ្វើឡើងជាសមូហភាព។

សកម្មភាពបន្ទាំត្រូវចាប់ផ្តើមពីឥឡូវនេះតទៅ។

អរគុណចំពោះការយកចិត្តទុកដាក់ស្តាប់។

សុន្ទរកថាស្វាគមន៍ថ្ងៃទី០៣

*របស់ ឯកឧត្តម **រស់ សីលវ៉ា** អនុរដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

- ឯកឧត្តមទេសរដ្ឋមន្ត្រី

- ឯកឧត្តមលោកជំទាវ លោក លោកស្ត្រីភ្ញៀវកត្តញ្ញូសជាតិ និងអន្តរជាតិ

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយនិង មានកិត្តិយសយ៉ាងខ្លាំង ដែលបានអញ្ជើញចូលរួមថ្លែងសុន្ទរកថាស្វាគមន៍ក្នុងវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុ ក្នុងនាមតំណាងឲ្យ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ខ្ញុំសូមថ្លែងសេចក្តីកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះក្រសួងបរិស្ថាន ដែលបានរៀបចំវេទិកាជាតិ ដ៏មានសារសំខាន់នេះ និងសូមថ្លែងអំណរអរគុណដល់ អង្គការអភិវឌ្ឍសហប្រជាជាតិ សហគមន៍អឺរ៉ុប និងដៃគូអភិវឌ្ឍន៍សំខាន់ៗផ្សេងទៀត ដែលបានឧបត្ថម្ភ គាំទ្រទាំងថវិកា និងបច្ចេកទេសក្នុងវិស័យបរិស្ថាន ជាពិសសការប្រែប្រួលអាកាសធាតុព្រមទាំងការរៀបចំវេទិកានៅថ្ងៃនេះ ។

វេទិកានេះមានសារសំខាន់ណាស់ សម្រាប់ផ្តល់ឱកាសដល់ទាំងមន្ត្រីជំនាញ ដែលកំពុងអនុវត្តកិច្ចការ អ្នកសិក្សាស្រាវជ្រាវ អ្នករៀបចំគោលនយោបាយ និងអ្នកពាក់ព័ន្ធផ្សេងទៀតក្នុងវិស័យនេះបានធ្វើការសិក្សាស្វែងយល់បន្ថែមពីទស្សនាទាន របកគំហើញ និងព័ត៌មានវិទ្យាសាស្ត្រនៃផលប៉ះពាល់បរិស្ថាន ដែលអាចឲ្យយើងពិនិត្យមើលពីបញ្ហាប្រឈមនៃការប្រែប្រួលអាកាសធាតុ នៅទូទាំងប្រទេស និងនៅតាមតំបន់ តាមរយៈបទបង្ហាញនានារបស់អ្នកជំនាញ និង វាគ្មិន ដែលបានចូលរួម។ ជាមួយគ្នានេះ វេទិកានេះក៏នឹងអនុញ្ញាតឲ្យយើងស្វែងយល់ពី កាលានុវត្តភាពថ្មីៗជាច្រើន ដែលអាចឲ្យយើងទាញយកប្រយោជន៍ពីការចូលរួមអនុវត្តកម្មវិធីពាក់ព័ន្ធការគ្រប់គ្រងបរិស្ថាន និងការប្រែប្រួលអាកាសធាតុ តាមរយៈយន្តការនានា ដែលបានបង្កើតឡើងសម្រាប់ជួយប្រទេសអនុវត្តយន្តការទាំងនោះ ជាពិសេសប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជានេះ ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

វេទិកានេះគឺត្រូវបានរៀបចំធ្វើឡើងចំពេលដែលប្រទេសជាច្រើននៅលើពិភពលោកកំពុងជួបប្រទះគ្រោះមហន្តរាយធម្មជាតិដូចជាគ្រោះទឹកជំនន់ ខ្យល់ព្យុះរញ្ជួយដី និងកន្លែងខ្លះទៀតជួបប្រទះនឹងភាពរាំងស្ងួត
ដែលធ្វើឲ្យមានការខាតបង់សេដ្ឋកិច្ចការបាត់បង់អាយុជីវិតមនុស្សនិងសត្វគួរឲ្យសោកស្តាយ។ជាឧទាហរណ៍ជាក់ស្តែងប្រទេសកម្ពុជាយើងកំពុងតែទទួលរងគ្រោះទឹកជំនន់រហូតដល់មានការស្លាប់បាត់បង់ជីវិតមនុស្សថែមទៀត។ភស្តុតាងជាក់ស្តែងនេះស្របទៅនឹងអំណះអំណាងរបស់អ្នកអង្កេតស្រាវជ្រាវតាមបែបលក្ខណៈវិទ្យាសាស្ត្រដែលបានបង្ហាញពីផលប៉ះញល់យ៉ាងធ្ងន់ធ្ងរនៃគ្រោះធម្មជាតិដែ

លកើតមានឡើងគឺបណ្តាលមកពីការប្រែប្រួលអាកាសធាតុមកលើវិស័យសេដ្ឋកិច្ចសង្គមកិច្ច និងបរិស្ថានដែលជាខឿនទ្រទ្រង់ការរីកចំរើនលូតលាស់ និងនិរន្តភាពនៃសង្គមជាតិ ។

ដោយបានទទួលស្គាល់ពីបញ្ហានៃការប្រែប្រួលអាកាសធាតុ និងការខូចខាតនៃបរិស្ថាននេះ រាជរដ្ឋាភិបាលកម្ពុជាមានឆន្ទៈនយោបាយ និងប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការចូលរួមជាមួយសហគមន៍ជាតិ និងអន្តរជាតិ ដើម្បីបំពេញកាតព្វកិច្ចខ្លួនក្នុងនាមជាប្រទេសកំពុងអភិវឌ្ឍន៍ និងជាប្រទេសរងគ្រោះ ដើម្បីឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានផ្តល់សច្ចាប័នលើអនុសញ្ញាក្នុងក្របខណ្ឌសហប្រជាជាតិស្តីពីការប្រែប្រួលអាកាសធាតុតាំងពីឆ្នាំ១៩៩៥ និងបានចូលជាសមាជិកពិធីសារក្យូតូនៅឆ្នាំ២០០២ ព្រមទាំងចូលជាសមាជិកពិធីសារផ្សេងៗទៀត។ គោលបំណងសំខាន់ គឺបង្កើនកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានាក្នុងតំបន់ និងអន្តរជាតិ ដើម្បីគៀរគរប្រភពធនធានសម្រាប់កសាងសមត្ថភាពធនធានមនុស្ស និងពង្រឹងស្ថាប័ន ដើម្បីអនុវត្តការងារឲ្យកាន់តែមានប្រសិទ្ធភាព និងធានាបាននូវការអភិវឌ្ឍប្រកបដោយសមធម៌ និងចីរភាព។

ក្រៅពីនេះ រាជរដ្ឋាភិបាល បាននឹងកំពុងខិតខំប្រឹងប្រែងរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ដោយផ្តោតលើការបញ្ចូលបញ្ហាប្រែប្រួលអាកាសធាតុ ឲ្យបានទូលំទូលាយក្នុងវិស័យពាក់ព័ន្ធ ព្រមទាំងអនុវត្តគម្រោងអាទិភាពសំខាន់ៗ ក្នុងនោះការអនុម័ត និងដាក់ឲ្យអនុវត្តកម្មវិធីជាតិបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដោយផ្តល់អាទិភាពលើការងារប្រែប្រួលអាកាសធាតុ ដើម្បីធានាបានកំណើនសេដ្ឋកិច្ចខ្ពស់ ការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍប្រកបដោយចិរភាព។ រាជរដ្ឋាភិបាលបានផ្តល់អាទិភាពលើ ការអនុវត្តគម្រោងលើកកម្ពស់ការគ្រប់គ្រងទឹក និងកសិកម្មដែលធន់នឹងការប្រែប្រួលអាកាសធាតុនៅទីជនបទ កម្មវិធីសម្រាប់ភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុ និងគម្រោងការប្រែប្រួលអាកាសធាតុ និងសុខភាព ព្រមទាំងយន្តការកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់ និងយន្តការទីផ្សារកាបូនថ្មីៗ។ ជាមួយនេះដែរ រាជរដ្ឋាភិបាលនឹងជម្រុញឲ្យមានការពង្រឹងការបន្សាំតាមសហគមន៍ តាមរយៈក្រុមកសិកម្ម ដែលមានស្រាប់ដូចជា សហគមន៍កសិករ គណៈកម្មាការកសិករប្រើប្រាស់ទឹក សមាគមពាណិជ្ជកម្ម សហគមន៍នេសាទ និងសហគមន៍ព្រៃឈើ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ការងារទាំងអស់ខាងលើនេះ មានទំហំធំធេងណាស់ និងមិនអាចអនុវត្តបានជោគជ័យទេប្រសិនបើមិនមានការចូលរួមយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធ រួមមានទាំងដៃគូអភិវឌ្ឍន៍ និងវិស័យឯកជនផងដែរ។ យើងត្រូវការទាំងថវិកា និងបច្ចេកទេស ក្នុងដំណើរដោះស្រាយបញ្ហាប្រែប្រួលអាកាសធាតុ ដោយប្រទេសដែលមានការអភិវឌ្ឍជឿនលឿនគួរតែផ្តល់មូលនិធិ និងគួរតែផ្ទេរបច្ចេកទេសទៅដល់ប្រទេស ដែលមានការអភិឌ្ឍទាប ដើម្បីកាត់បន្ថយនូវគំលាតនៃការអភិវឌ្ឍ និងកាត់បន្ថយភាពក្រីក្រ។

ខ្ញុំមានជំនឿជឿជាក់ថា វេទិកានេះនឹងលើកយកបញ្ហាទាំងអស់នេះមកពិភាក្សា ដើម្បីឆ្លុះបញ្ចាំងពី ឆន្ទៈនយោបាយខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងយ៉ាងក្លាំងក្លារបស់រាជរដ្ឋាភិបាល ក្នុងការ

សម្រេចសមិទ្ធិផលនានាកន្លងមក និងពិភាក្សាលើបទបង្ហាញថ្មីៗរបស់វាគ្មិន ដែលបានចូលរួមសម្រាប់ផ្តល់ជាអនុសាសន៍ថ្មីៗ និងជាក់ស្តែង ដើម្បីអាចឲ្យយើងអភិវឌ្ឍសេដ្ឋកិច្ចខ្លួនធន់នឹងការប្រែប្រួលនៃអាកាសធាតុ និងធានាបានការអភិវឌ្ឍប្រកបដោយចីរភាព។

មុននឹងបញ្ចប់ ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណក្រសួងបរិស្ថាន ដែលបានអញ្ជើញខ្ញុំចូលរួមថ្លែងបើកវេទិកាដ៏មានសារសំខាន់នេះ និងសូមជូនពរដល់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ ទទួលបានពុទ្ធិពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈនិងសូមប្រកាសបើកវេទិកាជាតិលើកទី២ស្តីពីការប្រែប្រួលអាកាសធាតុចាប់ពីពេលនេះតទៅ។

សូមអរគុណ!

សុន្ទរកថាបិទ ថ្ងៃទី០៣

*របស់ ឯកឧត្តមបណ្ឌិត**ម៉ុក ម៉ារ៉ែត***

ទេសរដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងបរិស្ថាននិងជាប្រធានគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

- សូមគោរពគណៈអធិបតី
- ឯកឧត្តម លោកជំទាវ ជាអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុជាទីមេត្រី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការរាជរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់
- ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា ឯកអគ្គរាជទូត ឯកអគ្គរដ្ឋទូត តំណាងដៃគូអភិវឌ្ឍន៍ វិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល
- លោក លោកស្រី អ្នកនាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិ សមាជិក សមាជិកា នៃអង្គវេទិកាទាំងមូល

ជាកិច្ចចាប់ផ្តើម តាងនាមគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ជាសមាជិកអង្គវេទិកាជាតិលើកទី២ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមក្នុងវេទិកាជាតិនេះរហូតដល់ចប់សព្វគ្រប់។

ពីរឆ្នាំកន្លងទៅនេះ កម្ពុជាបានខិតខំព្យាយាមសម្រេចបាននូវសមិទ្ធិផលគួរជាទីមោទនៈក្នុងកិច្ចខិតខំប្រឹងប្រែងឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ។ បញ្ហាប្រែប្រួលអាកាសធាតុ បានក្លាយទៅជាប្រធានបទដ៏សំខាន់មួយនៅក្នុងរបៀបវារៈអភិវឌ្ឍន៍នៅថ្នាក់ជាតិ ហើយជាបណ្តើរៗ កំពុងតែបញ្ចូលទៅថ្នាក់ក្រោមជាតិ និងថ្នាក់សហគមន៍។ របាយការណ៍លទ្ធផលការងារនៃអង្គវេទិកាអស់រយៈពេល៣ថ្ងៃកន្លងទៅអម្បាញ់មិញនេះ បានបង្ហាញថា វេទិកាជាតិនេះពិតជានាំមកនូវលទ្ធផលគួរជាទីគាប់ចិត្ត ហើយដែលលទ្ធផលទាំងនេះកើតចេញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នា យ៉ាងសកម្មរបស់សមាជិក សមាជិកាទាំងអស់ ដែលមានវត្តមាននៅទីនេះ ជាតំណាងស្ថាប័នរាជរដ្ឋាភិបាលដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល និងវិស័យឯកជន ជាពិសេស ការចូលរួមប្រកបដោយអត្ថន័យរបស់ប្រធានដឹកនាំអង្គប្រជុំ និងវាគ្មិន អ្នកជំនាញការជាតិ និងអន្តរជាតិ ដែលបានយល់ព្រមអញ្ជើញមករួមសហការ ចែករំលែកចំណេះដឹង និងបទពិសោធន៍ ធ្វើឲ្យអង្គវេទិការបស់យើង មានភាពរស់រវើក និងសំបូរបែប។ ទាំងអស់នេះ គឺជាវិភាគទានថ្មីមួយក្នុងការជួយកម្ពុជាឆ្លើយតបនឹងអាទិភាពបន្ទាន់នានាផ្នែកការប្រែប្រួលអាកាសធាតុ ដូចជាការរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រស្តីពីការប្រែប្រួលអាកាសធាតុ ការពង្រឹងសមត្ថភាពស្ថាប័ន និងសមត្ថភាពបច្ចេកទេស

ការសម្របសម្រួល ការអនុវត្តគម្រោងជាក់ស្តែងឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុ ការកៀរគរធនធាន ការអប់រំ និងលើកកម្ពស់ការយល់ដឹងនិងការចរចាអន្តរជាតិ ដើម្បីដោះស្រាយការប្រែប្រួលអាកាសធាតុ ជាពិសេស ការរៀបចំសេចក្តីព្រាងឯកសារជំហររបស់កម្ពុជា សម្រាប់ត្រៀមចូលចរចានៅក្នុងកិច្ចប្រជុំលើកទី១៧ នៃបណ្តាប្រទេសជាសមាជិកអនុសញ្ញាប្រែប្រួលអាកាសធាតុ នៅទីក្រុងឌូបាននៃប្រទេសអាហ្វ្រិកខាងត្បូងចុងឆ្នាំនេះ។ ជាការពិតណាស់ យើងពុំត្រូវចាត់ទុកវេទិកានេះក៏ដូចជាវេទិកាបន្តបន្ទាប់ទៀតថាជា លទ្ធផលចុងក្រោយនោះទេ តែវាជាមធ្យោបាយ សម្រាប់ការចែករំលែកព័ត៌មាន ការពិគ្រោះយោបល់ ការពង្រឹងកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួល។

ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី អ្នកនាងកញ្ញាជាទីមេត្រី!

យើងបានយល់កាន់តែច្បាស់ថា ការប្រែប្រួលអាកាសធាតុ គឺជាប្រធានបទដ៏ក្តៅគគុករបស់ពិភពលោក ដោយសារតែឥទ្ធិពលដ៏គ្រោះថ្នាក់របស់វាលើដំណើរការអភិវឌ្ឍរបស់មនុស្ស។ អនាគតរបស់មនុស្សជាតិនឹងរងគ្រោះ ប្រសិនបើយើងនៅតែបន្តឲ្យការចចេសធ្វើមិនដឹងមិនលឺនូវគតិបណ្ឌិតដែលថា ការអភិវឌ្ឍដែលពឹងផ្អែកលើឥន្ធនៈហ្វូស៊ីលពុំមាននិរន្តរភាពទេ ហើយប្រសិនបើយើងយកចិត្តទុកដាក់គិតគូរពីអនាគតកូនចៅយើង យើងត្រូវតែបង្វែរទិសនៃការអភិវឌ្ឍទៅរកមាគ៌ាអភិវឌ្ឍមួយដែលបៃតងជាងមុន ប្រើប្រាស់កាបូនទាប និងធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ។

ក្នុងនាមជាប្រទេសដែលមានការអភិវឌ្ឍតិចតួច កម្ពុជាពុំបានរួមចំណែកឲ្យមានការប្រែប្រួលអាកាសធាតុ ហើយវិភាគទានរបស់យើងក្នុងការបង្កឲ្យមានបញ្ហានេះមានស្តួចស្តើងបំផុត ទាំងក្នុងអតីតកាល ទាំងនៅពេលអនាគត។ យើងគឺជាអ្នករងគ្រោះ ដោយសារបញ្ហា ដែលមិនមែនជាចំណែកមួយនៃមូលហេតុ។ តែកម្ពុជាចង់ជាផ្នែកមួយនៃដំណោះស្រាយពិភពលោកចំពោះបញ្ហានេះ ពីព្រោះយើងមានឆន្ទៈនយោបាយ និងការទទួលខុសត្រូវផ្នែកសីលធម៌។ ពិសេសទៅទៀតនោះ ពីព្រោះការដោះស្រាយបញ្ហានេះនឹងផ្តល់នូវប្រយោជន៍ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច បរិស្ថាន និងបច្ចេកវិទ្យា។ យើងជឿជាក់ថា យើងអាចប្រែក្លាយវិបត្តិអាកាសធាតុ ឲ្យទៅជាឱកាសសម្រាប់ការអភិវឌ្ឍមួយ ដែលមានចីរភាពជាងមុន។

នៅក្នុងពិធីបើកអង្គវេទិកាជាតិនេះ យើងបានត្រងត្រាប់នូវសុន្ទរកថាប្រកបដោយអត្ថន័យរបស់ ឯកឧត្តមឧបនាយក រដ្ឋមន្ត្រី **យឹម ឆៃលី** តំណាងដ៏ខ្ពង់ខ្ពស់របស់ សម្តេចអគ្គមហាសេនាបតីតេជោហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានផ្តល់នូវអនុសាសន៍ដ៏ មានតម្លៃដែលរួមផ្សំជាមួយនឹងលទ្ធផលនៃកិច្ចប្រជុំរយៈពេលបីថ្ងៃនេះ អាចជាមូលដ្ឋានដ៏រឹងមាំក្នុងការគាំទ្រការងារឆ្លើយតបទៅនឹងបញ្ហាប្រែប្រួលអាកាសធាតុនៅកម្ពុជា។ រូបភាពនៃប្រជាពលរដ្ឋរងគ្រោះដោយសារទឹកជំនន់ ដែលកំពុងតែយាយីកម្ពុជាក្នុងខណៈនេះគឺ វាច្រើនល្មមគ្រប់គ្រាន់សម្រាប់ឲ្យយើងរួមគ្នាធ្វើសកម្មភាពឆ្លើយតបជាបន្ទាន់ និងភ្លាមៗទាំងផ្នែកគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងសកម្មភាពជាក់ស្តែងនៅគ្រប់លំដាប់ថ្នាក់ ដើម្បីសម្រាលទុក្ខវេទនា ពង្រឹងភាពធន់ទ្រាំ

និង សមត្ថភាពឆ្លើយតបដើម្បីបង្កឱកាសឲ្យពួកគេធ្វើការអភិវឌ្ឍ ដោយចីរភាពក្រោមលក្ខខណ្ឌនៃការប្រែប្រួលអាកាសធាតុ។

ជាមួយនឹងអាណត្តិផ្លូវច្បាប់ ដែលរាជរដ្ឋាភិបាលប្រគល់ឲ្យគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ដែលមានក្រសួងបរិស្ថាន ជាលេខាធិការដ្ឋានត្រៀមខ្លួនជាស្រេច ដើម្បីបំពេញបេសកកម្មរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ ការសម្របសម្រួល និងជំរុញភាពជាដៃគូដោយ សមធម៌ តម្លាភាព ប្រសិទ្ធភាពនិងគួរឲ្យទុកចិត្ត។ គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ប្តេជ្ញាបង្កើត និងធានាឲ្យមានបរិស្ថានប្រកបមួយ ដែលតួអង្គប្រែប្រួលអាកាសធាតុទាំងអស់អាចមានឱកាសស្មើគ្នាក្នុងការរួមចំណែកដោយពេញលេញក្នុងបូជនីយកិច្ចប្រែប្រួលអាកាសធាតុនេះ។

ជាទីបញ្ចប់ តាងនាមឲ្យគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ ក៏ដូចជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងបរិស្ថាន ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះឯកឧត្តមលោកជំទាវ អ្នកឧកញ៉ា លោកលោកស្រី អ្នកនាងកញ្ញា វាគ្មិន និងអ្នកជំនាញជាតិ-អន្តរជាតិទាំងអស់ ដែលបានចំណាយពេលដ៏មានតម្លៃអញ្ជើញមកចូលរួមក្នុងវេទិកាជាតិនេះ ផ្តល់នូវចំណេះដឹង ចែករំលែកនូវបទពិសោធន៍ បង្ហាញ និងរួមចំណែកពិភាក្សាផ្តល់មតិយោបល់ដ៏មានតម្លៃ។ សូមថ្លែងអំណរគុណជាពិសេសចំពោះតំណាងវិស័យឯកជន និងអង្គការជាតិ អន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ជាដៃគូមួយចំនួន ដែលបានមកចូលរួមតាំងពិពរណ៌ផលិតផល ដែលជួយការពារអាកាសធាតុ។ សូមអរគុណ ជាពិសេសដល់ សមាជិកគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ និងមន្ត្រីលេខាធិការដ្ឋានរៀបចំវេទិកាទាំងអស់ ដែលបានខិតខំបំពេញការងារក្នុងការរៀបចំវេទិកានេះប្រកបដោយជោគជ័យ។ សូមអរគុណពិសេស ចំពោះអ្នកឧបត្ថម្ភទាំងអស់ដូចជា EU UNDP SIDA Oxfam America និង JCCI ដែលបានផ្តល់ការគាំទ្រផ្នែកថវិកា ដល់ការរៀបចំអង្គវេទិកានេះ។

សូមជូនពរ ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រី ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ឲ្យបានប្រកបដោយពរជ័យទាំង៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។ សូមប្រកាសបិទវេទិកាជាតិលើកទី២ ស្តីពីការប្រែប្រួលអាកាសធាតុ ចាប់ពីពេលនេះតទៅ។

សូមអរគុណ!

ឧបសម្ព័ន្ធ ៣ - បទបង្ហាញនៅក្នុងវេទិកា


ការពិនិត្យមើលសញ្ញាសារ - សីតុណ្ហភាព
សីតុ ជាមធ្យមលើពិភពលោក បានកើនឡើង 0.៧៤ °C នៅក្នុងអំឡុងឆ្នាំ ១៩០៥-២០០៥
សីតុ ជាមធ្យមនៅអាស៊ីអាគ្នេយ៍ បានកើនឡើង0.9-0.៣°C ក្នុងមួយទសវត្សរ៍ នៅក្នុងរយៈពេល ៥០ ឆ្នាំចុងក្រោយនេះ
កំណើនសីតុ មានភាពខុសគ្នារវាងប្រទេសនានា — ការប្រែប្រួលខ្លាំងជាងគេត្រូវបានសង្កេតឃើញក្នុងប្រទេសសីបេរី
Global Mean Temperature
Annual mean
Smoothed series
5-95% decadal error bars
Surface
Troposphere
°C per decade
UN life to combat CLIMATE CHANGE
Source: IPCC, 2007

វេទិកាជាតិលើកទីពីរស្តីពីការប្រែប្រួលអាកាសធាតុ
ថ្ងៃទី ០៣-០៥ ខែ តុលា ឆ្នាំ ២០១១
វិទ្យាសាស្ត្រនៃការប្រែប្រួលអាកាសធាតុ ផលប៉ះពាល់ និងការងារឆ្ពោះទៅមុខ
Mozaharul Alam
អ្នកសម្របសម្រួលផ្នែកប្រែប្រួលអាកាសធាតុប្រចាំតំបន់
កម្មវិធីបរិស្ថានសហប្រជាជាតិ (UNEP)
Sida
JCCI



ប្រភពនៃកំណើនកំពស់ទឹកសមុទ្រ	អត្រាកំណើនកំពស់ទឹកសមុទ្រ (ម.ម/ឆ្នាំ)	
	១៩៦១-២០០៣	១៩៩៣-២០០៣
ការរីកមានដោយសារកំណើនកំដៅ	០,៤២ ± ០,១២	១,៦ ± ០,៥
ភ្នំទឹកកក និងដែនទឹកកក	០,៥០ ± ០,១៨	០,៧៧ ± ០,២២
ទឹកកកនៅហ្គ្រីនលែន និងភ្នំទឹកកក	០,០៥ ± ០,១២	០,២១ ± ០,០៧
ទឹកកកនៅអង់តាក់ទិក	០,១៨ ± ០,៤១	០,២១ ± ០,៣៥
ផលប្រុកពីផ្នែកទាំងអស់ទាងលើផលកំណើនកំពស់ទឹកសមុទ្រ	១,១ ± ០,៥	២,៨ ± ០,៧
កំណើនកំពស់ទឹកសមុទ្រដែលបានសង្កេតឃើញ	១,៨ ± ០,៥	៣,១ ± ០,៧
ភាពខុសគ្នា (សង្កេតឃើញ-ផលប្រុកពីភាគច្រើនទាំងអស់)	០,៧ ± ០,៧	០,៣ ± ១,០

ការពិនិត្យមើលសញ្ញានានា — ប្រឹត្តិការណ៍អតីតកាល

ប្រឹត្តិការណ៍កំណាច	ប្រឹត្តិការណ៍សំខាន់ៗ
រលកកំដៅ	កំណើនចំនួនថ្ងៃក្តៅ និងយប់ក្តៅ និងការថយចុះនៃថ្ងៃនិងយប់ត្រជាក់ រវាងឆ្នាំ ១៩៦១ និង ១៩៩៨
ភ្លៀងនិងជំនន់ខ្លាំង	កំណើនករណីភ្លៀងធ្លាក់ខ្លាំង ដែលបង្កឱ្យមានជំនន់គំហុក នៅវៀតណាម, ការចាក់ដី និងទឹកជំនន់នៅឆ្នាំ ១៩៩០ និង ២០០៤ ក្នុងប្រទេសហ្វីលីពីន និងទឹកជំនន់ នៅកម្ពុជាក្នុងឆ្នាំ ២០០០
គ្រោះរាំងស្ងួត	តាមឧទាហរណ៍ ជំនន់កើតឡើង ខាក់ឆៅនិងឆ្នាំ អែលនីញ៉ូ នៅឥណ្ឌូនេស៊ី ឡាវ កុមា ហ្វីលីពីន និងវៀតណាម; គ្រោះរាំងស្ងួតនៅឆ្នាំ ១៩៩៧ និង ១៩៩៨ បង្កឱ្យខ្វះចំណីអាហារ ជាប្រចាំនិងអង្គរទឹក ក៏ដូចជា ភ្លើងឆេះព្រៃនៅក្នុងតំបន់នានានៃប្រទេសឥណ្ឌូនេស៊ី ឡាវ និងហ្វីលីពីនផងដែរ,
ព្យុះទីផុង	ជាមធ្យម មានព្យុះស៊ីក្លូនចំនួន ២០ នៅប្រទេសហ្វីលីពីន ដែលក្នុងនោះព្យុះចំនួនបមាណ ៨ ឬ ៩ បង្កឱ្យមានការចាក់ដីជារៀងរាល់ឆ្នាំ; កំណើនភាពញឹកញាប់នៃព្យុះស៊ីក្លូនជាមធ្យម ៤.២ ដែលបង្ហាញកាត់តំបន់ក្រោមការទន្ទូលខុសត្រូវរបស់ហ្វីលីពីន នៅក្នុងរវាងឆ្នាំ ១៩៩០ . ២០០៣

UNite to combat CLIMATE CHANGE

Source: IPCC, 2007

ការពិនិត្យមើលសញ្ញានានា — អំណះអំណាងអំពីកម្ពស់ទឹកសមុទ្រ

- កំពស់ទឹកសមុទ្រកើនឡើងតាមអត្រា ១.៨ម.ម/ឆ្នាំ ចាប់ពីឆ្នាំ ១៩៦១ និង ៣.១ម.ម ចាប់ពីឆ្នាំ ១៩៩៣មក
- IPCC បានចាត់ស្មានថា កំពស់ទឹកសមុទ្រអាចកើនឡើង ១៨.៥៩ស.ម នៅក្នុងសតវត្សរ៍ខាងមុខនេះ
- បច្ចុប្បន្ននេះ ការសិក្សាមួយចាត់ស្មានអំពីតំណើនកំពស់ទឹកសមុទ្ររវាង ០.៤ស.ម និង ១.៥ ម ចំណែកការសិក្សាផ្សេងទៀតសន្និដ្ឋានអំពីតំណើន ២ម នៅក្នុងសតវត្សរ៍ខាងមុខ ក្រាន់តែដោយសារតែការលាយទឹកកកពីតំបន់ប្រឹួលលែងប៉ុណ្ណោះ
- ផ្ទាំងទឹកកកនៅតំបន់ប្រឹួលលែង ដែលអាចបង្កើនកំពស់ទឹកសមុទ្រចាន ៦ម ប្រសិនបើលាយទាំងស្រុង បច្ចុប្បន្ននេះកំពុងលាយអស់ច្រើនជាង ១០០គ.ម^3 ក្នុងមួយឆ្នាំ ដែលជាអត្រាលឿនជាងគម្រោងដែលអាចពន្យល់ចានពីការលាយតាមលក្ខណៈធម្មជាតិ
- នៅអាស៊ីអាគ្នេយ៍ កំពស់ទឹកសមុទ្រចានកើនឡើង ១.៣ម.ម ក្នុងមួយឆ្នាំ និងត្រូវបានគិទស្សន៍ថា កើន ៨០ស.ម ហួសឧល់ឆ្នាំ ២១០០
- កម្ពុជា : កំពស់ទឹកសមុទ្រកើនឡើង ០.១៨.០.៥៦ស.ម ហួសឧល់ទសវត្សរ៍ ឆ្នាំ ២០៥០



UNite to combat CLIMATE CHANGE

ការពិនិត្យមើលសញ្ញានានា — កំណើនកំដៅដោយសារលើផែនដី និងកំណើនកំពស់ទឹកសមុទ្រ

ការរីកមានទឹកកក់ដោ	ការប្រែប្រួលសីតុ (°C នៅឆ្នាំ ២០៩០-២០៩៩ ធៀបនឹងឆ្នាំ ១៩៨០-១៩៩៩)		កំណើនកំពស់ទឹកសមុទ្រ (ម នៅឆ្នាំ ២០៩០-២០៩៩ ធៀបនឹង ១៩៨០-១៩៩៩)
ករណី	ការចាំន់ស្មានល្អបំផុត	រង្វង់នៃរចាយ	ម៉ូដែលផ្តែកលើរចាយ ដែលមិនរាប់បញ្ចូលការប្រែប្រួលរាប់រហ័សពីការរលាយទឹកកក
សេណារីយ៉ូ B1	១.៨	១.១ — ២.៩	០.១៨ — ០.៣៨
សេណារីយ៉ូ A1T	២.៤	១.៤ — ៣.៨	០.២០ — ០.៤៥
សេណារីយ៉ូ B2	២.៤	១.៤ — ៣.៨	០.២០ — ០.៤៣
សេណារីយ៉ូ A1B	២.៨	១.៧ — ៤.៤	០.២១ — ០.៤៨
សេណារីយ៉ូ A2	៣.៤	២.០ — ៥.៤	០.២៣ — ០.៥១
សេណារីយ៉ូ A1FI	៤.០	២.៤ — ៦.៤	០.២៦ — ០.៥៩

UN life to combat CLIMATE CHANGE

Source: IPCC, 2007

ការពិនិត្យមើលសញ្ញានានា — ការព្យាយាមសម្រាំងពីសីតុណ្ហភាព

- ឥណ្ឌូនេស៊ី : រហូតដល់ឆ្នាំ ២១០០ សីតុ កើន ២.១°C នៅក្រោមសេណារីយ៉ូ B2 និង ៣.៤°C នៅក្រោមសេណារីយ៉ូ A2
- ហ្វីលីពីន : កើន ១.២.៣.៩°C រហូតដល់ឆ្នាំ ២០៤០ ដោយប្រើប្រាស់សេណារីយ៉ូ នៃការបំភាយនៃលទ្ធផលពី IPCC
- សឹង្ហបុរី : ប្រហែលគ្នានឹងកំណើនសីតុ មធ្យមនៃលទ្ធផលនៃការស្រាវជ្រាវសម្រាប់ពិភពលោក នៃមានកើន ២.៥°C នៅឆ្នុងរចាយ ១.៧ — ៤.៤°C/
- ថៃ : កើន ២.៤°C រហូតដល់ចុងសតវត្សរ៍នេះ
- វៀតណាម : កើន ២.៤°C រហូតដល់ឆ្នាំ ២១០០
- កម្ពុជា : កើនសីតុ ជាមធ្យមប្រចាំឆ្នាំ ០.៣.០.៦ °C រហូតដល់ឆ្នាំ ២០២៥, ០.៧.២.៧ °C រហូតដល់ទសវត្សរ៍ឆ្នាំ ២០៦០ និង /.៤.៣ រហូតដល់ទសវត្សរ៍ឆ្នាំ ២០៩០.

UN life to combat CLIMATE CHANGE


ការពិនិត្យមើលសញ្ញាណនា — ការផ្ទៀងផ្ទាត់ពីអាកាសធាតុប្រក្រតី
Number of hot days (>30°C)
1900 1920 1940 1960 1980 2000 2020 2040 2060 2080 2100
Number of heavy rainfall days (100mm/day)
UN life to combat CLIMATE CHANGE


ការពិនិត្យមើលសញ្ញាណនា — ការផ្ទៀងផ្ទាត់ពីសីតុណ្ហភាព
▪ សីតុ មធ្យមលើពិភពលោក ប្រែប្រួលក្នុងចន្លោះ ទំនស្សន៍ថាអ្នកឡើងកើនឡើង១.៨ ទៅ ៤.៤°C រហូតដល់ឆ្នាំ ២១០០
▪ សីតុណ្ហភាពខ្យល់ជាមធ្យម នៅអាស៊ីអាគ្នេយ៍ អាចកើនឡើងរវាង ០.៧៥-០.៨៧°C រហូតដល់ឆ្នាំ ២០៣៩, ១.៣២-២.០១°C រហូតដល់ឆ្នាំ ២០៦៩, និង ១.៩៦-៣.៧៧°C រហូតដល់ឆ្នាំ ២១០០ (IPCC, 2007)
1900 1950 2000 2050 2100
Source: IPCC, 2007
UN life to combat CLIMATE CHANGE




ផលប៉ះពាល់សំខាន់ៗ អតីតកាលក្នុងតួនាទីគន្លឹះសម្រាប់ពិភពលោក
ការប្រែប្រួលដែលបានឃើញស្រាប់ (%) នៃទឹកហូរលើផ្ទៃដី , សតវត្សរ៍ទី ២១/
ផ្ទៃលើសែ ជាតំបន់ដែលទឹកដីនាង ពីរភាគបីបង្ហាញលទ្ធផលឯកភាព, ផ្ទៃខ្មែរ ដែលពីមុនដែល ៩០% បង្ហាញលទ្ធផល
ឯកភាព (IPCC SYR)
តំបន់ស្ងួតខ្លាំង ជាងមុន
ប្រែប្រួលភាពនៃការបាត់បង់ទឹកក្នុងតំបន់ភក់ធ្លាក់ទឹកសន្សើម
% -40 -20 -10 -5 -2 2 5 10 20 40
Source: IPCC, 2007



ការប្រែប្រួលអាកាសធាតុ	ផលប៉ះពាល់ដែលសង្កេតឃើញ
កំណើនសីតុណ្ហភាព	- កំណើនវិហគុន.រីកាយចំហាយទឹកពីទន្លេ ទំនប់ និងអាងទឹកដទៃទៀត ដែលនាំឱ្យថយចុះ វត្តមានទឹកសម្រាប់មនុស្សប្រើប្រាស់ ការស្រោចស្រពកសិកម្ម និងការផលិតថាមពលវារីអគ្គិសនី
ការប្រែប្រួលនៃរបបទឹកភ្លៀង (ដែលរួមទាំង រំលងនិញ្ញឹងរដូវ)	- ការថយចុះនៃការទឹកទន្លេ និងកំពស់ទឹកនៅក្នុងទំនប់ផាត្រែល និងអាងទឹកនានា ជាពិសេស នៅក្នុងឆ្នាំដែលមានរំលងនិញ្ញឹង ដែលនាំឱ្យថ្លង់ចុះបរិមាណទឹក កំណើនចំនួនប្រជាជនដែល ខ្វះទឹក - កំណើនលំហូរទឹក ជាពិសេស នៅក្នុងឆ្នាំមានឡានិញ្ញាដែលនាំឱ្យមានកំណើនរួមមានទឹក នៅក្នុងតំបន់ខ្ពង់រាប - កំណើនទឹកហូរនៅលើដងផ្ទៃដី សំណឹក និងទឹកជន់ឥន ដែលមានឥទ្ធិពលមកលើគុណភាពទឹក នៅលើផ្ទៃដី និងទឹកក្រោមដី
កំណើនកំពស់ទឹកសមុទ្រ	- ការជ្រាបចូលនៃទឹកសមុទ្រទៅក្នុងស្រទាប់ទឹកក្រោមដី និងបន្ទាប់ទឹកក្រោមដី ដែលនាំឱ្យមានការថយចុះបរិមាណទឹក។

ការប្រែប្រួលអាកាសធាតុ	ឥណ្ឌូនេស៊ី	ហ្វីលីពីន	ស៊ីង្ហបូរ	ថៃ	វៀតណាម
កំណើនសីតុណ្ហភាព និង ការប្រែប្រួលនៃរបបទឹកភ្លៀង	កំណើនយ៉ាងច្រើននៃករណីគ្រុនឈាមនៅឆ្នាំមានឡានិញ្ញា ករណីជម្ងឺនិងការផ្ទាត់បង់ជីវិត ដោយការវែកតំណោ	កំណើនយ៉ាងច្រើននៃករណីគ្រុនឈាមនៅឆ្នាំមានឡានិញ្ញា ករណីជម្ងឺនិងការផ្ទាត់ បង់ជីវិត ដោយការវែកតំណោ	កំណើនជម្ងឺគ្រុនឈាម និងការរាតត្បាតទៅកន្លែង ដែលពុំធ្លាប់មានពីមុនមក	ផលប៉ះពាល់ច្បាស់ថ្នូរពីជម្ងឺគ្រុនឈាមនិងកំពុងកើនឡើង	កំណើនករណីជម្ងឺគ្រុនឈាម
កំណើនកំពស់ទឹកសមុទ្រ	ការរាតត្បាតនៃជម្ងឺឆ្លងដែលទាក់ទងនឹងទឹក	ការរាតត្បាតនៃជម្ងឺឆ្លងដែល ទាក់ទងនឹងទឹក		ការរាតត្បាតនៃជម្ងឺឆ្លងដែល ទាក់ទងនឹងទឹក	ការរាតត្បាតនៃជម្ងឺឆ្លងដែល ទាក់ទងនឹងទឹក

ការរួមលេងនៅក្នុងការបន្សាំ

- ព័ត៌មានដែលចំណេះដឹងមិនគ្រប់គ្រាន់ អំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ និងការឆ្លើយតបនៃប្រព័ន្ធធម្មជាតិទៅនឹងអាកាសធាតុ;
- ការសិក្សាក្នុងគំរូកម្រិតតំណាក់កាលទាក់ទងរវាងជម្រើសបន្សាំនិងការគាត់បន្ថយ ថ្លៃចំណាយនិងផលចំណេញពីការបន្សាំ និងសម្បទានរវាងចំណាត់ការតាមទម្រង់ខុសៗគ្នា;
- អវត្តមានព័ត៌មានអំពីថ្លៃចំណាយ និងផលចំណេញពីការបន្សាំ ធ្វើឱ្យលំបាកអនុវត្តជម្រើសបន្សាំល្អ?;
- កង្វាក់ហិរញ្ញវត្ថុសាធារណៈនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ដែលប្រព័ន្ធទានសម្រាប់តាមដាន និងស្រាវជ្រាវអំពីអាកាសធាតុ និងការឆ្លើយតបនៃប្រព័ន្ធធម្មជាតិ និងមនុស្ស នៅចំពោះមុខអាកាសធាតុ តាមធម្មតានៅខ្វះខាត;
- ព័ត៌មានពាក់ព័ន្ធកាន់តែប្រើនទៀត គឺជាតម្រូវការចាំបាច់ដើម្បីធ្វើសកម្មភាព
  - ផលប្រយោជន៍ពិន្ទុផលដំណាំ ផ្សារភ្ជាប់ទៅនឹងការថ្លាស់ប្តូរកាលបរិច្ឆេទដាំដំណាំនៅតំបន់ខុសៗគ្នា
  - ថ្លៃចំណាយសម្រាប់ការវិនិយោគលើកិច្ចការពារទន្លេប្រទេសវៀតណាមនិងកម្ពុជា

UN Life to combat CLIMATE CHANGE

ផលប៉ះពាល់នៅអនាគត — និងសម្ភារៈអំពីការឈឺចាប់ជីវិត



UN Life to combat CLIMATE CHANGE

ភាពចាំបាច់ឆ្លងដែន

- អាទិភាពខ្ពស់នៅក្នុងវេរបៀបវារៈនយោបាយ និងការទទួលស្គាល់ពីការពាក់ព័ន្ធ ជាមួយការអភិវឌ្ឍ — អនុញ្ញាតឱ្យអ្នកសាងគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចពាក់ព័ន្ធ
- ការបង្កើតស្ថាប័នថ្មី ដើម្បីសម្របសម្រួលការងារប្រែប្រួលអាកាសធាតុ — អាណត្តិ គោលនយោបាយ និងយុទ្ធសាស្ត្រ គឺជាគន្លឹះ
- ការផ្តល់ហិរញ្ញប្បទាន បច្ចេកវិទ្យា និងការកសាងសមត្ថភាព . ឧកាសផ្តល់មូលនិធិ នៅក្រោមអនុសញ្ញា UNFCCC (ដែលមានស្រាប់ និងថ្មី?), យន្តការបច្ចេកវិទ្យា ការកសាងសមត្ថភាព
- ការអភិវឌ្ឍកំពុងដែរធ្វើឡើង ហើយការបញ្ចូលកិច្ចការប្រែប្រួលអាកាសធាតុ និងតំរែតំរង់ការអភិវឌ្ឍ នៅមានចន្លោះ — ការរួមបញ្ចូលបញ្ហាពហុវិស័យ និងច្រើនមុខ គឺជាការលំបាក

ផលប៉ះពាល់ក្នុងករណីនៃការបំភាយឧស្ម័នត្រូវបានកាត់បន្ថយ ៥០% រហូតដល់ឆ្នាំ ២០៥០ [$% ក្នុងមួយឆ្នាំ] (Parry, et al//,2008



សូមអរគុណ!
ចំពោះព័ត៌មានបន្ថែម
Mozaharul Alam
Email: mozaharul.alam@unep.org
Web: www.unep.org/climatechange

ផ្នែកសង្ខេបអំពីសកម្មភាព — ការគាំទ្រសម្រាប់ការរៀបចំនូវការិយាល័យជាតិសម្រាប់ការអនុវត្ត
• វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា មានសក្តានុពលក្នុងការជួយដោះស្រាយបញ្ហាការប្រែប្រួលអាកាសធាតុ
• វិធានការដែលត្រូវបានស្នើឡើង ដើម្បីការពារការប្រែប្រួលអាកាសធាតុ
• ការបណ្តុះបណ្តាលអំពីការអភិវឌ្ឍ និងជួយទាំងការពារការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍ។

២. កម្មវិធីសាកល្បងតាមបណ្តាំនឹងការប្រែប្រួលអាកាសធាតុ ដែលមានស្រាប

- ម្ចាស់ជំនួយ៖ ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី NDF និង រាជរដ្ឋាភិបាលកម្ពុជា
- ដំណាក់កាលទី ១៖ ១,៥ លានដុល្លារសហរដ្ឋអាមេរិច
- ដំណាក់កាលទី ២៖ ជំនួយឥតសំណង ៥០ លានដុល្លារសហរដ្ឋអាមេរិច និងប្រាក់កម្ចី ៣៦ លានដុល្លារសហរដ្ឋអាមេរិច
- រយៈពេល៖ ២០១០-២០??

គោលបំណង នៃដំណាក់កាលទី ១៖ ការវាយតម្លៃ និងពង្រឹងភាពរួចរាល់របស់ស្ថាប័ន សម្រាប់គម្រោង ដោយផ្តោតលើវិស័យអាទិភាព ៣ រួមមានការអភិវឌ្ឍធនធានទឹក កសិកម្ម/ធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធជនបទ

គោលបំណង នៃដំណាក់កាលទី ២៖ ការអនុវត្តកម្មវិធីយុទ្ធសាស្ត្រ តាមរយៈគម្រោងវិនិយោគ ដោយមាន ៧ ផ្នែកសំខាន់ រួមមាន កំណែទម្រង់រដ្ឋបាល ការកសាងសមត្ថភាពស្ថាប័ន និងការវិនិយោគនៅតាមទីតាំងគម្រោង ក្នុងវិស័យអាទិភាពទាំង ៣

4

មាតិកា

១. សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា

២. កម្មវិធីសាកល្បង សម្រាប់ភាពធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

2

១. សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា

- **ម្ចាស់ជំនួយ៖** សហភាពអឺរ៉ុប UNDP, SIDA, និង DANIDA
- **ថវិកា៖** ៨,៩ លានដុល្លារសហរដ្ឋអាមេរិច
- **រយៈពេល៖** ២០១០-២០១២
- **គោលបំណង៖** សកម្មភាពប្រែប្រួលអាកាសធាតុក្នុងប្រទេសកម្ពុជា គឺជាការងារជាតិ ដឹកនាំ និងអនុវត្តស្របតាមអាទិភាពអភិវឌ្ឍន៍ជាតិ ហើយសកម្មភាពទាំងនេះ មានការសម្របសម្រួល និងអនុវត្តប្រកបដោយប្រសិទ្ធភាព

សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជាមានលទ្ធផល ៣សំខាន់៖

- **លទ្ធផល ទី១៖** ពង្រឹងសមត្ថភាពរបស់ NCCC ក្នុងការសម្របសម្រួលបង្កើតគោលនយោបាយ អភិវឌ្ឍន៍សមត្ថភាព និងការធ្វើប្រជាមតិ/ផ្សព្វផ្សាយ និងធ្វើការតាមដានការអនុវត្តយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុជាតិ
- **លទ្ធផល ២៖** លើកកម្ពស់ការទទួលបានព័ត៌មានប្រែប្រួលអាកាសធាតុ ដែលមានបច្ចុប្បន្នភាព ផ្តល់ឱកាសសិក្សារៀនសូត្រ និងទទួលបានចំណេះដឹងនៅគ្រប់កម្រិត
- **លទ្ធផល ៣៖** គ្រប់គ្រងមូលនិធិ (រួមមានជំនួយឥតសំណងរបស់គម្រោង) និងធ្វើការងារជាមួយនឹងរចនាសម្ព័ន្ធរបស់ មូលនិធិ នាពេលអនាគត

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៤ គំនិតផ្តួចផ្តើមប្រែប្រួលអាកាសធាតុរួម (JCCI)

- ម្ចាស់ជំនួយ៖ SIDA
- ដៃគូ/អ្នកអនុវត្ត៖ Forum Syd, DCA/CA and CORD
- ថវិកាប៉ាន់ស្មាន៖ ១,២៨ លានដុល្លារសហរដ្ឋអាមេរិច
- រយៈពេល៖ មេសា ២០១០ - ធ្នូ ២០១២ (ដំណាក់កាលទី ១ និង ដំណាក់កាលទី ២)

គោលបំណង៖ ធ្វើការលើកកម្ពស់សមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលកម្ពុជានៅមូលដ្ឋាន និងធ្វើការបញ្ជាតការអន្តរាគមប្រែប្រួលអាកាសធាតុ ទៅក្នុងកម្មវិធីរបស់អង្គការទាំងនោះ និងលើកកម្ពស់សមត្ថភាពរបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ (Cord DCA/CA និង Forum Syd) លើការប្រែប្រួលអាកាសធាតុ និងធ្វើការកំណត់ នូវវិធីសាស្ត្រសមស្រប និងសម្របសម្រួលកម្មវិធីសកម្មភាព ឆ្លើយតបនឹងការគម្រាមកំហែង នៃការប្រែប្រួលអាកាសធាតុ ប្រកបដោយប្រសិទ្ធភាព

ទីតាំង៖ ខេត្តរតនៈគីរី ខេត្តស្វាយរៀង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ស្ពឺ

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.២ កម្មវិធី REDD+

- ម្ចាស់ជំនួយ៖ ដានីដា DFID និង NZAID
- ដៃគូ/អ្នកអនុវត្ត៖ FA/CFI/PACT Cambodia
- ថវិកាប៉ាន់ស្មាន៖ ៣០០.០០០ ដុល្លារសហរដ្ឋអាមេរិច
- រយៈពេល៖ ២០០៨ - ២០២៨

គោលបំណង៖ ការពារធនធានព្រៃឈើក្នុងប្រទេសកម្ពុជា លើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ពឹងផ្អែកលើធនធានព្រៃឈើ និងធានាការស្រូបយកដោយប្រសិទ្ធភាព នៃកាបូនព្រៃឈើ ដើម្បីកាត់បន្ថយការកើនកំដៅផែនដីតាមរយៈកម្មវិធី REDD

ទីតាំង៖ ឧត្តរមានជ័យ

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៣ អុកហ្វាម អាមេរិចកាំង

- ម្ចាស់ជំនួយ៖ ជំនួយរបស់បុគ្គល
- ដៃគូ/អ្នកអនុវត្ត៖ អុកហ្វាមអាមេរិចកាំង
- ថវិកា៖ មិនមានទិន្នន័យ
- រយៈពេល៖ ២០១០-២០២២

សកម្មភាពសំខាន់ៗ៖ ការបន្សាំនឹងការប្រែប្រួលអាកាសធាតុក្នុងវិស័យកសិកម្ម និងការកសាងសមត្ថភាព និងការលើកកម្ពស់ចំណេះដឹង នៃការប្រែប្រួលអាកាសធាតុ

ទីតាំង៖
ខេត្តកំពង់ស្ពឺ ខេត្តព្រៃវែង ខេត្តតាកែវ និងខេត្តពោធិសាត់

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.9 គម្រោង USAID/Fintract កម្ពុជា

- ម្ចាស់ជំនួយ៖ USAID
- ដៃគូ/អ្នកអនុវត្ត៖ Fintrac
- ថវិកាប៉ាន់ស្មាន៖ ៥៤ លានដុល្លារសហរដ្ឋអាមេរិច
- រយៈពេល៖ ខែធ្នូ ២០១០ ដល់ ខែធ្នូ ២០១៥

សកម្មភាពសំខាន់ៗ៖ លើកកម្ពស់សន្តិសុខស្បៀង តាមរយៈការលើកកម្ពស់ការអភិវឌ្ឍវិស័យកសិកម្ម និងការគ្រប់គ្រងដោយមានសន្និទានភាព នៃធនធានធម្មជាតិ។ សកម្មភាពពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ រួមមានលើកកម្ពស់ភាពធន់ទ្រាំនឹងវិស័យកសិកម្ម និងធានានីវន្តរភាពមុខងារប្រព័ន្ធអេកូឡូស៊ី។

ទីតាំង៖ ខេត្តបាត់ដំបង ខេត្តពោធិសាត់ ខេត្តកំពង់ធំ និងខេត្តសៀមរាប

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៧ គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុផ្សេងៗ

ចំណងជើងសកម្មភាព	ម្ចាស់ជំនួយ	ភ្នាក់ងារគ្រប់គ្រង និងអនុវត្ត	ជែង្គអនុវត្ត	កាលបរិច្ឆេទចាប់ផ្តើម (ខែ/ឆ្នាំ)	កាលបរិច្ឆេទបញ្ចប់ (ខែ/ឆ្នាំ)	ថវិកាសរុប	ក្រុមគោលដៅ	ការបន្សាំ ការកាត់បន្ថយ ឬទាំង ២
គម្រោងលើកកម្ពស់ការបន្សាំ និងអាកាសធាតុ ក្នុងការធ្វើកសិកម្ម និងការគ្រប់គ្រងធនធានទឹក នៅតាមទីជនបទ ប្រទេសកម្ពុជា (គម្រោងបន្ទាប់ពី NAPA)	GEF/LDCF, UNDP	UNDP	ក្រសួងកសិកម្ម រ៉ូហ្វប្រមាញ់ និងនេសាទ	ខែកញ្ញា ឆ្នាំ២០០៩	ខែមិថុនា ឆ្នាំ២០១៣	៣.១ លានដុល្លារសហរដ្ឋអាមេរិច	រដ្ឋាភិបាល និងសហគមន៍មូលដ្ឋាន	ការបន្សាំ
គម្រោងសិស្សយាកាសស្រូវតាយល្ប		AFD	ក្រសួងធនធានទឹក និងឧតុនិយម	២០០៧	២០១១	១៧.៥៣ លានដុល្លារសហរដ្ឋអាមេរិច		ការបន្សាំ
គម្រោងលើកកម្ពស់សន្តិសុខស្បៀង ទល់ក្រសារ ដែលទទួលរងផលប៉ះពាល់ដោយសារតម្លៃស្បៀងមានការប្រែប្រួល	EU	FAO	MAFF/MOWRAM/MOWA	២០១០	មិថុនា ២០១១	៥០.០០០ តាមផ្តុក	ជាតិ	ការបន្សាំ
កំនត់ថ្នូរថ្មីម ទៅការបន្សាំនឹងការប្រែប្រួលអាកាសធាតុ	AusAID, DANIDA, SIDA, Luxembure, Finnida	MRC	NMCs, MoE CSIRO, GTZ, SEI, UNDP, SEA START...	សីហា ២០០៩	២០២៥	១៥ លានដុល្លារសហរដ្ឋអាមេរិច សម្រាប់រយៈពេល ៥ ឆ្នាំ ចំបួន ប្រហែលជា	អាងទន្លេមេគង្គក្រោម	ជែង្គការបន្សាំ ក្នុងអាងទន្លេមេគង្គក្រោម

12

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៥ DIPEHCO

- ម្ចាស់ជំនួយ៖ DIPEHCO
- ដៃគូ/អ្នកអនុវត្ត៖ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ
- ថវិកា៖ ៧,៥ លានដុល្លារ
- រយៈពេល៖ ២០០៤ មកដល់បច្ចុប្បន្ន

សកម្មភាពសំខាន់ៗ៖ បង្កើតទ្វើរ នូវប្រព័ន្ធប្រកាសភាពអាសន្ន អោយបានទាន់ពេល ទាក់ទងនឹងទឹកជំនន់ និងភាពរាំងស្ងួត ការលើកកម្ពស់វិធានការកាត់បន្ថយខ្នាតតូច ដូចជាទំនប់ និងស្រះទឹក ការបង្កើត និងបណ្តុះបណ្តាលដល់គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយតាមភូមិ ការធ្វើផែនការគ្រប់គ្រងគ្រោះមហន្តរាយនៅមូលដ្ឋាន និងការធ្វើសមាហរណកម្មផែនការទាំងនោះទៅក្នុងផែនការថ្នាក់ឃុំ និងថ្នាក់ស្រុក

ទីតាំង៖ សហគមន៍

10

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៦. រដ្ឋាភិបាលចិន

- ម្ចាស់ជំនួយ៖ រដ្ឋាភិបាលចិន
- ដៃគូ/អ្នកអនុវត្ត៖ ក្រសួងធនធានទឹក និងឧតុនិយម
- ថវិកា៖ ៣០ លានដុល្លារសហរដ្ឋអាមេរិច
- រយៈពេល៖ ២០១០ - ២០១២

សកម្មភាពសំខាន់៖ អនុវត្តគម្រោងការពារទឹកជំនន់

ទីតាំង៖
ស្រុកកំពង់ត្របែក ខេត្តព្រៃវែង

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៤ គំនិតផ្តួចផ្តើមប្រែប្រួលអាកាសធាតុរួម (JCCI)

សកម្មភាពសំខាន់ៗ៖ JCCI ធ្វើការតាមដំណើរការស្របគ្នាចំនួន ៣៖

១) ចំណេះដឹង អរិយាបទ និងដំណើរការ
២) ការភ្ជាប់នឹងតម្រូវការ និង
៣) ការឆ្លើយតបទាំងស្ថាប័ន និងតាមទីតាំង។

ដំណើរការ JCCI រួមមានវគ្គបណ្តុះបណ្តាល/ការកសាងសមត្ថភាព ការបង្វឹក និងបង្រៀន ការតាមដាន ការស្នើសុំណើគម្រោង និងការអនុវត្តគម្រោងសាកល្បង។ លើសពីនេះ ទីប្រឹក្សាគម្រោង JCCI ទទួលបានចំណេះដឹង និងជំនាញតាមវិស័យនានាជាច្រើន រួមមានការកាត់បន្ថយ និងការបន្ទាំនឹងការប្រែប្រួលអាកាសធាតុ តាមរយៈវេទិកាវៀនសូត្រ។ ដៃគូសរុប ក្នុងដំណាក់កាលទាំង ២ មានអង្គការកម្ពុជាចំនួន ២២។

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៧ គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុផ្សេងៗ

ចំណងជើងសកម្មភាព	ម្ចាស់ជំនួយ	ភ្នាក់ងារគ្រប់គ្រង និងអនុវត្ត	ដៃគូអនុវត្ត	កាលបរិច្ឆេទចាប់ផ្តើម (ខែ/ឆ្នាំ)	កាលបរិច្ឆេទបញ្ចប់ (ខែ/ឆ្នាំ)	ថវិកាសរុប	កម្រិតដោលដៅ	ការបន្សាំ ការកាត់បន្ថយ ឬទាំង ២
ការគាំទ្រដល់ CARE IRDM ក្នុងការសហការជាមួយ NCDM ក្នុងការកាត់បន្ថយហានិភ័យព្រោះមហន្តរាយ		AusAID	CARE-IRDM និង គណៈកម្មាធិការជាតិគ្រប់គ្រងព្រោះមហន្តរាយ	២០០៦	២០១០	១,២ លានដុល្លារសហរដ្ឋអាមេរិច		ការបន្សាំ
ការបូព្វិត ខ្នះខ្នែទស្សាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុពហុវិស័យ សម្រាប់សហគមន៍កសិដ្ឋាន ក្នុងប្រទេសកម្ពុជា ឡាវ បង់ក្លាដេស និងវៀតណាម		AusAID	CARDI, MAFF (Agricultural Extension Department) និង IDE	២០០៩	២០១៥			ការបន្សាំ
គម្រោងគាំទ្រដល់ក្រសួងបរិស្ថាន ក្នុងការរៀបចំមធ្យោបាយទំនាក់ទំនងជាតិលើកទី ២ សម្រាប់ UNFCCC (SNC)	GEF, UNDP	UNDP	ក្រសួងបរិស្ថាន	២០០៧	២០១០	១,៣ លានដុល្លារសហរដ្ឋអាមេរិច	ជាតិ	ទាំង ២
ការិយាការសំណាងអភិវឌ្ឍន៍មនុស្សជាតិរបស់ប្រទេសកម្ពុជា ស្តីពីការប្រែប្រួលអាកាសធាតុ	UNDP	UNDP	UNDP	២០០៩	២០១១	០,៣ លានដុល្លារសហរដ្ឋអាមេរិច	ជាតិ	ទាំង ២
ការសិក្សាអំពី ចំណេះដឹងពីយោបល់ និងការអនុវត្ត ស្តីពីការប្រែប្រួលអាកាសធាតុ	UNDP, Danida, Oxfam	ក្រសួងបរិស្ថាន	BBC Trust	មីនា ២០១០	តុលា ២០១០	០,១ លានដុល្លារសហរដ្ឋអាមេរិច	ជាតិ	ទាំង ២

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៧ គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុផ្សេងៗ

ចំណងជើងសកម្មភាព	ម្ចាស់ជំនួយ	ភ្នាក់ងារគ្រប់គ្រង និងអនុវត្ត	ដៃគូអនុវត្ត	កាលបរិច្ឆេទចាប់ផ្តើម (ខែ/ឆ្នាំ)	កាលបរិច្ឆេទបញ្ចប់ (ខែ/ឆ្នាំ)	ថវិកាសរុប	កម្រិតដោលដៅ	ការបន្សាំ ការកាត់បន្ថយ ឬទាំង ២
កម្មវិធី សម្រាប់លើកកម្ពស់សមត្ថភាព ក្នុងការថ្លៅ ស្រាយព្រោះមហន្តរាយដូចជាពិបច្ចុប្បន្នភាពការប្រែប្រួលអាកាសធាតុ	Japan	Japan		២០១០		១ ពាន់លានយ៉េន		ការបន្សាំ
គម្រោងបណ្តុះបណ្តាលការអភិវឌ្ឍលើកទី ៦	British Embassy		UNESCAP, ក្រសួងបរិស្ថាន	មករា ឆ្នាំ ២០១៤	កម្ភៈ ឆ្នាំ ២០១៦	១០,០០០ ដុល្លារសហរដ្ឋអាមេរិច		ការពាក់បន្ថយ
គម្រោងការប្តូរដែនការប្តេជ្ញាទំនាក់ទំនងបន្សាំនៅតាមតំបន់ឆ្នេរ (ជ្រាកជំនួយពីការសំណាងរបស់ CCCA)		UNEP	ក្រសួងបរិស្ថាន	២០១០-២០១២		២,២ លានដុល្លារសហរដ្ឋអាមេរិច		ការបន្សាំ
ដែនការជួយដើមប្រែប្រួលអាកាសធាតុ (CC IP)	UNDP	UNDP	UNDP	២០០៩	២០១០	០,៧ លានដុល្លារសហរដ្ឋអាមេរិច	ជាតិ	ទាំង ២

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៧ គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុផ្សេងៗ

ចំណងជើងសកម្មភាព	ថ្ងៃសិទ្ធិ	ភ្នាក់ងារគ្រប់គ្រង និងអនុវត្ត	ដៃគូអនុវត្ត	កាលបរិច្ឆេទចាប់ផ្តើម (ខែ/ឆ្នាំ)	កាលបរិច្ឆេទបញ្ចប់ (ខែ/ឆ្នាំ)	ថវិកាសរុប	កម្រិតគោលដៅ	ការចុះឈ្មោះកាត់បន្ថយឧស្ម័ន ២
មជ្ឈមណ្ឌលចំណេះដឹងការបន្សាំនឹងការប្រែប្រួលអាកាសធាតុអាស៊ី		UNEP	UNEP	២០០៩-២០១១		០,៩ លានដុល្លារសហរដ្ឋអាមេរិក ក្នុង ១ ឆ្នាំ		ការបន្សាំ
ការវាយតម្លៃភាពងាយរងគ្រោះ និងកម្មវិធីបន្សាំ សម្រាប់ការប្រែប្រួលអាកាសធាតុ ក្នុងតំបន់ឆ្នេរកម្ពុជា ដោយផ្តោតលើការលើកកម្ពស់ជីវភាពរស់នៅ និងប្រព័ន្ធអេកូឡូស៊ី		UNEP	ក្រសួងបរិស្ថាន	២០១០-២០១៣		៩,៦ លាន ដុល្លារសហរដ្ឋអាមេរិក		ការបន្សាំ
ការពាក្យស្នើសុំការជៀបចំដែនទឹបឆ្លាញផ្លូវអភិរក្សនៃបៃតង		UNESCAP	ក្រសួងបរិស្ថាន	២០០៩				ការកាត់បន្ថយ
កម្មវិធីកសាងសមត្ថភាព និងលើកកម្ពស់ចំណេះដឹងសាធារណៈ លើការផលិត និងស្តុក PoPs ដោយអចេតនា តាមរយៈការជំរុញសំណមជាយថាហេតុ ក្នុងសាធនដ្ឋានចាក់សំរាម		UNIDO	ក្រសួងបរិស្ថាន			០,៩ លានដុល្លារសហរដ្ឋអាមេរិក		ការកាត់បន្ថយ
ការកាត់បន្ថយឧស្ម័នផ្ទះកញ្ចក់ តាមរយៈការលើកកម្ពស់ប្រសិទ្ធភាពថាមពល ក្នុងវិស័យឧស្សាហកម្ម ក្នុងប្រទេសកម្ពុជា		UNIDO	MoE MIME	២០១០-២០១៥		៦,៥ លានដុល្លារសហរដ្ឋអាមេរិក		ការកាត់បន្ថយ
កម្មវិធីជំរុញកម្មសិទ្ធភាព និងប្រសិទ្ធភាពចំណាយ សម្រាប់អភិវឌ្ឍន៍បៃតងក្នុងវិស័យកសាងកម្ម និងការិយាល័យក្នុងក្រុងភ្នំពេញ		UNIDO	ក្រសួងឧស្សាហកម្ម និងថាមពល	២០០៩-២០១៣		១,៦ លានដុល្លារសហរដ្ឋអាមេរិក		ការកាត់បន្ថយ

៣. គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុដែលមានស្រាប

៣.៧ គម្រោងពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុផ្សេងៗ

ចំណងជើងសកម្មភាព	ថ្ងៃសិទ្ធិ	ភ្នាក់ងារគ្រប់គ្រង និងអនុវត្ត	ដៃគូអនុវត្ត	កាលបរិច្ឆេទចាប់ផ្តើម (ខែ/ឆ្នាំ)	កាលបរិច្ឆេទបញ្ចប់ (ខែ/ឆ្នាំ)	ថវិកាសរុប	កម្រិតគោលដៅ	ការចុះឈ្មោះកាត់បន្ថយឧស្ម័ន ២
គម្រោងគ្រប់គ្រងព្រៃឈើប្រកបដោយចីរភាព (SFM)	GEF, UNDP	UNDP	រដ្ឋបាលព្រៃឈើ	២០១១	២០១៥	៥,៥ លានដុល្លារសហរដ្ឋអាមេរិក	សហគមន៍	ការកាត់បន្ថយ
ផែនការគោលនយោបាយសម្រាប់ REDD	UN-REDD, UNDP, FAO, UNEP	UNDP, FAO, UNEP	រដ្ឋបាលព្រៃឈើ	២០១១	២០១១	៥,១ លានដុល្លារសហរដ្ឋអាមេរិក	ជាតិ	ការកាត់បន្ថយ
គម្រោង សម្រាប់ការសិក្សាទាំងអំពីថាមពលស្អាត ដោយប្រព័ន្ធផលិតអគ្គិសនីព្រះអាទិត្យ	Japan	JICA		២០១០		៧២០ លានយ៉ែន		ការកាត់បន្ថយ
កម្មវិធីអភិរក្សព្រៃឈើ	Japan	Japan		២០១០		១០០ លានយ៉ែន		ការកាត់បន្ថយ
គម្រោងជាំការអភិវឌ្ឍវិស័យកសិកម្មកម្ពុជា		AFD	ក្រសួងកសិកម្ម ឆ្លាប្រមាញ់ និងនេសាទ/CIRAD	២០០៩	២០១៣	២,៥ លាន អឺរ៉ូ		ការកាត់បន្ថយ

For more information:
Ministry of Environment, Department of Climate Change
48, Samdech Preah, Sihanouk Bld, Phnom Penh,
Cambodia
Phone: (855-23)218-370 Fax: (855-23)218-370
E-mail: ETAP@online.com.kh, cceap@online.com.kh
www.camclimate.gov.kh

17

២. ភាសៈទេសៈរបស់ជាតិ

- រចនាសម្ព័ន្ធនយោបាយ និងការធ្វើសេចក្តីសម្រេច
- អាទិភាពអភិវឌ្ឍន៍
- ស្ថានភាពភូមិសាស្ត្រ
- អាកាសធាតុ
- ចំនួនប្រជាជន
- សេដ្ឋកិច្ច ពាណិជ្ជកម្ម
- ការចាត់ចែងស្ថាប័នប្រែប្រួលអាកាសធាតុ

១. សាចសារ

- កម្ពុជាផ្តល់សច្ចាប័នលើអនុសញ្ញា UNFCCC នៅថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ១៩៩៥
- ក្នុងនាមជាភាគីនៃអនុសញ្ញា UNFCCC> កម្ពុជាជាប់កាតព្វកិច្ចធ្វើរបាយការណ៍ទៅសេនុីស័ទនៃភាគីអំពី (មាត្រា ១២ នៃអនុសញ្ញា UNFCCC):
  - ការបំភាយ និងសម្រួលឧស្ម័នផ្ទះកញ្ចក់ទាំងអស់ តិតាមប្រភព
  - វិធានការនានារបស់ជាតិ ដើម្បីកាត់បន្ថយ និងបន្ថយ៍ទៅនឹងការប្រែប្រួលអាកាសធាតុ
- របាយការណ៍នេះត្រូវបានហៅជាឯកសារថា "National Communication"
- សេចក្តីសម្រេចលេខ 17>CP.8: ភាគីមិនទៅក្នុងឧបសម្ព័ន្ធ ១ គួរតែពិចារណាអំពីអាទិភាព គោលបំណង និងកាលៈទេសៈនៃការអភិវឌ្ឍជាតិរបស់ខ្លួន
- ក្នុងនាមជាប្រទេសអភិវឌ្ឍន៍តិចតួច កម្ពុជាមានសិទ្ធិទទួលបានការគាំទ្រហិរញ្ញប្បទានពេញលេញ សម្រាប់រៀបចំរបាយការណ៍ជាតិរបស់ខ្លួន (តាមការយល់ឃើញរបស់ខ្លួន)
- ក្រសួងបរិស្ថានជាស្ថាប័នអនុវត្ត។ ថវិកាសរុប : ៤០៥.០០០ ដុល្លា (GEM)

និដ្ឋាការួម

- កម្ពុជាជាប្រទេសកំពុងអភិវឌ្ឍន៍ដែលពឹងផ្អែកលើកសិកម្ម និងងាយរងគ្រោះជាខ្លាំងពីឥទ្ធិពលនៃការប្រែប្រួលអាកាសធាតុ
- រចាយការណ៍ជាតិលើកទីពីរបង្ហាញពីការវាយតម្លៃ ការប្រែប្រួលអាកាសធាតុពីមុនមក និងទៅអនាគតនៅកម្ពុជា, ការបង្កើតជែនទីភាពងាយគ្រោះនឹងការប្រែប្រួលអាកាសធាតុ, និងអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុមកលើវិស័យសំខាន់ៗ (កសិកម្ម, ធនធានទឹក, ព្រៃឈើ, តំបន់ឆ្នេរ និងសុខភាព) ដោយប្រើប្រាស់ម៉ូដែលអាកាសធាតុកម្រិតតំបន់ (PRECIS) រួមផ្សំជាមួយម៉ូដែល GCM មួយចំនួន

៣. សារៈពើតំណែទ្យជាតិឱ្យស្ថិនដ្ឋះកញ្ចក់សម្រាប់ឆ្នាំ ២០០០ (២)



៤. ការវាយតម្លៃគាំពារយងគ្រោះ និងការបន្សាំ

៣. សារពើភ័ណ្ឌជាតិឧស្ម័នផ្ទះកញ្ចក់សម្រាប់ឆ្នាំ ២០០០ (១)

ប្រភពឧស្ម័នផ្ទះកញ្ចក់ និងធាតុអង្គសម្រួប	CO_2 វិស្ថបំភាយ	CO_2 វិស្ថស្រូប	CH_4	N_2O	សរុប> Gg CO_2e/
ថាមពល	២.០៤៧.៦៦		៥៥.៣៨	០.៧៥	៣.៤៤៣.១៤
កសិកម្ម			៨៧៥.៥២	៨.៧៩	២១.១១០.៨២
ការប្រែប្រួលលើការប្រើប្រាស់ដី វិមាងព្រៃឈើ	២២.៨៥៨.៧៣	-៤៨.១៦៥.៨៦	៣២.០៦	០.២២	-២៤.៥៦៥.៦៧
សំណល់			១០.១៨	០.០៥	២២៩.២៤
សំណល់	២៤.៩០៦.៣៩	-៤៨.១៦៥.៨៦	៩៧៣.១៤	៩.៨១	២១៧.៥៧


សីតុណ្ហភាពជាមធ្យមពីមុនមកដល់នៅអនាគតនៅលើដែនដីគោកប្រទេសកម្ពុជា
(ខ្នាតតាមPRECIS)
ឆ្នាំ
1 / 1960 -1989
2 / 1970 -1999
3 / 1980 -2009
4 / 1990 -2019
5 / 2000 -2029
6 / 2010 -2039
7 / 2020 -2049
8 / 2030 -2059
9 / 2040 -2069
10 / 2050 -2079
11 / 2060 -2089
12 / 2070 -2099
ឆ្នាំ
11


ចំនួនសហគមន៍ងាយរងគ្រោះ
2006
2008
9

ការប៉ាន់ស្មានតម្រូវការនិងការផ្គត់ផ្គង់ ដីឥដ្ឋ
ការប៉ាន់ស្មានតម្រូវការនិងការផ្គត់ផ្គង់ ថ្មភ្នំ
ការប៉ាន់ស្មានតម្រូវការនិងការផ្គត់ផ្គង់ ខ្សាច់ស្រោប
ការប៉ាន់ស្មានតម្រូវការនិងការផ្គត់ផ្គង់ ខ្សាច់ទន្លេ
ក្រាហ្វបង្ហាញពីតម្រូវការនិងការផ្គត់ផ្គង់ឥដ្ឋ
សក្តានុពលដីឥដ្ឋនៅតំបន់ទី ១ ក្នុង ១ ឆ្នាំ ១.៣០០
សក្តានុពលដីឥដ្ឋនៅតំបន់ទី ២ ក្នុង ១ ឆ្នាំ ០.៩៥
សក្តានុពលដីឥដ្ឋនៅតំបន់ទី ៣ ក្នុង ១ ឆ្នាំ ០.៩៥
Demand
Supply-Scenario1
Supply-Scenario2
Current
2025
2030
2035
Floor Demand/Supply (ton)
ភាគរយនៃការប្រើប្រាស់ដីឥដ្ឋ
ប្រូវ
ពោត
ដំឡូងមី
សណ្តែកសៀង
សណ្តែកបាយ
ផ្សេងទៀត
83%
5%
4%
2%
2%
4%



សារគន្លឹះ

- ផ្អែកលើទិន្នន័យឆ្នាំ ១៩៦០-២០០០, អាកាសធាតុនៅកម្ពុជា (កំពស់ទឹកភ្លៀងនិងសីតុណ្ហភាព) បានប្រែប្រួលរួចទៅហើយ, ចំណែកឯបាទឹកភ្លៀងទៅអនាគត នឹងបន្តប្រែប្រួលថែមទៀត អាស្រ័យលើសេណារីយ៉ូនៃការបំភាយឧស្ម័ន
- នៅក្រោមសេណារីយ៉ូនៃការបំភាយកម្រិតខ្ពស់ (SRESA2)
  - កំពស់ទឹកភ្លៀងនៅវស្សរដូវត្រាំងនឹងថយចុះ ទោះមានការកើនឡើងកម្រិតខ្ពស់ ហើយកំពស់ទឹកភ្លៀងនៅវស្សរដូវស្រាអាចកើនឡើង ប៉ុន្តែមានការថយចុះកម្រិតទាបដាងការខ្លាតំភ្លៀងនៅវស្សរដូវត្រាំង។ ប្រការនេះបង្ហាញថា នៅអនាគត ការចាប់ផ្តើមវស្សរដូវស្រាអាចមានភាពយឺតយ៉ាវ
  - កំពស់ទឹកភ្លៀងនៅវស្សរដូវស្រាថយចុះរហូតដល់ឆ្នាំ ២០២៥ ហើយបន្តាប់មកកើនឡើងវិញនៅឆ្នាំ ២០៥០ និង ២០៩០
- ក្រោមសេណារីយ៉ូនៃការបំភាយកម្រិតទាប (SRESB1)
  - ដូចគ្នានឹង SRESA2 តែរ តំពស់ទឹកភ្លៀងនៅវស្សរដូវត្រាំង នឹងថយចុះ ប៉ុន្តែមានការថយចុះកម្រិតទាបដាង
  - ខុសគ្នាពី SRESA2> កំពស់ទឹកភ្លៀងនៅវស្សរដូវស្រាថយចុះរហូតដល់ឆ្នាំ ២០៥០ បន្តាប់មកថយចុះវិញនៅឆ្នាំ ២០៥០និង២០៩០
- ការប្រែប្រួលរបបទឹកភ្លៀង នឹងមានឥទ្ធិពលមកលើសំណាំប្រើន។ ត្រូវបង្កើតឱ្យមាន និងអនុវត្តគម្រោងសិក្សា និងការសាកល្បងអំពីការបន្សាំនៅថ្នាក់មូលដ្ឋាន
- សមិទ្ធផលរបស់ពិភពលោកក្នុងការកាត់បន្ថយនូវការបំភាយឧស្ម័នផ្ទះកញ្ចក់នឹងមានការរាកត់ពុំខុសៗគ្នាមកលើកម្ពុជា

13

តំបន់ឆ្នេរ

- កំណើនកំពស់ទឹកសមុទ្រនិងអាចមានឥទ្ធិពលមកលើប្រព័ន្ធអេកូឡូស៊ីតំបន់ឆ្នេរ ក្រោមទម្រង់ខុសៗគ្នា ដែលរួមទាំង ការជន់លិច, ការខ្ជះខ្ជាតដោយសារជំនន់ និងខ្យល់ព្យុះ, ការចាត់បង់តំបន់អ៊ីសេម, សំណឹកអ៊ី, ការជ្រាបចូលនៃទឹកប្រៃ, និងកំណើនកំពស់ខ្សែទឹកក្រោមអ៊ី
- កំពត និងតែបទំនងជាងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ ជាងខេត្តផ្សេងទៀតនៅតំបន់ឆ្នេរ
- ផ្ទៃអ៊ីសរុបមានប្រមាណ ២៥.០០០ ហិកតា និងត្រូវជន់លិចជាអចិន្ត្រៃយ៍ ដោយសារកំណើនកំពស់ទឹកសមុទ្រ ១ម, កើនដល់ ៣៨.០០០ ហិកតា ប្រសិនបើកំពស់ទឹកសមុទ្រកើន ២ម
- វិធានការនានាបន្សាំរាប់បញ្ចូល — ការគិតគូរអំពីកត្តានានានៃការប្រែប្រួលអាកាសធាតុនៅក្នុងការបង្កើតប្លង់ហេដ្ឋារចនាសម្ព័ន្ធ.កូដសម្រាប់អាគារថ្មី។, ដាំដើមឈើជារចាំងខ្យល់ដើម្បីការពារខ្យល់និងខ្យល់ខ្លាំង និងការកើនឡើងនៃកំពស់ទឹកសមុទ្រ

ចលចាលទឹក

រយៈពេលដាំដំណាំនៅក្រោមលក្ខខណ្ឌអាកាសធាតុបច្ចុប្បន្ន និងទៅអនាគត នៅលើដីកសិកម្ម



	Baseline	B1-2025	B1-2050	B1-2080	A2-2025	A2-2050	A2-2080
7 months	3.01	0.16	0.07	2.30	0.25	0.07	3.85
5 Months	0.72	2.39	2.41	0.00	1.59	2.45	0.00
3 Months	0.11	0.00	0.00	1.68	0.00	0.00	0.13
2 Months	0.14	1.43	1.50	0.00	2.14	1.45	0.00

ព្រៃឈើ

- ទៅក្រោមសេណារីយ៉ូនៃការបំភាយកម្រិតខ្ពស់ និងទាប, រហូតដល់ឆ្នាំ ២០៥០ ភាគច្រើននៃព្រៃនៅតំបន់ទំនាប និងស្ថិតក្រោមឥទ្ធិពលនៃគ្រោះរាំងស្ងួតរយៈពេលវែងជាងមុនរវាង ៦ និង ៨ ខែ ឬ យូរជាងនេះ។ ទោះជាយ៉ាងណាក៏ដោយ រហូតដល់ឆ្នាំ ២០៨០ លក្ខខណ្ឌអ៊ី និងទឹក និងប្រហាក់ប្រហែលទៅនឹងលក្ខខណ្ឌបច្ចុប្បន្ននេះ
- វិធានការបន្សាំ រួមបញ្ចូលការបង្កើតព្រៃការពារ នៅក្នុងតំបន់ងាយរងគ្រោះភាគច្រើននៅភាគឦសាន និងនិរតីនៃប្រទេសកម្ពុជា, ការបង្កើតចំការព្រៃឈើ, ការប្រកាន់យកទម្លាប់អនុវត្តដែលមានឥរិយាភាពពិសំណាក់ម្ចាស់ព្រៃសម្បទាន, ការពង្រឹងក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ, ជែនការគ្រប់គ្រងតំបន់ការពារធម្មជាតិ និងប្រព័ន្ធតាមអានដែលមានប្រសិទ្ធភាព

19

សំណើជម្រើសបន្សាំខ្លះៗ

១. បង្កើនសមត្ថភាពប្រើប្រាស់ព័ត៌មានអំពីអាកាសធាតុ

២. បច្ចេកវិទ្យាប្រើប្រាស់ទឹកដោយប្រសិទ្ធភាព, ការធ្វើស្រែតាមគោលការធម្មជាតិ(SRI)

៣. ប្រាក់ចំណូលបន្ថែមពីគណនាទេសចរ(ពីជីវៈស្មុំនសម្រាប់ការចិញ្ចឹមអាហារ, ថាមពលជីវម៉ាសក្នុងម៉ាស៊ីនកិនស្រូវ, ការផលិតជីកំប៉ុស្តិ៍, ។ល។)

៤. បញ្ចូលការប្រើប្រាស់ដាលក្ខណៈប្រព័ន្ធនូវព័ត៌មានអំពីអាកាសធាតុនៅក្នុងការគ្រប់គ្រង និងអភិវឌ្ឍន៍កសិកម្ម

៥. ចាត់ដាអាទិភាពកម្មវិធីអន្តរាគមន៍ដាលក្ខណៈប្រព័ន្ធ(នៅកន្លែង និងនៅពេលដែលត្រូវតែអនុវត្តអន្តរាគមន៍ណាមួយដាក់លាក់ ដើម្បីកាត់បន្ថយឱ្យនៅកម្រិតអប្បបរមានូវផលប៉ះពាល់ពីកំណើនហានិភ័យអាកាសធាតុ ដូចជាការសាងសង់ទំនប់, សម្បទាសម្រាប់ការស្រោចស្រព)

៦. ពង្រីកវិធីកសិកម្ម ទៅក្នុងតំបន់នានា ដែលមានហានិភ័យអាកាសធាតុកម្រិតទាប

៧. បង្កើនឱ្យមានការរាន៉ាប់រងអាកាសធាតុសម្រាប់សហគមន៍ដែលងាយរងគ្រោះ

៨. បង្កើតភ្ជាប់ការតែច្រើនដែលពន់ទ្រាំនឹងគ្រោះរាំងស្ងួត, ទឹកជំនន់ និងកម្រិតប្រៃខ្លាំង

៩. បង្កើត និងអនុវត្តការស្រាវជ្រាវសម្រាប់រយៈពេលវែងអំពីការបង្កើតម៉ូដែលអាកាសធាតុ, បច្ចេកវិទ្យាកាត់បន្ថយ និងបន្សាំ

17

ថាមពល ឯកសារដឹកជញ្ជូន (១)

- នៅក្រោមលក្ខខណ្ឌគោល ការបំភាយសរុបពីវិស័យថាមពល និងឯកជញ្ជូន កើនឡើងពី ២.៦៣២ $GgCO_2$ eq. នៅឆ្នាំ ២០០០ ដល់ ២៥.៥៤៩ Gg CO_2 eq. នៅឆ្នាំ ២០៥០
- ប៉ុន្តែ ការបំភាយក្នុងម្នាក់ៗ នៅតែមានកម្រិតទាបនៅឡើយ ធៀបនឹងប្រទេសជិតខាង ដោយកើនឡើងពី ០.២ tCO_2 eq. ក្នុងមួយឆ្នាំៗ នៅឆ្នាំ ២០០០ ដល់ ១.៣ tCO_2 eq. ក្នុងមួយឆ្នាំៗ នៅឆ្នាំ ២០៥០
- តម្រូវការអុសត្រូវចាន់ព្យាករណ៍ថានឹងថយចុះពី ៤៩% នៅឆ្នាំ ២០០០ មកត្រឹម ១៣% នៅឆ្នាំ ២០៥០
- វិស័យឯកជញ្ជូនត្រូវគេរំពឹងថានឹងមានកំណើនច្រើនជាងគេ ហើយភាគច្រើនស្មើនឹងបំភាយនៅ ឆ្នាំ ២០៥០ និងមាន ១០.៨១៦ $GgCO_2$ eq. បន្ទាប់មកគឺឧស្សាហកម្មថាមពល (ការផលិតអគ្គិសនី) ដែលមាន ៨.៨៨៨ Gg CO_2 eq.

សុខភាព

- ជម្ងឺគ្រុនចាញ់នៅកម្ពុជា មានទំនាក់ទំនងជិតស្និទ្ធជាមួយទឹកភ្លៀង និងសីតុណ្ហភាព, ដោយកំពស់ទឹកភ្លៀងអាចបង្ហាញពីទំនាក់ទំនងជិតស្និទ្ធជាមួយការណាំជារច្រើននៃគ្រុនចាញ់
- ហានិភ័យនៃរោគគ្រុនចាញ់អាចកើនឡើងទៅអនាគត រហូតដល់ឆ្នាំ ២០៥០ ជាពិសេស នៅខេត្តនានា ដែលស្ថិតនៅភាគឦសាន អូចជា ខេត្តព្រះវិហារ, ស្ទឹងត្រែង, រតនៈគិរី និងមួយផ្នែកនៃខេត្តមណ្ឌលគិរី និងក្រចេះ
- វិធានការបន្សាំ រួមមាន វិធានការនានា ដែលមានគោលដៅកាត់បន្ថយចំនួនការណាំរោគគ្រុនចាញ់ . អូចជា ការចាញ់ថ្នាំ និងការចែកមុង, និងវិធានការនានាសំដៅកាត់បន្ថយចំនួនការណាំចាត់បង់ជីវិតដែលបង្កដោយរោគគ្រុនចាញ់ អូចជា ការកែលម្អលើការព្យាបាល និងភាពងាយស្រួលរកសេវាព្យាបាល

21
Sihanouk
Kep

23

៦. ពិតិយាលេខ្យេចខ្យែត

- ការរួមបញ្ចូលការប្រែប្រួលអាកាសធាតុទៅក្នុងយុទ្ធសាស្ត្រនានា គោលនយោបាយ និងផែនការ នៅមានកម្រិតតិចណាស់នៅឡើយ ។ ប៉ុន្តែ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ថា ការប្រែប្រួលអាកាសធាតុគឺជាអាទិភាពមួយ (RS 2, NSDP បច្ចុប្បន្នកម្ម) ហើយកិច្ចខ្ចប្តេីមមួយចំនួន គាំទ្រដល់ប្រការនេះ (CCCA, PPCR)
- កម្ពុជាគាំទ្រឱ្យមានការផ្តួរបច្ចេកវិទ្យា និងហិរញ្ញប្បទានគ្រប់គ្រាន់ សម្រាប់ជាមធ្យោបាយសម្រាប់ដោះស្រាយការបន្ស៊ាំ និងការកាត់បន្ថយ
- ការស្រាវជ្រាវខ្លះៗដែលពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ កំពុងអនុវត្តនៅក្នុងក្រសួងមួយចំនួននៃរដ្ឋាភិបាល និងវិទ្យាស្ថានអប់រំដាន់ខ្ពស់របស់កម្ពុជា ប៉ុន្តែ ការគាំសាសងសមត្ថភាព និងការគាំទ្រហិរញ្ញវត្ថុ នៅតែជាតម្រូវការនៅឡើយ ដើម្បីអនុវត្តរបៀបវារៈស្រាវជ្រាវ
- មានកិច្ចខ្ចប្តេីមខ្លះៗ ដើម្បីបង្កើនការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ ប៉ុន្តែការយល់ដឹងជារួមក្នុងចំណោមសាធារណជន នៅមានកម្រិតទាប ហើយនិស្សិត បុគ្គលិករដ្ឋាភិបាល និងប្រព័ន្ធព័ត៌មានមានការយល់ដឹងក្នុងកម្រិតកំណាត់អំពីការប្រែប្រួលអាកាសធាតុ ជាពិសេស ឱកាសសម្រាប់ការកាត់បន្ថយ និងការបន្ស៊ាំ
- កិច្ចខ្ចប្តេីមនានា នៅគ្រប់លំដាប់ថ្នាក់នៃការអប់រំបានបង្ហាញច្បាស់ ប៉ុន្តែនៅក្រៃមកម្រិតកំណាត់ ខាកខានទឹងកម្រិតស៊ីជម្រៅ និង វិសាលភាពគ្របដណ្តប់
- គេមានការព្រឹងអំពីការកែចម្រើនចាន់ទៅអនាគត លើការសម្របសម្រួលកិច្ចការប្រែប្រួលអាកាសធាតុ ការបញ្ជ្រាបហិរញ្ញវត្ថុប្បទាន ក្នុងចំណោមស្ថាប័ននានារបស់រដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និង NGOs

កសិកម្ម ព្រៃឈើ និងការប្រើប្រាស់ដី (AFOLU) (១)

- ជារួម ការបំភាយផ្តួរចាន់ព្យាករណ៍ថាកើនឡើងពី -៨.៨២២ $GgCO_2e$ នៅឆ្នាំ ២០០០ ដល់ ៣៤.១៩២ នៅឆ្នាំ ២០៥០ ទឹងជាលទ្ធផល វិស័យ AFOLU ទឹងបំភាយច្រើនជាងស្រូប
- ការបំភាយក្នុងម្នាក់ៗនៅតែមានកម្រិតទាប ធៀបទឹងប្រទេសផងទៃ ដោយមានកំណើនពី -0.៨១ នៅឆ្នាំ ២០០០ ដល់ ១.៣៦ tCO_2e. ក្នុងម្នាក់ៗនៅឆ្នាំ ២០៥០
